# ម៉ូឌុលសិក្សា១

*ជំនាញទន់*

# មាតិកា

**ទំព័រ**


មេរៀនទី១៖ មនសិការវិជ្ជាជីវៈ និងការធ្វើការងារជាក្រុម ........................................................ ១

មេរៀនទី២៖ សុវត្ថិភាព និងសុខភាពការងារ និង Kaizen (5S)............................................................ ១៥

មេរៀនទី៣៖ ការចាត់ជាអាទិភាពនិងរៀបចំការងារ និងការគ្រប់គ្រងពេលវេលា ............................... ១៦៧

មេរៀនទី៤៖ ការប្រាស្រ័យទាក់ទងនៅកន្លែងការងារ ...................................................................២០៤

មេរៀនទី៥៖ សហគ្រិនភាព ...........................................................................................................២០៩

មេរៀនទី៦៖ មូលដ្ឋានគ្រឹះនៃច្បាប់ស្ដីពីការងារ...........................................................................២៦៣

មេរៀនទី៧៖ ចរណៈវិជ្ជា................................................................................................................ ៣១០

មេរៀនទី៨៖ ការប្រតិបត្តិការបណ្ដុះបណ្ដាលបែតងក្នុងគ្រឹះស្ថាន អ.ប.វ. ........................................៣២៧

## មេរៀនទី១

# មនសិការវិជ្ជាជីវៈ និងការធ្វើការងារជាក្រុម












**គោលដៅមេរៀន៖**

ក្រោយពីបានបញ្ចប់នៃមេរៀននេះ សិស្ស/សិក្ខាកាមនឹងមានសមត្ថភាព៖

-កំណត់អត្ថន័យនៃពាក្យ «មនសិការវិជ្ជាជីវៈ»។

-អត្ថប្រយោជន៍នៃមនសិការវិជ្ជាជីវៈ។

-កំណត់សារៈសំខាន់នៃការងារ។

-កំណត់សម្គាល់ចរិតលក្ខណៈរបស់បុគ្គលិក។

-កំណត់តម្លៃ និងសារៈសំខាន់នៃការងារជាក្រុម។

-ប្រើប្រាស់ជំនាញបំពេញការងារជាក្រុម។

-បន្ថយសកម្មភាព និងភាពអវិជ្ជមានក្នុងកន្លែងការងារ។

-ស្រលាញ់ការងារ និងព្យាយាមបំពេញការងារ។

-សុខដុមរមនាផ្លូវចិត្តនៅកន្លែងការងារ និងគ្រួសារ។

**១. សេចក្តីផ្តើម៖**

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលធ្លាប់តែពឹងផ្អែកតែលើវិស័យកសិកម្មជាចម្បង។ តែបច្ចុប្បន្ន ប្រទេសកម្ពុជា យើងបានផ្លាស់ប្តូរទៅជាប្រទេសដែលកំពុងមានការរីកចម្រើនលើគ្រប់វិស័យ និងពឹងផ្អែកលើវិស័យឧស្សាហកម្ម ដើម្បីការអភិវឌ្ឍន៍ប្រទេសជាតិ ក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្ម ៤.០ ដូចនេះរាជរដ្ឋាភិបាលបានដាក់ចេញជាគោលដៅសម្រាប់បម្រើលើគ្រប់វិស័យ ដល់យុវជនទាំងអស់ដែលជាកម្លាំងពលកម្មចម្បងនូវសកម្មភាពពាណិជ្ជកម្ម ការវិនិយោគក្នុង និងក្រៅប្រទេស។

ក្នុងនោះផងដែរ ដើម្បីឱ្យចង្វាក់ផលិតកម្មតាមរោងចក្រ សហគ្រាស ឧស្សាហកម្ម មានប្រសិទ្ធភាព និងភាពរីកចម្រើន លុះត្រាតែធនធានមនុស្សគ្រប់កម្រិត មានចំណេះដឹង ជំនាញ សមត្ថភាព ទេពកោសល្យ និងភាពប៉ិនប្រសព្វ ក្នុងការបំពេញតួនាទីរបស់ខ្លួន។

ដូច្នេះដើម្បីទទួលបានប្រសិទ្ធិភាពការងារដែលកំពុងអនុវត្ត ប្រកបដោយភាពជោគជ័យ និងការអភិវឌ្ឍន៍ជឿនលឿនតាមយុគសម័យនោះ យើងគួរបគ្បីស្គាល់ខ្លួនឯងច្បាស់លាស់ និងសួរថា «តើអ្នកចង់ក្លាយទៅជាមនុស្សជោគជ័យឬទេ?» «មានអ្វីខ្លះជាមធ្យោបាយ?» «ក្នុងករណីជួបឧបសគ្គ តើគួរធ្វើយ៉ាងដូចម្តេច?...» ចំពោះចម្លើយសម្រាប់សំណួរទាំងនេះ ត្រូវបានលើកមកសិក្សានៅក្នុងមុខវិជ្ជា "**មនសិការវិជ្ជាជីវៈ និងការបំពេញការងារជាក្រុម**"។

"**មនសិការវិជ្ជាជីវៈ និងការបំពេញការងារជាក្រុម**" គឺជាមុខវិជ្ជាដ៏សំខាន់នាពេលបច្ចុប្បន្ន ហើយយើងអាចចាត់ទុកមុខវិជ្ជានេះថា ជាថ្នាំដ៏ស័ក្តិសិទ្ធិសម្រាប់ព្យាបាលជំងឺប្រថុយប្រថានរបស់ថៅកែ ឬបុគ្គលិក ភាគច្រើនដែលកំពុងជួបឧបសគ្គ ឬយើងអាចនិយាយម្យ៉ាងទៀតបានថា វាជាត្រីវិស័យសម្រាប់ដឹកនាំបុគ្គលណាដែលមានបំណងឆ្ពោះទៅរកភាពជាអ្នកដឹកនាំ និងបុគ្គលិកឆ្នើម។

បន្ទាប់ពីអ្នកសិក្សាមុខវិជ្ជានេះចប់អ្នកនឹងដឹងថាមនុស្សម្នាក់ដែលពោរពេញទៅដោយ **មនសិការវិជ្ជាជីវៈ** និងសុខដុមរមនាផ្លូវចិត្តសម្រាប់បុគ្គលិក និងថ្នាក់ដឹកនាំ ដែលជាថាមពលដ៏មានសារៈសំខាន់នៅក្នុងអង្គភាព

ហើយអង្គភាពណាក៏ត្រូវការដោយខានមិនបាន **ក្នុងការបំពេញការងារជាក្រុម** ដើម្បីឈានទៅរកភាពជោគជ័យឥតឈប់ឈរក្នុងអង្គភាព និងបុគ្គលខ្លួនឯងផ្ទាល់។

**២. តើអ្វីជា មនសិការវិជ្ជាជីវៈ?**

1. **និយមន័យ**

**-មនសិការ** មានន័យថា ការធ្វើទុកក្នុងចិត្ត ការកំណត់ទុកក្នុងចិត្ត ដំណើរយកចិត្តទុកដាក់។ (វចនានុក្រមសម្តេចសង្ឃ ជួនណាត)។

**-វិជ្ជាជីវៈ** មានន័យថា ( វិជ្ជា+អាជីវ ) មុខតំណែង មុខការរបរសម្រាប់ចិញ្ចឹមជីវិត។ (វចនានុក្រមសម្តេចសង្ឃ ជួនណាត)។

**មនសិការវិជ្ជាជីវៈ** មានន័យថា ការបំពេញមុខងារប្រកបរបរចិញ្ចឹមជីវិតដោយការយកចិត្តទុកដាក់។ តែយើងអាចឱ្យនិយមន័យផ្សេងផងដែរអាស្រ័យលើ ស្ថានភាពជំនាញ សមត្ថភាព គុណតម្លៃ គោលដៅ និងការលើកទឹកចិត្តរបស់ខ្លួនថាជាអ្នកមានជំនាញវិជ្ជាជីវៈក្នុងវិស័យ ឬដែនដាក់លាក់ណាមួយ។

**មនសិការវិជ្ជាជីវៈ** ក៏រួមបញ្ចូលនូវការយល់ដឹង អំពីការរំពឹងទុក ក្រមសីលធម៌ និងបញ្ហាប្រឈមនៃវិជ្ជាជីវៈរបស់បុគ្គល ក៏ដូចជាផលប៉ះពាល់នៃការងាររបស់មនុស្សម្នាក់មកលើខ្លួនឯង អ្នកដទៃ និងសង្គមផងដែរ។

**មនសិការវិជ្ជាជីវៈ** ជួយឱ្យអ្នកជំនាញធ្វើឱ្យប្រសើរឡើងនូវការអនុវត្ត ការពេញចិត្ត និងសុខុមាលភាពក្នុងអាជីពរបស់ពួកគេ។

**មនសិការវិជ្ជាជីវៈ** ក៏សំដៅទៅលើប្រភេទថ្នាំដែលផ្តោតលើតួនាទីនៃស្មារតីក្នុងសុខភាព និងការព្យាបាល។

**មនសិការវិជ្ជាជីវៈ** ក៏សំដៅទៅលើប្រភេទនៃការបង្វឹកដែលជួយបុគ្គលក្នុងការអភិវឌ្ឍសក្តានុពលផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់ពួកគេ ដោយបង្កើនការយល់ដឹងអំពីខ្លួនឯង និងបរិស្ថានរបស់ពួកគេ។ ការបង្វឹកមនសិការវិជ្ជាជីវៈគឺផ្អែកលើមូលដ្ឋានដែលមនុស្សគ្រប់រូបមានមនសិការច្នៃប្រឌិតដែលអាចចូលប្រើ និងបង្ហាញតាមរយៈការបង្វឹក។ ការបង្វឹកស្មារតីវិជ្ជាជីវៈប្រើប្រាស់ឧបករណ៍ និងបច្ចេកទេសផ្សេងៗដូចជា ការសួរសំណួរមតិកែលម្អ ការឆ្លុះបញ្ចាំង ការមើលឃើញ និងផែនការសកម្មភាព ដើម្បីជួយអតិថិជនសម្រេចបាននូវគោលដៅរបស់ពួកគេ យកឈ្នះលើបញ្ហាប្រឈម និងបង្កើតការផ្លាស់ប្តូរជាគំនិតវិជ្ជមាននៅក្នុងជីវិតរបស់ពួកគេ។ ការបណ្តុះបណ្តាលមនសិការវិជ្ជាជីវៈ អាចត្រូវបានអនុវត្តទៅលើផ្នែកផ្សេងៗដូចជា ភាពជាអ្នកដឹកនាំ ការទំនាក់ទំនង ការអភិវឌ្ឍអាជីព និងការលូតលាស់ផ្ទាល់ខ្លួន។

សរុបជារួមមក នេះគឺជាការបកស្រាយមួយចំនួននៃ **មនសិការវិជ្ជាជីវៈ** ដែលយើងអាចឱ្យនិយមន័យផ្សេងៗគ្នា។

2. ***សារៈសំខាន់នៃការងារ***

ហេតុអ្វីបានជាយើងត្រូវការ ***ធ្វើការងារ?***

តាមនិយមន័យ ***ការងារ*** គឺជាកិច្ចដែលត្រូវធ្វើតាមមុខងាររបស់ខ្លួន។

-***ការងារ*** ជាប្រភពនៃចំណូលសេដ្ឋកិច្ចក្នុងគ្រួសាររបស់មនុស្សម្នាក់ដែលមិនអាចខានបាន។ ច្បាស់ណាស់ការងារ ជាសកម្មភាពដែលផ្តល់នូវប្រាក់កម្រៃសម្រាប់ផ្គត់ផ្គង់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជា

ការទិញម្ហូបអាហារ ឧបត្ថម្ភកូនសិក្សារៀនសូត្រ ការចូលរួមក្នុងកិច្ចការសង្គម (ពិធីបុណ្យ ពិធីមង្គលការ ពិធីបុណ្យសាសនា ...)។

-**ការងារ** ដែលប្រកបដោយសុចរិតទៀងត្រង់ ត្រឹមត្រូវ នាំឱ្យមនុស្សទទួលបាននូវសេចក្តីថ្លៃថ្នូរ និងកិត្តិយស ព្រោះនៅក្នុងសង្គមគេតែងតែឱ្យតម្លៃមនុស្សតាមរយៈសកម្មភាពការងារប្រចាំថ្ងៃ។ ឧទាហរណ៍ យើងឱ្យតម្លៃអ្នកធ្វើការងារ ជាអ្នកបោសសម្អាត ច្រើនជាងអ្នកសុំទាន ព្រោះទោះបីមុខរបររបស់គាត់មិនបង្ហាញអំពីឋានៈតួនាទីខ្ពស់ក្នុងសង្គមក្តី តែគាត់បានព្យាយាមយកកម្លាំង និងការអត់ធ្មត់របស់គាត់ទៅដោះដូរនឹងប្រាក់កម្រៃ ដើម្បីសម្រាលជីវភាពគ្រួសារ ក៏ដូចជាបន្ទុករបស់រាជរដ្ឋាភិបាល។

-**ការងារ** ត្រឹមត្រូវផ្តល់នូវសេចក្តីរីករាយ និងសុភមង្គលដល់មនុស្សជុំវិញខ្លួន។ នៅពេលដែលយើងបំពេញការងារសុចរិត(មិនខុសច្បាប់) នោះក្រោយពេលបំពេញការងារចប់ មកដល់ផ្ទះធ្វើឱ្យយើងមានអារម្មណ៍ស្រស់ស្រាយ និងមិនមានការភ័យខ្លាចចំពោះការងារដែលខ្លួនបំពេញ ឬបរិយាកាសជុំវិញជាដើម។

-**ការងារ** ជាចំណងចងឱ្យមនុស្សចេះរស់នៅជាក្រុម មានសាមគ្គីភាពក្នុងគ្រួសារ និងសង្គមជាតិ។ នៅក្នុងសង្គមការងារ ការបំពេញការងារជាក្រុម គឺជាការប្រាស្រ័យទាក់ទងគ្នា ការសម្របខ្លួនក្នុងការងារ ការអត់ធ្មត់ ការអធ្យាស្រ័យ និងការដោះស្រាយបញ្ហា។ ដូចនេះការងារជាអ្នកបង្រៀនអ្នកមិនចេះធ្វើការឱ្យចេះធ្វើការ អ្នកមានចរិតកោងកាច ផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនស្របតាមបរិយាកាសការងារ។ បុគ្គលខ្លះបានរៀនសូត្រពីអត្តចរិតរបស់ខ្លួនតាមរយៈការងារ សម្រាប់ផ្លាស់ប្តូរការរស់នៅក្នុងសង្គមគ្រួសារ និងសង្គមជាតិ។

-**ការងារ** នាំឱ្យមនុស្សឈានទៅរកភាពម្ចាស់ការលើខ្លួនឯង ដោយមិនមានទំនោរពឹងផ្អែកទៅលើក្រុមការងារ។ ឧទាហរណ៍ ក្រុមការងារមួយក្រុម មានសមាជិក៤នាក់ តែមានសមាជិក១នាក់ បានអវត្តមាន ដូច្នេះសមាជិកក្នុងក្រុមនៅសល់តែ៣នាក់ ប៉ុន្តែពួកគាត់បំពេញការងារបានធម្មតា នេះដោយពួកគាត់មានម្ចាស់ការលើខ្លួនឯងគ្រប់ៗគ្នា។

-**ការងារ** ធ្វើឱ្យមនុស្សមានសមត្ថភាពពិតប្រាកដ ពេលដែលមនុស្សមានចំណេះដឹង ជំនាញ និងបំណិនក្នុងខ្លួន គាត់អាចដោះស្រាយរាល់ឧបសគ្គនានាដែលប្រឈមមុខ ដែលរំលេចឱ្យឃើញនូវភាពប៉ិនប្រសប់ ទេពកោសល្យ និងសមត្ថភាពដោយឯកឯង។

-**ការងារ** នាំឱ្យមនុស្សស្គាល់ពីតម្លៃខ្លួនឯង។ ជាការពិតណាស់បន្ទាប់ពីទទួលបានការងារ វាធ្វើឱ្យយើងទទួលបានបទពិសោធន៍ ចំណេះដឹងឥតឈប់ឈរ ការងារនាំឱ្យយើងទទួលបានប្រាក់កម្រៃចិញ្ចឹមជីវិតនៅក្នុងសង្គមដោយភាពថ្លៃថ្នូរ។ ក្រៅពីនេះការធ្វើការដែលពោរពេញដោយមនសិការវិជ្ជាជីវៈ ធ្វើឱ្យយើងទទួលបានសេចក្តីទុកចិត្ត ការកោតសរសើរ ការដំឡើងប្រាក់ខែ ការដំឡើងឋានៈតួនាទី ពីអ្នកគ្រប់គ្រង ឬថៅកែ។

សរុបជារួមមក យើងអាចរកចម្លើយសម្រាប់សំណួរ «ហេតុអ្វីបានជាយើងត្រូវការ **ធ្វើការងារ?**» ព្រោះការងារជាកាតាលីករជំរុញ និងកំណត់បាននូវគុណតម្លៃសម្រាប់មនុស្សម្នាក់ៗនៅក្នុងសង្គម។

### 3. ការស្វែងយល់ពីចរិតលក្ខណៈរបស់និយោជិត

**ក-ភាពស្មោះត្រង់** មានន័យថានិយាយពិត សម្តែងនូវការពិត មិនភូតភរ មិនកុហកបោកប្រាស់។

គ្រប់អង្គភាពទាំងអស់ **ភាពស្មោះត្រង់**របស់បុគ្គលិក គឺជាភាពចាំបាច់របស់អង្គភាពដែលត្រូវមានចាប់ពីកម្រិតថ្នាក់ដឹកនាំ រហូតដល់បុគ្គលិកថ្នាក់ទាប។

**ភាពស្មោះត្រង់** ជួយឱ្យយើងបង្កើតទំនុកចិត្ត ការគោរព និងទំនាក់ទំនងវិជ្ជមានជាមួយអ្នកដទៃ ដើម្បីជៀសផុតពីបញ្ហា និងជម្លោះដែលអាចកើតឡើងដោយការកុហក ឬបោកប្រាស់។

លក្ខណៈពិសេសដែលនិយោជិត ត្រូវចងចាំចំពោះអង្គភាពមានៈ

-ទីនេះជាកន្លែង(កន្លែងការងារ) ដែលផ្តល់ការងារឱ្យយើង។

-ទីនេះជាកន្លែងសម្រាប់រៀបចំជីវិតយើង។

-ទីនេះហើយដែលយើងហាត់រៀនធ្វើការ និងទទួលបាននូវប្រាក់កម្រៃដើម្បីដោះស្រាយជីវភាព ការហូបចុក ការស្លៀកពាក់ និងសម្រួលបញ្ហាផ្សេងៗដែលយើងត្រូវការ។

-ទីនេះជាកន្លែងផ្តល់បទពិសោធន៍ការងារ និងបទពិសោធន៍សម្រាប់អភិវឌ្ឍជីវិតរបស់យើង។

**ខ-ភាពទៀងទាត់**

តើ**ភាពទៀងទាត់** សំដៅទៅលើអ្វី?

**ភាពទៀងទាត់** សំដៅទៅលើពេលវេលា ដូចជាម៉ោងពេលបំពេញការងារ(ម៉ោងចូល-ចេញ) ការណាត់ជួប ការឆ្លើយតបសារទំនាក់ទំនងលឿនតាមដែលអាចធ្វើទៅបាន។

ជាទូទៅ**ភាពទៀងទាត់** តែងតែចោទជាសំណួរទៅយើងម្នាក់ថាៈ

-តើអ្នកចូលចិត្តធ្វើការងារជាមួយអ្នកដែលមិនគោរពពេលវេលាដែរឬទេ?

-តើអ្នកអាចត្រឡប់ទៅកាន់ពេលវេលា១នាទីមុនដែរឬទេ?

-បើសិនជាអ្នក ជាអ្នកគ្រប់គ្រង ឬថៅកែ តើលោកអ្នកយល់ដូចម្តេចចំពោះគេ(និយោជិត) ហើយប្រព្រឹត្ត ដូចម្តេចចំពោះពួកគេ?

ការគោរព**ពេលវេលា**ធ្វើការ មានឥទ្ធិពលវិជ្ជមានទៅលើផលិតភាព ការលើកទឹកចិត្ត ការពេញចិត្ត និងសុខុមាលភាពរបស់និយោជិត និងនិយោជក។

សរុបមកមនុស្សគ្រប់រូបត្រូវចេះគ្រប់គ្រង និងគោរពភាពទៀងទាត់ ជៀសវាងដៃគូមានការធុញទ្រាន់ក្នុងការរង់ចាំ ព្រោះយើងត្រូវចាំសុភាសិតខ្មែរមួយ ដែលបានលើកឡើងថា «ពេលវេលា ជាមាសប្រាក់»។

**គ-ការមានរបៀប និងការសម្អាត**

**-ការមានរបៀប និងការសម្អាត នាំឱ្យមានអនាម័យ។**

**-អនាម័យ** នាំមកនូវសុខភាពល្អ អារម្មណ៍ស្រស់ស្រាយ មានទ្រព្យសម្បត្តិ និងសុភមង្គល ដែលយើងអាចបង្រួមជាខ្លីថា «**សុខភាពល្អ អនាគតបវរុងរឿង**»។

-សកម្មភាពដែលនិយាជិតត្រូវអនុវត្តជាប្រចាំរាល់ថ្ងៃនៅកន្លែងធ្វើការមានដូចជាៈ

- មុនពេលចាប់ផ្តើមការងារ នាពេលព្រឹក អ្នកត្រូវរៀបចំសម្ភារដែលត្រូវប្រើប្រាស់ក្នុងការិយាល័យ រោងជាង បន្ទប់ធ្វើការ ឱ្យមានរបៀបរៀបរយ។
- មុនពេលបញ្ចប់ការងារ ត្រូវរៀបចំទុកដាក់ បោស-លាងសម្អាត រួចទុកដាក់ឱ្យចំកន្លែងដើម។
- មុននឹងចាកចេញពីការិយាល័យ រោងជាង បន្ទប់ធ្វើការ ត្រូវរៀបចំទុកដាក់សម្ភារប្រើប្រាស់ឱ្យបានរៀបរយ ប្រកបដោយសុវត្ថិភាព ដូចជាការបិទកុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកផ្សេងៗឱ្យបានត្រឹមត្រូវ រួចបិទភ្លើង និងចាក់សោទ្វារមុនពេលចាកចេញ (ករណីយើងចេញក្រោយគេ)។

## ៣. ការចំពេញការងារជាក្រុម

### ៣.១ និយមន័យ

**-ការចំពេញការងារជាក្រុម** ជាក្រុមមនុស្សចូលរួមទាំងកម្លាំងកាយចិត្ត ដើម្បីសម្រេចការងារដោយជោគជ័យ។

**-ការចំពេញការងារជាក្រុម** ជាបណ្តុំនៃមនុស្សដែលធ្វើការជាមួយគ្នា ដើម្បីសម្រេចគោលដៅរួម។

**-ការចំពេញការងារជាក្រុម** ជាសមត្ថភាពក្នុងការធ្វើការបានយ៉ាងល្អជាមួយអ្នកដទៃ ដើម្បីសម្រេចគោលដៅរួមមួយ។ វាគឺជាជំនាញដ៏មានតម្លៃបំផុត នៅក្នុងកន្លែងធ្វើការ ព្រោះវាអាចបង្កើនផលិតភាព ភាពច្នៃប្រឌិត និងសីលធម៌។

**-ការចំពេញការងារជាក្រុម** ជួយឱ្យការដោះស្រាយបញ្ហាកាត់តែប្រសើរឡើង។ នៅពេលដែលមនុស្សសហការគ្នា ពួកគេអាចបង្កើត និងវាយតម្លៃគំនិតកាន់តែច្រើន ជៀសវាងកំហុស និងស្វែងរកដំណោះស្រាយដ៏ល្អប្រសើរ។

ឧទាហរណ៍៖ -កីឡាករបាល់ទាត់។

-ការធ្វើកិច្ចការជាក្រុម ....។

### ៣.២ សារៈសំខាន់នៃការចំពេញការងារជាក្រុម

ដើម្បីទទួលបាននូវប្រសិទ្ធភាពការងារទាមទារឱ្យសមាជិកក្រុមមានការសហការគ្នា រហូតឈានដល់ការទទួលបានអត្ថប្រយោជន៍សំខាន់ៗដូចជា៖

**-អាចបង្កើតគំនិត និងការច្នៃប្រឌិត** ដែលបានមកពីការពិភាក្សា ផ្លាស់ប្តូរមតិយោបល់ក្នុងការកែលម្អ ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន។

**-បង្កើនផលិតផល និងសេវាកម្ម** តាមរយៈការសហការគ្នាស៊ីចង្វាក់ រហូតអាចចេញជាសមិទ្ធផលនៃការច្នៃប្រឌិត និងការបង្កើតថ្មី។

**-លើកកម្ពស់សីលធម៌បុគ្គល និងក្រុមការងារ** ជាការស្វែងយល់ពីសីលធម៌ និងសុជីវធម៌របស់សមាជិកគំរូ ដែលមានកិរិយាមាយាទល្អ សណ្តាប់ធ្នាប់ ច្បាប់ជីវិតល្អៗ អនុវត្តសកម្មភាពរស់នៅប្រចាំថ្ងៃនៅកន្លែងធ្វើការ។ ដូចនេះទម្លាប់ជាប្រចាំថ្ងៃនៅកន្លែងធ្វើការរបស់នឹងបង្កើតបានជាវប្បធម៌រួមរបស់និយោជិតនៅក្នុងរោងចក្រ សហគ្រាស។

**-បង្កើតមានភាពស្និតស្នាល និងភាពតានតឹង** ការឱ្យតម្លៃមតិយោបល់ខុសគ្នា មានន័យថាប្រាប់ពីយោបល់របស់ខ្លួន និងស្តាប់ពីមតិយោបល់របស់សមាជិកផ្សេងៗទៀត។ រាល់មតិយោបល់របស់សមាជិកក្រុមដែលបានលើកឡើងមិនប្រាកដថា ទទួលបានឯកភាពគ្នាទាំងស្រុងនោះទេ។ អ្នកខ្លះស្តាប់ភ្លាមប្រតិកម្មភ្លាម អ្នកខ្លះទៀតគេយកទៅគិតពិចារណាជាមុនសិន មុននឹងឯកភាព ឬជំទាស់ចំណុចនេះហើយដែលធ្វើឱ្យពួកគេមានការខ្វែងគំនិតគ្នាខ្លះៗនៅគ្រាដំបូង និងបន្តបន្ទាប់។ បញ្ហានេះតែងតែកើតមាន ប៉ុន្តែវាមិនបង្កជាបញ្ហាធំ ឬធ្ងន់ធ្ងរពេកនោះទេ បើយើងអាចដោះស្រាយបញ្ហានេះទាន់ពេលពេលវេលា តាមរយៈព្យាយាមការបកស្រាយ និងទទួលស្តាប់ប្រកបដោយក្រមសីលធម៌។

**-បង្កើនវិជ្ជាជីវៈ** ជាការទទួលយក និងផ្លាស់ប្តូរចំណេះដឹងបទពិសោធន៍ដល់គ្នាទៅវិញទៅមក ក្នុងន័យបង្កើនសមត្ថភាពវិជ្ជាជីវៈសមាជិកក្រុម។ ចំណុចនេះអាចមានន័យថាការណែនាំក្នុងពេលអនុវត្ត ឬការរៀបចំជាវគ្គបណ្តុះបណ្តាលជាដើម។

### ៣.៣ កំហុសក្នុងការបំពេញការងារក្រុម និងដំណោះស្រាយកំហុសឆ្គង

កំហុសក្នុងការងារជាក្រុមគឺជារឿងធម្មតា ហើយអាចប៉ះពាល់ដល់ផលិតភាព និងសីលធម៌របស់ក្រុម។ កំហុសមួយចំនួនក្នុងការងារជាក្រុម ដែលអ្នកអាចជួបប្រទះនៅកន្លែងធ្វើការគឺ៖

**-ខ្វះភាពច្បាស់លាស់៖** នៅពេលដែលសមាជិកក្រុមមិនច្បាស់លាស់អំពីតួនាទី ទំនួលខុសត្រូវ គោលដៅ និងការរំពឹងទុករបស់ពួកគេ ពួកគេអាចខ្ជះខ្ជាយពេលវេលា ធនធាន និងថាមពលលើការងារដែលមិនពាក់ព័ន្ធ។ ដើម្បីជៀសវាងកំហុសឆ្គងនេះ អ្នកដឹកនាំក្រុមគួរតែប្រាស្រ័យទាក់ទងគ្នាឱ្យបានច្បាស់លាស់ និងញឹកញាប់ជាមួយសមាជិកក្រុមរបស់ពួកគេ ផ្តល់មតិកែលម្អ កំណត់គោលដៅ SMART ( ជាក់លាក់ ដែលអាចវាស់វែងបាន សម្រេចបានពាក់ព័ន្ធនឹងពេលវេលាកំណត់ ) និងឯកសារព័ត៌មានសំខាន់ៗ។

**-បញ្ហាទំនុកចិត្ត៖** នៅពេលដែលសមាជិកក្រុមមិនមានការទុកចិត្តគ្នា ឬអ្នកដឹកនាំ ពួកគេអាចស្ទាក់ស្ទើរក្នុងការចែករំលែកព័ត៌មាន គំនិត យោបល់ ឬមតិកែលម្អ ដែលអាចកំណត់ការច្នៃប្រឌិត និងសមត្ថភាពដោះស្រាយបញ្ហារបស់ក្រុម។ ដើម្បីជៀសវាងកំហុសឆ្គងនេះ អ្នកដឹកនាំក្រុមគួរតែពង្រឹងវប្បធម៌នៃការជឿទុកចិត្ត និងការគោរពគ្នាក្នុងចំណោមសមាជិកក្រុមរបស់ពួកគេ លើសពីនេះទៀត ការលើកទឹកចិត្តដល់ការសហការ និងកិច្ចសហប្រតិបត្តិការ ការទទួលស្គាល់ចំពោះការរួមចំណែក និងភាពខ្លាំងរបស់គ្នាទៅវិញទៅមក និងដោះស្រាយជម្លោះ ឬបញ្ហានានាបានទាន់ពេលវេលា។

**-ជម្លោះបុគ្គលិកលក្ខណៈ៖** នៅពេលដែលសមាជិកក្រុមមានបុគ្គលិកលក្ខណៈ គុណតម្លៃ ជំនឿ ឬទម្រង់ការងារខុសៗគ្នា ពួកគេអាចប៉ះទង្គិច ឬមិនយល់ស្របនឹងគ្នា ដែលអាចបង្កើតភាពតានតឹងក្នុងក្រុម។ ដើម្បីជៀសវាងកំហុសឆ្គងនេះ អ្នកដឹកនាំក្រុមគួរតែលើកកម្ពស់ភាពចម្រុះ និងការរួមបញ្ចូលនៅក្នុងក្រុមរបស់ពួកគេ អធ្យាស្រ័យ គោរព និងឱ្យតម្លៃចំពោះភាពខុសគ្នារបស់គ្នាទៅវិញទៅមក ប្រើប្រាស់ជំនាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងដំណោះស្រាយជម្លោះ និងស្វែងរកការយល់អំពីទស្សនៈរបស់គ្នាទៅវិញទៅមក។

**-កង្វះខាតព័ត៌មាន៖** នៅពេលដែលសមាជិកក្រុមមិនចែករំលែកព័ត៌មានដែលពាក់ព័ន្ធ ឬសំខាន់ជាមួយគ្នាទៅវិញទៅមក ឬអ្នកដឹកនាំរបស់ពួកគេ ពួកគេអាចនឹងខកខានឱកាសបង្កើតកំហុស ឬបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការងាររបស់ក្រុម។ ដើម្បីជៀសវាងកំហុសឆ្គងនេះ អ្នកដឹកនាំក្រុមគួរតែបង្កើតបណ្តាញទំនាក់ទំនងច្បាស់លាស់ និងបើកចំហក្នុងចំណោមសមាជិកក្រុមរបស់ពួកគេ លើកទឹកចិត្តការចែករំលែកព័ត៌មាន និងតម្លាភាព ផ្តល់ព័ត៌មានថ្មីៗ និងរបាយការណ៍ជាប្រចាំ ហើយប្រើប្រាស់ឧបករណ៍ និងវេទិកាសមស្របដើម្បីរក្សាទុក និងចូលប្រើព័ត៌មាន។

**-ភាពត្រេកត្រអាល៖** នៅពេលដែលសមាជិកក្រុមកាន់តែមានផាសុកភាព ឬពេញចិត្តនឹងស្ថានភាពបច្ចុប្បន្នរបស់ពួកគេ ពួកគេអាចបាត់បង់ការលើកទឹកចិត្ត គំនិតផ្តួចផ្តើម ឬការបង្កើតថ្មីក្នុង

ការងាររបស់ពួកគេ។ ដើម្បីជៀសវាងកំហុសឆ្គងនេះ អ្នកដឹកនាំក្រុមគួរតែប្រកួតប្រជែង និងជំរុញសមាជិកក្រុមរបស់ពួកគេឱ្យរីកចម្រើន និងកែលម្អខ្លួនឯង ផ្តល់មតិស្ថាបនា និងការទទួលស្គាល់កំណត់ស្តង់ដា និងការរំពឹងទុកខ្ពស់ ប៉ុន្តែជាក់ស្តែង និងអបអរសាទរសមិទ្ធផល និងភាពជោគជ័យ។

ដំណើរនៃការសម្រេចគោលដៅតែងតែជួបនូវឧបសគ្គ ដែលជៀសមិនផុតរាល់ផែនការសកម្មភាពដែលតែងមាន ដូចនេះទាមទារឱ្យប្រធានក្រុម ឬសមាជិកក្រុមត្រូវពិនិត្យ និងដោះស្រាយជាបន្ទាន់ កុំរង់ចាំទាល់តែក្លាយទៅជាជំងឺមហារីកទើបស្វះស្វែងរកគ្រូពេទ្យទេវតាមកព្យាបាល។

ខាងក្រោមនេះ ជាដំណោះស្រាយកំហុសឆ្គងការងារ ដែលជាការជំនួយស្មារតីបន្ថែមដែលអ្នកដឹកនាំក្រុម អ្នកគ្រប់គ្រង និងថៅកែជួយក្នុងការដាស់តឿនស្មារតីនិយោជិត ក៏ដូចជាសមាជិកក្រុមមានដូចជា៖

**-ពិនិត្យមើលហេតុ និងផល ឱ្យបានច្បាស់លាស់ ៖** ជៀសវាងនូវការប្រកាន់ ឬចាប់កំហុសគ្នា។

**-អត់ឱន និងផ្តល់ឱកាសកែខ្លួន ៖** បើមានសមាជិកណាពិនិត្យឃើញថាខ្លួនមានកំហុស ត្រូវចេះទទួលស្គាល់ និងបើឃើញអ្នកដទៃមានកំហុស ត្រូវចេះប្រាប់ដើម្បីឱ្យគាត់ដឹងនឹងកែលម្អទាន់ពេលវេលា។

**-លើកទឹកចិត្តគាំទ្រ និងជំរុញ ៖** ជាការបង្កើតបរិយាកាសរីករាយ ផ្តល់កម្លាំងចិត្ត និងផ្តល់ឱកាសឱ្យសមាជិកក្រុមបានទទួលនូវអ្វីដែលគាត់ចង់ចេះ ចង់ដឹងឬអ្នកដឹកនាំគិតថាមានសារៈសំខាន់សម្រាប់ការងារក្រុម។

**-ដោះស្រាយបញ្ហាភ្លាមៗ ៖** ជាមធ្យោបាយដើម្បីកុំឱ្យរីករាលដាល កុំរង់ចាំទាល់តែក្លាយជាអំពើហិង្សា ព្រោះជម្លោះមួយចំនួនកើតចេញពីការនិយាយលេងសើច ឬសកម្មភាពមិនសមរម្យណាមួយ។

**-រំងាប់អារម្មណ៍ ៖** ដោយការនៅស្ងៀមស្ងាត់ម្នាក់ឯង និងព្យាយាមបន្ធូរបរិយាកាសដោយការជួបជុំមិត្តភក្តិជជែកគ្នាលេង ឬប្រាប់រឿងមិនពេញចិត្តទៅអ្នកដែលអាចដោះស្រាយបាន ស្តាប់បទចម្រៀង ការលេងកីឡា ...។

### ៣.៤ ទំនួលខុសត្រូវក្នុងការបំពេញការងារឱ្យសម្រេចបានជោគជ័យ

ដើម្បីឈានដល់គោលដៅដែលក្រុមការសម្រេចបាន សមាជិកក្រុមនីមួយៗត្រូវមានការទទួលខុសរបស់ខ្លួនដូចជា៖

**-ស្គាល់តួនាទីខ្លួន៖** អ្នកដឹកនាំក្រុមត្រូវតែរៀបចំរចនាសម្ព័ន្ធការងារឱ្យបានច្បាស់លាស់ ផ្សព្វផ្សាយ និងណែនាំសមាជិកក្រុមដឹងពីការបំពេញការងាររបស់ខ្លួន។

**ឧទាហរណ៍៖** ក្នុងគ្រួសារ១ ដែលមានសមាជិក៤នាក់ ឪពុក ម្តាយ កូនច្បង និងកូនពៅ។ ដើម្បីកាត់បន្ថយនូវការប្រចាំការងារគ្នា មេគ្រួសារត្រូវកំណត់ពីតួនាទី ឪពុក ម្តាយ កូនច្បង និងកូនពៅ ធ្វើជាប្រចាំថ្ងៃរួចកំណត់ការបំពេញការងាររៀងៗខ្លួន តាមរចនាសម្ព័ន្ធចាត់តាំង។

**-ធ្វើតាមផែនការ ឬគោលដៅការងារ៖** ការរៀបចំធ្វើផែនការ គឺជាដំណើរការដើម្បីកំណត់គោលដៅរបស់ការងារក្រុម ឬសមាជិកក្រុម។ ធ្វើការអនុវត្តតាមការកំណត់យុទ្ធសាស្ត្រ និងមធ្យោបាយ ហើយនឹងធ្វើឲ្យផែនការ ឬគោលដៅនោះសម្រេចដោយជោគជ័យ។

**-ការតាំងចិត្តបំពេញការងារ៖** ការខិតខំព្យាយាមជាការប្រសើរណាស់ដែលក្រុមអាចជួយគ្នាបានទៅវិញទៅមក អាចចែករំលែកគំនិតគ្នា និងអាចធ្វើការប្រាស្រ័យទាក់ទងគ្នាជាផ្លូវមួយ សុទ្ធតែកើតចេញពីការខិតខំប្រឹងប្រែងតាំងចិត្តបំពេញការងារឱ្យទទួលបានប្រសិទ្ធភាព និងជោគជ័យ។

**-ការអត់ឱនអធ្យាស្រ័យ៖** ការបំពេញការងារជាក្រុម គឺជៀសមិនផុតពីការធ្វើការជួយបុគ្គលដែលមានស្ថានភាពផ្សេងៗ (ស្ងៀមស្ងាត់ និយាយច្រើន) រូបរាង(ជាត់ ស្គម) ពូជសាសន៍ ភេទ(ស្រី ប្រុស)។

**-ការត្រួតពិនិត្យការងារ ខ្លួនឯង និងក្រុមជាប្រចាំ៖** ការត្រួតពិនិត្យ គឺជាការវាយតម្លៃរាល់សកម្មភាពដែលបានអនុវត្តកន្លងមក ធៀបទៅនឹងផែនការកំណត់ព្រមទាំងតភ្ជាប់ទៅនឹងលទ្ធផល។ ការកំណត់ផែនការជ្រើសរើសគោលដៅ និងគ្រោងឡើងនូវយុទ្ធសាស្ត្រ និងយុទ្ធវិធីចាំបាច់។ ការត្រួតពិនិត្យព្យាយាមការពារការបរាជ័យដោយការផ្តល់នូវមធ្យោបាយ ដើម្បីពិនិត្យមើលនូវសកម្មភាពការងាររបស់សមាជិកម្នាក់ៗតាមការិយាល័យ រោងចក្រ សហគ្រាស និងអង្គភាពទាំងមូល។ ការព្យាយាមការពាររាល់បញ្ហាផ្សេងៗដែលកើតមានឡើង និងរកវិធីដោះស្រាយបញ្ហាឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

**៤. មនុស្សដែលប្រកបដោយមនសិការវិជ្ជាជីវៈ**

-ស្រឡាញ់ការងារ។

-ចំណង់ចំណូលចិត្តក្នុងការបំពេញការងារ។

-និយតភាពក្នុងការងារបំពេញការងារ(ភាពទៀងទាត់)។

-ភាពវាងវៃ និងស្មារតីច្នៃប្រឌិត។

-ប៉ិនប្រសព្វ និងការដោះស្រាយក្នុងការងារ។

-គំនិតរីកចម្រើន និងកំណែលម្អ៕

## កិច្ចការអនុវត្ត

### ក. សំណួរជ្រើសរើស

១. ជំនាញទន់ ត្រូវបានគេចាត់ទុកជា៖

☐ ជំនាញរូបី ☐ ជំនាញអរូបី ☐ មិនដឹង

២. តើអ្នកធ្លាប់ឮពាក្យថា «មនសិការវិជ្ជាជីវៈ» ដែរឬទេ ?

☐ ធ្លាប់ឮ ☐ មិនធ្លាប់

៣. តើជំនាញដែលមនុស្សម្នាក់ៗត្រូវការចាំបាច់មានប៉ុន្មានប្រភេទ ?

☐ ២ប្រភេទ ☐ ៣ប្រភេទ ☐ ៤ប្រភេទ

៤. តើអ្នកធ្លាប់ឮពាក្យថា «មនសិការវិជ្ជាជីវៈ» ដែរឬទេ ?

☐ ធ្លាប់ឮ ☐ មិនធ្លាប់

៥. ជំនាញរឹង/ជំនាញឯកទេស ត្រូវបានគេចាត់ទុកជា៖

☐ ជំនាញរូបី ☐ ជំនាញអរូបី ☐ មិនដឹង

៦. ជំនាញរឹង សំដៅទៅលើ៖

☐ ភាពប៉ិនប្រសព្វ ☐ជំនាញដ៏ស្ទាត់ជំនាញ ☐ មិនដឹង

### ខ. សំណួរផ្គូផ្គង

| អត្ថន័យ | | រូបភាព | | ចម្លើយ |
|---|---|---|---|---|
| ១- | ជំនាញទន់ | ក- |  | ១- |
| ២- | ជំនាញរឹង | ខ- |  | ២- |
| ៣- | ភាពទៀងទាត់ | គ- |  | ៣- |
| ៤- | អនាម័យ | ឃ- |  | ៤- |
| ៥- | ការរៀបចំខ្លួន | ង- |  | ៥- |

| | | | | |
|---|---|---|---|---|
| ៦- | ភាពជោគជ័យ | ច- |  | ៦- |
| ៧- | កំហឹង និងជំលោះ | ឆ- |  | ៧- |
| ៨- | ការលើកទឹកចិត្ត និងគាំទ្រ | ជ- |  | ៨- |
| ៩- | ការអត់ឱន និងផ្តល់ឱកាស | ឈ- |  | ៩- |
| ១០- | ការងារជាក្រុម | ញ- |  | ១០- |

**គ. សំណួរសរសេរ**

១.តើអ្នកយល់ដូចម្តេចចំពោះសមត្ថភាពជំនាញរបស់ខ្លួន ?

២.តើអ្វីជាកត្តាជំរុញឲ្យអ្នកប្រឹងប្រែងបំពេញការងារ ?

៣.តើអ្វីជាបញ្ហាចម្បងសម្រាប់ការស្វែងរកការងារ (អ្នកមិនដែលធ្លាប់បំពេញការងារ) ?

៤.តើអ្វីជាបញ្ហាក្នុងបំពេញការងារប្រចាំថ្ងៃរបស់អ្នក (សម្រាប់អ្នកមានការងារ) ?

៥.តើការបំពេញការងារជាក្រុមមានសារៈសំខាន់ដែរឬទេ ?

## ប្រតិសកម្មចំពោះកិច្ចការអនុវត្ត

### ក. សំណួរជ្រើសរើស

១. ជំនាញទន់ ត្រូវបានគេចាត់ទុកជា៖

☐ ជំនាញរូបី ☑ ជំនាញអរូបី ☐ មិនដឹង

២. តើអ្នកធ្លាប់ឮពាក្យថា «មនសិការវិជ្ជាជីវៈ» ដែរឬទេ ?

☑ ធ្លាប់ឮ ☐ មិនធ្លាប់

៣. តើជំនាញដែលមនុស្សម្នាក់ៗត្រូវការចាំបាច់មានប៉ុន្មានប្រភេទ ?

☑ ២ប្រភេទ ☐ ៣ប្រភេទ ☐ ៤ប្រភេទ

៤. ជំនាញរឹង/ជំនាញឯកទេស ត្រូវបានគេចាត់ទុកជា៖

☑ ជំនាញរូបី ☐ ជំនាញអរូបី ☐ មិនដឹង

៥. ជំនាញទន់ សំដៅទៅលើ៖

☑ ភាពប៉ិនប្រសប់ ☐ជំនាញដ៏ស្ទាត់ជំនាញ ☐ មិនដឹង

### ខ. សំណួរផ្គូផ្គង

| អត្ថន័យ | | រូបភាព | | ចម្លើយ |
|---|---|---|---|---|
| ១- | ជំនាញទន់ | ក- |  | ១-ញ |
| ២- | ជំនាញរឹង | ខ- |  | ២-ឈ |
| ៣- | ភាពទៀងទាត់ | គ- |  | ៣-ជ |
| ៤- | អនាម័យ | ឃ- |  | ៤-ឆ |
| ៥- | ការរៀបចំខ្លួន | ង- |  | ៥-ច |
| ៦- | ភាពជោគជ័យ | ច- |  | ៦-ង |

| | | | | |
|---|---|---|---|---|
| ៧- | កំហឹង និងជំលោះ | ឆ- |  | ៧-ឃ |
| ៨- | ការលើកទឹកចិត្ត និងគាំទ្រ | ជ- |  | ៨-គ |
| ៩- | ការអត់ឱន និងផ្តល់ឱកាស | ឈ- |  | ៩-ខ |
| ១០- | ការងារជាក្រុម | ញ- |  | ១០-ក |

**គ. ចម្លើយសំណួរសរសេរ**

១.ចម្លើយផ្ទាល់ខ្លួន

២.កត្តាជំរុញឱ្យអ្នកប្រឹងប្រែងបំពេញការងារព្រោះ៖

- ការងារជាប្រភពនៃចំណូលសេដ្ឋកិច្ចក្នុងគ្រួសាររបស់មនុស្សម្នាក់ៗ
- ការងារប្រកបដោយសុចរិត ទៀងត្រង់ត្រឹមត្រូវ នាំឱ្យមនុស្សទទួលបាន នូវសេចក្តីថ្លៃថ្នូរ និងមានកិត្តិយស។
- ការងារត្រឹមត្រូវផ្តល់នូវសេចក្តីរីករាយ និងសុភមង្គលដល់មនុស្ស។
- ការងារជាចំណងចងឱ្យមនុស្សចេះរស់នៅជាក្រុម និងមានសាមគ្គីភាព ក្នុងគ្រួសារ និងសង្គមជាតិ។
- ការងារនាំឱ្យមនុស្សទៅរកភាពម្ចាស់ការលើខ្លួនឯង។
- ការងារធ្វើឱ្យមនុស្សមានសមត្ថភាពពិតប្រាកដ។
- ការងារនាំឱ្យមនុស្សស្គាល់ពីតំលៃខ្លួនឯង។

៣. ចម្លើយផ្ទាល់ខ្លួន «បញ្ហាចម្បងសម្រាប់ការស្វែងរកការងារ (អ្នកមិនដែលធ្លាប់បំពេញការងារ)»។

៤. ចម្លើយផ្ទាល់ខ្លួន «បញ្ហាក្នុងបំពេញការងារប្រចាំថ្ងៃរបស់អ្នក (សម្រាប់អ្នកមានការងារ)»។

៥. ការបំពេញការងារជាក្រុមមានសារៈសំខាន់ដូចជា៖

-បង្កើតការប្រាស្រ័យទាក់ទងល្អ។

-សហការការងារបានដោយរលូន។

-ទំនួលខុសត្រូវក្នុងការបំពេញការងារ។

-ដំណោះស្រាយបញ្ហា ដោយភាពប៉ិនប្រសប់។

-ការងារទទួលបានជោគជ័យ៕

## មេរៀនទី២

# សុវត្ថិភាព និងសុខភាពការងារ និង Kaizen (5S)

### ១. និយមន័យសុវត្ថិភាពការងារ (Safety)

សុវត្ថិភាពការងារ (Safety) គឺជាការជៀសវាងពីគ្រោះថ្នាក់ និងនិរភ័យកន្លែងការងារផ្សេងៗដែលអាចមានគ្រោះថ្នាក់ដល់ជីវិត សុខភាព ទ្រព្យសម្បត្តិ បរិស្ថាន។ល។

- ចៀសវាងកុំឱ្យមានគ្រោះថ្នាក់ ឬរបួសដល់ខ្លួនឯង ឬអ្នកដទៃ។
- ធ្វើយ៉ាងណាកុំឱ្យខូចខាតដល់ឧបករណ៍ ឬបរិធានវង្វាស់ប្រើប្រាស់ពេលធ្វើការងារ។




រូបភាព១ រៀបចំកន្លែងការងារឲ្យមានសុវត្ថិភាព

### មូលហេតុនៃគ្រោះថ្នាក់នៅកន្លែងការងារ

- ✓ ការធ្វេសប្រហែស ឬលេងសើចច្រើននៅកន្លែងការងារ មិនបានវាយតម្លៃពីគ្រោះថ្នាក់។
- ✓ កន្លែងការងារគ្មានសុវត្ថិភាព។
- ✓ ខ្វះការយល់ដឹងពីរបៀបការពារ។
- ✓ មិនបានប្រើប្រាស់ PPE (Personal Protective Equipment) ។
- ✓ មិនយល់ពីស្លាកសញ្ញាសុវត្ថិភាពការងារ។
- ✓ កាយសម្បទាមិនគ្រប់គ្រាន់។
- ✓ ឧបករណ៍ សម្ភារ ឬម៉ាស៊ីន គ្មានរបាំងការពារ។
- ✓ ខ្វះការបណ្តុះបណ្តាលបច្ចេកទេសការពារឲ្យមានសុវត្ថិភាព។ល។

### ការរក្សាសុវត្ថិភាពនៅកន្លែងធ្វើការងារ

- ✓ ត្រូវប្រុងប្រយ័ត្ន និងទម្លាប់វាយតម្លៃពីគ្រោះថ្នាក់មុនមានសកម្មភាពធ្វើការងារ។
- ✓ ត្រូវចូលរួមសម្អាត រៀបចំកន្លែងការងារឱ្យមានសណ្តាប់ធ្នាប់ បរិស្ថានល្អ តាមគោលការណ៍5S។

✓ ធ្វើការតាមបទដ្ឋានការងារ។
✓ ត្រូវប្រមូលអារម្មណ៍ធ្វើការងារដោយប្រុងប្រយ័ត្ន។
✓ បង្កើនការយល់ដឹងពីគ្រោះថ្នាក់ ត្រូវចេះប្រើប្រាស់ PPE ឱ្យបានត្រឹមត្រូវ។
✓ ត្រូវយល់ដឹងពីស្លាកសញ្ញាសម្គាល់ទាំងអស់នៅកន្លែងការងារ។
✓ ត្រូវរក្សាសុខភាពឲ្យបានល្អ បើឈឺត្រូវសម្រាក។
✓ ត្រូវពិនិត្យមើលឧបករណ៍ ឬគ្រឿងការពារលើម៉ាស៊ីនជាដើម មុនធ្វើការងារ។
✓ ត្រូវមានជំនាញច្បាស់លាស់លើការងារដែលត្រូវធ្វើ។




រូបភាព៧ ជៀសវាងពីគ្រោះថ្នាក់នៅកន្លែងការងារ

**គ្រោះថ្នាក់ដែលអាចកើតមាន៖**

- កន្លែងពន្លឺមិនគ្រប់គ្រាន់។
- កន្លែងការងារគ្មានសណ្តាប់ធ្នាប់។
- ឧបករណ៍សម្ភារទុកដាក់មិនត្រឹមត្រូវ។
- កន្លែងមានតង់ស្យុងខ្ពស់។
- កន្លែបិទជិតគ្មានខ្យល់អាកាស ឬមានផ្សែង ឬក្លិនគីមីផ្សេងៗ។ល។

**វិធីបង្ការគ្រោះថ្នាក់**

- រក្សាទម្លាប់ធ្វើការងារឲ្យមានសុវត្ថិភាព។
- គោរពតាមគោលការណ៍ ឬច្បាប់សុវត្ថិភាពក្នុងកន្លែងការងារ។
- វាយតម្លៃគ្រោះថ្នាក់មុខចាប់ផ្តើមធ្វើការងារ។
- ជៀសវាងអនុវត្តនូវសកម្មភាពដែលនាំមកនៅគ្រោះថ្នាក់។
- វិធីសាស្ត្រដោះស្រាយពេលមានគ្រោះថ្នាក់។។

## គ្រោះថ្នាក់ដែលបណ្តាលមកពីអគ្គិសនី

## សេចក្តីផ្តើម

បច្ចុប្បន្ននេះ ថាមពលអគ្គិសនីបានបម្រើសេចក្តីត្រូវការក្នុងការប្រើប្រាស់ផ្សេងៗ ដើម្បីធ្វើឲ្យការរស់នៅរបស់មនុស្សមានលក្ខណៈល្អប្រសើរឡើង។ ទន្ទឹមនឹងនេះ ការនាំយកថាមពលអគ្គិសនីទៅប្រើប្រាស់ បើមានការធ្វេសប្រហែសមិនសមស្របទៅតាមលក្ខណៈបច្ចេកទេស ឬមិនប្រុងប្រយ័ត្ននោះទេ នឹងបង្ករខូចខាតដល់ទ្រព្យសម្បត្តិ និងគ្រោះថ្នាក់ដល់រាងកាយ ឬអាយុជីវិតថែមទៀតផងដែរ គឺដោយសារតែអ្នកប្រើប្រាស់ភាគច្រើនខ្វះការយល់ដឹងអំពីវិធីការពារ ដើម្បីទទួលបានសុវត្ថិភាពការងារ។ ដូចនេះសុវត្ថិភាពនៃការប្រើប្រាស់ថាមពលអគ្គិសនី គឺជាបញ្ហាដ៏សំខាន់មួយដែលត្រូវយកចិត្តទុកដាក់ជាទីបំផុត។ តាមការត្រួតពិនិត្យ និងសង្កេតកន្លងមកឃើញថា រាល់ឧប្បត្តិហេតុកើតឡើងភាគច្រើន បណ្តាលមកពីការមិនយល់ដឹងច្បាស់លាស់ លើផ្នែកអគ្គិសនី ដោយបណ្តោយទុកឲ្យខ្សែភ្លើងខូចខាត រហូតដល់អ៊ីសូឡង់របស់ខ្សែ ដែលស្រោបលួស ស្ពាន់ ប្រេះបែក ឬដាច់អ៊ីសូឡង់ ដែលជាវត្ថុការពារមិនឱ្យចរន្តអគ្គិសនីលិចធ្លាយចេញមកក្រៅ ធ្វើឲ្យប៉ះពាល់ដល់ឧបករណ៍បរិក្ខារអគ្គិសនី និងជាហេតុដែលបង្កគ្រោះថ្នាក់ដល់មនុស្ស និងសត្វ។ ដូច្នេះយើងត្រូវមើលថែរក្សាអ៊ីសូឡង់កុំឱ្យហែកដាច់ ឬត្រូវកម្តៅខ្លាំង។ ចំពោះអ្នកធ្វើការងារផ្ទាល់ជាមួយអគ្គិសនីត្រូវតែស្វែងយល់ឲ្យបានច្បាស់លាស់អំពីការការពារសុវត្ថិភាព និងផលប៉ះពាល់ដែលអាចកើតមានឡើងដោយសារអគ្គិសនីដែលបង្កឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វ និងទ្រព្យសម្បត្តិផ្សេងៗ។

## ការណែនាំឲ្យស្គាល់ពីអគ្គិសនី

+ តើប្រភពចរន្តអគ្គិសនីមានប៉ុន្មានប្រភេទ ?អ្វីខ្លះ ?

- ប្រភពចរន្តអគ្គិសនីមាន ២ប្រភេទគឺ៖
  - ប្រភពអគ្គិសនីចរន្ត DC ( Direct Current)
  - ប្រភពអគ្គិសនីចរន្ត AC ( Alternating Current)

+ តើប្រភពចរន្តអគ្គិសនី DC មាននៅឯណាខ្លះ ?

- ប្រភពចរន្តអគ្គិសនី DC មាននៅដូចជា៖
  - អាគុយ
  - ថ្មពិល
  - ថ្មទូរស័ព្ទ
  - ឌីណាម៉ូ។ល។

+ តើប្រភពចរន្តអគ្គិសនី AC មាននៅឯណាខ្លះ ?

- ប្រភពចរន្តអគ្គិសនី AC មាននៅដូចជា៖

- វ៉ារីអគ្គិសនី។

- ម៉ាស៊ីនភ្លើង។ល។

\+ ដូចម្តេចដែលហៅថា សៀគ្វីអគ្គិសនី?

- ដែលហៅថាសៀគ្វីអគ្គិសនី គឺសៀគ្វីមួយបិទជិតដែលមានប្រភព កុងតាក់ ខ្សែភ្លើង និង គ្រឿងទទួល ដែលតភ្ជាប់បានមួយជុំសៀគ្វី។

\+ តើគ្រឿងទទួលអគ្គិសនីមានអ្វីខ្លះ?

- គ្រឿងទទួលអគ្គិសនីមានដូចជា៖ ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនថតចម្លង ម៉ាស៊ីនបោះពុម្ព កង្ហារ កុំព្យូទ័រ ទូរទស្សន៍ វិទ្យុ ឆ្នាំងដាំបាយអគ្គិសនី គ្រឿងបរិក្ខារអគ្គិសនី និងគ្រឿងអេឡិចត្រូនិចផ្សេងៗទៀត។

**គ្រោះថ្នាក់បណ្តាលមកពីការឆក់ចរន្តអគ្គិសនី**

ភាពធ្ងន់ធ្ងរនៃការរងរបួសដែលកើតឡើងមកពីការឆក់នៃចរន្តអគ្គិសនី គឺអាស្រ័យទៅលើអាំងតង់ស៊ីតេចរន្ត ដែលឆ្លងកាត់រាង្គកាយ និងរយៈពេលដែលចរន្តអគ្គិសនីឆ្លងកាត់។

**ឧទាហរណ៍៖** ចរន្ត 1/10A គឺវាចំណាយពេលត្រឹមតែ ២វិនាទី ជាការគ្រប់គ្រាន់បណ្តាលឲ្យជនរងគ្រោះស្លាប់បាន ពីព្រោះរាង្គកាយមនុស្ស អាចធន់នឹងចរន្តត្រឹមតែ10mA យ៉ាងច្រើនប៉ុណ្ណោះ ព្រោះ10mA គឺមិនធ្វើឱ្យមានការឈឺចាប់ខ្លាំងទេ ប៉ុន្តែ10mA ឡើងទៅ គឺអាចធ្វើឱ្យសាច់ដុំឡើងរឹងលែងកម្រើកបាន។

នៅពេលដែលសាច់ដុំរឹងលែងកម្រើកបានកើតឡើងនោះ ធ្វើឱ្យមានការគ្រោះថ្នាក់កាន់តែខ្លាំង ព្រោះជនរងគ្រោះមិនអាចចាក់ចេញពីគ្រឿង ឬឧបករណ៍ និងកន្លែងដែលមានចរន្តអគ្គសនីឆ្លងកាត់បានឡើយ។ នៅពេលនោះ ចលនាដង្ហើម និងបេះដូងត្រូវបានឈប់ដំណើរការរហូតដល់ពេលមួយ គឺត្រូវស្លាប់តែម្តង ប្រសិនបើគ្មានការជួយសង្គ្រោះបន្ទាន់។

ត្រូវចាំថា ការឆក់កាន់តែយូររបួសកាន់តែរីកធំនៅលើជនរងគ្រោះ ហើយជាធម្មតារបួសដែលកើតពីការឆក់ដោយចរន្តអគ្គសនី គឺជាការដុតរោលដោយកម្តៅ។ ដូច្នេះហើយ កាលណាចរន្តកាន់តែធំគឺកាន់តែក្តៅ។

ឧទាហរណ៍៖ ចរន្តអគ្គិសនី 5A អាចដុតជាលិការបស់មនុស្សឲ្យខូចបាន។

**<u>មូលហេតុនាំឲ្យឆក់ចរន្តអគ្គិសនី</u>**

គ្រោះថ្នាក់ដែលកើតមកពីការឆក់ចរន្តអគ្គិសនី គឺបណ្តាលមកពីកត្តាមនុស្ស និងកត្តាសម្ភារ។

**ក. កត្តាមនុស្ស**

- មិនមានការយល់ដឹងច្បាស់លាស់ពីផ្នែកអគ្គិសនី។
- ប្រើប្រាស់សម្ភារអគ្គិសនីមិនត្រូវតាមបច្ចេកទេស ។
- ប៉ះពាល់ទៅនឹងឆ្នាប់ចរន្តអគ្គិសនីទាំងដៃសើមមិនមានការប្រុងប្រយ័ត្ន។
- មិនធ្លាប់ស្គាល់ពីសម្ភារអគ្គិសនី និងមិនធ្លាប់សិក្សាពីអគ្គិសនី។

- ការជួសជុលឧបករណ៍បរិក្ខារអគ្គិសនី ឬបណ្ដាញអគ្គិសនីដោយមិនបានកាត់ផ្ដាច់ សៀគ្វីអគ្គិសនី និងមិនបានប្រើប្រាស់ឧបករណ៍ការពារដើម្បីការពារសុវត្ថិភាព។



រូបភាព៣ ភាពខ្វះការយល់ដឹងពីការទុកដាក់ឧបករណ៍ប្រើប្រាស់



រូបភាព៤ ការទុកដាក់ខ្សែដោយមិនមានការត្រួតពិនិត្យ

### ខ. កត្តាសម្ភារ

ដោយសារតែសង្គមបច្ចុប្បន្ននេះ បច្ចេកវិទ្យាមានការរីកចម្រើនសម្បូរបែប ដូច្នេះប្រជាជនគ្រប់មជ្ឈដ្ឋានទាំងអស់ពួកគេក៏បានទិញសម្ភារទំនើបៗទៅប្រើប្រាស់ ដែលផ្លាស់ប្ដូរទៅតាមស្ថានភាពគ្រួសារ និងធនធានដែលពួកគេមានរៀងៗខ្លួន ហើយក្នុងការដែលយកឧបករណ៍ ឬសម្ភារទាំងអស់នោះទៅប្រើប្រាស់ បើពួកគេ

មិនបានការយល់ដឹងអំពីលក្ខណៈបច្ចេកទេស ឬក៏ហៅជាភាសាសាមញ្ញថា របៀបប្រើប្រាស់ *បើមិនចេះប្រើប្រាស់នោះទេ ពួកគេនឹងប្រឈមមុខទៅនឹងការបាត់បង់សម្ភារ ទ្រព្យសម្បត្តិ និងឈានទៅកការបាត់បង់ជីវិតទៀតផង។* ចំពោះករណីនេះ គេប្រទះឃើញកើតមានជាញឹកញាប់នៅក្នុងសង្គមខ្មែរបច្ចុប្បន្ននេះ។



រូបភាព៥ ខ្សែរលាត់ខ្វះការត្រួតពិនិត្យ

- ❖ **គុណប្រយោជន៍សុវត្ថិភាពការងារ**

ការយល់ដឹងពីរបៀបធ្វើការប្រកបដោយសុវត្ថិភាព អាចជួយសង្គ្រោះជីវិតរបស់អ្នកបាន។ ផ្ទុយទៅវិញបើសិនជាយើងមិនយល់ដឹងពីសុវត្ថិភាពការងារ គឺធ្វើឲ្យយើងមានគ្រោះថ្នាក់រងរបួស ឬអាចបាត់បង់ជីវិតនៅពេលបំពេញការងារ។ ការយកចិត្តទុកដាក់យល់ដឹងអំពីសុវត្ថិភាព ផ្អែកទៅលើស្ថានភាពជាក់ស្តែងដែលទទួលបានពីបទពិសោធន៍ការងារប្រចាំថ្ងៃ និងការរៀបចំគម្រោងការងារឲ្យមានសុវត្ថិភាពខ្ពស់។ ការងារប្រកបដោយសុវត្ថិភាព គឺជាបំណងប្រាថ្នាសម្រាប់មនុស្សគ្រប់ៗរូប មិនថាតែអ្នកគ្រប់គ្រង បុគ្គលិក កម្មករ។ល។

គោលបំណងនៃការសិក្សាអំពីសុវត្ថិភាពនេះ គឺផ្តល់ដល់អ្នកសិក្សានូវអត្ថប្រយោជន៍ដូចជា៖

- ➢ ការសន្សំសំចៃពេលវេលា។
- ➢ ការសន្សំសំចៃថវិកា។
- ➢ សោភ័ណ្ឌភាព។
- ➢ គុណភាព។
- ➢ ពុំប៉ះពាល់ដល់សុខភាព។
- ➢ សុវត្ថិភាពផ្ទាល់ខ្លួនក្នុងពេលបំពេញការងារ។
- ➢ សុវត្ថិភាពដល់អ្នកដែលនៅជុំវិញខ្លួនយើង។
- ➢ ការពារសុវត្ថិភាពដល់ឧបការណ៍ប្រើប្រាស់អាចធ្វើឱ្យឧបករណ៍ប្រើប្រាស់បានយូរ។

## សំណួរពិភាក្សា

1. តើប្រភពអគ្គិសនីមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. ដូចម្តេចដែលហៅថា សៀគ្វីអគ្គិសនី ?
3. តើគ្រឿងទទួលអគ្គិសនីមានអ្វីខ្លះ ?
4. តើគ្រោះថ្នាក់ដែលកើតមានពីការឆក់ចរន្តអគ្គិសនីមានប៉ុន្មានកត្តា ? អ្វីខ្លះ ?
5. តើកត្តាមនុស្សមានអ្វីខ្លះ ?
6. តើកត្តាសម្ភារមានអ្វីខ្លះ ?
7. តើគុណប្រយោជន៍សុវត្ថិភាពការងារបានផ្តល់ឲ្យយើងអ្វីខ្លះ ?

## ប្រភេទនៃគ្រោះថ្នាក់បណ្ដាលមកពីការឆក់

ថាមពលអគ្គិសនី មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្នុងនោះវាមានតួនាទីសម្រាប់បំពេញនូវតម្រូវការក្នុងការប្រើប្រាស់ប្រចាំថ្ងៃ ដើម្បីធ្វើឲ្យជីវភាពរស់នៅរបស់មនុស្សលើផែនដីមានលក្ខណៈទ្រព្យសម្បត្តិ អាយុជីវិតផងដែរ ប្រសិនបើជាយើងមិនបានប្រើប្រាស់ និងមិនអនុវត្តឲ្យបានត្រឹមត្រូវ ហើយនៅខ្វះការយល់ដឹងអំពីវិធីការពារនៃអគ្គិសនី។ ចំពោះអ្នកដែលធ្វើការជាមួយនឹងឧបករណ៍អគ្គិសនីត្រូវស្វែងយល់ឲ្យច្បាស់អំពីច្បាប់សុវត្ថិភាព ក្នុងគោលបំណងដើម្បីជៀសវាងពីគ្រោះថ្នាក់ដល់អាយុជីវិត និងការបាត់បង់ទ្រព្យសម្បត្តិផ្សេងៗ។

គ្រោះថ្នាក់អាចកើតឡើងក្នុងមួយពព្រិចភ្នែក ដែលយើងទាំងអស់គ្នានឹកស្មានមិនដល់ដូចគ្នានេះដែរ ការធ្វើការជាមួយនឹងអគ្គិសនី គឺជាការងារដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់បំផុត ប្រសិនបើយើងមិនមានការប្រុងប្រយ័ត្ន និងមិនយល់ច្បាស់អំពីវា។ ការប្រើប្រាស់អគ្គិសនី គឺពិតជាមានការគ្រោះថ្នាក់ខ្លាំងណាស់ កាលណាបើយើងប្រើប្រាស់ទៅតាមបទដ្ឋានបច្ចេកទេសឲ្យបានត្រឹមត្រូវ នោះយើងនឹងមិនមានគ្រោះថ្នាក់ ព្រមទាំងយើងទទួលបាននូវផលប្រយោជន៍ពីវាជាច្រើនទៀតផង។ ប៉ុន្តែប្រសិនបើយើងប្រើប្រាស់ដោយមិនមានការយល់ដឹងអំពីអគ្គិសនី ហើយនឹងមិនបានពិគ្រោះជាមួយអ្នកជំនាញទេនោះ យើងនឹងអាចមានការគ្រោះថ្នាក់កើតមានដល់យើងជាយថាហេតុ។ គ្រោះថ្នាក់ដែលបណ្ដាលមកពីការឆក់អគ្គិសនី គឺកើតមាននៅពេលមានចរន្តអគ្គិសនីមកប៉ះសរីរាង្គកាយ ដែលបង្កឲ្យមាននូវការកន្ត្រាក់សាច់ដុំ។ អំពើរបស់ចរន្តអគ្គិសនីមកលើរាងកាយរបស់មនុស្សមានសភាពខុសៗគ្នាដូចខាងក្រោម៖



រូបភាព៦ ការបង្ហាញពីការគ្រោះថ្នាក់ដោយចរន្តអគ្គិសនី



រូបភាព១ ការបង្ហាញពីការឆក់អគ្គិសនី

## គ្រោះថ្នាក់ដោយចរន្តអគ្គិសនី

### សេចក្ដីផ្ដើម

បច្ចុប្បន្នជាសម័យកាលដែលជឿនលឿនបំផុតនៅក្នុងសង្គមមនុស្ស ជាពិសេស គឺផ្នែកវិស័យបច្ចេកទេសដែលមានការរីកចម្រើនឥតឈប់ឈររួមមាន ផ្នែកមេកានិក ព័ត៌មានវិទ្យា អេឡិចត្រូនិក សំណង់ស៊ីវិល និងផ្នែកបច្ចេកទេសអគ្គិសនីជាដើម។ ជាទូទៅផ្នែកវិស័យបច្ចេកទេស តែងតែជួបប្រទះនូវគ្រោះថ្នាក់ផ្សេងៗ បើមិនច្រើន ក៏តិចតួចដែរ។ ជាពិសេសនៅក្នុងការអនុវត្តនៅតាមការដ្ឋានផ្សេងៗជាដើម។ ក្នុងនោះ យើងឃើញថាក្នុងផ្នែកបច្ចេកទេសអគ្គិសនី ក៏តែងតែប្រទះនូវគ្រោះថ្នាក់ដែលបណ្ដាលមកពីការឆក់ចរន្តអគ្គិសនីជាច្រើនលើក

ច្រើនសារផងដែរ។ ចំពោះបញ្ហានេះ យើងនឹងធ្វើការអធិប្បាយពីមូលហេតុផ្សេងៗ និងដោះស្រាយបញ្ហាដែលពាក់ព័ន្ធទៅតាមចំណុចដូចខាងក្រោម៖

**គ្រោះថ្នាក់ដែលបណ្តាលមកពីការឆក់ចរន្តអគ្គិសនី**

**ការឆក់ចរន្តអគ្គិសនី គឺជាអ្វី?**



រូបភាព៧ ឆក់ដោយខ្សែភ្លើង

មុននឹងឲ្យនិយមន័យទៅលើការឆក់ចរន្តអគ្គិសនី យើងគួរដឹងមុនថា "**ចរន្តអគ្គិសនី គឺជាអ្វី**"?

" **ចរន្តអគ្គិសនី** គឺវាគ្មានពណ៌ គ្មានក្លិន គ្មានរសជាតិ ហើយមានខ្នាតគិតជាអំពែ (A)។ ចរន្តអគ្គិសនីកើតមាននៅពេលមានលំហូរអេឡិចត្រុងនៅក្នុងអង្គធាតុចម្លង"។ ដូចនេះយើងអាចពន្យល់បានថា ការឆក់នៃចរន្តអគ្គិសនី គឺជាការឈឺចាប់មួយប្រភេទដែលកើតឡើងនៅពេលមានលំហូរអេឡិចត្រុងនៃចរន្តអគ្គិសនីរត់ឆ្លងកាត់លើសរីរាង្គកាយមនុស្ស ( ដៃ ជើង ស្បែក សក់...)។ ភ្លាមៗនោះ យើងអាចនិយាយបានថា ជនរងគ្រោះគឺជាអង្គធាតុចម្លងរបស់ចរន្តអគ្គិសនី។



រូបភាព៣៨ ការឆក់ដោយចរន្តអគ្គិសនី

**ហេតុអ្វីបានជាចរន្តអគ្គិសនីមានគ្រោះថ្នាក់**

យើងប្រហែលជាឆ្ងល់ហើយថា ចុះបើចរន្តអគ្គិសនី វាគ្មានពណ៌ គ្មានក្លិន គ្មានរសជាតិផង ហេតុអ្វីបានជាវាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់ ?

យោងទៅតាមរូបមន្តៈ

V = R*I

V ជាតង់ស្យុង មានខ្នាតគិតជា វ៉ុល (V)

R ជារេស៊ីស្តង់ មានខ្នាតគិតជា អូម (Ω)

I ជាអាំងតង់ស៊ីតេចរន្ត មានខ្នាតគិតជា អំពែ (A)

យើងសង្កេតឃើញថា

- R មានតម្លៃថេរ
- V មានតម្លៃប្រែប្រួល បើ V ប្រែប្រួល I ក៏ប្រែប្រួលដែរ
- ផ្ទុយទៅវិញ បើ I ប្រែប្រួល នោះ V ក៏ប្រែប្រួលដែរ។
- *ចំពោះ V ជាកម្លាំងដែលវាមានរូបមន្ត 1V = 1J/1C មានន័យថាតង់ស្យុង ១វ៉ុល គឺវាត្រូវការថាមពល ១ស៊ូល ដើម្បីរុញច្រានបន្ទុក១គូឡុំឲ្យធ្វើចលនា។ ត្រង់ចំណុចនេះ បានបញ្ជាក់ថា*

*ចរន្តអគ្គិសនី គឺវាមានតង់ស្យុងដែលជាកម្លាំងមួយ។ ដូច្នេះហើយ បើវាជាកម្លាំង នោះច្បាស់ជាមានគ្រោះថ្នាក់ កាលណាយើងទទួលរងនូវកម្លាំងនោះ។*

- ក្នុងភាពជាក់ស្តែង បើគ្មានV ក៏មិនអាចមាន I ដែរ។ តែ I អាចគ្មាន នៅពេលដែលមាន V ព្រោះចរន្តកើតមានឡើង លុះត្រាតែមានគ្រឿងទទួល ឬយើងអាចនិយាយបានថា មានចរន្តគឺនៅពេលមានលំហូរអេឡិចត្រុង ដែលបណ្តាលមកពីមានផលសងប៉ូលតង់ស្យែលរវាងខ្សែហ្វា និងខ្សែណឺត ឬខ្សែហ្វា និងខ្សែហ្វា។
- ការឆក់នៃចរន្តអគ្គិសនីកើតមានឡើង កាលណាជនរងគ្រោះដើរតួជាអង្គធាតុចម្លងរវាងខ្សែដូចខាងលើ។

យើងអាចកំណត់រូបមន្តការឆក់បានគឺៈ

$V_{ph} = R_h * I_h$

- ➢ $V_{ph}$ = ថេរ
- ➢ $I_h$ គឺអាស្រ័យលើ $R_h$ ហើយកាលណា $R_h$ កាន់តែធំ នោះចរន្តដែលរត់ឆ្លងកាត់លើរាង្គកាយមនុស្សកាន់តែតូចដែរ។ កាលណា $I_h$កាន់តែធំ នោះគ្រោះថ្នាក់កាន់តែខ្លាំងចំពោះជនរងគ្រោះ។
- ➢ ចំពោះរេស៊ីស្តង់ខ្លួនមនុស្សគឺវាប្រែប្រួលពី ១០០០Ω ទៅ ១០០០០០Ω គឺវាអស្រ័យទៅលើមាឌ ស្បែក ភាពសើម ភាពស្ងួត និងសីតុណ្ហភាពនៃរាង្គកាយជាដើម។

**ប្រភេទនៃការឆក់ដោយចរន្តអគ្គិសនី**

ការឆក់ដោយចរន្តអគ្គិសនីមាន២ប្រភេទ គឺការឆក់ដោយផ្ទាល់ និងការឆក់ដោយប្រយោល។

**ក. <u>ការឆក់ដោយផ្ទាល់</u>**

**ការឆក់ដោយផ្ទាល់** គឺជាការឆក់ចរន្តអគ្គិសនី ដែលជនរងគ្រោះប៉ះទៅនឹងខ្សែចម្លងដែលមានចរន្ត។ ការឆក់ដោយផ្ទាល់កើតឡើងដោយសារៈ

- ➢ មនុស្សគ្មានអ៊ីសូឡង់ជៀបទៅនឹងដីហើយប៉ះនឹងខ្សែហ្វាម្ខាងនៃខ្សែចម្លងដែលមានចរន្ត។

$I_h = V_{ph} / R_{total}$




រូបភាព៩  ការឆក់ផ្ទាល់ដោយសារតែដៃប៉ះនឹងខ្សែភ្លើង

- ➢ មនុស្សប៉ះទាំងខ្សែហ្វា និងខ្សែណឺតនៃខ្សែចម្លងដែលមានចរន្ត។

$I_h = V_{ph} / R_h$




រូបភាព១០ ការឆក់ដោយសារតែដៃប៉ះទាំងខ្សែហ្វា និងខ្សែណឺត

- ➢ មនុស្សប៉ះទៅនឹងខ្សែហ្វា២ នៅក្នុងប្រព័ន្ធបណ្តាញខ្សែទ្រីហ្វា (3-phase)។

$I_h = \sqrt{3} * V_{ph} / R_h$ ឬ $I_h = V_L / R_h$

$V_L$ ជាតង់ស្យុងលីង ( ហ្វា និងហ្វា )




រូបភាព១១ ការឆក់ដោយសារតែដៃប៉ះទាំងខ្សែហ្វា និងខ្សែហ្វា

**ខ. ការឆក់ដោយប្រយោល**

**ការឆក់ដោយប្រយោល** គឺជាការឆក់ចរន្តអគ្គិសនី ដែលមនុស្សគ្មានអ៊ីសូឡង់ជៀបទៅនឹងដី ហើយប៉ះទៅនឹងតួឧបករណ៍ដែលមានចរន្តឆ្លងតួ។




រូបភាព១២ មនុស្សប៉ះទៅនឹងតួឧបករណ៍ដែលមានចរន្តឆ្លងតួ

**ការឆក់ចរន្តអគ្គិសនីដោយផ្ទាល់**

**ការឆក់ដោយផ្ទាល់** គឺសំដៅទៅលើសកម្មភាពនៅពេលមនុស្សមកប៉ះនឹងអង្គធាតុចំលង ដែលកំពុងតែមានចរន្តឆ្លងកាត់។ ក្នុងរូបភាពខាងក្រោមនេះបានបង្ហាញពីការឆក់ដោយផ្ទាល់ដែលមនុស្សមកប៉ះនឹងខ្សែចម្លង៖




រូបភាព១៣ ការឆក់ដោយផ្ទាល់

## ការឆក់ចរន្តអគ្គិសនីដោយប្រយោល

**ការឆក់ដោយប្រយោល** គឺសំដៅទៅលើសកម្មភាពដែលមនុស្សមកប៉ះនឹងផ្នែកខាងក្រៅនៃអង្គធាតុចម្លង ដែលជាធម្មតាគ្មានចរន្តឆ្លងកាត់ ប៉ុន្តែវានឹងក្លាយជាអង្គធាតុចម្លងនៅពេលណាមួយ ដែលបណ្តាលមកពីមានកំហូចអ៊ីសូឡង់ ឬដោយមូលហេតុផ្សេងទៀត។ ក្នុងរូបភាពខាងក្រោមនេះបានបង្ហាញពីការឆក់ដោយប្រយោល ដែលមនុស្សបានមកប៉ះនឹងផ្នែកខាងក្រៅរបស់អង្គធាតុចម្លង៖




រូបភាព១៤ ការឆក់ដោយប្រយោល

## កម្រិតនៃការឆក់ចរន្តអគ្គិសនី

កម្រិតនៃការឆក់ចរន្តអគ្គិសនីមានច្រើនករណីដែលបណ្តាលឲ្យមានគ្រោះថ្នាក់ ហើយករណីនោះមានដូចជា៖

- ក្រោម 1mA ជាធម្មតា គឺយើងមិនអាចដឹងថា យើងត្រូវបានឆក់ឡើយ។
- ករណី ចរន្ត 1mA មានអារម្មណ៍ស្ពឹក ហើយភ្ញាក់។
- ករណី ចរន្ត 5mA មានអារម្មណ៍ឈឺចាប់ល្មមអាចទ្រាំបាន។
- ករណី ចរន្ត 10mA មានអារម្មណ៍ឈឺចាប់ល្មមទ្រាំមិនបាន។

- ករណី ចរន្ត 15mA ធ្វើឲ្យសាច់ដុំឡើងរឹង បាត់ការបញ្ជារបស់សាច់ដុំ និងធ្វើឲ្យពិបាកដល់ការដកដង្ហើម បើការឆក់នៅតែបន្តក្នុងរយៈពេលយូរនឹងធ្វើឲ្យមនុស្សស្លាប់បាន។
- ស្ត្រី ចរន្ត 6mA – 25mA គឺត្រូវបានឆក់ក្នុងកម្រិតមួយស្រាល តែបើក្នុងរយៈ ពេលយូរ អាចបង្កឲ្យមានគ្រោះថ្នាក់ដល់បាត់បង់ជីវិតដូចគ្នា។
- បុរស ចរន្ត 9mA – 30mA គឺត្រូវបានឆក់ក្នុងកម្រិតមួយស្រាល តែបើក្នុងរយៈពេលយូរ អាចបង្កឲ្យមានគ្រោះថ្នាក់ដល់បាត់បង់ជីវិតដូចគ្នា។
- ករណី ចរន្ត 50mA ទោះបីនៅក្នុងរយៈពេលខ្លីយ៉ាងណា ក៏ចរន្តអាចសម្លាប់ជីវិតមនុស្សបានដែរ។
- ករណី ចរន្ត 100mA ធ្វើឲ្យមនុស្សប្រកាច់ និងគ្រោះថ្នាក់ដល់ជីវិតភ្លាមៗ ម្យ៉ាងទៀត កម្រិតនេះ គឺមនុស្សពិបាកគេចផុតពីគ្រោះថ្នាក់ដោយការឆក់ចរន្តអគ្គិសនីណាស់។
- ករណី ចរន្តចាប់ពី 10000mA – 15000mA ( 10A – 15A ) វិញនោះ មនុស្សមានគ្រោះថ្នាក់ដល់ជីវិតភ្លាមៗ មិនអាចគេចផុតពីការឆក់ចរន្តអគ្គិសនីបានទេ។

ក្នុងចំណុចនេះ កម្រិតដែលមនុស្សអាចគេចផុតពីគ្រោះថ្នាក់ដោយការឆក់ចរន្តអគ្គិសនីបាន គឺជាទូទៅចរន្តតិចជាង 30mA ក្នុងរយៈពេលត្រឹមតែមួយវិនាទី។

យើងនឹងបង្ហាញនូវក្រាហ្វិក ដែលទាក់ទងទៅនឹងតំបន់( Zone )គ្រោះថ្នាក់ដូចជា តំបន់[ រយៈពេលលើចរន្ត ( time / current )] នៃចរន្ត AC ដែលហូរឆ្លងកាត់លើសរីរាង្គកាយមនុស្សដូចខាងក្រោម៖




រូបភាព១៥ ក្រាហ្វិកឥទ្ធិពលនៃការឆក់ចរន្តអគ្គិសនី

- AC-1 zone: មិនអាចដឹងថាមានចរន្តឆ្លងកាត់ ( Imperceptible )។
- AC-2 zone: អាចដឹងថាមានចរន្តឆ្លងកាត់ ( Perceptible )។
- AC-3 zone: ប៉ះហើយអាចដកវិញបាន មានអារម្មណ៍កន្ត្រាក់សាច់ដុំ ( Possibility of irreversible effects )។
- AC-4 zone: ប៉ះហើយមិនអាចដកវិញបាន ( Non possibility of irreversible effects )។
- AC-4.1 zone : ចាប់ពី5%ធ្វើឲ្យប៉ះពាល់ដល់ចង្វាក់បេះដូង( Probability of heart fibrillation )។
- AC-4.2 zone: ចាប់ពី 50% Probability of heart fibrillation ។
- AC-4.3 zone : លើស 50% Probability of heart fibrillation។
- ខ្សែបន្ទាត់ A : ចំណុចដែលមានគ្រោះថ្នាក់ ( Threshold to perception of current )។
- ខ្សែបន្ទាត់ B : ចំណុចដែលមានគ្រោះថ្នាក់ដល់សាច់ដុំ ( Threshold of muscular reactions )។
- ខ្សែបន្ទាត់ $C_1$ : Threshold of 0% : ប៉ះពាល់ដល់ចង្វាក់បេះដូង ( Probability of ventricular fibrillation )។
- ខ្សែបន្ទាត់ $C_2$ : Threshold of 5% : ប៉ះពាល់ដល់ចង្វាក់បេះដូង ( Probability of ventricular fibrillation )។
- ខ្សែបន្ទាត់ $C_3$ : Threshold of 50% : ប៉ះពាល់ដល់ចង្វាក់បេះដូង ( Probability of ventricular fibrillation )។

ចំណាំ

- 0.001A ដែលធ្វើឲ្យមនុស្សទទួលរងការឈឺស្រាល។
- 0.015A ដែលធ្វើឲ្យមនុស្សបាត់បង់ភាពម្ចាស់ការលើផ្នែកសាច់ដុំ។
- 0.05A ដែលធ្វើឲ្យស្បែក និងសាច់មនុស្សទទួលរងការដុតកម្ដៅ។
- 0.1A ដែលធ្វើឲ្យមនុស្សគាំងបេះដូងស្លាប់បាន។
- ចរន្តដែលលេចចេញត្រឹមតែ 0.3A អាចបង្កជាអគ្គីភ័យបាន។

**ការឆេះ ឬដុតបណ្ដាលមកពីអគ្គិសនី**

**ការឆេះ ឬដុតបណ្ដាលមកពីអគ្គិសនី** គឺជាការបញ្ចេញពន្លឺ ឬកាយចេញមកក្រៅនៃផ្កាភ្លើង ឬភ្លើង ដែលជាមូលហេតុធ្វើឲ្យរលាកស្បែកយ៉ាងធ្ងន់ធ្ងរ និងប៉ះពាល់ទៅដល់ត្រចៀកនូវការស្ដាប់ ឬស្ដាប់មិនសូវលឺ និងប៉ះពាល់ដល់ភ្នែកមើលមិនសូវឃើញច្បាស់ ក្រោយពេលដែលបានជួបហេតុការណ៍នេះ។

**ការបញ្ចេញពន្លឺដោយការបែកផ្កាភ្លើងនៃអគ្គិសនី** គឺជាលទ្ធផលដែលបានមកពីការឆ្លងអគ្គិសនីរវាងខ្សែណឺត និងខ្សែហ្វា ឬ ខ្សែហ្វា និងខ្សែហ្វា។

ការរលាកដោយការបែកផ្កាភ្លើងនៃអគ្គិសនីនេះចែកចេញជា ២ប្រភេទគឺ ការរលាកដោយផ្ទាល់ជាមួយចរន្តអគ្គិសនី និងការផ្ទុះកម្ទេចចេញពីការបែកផ្កាភ្លើង នៃកម្ដៅអគ្គិសនី។ ការបែកផ្កាភ្លើងនេះ កើតឡើងនៅពេលដែលមានអនុភាពខ្ពស់ និងអំពែធំ។ ទាំងនេះវាអាចកើតឡើងនៅពេលដែលមានតង់ស្យុងធំខុសគ្នាដែលឆ្លងកាត់អង្គធាតុចម្លងនៃចន្លោះទាំងពីរ។ ខណៈពេលដែលមានការបញ្ចេញកម្ដៅយ៉ាងខ្លាំង ដោយសារបរិមាណថាមពលនៃការបែកផ្កាភ្លើងអគ្គិសនីនៅសីតុណ្ហភាពខ្ពស់បំផុត 36000 °F។



រូបភាព១៦ ការបែកផ្កាភ្លើង

ដោយសារតែមូលហេតុនេះហើយ បានជាអ្នកបច្ចេកទេសមានការចាប់អារម្មណ៍លើការបែកផ្កាភ្លើងនៃអគ្គិសនីដូចជា៖

- មានគ្រោះថ្នាក់ពេលកំពុងអនុវត្តការងារកើតឡើងយ៉ាងច្រើន និងមនុស្សស្លាប់ជាបន្តបន្ទាប់នៅពេលធ្វើការចែកចាយបណ្តាញអគ្គិសនីខ្វះបច្ចេកទេស ដែលនាំឱ្យបែកផ្កាភ្លើងចេញពីប្រភពផ្សេងៗ។
- គ្រប់ឧស្សាហកម្មទាំងអស់ ជាទូទៅមិនទាន់មានឧបករណ៍សម្ភារប្រើប្រាស់តាមលក្ខណៈបច្ចេកទេសទេ។

**គ្រោះថ្នាក់ដោយការឆេះ ឬដុតពីអគ្គិសនី**

ផលវិបាកនៃការលោកផ្កាភ្លើងអគ្គិសនី បានជះឥទ្ធិពលដល់ជនរងគ្រោះបណ្តាលឲ្យមានការឈឺចាប់ខ្លាំង និងបង្កឲ្យមានស្លាកស្នាមពុំរែជារៀងរហូត។ អ្នកធ្វើការតែងតែជួបប្រទះការលំបាកក្នុងការតតំណរខ្សែភ្លើងតាមកន្លែងនានា និងមានការព្រួយបារម្ភពីការអូសបណ្តាញនៅតាមតំបន់ផ្សេងៗ ទាំងទីក្រុង និងជនបទត្រូវជួបឧបសគ្គជាច្រើន និងប៉ះពាល់ដល់អ្នកដែលរស់នៅទីនោះទៀតផង។

ការបែកផ្កាភ្លើងអគ្គិសនីជាលទ្ធផលដែលនាំឲ្យមានគ្រោះថ្នាក់ដូចជា៖

- ការរលាកស្បែកដោយការឆេះ ឬខ្លោច។
- ការគ្រោះថ្នាក់ដល់ប្រព័ន្ធដកដង្ហើម។
- ធ្វើឲ្យត្រចៀកទៅជាថ្លង់ ឬស្តាប់មិនលឺ។
- ការមុតស្បែកមកពីសំណល់អំបែងចាស់ៗដែលឆេះរួច។
- បើកម្ទេចផ្កាភ្លើងខ្ទាតចូលភ្នែក វាអាចបង្កឲ្យភ្នែកយើងរងរបួសអាចឈានទៅដល់ការមើលមិនឃើញ និងធ្វើឲ្យមុខ ឬដងខ្លួនត្រូវរបួសដោយសារផ្កាភ្លើងនោះ។



រូបភាព១៧ ការដុតកម្លោចនៃចរន្តអគ្គិសនី

ការជះឥទ្ធិពលនៃកម្តៅដែលបានមកពីការបែកផ្កាភ្លើង និងកម្រិតកម្តៅផ្សេងៗដូចជា៖

- ❖ ការរលាកស្បែកដោយកម្តៅដែលអាចព្យាបាលបាននៅសីតុណ្ហភាព 176 °F។
- ❖ សីតុណ្ហភាពដែលធ្វើឲ្យស្បែកមានការរងរបួស និងឈឺចាប់ខ្លាំង 205 °F។
- ❖ កម្តៅដែលធ្វើឲ្យឆេះសំលៀកបំពាក់ និងវត្ថុផ្សេងៗ គឺនៅសីតុណ្ហភាព 752-1472 °F។
- ❖ Surface Of Sun 9000 °F។
- ❖ កន្លែងដែលមានការបង្កើតបែកផ្កាភ្លើងចេញមក គឺនៅសីតុណ្ហភាព 35000 °F។



រូបភាព១៨ ការឆេះនៃចរន្តអគ្គិសនី

ករណីតង់ស្យុងខ្ពស់ និងមានផ្កាភ្លើងកើតមានឡើង ហើយយើងធ្វើការដោយខ្វះការត្រួតពិនិត្យឲ្យបានត្រឹមត្រូវ។

សីតុណ្ហភាពដែលធ្វើឲ្យយើងមានគ្រោះថ្នាក់ គឺមាន៣ប្រភេទ

- **ការប៉ះពាល់ស្បែកកម្រិតទី១**

ការរលាកដំបូងធ្វើឲ្យស្បែកនៅស្រទាប់លើ មានស្នាមក្រហមដែលយើងទទួលអារម្មណ៍ថា ឈឺចាប់។ ស្នាមក្រហមនេះហើយបានជាវាមានគ្រោះថ្នាក់ដល់ស្បែកបន្តិចបន្តួចតែប៉ុណ្ណោះ និងធ្វើឲ្យស្បែកយើងជាប់សន្លាក់ពណ៌ក្រហមនៅកន្លែងរលាកនោះ។




រូបភាព១៩ ការប៉ះពាល់ទី១

### ➢ ការប៉ះពាល់ស្បែកកម្រិតទី២




រូបភាព២០ ការប៉ះពាល់ទី២

ក្នុងការរលាកដល់ស្បែកក្នុងកម្រិតទី២ វាជាប់ទាក់ទងនឹងស្បែកស្រទាប់កម្រិតទី១ និងកម្រិតទី២ ដែលធ្វើឲ្យស្បែកយើងមានលក្ខណៈហើម ហើយឡើងពងជាច្រើននៅលើស្បែក មនុស្សដែលរងគ្រោះដោយការរលាកក្នុងកម្រិតទី២ ដែលបណ្ដាលឲ្យមានការឈឺចាប់ និងការប្រឈមមុខឆ្លងមេរោគនៃជម្ងឺផ្សេងៗតាមរយៈស្បែកដែលមានឡើងពង។

### ➢ ការប៉ះពាល់ស្បែកកម្រិតទី៣

ក្នុងការរលាកក្នុងកម្រិតទី៣ វាបណ្ដាលឲ្យស្បែកយើងកកឈាមក្នុងសសៃឈាមខាងក្នុងនៃស្រទាប់ស្បែក ហើយស្រទាប់ស្បែកទាំង៣នេះ មានឥទ្ធិពលយ៉ាងខ្លាំងដែលធ្វើឲ្យស្បែកយើងឡើងខ្លោចក្រហមឆ្អាល។




រូបភាព២១ ការប៉ះពាល់ទី៣

ការគ្រោះថ្នាក់ដល់ស្បែកនេះ វាកើតឡើងដោយសារកម្ដៅបានមកពីបែកផ្ទាភ្លើងនៃចរន្តអគ្គិសនី ដូចនេះ យើងត្រូវប្រុងប្រយ័ត្ន ហើយពេលមានហេតុការណ៍នេះកើតឡើងអ្នកត្រូវធ្វើដូចជា៖

- ត្រូវរកមូលហេតុនៃការបែកផ្ទាភ្លើង។

- បើមានហេតុការណ៍នេះកើតមានឡើងអ្នកត្រូវស្ថិតនៅឲ្យឆ្ងាយពីកន្លែងបែកផ្កាភ្លើងនៃចរន្តអគ្គិសនីនោះ។
- ពេលអ្នកឃើញមានការបែកផ្កាភ្លើងនៃចរន្តអគ្គិសនីនៅកន្លែងណាមួយ អ្នកត្រូវរាយការណ៍បន្ទាន់។

**វិធីការពារដោយការឆេះមកពីបែកផ្កាភ្លើងអគ្គិសនី**

មនុស្សប្រហែល2000នាក់ ត្រូវគ្រោះថ្នាក់ជារៀងរាល់ឆ្នាំដោយសារការលោកជាមួយផ្កាភ្លើងអគ្គិសនី។ គេបានស្រាវជ្រាវនៃការលោកនេះថាគ្រោះថ្នាក់នៃចរន្តអគ្គិសនី គឺមកពីការបញ្ចេញពន្លឺពីការបែកផ្កាភ្លើងនៃចរន្តអគ្គិសនី ហើយមនុស្សប្រហែល 350នាក់ ត្រូវបានស្លាប់នៅនឹងកន្លែងធ្វើការជាមួយចរន្តអគ្គិសនី។ នៅក្នុងឆ្នាំ 2009 ប្រហែល 50% ត្រូវបានស្លាប់ដែលទាក់ទងទៅនឹងការបញ្ចេញពន្លឺពីការបែកផ្កាភ្លើងនៃចរន្តអគ្គិសនី។

តើយើងត្រូវធ្វើយ៉ាងណា ដើម្បីការពារខ្លួនឲ្យរួចផុតពីការបែកផ្កាភ្លើងនៃចរន្តអគ្គិសនីដែលប្រកបដោយសុវត្ថិភាព?

បើមានហេតុការណ៍នេះកើតមានឡើង យើងត្រូវការពារខ្លួន និងអនុវត្តដូចខាងក្រោម៖

- ត្រូវការពារខ្លួនដោយរត់គេចចេញឲ្យឆ្ងាយផុតពីការបញ្ចេញពន្លឺនៃការបែកផ្កាភ្លើងអគ្គិសនីនោះ ហើយយើងត្រូវកាត់ផ្តាច់ប្រភពចរន្តអគ្គិសនីនោះចេញពីសៀគ្វីសិន មុនចាប់ផ្តើមធ្វើការងារ។
- ត្រូវត្រួតពិនិត្យមើល និងបិទផ្លាកសញ្ញាគ្រោះថ្នាក់ ហាមទៅប៉ះពាល់ ឬធ្វើការនៅកន្លែងនោះ និងត្រូវបង្កើតផ្លាកសញ្ញាគ្រោះថ្នាក់នៅកន្លែងដែលមានការបែកផ្កាភ្លើង។
- មិនត្រូវប៉ះពាល់បរិក្ខារអគ្គិសនីនៅកន្លែងធ្វើការដែលយើងមិនស្គាល់ពីមុខងារ និងតួនាទីរបស់បរិក្ខារនោះ ហើយបើយើងចង់ប្រើប្រាស់វា យើងត្រូវស្តាប់ការណែនាំ អំពីការប្រើប្រាស់បរិក្ខារអគ្គិសនីទាំងនោះដោយអ្នកគ្រប់គ្រងនៅកន្លែងនោះផ្ទាល់។
- ត្រូវដឹង និងប្រកាន់ភ្ជាប់នូវគោលការណ៍របស់ក្រុមហ៊ុនពេលកំពុងធ្វើការងារ និងសម្រាកពីការងារ។
- ពេលធ្វើការជាមួយគ្រឿងបរិក្ខារអគ្គិសនី យើងត្រូវមានស្មារតីប្រុងប្រយ័ត្នឲ្យបានខ្ពស់មុនចាប់ផ្តើមធ្វើការងារជាមួយវា។
- ត្រូវប្រុងប្រយ័ត្ននៅពេលធ្វើការងារជាមួយចរន្តអគ្គិសនី ទោះបីកន្លែងស្នាក់នៅ ឬតំបន់ផ្សេងៗ។
- ពេលប្រើប្រាស់ឧបករណ៍សម្ភារ ( យកពីកន្លែងណា ត្រូវទុកដាក់កន្លែងនោះវិញ )។
- ត្រូវស្លៀកសំលៀកបំពាក់ជាឯកសណ្ឋានសុវត្ថិភាព។
- ត្រូវចេះប្រើប្រាស់បំពង់ពន្លត់អគ្គីភ័យទៅតាមប្រភេទនីមួយៗឲ្យបានត្រឹមត្រូវ។
- ត្រូវចេះប្រើប្រាស់ទុយោបាញ់ទឹកពន្លត់អគ្គីភ័យ។

- **ឯកសណ្ឋានសុវត្ថិភាពការពារបែកផ្កាភ្លើង និងអណ្តាតភ្លើង**



រូបភាព២២ ឯកសណ្ឋានការពារបែកផ្កាភ្លើង និងអណ្តាតភ្លើង

- **ឯកសណ្ឋានសុវត្ថិភាពការពារឆក់ចរន្តអគ្គិសនី**




រូបភាព២៣ ឯកសណ្ឋានសុវត្ថិភាពការពារឆក់ចរន្តអគ្គិសនី

- **មួកសុវត្ថិភាព**

មួកការពារសុវត្ថិភាពក្នុងការដ្ឋានចាំបាច់ត្រូវតែមានដោយខានមិនបាន គឺដើម្បីការពារនៅពេលឡើងបង្គោល និងការធ្លាក់សម្ភារបម្រុង ឬវត្ថុផ្សេងៗដើម្បីការពារគ្រោះថ្នាក់ដោយប្រការណាមួយ។

- **វ៉ែនតា**

វ៉ែនតាសុវត្ថិភាព គឺជាមធ្យោបាយមួយដោយមានសុវត្ថិភាពខ្ពស់ ដើម្បីការពារភ្នែករបស់អ្នក វាទប់ទល់នឹងគ្រោះថ្នាក់ដែលបណ្តាលមកពីការហើរ ឬខ្ទាតកម្ទេចតូចៗ ឬកាំរស្មីដែលមានគ្រោះថ្នាក់មកប៉ះនឹងភ្នែករបស់យើង។ ការពាក់វ៉ែនតាដែលប្រឆាំងកាំរស្មីស្វាយអ៊ុលត្រា គឺជាកាតព្វកិច្ចមួយនៅពេលចូលប្រលូក

ការងារលើបណ្តាញខ្សែភ្លើងដែលមានចរន្ត ឬនៅជិតគ្រឿងបរិក្ខារដែលមានចរន្ត ឬករណីគ្រោះថ្នាក់ដោយចំណាលផ្កាភ្លើង ឬធ្នូចរន្តអគ្គិសនី។ វ៉ែនតាដែលខូច យើងមិនត្រូវយកវាមកប្រើប្រាស់ទៀតទេ យើងត្រូវយកវ៉ែនតាដែលល្អមកប្រើប្រាស់ជំនួសវិញ ជៀសវាងគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើង។

- **ស្បែកជើងសុវត្ថិភាព**

ស្បែកជើងសុវត្ថិភាព គឺជាមធ្យោបាយការពារជើងរបស់អ្នក វាទប់ទល់នឹងការប៉ះទង្គិច ឬការធ្លាក់ចុះវត្ថុដែលយើងកាន់មិនបានល្អ ជាពិសេសការពារពីការឆក់នៃការលេចធ្លាយចរន្តអគ្គិសនី។ ស្បែកជើងសុវត្ថិភាពបានផលិតឡើងជាមួយគ្រឿងការពារនៅខាងចុងនៃស្បែកជើង ធ្វើឡើងដោយដែកថែបដែលមានរេស៊ីស្តង់ខ្ពស់ និងមិនច្រេះចាប់។ ត្រូវពាក់វាគ្រប់ពេលទាំងអស់ នៅក្នុងការដ្ឋាន ឬនៅពេលមានការជួសជុលគ្រឿងបរិក្ខារអគ្គិសនី។

- **ស្រោមដៃសុវត្ថិភាព**

ស្រោមដៃសុវត្ថិភាពមាន២ប្រភេទ គឺប្រភេទធ្វើអំពីស្បែក និងប្រភេទធ្វើអំពីកៅស៊ូ ដែលមិនចម្លងចរន្តអគ្គិសនី។ ស្រោមដៃស្បែកនិងកៅស៊ូ ការពារដៃនៅពេលយើងធ្វើការដំឡើង ឬជួសជុលជាមួយគ្រឿងមេកានិក និងអគ្គិសនី។

- **ខ្សែក្រវ៉ាត់សុវត្ថិភាព**

ការប្រើខ្សែក្រវ៉ាត់សុវត្ថិភាព គឺជាការប្រសើរណាស់សម្រាប់យើងជាអ្នកបច្ចេកទេសអគ្គិសនីរាល់ពេលយើងបំពេញការងារនៅលើទីខ្ពស់នោះ ប្រសិនបើមានការឆក់ចរន្តអគ្គិសនីកើតឡើង ឬការរអិលជើងធ្លាក់ពីទីខ្ពស់។ ការប្រើប្រាស់ខ្សែក្រវ៉ាត់ ត្រូវតែត្រួតពិនិត្យមើលឱ្យបានប្រាកដ ដើម្បីឲ្យដឹងថា ចំណុចនៃទំពក់ខ្សែក្រវ៉ាត់សុវត្ថិភាពដែលបានថ្លក់ ឬព្យួរនោះ វាមានសុវត្ថិភាព ឬគ្មានសុវត្ថិភាព។ អ្នកពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព ត្រូវរក្សាជំហរត្រង់ទៅលើ ហើយត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព រាល់ពេលបំពេញការងារនៅទីខ្ពស់ចាប់ពី២ម៉ែត្រឡើងទៅ។

- **ប្រើកាសដើម្បីការពារត្រចៀក**

ការប្រើកាសដើម្បីការពារត្រចៀក គឺជាការល្អប្រសើរណាស់ចំពោះការងារប្រចាំថ្ងៃ ដែលតម្រូវឲ្យពាក់កាសទៅតាមផ្នែកការងារនីមួយៗ ព្រោះកន្លែងការងារខ្លះ មានសម្លេងខ្លាំង ដូច្នេះហើយ ទើបឲ្យមានការពាក់កាសដើម្បីការពារត្រចៀកកុំឲ្យថ្លង់ស្តាប់អីមិនលឺក្រោយពីធ្វើការងាររួច។

- **ម៉ាស់**

ការប្រើម៉ាស់ដើម្បីការពារច្រមុះ គឺជាការល្អប្រសើរណាស់ចំពោះការងារប្រចាំថ្ងៃ ដែលតម្រូវឲ្យពាក់ម៉ាស់ទៅតាមផ្នែកការងារនីមួយៗ ព្រោះកន្លែងការងារខ្លះមានធូលីច្រើន ឬមានក្លិនមិនល្អ ដូច្នេះហើយទើបឲ្យមានការពាក់ម៉ាស់ដើម្បីការពារច្រមុះ កុំឲ្យមានការប៉ះពាល់ដល់សុខភាពតាមផ្លូវដង្ហើមក្រោយពីធ្វើការងាររួច។

❖ **ផ្លាកសញ្ញាសុវត្ថិភាព**

ផ្លាកសញ្ញាសុវត្ថិភាពមាន៣ប្រភេទគឺ ផ្លាកសញ្ញាហាមឃាត់ ផ្លាកសញ្ញាផ្តល់ព័ត៌មាន និងផ្លាកសញ្ញាតំបន់ធ្វើការ។

-តំបន់ហាមឃាត់ ត្រូវខណ្ឌដោយរនាំងរបងជញ្ជាំងចម្រឹងដែក មានក្រវ៉ាត់ពណ៌ក្រហម ហើយចាក់សោឲ្យបានត្រឹមត្រូវ និងដាក់ផ្លាកសញ្ញា ( ប្រុងប្រយ័ត្នគ្រោះថ្នាក់ដល់ស្លាប់ ) ឬ( តំបន់ហាមឃាត់ )។




រូបភាព២៤ ផ្លាកសញ្ញាហាមឃាត់

-ផ្លាកសញ្ញាផ្តល់ព័ត៌មាន ត្រូវដាក់ទៅតាមកន្លែងដែលចាំបាច់ត្រូវធ្វើការជាមួយ




រូបភាព២៥ ផ្លាកសញ្ញាផ្តល់ព័ត៌មាន

-ផ្លាកសញ្ញាតំបន់ធ្វើការងារ ត្រូវមានផ្លាកសញ្ញាពណ៌បៃតង ( តំបន់អនុញ្ញាតឲ្យធ្វើការ ) ហើយត្រូវមានផ្លាកសញ្ញាខ្លះដើម្បីដាស់តឿនបុគ្គលិក និងអ្នកធ្វើការឲ្យប្រុងប្រយ័ត្ន ជាពិសេស គឺធ្វើឲ្យអ្នកធ្វើការទាំងអស់គោរពតាមផ្លាកសញ្ញាដែលដាក់តាមផ្នែកនីមួយៗ។




រូបភាព២៦ ផ្លាកសញ្ញាតំបន់ធ្វើការងារ

## ប្រភេទរេស៊ីស្តង់ខ្លួនមនុស្ស

រេស៊ីស្តង់របស់ខ្លួនមនុស្សម្នាក់ៗ គឺមិនមានភាពច្បាស់លាស់នោះទេ។ វាអាស្រ័យទៅលើមនុស្សម្នាក់ៗ និងទៅតាមពេលវេលាផងដែរ។ ប្រសិនបើខ្លួនមនុស្សជាត់ ឬស្គម គឺរបៀបកំណត់តម្លៃ រេស៊ីស្តង់ក្នុងខ្លួនមនុស្ស ត្រូវតែមាន Digital LCR Meter ដើម្បីវាស់ករេស៊ីស្តង់ ហើយការវាស់នោះគឺត្រូវតែវាស់ចាប់ផ្តើមនៅ ២ចំណុច គឺចំណុចចុងម្រាមដៃម្ខាង( ឆ្វេង ) ទៅចុងម្រាមដៃម្ខាង( ស្តាំ ) ទៀត។ ភាពខុសគ្នានៃរាងកាយមនុស្ស បានផ្តល់តម្លៃរេស៊ីស្តង់ខុសគ្នា ហើយសូម្បីតែរេស៊ីស្តង់ក្នុងខ្លួនមនុស្ស ម្នាក់ៗក៏មានតម្លៃប្រែប្រួលដែរ។ ការរៀបចំឲ្យបានត្រឹមត្រូវ មនុស្សគួរតែកំណត់ពីការប្រែប្រួលនៃវត្ថុរាវឲ្យបានល្អរាល់ម៉ោងមុនពេលធ្វើតេស្ត។




រូបភាព២៧ Digital LCR Meter



រូបភាព២៨ Red Probe & Black Probe

ក្នុងនោះដែរ មានការបង្ហាញមួយថា ជាតិទឹកគឺជាកត្តាមួយដែលមានឥទ្ធិពលលើរេស៊ីស្តង់របស់រាងកាយមនុស្ស។ ដូចនេះ រេស៊ីស្តង់មនុស្សមានការផ្លាស់ប្តូរផងដែរ នៅពេលដែលពួកគេប៉ះនឹងស្បែកដូចជា ដៃប៉ះដៃ ជើងប៉ះជើង ដៃប៉ះកដៃជាដើម។ ម្យ៉ាងទៀត នៅពេលមនុស្សមានការបែកញើស ហើយនៅក្នុងញើសមានសារធាតុខនិចជាច្រើន ដែលវាដើរតួជាកុងដង់សាទ័រអគ្គិសនីដ៏ល្អមួយនៅក្នុងវត្ថុរាវ។ ដូចនេះ ឈាមក៏ដូចជាកុងដង់សាទ័រដ៏ធំមួយដែរ។ ការប៉ះខ្សែភ្លើងដោយដៃ ដែលមានសំណើម ឬបែកញើស ឬប៉ះនឹងមុខរបួស វានិងធ្វើឲ្យរេស៊ីស្តង់មនុស្សថយចុះខ្សោយ។ ដូច្នេះ មនុស្សមុននឹងធ្វើការប៉ះពាល់ទៅលើអ្វីមួយដែលមានចរន្តអគ្គិសនីត្រូវប្រាកដថា ស្បែករបស់យើងស្ងួត មិនមានសំណើម។

ការវាស់រេស៊ីស្តង់ក្នុងខ្លួនមនុស្សដោយឧបករណ៍វង្វាស់ Digital LCR Meter បានបង្ហាញថា មនុស្សម្នាក់ៗមានរេស៊ីស្តង់ប្រហែល 1.000.000Ω ដែលស្ថិតនៅចន្លោះដៃទាំងពីរ ( វាស់រវាងម្រាមដៃ ទាំងសងខាង )។ ការពិសោធន៍ដោយឧបករណ៍ LCR Meter បានបង្ហាញថា មានរេស៊ីស្តង់ចុះតិចនៅពេលគេច្របាច់ Red Probe និង Black Probe ឲ្យណែនហើយរេស៊ីស្តង់កើនឡើងនៅពេលដែលគេកាន់ Red Probe និង Black Probe ស្រាលៗ។

មនុស្សម្នាក់បាននិយាយថា៖ ការអង្គុយលេងវាយ Typing នៅមុខ Computer ធ្វើឲ្យដៃស្ងួត និងស្អាត បន្ទាប់មកគេធ្វើការវាស់ដោយឧបករណ៍Digital LCR Meter បានទទួលលទ្ធផលឃើញថា រេស៊ីស្តង់ខ្លួនមនុស្សម្នាក់នោះកើនឡើងខ្ពស់។ ម្យ៉ាងទៀត គេបានធ្វើការពិសោធន៍ទៅលើមនុស្សម្នាក់ទៀត ដែលគេធ្វើការនៅកន្លែងក្តៅ ហើយស្មោគពោគធ្វើឲ្យបែកញើស ពេលគេធ្វើការវាស់ដោយឧបករណ៍ Red Probe និងBlack Probe ដូចគ្នា បានទទួលលទ្ធផលឃើញថា រេស៊ីស្តង់រវាងដៃទាំងសងខាងរបស់គេបានធ្លាក់ចុះ ការធ្លាក់ចុះនេះអាចបង្កឲ្យមានគ្រោះថ្នាក់ខ្លាំងដោយសារការឆក់ ដោយចរន្តអគ្គិសនី ប៉ុន្តែតើចរន្តអគ្គិសនីប៉ុន្មានអំពែដែលបង្កឲ្យឆក់ខ្លាំងចម្លើយគឺអាស្រ័យទៅលើកត្តាជាក់ស្តែង។ សារជាតុគីមី នៃរាងកាយរបស់មនុស្សម្នាក់ៗមានសារៈសំខាន់

ណាស់ ក្នុងការប្រឆាំងទៅនឹងឥទ្ធិពលផ្សេងៗ ដូច្នេះហើយ មនុស្សមួយចំនួនមានភាពរស់ផ្ទាល់ខ្លួន ដោយមានប្រតិកម្មតប ទៅនឹងការឆក់ចរន្តអគ្គិសនី ដូចជាការកន្ត្រាក់សាច់ដុំដោយមិនដឹងខ្លួន នៅពេលមានការឆក់ដោយចរន្តអគ្គិសនី។ ហើយមនុស្សមួយចំនួនទៀតគ្មានអារម្មណ៍ដឹងថាឆក់ដោយផ្កាភ្លើង (ពេលកំពុងផ្ទេរបន្ទុក)។

សូមចងចាំថារូបរាងខាងក្រៅរបស់មនុស្សម្នាក់ៗមានភាពប្រហាក់ប្រហែលគ្នា ប៉ុន្តែមនុស្សមានសារជាតុគីមីក្នុងខ្លួនខុសៗគ្នា ដែលបង្កឲ្យមានប្រតិកម្មខុសៗគ្នា។ មានការណែនាំថា ចរន្តអគ្គិសនីដែលរត់ឆ្លងកាត់ដើមទ្រូងត្រឹមតែ17mA ( AC ) គឺគ្រប់គ្រាន់ដែលអាចធ្វើឲ្យស្ទះសរសៃឈាមនៅក្នុងខ្លួនដោយលក្ខខណ្ឌជាក់ស្តែង ហើយចំពោះទិន្នន័យនេះ គឺបានមកពីការសាកល្បងទៅលើសត្វពាហនៈតែប៉ុណ្ណោះ ជាក់ស្តែងគឺមិនមែនអនុវត្តទៅលើមនុស្សនោះទេ។ ដូច្នេះវាគ្រាន់តែជាទិន្នន័យដែលមិនច្បាស់លាស់នៅឡើយទេ។

ការស្រាវជ្រាវបានបង្ហាញពីតម្លៃប្រហាក់ប្រហែល ដែលបានកំណត់លើរេស៊ីស្តង់ផ្នែកខាងក្រៅរបស់មនុស្សដែលភ្ជាប់ទៅនឹងចំណុចមួយៗតាមលក្ខខណ្ឌផ្សេងៗគ្នាដូចខាងក្រោម៖

- ប៉ះខ្សែភ្លើងដោយម្រាមដៃ : 40.000Ω to 1.000.000Ω ស្ងួត 4.000 to 15.000Ω សើម។
- កាន់ខ្សែភ្លើងដោយម្រាមដៃ : 15.000Ω to 50.000Ω ស្ងួត 3.000Ω to 5.000Ω សើម។
- កាន់ដង្កាប់ដែកគ្មានអ៊ីសូឡង់ : 5.000Ω to 10.000Ω ស្ងួត 1.000Ω to 3.000Ω សើម។
- កាន់ខ្សែភ្លើងដោយប្រអប់ដៃ : 3.000Ω to 8.000Ω ស្ងួត 1.000Ω to 2.000Ω សើម។
- កាន់បំពង់ដែកប្រវែង 1.5 inch ដោយដៃម្ខាង : 1.000Ω to 3.000Ω ស្ងួត 500Ω to 1.500Ω សើម។
- កាន់បំពង់ដែកប្រវែង 1.5 inch ដោយដៃសងខាង : 500Ω to 1.500Ω ស្ងួត 250Ω to 750Ω សើម។
- ដាក់ដៃក្នុងវត្ថុរាវដែលចម្លង : 200Ω to 500Ω។
- ដាក់ជើងក្នុងវត្ថុរាវដែលចម្លង : 100Ω to 300Ω។

ក្នុងឧស្សាហកម្មតង់ស្យុងត្រឹម 30V សមល្មមដែលអាចបង្កគ្រោះថ្នាក់បាន។ ហើយមនុស្សគួរតែប្រុងប្រយ័ត្នចំពោះតង់ស្យុងដែលលើសពី 30Vទៅ គឺអាចបង្កឲ្យមានគ្រោះថ្នាក់។ យើងមិនត្រូវទុកចិត្តលើ រេស៊ីស្តង់ធម្មតារបស់រាងកាយ ថាអាចការពារជាមួយចរន្តអគ្គិសនីបាននោះទេ។ ជាប្រការល្អសម្រាប់មនុស្សគួររក្សាដៃឲ្យស្ងួត ហើយមិនត្រូវពាក់លោហៈធាតុទាំងឡាយដូចជា៖ ចិញ្ចៀន ក្រវិល កងដៃ ខ្សែក នាឡិកាដៃ...នៅពេលធ្វើការងារជាមួយចរន្តអគ្គិសនី។ ទោះបីជាធ្វើការងារជាមួយតង់ស្យុងទាបក៏ដោយលោហៈ ឬគ្រឿងអលង្ការទាំងនោះនៅតែអាចបង្កគ្រោះថ្នាក់ដដែល ប្រសិនបើមានការភ្ជាប់ពីចំណុចនោះ ទៅនឹងចរន្តអគ្គិសនី។ ហើយគ្រោះថ្នាក់នេះ អាចបណ្តាលឲ្យមានរបួសរលាក ឬរលួយស្បែក នៅកន្លែងដែលពាក់គ្រឿងអលង្ការជាលោហៈធាតុនោះ។ ជាក់ស្តែង មានមនុស្សម្នាក់ធ្វើឡាននៅរដូវក្តៅ គាត់ស្លៀកសំលៀកបំពាក់ខ្លីៗ នៅពេលនោះជើងរបស់គាត់បានប៉ះនឹងតួចយន្ត ហើយគាត់យកដៃមួលខ្ចៅអាគុយខាងប៉ូលបូក (12V) ភ្លាមៗនោះ គាត់មានអារម្មណ៍

ថា ដូចជាធក់តិចៗនៅកន្លែងដែលជើងគាត់ប៉ះនឹងតួរថយន្ត ហើយនៅពេល បញ្ចេះឡាន បែរជាធក់ដៃគាត់វិញ (លទ្ធផលនៃលំហូរអេឡិចត្រុងឆ្លងកាត់ ឧបករណ៍លោហៈដែលធ្វើឲ្យមានបែកផ្កាភ្លើង)។ ដូចនេះយើងឃើញថាការប៉ះលោហៈនឹងស្បែកមានញើស គឺអាចបង្កឲ្យមានការធក់ ទោះបីជាមានផលសងប៉ូតង់ស្យែលត្រឹមតែ 12V ក៏ដោយ៕

# សំណួរពិភាក្សា

1. ការឆក់ចរន្តអគ្គិសនីគឺជាអ្វី?
2. ហេតុអ្វីបានជាចរន្តអគ្គិសនីមានគ្រោះថ្នាក់?
3. ការឆក់ដោយចរន្តអគ្គិសនីមានប៉ុន្មានប្រភេទ? អ្វីខ្លះ?
4. ដូចម្តេចដែលហៅថា ការឆក់ដោយផ្ទាល់?
5. ដូចម្តេចដែលហៅថា ការឆក់ដោយប្រយោល?
6. ចូរពន្យល់នៃការឆក់ចរន្តអគ្គិសនីដូចជា៖ 0.001A , 0.015A , 0.05A , 0.1A ?
7. តើចរន្តលេចធ្លាយចេញមកក្រៅប៉ុន្មាន អំពែ ( A ) ដែលបង្កហានិភ័យបាន?
8. តើការឆេះ ឬដុតបណ្តាលមកពីអគ្គិសនីគឺជាអ្វី?
9. តើការបែកផ្កាភ្លើងនៃអគ្គិសនីកើតឡើងដោយសារអ្វី?
10. តើលទ្ធផលនៃការបែកផ្កាភ្លើងអគ្គិសនីមានគ្រោះថ្នាក់អ្វីខ្លះ?
11. តើឯកសណ្ឋានសុវត្ថិភាពមានអ្វីខ្លះ? ចូរពន្យល់នីមួយៗ?
12. ចូរពន្យល់ពីវិធីសាស្ត្រសង្គ្រោះមនុស្សឲ្យផុតពីគ្រោះថ្នាក់ដោយការឆក់ចរន្តអគ្គិសនី?

## ការកំណត់ពីប្រភេទគ្រោះថ្នាក់

## សេចក្តីផ្តើម

នៅក្នុងការងារអគ្គិសនី នៅពេលបច្ចុប្បន្នតែងតែជួបប្រទះបញ្ហាជាច្រើន ដែលយើងជាអ្នកបច្ចេកទេសត្រូវតែដឹង និងត្រូវការពារកុំឲ្យបញ្ហាទាំងនោះកើតមានឡើង។ ដូចជាបញ្ហា ធក់ដោយចរន្តអគ្គិសនី ផ្ទុះសេខ្សែភ្លើង ខូចគ្រឿងបរិក្ខារអគ្គិសនី ជាពិសេសមានអគ្គិភ័យកើតឡើងដែលបណ្តាលឲ្យ មានការឆាប់ឆេះផ្ទះសំបែង បាត់បង់ទ្រព្យសម្បត្តិ អាយុជីវិតមនុស្ស សត្វ និងធ្វើឲ្យមានការប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារជនរងគ្រោះថែមទៀតផង។ ក្នុងនោះផងដែរ ក៏យើងត្រូវតែយល់ដឹងអំពីវិធីការពារខ្លះៗ និងវិធីសាស្ត្របង្ក្រាប ឬពន្លត់អគ្គិភ័យ ដែលកើតចេញពីការឆាប់ឆេះនៅវត្ថុផ្សេងៗដែលនៅជុំវិញខ្លួនយើង។

## ការប្រើប្រាស់ខ្សែភ្លើង

ការប្រើប្រាស់ខ្សែភ្លើងមិនបានត្រឹមត្រូវទៅតាមប្រភេទបន្ទុកនីមួយៗ គឺផ្តល់មកវិញនូវគុណវិបត្តិ និងហានិភ័យជាច្រើនដែលបានរៀបរាប់ដូចខាងលើ ហើយការជ្រើសរើសប្រភេទមុខកាត់ខ្សែទៅតាមប្រភេទបន្ទុកប្រើប្រាស់គឺអាស្រ័យទៅលើ ចរន្តអនុញ្ញាត ( $I_z$ ) ដែលជាចរន្តបម្រុងទៅលើការបាត់បង់លើកត្តាសីតុណ្ហភាព និងកត្តានៃស្ថានភាពទីតាំងការដាក់ខ្សែ។ ហើយការដាក់ខ្សែ ក៏ត្រូវបានជ្រើសរើសមុខកាត់ខ្សែទៅតាមប្រភេទបន្ទុកនៃគ្រឿងទទួលនីមួយៗ។ ខាងក្រោម នេះគឺជាតារាងជ្រើសរើសមុខកាត់ខ្សែតាមប្រភេទបន្ទុកប្រើប្រាស់៖

**Cable Size And Load Amp,Breaker Size**

| Cable Size | Maximum Ampere | Breaker Size |
|---|---|---|
| 1.5 mm | 14 A | 10 A |
| 2.5 mm | 22 A | 20 A |
| 4 mm | 33 A | 32 A |
| 6 mm | 42 A | 32 A |
| 10 mm | 58 A | 50 A |
| 16 mm | 77 A | 63 A |
| 25 mm | 102 A | 80 A |
| 35 mm | 125 A | 100 A |
| 50 mm | 150 A | 125 A |
| 70 mm | 192 A | 160 A |
| 95 mm | 230 A | 200 A |
| 120 mm | 267 A | 250 A |
| 150 mm | 290 A | 250 A |
| 185 mm | 348 A | 345 A |
| 240 mm | 409 A | 400 A |

រូបភាព២៩ តារាងមុខកាត់ខ្សែ

ប្រភេទខ្សែចម្លងមានច្រើនប្រភេទ និងច្រើនក្រុមហ៊ុនដែលបានប្រគួតប្រជែងលើទីផ្សារក្នុងពេលបច្ចុប្បន្ន។ រីឯអ្នកបច្ចេកទេសគួរតែគិតលើគុណភាពនៃខ្សែចម្លងដែលជាកត្តាសំខាន់បំផុត ក្នុងការដំឡើងបណ្តាញអគ្គិសនីក្នុងសំណង់អាគារដូចជា រោងចក្រ ផ្ទះល្វែង អាគារស្នាក់នៅ ជាពិសេសក្នុងវិស័យឧស្សាហកម្ម

សុខាភិបាល ពាណិជ្ជកម្ម ទូរគមនាគមន៍ និងវិស័យផ្សេងៗជាច្រើនទៀត។ ដូច្នេះខាងក្រោមនេះ គឺជាប្រភេទខ្សែភ្លើងខ្លះៗត្រូវបានបង្ហាញ៖



រូបភាព៣០ ប្រភេទខ្សែភ្លើង

ការអធិប្បាយខាងលើ គឺពិតជាត្រឹមត្រូវណាស់ ប៉ុន្តែវាមិនបានធានាសុវត្ថិភាពដល់ការរស់នៅប្រចាំថ្ងៃ ១០០% ឡើយទេ។ ពីព្រោះនៅតែមានហានិភ័យកើតឡើងដោយសារការតែផ្ទុះសេខ្សែភ្លើង ឬឆេះខ្សែភ្លើង ដែលជាខ្សែចម្លងចរន្តអគ្គិសនី ហើយជាកត្តាដែលបណ្តាលឲ្យឆេះខ្សែចម្លងចរន្តអគ្គិសនីមានដូចជា៖

-ជ្រើសរើសឧបករណ៍ការពារមិនបានត្រឹមត្រូវ។

-គណនាបន្ទុកប្រើប្រាស់មិនបានត្រឹមត្រូវ។

-គណនាមុខកាត់ខ្សែមិនត្រូវជាមួយបន្ទុកប្រើប្រាស់។

-ឧបករណ៍សម្ភារមិនមានគុណភាពល្អ ហើយដាក់ទីតាំងមិនបានត្រឹមត្រូវ។

-ការតំហែទាំមិនបានត្រឹមត្រូវ។

-ដំឡើងបណ្តាញអគ្គិសនីខុសបច្ចេកទេស។ល។

## ឧបករណ៍ការពារ

ការជ្រើសរើសឧបករណ៍ការពារ គឺមានសារៈសំខាន់ណាស់ដល់អ្នកប្រើប្រាស់ថាមពលអគ្គិសនី ព្រោះថាមពលអគ្គិសនីមានសារៈប្រយោជន៍ដល់ការរស់នៅប្រចាំថ្ងៃ របស់ប្រជាជនគ្រប់ៗរូបទូទាំងពិភពលោកយើងនេះ។ ទន្ទឹមនឹងនេះគ្រោះថ្នាក់ដែលបណ្តាលមកពី ចរន្តអគ្គិសនីក៏អាចកើតមានគ្រប់ពេលវេលាផងដែរ ប្រសិនបើយើងមានការធ្វេសប្រហែស ឬក៏មិនមានការយល់ដឹងឲ្យបានកាន់តែច្បាស់អំពីហានិភ័យការងារ និងការជ្រើសរើសឧបករណ៍ការពារមិនបានត្រឹមត្រូវ ទៅតាមបច្ចេកទេសនោះក៏ជាហេតុបណ្តាលឲ្យមានការកើតហានិភ័យ និងគ្រោះថ្នាក់ផ្សេងៗដែលជាកត្តាបង្កឲ្យមានការប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ ក៏ដូចជា សង្គមជាតិទាំងមូល។ ឧបករណ៍ការពារមានតួនាទីការពារឧបករណ៍ ឬបរិក្ខារអគ្គិសនីនៅពេលមានការលើសបន្ទុក ការផ្ទួបសៀគ្វី និងការកើតមានជម្រាបចរន្តអគ្គិសនី។ ឧបករណ៍ទាំងនោះរួមមានដូចជា៖

**ឌីសង់ទ័រ** ( Breaker ) LV 220-380

ឌីសង់ទ័រ គឺជាបរិក្ខារការពារបណ្តាញអគ្គិសនី និងបន្ទុកប្រើប្រាស់នៅពេលមានការលើសបន្ទុក ការផ្ទួបសៀគ្វី ចរន្តឆ្លងភ្លើង និងការបិទបើកមិនប្រក្រតីក្នុងរបបធម្មតា។

ប្រភេទឌីសង់ទ័រ គឺមានលក្ខណៈបច្ចេកទេសនៃកាផលិតឌីសង់ទ័រចែកចេញជា៣ប្រភេទ៖

- ឌីសង់ទ័រ Thermique មានលក្ខណៈតូចៗប្រើសម្រាប់ការពារបណ្តាញអគ្គិសនីពីការផ្ទួបសៀគ្វី និងការលើសបន្ទុក។
- ឌីសង់ទ័រ Magnetic មានលក្ខណៈតូចៗដូចគ្នាដែរ ប្រើសម្រាប់ការពារបណ្តាញអគ្គិសនីពីការផ្ទួបសៀគ្វី និងការលើសបន្ទុកតាមប្រព័ន្ធបញ្ជាម៉ូទ័រ។
- ឌីសង់ទ័រ Deferential ប្រើសម្រាប់ការពារបណ្តាញអគ្គិសនីពីការជម្រាបចរន្ត។

❖ **មុខងាររបស់ឌីសង់ទ័រ**

ឌីសង់ទ័រវាមានមុខងារខុសៗគ្នាដែលក្នុងនោះមានដូចជា៖

➢ **ឌីសង់ទ័រ** Thermique MCB ( Miniature Circuit Breakers )

ជាប្រភេទមិនអាចលៃតម្រូវបាន 1 2 3 4ប៉ូល មានតួនាទីត្រួតពិនិត្យ និងការពារសៀគ្វីពីការលើសបន្ទុកឆ្លងភ្លើង ដែលគេភាគច្រើនដំឡើងនៅអគារស្នាក់នៅ ការិយាល័យ រោងចក្រ...។



រូបភាព៣១ ឌីសង់ទ័រប្រភេទ MCB

➢ **ឌីសង់ទ័រ** Magnetic MCCB ( Molded Case Circuit Breaker )

ជាប្រភេទដែលអាចអាចលៃតម្រូវបាន 3 4ប៉ូល មានតួនាទីត្រួតពិនិត្យ និងការពារសៀគ្វី ពីការលើសបន្ទុក ឆ្លងភ្លើង ភាគច្រើនគេប្រើប្រាស់វានៅក្នុងរោងចក្រ។



រូបភាព៣២ ឌីសង់ទ័រប្រភេទ MCCB ឬឌីសង់ទ័រមេកានិក

➢ **ឌីសង់ទ័រ** Deferential ELP ( Earth Leakage Protection )

គឺជាបរិក្ខារអគ្គិសនីមួយដែលការពារនូវអាយុជីវិតរបស់មនុស្ស នៅពេលមនុស្សធក់ខ្សែភ្លើង ឬមានការជ្រាបចរន្តពេលនោះវានឹងផ្តាច់ចរន្តដោយស្វ័យប្រវត្តិ។ តែវាមានលក្ខណៈពិសេសមួយទៀត ត្រង់ពេលមានការឆ្លងភ្លើង ឬមានចរន្តធក់ត្រឹមតែ 0.03A វានឹងលោតផ្តាច់ចរន្តអគ្គិសនីភ្លាម។ ដូច្នេះវាមិនឱ្យអ្នកធក់ចរន្តអគ្គិសនី បាត់បង់ជីវិតឡើយ។ ឌីសង់ទ័រ Deferentail មាន 2 ឬ 4ប៉ូល




រូបភាព៣៣ ឌីសង់ទ័រប្រភេទ ELP ឬឌីសង់ទ័រធក់លោត

❖ គុណសម្បត្តិឌីសង់ទ័រ

- អាចផ្តាច់សៀគ្វីដោយស្វ័យប្រវត្តិពេលបណ្តាញមានបញ្ហា។
- មានប៉ូល (1P,2P,3P,4P) អាចជ្រើសរើសប្រើប្រាស់ជាមួយបណ្តាញគ្រប់ប្រភេទ។
- អាចប្រើប្រាស់បាននូវគ្រប់លក្ខខណ្ឌដូចជា តង់ស្យុងទាប តង់ស្យុងមធ្យម និងតង់ស្យុងខ្ពស់ AC,DC។

❖ **ហ្វុយហ្ស៊ីប (Fuse )**

ហ្វុយហ្ស៊ីប គឺជាឧបករណ៍ការពារមួយប្រភេទដែលគេធ្វើឡើងដើម្បីការពារគ្រឿងអគ្គិសនី ពី Overcurrent ដែលឆ្លងកាត់លើខ្លួនរបស់វាទៅគ្រឿងទទួល។ ក្នុងពេលដែលមានការ Overcurrent កើតឡើងលើខ្លួនរបស់វា ហើយនៅក្នុងលក្ខខណ្ឌដែលហួសពីសមត្ថភាពរបស់វា វានឹងផ្តាច់ខ្លួនរបស់វាភ្លាមមុន Overcurrent កើតមានលើគ្រឿងទទួល។ ហ្វុយហ្ស៊ីបជាអ្នកកំណត់អាំងតង់ស៊ីតេ នៃបណ្តាញហើយវាតជាស៊េរីជាមួយបណ្តាញ។ ពេលមានចរន្តឆ្លងកាត់ វាមានផលកម្តៅ បើចរន្តលើសកំណត់ ហ្វុយហ្ស៊ីបក្តៅខ្លាំងហើយរលាយធ្វើឱ្យចរន្តក្នុងសៀគ្វីដាច់ ការដាច់ចរន្តរបស់ហ្វុយហ្ស៊ីប គឺផ្តាច់ដោយកម្តៅ។ ជាធម្មតា ឧបករណ៍ ឬគ្រឿងទទួលនៃបរិក្ខារអគ្គិសនី តែងតែមានហ្វុយហ្ស៊ីបផ្ទាល់មួយដើម្បីការពារគ្រឿងបរិក្ខារនោះ។ ហ្វុយហ្ស៊ីបវាមានច្រើនប្រភេទដែលគេយកមកប្រើប្រាស់ទៅតាមគ្រឿងឧបករណ៍ បរិក្ខារអគ្គិសនី ផ្សេងៗគ្នា ហើយវាមានសមត្ថភាព និងតម្លៃផ្សេងៗពីគ្នា។ ហើយហ្វុយហ្ស៊ីបមានច្រើនបែបដូចជា៖ សរសៃហ្វុយហ្ស៊ីប បន្ទះហ្វុយហ្ស៊ីប ហ្វុយហ្ស៊ីបបំពង់។

- សរសៃហ្វុយហ្ស៊ីប គឺធ្វើឡើងពីសំណលាយ សំណប៉ាហាំង ឬអាលុយមីញ៉ូម ឬប្រាក់។




រូបភាព៣៤ សរសៃហ្វុយហ្ស៊ីប

- បន្ទះហ្វុយហ្ស៊ីប គឺជាបន្ទះលោហៈធាតុសម្រាប់ដំឡើង និងផ្លាស់ប្តូរដោយការមួលវីស។



រូបភាព៣៥ បន្ទះហ្វុយហ្ស៊ីប

- ហ្វុយហ្ស៊ីបបំពង់ គឺជាសរសៃហ្វុយហ្ស៊ីបដែលស្ថិតនៅក្នុងបំពង់កែវ ដោយសរសៃហ្វុយហ្ស៊ីបធ្វើអំពីសំណ ឬសំណលាយ។







រូបភាព៣៦ ហ្វុយហ្ស៊ីបបំពង់

បណ្តាញសៀគ្វីប្រើហ្វុយហ្ស៊ីបជាបរិធានការពារបណ្តាញបានល្អ តែមានផលវិបាកព្រោះយើងត្រូវធ្វើការផ្លាស់ប្តូរនៅពេលវាដាច់។ ហើយហ្វុយហ្ស៊ីបធ្វើអំពី Pb Sn Al ។

*តារាងអង្កត់ផ្ចិតសរសៃភុយស៊ីប*

| អង្កត់ផ្ចិតសរសៃភុយស៊ីប | ចរន្តឆ្លងកាត់សរសៃភុយស៊ីប I (A) | | |
|---|---|---|---|
| (mm) | Sn | Pb | Al |
| 0,3 | 1,8 | 2 | 5 |
| 0,4 | 2,5 | 3 | 8 |
| 0,5 | 4 | 5 | 12 |
| 0,7 | 7 | 8,5 | 20 |
| 1 | 12,5 | 14 | 35 |
| 1,2 | _ | _ | 42 |
| 1,5 | _ | _ | 60 |
| 2 | _ | _ | 85 |

តាមតារាងខាងលើ ហ្វុយហ្ស៊ីបខាងលើអាចប្រែប្រួលចរន្តដែលអាចអនុញ្ញាតឱ្យចរន្តឆ្លងកាត់ខ្លួនវាបាន អាស្រ័យទៅនឹងប្រវែងរបស់ហ្វុយហ្ស៊ីប ហើយតារាងអង្កត់ផ្ចិតសរសៃហ្វុយហ្ស៊ីបខាងលើមានប្រវែងពី ៤ ទៅ១០ cm។

GFCI ( Ground Fault Circuit Interrupters )

GFCI គឺជាព្រីមួយប្រភេទសម្រាប់ការពារ លេចធ្លាយចរន្តអគ្គិសនីជ្រាបចូលក្នុងដី និងការពារឆក់មនុស្ស។ GFCI វាមានTrip & Reset button សម្រាប់ចុចឲ្យវាដំណើរការម្តងទៀត ហើយវាTrip ទៅលើចរន្តលេចធ្លាយចេញមកក្រៅលើស0.005amp ( 5 milliamps ) ដោយមិនអាស្រ័យជាមួយខ្សែដីឡើយ។

ជាទូទៅ GFCI អាចប្រើបាននៅកន្លែងដែលសើម ឬមានសំណើម និងស្អួតមានដូចជា៖ បន្ទប់ទឹក ផ្ទះបាយ បន្ទប់ក្រោមដី ចំណតឡាន កន្លែងជួសជុល តាមជញ្ជាំងអាគារ ទីធ្លា (ផ្ទះ សាលា នាវា) បន្ទប់ទទួលភ្ញៀង បន្ទប់គេង ផ្សេងៗទៀត។ល។ ខាងក្រោមនេះ ជារូបភាព GFCI៖




រូបភាព៣៧ GFCI

## ការប្រើប្រាស់ឌុយមុខ ២ ( 2 Prong Equipment )

ប្រដាប់ប្រើប្រាស់ និងឧបករណ៍ប្រើប្រាស់ជាមួយឌុយមុខ២ គឺវាមាន Insulate ២ជាន់ ដែលមាន ២ កម្រិត នៃវត្ថុមិនចម្លងចរន្តអគ្គិសនី រវាងសមាសភាគអគ្គិសនី និងវត្ថុដែលអ្នកប្រើប្រាស់អាចកាន់បាន ដោយមានជ័រអ៊ីសូឡង់ស្រោបជុំវិញ។

ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ឌុយមុខ២ នៅតែបង្កបញ្ហាខ្លះៗដល់អ្នកប្រើប្រាស់ នៅពេលអ៊ីសូឡង់របស់ខ្សែចម្លង កកិតដាច់រលោត ឬឧបករណ៍ដែលមានសំណើម ឬសើម ធ្វើឲ្យ មានការឆ្លងចរន្តអគ្គិសនីទៅផ្នែកផ្សេងទៀត ជាពិសេសចំពោះអ្នកប្រើប្រាស់អាចទទួលរងការឆក់ដោយចរន្តអគ្គិសនីពី ការលេចធ្លាយចរន្តនោះ។

ហេតុដូចនេះហើយ ទើបមានការស្រាវជ្រាវទៅលើបញ្ហានោះ ដោយអ្នកបច្ចេកទេសបានផ្លាស់ប្តូរពីការប្រើប្រាស់ឌុយមុខ២ មកប្រើប្រាស់ឌុយមុខ៣វិញម្តង។ ព្រោះឌុយមុខ៣ វាមានការបញ្ចូលទាំងខ្សែហ្វា ខ្សែណឺត និងខ្សែដី ដើម្បីការពារពេលមានការលេចធ្លាយចរន្តកើតឡើង។




រូបភាព៣៨ ឌុយមុខ ២

**ការប្រើប្រាស់ព្រីមុខ ២ (2 Prong Outlets)**

ការប្រើប្រាស់ប្រអប់ព្រី ឬធ្នាប់ចរន្តដែលមានរន្ធ២ និងរន្ធ៣ ក៏មានលទ្ធផលដូចការប្រើប្រាស់ឌុយមុខ២ និងមុខ៣ផងដែរ។ ម្យ៉ាងទៀត បើការប្រើប្រាស់ប្រអប់ព្រី ឬធ្នាប់ចរន្តដែលមានរន្ធ២ខូចយើងត្រូវយកប្រអប់ព្រី ឬធ្នាប់ចរន្តដែលមានរន្ធ២ មកជំនួសវិញ ដោយមិនត្រូវយកប្រអប់ព្រី ឬធ្នាប់ចរន្តដែលមានរន្ធ៣ មកជំនួសទេ ពីព្រោះមិនត្រូវតាមអ្វីដែលមានពីមុនមក។ រីឯការប្រើប្រាស់ប្រអប់ព្រី ឬធ្នាប់ចរន្តដែលមានរន្ធ៣ ក៏ដូចគ្នាអញ្ចឹងដែរ គឺមិនត្រូវធ្វើការផ្លាស់ប្តូរគ្នាទេ ប៉ុន្តែមានករណីមួយអាចធ្វើការផ្លាស់ប្តូរបានគឺ យកប្រអប់ព្រី ឬធ្នាប់ចរន្តប្រភេទ GFCI មកជំនួសវិញ ព្រោះវាមិនអាស្រ័យទៅលើខ្សែដីឡើយ។ ខាងក្រោមនេះ ជារូបភាពប្រអប់ព្រី ឬធ្នាប់ចរន្តដែលអាចប្តូរបាន។




រូបភាព៣៩ ព្រីមុខ ២

Surge Arrester MV 22KV

Surge Arrester ដើរតួ២យ៉ាង គឺដើរតួជាអ៊ីសូឡង់ និងដើរតួជាអង្គធាតុចម្លងសម្រាប់ការពារគ្រឿងអេឡិចត្រូនិក បរិក្ខារអគ្គិសនី និងខ្សែចម្លងកុំឲ្យឆេះខូចដោយបញ្ចៀសតង់ស្យុងខ្ពស់ដែលបណ្ដាលមកពីរន្ទះ។

- ដើរតួជាអ៊ីសូឡង់ នៅពេលដែលខ្សែបណ្ដាញអគ្គិសនីកំពុងដំណើរការធម្មតា ដោយគ្មានបញ្ហាអ្វីកើតឡើង។
- ដើរតួជាអង្គធាតុចម្លង នៅពេលដែលមានបាតុភូតរន្ទះកើតមានឡើងនៅលើបណ្ដាញអគ្គិសនីដែលកំពុងដំណើរការ។



រូបភាព៤០ Surge Arrester

## វិធានការណ៍ដើម្បីការពារភ្លើងឆក់

យើងបានដឹងហើយថា ក្នុងការងារអគ្គិសនីតែងតែជួបប្រទះបញ្ហាឆក់ដោយចរន្តអគ្គិសនីជាច្រើន និងមានភាពស្មុកស្មាញថែមទៀត បើសិនយើងមិនអាចគ្រប់គ្រង វាបានជាមួយវិធីសាស្ត្រដោះស្រាយ ក៏ដូចជាវិធីសាស្ត្រការពារបញ្ហាទាំងនោះ។ ខាងក្រោមនេះជាចំណុចខ្លះៗ ដើម្បីការពារភ្លើងឆក់ដោយចរន្តអគ្គិសនី៖

- មិនត្រូវប៉ះខ្សែចម្លង(ខ្សែភ្លើង) ទាំងឡាយណាដែលយើងមិនប្រាកដថាវាមានចរន្ត ឬអត់។
- ត្រូវប្រើប្រាស់ប៊ិចភ្លើង ធ្វើការតេស្តទៅលើខ្សែចម្លង ឬឧបករណ៍ប្រើប្រាស់ចរន្តអគ្គិសនីទាំងអស់មុននឹងយើងធ្វើការជួសជុល ឬផ្លាស់ប្ដូរទីតាំងសម្ភារទាំងនោះ។
- រាល់ពេលជួសជុល ឬធ្វើការដំឡើងឧបករណ៍សម្ភារអគ្គិសនីដែលប្រើប្រាស់នៅក្នុងផ្ទះ ក្រុមហ៊ុនសហគ្រាស រោងចក្រ គ្រប់ទីកន្លែងណាក៏ដោយ ក៏យើងត្រូវតែធ្វើការផ្ដាច់ចរន្តអគ្គិសនី(ប្រភពភ្លើង) ជាមុនសិនមានដូចជា៖ ឌីសង់ទ័រ ប៉ារ៉ែត កុងតាក់ជាដើម។
- យើងមិនត្រូវបន្តការប្រើប្រាស់រាល់ខ្សែចម្លងដែលមានអ៊ីសូឡង់មិនល្អ(ដាច់រលោត)ឡើយ។ ចំណុចដែលល្អ គួរប្ដូរខ្សែចម្លងថ្មី ជៀសវាងមានបញ្ហាកើតឡើង។
- រាល់បរិក្ខារដែលប្រើប្រាស់ជាមួយចរន្តអគ្គិសនីទាំងអស់ ត្រូវតែមានបរិធានបណ្ដាច់សៀគ្វីជាដាច់ខាត។
- នៅពេលដែលរាង្គកាយរបស់យើងទទឹក ឬសើមយើងមិនត្រូវប៉ះពាល់បរិក្ខារគ្រឿងអគ្គិសនីដែលមានចរន្តអគ្គិសនីឡើយ។
- រាល់ឧបករណ៍សម្ភារប្រើប្រាស់ទាំងអស់ ត្រូវដំឡើងតាមលក្ខណៈបច្ចេកទេស។

- ពិនិត្យឧបករណ៍សម្រាប់ការពារបរិក្ខារអគ្គិសនីរួមមាន៖ ហ្វុយហ្ស៊ីប និងឌីសង់ទ័រដើម្បីប្រាកដថា វានៅមានដំណើរការល្អ និងមិនខូច។
- ពិនិត្យឧបករណ៍ទាំងមុនពេលប្រើប្រាស់ និងក្រោយពេលប្រើប្រាស់វា។
- ត្រួតពិនិត្យមើលថា តើមានឌុយដែលខូច ឬបាក់បែកទេ បើមានដូចនេះត្រូវធ្វើការផ្លាស់ប្តូរឌុយនោះចេញជាប្រញាប់។
- ពិនិត្យថា តើមានរបស់អ្វីដែលគាប ឬមានអ្វីជាន់លើខ្សែភ្លើង។
- មិនត្រូវដាក់ឌុយ ឬខ្សែភ្លើងនៅកន្លែងសើម ឬកន្លែងដែលមានភ្លៀងធ្លាក់។

# សំណួរពិភាក្សា

1. តើឌីសង់ទ័រមានប៉ុន្មានប្រភេទ ?អ្វីខ្លះ ?ចូរពន្យល់ឌីសង់ទ័រនីមួយៗ ?
2. តើហ្វុយហ្ស៊ីបមានប៉ុន្មានប្រភេទ ?អ្វីខ្លះ ?ចូរពន្យល់ពីហ្វុយហ្ស៊ីនីមួយៗ ?
3. តើ GFCI គឺជាអ្វី ?
4. ចូរពន្យល់ពីការប្រើប្រាស់របស់ឌុយមុខ២ និងមុខ៣ ?
5. ចូរពន្យល់ពីតួនាទីរបស់ Surge Arrester ?
6. តើវិធានការណ៍ដើម្បីការពារភ្លើងធក់មានអ្វីខ្លះ ?

## ប្រព័ន្ធខ្សែដី និង ខ្សែណឺត

➢ **សេចក្តីផ្តើម**

នៅលើប្រព័ន្ធ ឬបណ្តាញអគ្គិសនីដែលអ្នកធ្លាប់បានប្រើប្រាស់ តើអ្នកធ្លាប់បានស្គាល់ទៅលើប្រព័ន្ធខ្សែដី និងខ្សែណឺតទេ? ដូច្នេះសូមអ្នកទាំងអស់គ្នាមើលរូប និងឆ្លើយសំណួរដូចខាងក្រោម៖




រូបភាព៤១ ខ្សែណឺត និងខ្សែដី

-ដូចម្តេចដែលហៅថា ខ្សែណឺត?

-ដូចម្តេចដែលហៅថា ខ្សែដី?

**ខ្សែណឺត** គឺជាខ្សែដែលតភ្ជាប់ចេញពីសៀគ្វីអគ្គិសនី បុកចូលទៅដី ហើយយកខ្សែណឺតនោះប្រើប្រាស់ជាមួយគ្រឿងទទួល។ ខ្សែដីគឺជាខ្សែដែលតភ្ជាប់ចេញពីតួឧបករណ៍ ឬបរិក្ខារអគ្គិសនីបុកចូលទៅដី។

**ប្រព័ន្ធខ្សែដី**

ប្រព័ន្ធខ្សែដី មានតួនាទីយ៉ាងសំខាន់ក្នុងការប្រើប្រាស់ថាមពលអគ្គិសនី ចំពោះគ្រប់វិស័យដូចជា៖ ឧស្សាហកម្ម សណ្ឋាគារ លំនៅដ្ឋាន សាលារៀន មន្ទីរពេទ្យ ។ល។ វាមានសារៈសំខាន់ក្នុងការការពារដល់អាយុជីវិតមនុស្ស សត្វ និងឧបករណ៍អគ្គិសនីផ្សេងៗដូចជា៖ ម៉ាស៊ីនអគ្គិសនី ត្រង់ស្វូអគ្គិសនី ម៉ូទ័រ កុំព្យូទ័រ អំពូល ម៉ាស៊ីនត្រជាក់ ។ល។

ការដំឡើងប្រព័ន្ធខ្សែដី ដែលមានលក្ខណៈត្រឹមត្រូវស្របទៅតាមបច្ចេកទេស គឺអាចធានា និងជៀសផុតពីគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើងដោយថាហេតុនៅក្នុងការរស់នៅប្រចាំថ្ងៃ ក៏ដូចនៅកន្លែងការងារផងដែរ។ ទន្ទឹមនឹងនេះ វាក៏បានធានាដល់និរន្តរភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីផងដែរ។

ក្នុងការរៀបចំប្រព័ន្ធខ្សែដី ត្រូវផ្អែកលើមូលដ្ឋាន៣ គឺ៖

-ធ្វើឲ្យប្រាកដថាគ្មានចរន្តឆ្លងកាត់ពីឧបករណ៍ទៅម៉ាស់។

-ធានាដល់សុវត្ថិភាពមនុស្សពីការឆក់ដោយអគ្គិសនី។

-ការការពាររន្ទះ។

**ប្រភេទខ្សែដី**

ខ្សែដីមាន៣ប្រភេទធំ គឺ ប្រភេទខ្សែដីTT ប្រភេទខ្សែដីIT និងប្រភេទខ្សែដី TN។ ខ្សែដីប្រភេទTN ចែកចេញជា ៣ប្រភេទទៀតគឺ ប្រភេទខ្សែដីTN-C ប្រភេទខ្សែដីTN-S និងប្រភេទខ្សែដីTN-C-S។

**ប្រភេទខ្សែដី TT**

- ចំណុចមួយនៅទីតាំងប្រភពត្រូវបានភ្ជាប់ដោយផ្ទាល់ទៅដី។
- រាល់សំបកនៃឧបករណ៍ត្រូវបានភ្ជាប់ទៅនឹងខ្សែដី។
- ខ្សែម៉ាស់( ខ្សែការពារ PE ) ដែលត្រូវបានភ្ជាប់រវាងតួនៃបរិក្ខារអគ្គិសនីទៅដី ហើយវាមានតួនាទី ផ្ទេរចរន្តទៅដីនៅពេលមានការឆ្លងភ្លើងនៅលើ សំបកតួនៃឧបករណ៍ ធ្វើឲ្យមនុស្សរួចផុតពីការឆក់ដោយចរន្តអគ្គិសនី។
- វាមានប្រសិទ្ធភាពខ្ពស់ក្នុងការការពារដល់មនុស្ស ក្នុងករណីដែលយើងប្រើប្រាស់ ឧបករណ៍ការពារ គឺឌីសង់ទ័រឌីផេរ៉ងស្យែល។




រូបភាព៤២ បង្ហាញពីប្រព័ន្ធខ្សែដីប្រភេទTT

**ប្រភេទខ្សែដី IT**

- ប្រព័ន្ធនេះមិនត្រូវបានភ្ជាប់គ្នារវាងចំណុចណឺតនៃប្រភពទៅដីទេ។
- សំបកឧបករណ៍ត្រូវបានភ្ជាប់ទៅនឹងអេឡិចត្រូតដី។
- ត្រូវបានប្រើប្រាស់នៅតាមមន្ទីរពេទ្យ ក្នុងការការពារពេលភ្លើងឆក់។



រូបភាព៤៣ បង្ហាញពីប្រព័ន្ធខ្សែដីប្រភេទIT

**ប្រភេទខ្សែដី TN**

- ចំណុចប្រភពត្រូវបានបុកចូលដី។
- រាល់សំបកឧបករណ៍ត្រូវបានភ្ជាប់ជាមួយខ្សែណឺត។
- ខ្សែដី និងខ្សែការពារត្រូវបានប្រើរួមគ្នា ដោយមានចំណុចមួយភ្ជាប់ដោយផ្ទាល់ទៅដី។




រូបភាព៤៤ បង្ហាញពីប្រព័ន្ធខ្សែដីប្រភេទTN

**ប្រភេទខ្សែដី TN-C**

- ខ្សែណឺត និងខ្សែការពារត្រូវបានប្រើរួមគ្នា
- ប្រព័ន្ធត្រូវប្រើខ្សែចម្លងដែលមានមុខកាត់ធំជាង 10mm2
- ការដំឡើងប្រព័ន្ធនេះថោកជាងប្រព័ន្ធដទៃ
- ប្រព័ន្ធនេះត្រូវបានហាមឃាត់ចំពោះកន្លែងដែលមានការដាក់តាំង ឬប្រើប្រាស់ Computer ពីព្រោះមានចរន្ត harmonic អាចជះឥទ្ធិពលដល់ Computer ។




រូបភាព៤៥ បង្ហាញពីប្រព័ន្ធខ្សែដីប្រភេទTN-C

**ប្រភេទខ្សែដី TN-S**

- ខ្សែការពារ ហើយនិងខ្សែណឺតត្រូវបានចែកដាច់ពីគ្នា

- ការប្រើប្រាស់ខ្សែចម្លងនៃខ្សែការពារ និងខ្សែណឺតអាចតូចជាង$10mm^2$ សម្រាប់បរិក្ខារដែលងាយចល័ត។
- ការបែកដាច់នៃខ្សែការពារ និងខ្សែណឺតជួយកាត់បន្ថយគ្រោះថ្នាក់សម្រាប់ប្រព័ន្ធ Computer ។




រូបភាព៤៦ បង្ហាញពីប្រព័ន្ធខ្សែដីប្រភេទTN-S

**ប្រភេទខ្សែដី TN-C-S**

ប្រព័ន្ធខ្សែដីប្រភេទ TN-C-S គឺជាប្រព័ន្ធខ្សែដីដែលរួមមានទាំងប្រព័ន្ធTN-C និងប្រព័ន្ធTN-S ប៉ុន្តែប្រព័ន្ធTN-C មិនអាចនៅខាងក្រោម ប្រព័ន្ធTN-Sបានទេ ព្រោះនៅពេលដែលមានការកាត់ផ្តាច់ដោយចៃដន្យណាមួយនៅក្នុងខ្សែណឺតនៅផ្នែកខាងលើ(TN-S) អាចនឹងនាំទៅដល់ការកាត់ផ្តាច់ក្នុងខ្សែការពារផ្នែកខាងក្រោម ដែលអាចនាំមកនូវគ្រោះថ្នាក់នៅពេលដែលមានការឆ្លងភ្លើង នៅលើតួឧបករណ៍ ឬបរិក្ខារអគ្គិសនីដែលកំពុងប្រើប្រាស់។




រូបភាព៤៧ បង្ហាញពីប្រព័ន្ធខ្សែដីប្រភេទTN-C-S

# សំណួរពិភាក្សា

1. ដូចម្តេចដែលហៅថាខ្សែដី?
2. ដូចម្តេចដែលហៅថាខ្សែណឺត?
3. តើខ្សែដីមានតួនាទីអ្វីខ្លះ?
4. តើការរៀបចំប្រព័ន្ធខ្សែដីត្រូវផ្អែកទៅលើអ្វីខ្លះ?
5. តើប្រព័ន្ធខ្សែដី TT គឺជាអ្វី? ចូរគូសរូប?
6. តើប្រព័ន្ធខ្សែដី IT គឺជាអ្វី? ចូរគូសរូប?
7. តើប្រព័ន្ធខ្សែដី TN គឺជាអ្វី? ចូរគូសរូប?
8. តើប្រព័ន្ធខ្សែដី TN-C គឺជាអ្វី? ចូរគូសរូប?
9. តើប្រព័ន្ធខ្សែដី TN-S គឺជាអ្វី? ចូរគូសរូប?
10. តើប្រព័ន្ធខ្សែដី TN-C-S គឺជាអ្វី? ចូរគូសរូប?

➢ ការវាយតម្លៃអំពីគ្រោះថ្នាក់

## សេចក្តីផ្តើម

តើអ្នកវាយតម្លៃពីហានិភ័យរបស់អ្នកតាមរបៀបណា ?

ក្រោយពេលដែលអ្នកទទួលស្គាល់អំពីគ្រោះថ្នាក់មួយ បន្ទាប់មកអ្នកធ្វើការវាយតម្លៃជាជំហានៗ អំពីហានិភ័យរបស់អ្នក។ ត្រូវដឹងថា ការប៉ះពាល់ខ្សែភ្លើង គឺដូចជាការប្រឈមពីការគ្រោះថ្នាក់។ បើសិនបើការប៉ះខ្សែភ្លើង15feetពីដីហានិភ័យនៃការគ្រោះថ្នាក់គឺត្រូវបានកាត់បន្ថយមានន័យថា ហានិភ័យនៃការគ្រោះថ្នាក់មានកម្រិតទាប។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកកំពុងធ្វើការនៅលើដំបូលផ្ទះនៅជិតខ្សែភ្លើងដែលមានតង់ស្យុងខ្ពស់ ហានិភ័យនៃគ្រោះថ្នាក់របស់អ្នកនឹងមានកម្រិតខ្ពស់។ ហានិភ័យនៃការឆក់ដោយចរន្តអគ្គិសនីកាន់តែកើនឡើងបន្ថែមទៀត ប្រសិនបើអ្នកកាន់បំពង់ទុយោដែលមានសារធាតុលោហៈប៉ះទៅនឹងខ្សែភ្លើង។

អ្នកត្រូវតែធ្វើការវាយតម្លៃទៅលើហានិភ័យរបស់វាជានិច្ច មុនពេលអ្នកធ្វើការងារជាមួយចរន្តអគ្គិសនី ដែលនៅជុំវិញខ្លួនយើង។

## ការវាយតម្លៃទៅលើប្រភេទគ្រោះថ្នាក់

ការបន្សំនៃគ្រោះថ្នាក់ទាំងឡាយ គឺបានបង្កើននូវហានិភ័យគ្រោះថ្នាក់ដល់អ្នក។ ហានិភ័យរបស់អ្នកនឹងអាចកើនឡើងដែលបណ្តាលមកពីការតភ្ជាប់ខ្សែដីមិនបានត្រឹមត្រូវ និងប្រើប្រាស់ឧបករណ៍ដែលខូច។ ហានិភ័យរបស់អ្នកនឹងអាចកើនឡើងដែលបណ្តាលមកពីអ្នកធ្វើការងារ ក្នុងស្ថានភាពសើមជាមួយនឹងការងារដែលមានការគ្រោះថ្នាក់ផ្សេងៗទៀត។ អ្នកនឹងត្រូវធ្វើការសម្រេចចិត្តអំពីប្រភេទនៃគ្រោះថ្នាក់ ដើម្បីវាយតម្លៃទៅលើហានិភ័យរបស់អ្នក និងធ្វើវាឲ្យបានត្រឹមត្រូវដោយមានសុវត្ថិភាព។

**ឧទាហរណ៍៖** មានភ្លើងសញ្ញាមួយបានភ្លឺដែលបញ្ជាក់ពីគ្រោះថ្នាក់អគ្គិសនីត្រូវបានផ្តាច់ ដោយអំពូលសញ្ញានោះនៅក្នុងព្រីGFCI ឬឌីសង់ទ័រ។ ប្រសិនបើGFCI ឬឌីសង់ទ័រលោតផ្តាច់ចរន្តអគ្គិសនីខណៈពេលដែលអ្នកកំពុងប្រើប្រាស់ចរន្តអគ្គិសនីដោយឧបករណ៍បរិក្ខារអគ្គិសនី គឺព្រីGFCI ឬឌីសង់ទ័រ បានបង្ហាញថា វាមានបញ្ហាអ្វីមួយហើយ។ កុំព្យាយាមធ្វើឲ្យវាដំណើរការម្តងហើយម្តងទៀតអី អ្នកត្រូវតែធ្វើការវាយតម្លៃទៅលើអំពូលសញ្ញាដែលផ្តាច់ចរន្តអគ្គិសនី ហើយសម្រេចចិត្តថា តើមានមូលហេតុអ្វីបានជាភ្លើងសញ្ញាលោតផ្តាច់សៀគ្វីអគ្គិសនីកើតឡើង ?



រូបភាព៤៨ ការបន្សំនៃការគ្រោះថ្នាក់

ខាងក្រោមនេះ មានលក្ខខណ្ឌខ្លះដែលបង្ហាញអំពីគ្រោះថ្នាក់៖

- ការលោតឌីសង់ទ័រ និងដាច់ហ្វុយហ្ស៊ីបបានបង្ហាញថា មានចរន្តអគ្គិសនីច្រើនហួរលើសនៅក្នុងសៀគ្វី ឬមានកំហូចចរន្តអគ្គិសនីកើតឡើង។ ក្នុងលក្ខខណ្ឌនេះ អាចមានបញ្ហាកើនឡើងដូចជា៖ ដំណើរការខុសប្រក្រតីនៃឧបករណ៍បរិក្ខារអគ្គិសនី ឬមានការឆ្លងចរន្តអគ្គិសនីជាមួយខ្សែហ្វា និងខ្សែណឺត។ អ្នកត្រូវកំណត់ពីមូលហេតុ ឬគ្រប់គ្រងបញ្ហាដែលកើនមានឡើងឲ្យបានត្រឹមត្រូវ។
- បរិក្ខារអគ្គិសនី សម្ភារអគ្គិសនី ខ្សែភ្លើង ឬការតភ្ជាប់ដែលមានកម្ដៅដោយ ចរន្តអគ្គិសនីកើនឡើងនៅក្នុងសៀគ្វី ឬបរិក្ខារអគ្គិសនី ឬមានកំហូចចរន្តអគ្គិសនី។ អ្នកត្រូវតែវាយតម្លៃពីស្ថានភាព និងធ្វើការកំណត់ពីហានិភ័យរបស់អ្នក។
- នៅក្នុងបណ្ដាញអគ្គិសនី បើមានផ្នែកខ្សែមួយណាដែលមានកម្ដៅខុសប្រក្រតី គឺវាបង្ហាញថាចរន្តដែលហួរលើផ្នែកខ្សែនោះ ធំជាងមុខកាត់ខ្សែ និងមានកំហូចចរន្តកើតឡើង។ អ្នកត្រូវតែសម្រេចចិត្តថា តើមានវិធីសាស្ត្រអ្វីខ្លះដែលអាចកាត់បន្ថយកម្ដៅលើផ្នែកខ្សែនោះបាន។
- ខ្សែប្រអប់ហ្វុយហ្ស៊ីប ឬប្រអប់បំបែកដែលមានកម្ដៅបានបង្ហាញថា មានចរន្តច្រើនខុសប្រក្រតីនៅក្នុងសៀគ្វី។
- មានក្លិនស្អៀមចេញពីខ្សែ បានបង្ហាញថា មានកម្ដៅក្ដៅនៅក្នុងខ្សែដែលបណ្ដាលឲ្យឆេះរលាកអ៊ីសូឡង់របស់ខ្សែបាន។
- រហែក ឬការខូចខាតអ៊ីសូឡង់ជុំវិញខ្សែ ឬជុំវិញអង្គធាតុចម្លង គឺវាមានគ្រោះថ្នាក់ ចំពោះអ្នកប្រើប្រាស់ ពីព្រោះអង្គធាតុចម្លងនឹងអាចត្រូវបានប៉ះពាល់។ ការទាក់ទងជាមួយការប៉ះពាល់ខ្សែ នឹងអាចជាមូលហេតុបណ្ដាលឲ្យឆក់បាន។ ការខូចខាតអ៊ីសូឡង់ខ្សែ នឹងអាចជាមូលហេតុបង្កើតការឆ្លងចរន្តអគ្គិសនីជាមួយខ្សែហ្វា និងខ្សែណឺត បង្កើតផ្កាភ្លើង ឬបង្កើតជាហានិភ័យតែម្ដង។ ត្រូវត្រួតពិនិត្យលើអ៊ីសូឡង់ទាំងអស់ ដើម្បីឲ្យប្រាកដថាគ្មានអ៊ីសូឡង់ណាដែលដាច់

វហែក ឬខូចមុន និងក្រោយជំទើង។ អ្នកត្រូវធ្វើការវាយតម្លៃទៅលើបញ្ហាដែលធ្ងន់ធ្ងរ ក្នុងការងារដែលអ្នកស្វែងរកឃើញ នៅភាពខ្វះខាតចំពោះការងារ ហើយអ្នកត្រូវសម្រេចចិត្តថាមានវិធីស្រាស្ត្រអ្វីខ្លះដែលអាចដោះស្រាយជាមួយគ្រោះថ្នាក់ទាំងនោះបាន។

- GFCI បានលោតផ្តាច់ បានបង្ហាញថា មានការលេចធ្លាយចរន្តពីសៀគ្វី។ ជាដំបូង អ្នកត្រូវសម្រេចចិត្តពីមូលហេតុនៃការលេចធ្លាយចរន្តចេញមកខាងក្រៅ ហើយត្រូវដឹងថាការលេចធ្លាយចរន្តនោះគឺមានការគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់។ បន្ទាប់មកត្រូវរកវិធីសាស្ត្រ ដើម្បីទប់ស្កាត់នៃការលេចធ្លាយចរន្តចេញមកខាងក្រៅ។

**ការព្យាករណ៍គ្រោះថ្នាក់ដោយគិតទុកជាមុន**

**ក. ការព្យាករណ៍គ្រោះថ្នាក់ដោយគិតទុកជាមុន**

តើអ្វីជាការព្យាករណ៍គ្រោះថ្នាក់គិតទុកជាមុន?

ការព្យាករណ៍គ្រោះថ្នាក់គិតទុកជាមុន គឺជាការរិះរកនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងក្នុងពេលដែលយើងកំពុងបំពេញការងារ ហើយត្រូវស្វែងរកវិធីសាស្ត្រទប់ស្កាត់ និងដោះស្រាយបញ្ហាគ្រោះថ្នាក់នោះ។

តើមូលដ្ឋាននៃការកើតឡើងនូវគ្រោះថ្នាក់ការងារមានប៉ុន្មានកត្តាដែលចូលរួម?

មូលដ្ឋាននៃការកើតឡើងនូវគ្រោះថ្នាក់ការងារមាន២ គឺស្ថានភាពអស្លេរភាព និងអំពើគ្មានសុវត្ថិភាព។




រូបភាព៤៩ មូលដ្ឋាននៃការកើតឡើងនូវគ្រោះថ្នាក់ការងារ

មូលដ្ឋាននៃការកើតឡើងនូវគ្រោះថ្នាក់ការងារមាន២ គឺស្ថានភាពអស្លេរភាព និងអំពើគ្មានសុវត្ថិភាព។

- ស្ថានភាពអស្លេរភាពដូចជា៖ វត្ថុបាតុភូត។
- អំពើគ្មានសុវត្ថិភាព មានដូចជា៖ មនុស្ស។

អំពើគ្មានសុវត្ថិភាពចែកចេញជា២ គឺខុសដោយសារលក្ខណៈរបស់មនុស្ស និងអំពើគួរឱ្យមានហានិភ័យ (ដឹងថាមានគ្រោះថ្នាក់នៅតែប្រព្រឹត្ត)។




រូបភាព៥០ មុខទាំងពីរនៃអំពើគ្មានសុវត្ថិភាពការងារ

ខុសដោយសារលក្ខណៈរបស់មនុស្សមានដូចជា៖ ស្តាប់ខុស ស្តាប់ច្រឡំ ការស្មាន ស្មានតាំងពីមុន អំពើអចេតនាជាទំលាប់ភ័ន្តស្មារតីភ្លេច។ *ហៅដោយចង្អុល...!*

អំពើគួរឱ្យមានហានិភ័យ(ដឹងថាមានគ្រោះថ្នាក់ តែនៅប្រព្រឹត្ត)មានដូចជា៖ ដោយសារខ្ជិល ប្រហែលមិនអីទេ ដោយសារតិចតួច អ្នកដ៏ទៃធ្វើដែរ។ *ពិភាក្សាពីហានិភ័យនៅកន្លែងធ្វើការ...!*

ការប្រើប្រាស់វិធី *ហៅដោយចង្អុល និងពិភាក្សាពីហានិភ័យនៅកន្លែងធ្វើការ* គឺបង្កើនវិញ្ញាណដែលដឹងខ្លួនអំពីគ្រោះថ្នាក់តាមរយៈការប្រជុំ រួមទាំងព័ត៌មានស្តីអំពីគ្រោះថ្នាក់ផង និងធ្វើការដោះស្រាយតាមរយៈប្រជុំផង នាំឱ្យបង្កើនសមត្ថភាពដោះស្រាយបញ្ហាព្រមទាំងធ្វើការហៅដោយចង្អុល នៅពេលដែលសំខាន់ៗក្នុងការងារដែលជំរុញឱ្យជិតអារម្មណ៍ និងធ្វើការជាក្រុម ដើម្បីលើកកម្ពស់ធន្ទៈចូលរួមសកម្មភាព។

## គ្រោះថ្នាក់កើតឡើងដូចរបៀបនេះ.......!




រូបភាព៥១ មិនប្រុងប្រយ័ត្នពេលដើរ




រូបភាព៥២គ្រួតពិនិត្យឯកសណ្ឋាន

ខ. Touch & Call

Touch & Call គឺជាអ្វី?

Touch & Call គឺជាវិធីមួយដែលមានគោលបំណងលើកកម្ពស់ភាពរួបរួមសាមគ្គីរបស់ក្រុម ដែលមានប្រយោជន៍សម្រាប់បង្កើតលក្ខណៈការងារជាក្រុម។

Touch & Call ត្រូវអនុវត្តដោយសមាជិកក្រុមទាំងអស់ ដោយមានលក្ខណៈ៣ប្រភេទ គឺ៖

- ❑ ដាក់ដៃលើស្មា
- ❑ ដាក់ដៃលើគ្នា
- ❑ ក្តាប់ដៃធ្វើជារង្វង់

## គ. វិធីបង្វិល៤ជុំនៃមូលដ្ឋាន KYT

KYT មានន័យថា៖ គិកេន(ដែលបង្កឲ្យមានគ្រោះថ្នាក់) យ៉ូឈិ(ព្យាករណ៍) Training (ការបណ្តុះបណ្តាល)

| ជុំទី | ហ្វឹកហាត់ប៉ាន់ស្មានគ្រោះថ្នាក់៤ជុំ | វិធីអនុវត្តហ្វឹកហាត់ប៉ាន់ស្មានគ្រោះថ្នាក់ |
|---|---|---|
| 1R | អាចមានគ្រោះថ្នាក់បែបណា | ស្វែងរកនូវគ្រោះថ្នាក់ដែលលាក់ខ្លួននៅក្នុងស្ថានការណ៍នៃគំនូរនោះហើយប៉ាន់ស្មានពីបាតុភូតដែលអាចកើតឡើងតាមរយៈមូលហេតុនោះ (អំពើគ្មានសុវត្ថិភាព និងស្ថានភាពអសុវត្ថិភាព) និងពិភាក្សាគ្នា។ |
| 2R | នេះជាចំនុចគោលនៃគ្រោះថ្នាក់ | ក្នុងចំណោមគ្រោះថ្នាក់ដែលបានរកឃើញនោះគ្រោះថ្នាក់ដែលគិតថាសំខាន់ត្រូវដាក់សញ្ញា○ហើយជ្រើសរើសតាមការយល់ព្រមគ្នារួចហើយដាក់សញ្ញា◎ និងខ្សែបន្ទាត់ក្រោមដោយចាត់ទុកថា“ចំនុចគោលនៃគ្រោះថ្នាក់”ហើយពិនិត្យគ្នាដោយហៅចង្អុល។ |
| 3R | ចុះអ្នកវិញធ្វើយ៉ាងដូចម្តេច? | គិតពិចារណាពីវិធីដោះស្រាយចំនុច◎ហើយពិភាក្សាគ្នាពីវិធានការណ៍ដោះស្រាយ។ |
| 4R | យើងខ្ញុំនឹងធ្វើដូច្នេះ | ក្នុងចំណោមវិធានការណ៍នោះជ្រើសរើសតាមការយល់ព្រមគ្នាហើយដាក់សញ្ញា※ដោយចាត់ទុកថាជា“ប្រការអនុវត្តសំខាន់”ហើយបង្កើត “គោលដៅរបស់ក្រុម”សំរាប់អនុវត្តនោះហើយពិនិត្យគ្នាដោយហៅចង្អុលលើការកំណត់។ |

❑ តើចំណុចគ្រោះថ្នាក់ខ្លាំងនៅក្នុងរូបខាងក្រោមនេះគឺជាអ្វី?

**លក្ខខណ្ឌ៧ចំណុច**

1. សុំគិតថាមនុស្សនៅក្នុងរូបភាព គឺជាអ្នក។
2. ចាប់យកចំណុចគ្រោះថ្នាក់ដោយគិតទៅលើ "ធាតុដែលបង្កឲ្យមានគ្រោះថ្នាក់"និង "ប៉ាន់ប្រមាណបាតុភូតដែលបង្កឲ្យគ្រោះថ្នាក់( ប្រភេទនៃគ្រោះថ្នាក់ )"។
3. គូសបញ្ជាក់បាតុភូត ទៅជាប្រភេទគ្រោះថ្នាក់។
4. ចាប់យកធាតុដែលបង្កឲ្យមានគ្រោះថ្នាក់ ទៅជាសកម្មភាពគ្មានសុវត្ថិភាព និងស្ថានភាពគ្មានសុវត្ថិភាព
5. រំលេចចូលក្នុងធាតុដែលបង្កឲ្យមានគ្រោះថ្នាក់
6. បញ្ជាក់ធាតុដែលបង្កឲ្យមានគ្រោះថ្នាក់ឲ្យច្បាស់លាស់។
7. បញ្ជាក់ធាតុដែលបង្កឲ្យមានគ្រោះថ្នាក់ មានពិតប្រាកដ។



រូបភាព៥៣ អ្នកកំពុងជួសជុលបណ្តាញអគ្គិសនី

## សំណួរពិភាក្សា

1. តើអ្នកវាយតម្លៃពីហានិភ័យរបស់អ្នកតាមរបៀបណា?
2. តើមានលក្ខខណ្ឌអ្វីខ្លះដែលបង្ហាញអំពីគ្រោះថ្នាក់?
3. តើមូលដ្ឋាននៃការកើតឡើងនូវគ្រោះថ្នាក់ការងារមានអ្វីខ្លះ? ចូរពន្យល់នីមួយៗ?
4. តើអ្វីដែលហៅថា ហៅដោយចង្អុល និងពិភាក្សាពីហានិភ័យនៅកន្លែងធ្វើការ?

- ➢ **អនុវត្តន៍ការងារដោយមានសុវត្ថិភាព**

## សេចក្តីផ្តើម

តើសុវត្ថិភាពការងារធ្វើឡើងយ៉ាងដូចម្តេច?

សុវត្ថិភាពការងារនៅតាមមជ្ឈដ្ឋាន គឺមិនគ្រប់គ្រាន់ដើម្បីគ្រប់គ្រងគ្រោះថ្នាក់ដោយអគ្គិសនីបានទាំងអស់ឡើយ។ អ្នកត្រូវតែធ្វើការងារដោយមានសុវត្ថិភាពខ្ពស់។ ការអនុវត្តការងារដោយសុវត្ថិភាព ជួយអ្នកគ្រប់គ្រងនូវហានិភ័យរបស់អ្នកបានមានដូចជាៈ ជៀសផុតពីការរងរបួស ឬស្លាប់នៅនឹងកន្លែងធ្វើការងារណាដែលមានគ្រោះថ្នាក់បាន។ ប្រសិនបើអ្នកកំពុងធ្វើការងារជាមួយបណ្តាញអគ្គិសនី ឬជាមួយឧបករណ៍បរិក្ខារអគ្គិសនី អ្នកត្រូវតែប្រើប្រាស់នូវការអនុវត្តការងារដោយមានសុវត្ថិភាព ។

អ្នកត្រូវតែសួរខ្លួនឯង មុនអ្នកចាប់ផ្តើមធ្វើការនៅលើឧបករណ៍បរិក្ខារអគ្គិសនីអ្វីមួយ។

- តើអ្វីអាចទៅជាខុស?
- តើខ្ញុំដឹងអ្វីខ្លះដែលទាក់ទងជាមួយឧបករណ៍ និងមានបទពិសោធន៍អ្វីដើម្បីធ្វើការងារមួយទទួលបានជោគជ័យ និងមានសុវត្ថិភាពការងារ?

គ្រប់អ្នកធ្វើការទាំងអស់ដែលទាក់ទងទៅលើផ្នែកអគ្គិសនី គួរតែមាននីតិវិធីការងារដែលមាន ប្រសិទ្ធភាព និងមានសុវត្ថិភាពប្រហាក់ប្រហែលគ្នា ដើម្បីធានានូវសុខសុវត្ថិភាពចំពោះអ្នកប្រើប្រាស់ ក៏ដូចជាអ្នកធ្វើការផ្ទាល់ជាមួយផ្នែកអគ្គិសនី។ អ្នកត្រូវតែដឹងពីរបៀបគ្រប់គ្រងការងារយ៉ាងជាក់លាក់ជួយថែរក្សាអ្នកឲ្យមានសុវត្ថិភាព ក្នុងពេលបំពេញការងារ។ អ្នកត្រូវតែប្រើប្រាស់ការវិនិច្ឆ័យដោយភាពត្រឹមត្រូវ។

ការគ្រប់គ្រងគ្រោះថ្នាក់ដោយអគ្គិសនីតាមរយៈ ការអនុវត្តការងារដោយមានសុវត្ថិភាព ដូចខាងក្រោមៈ

១ គម្រោងការងាររបស់អ្នក និងគម្រោងសម្រាប់សុវត្ថិភាព។

២ ជៀសវាងធ្វើការងារក្នុងស្ថានភាពសើម និងគ្រោះថ្នាក់ផ្សេងៗ។

៣ ជៀសវាងពីខ្សែដែលមានអនុភាពធំតាមបណ្តាញអាកាស។

៤ ការប្រើប្រាស់ខ្សែ និងការធ្វើតំណខ្សែឲ្យបានត្រឹមតត្រូវ។

៥ ប្រើប្រាស់ឧបករណ៍សម្ភារ និងតំហែទាំឲ្យបានត្រឹមត្រូវ។

៦ ស្លៀកសំលៀកបំពាក់PPE ឲ្យបានត្រឹមត្រូវ។

៧ ស៥ ឬ5S។

## គម្រោងការងាររបស់អ្នក និងគម្រោងសម្រាប់សុវត្ថិភាព

យកពេលវេលាដើម្បីធ្វើគម្រោងរបស់អ្នកដោយខ្លួនរបស់អ្នក និងជាមួយអ្នកផ្សេងទៀត។ ការរៀបចំគម្រោងសម្រាប់សុវត្ថិភាព គឺជាផ្នែកមួយដែលមានសារៈសំខាន់ខ្លាំងណាស់រាល់ភារកិច្ចទាំងអស់ ក្នុងវិស័យការងារនីមួយៗ។ ការងារនីមួយៗតែងតែត្រូវការខិតខំប្រឹងប្រែងស្វែងយល់ និងផ្តល់ការវាយតម្លៃលើគ្រប់ជ្រុងជ្រោយនៃការគ្រប់គ្រងគ្រោះថ្នាក់ហានិភ័យទាំងអស់។ ប្រសិនបើអ្នកកំពុងតែគិតថា ការងាររបស់អ្នកគ្រាន់តែជាការងារសាកល្បង ឬក៏អ្នកគិតអ្វីផ្សេងពីហ្នឹង វាគឺពិបាកយកពេលវេលាដើម្បីរៀបចំគម្រោងសម្រាប់សុវត្ថិភាពខ្លាំងណាស់។ ប៉ុន្តែ... អ្នកត្រូវតែរៀបចំវា...!

ការរៀបចំគម្រោងជាមួយអ្នកផ្សេងៗទៀត គឺជាវិធីសាស្ត្រជំនួយមួយដែលមានលក្ខណៈ ពិសេស។ វាផ្តល់ដោយអ្នកសម្របសម្រួលដល់ការងាររបស់អ្នក និងមានគុណប្រយោជន៍នូវអ្វីដែលអ្នកផ្សេង បានគិតអំពីលក្ខណៈបច្ចេកទេសក្នុងការគ្រប់គ្រងគ្រោះថ្នាក់ ហានិភ័យ ដែលកើតមានឡើងដោយបន្សល់នៅតារាងមួយដែលមានការគិតរួមនៃការរៀបចំគម្រោងសម្រាប់សុវត្ថិភាព។

**កុំធ្វើការងារតែម្នាក់ឯង**

- ធ្វើការងារជាមួយមិត្តរួមការងារ ( កុំធ្វើការងារតែម្នាក់ឯង ) មិត្តរួមការងាររបស់អ្នក គួរតែបានឆ្លងកាត់វគ្គបណ្តុះបណ្តាលជួយសង្គ្រោះបឋម។ មិត្តរួមការងាររបស់អ្នកត្រូវតែដឹងថាតើត្រូវធ្វើអ្វីក្នុងពេលជួយសង្គ្រោះបន្ទាន់។
- ដឹងពី របៀបបិទ និងផ្តាច់សៀគ្វីអគ្គិសនី អ្នកត្រូវតែស្វែងរកឌីសង់ទ័រ ហ្វុយហ្ស៊ីប និងកុងតាក់ដែលមានគ្រប់ទីកន្លែង។ បន្ទាប់មកនៅលើសៀគ្វីដែលអ្នកនឹងធ្វើការងារជាមួយ(ទោះបីជាសៀគ្វីនោះ មានតង់ស្យុងទាបក៏ដោយ) អ្នកត្រូវតែកាត់ផ្តាច់សៀគ្វីនោះ ហើយធ្វើការតេស្តទៅលើសៀគ្វីនោះ មុនពេលដែលអ្នកចាប់ផ្តើមធ្វើការងារដើម្បីឲ្យដឹងពិតប្រាកដថា សៀគ្វីនោះត្រូវបានកាត់ផ្តាច់ទាំងស្រុង ឬនៅ។



រូបភាព៥៤ ធ្វើតេស្ត៍ មុនចាប់ផ្តើមធ្វើការងារ

**ចាក់សោ និងដាក់ផ្លាកសញ្ញា**

បង្កើតភាពជាក់លាក់លើប្រភពទាំងអស់នៅទិសដៅផ្តាច់ មានការចាក់សោ និងដាក់ផ្លាកសញ្ញាមុនធ្វើការអនុវត្តការងារនៅលើសៀគ្វីអគ្គិសនី ឬគ្រឿងបរិក្ខារអគ្គិសនី។ អ្នកធ្វើការកំពុងតែធ្វើការងាររបស់អ្នកនៅលើសៀគ្វីដែលបានផ្តាច់វាក៏ប្រឈមនឹងគ្រោះថ្នាក់មួយ ក្នុងចំណោមគ្រោះថ្នាក់ផ្សេងៗទៀត។ ប្រសិនបើមាននរណាម្នាក់មកបើកសៀគ្វីនោះ(Turn on) ដោយគ្មានប្រាប់អ្នក នោះអ្នកអាចទទួលរងការឆក់ ដុតកម្លោច ឬឆក់ដោយចរន្តអគ្គិសនីតែម្តង។ ការធ្វើការដោយមិនបានត្រៀមទុកជាមួយឧបករណ៍សម្ភារអគ្គិសនី អាចជាមូលហេតុធ្វើឲ្យរងរបួស ឬស្លាប់បាន។

មុនចាប់ផ្តើមធ្វើការងារផ្សេងទៀត គឺត្រូវធ្វើនៅលើសៀគ្វីដូចជា៖បិទ ឬកាត់ផ្តាច់សៀគ្វីចាក់សោ និងដាក់ផ្លាកសញ្ញាលើសៀគ្វីនៅកន្លែងប្រអប់ ឬទូចែកចាយ។ បន្ទាប់មក ធ្វើការតេស្តសៀគ្វី ដើម្បីឲ្យដឹងថាសៀគ្វីត្រូវបានកាត់ផ្តាច់ពិតប្រាកដមែន។

មុនចាប់ផ្តើមធ្វើការត្រួតពិនិត្យ ឬជួសជុលឧបករណ៍បរិក្ខារអគ្គិសនី ទោះបីជាសៀគ្វីនោះមានតង់ស្យុងទាប ឬមានចរន្តតិចក៏ដោយ ក៏ត្រូវតែកាត់ផ្តាច់វានៅន្លែងប្រអប់កុងតាក់ដែរ ហើយកុងតាក់ត្រូវតែចាក់សោក្នុងទិសដៅបិទ(Turn Off)។ ក្នុងពេលតំណាលគ្នានោះដែរ ឧបករណ៍ បរិក្ខារអគ្គិសនី ត្រូវបានបំពាក់ផ្លាកសញ្ញាសុវត្ថិភាពគ្រប់ទីកន្លែងដែលត្រូវបំពេញការងារ គឺត្រូវបានចាប់ផ្តើមការអនុវត្ត។ ធ្វើការតេស្តម្តងទៀតទៅលើសៀគ្វី និងឧបករណ៍បរិក្ខារអគ្គិសនី ដើម្បីធានាឲ្យបាននូវការកាត់ផ្តាច់ចេញពីសៀគ្វីអគ្គិសនី។



រូបភាព៥៥ ចាក់សោ និងដាក់ផ្លាកសញ្ញា

មិនគួរមានសោ២ ដែលដូចគ្នានោះទេ សោនីមួយៗគួរតែត្រូវតែមេសោ១ ហើយមេសោ១ ត្រូវមានសិទ្ធតែអ្នកប្រើប្រាស់តែម្នាក់គត់។ ប្រសិនបើអ្នកកំពុងធ្វើការងារលើសៀគ្វី ឬជួសជុលផ្នែកណាមួយនៃឧបករណ៍បរិក្ខារអគ្គិសនី ហើយអ្នកបានកាត់ផ្តាច់សៀគ្វី និងចាក់សោ ហើយដាក់ផ្លាកសញ្ញានៅលើសៀគ្វីនោះ គឺអ្នកទទួលបាននូវសុវត្ថិភាពខ្ពស់ ដោយគ្មាននរណាម្នាក់មកបើកសៀគ្វីនោះបានក្រៅពីខ្លួនអ្នកផ្ទាល់ឡើយ។ គ្រប់ពេលវេលាទាំងអស់ អ្នកត្រូវតែជឿជាក់ថា អ្នកគឺមិនប្រឈមនឹងគ្រោះថ្នាក់ដូចអ្នកធ្វើការងារផ្សេងទៀតឡើយ។ អ្នកធ្វើការដែលបំពេញនៅនីតិវិធី ចាក់សោដាក់ផ្លាកសញ្ញាសុវត្ថិភាព ត្រូវតែបានឆ្លងកាត់វគ្គបណ្តុះបណ្តាល និងបានអនុញ្ញាតឲ្យទៅជួសជុល និងតំហែទាំទៅលើឧបករណ៍បរិក្ខារអគ្គិសនី។ ការចាក់សោ ឬដាក់ផ្លាកសញ្ញានៅកន្លែង ប្រអប់ ឬទូចែកចាយ គឺដើម្បីបង្ការអ្នកផ្សេងទៀតដែលចង់មកបើក សៀគ្វី(Turn On)។ ការដាក់ផ្លាកសញ្ញា គឺដើម្បីផ្តល់ព័ត៌មានដល់អ្នកធ្វើការផ្សេងទៀត ឲ្យដឹងពីសកម្មភាពធ្វើការងារនៅកន្លែងនោះ។

**គ្រឿងអលង្ការ និងវត្ថុលោហៈ**

អ្នកគួរតែយកចេញនូវគ្រឿងអលង្ការ និងវត្ថុផ្សេងៗដែលជាសារជាតុលោហៈ នៅជាប់ខ្លួនរបស់អ្នកមុនពេលចាប់ផ្តើមធ្វើការងាររបស់អ្នក។ វត្ថុទាំងនេះអាចជាមូលហេតុបណ្តាលឲ្យមានការឆក់ រលាកពីចរន្ត អគ្គិសនីផងដែរ ប្រសិនបើអ្នកពាក់វានៅជិតសៀគ្វីដែលមានចរន្តធំ នឹងអាចទទួលរងការប៉ះពាល់ដល់ការងាររបស់អ្នកដែរ។

**គម្រោងការងារដើម្បីជៀសវាងនៃការធ្លាក់ពីទីខ្ពស់**

ជាលទ្ធផល របួសអាចផ្តើមចេញពីការធ្លាក់ចុះពីលើរន្ទា ឬជណ្តើរ។ អ្នកធ្វើការមួយចំនួនផ្សេងទៀតអាចទទួលរងរបួសពីឧបករណ៍ បរិក្ខារ និងកម្ទេចកម្ទីដែលធ្លាក់ចុះពីលើរន្ទា ឬជណ្តើរហើយនេះជាមូលហេតុដែលបណ្តាលឲ្យកើតមានរបួសចំពោះអ្នកធ្វើការងារ។

**ឧទាហរណ៍៖**

អ្នកជួសជុលផ្នែកអគ្គិសនីម្នាក់ គាត់បានទៅជួសជុលអំពូលភ្លើងមួយដែលមានបញ្ហាដោយអំពូលភ្លើងមិនភ្លឺ ហើយគាត់គិតថា គាត់នឹងខិតខំប្រឹងប្រែងជួសជុលអំពូលភ្លើងនោះ ឲ្យបានល្អត្រឹមត្រូវ និងមិនមានបញ្ហាអ្វីឡើយ។ គាត់បានយកជណ្ដើរមក ហើយគាត់បានត្រួតពិនិត្យលើសៀគ្វីនោះ ហើយគាត់មិនបានកាត់ផ្ដាច់សៀគ្វីចេញពីប្រភពតាមរយៈឌីសង់ទ័រនៅក្នុងប្រអប់ ឬទូចែកចាយទេ គាត់ក៏មិនបានតេស្ដខ្សែឲ្យដឹងថាខ្សែនោះមានចរន្តឆ្លងកាត់ឬទេ។ គាត់បានទទួលរងការឆក់ ដោយចរន្តអគ្គិសនីក្នុងពេលដែលគាត់បានយកដៃខាងឆ្វេងរបស់គាត់ទៅកាន់ខ្សែភ្លើង។ គាត់បានដួលរលំទៅលើឥដ្ឋការ៉ូ ហើយគាត់ក៏បានស្លាប់ភ្លាមៗតែម្ដង។




រូបភាព៥៦ មិនបានកាត់ផ្ដាច់ប្រភព

- អ្នកធ្វើការ មិនគួរធ្វើការងារនៅលើសៀគ្វីអគ្គិសនីទេ លុះត្រាតែមានប្រសិទ្ធភាព ចំពោះការចាក់សោ និងដាក់ផ្លាកសញ្ញាសុវត្ថិភាពនៅកន្លែងប្រអប់ ឬទូចែកចាយ។
- អ្នកធ្វើការ មិនគួរធ្វើការងារនៅលើសៀគ្វីអគ្គិសនី ដែលមិនទាន់បានកាត់ផ្ដាច់សៀគ្វី អគ្គិសនីចេញពីប្រភព។ សៀគ្វីអគ្គិសនីត្រូវតែបានកាត់ផ្ដាច់ចេញពីប្រភព ចាក់សោ និងដាក់ផ្លាកសញ្ញា។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់មក អ្នកត្រូវតែធ្វើតេស្តទៅលើសៀគ្វីនោះ មុនអ្នកចាប់ផ្ដើមធ្វើការងារដោយដឹងឲ្យប្រាកដថាសៀគ្វីអគ្គិសនី នោះត្រូវបានកាត់ផ្ដាច់ចេញពីប្រភពពិតប្រាកដមែន។

**ការដាក់ជណ្ដើរឲ្យមានសុវត្ថិភាព**

ដើម្បីបង្ការនៃការរងរបួសនៅពេលឡើងជណ្ដើរ សូមអនុវត្តដូចខាងក្រោម៖

ក. ទីតាំងជណ្ដើរត្រូវដាក់នៅកន្លែងដែលមានមុំសុវត្ថិភាពដើម្បីបង្ការការរអិលរបស់ជណ្ដើរ ចម្ងាយចំណុចកណ្ដាលពីចំណុចក្រោមនៃជណ្ដើរ ទៅកាន់ចំណុចក្រោមនៃការដាក់ជណ្ដើរ គួរតែដាក់ចម្ងាយចាប់ពីមួយភាគបួន ( ¼ ) នៃចម្ងាយសរុបពីចំណុចក្រោមនៃជណ្ដើរ ទៅកាន់ចំណុចលើនៃជណ្ដើរ។

ខ. ត្រូវឲ្យប្រាកដថា ចំណុចក្រោមនៃជណ្ដើរត្រូវបានទ្រដោយប្រភេទដីឥដ្ឋ ឬស៊ីម៉ងត៍។ ត្រូវបង្កើនការប្រុងប្រយ័ត្ន នៅពេលដែលទីតាំងជណ្ដើរដាក់នៅកន្លែងដែលសើម ឬកន្លែងធ្លាក់ទឹកកក បើមិនដូច្នេះទេ គឺកន្លែងដែលមានផ្ទៃរអិល។ ករណីពិសេសជណ្ដើរប្រហែលជាមានកន្លែងសម្រាប់ចាក់សោ ឬដាក់គន្លឹះដើម្បីបង្ការការរអិល។



រូបភាព៥៧ សុវត្ថិភាពនៃជណ្ដើរ

គ. ចំពោះអ្នកប្រើប្រាស់ជណ្ដើរ ត្រូវតែអនុវត្តតាមបទដ្ឋាននៃការប្រើប្រាស់ជណ្ដើរឲ្យបានត្រឹមត្រូវ ទើបទទួលបានមកវិញនូវសុខសុវត្ថិភាព។




រូបភាព៥៨ ការដាក់ជណ្តើរ

ឃ. ធ្វើការត្រួតពិនិត្យមើលទីតាំងជណ្តើរមុនប្រើប្រាស់។ ជើងជណ្តើរត្រូវតែដាក់បាន និងនៅមួយកន្លែង ដើម្បីជៀសវាងមានការរង្គើ ឬមាន គំលាតធ្វើឲ្យជណ្តើររអិលបាន។

ង. នៅពេលដែលប្រើប្រាស់ជណ្តើរមានលក្ខណៈជាជំហាន ត្រូវតែបើកជើងទាំង២ របស់ជណ្តើរឲ្យត្រូវកម្រិតមួយពិតប្រាកដនៃគម្លាតរបស់ជណ្តើរ។ ជាធម្មតាជណ្តើរ តែងតែមានត្រចៀករបស់វាសម្រាប់ដាក់គន្លឹះ។ ចំពោះអ្នកប្រើប្រាស់ មិនអនុញ្ញាតឲ្យឈរចំ ចំណុចកំពូលរបស់ជណ្តើរឡើយ។



រូបភាព៥៩ ការឈរលើជណ្តើរ

ច. ពេលដែលឡើងលើរន្ទា ត្រូវប្រើប្រាស់ជណ្ដើរសម្រាប់ឡើង។

ឆ. មិនត្រូវប្រើប្រាស់ជណ្ដើរដែលមានសារធាតុលោហៈទេ ជំនួសមកវិញត្រូវតែប្រើប្រាស់ជណ្ដើរឈើ ព្រោះវាជាឈើស្ងួតមានអ៊ីសូឡង់ខ្ពស់សម្រាប់ការពារការឆ្លងចរន្តអគ្គិសនី។

ជ. ចូរប្រុងប្រយ័ត្នចំពោះអ្នកប្រើប្រាស់ជណ្ដើរ ឬរន្ទានៅជិតបណ្ដាញអាកាសដែលមានអនុភាពធំ។



រូបភាព៦០ ការឡើងលើរន្ទា



រូបភាព៦១ ប្រភេទជណ្ដើរ

## ជៀសវាងធ្វើការងារក្នុងស្ថានភាពសើម និងគ្រោះថ្នាក់ផ្សេងៗ

ចូរចងចាំថា គ្រោះថ្នាក់ខ្លះក្លាយទៅជាគ្រោះថ្នាក់មួយទៀតដ៏ធ្ងន់ធ្ងរនៅក្នុងស្ថានភាពសើម ឬទីតាំងដែលមានសំណើម។ ដើម្បីឲ្យមានសុវត្ថិភាពខ្ពស់ យើងត្រូវសន្មត់ថា នៅក្នុងទីតាំងការងារទាំងអស់ គឺមានសំណើម។ ទោះបីជាយ៉ាងណា ប្រសិនបើអ្នកធ្វើការងារនោះមិនឃើញមានទឹក ឬសំណើមក៏ដោយ ក៏អ្នកកុំភ្លេចគិតថា ក្នុងស្ថានភាពខ្លះសំណើមអាចកើតចេញពីញើស។

- កុំធ្វើការងារណាដែលសើម

មិនត្រូវធ្វើការងារនៅលើសៀគ្វី ឬប្រើប្រាស់ឧបករណ៍សម្ភារអគ្គិសនីដែលសើម ឬកន្លែងដែលសើម។ ប្រសិនបើមានការចាំបាច់ ត្រូវសម្អាតកន្លែងដែលទុកដាក់ឧបករណ៍ ឬកន្លែងដែលព្យួរ ឧបករណ៍បរិក្ខារអគ្គិសនី។ បន្ទះឈើដែលសើមនៅលើឥដ្ឋការ៉ូ ត្រូវសម្អាតវាឲ្យស្ងួត និងរក្សាវាទុក។ ត្រូវពាក់ស្បែកជើងដែលមានអ៊ីសូឡង់ ឬស្បែកជើងដែលមានជ័រសម្រាប់ការពារ។ ដៃរបស់អ្នក ត្រូវតែស្ងួតនៅពេលដែលអ្នកចាប់ដោតឌុយ ឬដកឌុយចេញពីប្រភពភ្លើង។ កុំធ្វើការសម្អាត ឧបករណ៍បរិក្ខារអគ្គិសនីផ្សេងៗ ដោយមិនបានកាត់ផ្តាច់ប្រភពភ្លើង។

- ប្រើ GFCI

នៅពេលដែលអ្នកប្រើប្រាស់ឧបករណ៍ចល័ត និងបន្ថែមចំនួនឌុយ អ្នកត្រូវតែប្រើប្រាស់ GFCI។



រូបភាព៦២ ប្រើ GFCI

## ជៀសវាងពីខ្សែដែលមានអនុភាពធំតាមបណ្តាញអាកាស

ចូរប្រុងប្រយ័ត្នឲ្យបានខ្ពស់ កុំប៉ះពាល់ខ្សែភ្លើង ឬនៅជិតខ្សែបណ្តាញដែលមានអនុភាពធំតាមបណ្តាញអាកាស។ អ្នកធ្វើការនៅជិតខ្សែបណ្តាញដែលមានអនុភាពធំតាមបណ្តាញអាកាស លើសពីពាក់កណ្តាលដែលទទួលរងការឆក់ដោយចរន្តអគ្គិសនី។ ជៀសវាងទីតាំងរបស់អ្នកនៅពេលដែលអ្នកកំពុងធ្វើការនៅក្នុងប្រអប់ជាមួយឡានស្ទូច ហើយនៅជិតខ្សែបណ្តាញដែលមានអនុភាពធំតាមបណ្តាញអាកាស(អង្គធាតុចម្លងខ្លះដែលអ្នកកាន់នៅក្នុងដៃ)។ អ្នកគួរតែស្ថិតនៅទីតាំងមួយដែលមានសុវត្ថិភាព គឺគម្លាតចាប់ពី ៣ម៉ែត្រឡើងទៅពីខ្សែបណ្តាញដែលមានអនុភាពធំ តាមបណ្តាញអាកាស។

គួរតែមានឡានមួយទុកសម្រាប់ដំណើរការនៅលើបណ្ដាញខ្សែដែលមានអនុភាពធំ។ ប្រើប្រាស់ឡានទ្រុង ឡានស្ទូច និងឡានដែលអាចលើករបស់បាន និងមានការទំនាក់ទំនង ជាមួយខ្សែបណ្ដាញមានអនុភាពធំតាមបណ្ដាញអាកាសបានមិនមែនអ្នក។ ប្រសិនបើអ្នកកាន់ឧបករណ៍ ហើយប៉ះពាល់ជាមួយខ្សែបណ្ដាញអាកាសនោះ អ្នកនឹងទទួលរងការឆក់ដោយចរន្តអគ្គិសនី ហើយចរន្តអគ្គិសនីអាចសម្លាប់អ្នកបាន។ ប្រសិនបើអ្នកនៅក្នុងឡាន ឬនៅខាងក្រៅតែងតែដឹងថាអ្វីនឹងកំពុងកើតឡើងនៅលើខ្លួនរបស់អ្នក។

**ការប្រើប្រាស់ខ្សែ និងការធ្វើតំណខ្សែឲ្យបានត្រឹមត្រូវ**

- ជៀសវាងការលើសបន្ទុក ( មិនធ្វើឲ្យលើសបន្ទុកនៅលើសៀគ្វីណាមួយ )។
- តេស្ត GFCI ( ការធ្វើតេស្តទៅលើកុងតាក់លោតរបស់ GFCI )។
- ត្រួតពិនិត្យកុងតាក់ និងអ៊ីសូឡង់( ឧបករណ៍ និងគ្រឿងបរិក្ខារផ្សេងៗត្រូវតែដំណើរការយ៉ាងត្រឹមត្រូវ ហើយត្រូវត្រួតពិនិត្យឲ្យប្រាកដថាផ្នែកកុងតាក់ និងអ៊ីសូឡង់នៅមានគុណភាពល្អប្រសើរ )។
- ប្រើប្រាស់ឌុយមុខ៣ (ត្រូវតែប្រើប្រាស់ឌុយមុខ៣ ដែលមានមុខងារដូចជា៖ ខ្សែហ្វា ខ្សែណឺត និងខ្សែដី )។




រូបភាព៦៣ ឌុយមុខ៣

- ប្រើប្រាស់ចំនួនខ្សែឲ្យបានត្រឹមត្រូវ (ប្រសិនបើអ្នកចង់បន្ថែមខ្សែសម្រាប់ការប្រើប្រាស់នៅលើព្រី ឬលើសៀគ្វី សូមត្រួតពិនិត្យមើលមុខកាត់ខ្សែឲ្យបានត្រឹមត្រូវមុននឹងអ្នកសម្រេចចិត្តប្រើប្រាស់វា )។
- ពេលដកឌុយ កាន់ឌុយមិនមែនកាន់ខ្សែ (ពេលដែលអ្នកដកឌុយ បើអ្នកកាន់ខ្សែដក ធ្វើឲ្យខ្សែភ្លើងខាងក្នុង ប្រឈមនឹងការដាច់ ឬលាកអ៊ីសូឡង់ ជាហេតុនាំឲ្យមានការកើតទុសខ្សែភ្លើង )។
- ការធ្វើតំណខ្សែឲ្យបានត្រឹមត្រូវ ( ការធ្វើតំណមិនបានត្រឹមត្រូវ គឺជាឧបសគ្គនៃលំហូរចរន្ត )។
- ការប្រើប្រាស់ឌុយញី ឈ្មោល (ការប្រើប្រាស់ឌុយប្រភេទញី ឈ្មោល ឬប្រភេទឌុយដែលមានគន្លឹះដែលបានចាប់ភ្ជាប់គ្នាយ៉ាងតឹង ហើយដើម្បីបង្ការឌុយនោះ កុំឲ្យងាយសណ្ដក )។



រូបភាព៦៤ ប្រភេទឌុយញី ឈ្មោល

**ការប្រើប្រាស់ឧបករណ៍សម្ភារ និងតំហែទាំឲ្យបានត្រឹមត្រូវ**

ឧបករណ៍ សម្ភារ របស់អ្នកមានបេះដូងដូចយាន្តជំនិះរបស់អ្នកដែរ។ ឧបករណ៍ សម្ភារ ជួយអ្នកធ្វើការងារអ្នកជាមួយកម្រិតគុណភាពខ្ពស់។ ឧបករណ៍ សម្ភារ អាចជួយអ្នកធ្វើអ្វីគ្រប់បែបយ៉ាងបានផងដែរ។ ឧបករណ៍ សម្ភារ អាចជួបបញ្ហាខូចខាតបន្តិចបន្តួច ឬធេះខូចខាតទាំងស្រុង នេះក៏ជាមូលហេតុមួយប្រសិនបើអ្នក ប្រើប្រាស់ឧបករណ៍ សម្ភារ នោះមិនបានត្រឹមត្រូវទៅតាមមុខងាររបស់វានីមួយៗ។ ការតំហែទាំឧបករណ៍សម្ភារ និងគ្រឿងបរិក្ខារអគ្គិសនី គឺវាមានសារៈសំខាន់ខ្លាំងណាស់ចំពោះអ្នកប្រើប្រាស់។ ការតំហែទាំមិនបានត្រឹមត្រូវ អាចជាមូលហេតុធ្វើឲ្យឧបករណ៍សម្ភារកាន់តែមានសភាពចាស់ និងពិបាកប្រើប្រាស់ ហើយស្ថានភាពនោះបង្កើនការគ្រោះថ្នាក់កាន់តែខ្ពស់។ អ្នកត្រូវតែថែរក្សាឧបករណ៍សម្ភាររបស់អ្នកឲ្យបានស្អាត ល្អពីព្រោះឧបករណ៍ សម្ភារ អាចជួយអ្នក និងមិនឲ្យអ្នកទទួលរងការឈឺចាប់ ឬធក់ឡើយ។

**ការត្រួតពិនិត្យឧបករណ៍សម្ភារ មុនប្រើប្រាស់វា**

ធ្វើការត្រួតពិនិត្យមើលទៅលើតួឧបករណ៍ សម្ភារមានដូចជាៈ តួ ឬសំបក ឧបករណ៍ សម្ភារ មានការបែកស្នាមប្រេះ ឬមានការខូចខាតលើផ្នែកណាមួយ នៃឧបករណ៍សម្ភារនោះ ហើយត្រូវជៀសវាង នៃការជ្រាបចូលនូវសារធាតុដូចជាៈ ប្រេង សំណើម ធូលី និងសារធាតុរាវផ្សេងៗទៀត។ ឧបករណ៍ សម្ភារ ណាដែលខូចត្រូវជួសជុលវា ឬយកវាចេញ និងដាក់ផ្លាកសញ្ញាឲ្យបានត្រឹមត្រូវ។ ឧបករណ៍ សម្ភារដែលមានការខូចខាតមិនត្រូវយកវាមកប្រើប្រាស់ជាដាច់ខាត រហូតវាត្រូវបានជួសជុល និងបានតេស្តរួចរាល់។



រូបភាព៦៥ ការប្រើប្រាស់ឧបករណ៍មិនបានត្រួតពិនិត្យខ្សែ

## ឧទាហរណ៍

អ្នកធ្វើការបានឡើងលើជណ្ដើរដែលមានសារធាតុលោហៈដោយដៃរបស់គាត់កាន់ម៉ូទ័រស្វាន យកទៅប្រើប្រាស់នៅលើរន្ធ កម្ពស់ប្រហែល 1.5 ម៉ែត្រ។ នៅពេលដែលជនរងគ្រោះឡើងដល់កាំជណ្ដើរទី៣ គាត់បានទទួលរងការឆក់ដោយចរន្តអគ្គិសនី ហើយគាត់បានរងរបួសរហូតដល់ថ្នាក់បាត់បង់ជីវិត។ ការស៊ើបអង្កេត និងធ្វើការត្រួតពិនិត្យ ក៏បានទទួលលទ្ធផលថា ឌុយខ្សែដីរបស់ម៉ូទ័រ បានបាក់ដាច់ ហើយខ្សែដីនោះ មិនបានតភ្ជាប់ដល់ម៉ូទ័រស្វានទេ។ ស្របពេលនោះដែរ ខ្សែដីរបស់ម៉ូទ័របានធ្លាក់ចូលទៅភ្ជាប់ជាមួយខ្សែភ្លើង ( ហ្វា ) ព្រោះតែមានភាពទំនាក់ទំនងជាមួយខ្សែភ្លើង តាមរយៈ ចូលតាមខ្សែដីរបស់ម៉ូទ័រ ហើយតាមរយៈតួរបស់ម៉ូទ័រដែលបានប៉ះភ្ជាប់ជណ្ដើរ។ ជាធម្មតាម៉ូទ័រគ្មានអ៊ីសូឡង់២ជាន់ទេ។

ដើម្បីជៀសវាងគ្រោះថ្នាក់ដល់បាត់បង់ជីវិតដូចនេះ សូមរក្សាការប្រុងប្រយ័ត្នៈ

- ត្រូវប្រើប្រាស់ GFCI ឬប្រើប្រាស់ឧបករណ៍សម្ភារដែលមានប្រព័ន្ធខ្សែដី និងភ្ជាប់ខ្សែដីជាមួយផ្ទៃដែលយើងធ្វើការជាមួយ។
- ប្រើប្រាស់ឧបករណ៍ឲ្យមានទម្លាប់ល្អដោយប្រើខ្សែដីការពារនៅពេលដែលមានការលេចធ្លាយចរន្តចេញមកក្រៅ និងមានសុវត្ថិភាពយូរអង្វែង។
- ត្រួតពិនិត្យឧបករណ៍សម្ភារ និងគ្រឿងបរិក្ខារអគ្គិសនីជារៀងរាល់ថ្ងៃ និងផ្លាស់ប្ដូរឧបករណ៍ណាដែលខូចគ្មានប្រសិទ្ធភាពពីកន្លែងប្រើប្រាស់ គឺជាវិធីដែលត្រឹមត្រូវបំផុត។



រូបភាព៦៦ គ្រោះថ្នាក់ដោយការដាច់ខ្សែដី

## ការប្រើប្រាស់ឧបករណ៍បានត្រឹមត្រូវ

ប្រើប្រាស់ឧបករណ៍ឲ្យបានត្រឹមត្រូវ និងទៅតាមគោលដៅនៃមុខងាររបស់ឧបករណ៍សម្ភារ។ ការអនុវត្តន៍ដោយមានសុវត្ថិភាព និងដំណើរការទៅតាមការកំណត់របស់ឧបករណ៍សម្ភារនីមួយៗ។ ទោះបីជាយ៉ាងណាក៏ដោយនៅពេលដែលអ្នកធ្វើការនៅលើសៀគ្វីអគ្គិសនី ត្រូវតែប្រើប្រាស់ឧបករណ៍ សម្ភារ ជាមួយអ៊ីសូឡង់

ការពារដៃរបស់អ្នក។ កុំយកឧបករណ៍សម្ភារដើម្បីធ្វើការងារនៅលើសៀគ្វីអគ្គិសនីដែលមិនទាន់កាត់ផ្តាច់ចេញពីប្រភពឡើយ។ ត្រូវតែកាត់ផ្តាច់សៀគ្វីអគ្គិសនីចេញពីប្រភពមុនពេលដែលអ្នកចាប់ផ្តើមធ្វើការងារជាមួយវា។

## ការពារឧបករណ៍របស់អ្នក

ថែរក្សាឧបករណ៍ និងខ្សែភ្លើងរបស់អ្នកឲ្យនៅឆ្ងាយពីកន្លែងដែលមានកម្តៅប្រេង និងកន្លែងដែលមានកម្ទេចកម្ទីតូចៗ។ គ្រោះថ្នាក់អាចកើតចេញពីការខូចអ៊ីសូឡង់។ ប្រសិនបើមានឧបករណ៍សម្ភារ ឬខ្សែដែលកំពុងប្រើប្រាស់ កើនឡើងនូវកម្តៅ ត្រូវបញ្ឈប់ការប្រើប្រាស់វាភ្លាម។ ត្រូវរាយការណ៍ពីស្ថានភាពដែលបានកើតឡើងដល់ប្រធានក្រុម ឬទៅដល់អ្នកគ្រប់គ្រង។ ប្រសិនបើឧបករណ៍មានការជួសជុល ត្រូវប្រាកដថាឧបករណ៍បានឆ្លងកាត់ការធ្វើតេស្តមុននឹងយកវាទៅប្រើប្រាស់ឲ្យមានសុវត្ថិភាពក្នុងការងារ។ មិនត្រូវយោង ឬយួរឧបករណ៍ដោយកាន់ខ្សែរបស់ឧបករណ៍ឡើយ ព្រោះបង្កឲ្យមានការដាច់សរសៃខ្សែភ្លើងនៅផ្នែកខាងក្នុងរបស់ឧបករណ៍។



រូបភាព៦៧ ការធ្វើតេស្ត

- ការអនុវត្តឲ្យមានសុវត្ថិភាពទូទៅ

ចូរចងចាំថា ខ្សែដែលនៅក្នុងសៀគ្វី គឺមិនមានភាពត្រឹមត្រូវទេ (ប្រភពមួយ ប្រើគ្រឿងទទួល២ផ្សេងគ្នា)។ ខ្សែដែលនៅក្នុងសៀគ្វីមួយ អាចមានភាពពាក់ព័ន្ធជាមួយខ្សែភ្លើង (ហ្វា) ផ្សេងទៀត។ ពេលអ្នកធ្វើការទៅលើសៀគ្វីនោះ ហើយមាននរណាម្នាក់មកធ្វើអ្វីនៅទីនោះដែរ អ្នកគឺស្ថិតនៅក្នុងភាពមួយដែលគ្រោះថ្នាក់បំផុត។

## ស្លៀកសំលៀកបំពាក់ PPE ឲ្យបានត្រឹមត្រូវ

យើងធ្លាប់បានសិក្សារួចមកហើយ ចំពោះឯកសណ្ឋានសុវត្ថិភាព កាលពីមេរៀនមុនមក។ ប៉ុន្តែក្នុងចំណុចនេះ យើងនិយាយអំពីសុវត្ថិភាព និងបទដ្ឋានសុខភាព ។ សុវត្ថិភាព និងបទដ្ឋានសុខភាព បានតម្រូវឲ្យអ្នកប្រើប្រាស់នូវឯកសណ្ឋានសុវត្ថិភាព ដែលមានប្រសិទ្ធភាពការពារខ្លួនអ្នកក៏ដូចជាផ្នែកខ្លះៗ នៃរាងកាយរបស់អ្នកក្នុងពេលបំពេញការងារ។ ហើយឯកសណ្ឋាននោះមានដូចជាៈ



រូបភាព៦៨ ពាក់មួក



រូបភាព៦៩ ពាក់វ៉ែនតា



រូបភាព៧០ ស្បែកជើង ANSI

## ១.៤ ប្រភេទ និងវិធីប្រើប្រាស់ឧបករណ៍សុវត្ថិភាព

➢ **ការយល់ដឹងដ៏ត្រឹមត្រូវ អំពីឧបករណ៍សុវត្ថិភាព**

### ភាពចាំបាច់នៃឧបករណ៍សុវត្ថិភាព

ឧបករណ៍សុវត្ថិភាព គឺជាឧបករណ៍ដែលត្រូវប្រើប្រាស់សម្រាប់បំពាក់លើផ្នែកមួយ ឬផ្នែកទាំងមូលនៃរាងកាយ ដើម្បីទប់ស្កាត់ ឬកាត់បន្ថយឥទ្ធិពលនៃកត្តាបំពុល ឬបង្កគ្រោះថ្នាក់នៅក្នុងបរិស្ថានជុំវិញ។ ឧបករណ៍សុវត្ថិភាព ជួយទប់ស្កាត់ ឬកាត់បន្ថយកម្រិត និងអត្រាគ្រោះថ្នាក់នៅក្នុងការងារ ។





រូបភាព៧១ ឧបករណ៍សុវត្ថិភាព



- តើកត្តាបង្កឬមានគ្រោះថ្នាក់ នៅកន្លែងធ្វើការមានអ្វីខ្លះ?
  - កត្តាដែលបង្កឬមានគ្រោះថ្នាក់មានដូចជា សារធាតុរំលាយសរីរាង្គ ឧស្ម័ន លោហៈធ្ងន់ កាំរស្មី និងធូលីបង្កគ្រោះថ្នាក់ សម្លេង រំញ័រ។
- ហេតុអ្វីបានជាកត្តាដែលបង្ក និងមានគ្រោះថ្នាក់កើតឡើង?
  - កង្វះខាតបច្ចេកទេសក្នុងការព្រាងគម្រោង ការផលិត និងដំឡើងម៉ាស៊ីន ឬឧបករណ៍ បញ្ហាហិរញ្ញវត្ថុក្នុងការព្រាងគម្រោង ការផលិត និងដំឡើងម៉ាស៊ីនឬឧបករណ៍ ការធ្លាក់ចុះនៃសមត្ថភាព ឬកំហូចរបស់ម៉ាស៊ីនឬឧបករណ៍។
  - ភាពចាំបាច់នៃឧបករណ៍សុវត្ថិភាព៖ អត្ថិភាពនៃករណីកង្វះការការពារ ឬមិនអាចការពារអ្នកធ្វើការងារពីកត្តាបង្ក ឬមានគ្រោះថ្នាក់ត្រូវផ្តល់ និងកំហិតឲ្យប្រើប្រាស់ឧបករណ៍ការពារសុវត្ថិភាព ដើម្បីបង្ការករណីកង្វះការការពារដល់អ្នកធ្វើការងារ ត្រូវតែយល់ដឹងឲ្យបានច្បាស់អំពីលក្ខណៈ មុខងារ និងវិធីប្រើប្រាស់របស់ឧបករណ៍ការពារ សុវត្ថិភាព ទើបអាចការពារអាយុជីវិត និងទ្រព្យសម្បត្តិបាន។

## រាងកាយ និងកត្តាគ្រោះថ្នាក់




រូបភាព ៧២ រាងកាយ និងកត្តាគ្រោះថ្នាក់

## វិធីជ្រើសរើសឧបករណ៍សុវត្ថិភាព

ដើម្បីជ្រើសរើសឧបករណ៍សុវត្ថិភាព ដែលសមស្របទៅនឹងកន្លែងការងារ អ្នកត្រូវយល់ដឹងអំពីកត្តាខាងក្រោមនេះ៖



- ការវិភាគលើកត្តាមាន ឬបង្កគ្រោះថ្នាក់នៅកន្លែងការងារ
  - ស្រង់ស្ថិតិនៃអត្ថិភាពរបស់ឧស្ម័ន ធូលី សារធាតុគីមី សម្លេង កាំរស្មីគ្រោះថ្នាក់ អគ្គិសនីចរន្តថេរ អគ្គិសនីកម្រិតខ្ពស់ កង្វះអុកស៊ីសែន ហើយធ្វើការជ្រើសរើសឧបករណ៍សុវត្ថិភាពទៅតាមកត្តានីមួយៗ ជាក់លាក់។
- កម្រិតនៃកត្តាបង្ក ឬមានគ្រោះថ្នាក់
  - អ្នកត្រូវដឹងអំពីកម្រិតគ្រោះថ្នាក់នៃកត្តានីមួយៗ ។ កម្រិតនៃកត្តាមានឬបង្កគ្រោះថ្នាក់អាចដឹងបានតាមរយៈលទ្ធផលនៃវាយតម្លៃបរិស្ថានការងារ ហើយពេលខ្លះអ្នកគ្រប់គ្រងសុវត្ថិភាព និងសុខភាព ឬអ្នកអង្កេតការគ្រប់គ្រងអាចវាស់ស្ទង់ដោយផ្ទាល់ ។
- ការជ្រើសរើសទៅតាមចំនួនដងនៃការប្រើប្រាស់
  - ដើម្បីជ្រើសរើសឧបករណ៍សុវត្ថិភាពឲ្យបានត្រឹមត្រូវ អ្នកត្រូវដឹងអំពីចំនួនដងនៃការប្រើប្រាស់របស់ឧបករណ៍នីមួយៗ ។ បើសិនជាឧករណ៍ត្រូវការប្រើប្រាស់ជាញឹកញាប់ អ្នកត្រូវជ្រើសរើសឧបករណ៍ដែលមានភាពធន់ និងអាចប្រើប្រាស់ក្នុងរយៈពេលវែង ដែលអាចឲ្យអ្នកចំណេញប្រាក់ ហើយក៏អាចការពារអ្នកធ្វើការបានដោយត្រឹមត្រូវ ។ បើសិនការងារមានការទាក់ទងនឹងធូលីហុយជាបណ្តោះអាសន្ន អ្នកអាចប្រើប្រាស់ម៉ាសការពារធូលីបែបចម្រោះខ្យល់ ប៉ុន្តែបើការងារមានរយៈពេលវែង អ្នកគួរតែប្រើប្រាស់ម៉ាសការពារធូលីបិទពាក់កណ្តាលមុខ ឬបិទពេញមួយផ្ទៃមុខ។



- ការកំណត់ដែននៃប្រសិទ្ធភាពការពារ

  អ្នកត្រូវកំណត់ដែន នៃប្រសិទ្ធភាពការពារ ដោយយោងទៅតាមបរិស្ថានការងារៈ

  - នៅក្នុងកន្លែងការងារដែលទាក់ទងនឹងការកិនវត្ថុ ការប្រើប្រាស់ម៉ាសការពារធូលីទូទៅ និង វ៉ែនតាការពារធូលី អាចទទួលយកបាន ប៉ុន្តែបើសិនជាអ្នកប្រើប្រាស់ម៉ាសការពារធូលីបិទពេញមួយផ្ទៃមុខវានឹងអាចជួយពង្រីកដែននៃប្រសិទ្ធភាពការពារបាន ។
  - នៅក្នុងកន្លែងការងារ ដែលទាក់ទងនឹងម៉ាស៊ីនការប្រើប្រាស់វ៉ែនតាសុវត្ថិភាពធម្មតាអាចទទួលយកបាន ប៉ុន្តែបើសិនជាអ្នកប្រើប្រាស់របាំងមុខសុវត្ថិភាព ដែលអាចគ្របដណ្តប់ផ្ទៃមុខទាំងមូលបាន វានឹងកាន់តែប្រសើរ ។

**ការពិនិត្យភាពគ្រោះថ្នាក់ មុនពេលជ្រើសរើសឧបករណ៍សុវត្ថិភាព**

ចុះត្រូវធ្វើយ៉ាងដូចម្តេចចំពោះគ្រោះថ្នាក់ដែលនៅក្រៅដែនប្រសិទ្ធភាពការពារ ? អ្នកត្រូវពិនិត្យមើលភាពគ្រោះថ្នាក់ ថាតើស្ថិតនៅក្រៅដែនការពារឬទេ ។ នៅក្នុងកន្លែងការងារដែលទាក់ទងនឹងអាស៊ីតសុលផួរិច បើសិនជាអាស៊ីតត្រូវរក្សាកំហាប់ជាក់លាក់មួយ អ្នកអាចប្រើប្រាស់ម៉ាសការពារជាតិពុល សម្រាប់អាស៊ីតសុលផួរិច ។ ប៉ុន្តែសម្រាប់ការងារដែលអាចមាន គ្រោះថ្នាក់ទាក់ទងនឹងកម្រិតអាស៊ីតខ្ពស់ ដោយសារការលេចចេញនៃអាស៊ីតមានកម្រិតខ្ពស់ដោយសារការលេចចេញក្នុង រយៈពេលខ្លី ដូចជាការជួសជុលបំពង់បង្ហូរអាស៊ីត អ្នកត្រូវតែប្រើប្រាស់ម៉ាសផ្គត់ផ្គង់ខ្យល់ ឬម៉ាសផ្តល់អុកស៊ីសែន ។

តើត្រូវធ្វើដូចម្តេចចំពោះគ្រោះថ្នាក់ដោយសារកង្វះអុកស៊ីសែន ? អ្នកត្រូវពិនិត្យថាតើនៅកន្លែងការងារមានគ្រោះថ្នាក់ដោយសារកង្វះអុកស៊ីសែនដែឬទេ ។ នៅក្នុងកន្លែងដែលមានអុកស៊ីសែនគ្រប់គ្រាន់ អ្នកគ្រាន់តែប្រើម៉ាសការពារធូលី ឬម៉ាសការពារខ្យល់ពុល ។ ប៉ុន្តែជាគ្រោះថ្នាក់កង្វះអុកស៊ីសែនក្រោម ១៨% អ្នកត្រូវប្រើប្រាស់ម៉ាសផ្គត់ផ្គង់ខ្យល់ ឬម៉ាសផ្តល់អុកស៊ីសែន ។

## ករណីយុទ្ធសាស្ត្រទាក់ទងនឹងការប្រើប្រាស់



**ពិការត្រចៀកដោយសារសម្លេង និងការប្រើប្រាស់ប្រដាប់ញាត់ត្រចៀក**

- ការទាមទារសំណងពីក្រុមហ៊ុន ក្រោយទទួលបានការកាត់ក្តីថា ការពិការត្រចៀកដោយសម្លេងគឺជាជម្ងឺកើតដោយសារការងារ ។
- តុលាការកំពូលទទួលស្គាល់ថាអ្នកធ្វើការមានកំហុស ៦០% ដោយសារការមិនប្រើប្រាស់ប្រដាប់ញាត់ត្រចៀក ។



**ការធ្លាក់ពីលើកន្លែងខ្ពស់ក្នុងពេលកំពុងបំពេញការងារ និងការប្រើប្រាស់ខ្សែក្រវ៉ាត់សុវត្ថិភាព**

- ការធ្លាក់ពីកន្លែងដែលមានកម្ពស់ ៨ម៉ែត្រ នៅក្នុងពេលបំពេញការងារ
- អ្នកធ្វើការទទួលកំហុស ៤០% ដោយសារតែមិនប្រើប្រាស់ខ្សែក្រវ៉ាត់សុវត្ថិភាព ។



**ការបើកម៉ូតូ និងការប្រើប្រាស់មួកសុវត្ថិភាព**

- គ្រោះថ្នាក់ដោយសារឡានបុកពីក្រោយ នៅពេលកំពុងតែបើកម៉ូតូ
- អ្នកបើកម៉ូតូមានកំហុស ២០% ដោយសារតែមិនបានប្រើប្រាស់មួកសុវត្ថិភាព ។

## ប្រភេទនៃឧបករណ៍សុវត្ថិភាព និងវិធីប្រើប្រាស់

### ប្រភេទនៃឧបករណ៍សុវត្ថិភាព

ឧបករណ៍សុវត្ថិភាព ដែលត្រូវបានកំណត់ដោយសាជីវកម្មសាធារណៈ ដើម្បីសុខភាពនិងសុវត្ថិភាព មានដូចខាងក្រោម៖




រូបភាព ៧៣ ប្រភេទនៃឧបករណ៍សុវត្ថិភាព

## កិច្ចការដែលត្រូវការឧបករណ៍សុវត្ថិភាព

សាជីវកម្មសាធារណៈដើម្បីសុខភាពនិងសុវត្ថិភាព បានកំណត់អំពីឧបករណ៍សុវត្ថិភាព សម្រាប់អ្នកធ្វើការងារ ដែលមានគ្រោះថ្នាក់ ដូចខាងក្រោម៖



| | |
|---|---|
| • កិច្ចការដែលអាចមានរបស់ធ្លាក់លើ ឬរបស់ហោះបុកអ្នកធ្វើការ និងអ្នកធ្វើការអាចធ្លាក់ពីកន្លែងខ្ពស់ | មួកសុវត្ថិភាព |
| • កិច្ចការដែលអាចបង្កឲ្យមានរបស់ធ្លាក់លើ ឬគៀបអ្នកធ្វើការ ឬឆក់អគ្គិសនី | ស្បែកជើងសុវត្ថិភាព |
| • កិច្ចការដែលមានសម្លេងខ្លាំង សម្លេងប៉ះទង្គិច | ឧបករណ៍ការពារត្រចៀក |
| • កិច្ចការលើកដាក់ទំនិញនៅកន្លែងដែលមានធូលីច្រើន ដូចជានៅកំពង់ផែ | ម៉ាសការពារធូលី |
| • កិច្ចការដែលត្រូវបង្កើត ឬប្រើប្រាស់សារធាតុពុល ដែលត្រូវបានអនុញ្ញាត | ម៉ាសការពារធូលី<br>ឬម៉ាសការពារសារធាតុពុល |
| • កិច្ចការដែលមានធូលីច្រើន | ឧបករណ៍ការពារប្រព័ន្ធដកដង្ហើម |
| • កិច្ចការជួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះ នៅក្នុងកន្លែងបិទជិត<br>• កិច្ចការបន្សារនៅក្នុងកន្លែងដែលមិនមានខ្យល់ចេញចូលគ្រប់គ្រាន់ ដូចជាក្នុងស៊ីទែន ឡ និងប៉មប្រតិកម្ម<br>• កិច្ចការដេក ឬតភ្ជាប់បំពង់ឧស្ម័ន នៅក្នុងកន្លែងដែនមិនមានខ្យល់ចេញចូលគ្រប់គ្រាន់ ដូចជាបន្ទប់ក្រោមដី ឬរន្ធក្រោមដី<br>• កិច្ចការវាស់ស្ទប់កំហាប់នៃឧស្ម័នអុកស៊ីសែន នៅក្នុងកន្លែងការងារដែលបិទជិត កិច្ចពិនិត្យមើលឧបករណ៍វាស់ស្ទង់ និងឧបករណ៍ប្តូរខ្យល់ កិច្ចការត្រួតពិនិត្យឬដឹកនាំឲ្យអ្នកធ្វើការពាក់ម៉ាសការពារប្រព័ន្ធដង្ហើម<br>• កិច្ចការវាស់ស្ទង់កំហាប់នៃអុកស៊ីសែន របស់អ្នកអង្កេតការគ្រប់គ្រងជាមុន នៅក្នុងកន្លែងដែលបិទជិត | ម៉ាស់ផ្គត់ផ្គង់ខ្យល់ |



| | |
|---|---|
| • កិច្ចការទាក់ទងនឹងសារធាតុគីមីសារីរាង្គ ក្នុងរយៈពេលខ្លីនៅក្នុង កន្លែងពិសេសសម្រាប់ការងារសារធាតុគីមីសរីរាង្គ (ឡាន កប៉ាល់ ស៊ីទែន រូងផ្លូវ រូងជីកយករ៉ែ រូងដី បំពង់បង្ហូរល្បាប់ភក់ បំពង់ទឹកឬផ្លូវទឹក ដែលមិនមានខ្យល់ចេញចូលគ្រប់គ្រាន់ )<br>• កិច្ចការដូចជាការលាងសម្អាត ការលាបថ្នាំនៅក្នុងស៊ីទែនដែលធ្លាប់ផ្ទុកសារធាតុគីមីសរីរាង្គ (ស៊ីទែន ដែលមិនមានបញ្ហាលេចឧស្ម័ន)<br>• កិច្ចការទាក់ទងនឹងសារធាតុគីមីសរីរាង្គ នៅក្នុងកន្លែងពិសេសសម្រាប់កិច្ចការសារធាតុគីមីសរីរាង្គ<br>• កិច្ចការទាក់ទងនឹងសារធាតុគីមីសរីរាង្គ នៅក្នុងកន្លែងដែលបិទជិត ឬមិនមានបំពាក់បំពង់ផ្សែងនៅតាមកន្លែងនីមួយ<br>• កិច្ចការទាក់ទងនឹងវត្ថុ ដែលអាចភាយឧស្ម័ន នៅក្នុងឧបករណ៍ឬខ្យល់ នៃកន្លែងការងារសារធាតុគីមីសរីរាង្គ ។<br>• កិច្ចការអភិវឌ្ឍឧបករណ៍បិទប្រភពឧស្ម័នសារធាតុសរីរាង្គ នៅក្នុងកន្លែងប្រើប្រាស់សារធាតុគីមីសរីរាង្គ (លើកលែងកន្លែងដែលបានសម្អាតសារធាតុគីមីសរីរាង្គ) | ម៉ាសផ្គត់ផ្គង់ខ្យល់ ឬម៉ាសការពារសារធាតុពុល |
| • កិច្ចការនៅក្នុងកន្លែងបិទជិតដែលអ្នកធ្វើការអាចធ្លាក់ ដោយសារតែកង្វះអុកស៊ីសែន ឬឧស្ម័នពុល | ខ្សែក្រវ៉ាត់សុវត្ថិភាព ម៉ាសផ្គត់ផ្គង់ខ្យល់ |
| • កិច្ចការបំបាត់សារធាតុសរសៃ | ម៉ាសការពារធូលី (កម្រិតពិសេស) ម៉ាសផ្គត់ផ្គង់ខ្យល់ ឧបករណ៍ការពារប្រព័ន្ធដង្ហើមដោយប្រើម៉ូទ័រ វ៉ែនឧបករណ៍ការពារប្រព័ន្ធដង្ហើម ដោយប្រើអគ្គិសនី ពបិទជិតខ្លួនប្រាណ ស្រោមដៃសុវត្ថិភាព នឹងស្បែកជើងសុវត្ថិភាព |
| • កិច្ចការដែលអាចគ្រោះថ្នាក់ ដោយសាររបស់បែកខ្ចាយ | វ៉ែនតាសុវត្ថិភាព |



| | |
|---|---|
| • កិច្ចការបន្សារដែលអាចមានបែកផ្កាភ្លើង ឬរបស់បែកខ្ចាយ | របាំងមុខសុវត្ថិភាព |
| • កិច្ចការដែលអាចមានគ្រោះថ្នាក់ឆក់អគ្គិសនី<br>• កិច្ចការទាក់ទងនឹងអគ្គិសនី នៅក្នុងបន្ទប់បិទជិតដូចជា រូងដី និងបន្ទប់ក្រោមដីដែលមានលេចចរន្តអគ្គីសនី<br>• កិច្ចការទាក់ទងនឹងអគ្គិសនី ដែលប្រើប្រាស់ឧបករណ៍ឧបករណ៍ចល័ត<br>• កិច្ចការដែលទាក់ទងនឹងចរន្តអគ្គិសនី ដោយប្រើចរន្តថេរ ឬធ្វើការនៅក្នុងកន្លែងក្បែរនោះ<br>• កិច្ចការបង្កើតឬដំណើរការឧបករណ៍ រថយន្តនៅក្នុងតំបន់ដែលមានចរន្តអគ្គិសនី | ឧបករណ៍ការពារចរន្តអគ្គិសនី |
| • កិច្ចការដែលមានគ្រោះថ្នាក់ផ្ទុះ ឬអគ្គីភ័យ ដោយសារតែចរន្តថេរឆ្លងកាត់ខ្លួនមនុស្ស | ស្បែកជើងសុវត្ថិភាពដើម្បីបង្ការការឆ្លងចរន្តថេរ សម្លៀកបំពាក់ការពារចរន្តថេរ |
| • កិច្ចការដែលមានគ្រោះថ្នាក់ដោយការរងរបោះដោយសារកម្ដៅខ្ពស់ ឬជម្ងឺហត់ដោយសារកម្ដៅ<br>• កិច្ចការទាក់ទងនឹងរបស់ដែលមានកម្ដៅខ្ពស់ដ៏ច្រើន ឬនៅក្នុងកន្លែងដ៏ក្ដៅខ្លាំង | សម្លៀកបំពាក់ការពារកម្ដៅ |
| • កិច្ចការលើកដាក់ទំនិញ នៅក្នុងឃ្លាំងត្រី ដែលកកលឿនខ្លាំង ក្នុងសីតុណ្ហភាពក្រោម ១៨អង្សា<br>• កិច្ចការទាក់ទងនឹងរបស់ដែលមានកម្ដៅទាបដ៏ច្រើន ឬនៅក្នុងកន្លែងដ៏ត្រជាក់ខ្លាំង | មួកការពារត្រជាក់<br>សម្លៀកបំពាក់ការពារត្រជាក់<br>ស្បែកជើងការពារត្រជាក់<br>ស្រោមដៃការពារត្រជាក់ |
| • កិច្ចការទាក់ទងរំញ័រ | ឧបករណ៍ការពាររំញ័រ (ស្រោមដៃការពាររំញ័រ) |



| | |
|---|---|
| • កិច្ចការដែលប្រើប្រាស់សារធាតុពុលដូចជាដែលមានប្រតិកម្មនឹងស្បែក ឬសំណឹក<br>• កិច្ចការដែលទាក់ទងនឹងការបែកខ្ចាយនៃសារធាតុពុលដែលស្ថិតក្រោមការគ្រប់គ្រង (សារធាតុគីមីសរីរាង្គ ប្រភេទលោហធាតុ ប្រភេទអាស៊ីតឬបាស ប្រភេទឧស្ម័ន)<br>• ករណីប្រើប្រាស់សាធាតុពុល ដែលត្រូវបានអនុញ្ញាត | សម្លៀកបំពាក់ការជ្រៀបចូលស្រោមដៃសុវត្ថិភាព ស្បែកជើងសុវត្ថិភាពវ៉ែនតាសុវត្ថិភាព |
| • ករណីប្រើប្រាស់សារធាតុពុលដែលត្រូវបានហាមឃាត់ | សម្លៀកបំពាក់ការជ្រៀបចូល ស្រោមដៃសុវត្ថិភាព ម៉ាស់ការពារធូលី ម៉ាសការពារជាតិពុល និងឧបករណ៍ការពារប្រព័ន្ធដង្ហើមដែលមានធុងបន្សុទ្ធ |
| • កិច្ចការនៅក្នុងតំបន់ ដែលត្រូវបានបំពុលដោយជាតិវិទ្យុសកម្មក្នុងទម្រង់ជាកំទេច ឬអង្គធាតុរាវ | ឧបករណ៍ការពារប្រព័ន្ធដង្ហើម សម្លៀកបំពាក់សុវត្ថិភាព ស្រោមដៃសុវត្ថិភាពស្រោមស្បែកជើង មួកសុវត្ថិភាព |
| • កិច្ចការដែលអាចមានឈាមបាញ់ចេញ ឬសាចចេញ | វ៉ែនតាសុវត្ថិភាព ម៉ាសសុវត្ថិភាព |
| • កិច្ចការទាក់ទងនឹងឈាម ឬសារធាតុបំពុលឈាម | ស្រោមដៃសុវត្ថិភាព |
| • កិច្ចការដែលមានឈាមប្រឡាក់លើសម្លៀកបំពាក់ច្រើន ហើយប៉ះដល់ស្បែក | អៀមសុវត្ថិភាព |
| • កិច្ចការសម្អាត និងការថ្មែជាថ្មីឬជួសជុលម៉ាស៊ីនសម្អាតខ្យល់ | វ៉ែនតាសុវត្ថិភាព ម៉ាសការពារធូលី |
| • កិច្ចការនៅក្នុងកន្លែងដែលអាចគ្រោះថ្នាក់ធ្លាក់ពីកម្ពស់ ឬទៅជម្រៅលើសពី ២ម៉ែត្រ | ខ្សែក្រវ៉ាត់សុវត្ថិភាព |

## ការប្រើប្រាស់ឧបករណ៍សុវត្ថិភាព



- **មួកសុវត្ថិភាព**

ក. មុខងារការពារសំខាន់ៗរបស់មួកសុវត្ថិភាព

- ការការពារក្បាលរបស់អ្នកធ្វើការពីការធ្លាក់របស់លើ របស់ហោះមកបុក និងការប៉ះទង្គិចមុខងារជួយការពារក្បាលរបស់អ្នក។
- ធ្វើការតាមរយៈការកាត់បន្ថយឥទ្ធិពលទង្គិចពីខាងក្រៅ។
- ការបង្ការការឆក់អគ្គិសនី នៅពេលធ្វើកិច្ចការទាក់ទងនឹងអគ្គិសនី។





ខ. គ្រោះថ្នាក់ត្រូវបានបង្ការដោយប្រភេទមួក




បង្ការឬកាត់បន្ថយឥទ្ធិពល នៃការធ្លាក់ របស់លើឬរបស់ហោះមកបុក




បង្ការឬកាត់បន្ថយឥទ្ធិពល នៃការធ្លាក់ របស់លើឬរបស់ហោះមកបុក ឬការធ្លាក់ពីកន្លែងខ្ពស់




បង្ការឬកាត់បន្ថយឥទ្ធិពល នៃការធ្លាក់ របស់លើឬរបស់ហោះមកបុក ឬនិងបង្ការគ្រោះថ្នាក់ឆក់អគ្គិសនីនៅផ្នែកក្បាល




បង្ការ ឬកាត់បន្ថយឥទ្ធិពល នៃការធ្លាក់ របស់លើឬរបស់ហោះមកបុក ឬការធ្លាក់ពីកន្លែងខ្ពស់ និងបង្ការគ្រោះថ្នាក់ឆក់អគ្គិសនីនៅផ្នែកក្បាល

*រូបភាព ៧៤ ប្រភេទមួកសុវត្ថិភាព*

គ. វិធីប្រើប្រាស់ និងគ្រប់គ្រង

- ពង្រីកឬបង្រួមទំហំឱ្យត្រូវតាមទំហំក្បាលរបស់អ្នកដោយបង្វិលវីសរបស់មួកមុននឹងពាក់ ។
- ក្រោយពេលពាក់មួក ត្រូវបិទគន្លឹះខ្សែចង្កាដើម្បីកុំឲ្យរបូត ។
- បើសិនជាផ្នែកនៃមួកត្រូវបានប៉ះទង្គិច ឬខូចទ្រង់ទ្រាយត្រូវបោះមួកចោល ។
- មិនត្រូវជុសឬលាងមួក ដោយប្រើសាធាតុសរីរាង្គ
- ប្រដាប់សម្រាប់ចងដូចជាខ្សែចង្កា ត្រូវបានផ្លាស់ប្តូរ ដោយសារតែវាជារបស់មិនប្រែប្រួលទ្រង់ទ្រាយ ឬត្រូវបានទទួលស្គាល់។

ឃ. វិធីពាក់មួកសុវត្ថិភាព






- **ស្បែកជើងសុវត្ថិភាព**

ក. មុខងារការពារសំខាន់ៗ របស់ស្បែកជើងសុវត្ថិភាព

- ការពារប្រអប់ជើង និងខ្នងប្រអប់ជើង ពីការធ្លាក់របស់ធ្ងន់លើ ឬគាបជាប់
- ការពារបាតជើងពីការមុតនឹងរបស់មុត
- បង្ការការឆក់អគ្គិសនី និងការឆ្លងចរន្តថេរ
- ការពារជើងពីសារធាតុគីមីគ្រប់ប្រភេទ





ខ.គ្រោះថ្នាក់ត្រូវបានបង្ការដោយប្រភេទស្បែកជើងនីមួយៗ



| | |
|---|---|
|  ស្បែកជើងសុវត្ថិភា<br>ពប្រភេទស្បែក | ការពារប្រអប់ជើងពីការធ្លាក់របស់លើ ឬបុកទង្គិច ឬមុតនឹងរបស់ |
|  ស្បែកជើងសុវត្ថិភាព<br>ប្រភេទជ័រ | ការពារប្រអប់ជើងពីការធ្លាក់របស់លើ ឬបុកទង្គិច ឬមុតនឹងរបស់ និងធន់នឹងទឹក និងសារធាតុគីមី |
|  ស្បែកជើងការ<br>ពារចរន្តចរ | ការពារប្រអប់ជើងពីការធ្លាក់របស់លើ ឬបុកទង្គិច ឬមុតនឹងរបស់ និងបង្ការចម្លងចរន្តថេរទៅក្នុងខ្លួនមនុស្ស |
|  ស្បែកជើងការ<br>ពារខ្នងប្រអប់ជើង | ការពារប្រអប់ជើង និងខ្នងប្រអប់ជើងពីការធ្លាក់របស់លើ ឬបុកទង្គិច ឬមុតនឹងរបស់ |
|  ស្បែកជើងកា<br>រពារអគ្គិសនី | ការពារប្រអប់ជើងពីការធ្លាក់របស់លើ ឬបុកទង្គិច ឬមុតនឹងរបស់ និងបង្ការការឆក់ដោយចរន្តអគ្គិសនីទាប |
|  ស្បែកជើងក<br>វែងការពារអគ្គិសនី | ការពារការឆក់ដោយចរន្តអគ្គិសនីខ្ពស់ និងការពារការជ្រៀបទឹក |



គ. បំណែងចែកកន្លែងប្រើប្រាស់ទៅតាមកម្រិត

> ការប្រើប្រាស់សម្រាប់កិច្ចការធន់ធ្ងន់

- កន្លែងកែច្នៃ ឬផលិតវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មរ៉ែ សំណង់ និងរ៉ែដែក មានការប្រើប្រាស់ ឬដឹកជញ្ជូនដែក មានការដឹកជញ្ជូនវត្ថុធ្ងន់សម្រាប់ឧស្សាហកម្មសំណង់ មានការផលិតរបស់ធន់ធ្ងន់ និងអាចមានការមុតនឹងរបស់។

> ការប្រើប្រាស់សម្រាប់កិច្ចការធន់មធ្យម

- កន្លែងដែលមានការផលិតដោយដៃនូវសម្ភារៈសម្រាប់ឧស្សាហកម្មម៉ាស៊ីន ឧស្សាហកម្មផលិតដែក ការងារដឹកជញ្ជូន ឧស្សាហកម្មសំណង់ កន្លែងលក់រថយន្ត កន្លែងធ្វើការទូទៅដែលទាក់ទងនឹងការផលិត និងដឹកជញ្ជូនម៉ាស៊ីន ដែលអាចមានគ្រោះថ្នាក់មុតនឹងរបស់។

> ការប្រើប្រាស់សម្រាប់កិច្ចការធន់ស្រាល

- កន្លែងការងារធន់ស្រាល ដែលអាចគ្រោះថ្នាក់មុតនឹងរបស់ ដូចជាកន្លែងតម្រៀប លោហៈធាតុ ផ្គុំផលិតផលអគ្គិសនី តម្រៀបផលិតផលជាតិគីមី ដំណើរការឧបករណ៍ប្រតិកម្ម និងឧស្សាហកម្មផលិត ចំណីអាហារ។

ឃ. វិធីប្រើប្រាស់ និងគ្រប់គ្រង

- មិនត្រូវប្រើស្បែកជើងការពារចរន្តចេរ នៅកន្លែងដែលមានគ្រោះថ្នាក់ធក់អគ្គិសនីឡើយ។

- ស្បែកជើងសុវត្ថិភាពមិនត្រូវមានការខូតខាត ឬខូចទ្រង់ទ្រាយ។ ជាពិសេសមិនត្រូវពាក់នៅពេលខូចអ័ក្សខាងក្រោយ ។

- បើសិនជាមានប្រហោង ឬហែកនៅស្បែកជើងការពារអគ្គិសនី និងស្បែកជើងកវែងការពារអគ្គិសនីត្រូវតែបោះចោលជាបន្ទាន់។

- ត្រូវរក្សាផ្នែកខាងក្នុងស្បែកជើងឲ្យនៅស្ងួតជានិច្ច។

- សម្រាប់ស្បែកជើងសុវត្ថិភាពប្រភេទស្បែកមិនត្រូវឲ្យសើមឡើយ។

- បើសិនជាស្បែកជើងសុវត្ថិភាពប្រឡាក់នឹងសារធាតុគីមី ត្រូវលាងចេញនឹងទឹក ហើយហាលឲ្យស្ងួត ។

- ស្រោមដៃសុវត្ថិភាព





ក. ស្រោមដៃសុវត្ថិភាព

- មុខងារការពារសំខាន់ៗ របស់ស្រោមដៃសុវត្ថិភាព។
- បង្ការការឆក់អគ្គិសនី សម្រាប់កិច្ចការទាក់ទងនឹងអគ្គិសនី។
- ការពារប្រអប់ដៃពីសារធាតុគីមីគ្រប់ប្រភេទ។

ខ. គ្រោះថ្នាក់ត្រូវបានបង្ការតាមប្រភេទស្រោមដៃនីមួយៗ




គ. កម្រិត និងស្តង់ដាការជ្រើសរើស

- ត្រូវតែត្រូវនឹងកម្រិតប្រើប្រាស់ និងប្រភេទកិច្ចការ
- ស្រោមដៃការពារអគ្គិសនីចរន្តខ្ពស់ មានកម្រិតចាប់ពី 00 ទៅ៤ ។ លេខកាន់តែខ្ពស់ស្រោមដៃកាន់តែក្រាស់ ហើយមានសមត្ថភាពការពារចរន្តអគ្គិសនីបានកាន់តែខ្ពស់ដែរ។

- ស្រោមដៃសុវត្ថិភាពការពារសារធាតុគីមី មានកម្រិតពី ១ ទៅ៦ ហើយលេខកាន់តែខ្ពស់រយៈពេលការពារកាន់តែវែង និងមានសមត្ថភាពការពារកាន់តែខ្លាំងដែរ។

- ពិនិត្យមើលសញ្ញាការពារសារធាតុគីមីនៅខាងឆ្វេង នៃស្រោមដៃសុវត្ថិភាពការពារសារធាតុគីមី។

- ពិនិត្យមើលថាសមត្ថភាពការពាររបស់ស្រោមដៃសុវត្ថិភាពត្រូវនឹងវត្ថុដែលប្រើប្រាស់ដែរឬទេ។

- បើសិនជាសារធាតុគីមីដែលកំពុងប្រើប្រាស់ និងសារធាតុគីមីដែលបានបញ្ជាក់ មិនដូចគ្នា សូមទាក់ទងទៅកាន់ក្រុមហ៊ុនផលិតផល ដើម្បីសុំព័ត៌មាន និងផ្លាស់ប្តូរព័ត៌មានឲ្យបានត្រឹមត្រូវ។



រូបភាព ៧៥ និមិត្តសញ្ញាសារធាតុគីមី

ឃ. វិធីប្រើប្រាស់ និងគ្រប់គ្រង

- មុនយកប្រើប្រាស់ ត្រូវពិនិត្យថាស្រោមដៃមានប្រហោង ឬរហែកឬទេ។ បើសិនជាមានត្រូវបោះចោលជាបន្ទាន់។

- ស្រោមដៃការពារអគ្គិសនីត្រូវស្ងួតគ្រប់ពេល ។

- បើសិនជាស្រោមដៃការពារអគ្គិសនី ដែលខូចដោយសារម៉ាស៊ីន សារធាតុគីមី កម្តៅ អ្នកត្រូវតែបោះវាចោលជាបន្ទាន់ ។

- ស្រោមដៃការពារអគ្គិសនីត្រូវតែប្រើប្រាស់ នៅក្នុងដែនប៉ូតង់ស្យែលអគ្គិសនី ដែលបង្ហាញនៅលើផលិតផល។

- ស្រោមដៃការពារអគ្គិសនីងាយនឹងខូច ដោយសារតែជាតិប្រេង សាំង អាស៊ីត ឬបាស ដូចនេះមិនត្រូវឲ្យស្រោមដៃប៉ះនឹងរបស់ទាំងនោះឡើយ។



## ឯកសណ្ឋានសុវត្ថិភាព

ដើម្បីធ្វើការងារជាមួយចរន្តអគ្គិសនីឲ្យមានសុវត្ថិភាព គឺតម្រូវឲ្យអ្នកទាំងអស់គ្នាត្រូវមានការស្លៀកពាក់ឯកសណ្ឋានឲ្យត្រឹមត្រូវមុនពេលចូលធ្វើការងារ ដើម្បីធានានូវសុវត្ថិភាពការងារផ្ទាល់ខ្លួន និងអ្នកដទៃផងដែរ។ ដូច្នេះ ឯកសណ្ឋានសុវត្ថិភាពដែលអ្នកត្រូវមានដូចដែលបានបង្ហាញនៅខាងក្រោម៖



រូបភាព ៧៦ ឯកសណ្ឋានត្រូវបំពេញការងារ

- **មួកសុវត្ថិភាព៖** សម្រាប់ការពារសុវត្ថិភាពក្នុងការដ្ឋានដែលចាំបាច់ត្រូវតែមាន គឺដើម្បីការពារទៅនឹងការប៉ះទង្គិច និងវត្ថុរឹងផ្សេងៗធ្លាក់លើ។



រូបភាព ៧៧ មួកសុវត្ថិភាព

- **ស្បែកជើងសុវត្ថិភាព៖** មានតួនាទីយ៉ាងសំខាន់សម្រាប់ការពារជើងយើងមិនឲ្យគ្រោះថ្នាក់នៅពេលដើរ ជាន់លើឧបករណ៍ដែលមុតស្រួច ឬការពារនឹងឧបករណ៍ដែលធ្ងន់ៗធ្លាក់ពីលើជើងរបស់យើង និងជាអ៊ីសូឡង់សម្រាប់ការពារមិនឲ្យមានលំហូរចរន្តចូលទៅក្នុងដីដែលការពារមនុស្សមិនឲ្យទទួលរងនឹងការឆក់ដោយសារអគ្គិសនីបាន។



រូបភាព ៧៨ ស្បែកជើងសុវត្ថិភាព

- **ស្រោមដៃសុវត្ថិភាព៖** មានពីរប្រភេទ គឺធ្វើអំពីស្បែក និងធ្វើអំពីកៅស៊ូដែលមិនអាចចម្លងចរន្តអគ្គិសនី។ វាមានតួនាទីការពារមនុស្សឲ្យរួចផុតពី ការឆក់ដោយអគ្គិសនី នៅពេលមនុស្សប៉ះជាមួយនឹងអង្គធាតុចម្លង ពេលដែលមានចរន្តឆ្លងកាត់។



រូបភាព ៧៩ ស្រោមដៃសុវត្ថិភាព

- **វ៉ែនតាសុវត្ថិភាព៖** គឺសម្រាប់ការពារភ្នែករបស់យើង ដើម្បីទប់ទល់នឹងការគ្រោះថ្នាក់ដែលបណ្តាលមកពីការហើរធូលី ចំហាយ និងកម្ទេចកម្ទីមកប៉ះនឹងភ្នែក។ ហើយព្រមទាំងអាចប្រឆាំងនឹងកាំរស្មីស្វាយអ៊ុលត្រា ដែលកើតចេញពីចរន្តអគ្គិសនី ដែលហៅថាផ្កាភ្លើង ឬធ្នូចរន្ត។



រូបភាព ៨០ វ៉ែនតាសុវត្ថិភាព

- **ខ្សែក្រវ៉ាត់សុវត្ថិភាព៖** ជាអ្នកបច្ចេកទេសអគ្គិសនី រាល់ពេលយើងបំពេញការងារនៅលើទីខ្ពស់នោះ អាចនឹងប្រឈមមុខនឹងការឆក់ចរន្តអគ្គិសនី ឬក៏ការរអិលជើងធ្លាក់ពីទីខ្ពស់ ដូច្នេះយើងត្រូវប្រើខ្សែក្រវ៉ាត់សុវត្ថិភាពដើម្បីការពាររាង្គកាយ និងអាយុជីវិត។



រូបភាព ៨១ ខ្សែក្រវ៉ាត់សុវត្ថិភាព

- **ខ្សែក្រវ៉ាត់សុវត្ថិភាព**
- **វ៉ែនតាសុវត្ថិភាព**
- **របាំងមុខសុវត្ថិភាព**
- **ឧបករណ៍ការពារសម្លេង**

## ១.៥ សុវត្ថិភាពទៅលើការងារសំណង់ ចំណុចប្រុងប្រយ័ត្ននៃការការពារគ្រោះថ្នាក់

### ស្ថានភាពកើតមានគ្រោះថ្នាក់ពលកម្មទៅលើការងារសំណង់ស៊ីវិល

នៅក្នុងប្រទេសរបស់យើងការរងគ្រោះថ្នាក់ពលកម្មលើវិស័យសាងសង់គឺមាននិន្នាការធ្លាក់ចុះជាយូរយារណាស់មកហើយ។ ចំពោះសំណង់ស៊ីវិលក៏ដូចគ្នាដែរមាននិន្នាការធ្លាក់ចុះជាយូមកហើយ។ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះ ការគ្រោះថ្នាក់រហូតដល់ស្លាប់ក្នុងវិស័យសំណង់មានការឡើងចុះ ហើយគ្រោះថ្នាក់ពលកម្មក្នុងការងារសំណង់ស៊ីវិលប៉ុន្មានឆ្នាំចុងក្រោយនេះ គ្មានការធ្លាក់ចុះសោះ ។ នៅឆ្នាំ១៩៩៣ ក្នុងផ្នែកសំណង់ទាំងអស់ ចំនួននៃអ្នកគ្រោះថ្នាក់ស្លាប់ បើប្រៀបធៀបនឹងឆ្នាំចាស់ គឺធ្លាក់ចុះ ៤ ភាគរយ។ ក្នុងផ្នែកការងារសំណង់ស៊ីវិលចំនួនអ្នកស្លាប់មាន ៤៦៩ករណី បើប្រៀបធៀបនឹងឆ្នាំចាស់ គឺកើនឡើង៧,៣ ភាគរយ។ បើយើងមើលទៅលើប្រភេទផ្សេងៗទៀត គ្រោះថ្នាក់រហូតដល់ស្លាប់ក្នុងការងារសំណង់ស៊ីវិលមានគ្រោះថ្នាក់ដោយសារម៉ាស៊ីនសាងសង់ច្រើនជាងគេគឺ ១២១ ករណី គឺត្រូវជា ២៥,៨ ភាគរយ នៃគ្រោះថ្នាក់ទាំងអស់ ។ ក្រៅពីនេះគឺគ្រោះថ្នាក់ដោយសាររថយន្ត ៩៤ ករណី, គ្រោះថ្នាក់ដោយសារការធ្លាក់ ៧៩ ករណី, គ្រោះថ្នាក់ដោយសារធ្លាក់បាក់ដី ឬ ខ្សាច់ ៥៥ ករណី ។

នៅឆ្នាំ១៩៩៣គ្រោះថ្នាក់ធំដែលរួមបញ្ចូលទាំងការងាររងរបួសលើសពី ៣នាក់ក្នុងមួយម៉ោង ផងនោះក្នុងផ្នែកសំណង់ ទាំងអស់គឺកើតឡើង ៨១ករណី ដែលក្នុងនោះ ៣១នាក់ក្នុង ចំនោមអ្នករងរបួស ៤០៧នាក់ត្រូវបានស្លាប់បាត់បង់ជីវិត។ ក្នុងការងារសំណង់ស៊ីវិលក្រៅពីគ្រោះថ្នាក់ចរាចរណ៍ មានគ្រោះថ្នាក់ ១៧ករណីដែលក្នុងនោះមាន ១៩នាក់ ក្នុងចំណោមអ្នករងរបួស ៧១នាក់ ត្រូវស្លាប់បាត់បង់ជីវិត។ នៅខែកុម្ភៈការជួសជុលផ្លូវទឹកក្រោមដីមានគ្រោះថ្នាក់ការផ្ទុះបំពង់ឧស្ម័នដែលបណ្តាលឱ្យ ៤នាក់ក្នុងចំណោម ៥នាក់ នៃអ្នករងរបួសត្រូវស្លាប់។ នៅខែ កក្កដា មានគ្រោះថ្នាក់ធ្លាក់បាក់ទ្រូងស្ពានដែលបណ្តាលឱ្យ ៤នាក់ ក្នុងចំណោមអ្នករងរបួស ៩នាក់ត្រូវស្លាប់។ គ្រោះថ្នាក់ទាំងនេះហើយដែលបានធ្វើឱ្យសង្គមទាំងមូលមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះគ្រោះថ្នាក់ធំៗដែលកើតមានជាបន្តបន្ទាប់ ។

**ចំនុចបញ្ហាទៅលើការកើតមានគ្រោះថ្នាក់ពលកម្ម**

- **ចំនុចបញ្ហាដែលទាក់ទង និងប្រព័ន្ធគ្រប់គ្រងសុខភាពសុវត្ថិភាព**




ក)ដោយសារតែប្រព័ន្ធគ្រប់គ្រងសុខភាពសុវត្ថិភាពឱភាសកម្ម ពុំបានយកចិត្តទុកដាក់ចំពោះគ្រោះថ្នាក់ តូចៗ ការគ្រប់គ្រងសុខភាពសុវត្ថិភាព ឱភាសកម្មពុំមានលក្ខណៈគ្រប់គ្រាន់ ទើបបណ្តាលឱ្យមានគ្រោះថ្នាក់កើតមានជាញឹកញាប់ ។

ខ) ក្នុងការងារសំណង់តូចតាចគ្រោះថ្នាក់កើតឡើងជាញឹកញាប់ ។

- **ចំណុចបញ្ហាដែលទាក់ទងទៅនឹងការរក្សាឱ្យបានសុវត្ថិភាពនៃលំដាប់ថ្នាក់ផែនការ**

ក) ការបញ្ជាចេញពីថ្នាក់លើដោយពុំបានគិតពីសុវត្ថិភាពគឺមានករណីគ្រោះថ្នាក់កើតឡើង ។

ខ) ការត្រួតពិនិត្យការងារមុនទៅលើសុវត្ថិភាពនៃដំណើរការ ផែនការមិនបានដិតដល់គឺបណ្តាលឱ្យគ្រោះថ្នាក់កើតមានឡើង ។

គ).ការងារដែលស្ថិតក្នុងវត្ថុបំណងនៃសេចក្តីរាយការណ៍ របស់ផែនការគឺបង្កឱ្យមានគ្រោះថ្នាក់កើតឡើង ។

- **ចំណុចបញ្ហាដែលទាក់ទងទៅនឹងវិធានការ របស់អ្នកបញ្ជា និងអ្នករៀបចំការងារ**

ក).ដោយសារតែការរក្សាឱ្យមានសុវត្ថិភាព កន្លែងធ្វើការពុំបានដិតដល់បណ្តាលឱ្យកម្មករទទួលរងគ្រោះថ្នាក់។

ខ).ដោយសារតែការបំពានការងារអ្នកបញ្ជាប្រថុយបណ្តាលឱ្យ មានគ្រោះថ្នាក់កើតមានឡើង

គ).ដោយសារតែអ្នកម៉ៅការគ្មានចំណេះដឹងគ្រប់គ្រាន់អំពីលក្ខខណ្ឌ នៃការងារបណ្តាលឱ្យគ្រោះថ្នាក់កើតមានឡើង ។



ឃ).គ្រោះថ្នាក់ដែលបណ្តាលមកពីឡានស្ទូចរំកិល ម៉ាស៊ីនសាងសង់ដែលគ្មានការគ្រប់គ្រងឱ្យបានដិតដល់ពីក្រុមហ៊ុន ។

- **ចំណុចបញ្ហាដែលទាក់ទងទៅនឹងវិធានការរបស់អ្នកម៉ៅការ**

ការប្រព្រឹត្តទៅរបស់អ្នករៀបចំការងារទៅលើការគ្រប់គ្រងសុខភាពសុវត្ថិភាពគឺគ្មានគម្រោងការគ្រប់គ្រងចំពោះវិធានការការពារសុខភាពសុវត្ថិភាពរបស់អ្នកធ្វើការ ។

- **ចំណុចបញ្ហាដែលទាក់ទិនទៅនឹងវិចារណញ្ញាណនៃសុខភាព សុវត្ថិភាព របស់កម្មករនិងសហគ្រិន**

ក).គ្រោះថ្នាក់ដែលកើតឡើងដោយសារការសម្រេចចិត្តរបស់កម្មករមានបញ្ហា ។
ខ).ក្រោយពីគ្រោះថ្នាក់កើតមាននៅកន្លែងការងាររួចហើយ ការរៀបចំការពារគ្រោះថ្នាក់ពុំបានគ្រប់គ្រាន់ ។

- **ចំណុចបញ្ហាផ្សេងៗទៀត**

ក).ចំពោះការងារគ្រោះថ្នាក់ដែលប្រធានពុំបានយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចរបស់ខ្លួនបណ្តាលឱ្យមានគ្រោះថ្នាក់ធំៗកើតមានឡើង ។
ខ).គ្រោះថ្នាក់ធ្ងន់ៗដែលកើតមានឡើងដោយសារឡានស្ទូចរំកិល ។
គ).គ្រោះថ្នាក់ដែលកើតឡើងដោយសារបាក់ធ្លាក់នៃសំណង់គម្របបង្គោលទ្រង់ទ្រាយធំជាដើម។ ដោយយោងតាមចំណុចបញ្ហា ដែលបានរៀបរាប់ខាងលើ យើងនឹងលើកយកការប្រុងប្រយ័ត្ន និងវិធានការការពារគ្រោះថ្នាក់ពលកម្មសំខាន់ៗ មកនិយាយពេលក្រោយទៀត ។




**ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព**

**វិធានការ** :ដើម្បីឱ្យការគ្រប់គ្រងកន្លែងសំណង់ដំណើរការទៅមុខឱ្យមានប្រសិទ្ធភាព គឺអ្នកទទួលខុសត្រូវសុខភាព សុវត្ថិភាពឧិកាសកម្ម ត្រូវតែបង្កើននូវប្រព័ន្ធគ្រប់គ្រងសុខភាព សុវត្ថិភាពឧិកាសកម្ម ជាពិសេសចំពោះការងារដែលមានទំហំតូច និងមធ្យមដែលការគ្រប់គ្រងសុខភាព សុវត្ថិភាពឧិកាសកម្មរបស់ម្ចាស់ក្រុមហ៊ុនពុំបានជិតដល់ បណ្តាលឱ្យគ្រោះថ្នាក់កើតមានជាញឹកញាប់ ។ ដូច្នេះហើយពេលក្រោយការបំពេញបន្ថែមទៅលើប្រព័ន្ធគ្រប់គ្រងសុខភាពសុវត្ថិភាពឧិកាសកម្ម របស់ការងារដែលមានលក្ខណៈតូច និងមធ្យមគឺមានលក្ខណៈចាំបាច់ណាស់។ តាមប្រព័ន្ធគ្រប់គ្រងសុខភាពសុវត្ថិភាពឧិកាសកម្មការរៀបចំបុគ្គលិកតាមលំដាប់ថ្នាក់កន្លែង ធ្វើការរបស់ពួកអ្នកធ្វើអាជីវកម្មចាំបាច់រៀបចំតែងតាំងអ្នកគ្រប់គ្រងសុខភាពសុវត្ថិភាពកន្លែងការងារសាខាហាង ហើយដឹកនាំអាយបានច្បាស់ ។

**ការធានាឱ្យមានសុវត្ថិភាពទៅតាមកម្រិតផែនការ**

**វិធានការ** :ពង្រឹងការវាយតម្លៃលើគ្រោះថ្នាក់ជាមុន។ ផែនការដែលដាក់ចេញត្រូវធ្វើឱ្យពេញលេញ និងត្រឹមត្រូវ។ ក្នុងការងារសំណង់ដើម្បីឱ្យចៀសវាងផុតពីគ្រោះថ្នាក់ពលកម្ម យើងត្រូវយល់ដឹងពីឧបករណ៍សាងសង់ វិធីសាងសង់ត្រួតពិនិត្យផែនការពីកម្រិតសំណង់ រហូតដល់សុខភាពសុវត្ថិភាពការបង្កើតវិធានការចាំបាច់។ ដើម្បីអនុវត្តន៍អ្វីដែលបានរៀបរាប់នេះក្នុងក្រុមហ៊ុន ចាំបាច់ត្រូវបង្កើតឱ្យមាន ប្រព័ន្ធវាយតម្លៃ ទៅលើការងារមុន។ ហើយដើម្បីបង្ហាញឱ្យឃើញអត្ថន័យពេញលេញ នៃការវាយតម្លៃទៅលើការងារជាមុន។ ការប្រើសៀវភៅណែនាំ ប៉ាន់ស្មាន សៀវភៅសុវត្ថិភាព។ ការងារសំណង់មួយដែលមានកម្ពស់លើសពី ៣១ ម៉ែត្រ ឬ១០ម៉ែត្រឡើងទៅការដាក់ម៉ាស៊ីនប្រើប្រាស់ ចាំបាច់ត្រូវមានប្រធានគ្រប់គ្រងដើម្បីធ្វើផែនការសាងសង់។

**ការធានាឱ្យមានសុខភាព សុវត្ថិភាពទៅលើកម្រិតការងារសំណង់**

**វិធានការទីមួយ :**

ត្រូវតែបង្ហាញពីការប្រតិបត្តិដ៏ត្រឹមត្រូវនៃការត្រួតពិនិត្យដោយសុខភាព សុវត្ថិភាពដើម្បី ការពារកុំឱ្យមានគ្រោះថ្នាក់ពលកម្មកើតមាន នៅកន្លែងសំណង់ អ្នកម៉ៅការត្រូវគ្រប់គ្រងផ្នែកទាំងអស់នៃការងារសាងសង់ជាពិសេសចំនុចសំខាន់ៗ :

ក) យោងតាមវិធានការការពារនៃផែនការគ្រប់គ្រងសុខភាពសុវត្ថិភាព ដំណើរការសាងសង់ និង ការគ្រប់គ្រងសុខភាពសុវត្ថិភាពឱ្យទៅជាឆ្លុងតែមួយ ។

ខ) ត្រូវពង្រឹងកាតព្វកិច្ច និងអំណាចច្បាស់លាស់ និងភាពទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងសុខភាពសុវត្ថិភាពឱភាសកម្មនៅកន្លែងធ្វើការ។

គ) ត្រូវបង្ហាញ ឬដឹកនាំអំពីភាពរំលោភច្បាប់ សុខភាពសុវត្ថិភាពពលកម្មដល់អ្នកទាក់ទង។

ឃ) ត្រូវណែនាំដល់អ្នកទំនាក់ទំនងម៉ៅការ អំពីការការពារសុវត្ថិភាពនៅកន្លែងការងារ ដែលមានការគ្រោះថ្នាក់ដូចជាបាក់ដីជាដើម។

ង)ក្នុងករណីឱ្យកម្មករប្រើឧបករណ៍ផ្សេងៗ ត្រូវណែនាំឱ្យបានត្រឹមត្រូវ។

យោងតាមការគ្រប់គ្រងសុខភាព សុវត្ថិភាពរបស់អ្នកធ្វើការជាមួយនឹងការប្រកាន់យកជំហានធំអ្នកម៉ៅការប្រតិបត្តិការការងារដោយផ្ទាល់។ ចំពោះការការពារគ្រោះថ្នាក់របស់កម្មករ គឺជាកាតព្វកិច្ច របស់គេ។ ករណីទាក់ទងអ្នកម៉ៅការ ដូចជាការប្រើឧបករណ៍ស្មុចរំកិលផ្សេងៗ ត្រូវការស្ទាបស្ទង់ឲ្យមានប្រសិទ្ធភាពបំផុតពីអត្ថន័យការងារ។

**វិធានការទីពីរ :**

- ការបង្ហាញដ៏ល្អិតល្អន់អំពីវិធានការដ៏ត្រឹមត្រូវ

- ចំពោះការធ្វើការដឹកនាំដោយផ្ទាល់របស់ប្រធាន ឬ អ្នកដឹកនាំត្រូវតែធានាឱ្យបាននូវវិធីដ៏ត្រឹមត្រូវ។

-ចំពោះវិធានការការពារគ្រោះថ្នាក់រហូតដល់ស្លាប់នៅកន្លែងការងារសំណង់ស៊ីវិល ជាពិសេសគ្រោះថ្នាក់ដោយសារម៉ាស៊ីនសាងសង់ច្រើន គឺមុននឹងដំណើរការគឺត្រូវត្រួតពិនិត្យ ហើយយកលទ្ធផលមកធ្វើជាផែនការមូលដ្ឋានហើយធ្វើតាមនោះទៅ។ ដើម្បីការពារគ្រោះថ្នាក់ ឬក្រឡាប់ម៉ាស៊ីនត្រូវពង្រឹងគ្រឹះ ដើម្បីការពារពេលដាក់នៅចន្លោះត្រូវដាក់អ្នកបញ្ជា។ ករណីម៉ាស៊ីនសាងសង់ក្នុងការលើកស្ទូចឱ្យវាឡើងមុននឹងលើកត្រូវត្រួតពិនិត្យឲ្យបានដិតដល់ ជាពិសេសការធានាឱ្យមានសុវត្ថិភាព។ ហើយចំពោះការការពារការបាក់ដីកន្លែងជីក និងបរិវេណត្រូវតែត្រួតពិនិត្យឱ្យបានដិតដល់។

យោងតាមលទ្ធផលនៃការពិនិត្យ ត្រូវតែរៀបចំជីកឱ្យបានត្រឹមត្រូវ។ ចាំបាច់ត្រូវតែអនុវត្តជំហ៊ានៗ នូវវិធានការការពារកុំឱ្យដីបាក់។

**ការជម្រុញឱ្យមានដូចជាការសិក្សាសុខភាពសុវត្ថិភាព**

**វិធានការ :**

ការសិក្សាបន្ថែមដូចជាការចូលធ្វើការដំបូង ការសិក្សាជាលក្ខណៈពិសេសត្រូវអនុវត្តន៍ឱ្យបានម៉ត់ចត់នូវការសិក្សាសម្រាប់អ្នកចូលថ្មី។ កត្តាសំខាន់ចំពោះការការពារគ្រោះថ្នាក់នៅកន្លែងធ្វើការ ចំណេះដឹងបទពិសោធន៍ សមត្ថភាព គឺជាការដកយកចេញនូវមូលហេតុគ្រោះថ្នាក់ដោយសារឧបករណ៍ប្រើប្រាស់។

សាខាហាងកន្លែងលក់ដូរផ្សេង នៃដណ្តើរចាំបាច់ត្រូវជម្រុញឱ្យមានការអប់រំសុខភាពសុវត្ថិភាព ហើយចាំបាច់ត្រូវមានការជួយ ឬដឹកនាំឱ្យបានជិតដល់ របស់ប្រធានការងារ ចំពោះការអប់រំអ្នកចូលថ្មី អប់រំសុខភាពសុវត្ថិភាពនៃអ្នកម៉ៅការ។

## វិធានការសុវត្ថិភាពតាមរយៈការងារផ្សេងៗ

សំណង់ស៊ីវិល តើវាមិនមែនជាការប្រយុទ្ធប្រឆាំងនឹងធម្មជាតិទេឬ? គឺជាកាបំពានទៅលើទឹកបឹងសមុទ្រ ផ្ទៃដីដ៏ធំ ដោយឥតមានក្រែង។ ប្រសិនជាបង្កើតជាកំហុសនៃការបំពាន ទង្គិចម្តងៗវានឹងក្លាយទៅជាមហន្តរាយមួយដ៏ធំ ដោយសារការបាក់រលំ ខ្យាច់ជាដើម។ ឥឡូវនេះនិយាយទៅដល់ករណី កើតឡើងការគ្រោះថ្នាក់នៅពេលសាងសង់សំណង់ផ្សេងៗ និងវិធានការសុវត្ថិភាពរបស់សំណង់ស៊ីវិល មុនដំបូងត្រូវមើលគ្រោះថ្នាក់ដែលកើតឡើងពីអតីតកាល ប្រភេទសំណង់ទោះបីខុសគ្នាក៏ដោយក៏ស្ថានភាពគ្រោះថ្នាក់ដែលកើតឡើងគឺគេយល់ថាកើតឡើងខុសគ្នាទៅតាមសំណង់នីមួយៗ។ ពោលគឺ គ្រោះថ្នាក់ដោយសារម៉ាស៊ីនសំណង់ ការបាក់ដីខ្សាច់ ការធ្លាក់ មាននៅពេលសាងសង់ផ្លូវថ្នល់ សាងសង់ប្រព័ន្ធលូទឹកគ្រោះថ្នាក់ ដែលកើតឡើងតាមលក្ខណៈបែបនេះដូចគ្នានៅនឹងសំណង់ស៊ីវិលផងដែរ។

ដូច្នេះបានជាយើងធ្វើការណែនាំនូវឧទាហរណ៍ស្រដៀងគ្នាទាំងអស់មិនអាចជំនួសបានទាំងស្រុងនោះទេ ត្រូវជ្រើសរើសករណីដែលមានប្រភេទដូចគ្នា ទោះជាគ្រោះថ្នាក់កើតឡើងដោយសារម៉ាស៊ីនសំណង់ដូចគ្នាក៏ដោយ បញ្ហានេះកើតឡើងត្រូវជាបញ្ហាពិសេស ចំពោះសំណង់ទាំងនោះ ទោះបីតិចតួចក៏ដោយ ឧទាហរណ៍ចំពោះសំណង់កំពង់ផែ ត្រូវលើកឡើងនូវគ្រោះថ្នាក់ពេលមុជទឹក ចំពោះសំណង់ Tunnel ត្រូវលើកឡើងពីគ្រោះថ្នាក់នៃការផ្ទុះ។

ចំពោះវិធានការពារសុវត្ថិភាពនៃការសាងសង់ផ្សេងៗរបស់សំណង់ស៊ីវិលអំពី(ការសាងសង់នៅកន្លែងដែលគ្រោះថ្នាក់ខ្វះអុកស៊ីសែន ការសាងសង់នៅក្រោមបរិយាកាសសម្ពាធខ្ពស់ ការងារសាងសង់ធ្នឹមស្ពាន ការងារសំណង់ Tunnel និងការងារជីក ខួង) ដែលត្រូវបានកំណត់ដោយច្បាប់សុវត្ថិភាពនិងសុខភាពត្រូវបានគេបញ្ជាក់នូវវិធានការសុវត្ថិភាពនៅតាមការងារផ្សេងៗ ក្រៅពីនេះត្រូវបានគេបង្ហាញនូវសុវត្ថិភាពតាមរយៈផ្សេងៗទៅតាមម៉ាស៊ីនទាំងឡាយដែលបានកើតឡើងរួមគ្នា ចំពោះការងារនីមួយៗ ជាមួយនឹង (ម៉ាស៊ីនសំណង់ ឡានស្ទូច)។ ចំពោះលក្ខណៈពិសេសនៃការមុជទឹក សូមឲ្យមើលវិធាការដែលជា ឧទាហរណ៍នៃការសាងសង់នីមួយៗ។

## សំណួរ

១. ចូលធ្វើការប្រៀបធៀបរវាងការដ្ឋានទាំងពីរមួយណាមានសុវត្ថិភាពជាង ?



ការដ្ឋានទី១




ការដ្ឋានទី២

**វិធីអប់រំការការពារគ្រោះថ្នាក់ដ៏មានប្រសិទ្ធិភាព**

- **មូលដ្ឋាននៃការការពារគ្រោះថ្នាក់:**

កន្លែងធ្វើការមូលដ្ឋាននៃការការពារគ្រោះថ្នាក់គឺ ការធ្វើឲ្យអស់នៃសកម្មភាពអសុវត្ថិភាព លក្ខណៈអសុវត្ថិភាព។

លក្ខណៈអសុវត្ថិភាព គឺការគ្រប់គ្រងពុំបានត្រឹមត្រូវ ឧបករណ៍ម៉ាស៊ីនពុំបានត្រឹមត្រូវ បរិយាកាសជុំវិញពុំបានត្រឹមត្រូវ។ សកម្មភាពអសុវត្ថិភាព គឺសកម្មភាពអសុវត្ថិភាពរបស់អ្នកធ្វើការតាមតួអក្សរ។

បើមើលមូលហេតុនៃការគ្រោះថ្នាក់ពីស្ថិតិមុនៗមកឃើញថាដោយសារលក្ខណៈអសុវត្ថិភាពជាង ៨០% ទៅ ៩០%។ ដើម្បីការពារគ្រោះថ្នាក់ ចាំបាច់ត្រូវបំបាត់មូលហេតុគ្រោះថ្នាក់ទាំងពីរខាងលើ។ ប៉ុន្តែចំពោះលក្ខណៈអសុវត្ថិភាពកាតព្វកិច្ចរបស់សហគ្រិន គឺអាចបង្ហាញពីការធ្វើការឲ្យមាន សុវត្ថិភាព។ លក្ខណៈអសុវត្ថិភាពនៅកន្លែងធ្វើការងារគឺពិបាកនឹងធ្វើការបំបាត់ទាំងស្រុង ប៉ុន្តែអនុវត្តជាបន្តបន្ទាប់នូវវិធានការដើម្បីធ្វើឲ្យអស់នូវសកម្មភាពអសុវត្ថិភាព។ ចូរគិតមូលហេតុថា តើធ្វើយ៉ាងណាដែលអាចបំបាត់សកម្មភាព អសុវត្ថិភាពបាន។ ជាបឋមត្រូវពិចារណាថា តើហេតុអ្វីបានជាសកម្មភាពអសុវត្ថិភាពកើតឡើង ? ហើយចាំបាច់ត្រូវបង្កើតវិធានការទប់ស្កាត់។

**វិធានការការពារ និង មូលហេតុនៃសកម្មភាពអសុវត្ថិភាព:**

- **មូលហេតុនៃសកម្មភាពអសុវត្ថិភាព:**

មូលហេតុដែលកើតមានអសុវត្ថិភាពត្រូវបានគេគិតដូចខាងក្រោម:

១. ពុំបានដឹងអំពីគ្រោះថ្នាក់របស់ការងារ

២. ដឹងពីភាពគ្រោះថ្នាក់របស់ការងារ គេគិតថានឹងធ្វើដោយសុវត្ថិភាពតែពុំអាច
៣. ដឹងពីភាពគ្រោះថ្នាក់របស់ការងារ ប៉ុន្តែមិនព្រមអនុវត្តតាម( ព្រហើន )
៤. ដោយសារភាពភ្លាត់ស្នៀតរបស់មនុស្ស។

- **វិធានការការពារនៃមូលហេតុនៃសកម្មភាពអសុវត្ថិភាព:**

អត្ថន័យនៃពាក្យTBM ( Tool Boxes Meeting ) KYK សកម្មភាពព្យាករណ៍គ្រោះថ្នាក់ បើយើងសិក្សាពិនិត្យលើវិធានការចំពោះករណីខាងលើទាំង ៤ យើងអាចគិតដូចតទៅ៖

*ចំពោះករណីទីមួយ៖* ជនក្នុងករណីនេះគឺអ្នកចូលធ្វើការថ្មី អត្ថន័យរបស់ការងារប្រាកដក្នុងចិត្តដោយពុំបានសិក្សាដោយសារជាអ្នកថ្មីគេពុំដឹងពីភាពគ្រោះថ្នាក់នៃការងារដូចនេះ ចំពោះជនទាំងនោះចាំបាច់ត្រូវអប់រំ ពីសុវត្ថិភាពគ្រប់ឱកាសទាំងអស់។




*ចំពោះករណីទីពីរ៖* ចំពោះករណីនេះដឹងហួសពេកអាចគិតបានពីរករណី ដូចខាងក្រោម៖

១. ករណីដែលហេតុផលដែលមិនអាចដូចជា លើកម្លាំង លើសុខភាព។ ករណីនេះ ត្រូវធ្វើការបញ្ជាក់ដោយត្រួតពិនិត្យពី TBM-KYK ហើយចាំបាច់ត្រូវរៀបចំការងារឲ្យបានត្រឹមត្រូវ។

២. ករណីនេះពុំអាចដោយសារគ្មានចំណេះដឹង និងជំនាញគ្រប់គ្រាន់។ ករណីនេះត្រូវធ្វើដោយការហ្វឹកហាត់ជំនាញថែម ឬរៀបចំដំណាក់កាលការងារឲ្យបានម៉ត់ចត់។

*ចំពោះករណីទីបី៖* ក្នុងករណីនេះឆ្លងតាម TBM-KYK ដូចជាផ្តោតលើចំណាប់អារម្មណ៍ផ្នែកសុវត្ថិភាពពង្រឹងការអប់រំដែលមានលក្ខណៈល្អៗ។

*ចំពោះករណីទីបួន៖* ភាពប្រុងប្រយ័ត្នរបស់មនុស្សរយៈពេលវែង បរិយាកាសជុំវិញ ពុំបានគិតពីតូចដល់ធំ។ មិនថាពេលចាប់ផ្តើមការងារ សូម្បីពេលកំពុងធ្វើការត្រូវឆ្លងកាត់ពីគ្រោះថ្នាក់ ហើយត្រូវធ្វើការប្រុងប្រយ័ត្នជានិច្ចមិនថាក្នុងខ្លួន ឬ ក្រៅខ្លួននោះទេ។

- **ប្រសិទ្ធភាពនៃការហ្វឹកហាត់អប់រំ**

ដូចដែលបាននិយាយខាងលើ មូលហេតុរបស់សកម្មភាពអសុវត្ថិភាពមានច្រើន ហើយក៏អាចគិតរកវិធានការការពាររបស់វានីមួយៗដែរ។ វិធានការទាំងនោះចំបាច់ គឺអប់រំពីសុវត្ថិភាព ប៉ុន្តែបញ្ហានៅត្រង់ការអប់រំដោយមានសុវត្ថិភាពមានប្រសិទ្ធិភាព។




ត្រង់នេះយោងតាមស្ថិតិដែលបានត្រួតពិនិត្យលើវិធីអប់រំដ៏មានប្រសិទ្ធិភាព និងវិធិដើម្បីស្រាវជ្រាវត្រូវបានគេនិយាយថាមិនបានកំណត់បានជាទូទៅ ប៉ុន្តែអាចមានលទ្ធផល។ ឲ្យនិយាយ ឲ្យអនុវត្ត ៩០%, ឲ្យថា ៧០%, ឲ្យមើល ឬស្តាប់ ៥០%, ឲ្យមើល ៣០%, ឲ្យស្តាប់ ២០%, ឲ្យអាន ២០%។

ដូចដែលបានបង្ហាញខាងលើ គឺជាវិធីឲ្យអ្នកសិក្សាថា ឬអនុវត្តដោយផ្ទាល់។ ដោយបុគ្គលិកទាំងអស់មានចំណេះដឹងតាមរបៀប TBM-KYK គឺជាវិធាការណ៍អប់រំមានប្រសិទ្ធិភាព ជាពិសេសចំពោះអ្នកធ្វើការសាងសង់ទ្រង់ទ្រាយធំមិនអាចស្រែកថាមានប្រសិទ្ធិភាព ដោយសារប្រើរយៈពេលយូរពេក។ ដូច TBM-KYK មានរយៈពេលកំណត់បញ្ជាក់ដោយឃើញនឹងភ្នែកនូវស្ថានភាពកន្លែងធ្វើការបណ្តើរសិក្សាបណ្តើរ ត្រូវបានគេគិតថាជាវិធីដ៏មានប្រសិទ្ធិភាព ក៏ប៉ុន្តែបើតាមTBM-KYK រហូតទ្រទ្រង់ធ្វើឲ្យទៅជាគួរយ៉ាងនៃប្រសិទ្ធិភាពមិនអាចសង្ឃឹមបានទេ។

- **តំណាក់កាលបន្តបន្ទាប់ដ៏មានប្រសិទ្ធិភាពរបស់ TBM-KYK**
  - **វដ្ត (Cycle) នៃប្រត្តិបត្តិការដ៏មានប្រសិទ្ធិភាព នឹង TBM-KYK**

TBM-KYK បើពុំបានគេដាក់បញ្ចូលជាធរមានថាជាផ្នែកមួយ នៃប្រតិបត្តិការដ៏មានសុវត្ថិភាពនេះទេ គឺគ្មានន័យ។

ប្រធានការងារគឺជារៀងរាល់ថ្ងៃ ដើម្បីរៀបចំដំណើរការដ៏មានប្រសិទ្ធិភាព ត្រូវមកធ្វើការប្រកាន់យកការងារខ្ជាប់ខ្ជួន រួមបញ្ចូលទាំងអ្នកមិនមែនជាប្រធានផងដែរ ត្រូវតែយល់ពីអត្ថន័យនៃការងាររៀបចំដែលមានសភាពរញ៉េរញ៉ៃ រៀបចំម៉ាស៊ីនសាងសង់ ត្រូវធ្វើការសិក្សាបង្ហាញពីការម៉ៅការ និងទទួលព័ត៌មាន។



អត្ថន័យខាងលើគឺតាម TBM ខាងក្រោមនេះចំណេះដឹងទូទៅរបស់កម្មករ។ កម្មករត្រូវចាប់ផ្តើមការងារតាម KY ដោយប្រើក្រុមតូចៗ។ នៅ TBM កម្រិតដែលចេញពីអ្នកធ្វើការឆ្លុះបញ្ចាំងដើម្បីធ្វើឲ្យដំណើរការការងារបានល្អ។

- **ចំនុចប្រតិបត្តិការរបស់** TBM-KY

គឺត្រូវបានគេអប់រំ ឬបង្ហាត់បង្ហាញជាព័ត៌មានក្បោះក្បាយហើយក៏ត្រូវទទួលយកគំនិតរបស់ កម្មករផងដែរ។ ត្រូវធ្វើតាមគំនិត និងមតិរបស់កម្មករទាំងអស់នោះ។ និយាយឲ្យចំ ចំណុចល្អ អាក្រក់របស់ RBM-KY គឺមានអាចនិយាយថាការងារថ្ងៃនោះមានសុវត្ថិភាព និងប្រសិទ្ធិភាពទេ។ ខាងក្រោមនិយាយអំពីចំណុចដំណើរការដ៏មានប្រសិទ្ធិភាពនៃTBM-KY។

**ក. វាស់វែងការពិត:**

អ្នកធ្វើការប្រភេទដូចគ្នា គួរតែបង្កើតជាក្រុមតូចៗ។ ចំនុចដែលត្រូវមនុស្សពិភាក្សាក្នុងរយៈពេលខ្លីគឺមានគំនិតពី ៥-៦នាក់។ ជារឿយៗគេមើលទៅអ្នកធ្វើការច្រើនប្រភេទក្នុងមួយក្រុម ជាពិសេសផ្អែកលើ KY ពុំបានត្រឹមត្រូវ។ ប្រភេទការងារនៅកន្លែងធ្វើការដែលគេព្យាករណ៍ពីភាពគ្រោះថ្នាក់គឺខុសៗគ្នា។

**ខ. រយៈពេលពិភាក្សា:**

១. មកដល់កន្លែងធ្វើការក្រោយពីទទួលបានការបង្ហាញពីការងារតាមរបៀប TBM របស់ប្រធានការងារនៅថ្ងៃជាមួយគ្នានោះ យោងតាមចំនួនមនុស្សចូលធ្វើការ។ ចាប់ផ្តើមធ្វើកិច្ចប្រជុំតាម KY រយៈពេលខ្លីមួយ (៣ទៅ៥នាទី)។ ការប្រជុំនេះយ៉ាហោចណាស់ក៏មួយថ្ងៃម្តងដែរ។ នៅថ្ងៃនោះដែរបើមានការដូរកន្លែងធ្វើការ អត្ថន័យត្រូវធ្វើម្តងទៀត។

២. ការប្រជុំពេលកំពុងធ្វើការនៅពេលដែលស្ថានភាព(គ្រោះថ្នាក់ដែលមិនធម្មតា) កើតមានដោយពុំបានគិតទុកជាមុនទោះកំពុងធ្វើការក៏ដោយក៏ត្រូវធ្វើកិច្ចប្រជុំភ្លាម។ ចំពោះស្ថានភាពបន្ទាន់ដូចនេះត្រូវពិភាក្សាជាជំហាន។ ចំពោះវិធានការដ៏សមស្របគឺត្រូវអប់រំពីអ្វីដែលកើតឡើងនៅកន្លែងធ្វើការ។ ហើយប្រធានការងារត្រូវហៅអ្នកធ្វើការមកប្រាប់ថាការងារកំពុងធ្វើនេះកំពុងមានគ្រោះថ្នាក់ ដូចនេះត្រូវអប់រំតាម KY នូវវិធីដែលមានប្រសិទ្ធិភាព។

៣. ការប្រជុំពេលធ្វើការដែលមិនប្រក្រតី KY គឺថាបើពុំដឹងពីដំណាក់កាល នឹងអត្ថន័យការងារទេនោះពុំអាចប្រព្រឹត្តទៅបាននោះទេ។ មកដល់ពេលនេះ ករណីត្រូវតែធ្វើការងារមិនប្រក្រតីដែលពុំមានបទពិសោធន៍ពីមុនមកគឺ ជាដំបូងត្រូវចែកពេលវេលាតាម TBM ប្រធានការងារត្រូវស្វែងយល់យកគំនិតតាមអ្នកធ្វើការទាំងអស់។ ហើយត្រូវតែកំណត់ដំណាក់កាលការងារ អ្នកធ្វើការទាំងអស់ត្រូវយល់ឲ្យបានគ្រប់គ្រាន់ ត្រូវធ្វើដោយពេញចិត្ត។ ក្នុងករណីនេះយោងតាមវិធី KY ដំណាក់កាលការងារដែលបានកំណត់ គឺត្រូវធ្វើការព្យាករណ៍លើការគ្រោះថ្នាក់ វិធីពិភាក្សាដោះដូរយោបល់ដើម្បីរកវិធានការដែលមានប្រសិទ្ធិភាព។

៤. ពិភាក្សាពេលបញ្ចប់ការងារនៅថ្ងៃនោះ ពេលបញ្ចប់ការងារក្នុងករណីពេលដែលមានគ្រោះថ្នាក់បន្តិចបន្តួច ឬគ្រោះថ្នាក់ផ្សេងៗ ត្រូវគិតគូរពិភាក្សាក្នុងរយៈពេលខ្លីមួយ។ ហើយនៅពេលព្រឹកបន្ទាប់ត្រូវឆ្លុះបញ្ចាំងលើ TBM-KY បើ TBM-KY អាចដំណើការបានល្អ គឺការអប់រំមានប្រសិទ្ធិភាពបំផុត ផ្ទុយទៅវិញ បើពុំដូច្នេះគឺវាខ្ជះខ្ជាយពេលវេលា។

- **ការត្រៀមខ្លួនរួចស្រេចរបស់អ្នកដឹកនាំចំពោះ TBM-KY**

ដើម្បីឲ្យ TBM-KYដំណើរការទៅដោយប្រសិទ្ធិភាព មេការចាំបាច់ត្រូវចាប់អារម្មណ៍លើចំណុចដែលបានគិតដូចតទៅៈ

១.ចាប់អារម្មណ៍ទៅលើការធ្វើឲ្យមានសុវត្ថិភាពបរិយាកាសជុំវិញ និងឧបករណ៍ម៉ាស៊ីនជាដើម។ ដោយសារសេកម្មភាពការងារ ដែលគេព្យាករណ៍ថាមានសភាពគ្រោះថ្នាក់ដោយសារសង្ស័យខ្លាំងពេកលើ KY របស់អ្នកធ្វើការ KY បើប្រព្រឹត្តទៅបានល្អនោះ គឺកុំធ្វេសប្រហែសទៅលើការធ្វើឲ្យមានសុវត្ថិភាព បរិកាសជុំវិញ និងឧបករណ៍ម៉ាស៊ីន។

២. ត្រូវស្តាប់គំនិតអ្នកធ្វើការមូលដ្ឋានរបស់ TBM-KY គឺឲ្យអ្នកធ្វើការនិយាយបញ្ចេញគំនិតមតិយកគំនិតមតិនោះមកពិភាក្សាដើម្បីរកឲ្យឃើញនូវចំណេះដឹងមួយដ៏សុវត្ថិភាព។ គូសបង្ហាញពីវិធីការពារ កុំឲ្យមានគ្រោះថ្នាក់គ្រាន់តែឲ្យអ្នកធ្វើការបញ្ចេញគំនិតល្អៗ គឺលក្ខណៈធ្វើការដោយសកម្មបំផុត។

៣. ត្រូវយល់ឲ្យច្បាស់ពីលទ្ធភាព អត្តចរិកអ្នកធ្វើការ លទ្ធភាព អត្តចរិកអ្នកធ្វើការត្រូវបង្ហាញដើម្បីអប់រំ ជាពិសេសប្រធានការងារ ទំនាក់ទំនងជាមួយកម្មករគឺជាការសំខាន់ណាស់។ ដោយសារពុំធ្វើទៅតាម TBM-KY ដោយប្រសិទ្ធិភាព គឺវាពុំអាចប្រព្រឹត្តទៅបានទេ។

## វិធានការសុវត្ថិភាពតាមរយៈការងារផ្សេងៗ

សំណង់ស៊ីវិល តើវាមិនមែនជាការប្រយុទ្ធប្រឆាំងនឹងធម្មជាតិទេ ឬ? គឺជាកាបំពានទៅលើទឹកបឹង សមុទ្រ ផ្ទៃដីដ៏ធំ ដោយឥតមានក្រែង។ ប្រសិនជាបង្កើតជាកំហុសនៃការបំពាន ទង្គិចម្តងៗវានឹងក្លាយទៅជាមហន្តរាយមួយដ៏ធំ ដោយសារការបាក់រលំ ខ្សាច់ជាដើម។

ឥឡូវនេះ និយាយទៅដល់ករណីកើតឡើងការគ្រោះថ្នាក់នៅពេលសាងសង់សំណង់ផ្សេងៗ និង វិធានការសុវត្ថិភាពរបស់សំណង់ស៊ីវិល មុនដំបូងត្រូវមើលគ្រោះថ្នាក់ដែលកើតឡើងពីអតីតកាល ប្រភេទសំណង់ទោះបីខុសគ្នាក៏ដោយក៏ស្ថានភាពគ្រោះថ្នាក់ ដែលកើតឡើងគឺ គេយល់ថាកើតឡើងខុសគ្នាទៅតាមសំណង់នីមួយៗ។ ពោលគឺគ្រោះថ្នាក់ដោយសាម៉ាស៊ីនសំណង់ ការបាក់ដីខ្សាច់ ការធ្លាក់ មាននៅពេលសាងសង់ផ្លូវថ្នល់ សាងសង់ប្រព័ន្ធលូទឹក គ្រោះថ្នាក់ដែលកើតឡើងតាមលក្ខណៈបែបនេះដូចគ្នាទៅនឹងសំណង់ស៊ីវិលផងដែរ។

ដូច្នេះបានជាយើងធ្វើការណែនាំនូវឧទាហរណ៍ស្រដៀងគ្នាទាំងអស់មិនអាចជំនួសបានទាំងស្រុងនោះទេ ត្រូវជ្រើសរើសករណីដែលមានប្រភេទដូចគ្នា ទោះជាគ្រោះថ្នាក់កើតឡើងដោយសារម៉ាស៊ីនសំណង់ដូចគ្នាក៏ដោយ បញ្ហានេះកើតឡើងត្រូវជាបញ្ហាពិសេសចំពោះសំណង់ទាំងនោះ ទោះបីតិចតួចក៏ដោយ ឧទាហរណ៍ចំពោះសំណង់កំពង់ផែ ត្រូវលើកឡើងនូវគ្រោះថ្នាក់ពេលមុជទឹក ចំពោះសំណង់ Tunnel ត្រូវលើកឡើងពីគ្រោះថ្នាក់នៃការផ្ទុះ។

ចំពោះវិធានការការពារសុវត្ថិភាពនៃការសាងសង់ផ្សេងៗ របស់សំណង់ស៊ីវិលអំពី( ការសាងសង់នៅកន្លែងដែលគ្រោះថ្នាក់ខ្វះអុកស៊ីសែន ការសាងសង់នៅក្រោមបរិយាកាសសម្ពាធខ្ពស់ ការងារសាងសង់ផ្នឹមស្ពាន ការងារសំណង់ Tunnel ការងារជីក ខួង ) ដែលត្រូវបានកំណត់ដោយច្បាប់សុវត្ថិភាព និងសុខភាពត្រូវបានគេបញ្ជាក់នូវវិធានការសុវត្ថិភាពនៅតាមការងារផ្សេងៗ ក្រៅពីនេះត្រូវគេបង្ហាញនូវសុវត្ថិភាពតាមរយៈផ្សេងៗ ទៅតាមម៉ាស៊ីនទាំងឡាយដែលបានកើតឡើងរួមគ្នាចំពោះការងារនីមួយៗ ជាមួយនឹង(ម៉ាស៊ីនសំណង់ ឡានស្ទូច)។ ចំពោះលក្ខណៈពិសេសនៃការមុជទឹក សូមឲ្យមើលវិធាការដែលជាឧទាហរណ៍នៃការសាងសង់នីមួយៗ។

លើសពីនេះទៅទៀតវិធានការទប់ស្កាត់គ្រោះថ្នាក់ដែលបានបង្ហាញតាមរយៈសំណង់ជាច្រើនការងារផ្សេងវាមិនមែនជាវិធានការទាំងនោះទេ។សូមគិតថាវាជាផ្នែកមួយចំនុចនៃវិធានការ។

ម្យ៉ាងវិញទៀត នៅឆ្នាំ ១៩៩២ ច្បាប់សុវត្ថិភាព និង សុខភាព ត្រូវបានគេកែសម្រួលភាគច្រើនត្រូវបានគេអនុវត្តចាប់តាំពីខែ ១០ ឆ្នាំនោះ ចំណែកឯកន្លែងដែលមានការទាក់ទងគឺបានបង្ហាញកន្លែងប្រែតាមដែលអាចធ្វើទៅបាន។

ជាចុងក្រោយត្រូវមើលពីករណីគ្រោះថ្នាក់ដល់ស្លាប់ ហេតុអ្វីបានជាស្លាប់នៅកន្លែងបែបនេះ? តើត្រូវធ្វើយ៉ាងណា? អាចនិយាយថាគ្រោះថ្នាក់ដែលជាអំពើរបស់មនុស្សទាំងអស់មិនមែនជាគ្រោះថ្នាក់ដែលជៀសមិនរួចនោះទេ។

- **សុវត្ថិភាពក្នុងការប្រើប្រាស់សម្ភារៈ និងវិធីការពារខ្លួន**

ជាទូទៅមានសម្ភារច្រើនដែលត្រូវបានគេយកមក ប្រើប្រាស់នៅក្នុងការដ្ឋាន សំណង់ដើម្បីឱ្យការសាងសង់អាចប្រព្រឹត្តទៅបានរហូតដល់ទីបញ្ចប់។ ហើយដើម្បីឱ្យការប្រព្រឹត្តទៅបានរហូតទីបញ្ចប់ ប្រកបដោយសុវត្ថិភាព និងអ្នកប្រើប្រាស់ត្រូវដឹងពីមុខងារ និងតួនាទីរបស់សម្ភារនីមួយៗឱ្យបានច្បាស់លាស់។

**ភាពធន់ និងលំនឹង**

- រន្ទា
- ក្ដាក្រាល
- ក្ដាសម្រាប់ឆ្លងពីមួយទៅមួយ
- ខ្សែក្រវ៉ាត់
- ជន្ទល់



គ្រប់សម្ភារទាំងអស់មុននឹងប្រើប្រាស់ត្រូវមានការត្រួតពិនិត្យមុនសិន។ ប្រធានការដ្ឋានត្រូវដាក់វិធានការចំពោះបុគ្គលណាដែលទទួលខុសត្រូវលើផ្នែកនេះ។ ប្រធានការដ្ឋានត្រូវត្រួតពិនិត្យនូវការអនុវត្តការងាររបស់កម្មករដើម្បីជៀសវៀងនូវគ្រោះថ្នាក់ទាំងឡាយដែលអាចកើតមានឡើង។

**អនុវត្តន៍ការងារ**

១ សម្ភារៈគ្រប់ប្រភេទទាំងអស់ដូចជា ជណ្ដើរ រន្ទា ឧបករណ៍ការពារ ខ្សែកាប ខ្សែពួរ ច្រវ៉ាក់ និងសម្ភារសម្រាប់លើកដាក់ត្រូវឱ្យមានភាពជាប់ជានិច្ច និងមានលក្ខណៈល្អត្រឹមត្រូវនៅពេលយកទៅប្រើនៅក្នុងការដ្ឋាន។

២ បើសិនជារន្ទា ក្ដាក្រាល ជណ្ដើរ បង្កាន់ដៃ ឬ ឧបករណ៍ផ្សេងៗ ទៀតដែលប្រើប្រាសធ្វើអំពីឈើ ឧបករណ៍ទាំងនោះធ្វើអំពីឈើដែលរឹងមាំ។

ប្រសិនបើគ្រឿងឧបករណ៍ប្រើប្រាស់ធ្វើអំពីដែក ដែកទាំងនោះមិនឱ្យច្រេះស៊ី ឬស្នាមច្រេះ ដែលបង្កឡើងឱ្យមានពុកបាក់នៅអនាគត។







**វិធីការពារខ្លួន**

១. ប្រធានការដ្ឋានត្រូវផ្តល់សម្ភារ ឧបករណ៍គ្រឿងការពារខ្លួនដូចជា៖ ខ្សែក្រវ៉ាត់ខ្សែពាក់ ឈៀង Beaudier ,មួកCasque វ៉ែនតា Lunettes, ស្បែកជើងវែង Bottles, អាវភ្លៀង ,អៀម ឱ្យដល់បុគ្គលិកធ្វើការ ឱ្យបានគ្រប់គ្រាន់តាមតម្រូវការ។

២. សម្ភារឧបករណ៍ប្រើប្រាស់ត្រូវជាកម្មសិទ្ធផ្ទាល់ខ្លួនត្រូវត្រួតពិនិត្យសម្ភារ និងសម្អាតឡើងវិញមុននឹងផ្តល់ទៅឱ្យម្នាក់ទៀតយកទៅប្រើប្រាស់បន្ត។

៣.  គ្រប់សម្ភារការពារបុគ្គលិកផ្ទាល់ខ្លួនចាំបាច់ត្រូវតែទុកឱ្យបុគ្គលិកធ្វើការយកប្រើប្រាស់បាននៅលើការដ្ឋានរហូត ត្រូវមានលក្ខណៈត្រៀមប្រើជានិច្ច។

៤. ប្រធានការដ្ឋានត្រូវដាក់ផែនការពិនិត្យមើលថាសម្ភារការពារខ្លួនត្រូវបានគេប្រើប្រាស់ដែរឬទេ ?

៥. ប្រសិនបើសម្ភារការពារខ្លួនរបស់កម្មករម្នាក់មិនគ្រប់គ្រាន់ គឺមានត្រឹមតែខ្សែក្រវ៉ាត់ ឬខ្សែពាក់ឈាង នោះមិនត្រូវអនុញ្ញាតឱ្យកម្មករនោះនៅធ្វើការតែម្នាក់ឯងក្នុងការដ្ឋានបានឡើយ។



# <u>សំណួរ</u>

១.តើការរក្សាឱ្យមានសុវត្ថិភាពក្នុងពេលកំពុងធ្វើការរបស់កម្មករទាំងពីរបានត្រឹមត្រូវដែរ ឬទេ ?

២.ចូររៀបរាប់ឧបករណ៍ការពារសុវត្ថិភាពដែលកម្មករត្រូវប្រើប្រាស់នៅពេលកំពុងធ្វើការឱ្យបាន១០ ឧបករណ៍យ៉ាងតិច ?

- **សុវត្ថិភាពការដ្ឋាន**

នៅក្នុងព្រះរាជាណាចក្រកម្ពុជា វិស័យសំណង់ មានការរីកដុះដាលយ៉ាងខ្លាំងបំផុតដែលជាផ្នែកមួយនៅក្នុងការស្តារ និងកសាងប្រទេសជាតិ។ ប៉ុន្តែទោះបីជាមានការរីកដុះដាលយ៉ាងណាក៏ដោយក៏ត្រូវគិតពីបញ្ហាសុខភាព សុវត្ថិភាព ដែលជាកត្តាសំខាន់ ព្រោះវាអាចជះឥទ្ធិពលដល់ការសាងសង់វិញមិនខានឡើយ។

**វិធានការការពារផ្នែកបច្ចេកទេស**

អ្នកគ្រប់គ្រងការដ្ឋាន ត្រូវដឹងពីកម្រិតគ្រោះថ្នាក់ដែលអាចកើតឡើងក្នុងការដ្ឋានៈ

ក.ពេលកំពុងរៀបចំសង់ការដ្ឋាន។

ខ.ពេលកំពុងប្រកបការងារ។

គ.គុណភាពសំណង់។

ឃ.ការផ្តល់ឧបករណ៍ជួយសង្គ្រោះដល់ទីកន្លែង។

ចំណេះដឹងអាចកើតមាននៅគ្រប់ផ្នែកទាំងអស់(អង្គភាព)ដើម្បីកុំឱ្យមានគ្រោះថ្នាក់ត្រូវតែៈ

១.សិក្សាអំពីបទបញ្ជាសង្គ្រោះ និងបទបញ្ជាជៀសវាងគ្រោះថ្នាក់។

២.ពិចារណាទៅលើបញ្ហាសង្គ្រោះរំលឹកដាស់តឿនជានិច្ចពីរបៀបរបបរបស់ការដ្ឋាន។

៣.ចាំបាច់ត្រូវឱ្យពាក់ខ្សែក្រវ៉ាត់ការពារ វ៉ែនតា មួក ឬ សំលៀកបំពាក់ពិសេសក្នុងករណីចាំបាច់។

៤.ត្រូវពិនិត្យ និងជួសជុលសម្ភារៈបិទប្រកាសបទបញ្ជា ប្រើប្រាស់ឧបករណ៍ហើយត្រូវអនុវត្តតាម។

**វិធានការការពារផ្នែកចិត្តសាស្ត្រ**

ក្នុងករណីម្យ៉ាងទៀតមូលហេតុដើមនៃទុក្ខព្រួយ កើតឡើងពីសេចក្តីល្ងង់ និងការខ្វះបទពិសោធន៍បន្ទាប់មកទៀតសេចក្តីទុក្ខអាចបណ្តាលឱ្យមានគ្រោះថ្នាក់។ ដើម្បីឱ្យមានប្រសិទ្ធភាពប្រធានការដ្ឋានត្រូវតែបង្រៀនដល់សមាជិកក្រុមរបស់ខ្លួនឱ្យចងចាំនូវស្មារតីការងារ។

**ក្នុងករណីនេះត្រូវតែប្រើមធ្យោបាយដូចតទៅៈ**

ក.សង្កេតឱ្យបានហ្មត់ចត់ដោយខ្លួនឯងនូវរាល់បញ្ហាដើម្បីឱ្យឧទាហរណ៍។

ខ.អប់រំបំពាក់បំប៉នបុគ្គលិកហើយបង្ហាញឱ្យគេឃើញនូវគ្រោះថ្នាក់ទាំងនោះ។

គ.ផ្តល់ដំណឹងដល់ទីកន្លែងពីគ្រោះថ្នាក់ដែលកើតមានឡើង។

ឃ.ត្រួតពិនិត្យយ៉ាងម៉ត់ចត់ និងកត់ត្រាជានិច្ចនូវឧបទ្ទវហេតុទាំងនោះ។

ង.ជ្រើសរើសបុគ្គលិកឱ្យត្រូវតាមជំនាញសម្រាប់អនុវត្តការងារ។

ច.ដាស់តឿនជានិច្ចដល់បុគ្គលិកស្លៀកពាក់សំលៀកបំពាក់ការងារ។

**តើត្រូវធ្វើដូចម្តេចក្នុងករណីមានគ្រោះថ្នាក់?**

បើសិនជាមានគ្រោះថ្នាក់មិនធ្ងន់ធ្ងរ(ស្រាល)គេអាចប្រើត្រឹមតែប្រអប់រុំរបួសគ្រប់គ្រាន់ហើយ ប្រសិនបើមានគ្រោះថ្នាក់ធ្ងន់ធ្ងរត្រូវតែអញ្ជើញគ្រូពេទ្យជាប្រញាប់។

ក្នុងករណីមានធ្លាក់ឈាមពុំត្រូវធ្វើចលនាដើមទ្រូងទេ ប៉ុន្តែផ្តិតមុខរបួសដោយសំឡីអនាម័យ។ប៉ុន្តែផ្ទុយទៅវិញក្នុងករណីសន្លប់ ឬខ្សែភ្លើងឆក់ ត្រូវតែអនុវត្តជាបន្ទាន់នូវចលនាធ្វើឱ្យដកដង្ហើម ដើម្បីពន្យាពេលឱ្យបានយូរ ដើម្បីរង់ចាំគ្រូពេទ្យមកដល់។ មិនត្រូវនៅស្ងៀមរង់ចាំការមកដល់របស់គ្រូពេទ្យទេ។

**តារាងដែលបញ្ជាក់ពីករណីខ្លះដែលត្រូវជៀសវាងធ្វើដាច់ខាត៖**

| ករណីដែលកើតមាន | អ្វីដែលមិនត្រូវធ្វើ |
| --- | --- |
| ១.បាតបង់ស្មារតីដោយមានឈាមធ្លាក់ | -មិនត្រូវបញ្ច្រកថ្នាំឱ្យស្ទះដោយមានឈាមធ្លាក់។<br>-មិនត្រូវបញ្ច្រកថ្នាំដែលនាំឱ្យស្ទះបេះដូង។ |
| ២.មានការលើសចំណុះឈាមក្នុងសរសៃ | -មិនត្រូវឱ្យផឹកទឹកមុនពេលមានការដកដង្ហើមឡើយ។<br>-មិនត្រូវប៉ះពាល់ជនរងគ្រោះមុនពេលផ្តាច់ចរន្តអគ្គិសនី។ |
| ៣.ការលង់ទឹក(submersion) | -មិនត្រូវបញ្ច្រកថ្នាំបន្សាបដោយគ្មានការអន្តរាគមន៍ពីគ្រូពេទ្យឡើយ។ |
| ៤.ខ្សែភ្លើងឆក់(electrocution) | -មិនត្រូវដាក់ជនរងគ្រោះឱ្យអង្គុយមិនត្រូវផឹកទឹកមុនពេលដកដង្ហើមឡើយ។ |
| ៥.ពុល(empoisinnment) | -មិនត្រូវឱ្យអ្នករងគ្រោះភ័យរន្ធត់Affolesឡើយ ឬជៀសវាងនាំឱ្យអ្នកជំងឺនិយាយ។ |
| ៦.សន្លប់ | -មិនត្រូវលាបខ្លាញ់ ឬប្រេងឡើយ។ |
| ៧.ក្អកធ្លាក់ឈាម(orachement) | |
| ៨.រលាកភ្លើង | -មិនត្រូវឱ្យអ្នកជំងឺកម្រើកឡើយ។ |
| ៩.ការបាក់ឆ្អឹង | -មិនត្រូវញីភ្នែកទេ មិនត្រូវសាកល្បងយកក្រដាស់ជក់ ផ្លិតយកវត្ថុនោះចេញពីភ្នែកទេ ឬវិធីផ្សេងៗទៀត.....។ |
| ១០.វត្ថុចូលភ្នែក(Corps etrange) | -មិនត្រូវប៉ះមុខរបួសដោយដៃកខ្វក់ទេមិនត្រូវរុំរបួស។ |

# សំណួរ

១ តើករណីមានគ្រោះថ្នាក់ផ្សេងៗក្នុងការរដ្ឋាន ក្នុងនាមយើងជាអ្នកគ្រប់គ្រង តើត្រូវធ្វើដូចម្ដេច?
២ ក្នុងករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬបាត់បង់ជីវិតតើត្រូវផ្ដល់ព័ត៌មានដល់អ្នកណាខ្លះ? ហើយការផ្ដល់ព័ត៌មាននោះមានអត្ថប្រយោជន៍អ្វីខ្លះចំពោះខ្លួនផ្ទាល់ និងកម្មករ?

- **ច្បាប់ការពារ និងប្រុងប្រយ័ត្នក្នុងការងារគ្រប់គ្រងការដ្ឋានសំណង់**

នៅក្នុងវិស័យសាងសង់សំណង់គ្រប់ប្រភេទអ្នកគ្រប់គ្រងការដ្ឋានត្រូវមានចំណេះដឹងទាំងខាងផ្នែកគ្រប់គ្រង និងខាងផ្នែកសុវត្ថិភាពការងារ។ ដើម្បីកាត់បន្ថយនូវគ្រោះថ្នាក់ និងចំនួនដែលបានកើតឡើងពេលមានគ្រោះថ្នាក់ ។

- **ការរៀបចំការដ្ឋាន**

**ការរៀបចំឃ្លាំង និងកន្លែងដាក់គ្រឿងចក្រ**

- រៀបចំឱ្យមានរបងព័ទ្ធជុំវិញកម្ពស់ចាប់ពី(១.៨m) និងច្រកទ្វារចេញចូល។
- រៀបចំការិយាល័យនៅក្នុងការដ្ឋាន។
- រៀបចំកន្លែងដាក់គ្រឿងចក្រឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព។
- រដូវវស្សាត្រូវបង្ហូរទឹកចេញទៅក្រៅឱ្យអស់កុំឱ្យមានកន្លែងដក់នៅលើដីដើម្បីកុំឱ្យមានទឹកលិចចូលក្នុងឃ្លាំងសម្ភារៈ។
- នៅការដ្ឋានត្រូវរៀបចំឱ្យមានផ្លូវចេញចូល។
- ឃ្លាំងផ្ទុកសម្ភារៈមិនត្រូវតាំងនៅឆ្ងាយពីផ្លូវទេ។
- ត្រូវធ្វើឃ្លាំងដាក់សម្ភារៈសំណង់ និងឧបករណ៍ ផ្សេងៗ(ចប ប៉ែល ប្រេង ស៊ីម៉ង់ ដែក ..)ហើយឃ្លាំងនោះត្រូវសង់ក្នុងទីស្នាក់ការ។

**ការរៀបចំបង្គន់អនាម័យ**

- ការដ្ឋាននីមួយៗត្រូវមានបន្ទប់ទឹក និងបង្គន់អនាម័យជាចាំបាច់។
- នៅកន្លែងធ្វើសំណង់ត្រូវមានទឹកស្អាត ទឹកឆ្អិន សម្រាប់ឱ្យកម្មករផឹកហើយមិនត្រូវនៅឆ្ងាយពីកន្លែងធ្វើការលើសពី៧៥ម៉ែត្រ។
- នៅការដ្ឋាននៅពេលប្រើម៉ាស៊ីនភ្លើង ឬផ្សារដែកមិនត្រូវឱ្យឆ្ងាយពី៥០០ម៉ែត្រ។
- នៅពេលប្រើម៉ាស៊ីនភ្លើង ឬផ្សារដែកមិនត្រូវឱ្យគ្រឿងចក្រ ឬឡានមកឈប់ក្បែរនោះទេ។
- នៅពេលប្រើចរន្តអគ្គិសនីដើម្បីបំភ្លឺធ្វើការត្រូវយកខ្សែភ្លើងដែលមានស្រោមមកប្រើប្រាស់ដោយ។ ដាក់ឱ្យខ្ពស់ពីដីមានបង្គោលកុំឱ្យទ្រេតទ្រោតរលំបណ្តាលឱ្យមានគ្រោះថ្នាក់(ដើរជាន់ខ្សែភ្លើង ឬឡានបើកទាក់បណ្តាលឱ្យដាច់)។

**កម្ពស់ដែលត្រូវដាក់ខ្សែភ្លើង**

- ២.៥ ម៉ែត្រ កន្លែងកម្មករធ្វើការ។
- ៣.០ម៉ែត្រ កន្លែងដើរឆ្លងកាត់។
- ៥.០០ម៉ែត្រ កន្លែងឡានចេញចូល។




Bldg. 4200 takes shape in this photograph taken March 21, 1962.

**តួនាទីប្រធានការដ្ឋាន**

នៅតាមការដ្ឋានធ្វើសំណង់ប្រធានត្រូវមានការប្រុងប្រយ័ត្នឱ្យមែនទែនចំពោះសុខភាព និងគ្រោះថ្នាក់ដល់កម្មករនៅទីនោះ។

- គ្រប់ការដ្ឋានប្រភេទការងារទាក់ទងទៅនឹងចរន្តអគ្គិសនី។
- ជីកដីត្រូវប្រុងប្រយ័ត្នពេលដាក់លូធំៗ(ធ្លាក់បណ្តាលឱ្យមានគ្រោះថ្នាក់)។
- នៅពេលលើកស្ទូចលូ ឬផ្ទាំងបេតុងធំៗ(ធ្ងន់)ដោយប្រើឡានស្ទូច។
- បច្ចេកទេសដឹកជញ្ជូនឧបករណ៍សំណង់ធុនធ្ងន់។
- ជីករណ្តៅ ឬឈូសឆាយដីដែលមានជំរៅលើសពី១.៥ម៉ែត្រត្រូវមានមុំជម្រាល។
- ប្រុងប្រយ័ត្នចំពោះការងារខ្ពស់។
- ត្រូវចម្លងដោយទូក ឬដោយការឈូតឆ្លងកាត់ទន្លេ ឬស្ទឹង។
- មុនអនុវត្តការងារនេះ ប្រធានការដ្ឋានអ្នកដឹកនាំ ត្រូវណែនាំពីច្បាប់នៃការងារបច្ចេកទេសការពារសុវត្ថិភាពពលកម្ម ផ្តល់នូវឯកសារពិសេសៗឱ្យកម្មករយល់ដឹងហើយមានការប្រុងប្រយ័ត្នដោយខ្លួនឯង។

**ផ្ទះស្នាក់នៅបណ្តោះអាសន្ន**

នៅតាមបណ្តាក្រុមហ៊ុន សហគ្រាស ការដ្ឋានមួយចំនួនតែងតែរៀបចំអគារស្នាក់នៅសម្រាប់បុគ្គលិកកម្មករដើម្បីសម្រួលដល់ការធ្វើ និងការស្នាក់នៅ ពិសេសគឺនៅតាមបណ្តាការដ្ឋានសាងសង់ តែងតែត្រូវបានរៀបចំផ្ទះសម្រាប់កម្មករ សម្រាប់សំរាកបន្ទាប់ពីបានបំពេញការងារចប់។ ចំពោះការរៀបចំអគារស្នាក់នៅវិញត្រូវធ្វើដូចខាងក្រោម៖

## ការចាត់ការទូទៅ

ក. នៅក្នុងការដ្ឋានឯកជន និងសាធារណៈ ដែលកម្មករមិនអាចត្រលប់មកកាន់កន្លែងស្នាក់នៅបាន ហើយចាំបាច់ត្រូវមករាល់ថ្ងៃដោយធ្វើដំណើរលើសពី ២គីឡូម៉ែត្រ ប្រធានការដ្ឋានត្រូវតែដោះស្រាយនូវបញ្ហាកន្លែងស្នាក់នៅដល់បុគ្គលិកឲ្យបានសមរម្យ។

ខ. ប្រសិនបើកម្មករដដែលមិនអាចមកស្រស់ស្រូបអាហារទាន់ពេលវេលាធម្មតាបាន ប្រធានត្រូវតែរកវិធីយ៉ាងណាឱ្យកម្មករបានស្រស់ស្រូបអាហារ ឬរៀបចំឱ្យមានកន្លែងសំរាបញ៉ាំអាហារនៅក្នុងការដ្ឋានតែម្តង។

គ. ចំពោះការរដ្ឋានជិតខាងដែលសុំឱ្យកម្មករការរដ្ឋានយើងទៅជួយធ្វើការរយៈពេល៦ខែ ហើយកម្មករមានចំនួនតិចជាង២០នាក់ ប្រធានការដ្ឋានដែលហៅយើងឱ្យជួយជាអ្នកទទួលខុសត្រូវក្នុងស្នាក់នៅរបស់កម្មករយើង។

## អគារសម្រាប់សំរាក

ក.មានខ្យល់គ្រប់គ្រាន់សម្រាប់ដេកសម្រាប់មនុស្សម្នាក់មិនឱ្យ តិចជាង១១$m^3$ ទេគឺត្រូវ v>១១$m^3$·។ បន្ទប់នោះត្រូវធំទូលាយមានខ្យល់ចេញចូលមានពន្លឺគ្រប់គ្រាន់ត្រូវមាន បង្អួច ឬប្រលោះផ្សេងៗទៀតអាចមើលទៅក្រៅបាន។ ចំណែកដំបូលត្រូវប្រក់ឱ្យបានជិតល្អ និងមានពិដានបិទជិត។

ខ.បន្ទប់សម្រាករបស់កម្មករត្រូវស្អាតជានិច្ចការបោសសម្អាតគ្រប់ពេលវេលា ហើយត្រូវស្ងួតជានិច្ច និងរកមធ្យោបាយដើម្បីសម្លាប់សត្វល្អិត។

គ.ប្រធានការដ្ឋានត្រូវទទួលខុសត្រូវក្នុងការជួសជុល ត្រូវឱ្យមានបុគ្គលិកម្នាក់ជាជំនួយការពិសេស ត្រូវរៀបចំបណ្តាញទឹកស្អាត និងបង្គន់អនាម័យ។ សម្រាប់មនុស្ស ៥នាក់ បន្ទប់ទឹកមួយ និងសម្រាប់មនុស្ស ១២នាក់ មានLabo ១។ បន្ទប់ងូតទឹកត្រូវនៅជិតបន្ទប់សម្រាកជានិច្ច។ មិនត្រូវធ្វើបង្គន់នៅឆ្ងាយពីបន្ទប់សម្រាកព្រោះបណ្តាលឱ្យមានការលំបាកនៅពេលយប់។

## មធ្យោបាយទូទៅសម្រាប់អនាម័យ

ប្រធានការដ្ឋានផ្តល់នូវទឹកស្អាតឱ្យបានគ្រប់គ្រាន់ដែលធានានូវអនាម័យ ទាំងសុខភាព និងរាងកាយរបស់កម្មករ។ ក្នុងករណីដែលមិនអាចរកទឹកស្អាតបាន យើងអាចផ្តល់ទឹកសម្រាប់ឱ្យគាត់ប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ ដោយត្រូវប្រកាសប្រាប់មុន ឬសរសេរដាក់នៅលើក្តាខៀនពីកន្លែងត្រូវដាក់ទឹក។

- ក្នុងករណីដែលគ្មានលទ្ធភាពរកទឹកស្ទឹង ឬទន្លេបានត្រូវតែសាងសង់អាងទឹក( Water tank ) ឬតភ្ជាប់ពីបណ្តាញបំពង់មេចែកចាយដើម្បីយកទឹកមកប្រើប្រាស់ដល់ទីកន្លែង។
- ប្រសិនបើកម្មករស្រស់ស្រូបអាហារនៅលើការរដ្ឋានត្រូវត្រៀមធ្វើជម្រក និងតុអាហារឱ្យបានគ្រប់គ្រាន់( ករណីការរដ្ឋានថេរ )។ តុទាំងនេះត្រូវតែមានអ្នកសម្អាតជាប្រចាំយ៉ាងតិចម្តងក្នុងមួយថ្ងៃ ដើម្បីឱ្យការប្រើប្រាស់ប្រកបដោយផាសុខភាព។




បង្គន់អនាម័យ




Lavabo





Water tank

## សំណួរ

១ ក្នុងករណីការដ្ឋាននៅឆ្ងាយពីបណ្តាញទឹកមេ(បណ្តាញទឹករដ្ឋ)តើមានវិធីសាស្ត្រអ្វីខ្លះដើម្បីបានទឹកមកផ្គត់ផ្គង់ក្នុងការដ្ឋាន? រកឱ្យបាន ៤វិធីសាស្ត្រ?

២ ហេតុអ្វីបានជាគេធ្វើផ្ទះស្នាក់នៅបណ្តោះអាសន្នឱ្យកម្មករ?

## ការប្រើប្រាស់បច្ចេកទេសឧបករណ៍សម្រាប់ដំឡើង

ឧបករណ៍សម្រាប់ដំឡើងធ្វើការសម្រាប់អគារខ្ពស់ៗ មានរន្ទា ជណ្ដើរ និងធុងសម្រាប់ដាក់បេតុង បាយអរ និងសម្ភារៈម្សៅ ។ល។ ឧបករណ៍ទាំងនេះ ត្រូវបានកម្មករឡើងជាប់ធ្វើការ និងដាក់សម្ភារៈ ផ្សេងៗតាមកម្ពស់។ រន្ទាសម្រាប់កម្មករឡើងធ្វើការត្រូវមានផ្ទៃរាបស្មើ ហើយចន្លោះពីក្ដារនីមួយៗមិនត្រូវ ធំជាង ៥មមឡើយ។ បើក្ដារក្រាលរន្ទានៅកម្ពស់លើសពី 1.3ម៉ែត្រ ត្រូវមានបង្កាន់ដៃ និងរបាំងព័ទ្ធជុំវិញពីក្រោម។

**ក្នុងការប្រើប្រាស់រន្ទាត្រូវពិនិត្យ**

1. មុខតំណជាតុផ្សេងៗ។
2. ភាពរឹងមាំនៃកម្រាល និងភាពរឹងមាំរបស់វា។
3. ជំហរត្រង់របស់សសរ។
4. ពិនិត្យមើលចំណងដែលចងរន្ទាដើម្បីធានាភាពរឹងប៉ឹង(ឈើ)។
5. បើរន្ទាជាដែក ត្រូវបង្កប់ខ្សែចម្លងចរន្តទៅក្នុងដី(ក្នុងករណីមានអូសខ្សែ ភ្លើងធ្វើការងារផ្សេងទៀតនៅក្បែររន្ទា)
6. ក្នុងការប្រើរន្ទាត្រូវពិនិត្យរាល់ ១០ថ្ងៃម្ដង
7. បើក្នុងរយៈពេល ១ខែរន្ទាមិនត្រូវប្រើប្រាស់នោះ ចាំបាច់ត្រូវដំឡើងគ្រប់ចំនុច។
8. ក្រោយពេលភ្លៀង ឬក្រោយពេលទទួលឥទ្ធិពលមកានិចណាមួយនោះត្រូវពិនិត្យរន្ទាម្ដងទៀត។
9. ចន្លោះរវាងអគារ និងកម្រាល(L)៖
    - សម្រាប់ការរៀបឥដ្ឋ≤50mm។
    - សម្រាប់ការងារសម្អាតផ្សេងៗ L≤50mm។
    - អនុញ្ញាតឱ្យក្ដារជុលមុខគ្នាតែក្នុងករណីដែលមុខតំណជាន់លើមេទំរ។
    - ក្ដារត្រូវគងលើទំរលើសពី 0.20m។
    - ផ្ទៃដែលដាក់ជើងរន្ទាត្រូវបង្ហាប់ដើម្បីធានាការផុង ឬស្រុត។
    - រន្ទាត្រូវភ្ជាប់នឹងជញ្ជាំងអគារកំពុងសាងសង់។
10. មុនពេលចាប់ផ្ដើមធ្វើការងារដោយប្រើរន្ទាត្រូវពិសោធន៍រយៈពេល ១ម៉ោងដោយដាក់លើ រន្ទានៅបន្ទុកបទដ្ឋាន២០% ។
11. ជណ្ដើរផ្អែកប្រើតែក្នុងករណីដែលការងារតម្រូវឱ្យធ្វើនៅកន្លែងដំឡើងរន្ទាមិនកើត។
12. ជណ្ដើរផ្អែកមិនត្រូវមានកាំរង្វើលពេកទេ។ ត្រូវដាក់លើទំរមិនរអិល និងដាក់នៅក្នុងជំហរទ្រេតមានមុំជម្រាល ៧០°-៧៥°។

**ការដំឡើងរន្ទាមានកង់ គេត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖**

1. នៅពេលប្រើប្រាស់រន្ទានេះត្រូវដាក់កល់ និងភ្ជាប់ទៅនឹងជញ្ជាំងធ្វើយ៉ាងណាឱ្យស៊ុបល្អកុំឱ្យរអិល ឬប៉ះ។
2. រន្ទាត្រូវមានខ្ចៅភ្ជាប់ដែលការពារកុំឱ្យក្រឡាប់បាន។
3. រន្ទាត្រូវមានបង្គោលជ្រែង ឬខ្សែចងយឹតសងខាង។

**រន្ទាយោង**

រន្ទាយោងត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម៖

1. រន្ទាមិនត្រូវឱ្យលើសពី ៨ម៉ែត្រទេ។
2. ក្តារក្រាលលើរន្ទាត្រូវជិតល្អមិនត្រូវមានប្រឡោះទេ។
3. បន្ទះក្តារក្រាលរន្ទាត្រូវទ្រដោយខ្សែយោងតែមួយគត់ដែលមានប្រវែងលើសពី ៣.៥០ម។
4. ប្រសិនរន្ទាយោងត្រូវត្រៀមមនុស្សឱ្យឈរធ្វើការក្តារក្រាលបាតរន្ទាត្រូវរាបស្មើតាមប្លង់ដេក។
5. រន្ទាយោងត្រូវមានរបងសង់ខាងរុំព័ទ្ធជុំវិញដោយប្រឡោះពីបង្គោលបញ្ឈរ ពីមួយទៅមួយមិនឱ្យរង្វើលពេកទេគឺចន្លោះពី ១.៥ម៉ែត្រ រហូត២.០ម៉ែត្រ។

**ការរៀបចំកន្លែងបន្ថែមទៀត**

១. រន្ទាមិនត្រូវដាក់សម្ភារៈធ្ងន់ពេកទេនាំឱ្យលើសបន្ទុក។

២. មុននឹងដំឡើងឧបករណ៍ ឬសម្ភារៈលើកដាក់នៅលើរន្ទាត្រូវពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយពី របឹង និងលំនឹងរបស់រន្ទា។ ត្រូវយកដុំថ្ម ឬរបស់ប្រងេងប្រងាងចេញ ហាមមិនឱ្យយករបស់ដែលមិនបានចងភ្ជាប់មកដាក់នៅចុងរន្ទាដែលជាកន្លែងកម្មករដើរធ្វើការ។

៣. ការដំឡើង ឬដោះរន្ទាអាចធ្វើបានលុះត្រាតែ៖

- មានអ្នកឯកទេសម្នាក់នៅឈរ។
- អ្នកធ្វើការដាច់ខាតជាអ្នកប៉ិនប្រសព្វ និងមានជំនាញច្បាស់លាស់។
- អ្នកទទួលធ្វើការត្រូវពាក់ខ្សែក្រវ៉ាត់ ឬខ្សែពាក់ឈៀង ។
- នៅពេលដំឡើង ឬដោះរន្ទាត្រូវហាមមិនឲ្យមានមនុស្សដើរចេញចូលពីខាងក្រោម។
- ត្រូវប្រើខ្សែយោងទាំងពេលដំឡើង និងពេលដោះ ។

៤. រន្ទាទាំងអស់ត្រូវបានត្រួតពិនិត្យគ្រប់ជ្រុងនៃផ្នែកទាំងអស់យ៉ាងតិចរាល់បីខែម្តង។ លទ្ធផល និងកាលបរិច្ឆេទនៃការត្រួតពិនិត្យអំពីគុណភាព និងឈ្មោះអ្នកពិនិត្យត្រូវចុះក្នុងបញ្ជី ។

## សំណួរ

១. ដូចម្តេចដែលហៅថារន្ទា ?

២. រន្ទាធ្វើឡើងពីអ្វី ?

៣. រន្ទាមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

៤. ចូររៀបរាប់អំពីសារៈប្រយោជន៍របស់រន្ទា ?

## សុវត្ថិភាពការប្រើប្រាស់ម៉ាស៊ីនស្ទូច និងការបន្លាស់ទី

វិធីផ្លាស់ទីរបស់ម៉ាស៊ីនស្ទូច (Crane) ទោះបីចំពោះសំណង់ក៏ដោយ គឺមានម៉ាស៊ីនពិសេសដូចគ្នាទៅនឹងសំណង់វិស្វកម្មដែរ ។ បើគ្មានមធ្យោបាយផ្លាស់ទី Crane ទេសំណង់ស៊ីវិលក៏មិនអាចមានការរីក ចម្រើនទៅមុខដែរ ។

នៅឆ្នាំ ១៩៩៣ មនុស្ស ២០នាក់ស្លាប់ដោយសារម៉ាស៊ីនស្ទូចនៅក្នុងនោះ ១៥នាក់ស្លាប់ដោយសារវិធីផ្លាស់ទីម៉ាស៊ីនស្ទូច និងអ្នករងរបួសដោយមធ្យោយបាយផ្លាស់ទីម៉ាស៊ីនស្ទូចមានច្រើន។ គ្រោះថ្នាក់ដល់ស្លាប់ក្នុងពេលសាងសង់នៃការធ្វើចលនារបស់ Crane គឺកើតឡើងនៅពេលប្រតិបត្តិការសំណង់ស៊ីវិល ប៉ុន្តែបើយើងក្រឡេកមើលនៅឆ្នាំ ១៩៩៣ មាន ៤ករណីកើតឡើងចំពោះសំណង់ផ្លូវថ្នល់ក្រៅពីនេះភាគច្រើនកើតមាននៅពេលសាងសង់។

អញ្ចឹងហើយចូរពិនិត្យមើល តើគ្រោះថ្នាក់ដល់ស្លាប់ដោយសារការធ្វើចលនារបស់ Crane កើតឡើងនៅពេលណា?

- ស្លាប់ដោយសារការដួលរលំនៃ Truck Crane និង Wheel Crane គ្រោះថ្នាក់សង្កត់ និងកប់អ្នកបើកបរនៅក្នុងបន្ទប់បើកបរ។ គ្រោះថ្នាក់ដួលរលំនេះមានច្រើនណាស់គ្រោះថ្នាក់ដោយសារមធ្យោបាយផ្លាស់ទីរបស់ Grane មានប្រហែល៦០%។
- គ្រោះថ្នាក់ប៉ះ ឬកិនកម្មករពេលប្រដាប់ស្ទូចយោល និងការរមៀលនៃ Truck Crane និង Crane គ្រោះថ្នាក់នេះ តើវាមិនមែនជាគ្រោះថ្នាក់ដូចទៅនឹងទំនាក់ទំនងគ្រោះថ្នាក់ដួលរលំដែលមានរៀបរាប់ពីមុនឬ?
- គ្រោះថ្នាក់ដោយសារការគោបអីវ៉ាន់ និងម៉ាស៊ីនស្ទូចផ្សេងៗ។
- គ្រោះថ្នាក់នៃការធ្លាក់អីវ៉ាន់ស្ទូច គឺកើតមានច្រើន។
- គ្រោះថ្នាក់ដែលបណ្ដាលមកពីពេលរុះ Crane របស់ Tower Crane។ គ្រោះថ្នាក់នេះតែងតែកើតឡើងនៅពេលដោះ។
- គ្រោះថ្នាក់ភ្លើងឆក់នៅពេល Crane និង Tower Crane។ គ្រោះថ្នាក់នេះតែងតែកើតឡើងនៅពេលដោះ។
- គ្រោះថ្នាក់ភ្លើងឆក់នៅពេល Crane និង Tower Crane ប៉ះខ្សែភ្លើងអត់ស្រោម។ ដូចដែលបានឃើញខាងលើមកហើយគ្រោះថ្នាក់ដដែលៗ។មូលហេតុនៅពេលដួលរលំ ដោយមិនបោះចន្ទល់ទប់ ឬខ្សែកាបចងឃឹតដើម្បីទប់លំនឹង។ អាចបណ្ដាលមកពីជន្ទល់ទប់របូតចេញ ឬលេចចូលក្នុងដីដោយសារតែការវិនិច្ឆ័យរបស់អ្នកឯកទេសពុំបានត្រឹមត្រូវ ពុំគ្រប់គ្រាន់ចំពោះសុវត្ថិភាពណាមួយដោយអីវ៉ាន់ស្ទូចលើសទម្ងន់។

ចំណែកឯមធ្យោបាយផ្លាស់ទីរបស់ Crane វាមិនមែនជាគ្រោះថ្នាក់ដែលមិនអាចដឹងមុននោះទេរហូតមកដល់ពេលនេះគ្រោះថ្នាក់ដែលកើតឡើងគឺដោយសារមនុស្ស។

ចេញពីស្ថានភាពគ្រោះថ្នាក់ធ្លាក់របស់ និងដួលរលំនៅពេល Crane ផ្លាស់ទីនៅឆ្នាំ ១៩៩២ច្បាប់សុវត្ថិភាពសុខភាពត្រូវបានគេកែប្រែ ប៉ុន្តែកន្លែងការងារភាគច្រើនទើបតែធ្វើការអនុវត្ត។ គ្រោះថ្នាក់ភាគច្រើនគេឃើញបង្កើតនៅពេលដែល Crane ផ្លាស់ទី។ កាលណាគ្រោះថ្នាក់កើតឡើងនោះ ក្រុមហ៊ុនក៏ទទួលគ្រោះថ្នាក់។

ចូរយើងអនុវត្តការងារដោយសុវត្ថិភាពបំផុត។ ដូច្នេះចូរយើងធ្វើការកែប្រែច្បាប់សុវត្ថិភាព និងសុខភាពផង និងបង្ហាញចំណុចវិធានការទប់ស្កាត់គ្រោះថ្នាក់ដួលរលំនៃ Craneផង។




រូបភាព៨២ គ្រោះថ្នាក់ពេលស្ទូច

**វិធានការទប់ស្កាត់គ្រោះថ្នាក់ដួលរលំនៅពេល Crane ផ្លាស់ទី**

ក.កន្លែងដែលមានគ្រឹះបិទបាំង ឬមានរបស់កប់ក្នុងដី និងរបស់កម្ទេចកម្ទីសំរាមមានកប់ក្នុងដី ធ្វើឲ្យដីមិនហាប់បណ្តាលឲ្យដីមានស្រុតចុះធ្វើឲ្យមានការរលំ។ មិនត្រូវឲ្យCrane ធ្វើការនៅកន្លែងបែបនេះទេ។

ខ.លើកលែងតែមានដែកមាំធំពិសេសអាចការពារការដួលរលំបានដោយដាក់ជន្ទល់ នៅចំផ្នែកកណ្តាលនៃដែកបន្ទះនោះ។ មុនពេលក្រាលបន្ទះដែកត្រូវក្រាលថ្មគ្រួលខ្សាច់ បន្ទាប់មកក្រាលដែកបន្ទះលើនោះ។ម្យ៉ាងទៀតទោះបីមានករណីប្រើ Crane ធុនតូចនៅលើផ្លូវក៏ដោយ គឺអាចមានគ្រោះថ្នាក់ដូចគ្នាទៅនឹង Crane ធម្មតាដែលមានជន្ទល់របស់តូច។ ទម្ងន់ប្រមូលផ្តុំងាយដួលដូច្នេះចូរយើងក្រាលបន្ទះដែកជាចាំបាច់។

គ.នៅពេលសាងសង់ប្រើ Tower Crane និង Crane មានជន្ទល់ទប់ គឺជន្ទល់ដែលលយចេញដោយដែនកំណត់ធំបំផុត។ ប៉ុន្តែនៅតាមកន្លែងមានករណីខ្លះពុំងាយបន្លាយចេញបានធំទេ ដោយកន្លែងតូចចង្អៀត។ ក្នុងករណីបែបនេះ ទម្ងន់ត្រូវកំណត់ដើម្បីឆ្លើយតប និងទទឹងដែលបានលយចេញរបស់ Crawler ឬជន្ទល់ទប់ ដូច្នេះអីវ៉ាន់ស្ទូចត្រូវកំណត់មិនឲ្យលើសទម្ងន់ជាដាច់ខាតការដែលមិនបន្លាយចេញបានដែនកំណត់ធំបំផុត ត្រូវបានគេអនុគ្រោះ។ គ្រោះថ្នាក់ដួលរលំរបស់ Crane ពេលផ្លាស់ទីដោយសារជន្ទល់ទប់ និងCrawler មិនអាចបញ្ចេញបានអស់ករណីបង្វិលរបស់ស្ទូច ដោយសារបានប្រើខុសទទឹងបញ្ចេញទាំងអស់ ករណីបង្វិលរបស់ស្ទូចដោយសារបានប្រើខុសទទឹងបញ្ចេញទាំងអស់ឧបករណ៍ការពារការផ្ទុកលើសមានសកម្មភាពមិនមានប្រសិទ្ធភាពមូលហេតុទាំងនេះមានច្រើនណាស់។ ជាពិសេសកើតឡើងច្រើននៅពេលបង្វិលទៅស្តាំស្ទូចអីវ៉ាន់ទៅមុខ។ ចូរយើងយកចិត្តទុកដាក់ និងការពារដោយបញ្ជាក់ឲ្យច្បាស់ដោយភ្នែកផ្ទាល់នូវទម្ងន់កំណត់ដែលបានឆ្លើយតបទៅនឹងការលយចេញ និងទម្ងន់អីវ៉ាន់ស្ទូចម្តងទៀត។



ឃ. ក្នុងករណីអ្នកកុងត្រាទាក់ទិននឹងការសាងសង់តាមរយៈ Crane អ្នកម៉ៅការត្រូវជូនដំណឹងមុនគេចំពោះករណីដែលត្រូវកើតឡើងនៅកន្លែងជិត និងផ្លូវអគ្គិសនីនៃខ្សែភ្លើង និងកន្លែងដែលមានការព្រួយបារម្ភ Crane ដួលនៅពេលធ្វើចលនា ត្រូវតែតម្រូវឲ្យមានការទប់ស្កាត់ការដួលរលំ និងសហការជាមួយអ្នកដែលពាក់ព័ន្ធដើម្បីណែនាំពីបច្ចេកទេសដើម្បីការពារការដួលរលំផ្សេងៗ និងផ្តល់ព័ត៌មានពីស្ថានភាពគុណភាពដីនៃកន្លែងដែលជាប់ពាក់ព័ន្ធ។

**វិធានការទប់ស្កាត់គ្រោះថ្នាក់ដោយសារការប៉ះទង្គិច**

នៅក្នុងបរិវេណបង្ហិលដែលមានការព្រួយបារម្ភប៉ះទង្គិចជាមួយដងបង្ហិលផ្នែកខាងលើគឺត្រូវបង្កើតតំបន់ហាមចូលមិនអនុញ្ញាតឲ្យកម្មករចូលទេ។







រូបភាព៨៣ ប៉ះទង្គិចជាមួយដងបង្ហិល

**វិធានការទប់ស្កាត់គ្រោះថ្នាក់ដោយសារការធ្លាក់អីវ៉ាន់ស្ទូច**

១.គ្រោះថ្នាក់ធ្លាក់អីវ៉ាន់ស្ទូច គឺខ្សែកាបដែលប្រើបានដោយសារចងខ្សែកាបស្ទូចមួយសរសៃ គឺមិនសមរម្យទេការរបូតខ្សែកាបដែលចងចេញពីទំពក់ខ្សែកាបប្រើដើម្បីលើកឥវ៉ាន់ដែលពទ្ធ័ជុំវិញដងស្ទូចដាច់ឥវ៉ាន់ស្ទូចយោលទៅចំហៀងម្ខាងទាក់នឹងរបា។ ដោយសារតែការកែប្រែច្បាប់សុត្ថិភាព និងសុខភាពCrane៖

ក.អីវ៉ាន់ស្ទូចដោយប្រើឡានស្ទូច។

ខ.អីវ៉ាន់ដែលចងស្ទូចដោយប្រើខ្សែកាប។

គ.អីវ៉ាន់ដែលចងស្ទូចដោយប្រើអង្គំ(ម្នី)ស្ទូចជាមួយ។

ឃ.ករណីអីវ៉ាន់រាយគេស្ទូចឡើងដោយដាក់នៅក្នុងកន្ត្រក ឬឡាំងដោយប្រើទំពក់ថ្កក់។

ង.អីវ៉ាន់ដែលចងស្ទូចដោយប្រើមេដែក។

ដើម្បីការពារគ្រោះថ្នាក់ដែលកើតឡើងដោយសារលើកដាក់អីវ៉ាន់ដោយប្រើឡានស្ទូចមិនអនុញ្ញាតឲ្យអ្នកប្រតិបត្តិការការងារចូលទៅក្រោមអីវ៉ាន់ដែលស្ទូចនោះឡើយ។ ក្រោយពីត្រួតពិនិត្យការចងស្ទូចរួចហើយត្រូវជៀសចេញពីតំបន់ដែលអីវ៉ាន់នោះអាចវិលទៅប៉ះដល់ និងក្រោមអីវ៉ាន់ដែលបានស្ទូចនោះ។

២.ចំពោះការងារដែលឡានស្ទូចធ្វើចលនាក្រុមហ៊ុនជួលឡានស្ទូច ត្រូវបំពេញការងារជាមួយគ្នា ដើម្បីការពារគ្រោះថ្នាក់ដែលបណ្តាលមកពី ការប្រតិបត្តិការការងារមិនបានត្រឹមត្រូវ។ ត្រូវតែចេះសម្របសម្រួលទាក់ទងគ្នារវាងអ្នកធ្វើកុងត្រា និងអ្នកពាក់ព័ន្ធក្នុងកុងត្រាពេលធ្វើការងារ។

**សុវត្ថិភាពនៃការដោះ និងដំឡើង Tower Crane**

១.តែងតាំងអ្នកដឹកនាំការងារដោះ និងដំឡើង។

២.អ្នកដឹកនាំការងារត្រូវមានសមត្ថភាពទាំងផ្នែកបច្ចេកទេស និងគ្រប់គ្រង។

៣.ពេលធ្វើការហាមមិនឲ្យមនុស្សដើរចេញចូល។

៤.ពេលមានភ្លៀង ខ្យល់ និងអ័ព្ទខ្លាំង ត្រូវផ្អាកការងារ។

៥.ត្រូវប្រើខ្សែរ៉កទាំងពេលដំឡើង និងដោះចេញ។

៦.ត្រូវរៀបចំប្រព័ន្ធបញ្ជាឲ្យបានត្រឹមត្រូវ។

៧.អ្នកបញ្ជា Tower Crane ត្រូវមានសមត្ថភាពគ្រប់គ្រាន់។

អញ្ចឹងហើយយើងឃើញវិធានការសុវត្ថិភាពជាច្រើន តែងតែផ្តោតអារម្មណ៍ទៅលើគ្រោះថ្នាក់ច្រើនដែលកើតឡើង។



រូបភាព៨៤ Tower crane

## សំណួរ

១. ស្វែងរករូបភាព Bulldozer, Tractor Shovel, Power Shovel, Drag Shovel, Clam Shell, Roller, Motor Crater, Tire Shovel , Tire Roller, ក្នុងរូបនីមួយៗឱ្យបាន៣។

២. ចូរវិភាគរូបទី១មានន័យដូចម្តេច។

៣. ចូរវិភាគរូបទី២មានន័យដូចម្តេច។

៤. ចូររៀបរាប់អំពីគ្រោះថ្នាក់ដែលបង្ករដោយ Tower Crane និងវិធីការពារគ្រោះថ្នាក់។

៥. តើប្អូនទទួលបានអត្ថប្រយោជន៍អ្វីខ្លះនៅក្នុងមេរៀននេះ?

## វិធានការសុវត្ថិភាពនៃប្រតិបត្តិការដោយប្រើគ្រឿងចក្រសំណង់

សំណង់ស៊ីវិល និងម៉ាស៊ីនសំណង់មានទំនាក់ទំនងគ្នាមិនអាចកាត់ផ្តាច់ពីគ្នាបានឡើយនៅក្នុងនោះ មានដូចជាម៉ាស៊ីនប្រើសម្រាប់ដឹកជញ្ជូន និងពង្រាបដី ,Bulldozer Tractor Shovel ម៉ាស៊ីនដើម្បីប្រើសម្រាប់ ជីកខួងដី Power shovel, Drag shovel, Clam shell ,ម៉ាស៊ីនប្រើសម្រាប់បង្ហាប់ដី Roller ឡានដឹកជញ្ជូន ដីដែលមិនរាបស្មើ គឺប្រើប្រាស់ញឹកញាប់។ គ្រោះថ្នាក់នៅពេលការងារកើតញឹកញាប់ណាស់ដោយសារម៉ាស៊ីន ទាំងនោះ។

ដូច្នេះហើយចូរយើងយកចិត្តទុកដាក់ចំពោះការគ្រោះថ្នាក់ដែលកើតមានឡើងនៅពេលបំពេញការងារ នៃម៉ាស៊ីនសំណង់ទាំងនោះ។

ដោយសារតែគ្រឿងចក្រសំណង់នៅឆ្នាំ ១៩៩៣ មនុស្ស ១២១នាក់ត្រូវស្លាប់។ តាមរយៈការងារ ផ្សេងៗ ៣៨នាក់ស្លាប់ដោយសារសង់ផ្លូវថ្នល់, ២៦នាក់ស្លាប់ដោយសារការពង្រាប់ដី, ១០នាក់ស្លាប់ដោយសារសាងសង់ ផ្លូវលូ និងប្រឡាយ ៥នាក់ស្លាប់ដោយសារការសង់សំណង់ការពារដីខ្សាច់ ៤នាក់ស្លាប់ដោយសារសំណង់Tunel។

ប្រសិនបើយើងមើលទៅប្រភេទផ្សេងៗនៃម៉ាស៊ីនទាំងនោះមានមនុស្ស ៧៦នាក់ស្លាប់ដោយសារ ម៉ាស៊ីនជីក ឬខួងដូចជាPower shovel និង Drag shovel ចំនួនស្លាប់នេះគឺជាងពាក់កណ្តាលនៃចំនួន១២១ នាក់។ បន្ទាប់មក១៦នាក់ស្លាប់ដោយសារ Roller , ១០នាក់ស្លាប់ដោយសារម៉ាស៊ីនដឹកជញ្ជូន និងពង្រាប់ដី Bulldozer ក្រៅពីនេះស្លាប់ដោយសារមធ្យោបាយផ្សេងៗ។

ចំពោះគ្រឿងសំណង់ តើគ្រោះថ្នាក់កើតឡើងរបៀបណា? ប្រសិនបើយើងមើលដោយយោងទៅតាម សំណង់ផ្លូវដែលធ្វើឱ្យមានការគ្រោះថ្នាក់ដល់ស្លាប់ច្រើនដោយសារម៉ាស៊ីនសំណង់នោះមាន ស្ថានភាពដូច គូសបញ្ជាក់ខាងក្រោម។ សូមមើលជួរតាមលំដាប់លំដោយៈ

ក.ការធ្លាក់ពីស្មាផ្លូវ( Drag shovel ,Roller, Tractor shovel )។

ខ.ការធ្លាក់ពីដីជម្រាល( Drag shovel , Tractor shovel )។

គ.ការដែលត្រូវបានរុញផ្ទប់ និងគាបជាមួយឥវ៉ាន់ និងម៉ាស៊ីន( Drag shovel )។

ឃ.ការត្រូវឡានកិន ជាពិសេសនៅពេលឡានថយក្រោយ( Drag shovel Bulldozer Motor Crater )។

ង.ត្រូវគាបដោយឥវ៉ាន់ស្ទូចនៅពេលវិល ឬធ្លាក់ពីលើ( Power shovel, Drag shovel, Tire shovel )។

៦.ការរលំសង្កត់ដោយរថយន្តសណ្តោងនៅពេលផ្លាស់ទីគ្រឿងចក្រ( Dragshovel, Roller )។

ច.ការរអិលគ្រឿងយន្តនៅពេលឈប់លើដីជម្រាល( Tire Roller )។

ឆ.ការដួលដោយឥវ៉ាន់លើសទម្ងន់( ម៉ាស៊ីនដកសសរ )។



**គម្រោងសាងសង់ និងការស្រាវជ្រាវ**

សំណង់ស៊ីវិលគឺជាការប្រឡូកជាមួយដី ត្រូវពិនិត្យជាមុននូវដីដែលជាគោលដៅនោះ ធ្វើយ៉ាងណាក៏ដោយកុំឱ្យមានការខ្វះខាតនៃជំហានដំបូងនេះ។ ម៉ាស៊ីនសំណង់ គឺសូមធ្វើការកត់ត្រាស្រាវជ្រាវ លក្ខណៈ គុណភាព និងទ្រង់ទ្រាយនៃដីដែលត្រូវឆ្លងកាត់។ ប្រសិនបើការស្រាវជ្រាវត្រូវបានបញ្ចប់ហើយគេត្រូវបង្កើតគម្រោងសំណង់សម្រាប់ការងារបន្តបន្ទាប់។

១.តើគេប្រើប្រាស់គ្រឿងសំណង់ឡានដោយវិធីណា? សមត្ថភាពម៉ាស៊ីនយ៉ាងណា?

២.តើផ្លូវសម្រាប់ចរាចរណ៍ម៉ាស៊ីនសំណង់ឡានយ៉ាងម៉េច?

៣.តើការសង់បែបណានៅពេលប្រើប្រាស់ម៉ាស៊ីនសំណង់ចូរកំណត់គោរពទៅតាមលក្ខណៈ គុណភាព និងទម្រង់ដីទោះជាមានល្បឿនកំណត់នៃម៉ាស៊ីនយ៉ាងណាក៏ដោយ។ ល្បឿនគ្រឿងចក្រ សំណង់ត្រូវកំណត់ក្រោម ១០គីឡូម៉ែត្រ ក្នុង ១ម៉ោង។

អញ្ចឹងហើយដោយសារតែការកែកាន់តែប្រសើរ ច្បាប់សុវត្ថិភាពការងារ និងសុខភាពអ្នកម៉ៅការធ្វើការងារនៅម្តុំនោះជាមួយនឹងការបើកបរម៉ាស៊ីនគ្រឿងចក្រសំណង់ពេល គឺចំពោះកិច្ចការចំរុះនេះពុំមាន ការសម្រួលឱ្យបានគ្រប់គ្រាន់ នៃការងាររបស់មនុស្ស ដែលជាប់ពាក់ព័ន្ធនឹងកិច្ចសន្យា ដើម្បីទប់ស្កាត់គ្រោះថ្នាក់ការងារនេះអ្នកម៉ៅការត្រូវបង្ហាញអំពីការចាត់ចែងសំណង់បណ្តោះអាសន្នសម្រាប់ប្រើប្រាស់ក្នុងពេលសាងសង់ដាក់ឧបករណ៍ម៉ាស៊ីនសំណង់ដែលចាំបាច់ និងប្លង់ដែលទាក់ទិននឹងការងារចំរុះដែលមាននៅក្នុងប្លង់គម្រោងសាងសង់ដែលនឹងត្រូវធ្វើ។ ម្យ៉ាងវិញទៀត(អ្នកទាមទារដែលជាប់ពាក់ព័ន្ធ និងកិច្ចសន្យាកុងត្រាមុនដោយមានករណីកិច្ចសន្យាកុងត្រាជាន់គ្នាជាមួយលើកទី២ និងលើកទី៣) តាមមាត្រា១៥ នៃច្បាប់សុវត្ថិភាពការងារ និងសុខភាព ចំពោះការងារដែលប្រើប្រាស់គ្រឿងសំណង់ឡាន ដែលមានទម្ងន់ម៉ាស៊ីន និងប្រដាប់បូមលើសពី៣តោន ចំពោះអ្នកជាប់កុងត្រាដែលមានការពាក់ព័ន្ធត្រូវតែដឹកនាំ ឬចាត់ចែងយ៉ាងណាដោយផ្អែកទៅលើច្បាប់សុវត្ថិភាព និងសុខភាព។

ដូច្នេះអ្នកដែលជាប់ពាក់ព័ន្ធនឹងកុងត្រាមុន គឺអ្នកមានកុងត្រាបន្ទាប់ត្រូវមានគម្រោងសាងសង់ដោយម៉ាស៊ីនសំណង់ឡាន ដែលបង្កើតឡើងអ្នកជាប់កុងត្រាពីមុននោះ ត្រូវដឹកនាំឱ្យមានការសមស្របទៅនឹងគម្រោងសំណង់ដែលបានបង្កើតឡើង។

### វិធានការទប់ស្កាត់នៃការដួលរលំ និងការធ្លាក់

ដើម្បីទប់ស្កាត់ការគ្រោះថ្នាក់ការធ្លាក់ភាគច្រើនដោយសារម៉ាស៊ីន គ្រឿងចក្រសំណង់។ សូមអនុវត្តមាតិកាខាងក្រោម៖

១. កុំឱ្យខូចស្នាផ្លូវនៃផ្លូវបើកបរ។

២. កុំឱ្យស្រុតមិនស្មើគ្នា នៃផ្លូវបើកបរ។

៣. រក្សាទទឹងផ្លូវបើកបរ។

៤. នៅពេលសាងសង់ដោយប្រើឡានម៉ាស៊ីនសំណង់ នៅលើដីជម្រាល និងស្នាផ្លូវត្រូវចាត់ចែងអ្នកដឹកនាំឱ្យធ្វើការចាត់ចែង។

ម៉្យាងទៀតចំពោះឡានគ្រឿងចក្រសំណង់ មានកម្រិតក្នុងការសាងសង់ត្រូវបានគេកំណត់កម្រិតសុវត្ថិភាព តើការដួលរលំ និងការរមៀលរហូតដល់មុំប៉ុន្មាន? នៅពេលសាងសង់ត្រូវពិនិត្យឱ្យបានជិតដល់នូវមូលដ្ឋាននៃកម្លាំងទ្រ និងកម្រិតសុវត្ថិភាពនៅពេលបង្កើតគម្រោងសាងសង់ដោយគូសបញ្ជាក់ជាមុន។

ចំពោះការទប់ស្កាត់ការដួលរលំ នៃម៉ាស៊ីនសម្រាប់សង់គ្រឹះម៉ាស៊ីន តាមរយៈការកែសម្រួល នៃច្បាប់សុវត្ថិភាព និងសុខភាព អ្នកជាប់កុងត្រាលើកដំបូងត្រូវតែណែនាំបច្ចេកទេស ដើម្បីទប់ស្កាត់ការដួលរលំ និងផ្តល់ព័ត៌មាន ស្តីពីស្ថានភាពគុណភាពដី ចំពោះការរៀបចំដាក់ម៉ាស៊ីនសំណង់ ក្រៅពីនេះអ្នកជាប់កុងត្រាលើកដំបូងខ្លួនឯង ឬអ្នកពាក់ព័ន្ធនឹងកុងត្រាត្រូវតែបង្កើតវិធានការទប់ស្កាត់ការដួលរលំនោះ។

### វិធានការទប់ស្កាត់ការប៉ះទង្គិច

គ្រោះថ្នាក់ប៉ះទង្គិច ដែលកើតឡើងពីម៉ាស៊ីនថតចម្លងច្រើនវិធានការ គឺងាយស្រួលបំផុតត្រូវមានវិធានការហាមចូល។ បញ្ហានេះប្រសិនបើស្មុគស្មាញត្រូវរៀបចំឱ្យមានអ្នកដឹកនាំហើយឱ្យអ្នកនោះចាត់ចែងបញ្ហានេះ។ សូមកំណត់សញ្ញា។



### វិធានការសុវត្ថិភាពនៅពេលដាក់ចុះ ឬគរដើម្បីផ្លាស់ទីគ្រឿងសំណង់

ដើម្បីផ្លាស់ទីគ្រឿងចក្រសំណង់គេផ្ទុកនៅលើឡានសណ្តោង និងកាមីញ៉ុង នៅពេលផ្ទុក គឺកើតមានគ្រោះថ្នាក់ធ្លាក់ពីលើរថយន្តផ្ទុកនោះ។ ករណីដាក់ចុះពីលានសណ្តោង សូមគោរពតាមការងារដូចខាងក្រោម៖

១.ពេលដាក់ចុះត្រូវដាក់កន្លែងរឹង និងស្មើ។

២.នៅពេលប្រើប្រាស់បន្ទះក្រាលផ្លូវ ត្រូវប្រើបន្ទះក្រាលដែលមាន ទទឹងបណ្តោយសមរម្យត្រូវគិតគូរដល់លទ្ធភាព នៃកម្លាំងសង្កត់ម៉ាស៊ីននៅពេលដាក់ចុះ ជាការពិតណាស់ត្រូវឱ្យឡានកាមីញ៉ុងស្ថិតនៅជម្រាលដែលមានសុវត្ថិភាព។

៣.នៅពេលប្រើកំណល់បណ្តោះអាសន្ន និងដីដែលបានរៀបចំត្រូវជានាជម្រាល ភាពមាំ និងទទឹងឱ្យបានសមរម្យ។

**វិធានការសុវត្ថិភាពនៃការស្ទូចអីវ៉ាន់តាមរយៈម៉ាស៊ីនឡានសំណង់**

ចំពោះការលើកអីវ៉ាន់តាមរយៈ Power Shovel យើងគិតថាអ្នកមានការយល់ តាំងពីមុនមកម្ល៉េះ ការប្រើប្រាស់ខុសពីធម្មតាតាមច្បាប់ត្រូវហាមឃាត់។ កន្លែងដែលគ្រោះថ្នាក់កើតឡើងកម្មករត្រូវបានកប់ ហើយត្រូវបានធ្លាក់ចុះនៃសន្ទូចដោយសារការប្រើប្រាស់ខុសពីធម្មតា។

ប៉ុន្តែដោយសារការកែប្រែច្បាប់សុវត្ថិភាព និងសុខភាពវិធានការសុវត្ថិភាព ត្រូវបានកំណត់តាមលក្ខណៈដូចខាងក្រោម៖

១.បើកន្លែងការងារតូចចង្អៀតវិធីផ្លាស់ប្រដាប់ស្ទូចចូលនោះវាស្មុគស្មាញផ្ទុយទៅវិញគ្រោះថ្នាក់ត្រូវគេគិតថាកើនឡើងនៅពេលគេមិនអាចបញ្ឈប់ការងារនោះ ឬវាមិនចាំបាច់ត្រូវសាង់សង់ប្រកបដោយសុវត្ថិភាព។

២.ចំពោះឧបករណ៍សាងសង់កន្រ្តក និងដៃស្ទូចត្រូវជាប់ល្អកុំឱ្យឥវ៉ាន់ធ្លាក់ ឧបករណ៍កុំឱ្យរញ្ជែកចេញត្រូវបានគេប្រើប្រាស់ ដើម្បីកុំឱ្យរបូតចេញពីឧបករណ៍គ្រឿងខ្ចៅ។ល។ ត្រូវភ្ជាប់នៅពេលគេប្រើប្រាស់។

៣.ទម្ងន់សរុបនៃប្រដាប់ស្ទូច និងឥវ៉ាន់ស្ទូចត្រូវតិចជាងទម្ងន់នៃម៉ាស៊ីនស្ទូចមួយតោន។ ចំពោះការប្រើប្រាស់ខុសពីធម្មតា វាចាំបាច់ណាស់ដែលទាក់ទិនទៅនឹងផ្នែកណាមួយពី(១) ដល់(៣)ខាងលើ។

ប៉ុន្តែ(១) ករណីស្ទូចឥវ៉ាន់ដោយប្រើ Clan shell bucket Powers shovel និង drug shovel លើសពី ៣តោននៃទម្ងន់ម៉ាស៊ីន (២)ករណីសាងសង់ដោយប្រើ earth auger, earth drill ម៉ាស៊ីនវាយបង្គោល ម៉ាស៊ីនដកបង្គោលកម្មករត្រូវមានលើសពី ពីរ ឬបីនាក់នៅកន្លែងតែមួយ។ ចំពោះករណីដែលប្រើម៉ាស៊ីនដែលបានរៀបរាប់ខាងលើការសម្របសម្រួលដែលទាក់ទងទៅនឹងពេលបំពេញការងារគ្រោះថ្នាក់ ដែលកើតឡើងដោយពុំមានការពេញចិត្ត គឺមានមិនតិចទេ។ អ្នកម៉ៅការដែលបានទទួលម៉ៅការបន្ត ការងារមួយផ្នែកបានធ្វើការនេះដោយខ្លួនឯង ចំពោះតំបន់ដែលហាមចូល និងប្រព័ន្ធការងារ និងប្រព័ន្ធបញ្ជាត្រូវតែសម្របសម្រួលទំនាក់ទំនងទៅវិញទៅមករវាងអ្នកកុងត្រា និងអ្នកពាក់ព័ន្ធនឹងកុងត្រា។ សូមអនុវត្តឱ្យបាន ព្រោះវាជាការចាំបាច់ណាស់។

**សន្តិសុខការងារសាងសង់ដោយប្រើចរន្តអគ្គិសនីនៅក្នុងការដ្ឋាន**

**ការត្រួតពិនិត្យអគ្គិសនីដើម្បីសុវត្ថិភាព**

ក.ផ្លូវដែលអគ្គិសនីរត់ឆ្លងកាត់ត្រូវមានសភាពល្អ។

ខ.លក្ខខណ្ឌសម្រាប់ទាញខ្សែកាប ឬរូឡដើម្បីយកមកប្រើប្រាស់។

នៅលើរូឡគេមានកំណត់ចំនួនអំពៃដែលត្រូវប្រើ បើប្រើលើសខ្សែភ្លើង និងឡើងកម្តៅ ធ្វើឱ្យឆេះ អីសូឡង់ជាហេតុធ្វើឱ្យខ្សែភ្លើងរលាយ និងបង្កគ្រោះថ្នាក់។

ឧទាហរណ៍៖ ចំពោះរូឡ

១.ខ្សែលាតកំណត់បរិមាណអគ្គិសនីប្រើ ១៥អំពៃ

២.ខ្សែរុំកំណត់បរិមាណអគ្គិសនីប្រើ ៥អំពៃ

គ.ការតភ្ជាប់ពីខ្សែភ្លើងមួយទៅខ្សែភ្លើងមួយទៀត ត្រូវប្រើក្បាលត(ឧបករណ៍សម្រាប់ភ្ជាប់ចរន្ត)។

ឃ.មិនត្រូវប្រើខ្សែភ្លើងដែលមានសភាពរួញ ឬអង្កាញ់ទេ។

**ការទប់ស្កាត់គ្រោះថ្នាក់អគ្គិសនី និងការឆ្លងអគ្គិសនី**

ហេតុអ្វីបានជាមនុស្សត្រូវអគ្គិសនីឆក់?

បើយើងក្រឡេកមើលសត្វចាបវាមិនបានត្រូវចរន្តអគ្គិសនីឆក់ទេ ព្រោះជើងរបស់វាមានអ៊ីសូឡង់ ហើយវាមិនអាចមានលំហូរអគ្គិសនីឆ្លងកាត់ខ្លួនវា តែមនុស្សឆក់អគ្គិសនីព្រោះតែមនុស្សឈរនៅលើដី ហើយធ្វើឱ្យចរន្តអគ្គិសនីឆ្លងកាត់ពីមនុស្សចូលទៅក្នុងដី។ ម្យ៉ាងទៀត ការតខ្សែភ្លើងគ្មានលក្ខណៈបច្ចេកទេស។

**ចរន្តអគ្គិសនីពេលវត់ឆ្លងកាត់មនុស្ស និងផលប៉ះពាល់**

ក. 1 MA ធ្វើឱ្យស្ពឹកសាច់ដុំ។

ខ. 5 MA ធ្វើឱ្យឈឺចាប់ល្មម។

គ. 10 MA ធ្វើឱ្យឈឺចាប់មិនអាចទ្រាំបាន។

ឃ. 20 MA ធ្វើឱ្យសាច់ដុំរឹង និងពិបាកដកដង្ហើម។

ង. 50 MA ធ្វើឱ្យគ្រោះថ្នាក់អាចស្លាប់បាន។

ច. 100 MA ធ្វើឱ្យគ្រោះថ្នាក់ដល់ជីវិត។

**មធ្យោបាយក្នុងការជួយសង្គ្រោះ**

-ការការពារ និងទប់ការរលាករហូតដល់បេះដូង។

-ប្រើចរន្តដែលមានតង់ស្យុង១២ ទៅ៣៦វ៉ុល។

-ខ្សែកាបត្រូវកប់ក្នុងដី។

-ការពារមិនឱ្យមនុស្សចូលទៅប៉ះចរន្តអគ្គិសនី។

-ប្រើមធ្យោបាយការពារផ្ទាល់ខ្លួន(ស្បែកជើងកៅស៊ូ ស្រោមដៃការពារ ឧបករណ៍មិនចម្លងចរន្ត ឬបិទកុងតាក់)

១ ការជួយមនុស្សដែលរងគ្រោះដោយចរន្តអគ្គិសនី យកចេញពីចរន្តអគ្គិសនី ផ្តាច់ចរន្ត។

២ ប្រសិនមនុស្សនៅដកដង្ហើម(ដឹងខ្លួន) ចាំបាច់ត្រូវលើកគាត់មកទីវាល ហើយដាក់នៅកន្លែងសមរម្យ ឱ្យគាត់ស្រូបប្រេងខ្យល់ ឬបំពង់ហឺតតាមច្រមុះ ហើយគ្របគាត់ដោយភួយស្តើង។

៣ បើសិនមនុស្សបាត់បង់វិញ្ញាណ និងមិនដកដង្ហើមយកគាត់ចេញពីឥទ្ធិពលនៃចរន្តដាក់គាត់នៅកន្លែងមានខ្យល់អាកាសល្អហើយ ឱ្យគាត់ដេកស្មើលើទីសមរម្យ បើកមាត់របស់គាត់ហើយចាំទាញអណ្តាតចាប់ផ្តើមឱ្យគាត់ដកដង្ហើមសិប្បនិម្មិតដោយផ្លុំឱ្យបញ្ចូលតាមមាត់។ ខ្យល់ទៅអ្នករងគ្រោះរយៈពេល៥ទៅ៦នាទី និងធ្វើគាត់ពីក្រៅនៃបេះដូងផ្នែកខាងក្រោម។

**ការប្រុងប្រយ័ត្នដើម្បីកុំឱ្យឆក់ចរន្តអគ្គិសនី**

ក.មិនត្រូវដាក់ខ្សែភ្លើងឱយ ឬព្រីនៅជិតទឹក ឬកន្លែងដើរឆ្លងកាត់។

ខ.ដៃសើមមិនត្រូវប៉ះឧបករណ៍ ឬចរន្តអគ្គិសនីព្រោះចរន្តអាចឆ្លងកាត់កាន់តែខ្លាំង។

គ.ប្រើឌីសង់ទ័រព្រោះវាជាឧបករណ៍សុវត្ថិភាព សម្រាប់ផ្តាច់ភ្លើងដោយស្វ័យប្រវត្តិ ពេលមានបញ្ហាឆ្លងភ្លើង ឬចរន្តជាដើម ប៉ុន្តែវាមិនអាចការពារពេលមនុស្សដួល ឬធ្លាក់ពីទីខ្ពស់បានទេ។

ឃ.ករណីប្រើឌីសង់ទ័របើចរន្តឆក់តិចជាង៣០ មិនគ្រោះថ្នាក់ដល់ជីវិតទេ។

ង.ឱសង់ទ័រ គឺមិនអាចការពារ ១០០ភាគរយបានទេ យើងនៅមានវិធីមួយទៀត គឺដាក់ខ្សែម៉ាសដី ព្រោះពេលឆក់ចរន្តរត់ចូលទៅក្នុងដី។

**វិធីការពារផ្សេងៗ**

ក.ការការពារពេលឆ្លងភ្លើងគឺយើងត្រូវពិនិត្យមើលខ្សែម៉ាសឱ្យបានត្រឹមត្រូវ បើសិនជាខ្សែមិនត្រឹមត្រូវបណ្តាលឲ្យខ្សែម៉ាសរបស់យើងគ្មានប្រសិទ្ធភាព។

ខ.ការពិនិត្យសុវត្ថិភាពគឺយើងត្រូវពិនិត្យមើលខ្សែភ្លើង ឬឌុយដែលមិនត្រឹមត្រូវ ឬដាច់រលាត់ត្រង់ចំណុចណាមួយយើងត្រូវធ្វើការផ្លាស់ប្តូរវាចេញ។ ចំពោះខ្សែភ្លើង និងឌុយមិនត្រូវដាក់វត្ថុធ្ងន់ៗ ឬដើរជាន់លើវាឡើយ។

គ.ការព្យាបាលពេលរលាកគឺក្នុងករណីនេះការឆក់មានលក្ខណៈស្រាលវាអាចបណ្តាលឲ្យរលាកយើងត្រូវសង្គ្រោះបឋម ចំពោះករណីធ្ងន់ត្រូវហៅឡានពេទ្យជាដើម។

ឃ.ដំណោះស្រាយពេលដាច់ភ្លើង ត្រូវកាច់បារ៉ែត ឬបិទកុងតាក់ជាមុន បន្ទាប់មករាយការណ៍ទៅអ្នកទទួលខុសត្រូវ។ ហើយក្នុងករណីពេលមានចរន្តឡើងវិញត្រូវពិនិត្យម៉ាស៊ីន និងកុងតាក់ជាមុន។

ង.បញ្ហាអគ្គិភ័យ យើងត្រូវកាច់បារ៉ែត និងកុំប៉ះខ្សែភ្លើងជាដាច់ខាត។

## សំណួរ

១.ក្រោយពីបញ្ចប់ការទស្សនាវីដេអូដែលទាក់ទងទៅនឹងការការពារផ្នែកចរន្តអគ្គិសនីតើប្អូនទទួលបានចំណេះដឹងអ្វីខ្លះ ?

២.ចូររៀបរាប់អំពីមធ្យោបាយក្នុងការជួយសង្គ្រោះជនរងគ្រោះដោយការឆក់ចរន្តអគ្គិសនី ?

- **ការរៀបចំសម្រាប់ចរាចរណ៍យានយន្ត និងគ្រឿងចក្ររបស់ការដ្ឋាន**

  - **ការដឹកជញ្ជូនគ្រឿងចក្រសំណង់**

  **ប្រការត្រូវចងចាំអំពីការដឹកជញ្ជូន**

ក.នៅក្នុងករណីដឹកជញ្ជូនគ្រឿងចក្រសំណង់ដើម្បីធានាសុវត្ថិភាពបានល្អ ត្រូវតែដឹកជញ្ជូនដោយរថយន្តសណ្ដោងដែលមានរ៉ឺម៉កសណ្ដោងទាប។

ខ.ក្នុងពេលកំពុងដឹកជញ្ជូនត្រូវគោរពច្បាប់ដែលពាក់ពន្ធ័ទាំងឡាយដូចជាច្បាប់ចរាចរផ្លូវថ្នល់ ច្បាប់យានយន្តដឹកជញ្ជូនតាមផ្លូវថ្នល់ និងច្បាប់កំណត់របបយានយន្តជាដើម។

គ.ការងារលើក និងដាក់គ្រឿងចក្រត្រូវឱ្យមានអ្នកផ្ដល់សញ្ញា ហើយត្រូវធ្វើការងារដោយគោរពតាមសញ្ញារបស់អ្នកផ្ដល់ឱ្យនេះ។

**ការលើកដាក់លើយាន្តសណ្ដោង និងការដាក់ចុះវិញ**

ក្នុងករណីលើកគ្រឿងចក្រសំណង់លើយាន្តសណ្ដោង និងដាក់ចុះវិញត្រូវប្រើរ៉ឺម៉កសណ្ដោងដែលជំនាញខាងដឹកជញ្ជូនគ្រឿងចក្រនេះទើបប្រសើរបំផុត។ តែក្នុងករណីដែលខានមិនបានខ្លះដូចជា ការលើកដាក់ដោយប្រើពំនូកដី ឬក៏ប្រើឧបករណ៍សម្រាប់ឡើង(ផ្លូវជម្រាល)Ramp។



ក.ករណីលើក និងដាក់ចុះនៅពេលប្រើពំនូកដី៖

១.ត្រូវគូរអំពីទទឹង នៃកន្លែងពូនដីជាមួយនឹងទទឹងតួគ្រឿងចក្រដោយឱ្យទទឹងកន្លែងពូនដីឱ្យបានទូលាយគ្រប់គ្រាន់។

២.ចំណោត នៃកន្លែងពូនដីកុំឱ្យចោតពេក។

៣.ត្រូវបុកបង្ហាប់ឱ្យបានហាប់ណែននូវពំនូកដីប្រុងប្រយ័ត្នកុំឱ្យបាក់ដីពេលលើកដាក់គ្រឿងចក្រដែលបណ្ដាលឱ្យគ្រឿងចក្រដួលរលំមកក្រោមបាន។ ជាពិសេសកុំឱ្យបាក់ដីនៅផ្នែកខាងនៃកង់គ្រឿងចក្រ។ ត្រូវប្រើវត្ថុបង្ការក្នុងពេលចាំបាច់ខ្លះមានការបោះបង្គោលពង្រឹងការពារជាដើម។

៤.កម្ពស់ពំនូកដីត្រូវឱ្យស្មើនឹងកម្ពស់រ៉ឺម៉កសណ្ដោង (Platform) នៃយានសណ្ដោង។

ខ.ករណីលើក ឬដាក់គ្រឿងចក្រចុះដោយប្រើឧបករណ៍សម្រាប់ឡើង(ផ្លូវជម្រាល)៖

១.ឧបករណ៍សម្រាប់ឡើង ឬផ្លូវជម្រាលត្រូវឱ្យមាំគ្រប់គ្រាន់អាចធន់បាននឹងទម្ងន់គ្រឿងចក្រ ហើយភ្ជាប់បានប្រាកដប្រជាទៅនឹងយានសណ្ដោង។ ផ្លូវជម្រាលតែងផលិតដោយបន្ទះក្ដារឈើ ឬក៏បន្ទះដែក។

២.ផ្លូវជម្រាលត្រូវឱ្យមានមុំចំណោត (Slope)ប្រមាណ$10^{o}$-$15^{o}$។

៣.ចំណុចកណ្ដាល(Center) នៃយានសណ្ដោង(Trailer)ត្រូវឱ្យត្រួតស៊ីគ្នាជាមួយនឹងមណ្ឌលរបស់គ្រឿងចក្រហើយ ត្រូវមានផ្លូវជម្រាលទាំងឆ្វេង និងស្ដាំសម្រាប់ដាក់ឆ្លង។

៤.ផ្លូវជម្រាលនេះមិនត្រូវឱ្យបត់ពត់ខ្លាំងពេក នៅពេលគ្រឿងចក្របរឆ្លងឡើងចុះ។ ត្រូវពង្រឹងដោយកំណល់សណ្ឋានជ្រុង។







គ.ចំណុចប្រុងប្រយ័ត្នចំពោះគ្រឿងចក្រពេលលើកដាក់( ស្ថានភាពទូទៅនៃតួគ្រឿងចក្រ )៖

១.បើអាចធ្វើបានត្រូវដាក់ប្រព័ន្ធបំពេញការងារគ្រឿងចក្រចុះក្រោម ដើម្បីកុំឲ្យប៉ះទង្គិចជាមួយយានសណ្តោង។

២.ចំពោះអ៊ិកស្កាវ៉ាទ័រធម្មតាត្រូវចាក់សោចលនាវិលបែរ និងដងសន្ទូចត្រូវទម្លាក់ចុះ ហើយប៉ែលត្រូវលើកទុកដោយស្ថានភាពបត់ខ្វង់ចូលក្នុង។

**ចំណុចគួរយល់ដឹងអំពីការបើកបរដោយសុវត្ថិភាព**

ចំពោះគ្រឿងចក្រសំណង់ប្រភេទ ដូចយានយន្តបញ្ចេញអនុភាពដ៏ខ្លាំងក្លារបស់វា នៅក្នុងការងារសំណង់ ដូចជាដឹកជញ្ជូន ការលើកដាក់ ការចូកដីក ឬការរៀបចំជាដើម។ បើយើងចេះប្រើប្រាស់ វាយ៉ាងស្ទាត់ជំនាញ នឹងផ្តល់ទិន្នផលប្រសិទ្ធភាព ក្នុងការងារទាំងនោះ ព្រមទាំងមានសុវត្ថិភាពផង។ ប្រសិនបើមានការភាន់ច្រឡំក្នុងការប្រើប្រាស់វានឹងបណ្តាលឲ្យមានគ្រោះថ្នាក់។ ដូច្នេះក្នុងនាមជា អ្នកបើកបរគ្រឿងចក្រសំណង់គ្រប់ប្រភេទដូចយានយន្ត ត្រូវយល់ដឹងចំណុចសំខាន់ៗក្នុងការបើកបរឲ្យបានសុវត្ថិភាពដូចតទៅ៖

**ស្តីអំពីការត្រួតពិនិត្យសុវត្ថិភាពទូទៅ**

ចាំបាច់ត្រូវមានសមត្ថភាពគ្រប់គ្រាន់ចំពោះការបើកបរ៖

-ក្រៅពីអ្នកដែលមានសមត្ថភាពកំណត់ដោយច្បាប់មិនអាចបើកបរបានឡើយ។

-ត្រូវស្លៀកពាក់ និងប្រើគ្រឿងធានាសុវត្ថិភាពជានិច្ច ដូចជាមួកការពារ និងស្បែកជើងសុវត្ថិភាពជាដើម។

**ត្រូវអានសៀវភៅណែនាំការប្រើប្រាស់ដើម្បីឱ្យចេះចាំនូវចំណេះដឹងអំពីយានយន្ត**

-អ្នកបើកបរត្រូវអានសៀវភៅណែនាំការប្រើប្រាស់ ដើម្បីឱ្យយល់នូវការបញ្ជាក្នុងការបើកបរឲ្យបានត្រឹមត្រូវ វិធីប្រើប្រាស់ប្រព័ន្ធសុវត្ថិភាព ការពិនិត្យមើល និងការជួសជុលឲ្យបានត្រឹមត្រូវ។

-រាល់ការបញ្ជាការបើកបរគ្រឿងចក្រសំណង់ដោយភាន់ច្រឡំ វាបណ្តាលឲ្យមានគ្រោះថ្នាក់ ដែលជាកត្តានាំមកនូវការរងរបួស ឬដល់ស្លាប់។

## វិធីការពារសុវត្ថិភាពនៃការងារជីកខួង

## សេចក្តីផ្តើម

ការងារជីកខួង តើគេនឹងអាចនិយាយថាជាការងារដែលសំខាន់បំផុតនៅក្នុងសំណង់ស៊ីវិលឬ? ដែលហៅថាការជីកខួង គឺជាការងារជីកខួងដី រួមទាំងការងារដឹកជញ្ជូនដីថ្មនៅតំបន់នោះ និងកន្លែងជីក។ ចំពោះការងារជីកខួង គឺមានការងារសង់ជញ្ជាំងទប់ ការសង់គ្រឹះ ការបង្កើតវិធីសាងសង់ ការសាងសង់ផ្សេងៗ។ សំណង់ជីកគ្រឹះក្រោមដី និងសំណង់គ្រឹះរបស់ស្ថាបត្យកម្មក៏ជាការងារជីកខួងដែរ។

អញ្ចឹងហើយនៅពេលធ្វើការជីកខួងនេះ គឺមានអ្នកទទួលគ្រោះថ្នាក់ច្រើនជារៀងរាល់ឆ្នាំ។ តើគ្រោះថ្នាក់ភាគច្រើនមានបញ្ហាបែបណា? គឺការបាក់ដី ការធ្លាក់ថ្ម ការដួលរលំនៃម៉ាស៊ីនសំណង់ ការធ្លាក់ ការប៉ះទង្គិចជាដើម។

អញ្ចឹងហើយបង្ហាញតួលេខសម្រាប់សំណង់ស៊ីវិលនៅឆ្នាំ១៩៩៣ មាន ៤៦៩នាក់រងរបួស ក្នុងនោះ ៥៥នាក់ ដោយសារដីបាក់ ១៤១នាក់ ដោយសារ Crane ម៉ាស៊ីនសំណង់ ៩នាក់ ដោយសារការធ្លាក់។ បច្ចុប្បន្នការងារជីកខួង ត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំង នូវគ្រោះថ្នាក់ជាច្រើនដែលកើតមានឡើង។ ៧៦នាក់គ្រោះថ្នាក់ដោយសារម៉ាស៊ីនសំណង់ដូចជា Drug Shovel និងPower Shovel ។

គ្រោះថ្នាក់ការងារតាមរយៈការជីកខួងនេះ គឺកើតឡើងនៅពេលសាងសង់ផ្លូវថ្នល់ប្រព័ន្ធទឹកលូ។ ឆ្លងតាមស្ថានភាពគ្រោះថ្នាក់ ដែលកើតឡើងខាងលើ តើយើងត្រូវធ្វើបែបណាដើម្បីកុំឲ្យមានជាលើកទី២នោះ? សូមមើលការបង្ហាញចំណុចសំខាន់ខាងក្រោមៈ

### ស្រាវជ្រាវជាមុននៅតំបន់នោះ និងកន្លែងដែលត្រូវជីក

មានគ្រោះថ្នាក់ជាច្រើន ដែលធ្វើឲ្យខូចរបស់កប់ក្នុងដីដូចជា បំពង់ទឹក បំពង់ហ្គាស និងគ្រោះថ្នាក់បាក់ដីដោយសារ Drug Shovel ចាប់ពីពេលនេះតទៅត្រូវស្រាវជ្រាវឲ្យបានម៉ត់ចត់ពីស្ថានភាពដីនៅតំបន់នោះ និងកន្លែងជីកដែលនឹងចង់ផ្តើមការងារ។ នៅពេលជីកនៅតំបន់ទីប្រជុំជនត្រូវតែត្រួតពិនិត្យបញ្ជាក់ចំពោះអ្នកច្បាប់គ្រប់គ្រង និងអ្នកម្ចាស់កន្លែងថាតើមានរបស់កប់ក្នុងដីឬអត់។ ម៉្យាងទៀតត្រូវក្តាប់ឲ្យបានពីស្ថានភាពគុណភាពដីមុនពេលជីកខួង ហើយចាំបាច់ណាស់ត្រូវបង្កើតនូវវិធានការសមរម្យ។

### ការបង្កើតគម្រោងសាងសង់ដែលបានបង្ហាញពីលំដាប់លំដោយ និងរយៈពេលនៃការជីក

ក្រោយពីបានស្រាវជ្រាវរួចរាល់ហើយ ត្រូវបង្កើតគម្រោងសាងសង់ ដោយផ្អែកទៅលើលទ្ធផលនៃការស្រាវជ្រាវ។ ចំពោះគម្រោងសាងសង់នេះសូមបង្ហាញលំដាប់លំដោយ និងពេលវេលានៃការជីក។



ក្រៅពីនេះ កម្ពស់នៃជម្រាលផ្ទៃដីត្រូវធ្វើយ៉ាងណា? ត្រូវធ្វើជន្ទល់ជញ្ជាំងបែបណា?

ករណីសង់ជន្ទល់ទប់ គឺចាំបាច់ណាស់ត្រូវតែសាងសង់ ហើយត្រូវបង្ហាញជាមុននូវវិធីជញ្ជូនដីថ្ម និងវិធីបង្ហូរទឹក។

ដោយសារតែការសម្រួលច្បាប់សុវត្ថិភាព និងសុខភាពនៅឆ្នាំ១៩៩២ នៅកន្លែងដែលខ្លាចខូចខាតបាក់ដីជញ្ជាំងការពាររបស់អ្នកដែលកុងត្រាដំបូងគេត្រូវ ផ្តល់សម្ភារៈចាំបាច់សម្រាប់ការពារគ្រោះថ្នាក់ ណែនាំអំពីបច្ចេកទេស នៃរបៀបធ្វើជញ្ជាំងទប់ផ្តល់ព័ត៌មានពីស្ថានភាពគុណភាពដី នៃកន្លែងដែលទាក់ទិនអ្នកម៉ៅការត្រូវធ្វើការទប់ស្កាត់គ្រោះថ្នាក់ដោយសហការជាមួយអ្នកពាក់ព័ន្ធនឹងកុងត្រា ព្រមទាំងខ្លួនឯងផង។

**វិធានការទប់ស្កាត់ការធ្លាក់ថ្មលយ និងការបាក់ដី**

១. តាមមាត្រាទី៣៥៦, ៣៥៧ នៃច្បាប់សុវត្ថិភាព និងសុខភាព ការកំណត់កម្រិតយកមុំនៃផ្ទៃដីកដែលមានសុវត្ថិភាពតាមប្រភេទដី និងកម្ពស់ផ្ទៃជីកនោះគិតថា យើងមានការយល់ដឹងទាំងអស់ហើយ។ ករណីជីកដីដោយមិនសាងសង់ជញ្ជាំងទប់នោះត្រូវប្រើមុំលើសពី Standard ។ ម្យ៉ាងទៀតការចាប់ផ្តើមការងារគឺជាការគ្រោះថ្នាក់ ដូច្នេះត្រូវចៀសវាងជាដាច់ខាត។

២. នៅពេលសាងសង់ប្រព័ន្ធលូទឹក ដើម្បីក្រាលបំពង់ ការជីកដោយប្រើម៉ាស៊ីន Standard ត្រូវបេះប្រើជាប្រចាំ ប៉ុន្តែករណីជីកដោយម៉ាស៊ីននេះ ការត្រួតពិនិត្យនៃកម្រិតជម្រាល និងកម្ពស់ផ្ទៃទឹកគឺមិនអាចទទួលយកបានទេ តែគ្រោះថ្នាក់កប់ទាំងរស់ដោយសារ ការកប់ដីនៅពេលបំពេញការងារចូលទៅក្នុងទីកន្លែងដែលជីកមិនអាចបាត់បង់បានឡើយ។ កម្មករក្រោយពីការប្រើម៉ាស៊ីនជីក គឺត្រូវទៅរកកន្លែងជីកនៅពេលធ្វើការកែសម្រួល គឺគេជីកដោយដៃ មិនមែនដោយសារម៉ាស៊ីនទេ ដូច្នេះហើយត្រូវយកជម្រាលខ្លាំងជាងជម្រាលពីមុន ត្រូវធ្វើជន្ទល់ ជញ្ជាំង ឬអត់?

៣. ចំពោះករណីសង់ជញ្ជាំងទប់ ត្រូវបង្កើតប្លង់ជាមុន សូម្បីតែកន្លែងគម្រោងសង់ក៏បានបង្ហាញដែរ ប៉ុន្តែចំពោះកាដែលបង្កើតឡើងនេះត្រូវបង្ហាញ និងកំណត់លំដាប់លំដោយ និងរយៈពេលនៃការដំឡើងទៅតាមលំដាប់នៃគុណភាពរបស់ និងខ្នាតរៀបចំសម្ភារៈបន្ទះក្តារសរសៃ និងបន្ទះសម្រាប់បញ្ចូនក្នុងដីផ្សេងៗ។ បានតែដំឡើងជន្ទល់ទប់ ដើម្បីទប់ដីកុំឲ្យបាក់ដី ហើយត្រូវធ្វើឲ្យជន្ទល់ទប់ខ្លួនឯងនៅពេលធ្វើការដំឡើងទោះជាគ្រោះថ្នាក់បាត់នោះមានការចំឡែកក៏ដោយ ដូច្នេះត្រូវសិក្សាឲ្យបានជិតដល់នូវលំដាប់លំដោយ និងរយៈពេលនៃការរុះ ឬដំឡើង។ ម្យ៉ាងទៀតការជីកគឺមិនត្រូវធ្វើឲ្យមានកំហុសពេលវេលានៃការដំឡើងជញ្ជាំងទប់ និងជីកជ្រុលពេកនោះ។

៤. ការងារនៅលើផ្ទៃជម្រាល ករណីកម្មករគ្រោះថ្នាក់ដោយសារ ដី ឬថ្ម ដែលរមៀលធ្លាក់ពីលើ គឺចំឡែកណាស់។ ដោយសារតែមានថ្មធ្លាក់ ចាំបាច់ត្រូវមានវិធានការធ្វើឲ្យរឹងជាប់នូវថ្ម និងផ្នែកជ្រៅនៃផ្ទៃដែលជីកដោយប្រើនុកថ្ម ឬសង់ផ្នើរ និងសំណាញ់ការពារ។

៥. ចំពោះការងារនៅលើជម្រាលគឺមានករណីកម្មករធ្លាក់ស្លាប់ដោយសារជម្រាលចោតពេក។ ការធ្លាក់ពីលើជម្រាលមុំលើសពី ៤០ដឺក្រេ ការធ្លាក់នេះបានចែកនៅក្នុងមាត្រា៥១៨ និង៥១៩ នៃច្បាប់សុវត្ថិភាព និងសុខភាព ដូច្នេះករណីគ្មានដើមឈើ ការចងសំណាញ់ ទៅនឹងដើមនៃផ្នែកខាងលើត្រូវបោះយុថ្កាលើសពីនេះត្រូវមានវិធានការ ការពារធ្លាក់ និងឲ្យសំណាញ់រឹងមាំ។

## វិធានការសុវត្ថិភាពនៃការសាងសង់សំណង់រូងក្រោមដី

ការសាងសង់រូងក្រោមដីគឺជាការជីករូងជាបន្ទាន់ឲ្យមានពន្លឺចូល។ តើវាមិនមែនជាការងារជាមួយផ្នែកសំណង់វិស្វកម្មទេឬ? ភាពគ្រោះថ្នាក់នៃការងារ គឺកើតឡើងនៅពេលកំពុងសាងសង់ ដូច្នេះហើយសុវត្ថិភាពត្រូវតែយកចិត្តទុកដាក់គ្រប់វិនាទី។

បើយើងមើលពីការប្រើប្រាស់រូងក្រោមដី គឺវាមានលក្ខណៈខុសប្លែកគ្នា មានដូចជារូងប្រើសម្រាប់ ផ្លូវដែក ផ្លូវថ្នល់ ផ្លូវទឹកនៃថាមពលអគ្គិសនីសម្រាប់កិច្ចការចំណូលសាធារណៈ ផ្លូវខ្សែភ្លើង ទឹកម៉ាស៊ីន ប៉ុន្តែវិធីសាងសង់សំណង់ទាំងនោះមានវិធានការសុវត្ថិភាពរបស់វា។ ការគ្រោះថ្នាក់ នៃការងារកើតមានជាពិសេសនៅពេលសាងសង់រូងទាំងនោះ ដូចជាការបាក់ស្រុត ផ្ទុះហ្គាស ភ្លើងឆេះចេញទឹកច្រើនជម្មតា ហើយវាទាក់ទងទៅនឹងការដឹកជញ្ជូនតាមរថភ្លើង និងរថយន្តផ្សេងៗ។

ការងារសាងសង់រូងផ្លូវក្រោមដី ជាការងារច្រើន មានមុខសញ្ញាគ្រោះថ្នាក់បំផុត ប៉ុន្តែដោយមានការប្រឹងប្រែងរបស់អ្នកជាប់ពាក់ព័ន្ធ ការគ្រោះថ្នាក់នៅពេលប្រតិបត្តិការ ធ្វើឲ្យគ្រោះថ្នាក់ផ្សេងៗមានការថយចុះ ទោះជាយ៉ាងណាក៏ដោយនៅឆ្នាំ១៩៩៣ ជីវិតមនុស្ស ២០នាក់បានបាត់បង់ពេលសង់រូងក្រោមដី។ ៥នាក់ស្លាប់ដោយសារគ្រឿងស្ទូច និងគ្រឿងចក្រសំណង់ ៤នាក់ស្លាប់ ដោយសារការផ្ទុះបាក់ធ្លាក់មក ៣នាក់ស្លាប់ដោយសារការបាក់ និង៨នាក់ទៀតដោយសារករណីផ្សេងៗ។

ដូច្នេះសុវត្ថិភាពនៃកាសាងសង់រូងក្រោមដី គេយកការគ្រោះថ្នាក់ដែលបានកកើតឡើង ពីមុនជំនួសផង និងស្រាវជ្រាវបន្ថែមទៀតផង។

## គម្រោងសំណង់ និងការសង្កេតដីជាមុន

មុនសាងសង់រូងក្រោមដី ដំបូងគេត្រូវធ្វើការស្រាវជ្រាវតាមវិធីផ្សេងៗ ដូចការអង្កេត តាមបែបអេឡិចត្រូនិក ឬរូបវិទ្យា ការជីកដីយកមកត្រួតពិនិត្យស្រាវជ្រាវស្ថានភាពស្រទាប់ដី ទីតាំងភូមិសាស្ត្រ ស្ថានដីជាដើម។ រឿងរ៉ាវចាស់ចំពោះរូងក្រោមដី AOHAKO គឺមានការចុះនៅក្នុងកំណត់ហេតុពិភពលោកនៅកម្រិតនៃការវាស់ប្រវែង ២១៥០ម៉ែត្រ។

ពឹងផ្អែកទៅលើលទ្ធផលនៃការស្រាវជ្រាវនេះ គេបង្កើតគម្រោងសាងសង់ដើម្បីការពារគ្រោះថ្នាក់ដែលកើតឡើងនៅពេលបំពេញការងារ ដោយសារការផ្ទុះហ្គាស ចេញទឹកបាក់ស្រុត ។

**ឧទាហរណ៍៖** តើគេទទួលយកវិធីក្នុងការជីកបែបណា?

តើគេត្រូវធ្វើការសាងសង់ជន្ទល់នឹងគម្របរូងក្រោមដីយ៉ាងដូចម្តេច? តើមានវិធានការបែបណាពេលឆេះហ្គាស និងមានទឹកផុស? តើធ្វើយ៉ាងណាដើម្បីឲ្យមានពន្លឺ និងមានខ្យល់ចេញចូល? សូមធ្វើការសិក្សាឲ្យបានល្អពីបញ្ហាទាំងនេះ។ សូមបញ្ជាក់ នៅក្នុងគម្រោងសាងសង់។

ម្យ៉ាងទៀតក្រោយពីចាប់ផ្តើមសាងសង់រូងក្រោមដីជារៀងរាល់ថ្ងៃគេត្រូវមើលហ្គាសមាន ឬអត់ ស្ថានភាពទឹកផុស ស្រទាប់ដី ភូមិសាស្ត្រដី អំពីស្ថានភាពដីនៅជុំវិញ ហើយនឹងកន្លែងដែលកំពុងជីក។ យោងទៅតាមលទ្ធផលនេះ ធ្វើឲ្យមានការផ្លាស់ប្តូរ គម្រោងសំណង់។ នៅពេលសាងសង់ Tunnel បញ្ហាទាំងនេះតែងតែមានឡើងជាញឹកញាប់ ដូច្នេះសូមពិនិត្យជារៀងរាល់ថ្ងៃ។

**វិធានការទប់ស្កាត់នៃការបាក់ធ្លាក់ ឬស្រុត៖**

ការជីករូងក្រោមដី ជាទូទៅគេបំបែកថ្មដោយដាក់ឲ្យផ្ទុះ ក្បាលដំបូងនៃ Tunnel ហើយបញ្ជូនចេញនៅកម្ទេចថ្មនោះ ប៉ុន្តែភាពរញ្ជួយនៅពេលផ្ទុះធ្វើឲ្យដីធូរ ងាយឲ្យមានការបាក់ស្រុត។ ការធ្លាក់ និងការបាក់ស្រុតចុះ គឺកើតឡើងជាញឹកញាប់ នៅពេលជីកក្បាលដំបូងរបស់ Tunnel បន្ទាប់មកគឺផ្នែកកោង ផ្នែកជញ្ជាំងខាង ផ្នែកមាត់រូង។ តើការគ្រោះថ្នាក់ទាំងនេះ កើតមានឡើងនៅពេលធ្វើការងារបែបណា? គឺវាកើតឡើងនៅពេលដំណើរការជីកជើងក្រោមដើម្បីសង់គ្រឹះ និងទម្រ Tunnel ដំណើរការចោះរន្ធដាក់រំសេវឲ្យផ្ទុះ ម៉្យាងទៀតគេអាចនិយាយថាដំណើរការបំបែកថ្មធំៗដែលសំខាន់ដល់ការសាងសង់ Tunnel ដំណើរការទម្លាក់ថ្មដែលដុះចេញនៅជុំវិញផ្ទៃ ដែលបានជីកក្រោយពេលដាក់ឲ្យផ្ទុះរួចមក។ ខាងក្រោមនេះយើងមើលវិធានការទប់ស្កាត់នៃការបាក់ធ្លាក់ និងស្រុតចុះ។

១.សាងសង់ទម្រការពារ Tunnel ចំពោះដីភ្នំដែលមិនមែនដីភ្នំ បានមកពីថ្មមិនប្រេះហើយរឹង ការប្រើប្រាស់សំណាញ់លួស តាមករណីផ្សេងៗ ដូចជាការសាងសង់រនុកថ្ម នៅផ្នែកដែលមានការភ័យខ្លាច ការបាក់ស្រុតធ្លាក់ចំពោះដីភ្នំដែលជាថ្មរឹង។ ការសាងសង់ទម្រ Tunnel គឺគេសាងសង់ជាបន្ទាន់ ក្រោយពីការចោះរួចភ្លាម ដោយមកចន្លោះមិនលើសពី ១,៥ម៉ែត្រ ឡើយ។

២. ក្រោយពីដាក់ឲ្យផ្ទុះរួចមក គេត្រូវចាត់ឲ្យមានអ្នកត្រួតពិនិត្យអំពីផ្ទៃជីកក្បាលដំបូងរបស់ Tunnel ដំបូង និងជញ្ជាំងខាង។ល។ ដោយធ្វើការពិនិត្យមើល តើមានថ្មប្រេះ និងថ្មលយចេញ ឬអត់? ដើម្បីបំបាត់ការបញ្ហានេះ គេត្រូវបូកស៊ីម៉ង់ត៍ ឬបាយអរចៀសវាងការបាក់ស្រុត។

៣. ដំណើរការចោះរូង Jumbo គឺដាក់ឲ្យជិតទៅនឹងក្បាលដំបូងនៃ Tunnel ដោយធ្វើឲ្យចន្លោះ នៃក្បាលជីកដំបូងរបស់ Tunnel ចង្អៀត ការជីករូងនេះគេធ្វើតាមលំដាប់ពីថ្នាក់លើនៃ Jumbo មកថ្នាក់កណ្ដាលរូងទៅថ្នាក់ក្រោម។ ដាក់បញ្ជាឲ្យធ្វើការស្រាវជ្រាវជាន់នីមួយៗ និងពិនិត្យមើលថ្មដែលធ្លាក់។

**វិធានការចំពោះរំសេវដែលនៅសល់ និងរំសេវដែលមិនផ្ទុះ**

ក្រោយពេលឆេះ ក្រោយពេលរំសេវមិនទាន់ផ្ទុះ ឬមិនអាចធ្វើការពិនិត្យថា តើបានផ្ទុះហើយ ឬនៅ? សូមគោរពវិធីខាងក្រោម៖

១. ចំពោះកឹបគ្រាប់សម្រាប់ធ្វើឲ្យផ្ទុះ គឺត្រូវទាញខ្សែបញ្ឆះចេញពីឧបករណ៍ដែលឆេះហើយដាក់ឲ្យចុងនោះប៉ះគ្នា បើមិនអាចឆេះឡើងវិញទេ ត្រូវរង់ចាំ ៥នាទីយ៉ាងតិច មុននឹងចូលទៅជិតរំសេវ។

២. ចំពោះឧករណ៍ផ្សេងពីកឹប ដែលធ្វើឲ្យរំសេវផ្ទុះក្រោយពីផ្ទុះ ត្រូវរង់ចាំយ៉ាងតិច ១៥នាទី មុននឹងចូលទៅជិតវា។

**វិធានការទប់ស្កាត់ការផ្ទុះអគ្គិសនីផ្សេងៗ**

១. កន្លែងដែលមានគ្រោះថ្នាក់ ផ្ទុះអគ្គិសនី តាមរយៈកម្ទេចកម្ទីដែលឆេះ ឬហ្គាស ឬចំហាយដែលជារបស់ឆេះដែលកើតឡើងដោយសារខ្យល់បក់ ភាពស្ងួត ។ល។

២. កន្លែងគួរឲ្យភ័យចខ្លាចផ្ទុះឡើងនូវហ្គាសឆេះ(ជាពិសេស ឧស្ម័នមេតាន)។ ដោយបឺត យកឧស្ម័នចេញតាមរយៈម៉ាស៊ីនខួង ឬតាមការខ្ទប់ឧស្ម័នដោយបង្ហូរថ្នាំទឹកចូល។

៣. ទោះជាវិធានការ (១) (២) ដែលបានលើកឡើងខាងលើក៏ដោយ កន្លែងដែលមានគ្រោះថ្នាក់ផ្ទុះអគ្គីភ័យនៅពេលប្រើប្រាស់ឧបករណ៍ម៉ាស៊ីនភ្លើង ត្រូវតែបង្កើតការការពារថែមទៀត។

៤. ការកើតឡើងនូវអគ្គិភ័យតាមរយៈ ការរួមបញ្ចូលគ្នានៃហ្គាស គឺត្រូវធ្វើជញ្ជាំងការពារការសាចព្រាយផ្កាភ្លើងផ្សេងៗ ដោយគ្រប់របស់មិនឆេះ យកចេញរបស់ដែលងាយឆេះនៅជិត។

**វិធានការការពារអគ្គិភ័យតាមរយៈឧបករណ៍ដឹកជញ្ជូននៅក្នុងរូង**

នៅពេលសាងសង់សំណង់ Tunnel អគ្គិភ័យនឹងអាចកើតឡើងនៅពេលដែលឆេះឡើងនៅចន្លោះជញ្ជាំងម្ខាង និងយានយន្តហើយ និងការប៉ះគ្នាតាមរយៈរទេះដឹកជញ្ជូនកន្ទុយសណ្តោង ឬButtery ROKO។ សូមគោរពឲ្យបានម៉ត់ចត់នូវប្រការខាងក្រោម៖

១. ត្រូវទុកចន្លោះ ០,៦ម៉ែត្រ ឡើងទៅ នូវរបស់ដែលរារាំងដំណើរ ឬយានយន្តជាមួយនឹងជញ្ជាំងម្ខាង។ ករណីដែលមិនអាចធ្វើដូច្នេះបានត្រូវសង់កន្លែងចៀសគ្នា ដោយមានចន្លោះសមរម្យដែលអាចដាក់ដោយឡែកពីគ្នាឲ្យបានច្បាស់ ឬដាក់អ្នកត្រួតពិនិត្យ និងដាក់សញ្ញាភ្លើងដើម្បីកុំឲ្យកម្មកទៅតាមទិសបើករបស់យានយន្ត។

២.ត្រូវរក្សាចម្ងាយជាចំបាច់ដើម្បីកុំឲ្យអ្នកជិតនៅលើយានយន្តប៉ះទៅនឹងដំបូល, ជញ្ជាំង ឬរបស់រារាំងដំណើរផ្សេងៗ។

## ១.៦ ការប្រើប្រាស់បំពង់ពន្លត់អគ្គិភ័យ និងទុយយោបាញ់ទឹក

**សេចក្តីផ្តើម**

ចំពោះអ្នកប្រើប្រាស់ចរន្តអគ្គិសនី នៅពេលបច្ចុប្បន្នតែងតែជួបប្រទះបញ្ហាជាច្រើន ដូចជាបញ្ហា ឆក់ដោយចរន្តអគ្គិសនី ទុស្សេខ្សែភ្លើង ខូចគ្រឿងបរិក្ខារអគ្គិសនី ជាពិសេសមានអគ្គិភ័យកើតឡើងដែល បណ្តាលឲ្យមានការឆាបឆេះផ្ទះសម្បែង បាត់បង់ទ្រព្យសម្បត្តិ អាយុជីវិតមនុស្ស សត្វ និងធ្វើឲ្យមានការប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារជនរងគ្រោះថែមទៀតផង។ ក្នុងនោះផងដែរក៏យើងត្រូវតែយល់ដឹងអំពីវិធីការពារខ្លះៗ និងវិធីសាស្ត្របង្រ្កាប ឬពន្លត់អគ្គិភ័យដែលកើតចេញពីការឆាបឆេះ វត្ថុផ្សេងៗ ដែលនៅជុំវិញខ្លួនយើងដោយចរន្តអគ្គិសនី។

**ការប្រើប្រាស់បំពង់ពន្លត់អគ្គិភ័យ**

វិធីប្រើប្រាស់បំពង់ពន្លត់អគ្គិភ័យ មានដូចជា៖

- លើកបំពង់ឡើងរួចក្រឡុកវា ៣ ទៅ ៤ដងរួចដកគន្លឹះសុវត្ថិភាព។
- តម្រង់ឲ្យចំកន្លែងដែលឆាបឆេះ ហើយឈរចម្ងាយប្រហែល ២ម៉ែត្រពីចំណុចឆេះ។
- ច្របាច់ដៃខ្លាស់ ដើម្បីបញ្ចេញសារធាតុកាបូនឌីអុកស៊ីតទៅពន្លត់ចំហេះ។
- ត្រូវឈរបាញ់ពីលើខ្យល់ បាញ់ដេញពីជិតទៅឆ្ងាយ។
- ពេលអគ្គិភ័យឆាបឆេះខ្លាំង ត្រូវប្រើកម្លាំងរួមគ្នា ដើម្បីជួយពន្លត់គ្នា។

# របៀបប្រើប្រាស់បំពង់ពន្លត់អគ្គិភ័យ




រូបភាព៨៥ របៀបប្រើបំពង់ពន្លត់អគ្គិភ័យ

បំពង់ពន្លត់អគ្គិភ័យមាន ៤ ប្រភេទ គឺ ប្រភេទ A B C E ហើយប្រភេទនីមួយៗ មានការប្រើប្រាស់ផ្សេងៗពីគ្នា។

1. បំពង់ពន្លត់អគ្គិភ័យប្រភេទ A ប្រើសម្រាប់ការឆាបឆេះបណ្ដាលមកពី ឈើ ក្រដាស ក្រណាត់ សំរាម ភ្លើងធូប ភ្លើងទាន ភ្លើងចង្ក្រាន ឬរងើកភ្លើងផ្សេងៗ។
2. បំពង់ពន្លត់អគ្គិភ័យប្រភេទ B ប្រើសម្រាប់ការឆាបឆេះបណ្ដាលមកពី ប្រេង សាំង ប្រេងម៉ាសូត ប្រេងម៉ាស៊ីន និងជាតុរាវផ្សេងៗទៀតដែលអាចឆេះបាន។
3. បំពង់ពន្លត់អគ្គិភ័យប្រភេទ C ប្រើសម្រាប់ការឆាបឆេះបណ្ដាលមកពី ការឆ្លងចរន្តអគ្គិសនី។
4. បំពង់ពន្លត់អគ្គិភ័យប្រភេទ E ប្រើសម្រាប់ការឆាបឆេះបណ្ដាលមកពី ឧស្ម័ន Gas ឬសារជាតុងាយឆេះ។




រូបភាព៨៦ របៀបប្រើបំពង់ពន្លត់អគ្គិភ័យ

ក្នុងការប្រើប្រាស់បំពង់ពន្លត់អគ្គិភ័យ យើងក៏ត្រូវដឹងអំពីវិធីសាស្ត្រក្នុងការថែទាំបំពង់ពន្លត់អគ្គិភ័យដែរ ហើយក្នុងការថែទាំនោះមានដូចជា៖

- ត្រូវក្រឡុកវាឲ្យបានម្តងក្នុងរយៈពេល២ខែ ឬដាក់វាផ្តេកនៅពេលយប់ និងពេលថ្ងៃត្រូវដាក់វាបញ្ឈរ ធ្វើដូច្នេះដើម្បីកុំឲ្យម្សៅកាបូនឌីអុកស៊ីតងាយកក។
- ត្រួតពិនិត្យមើលកម្រិតនាឡិកានៅលើបំពង់។
- ដាក់វានៅកន្លែងស្ងួតមិនក្តៅពេក ( -20° to 60° C ) ហើយព្យួរជាប់ នឹងជញ្ជាំងអគារ ឬក្នុងទូសម្រាប់ដាក់បំពង់ពន្លត់អគ្គិភ័យ។

ម្យ៉ាងវិញទៀត ដើម្បីដឹងថាបំពង់ពន្លត់អគ្គិភ័យនៅមានគុណភាពល្អ ឬខូច យើងដឹងតាមរយៈ នាឡិកាបំពង់ពន្លត់អគ្គិភ័យ បើទ្រនិចនាឡិកាចង្អុលពណ៌បៃតង បញ្ជាក់ថាបំពង់ពន្លត់អគ្គិភ័យមានគុណភាពល្អ

ហើយប្រសិនបើទ្រនិចនាឡិកាចង្អុលពណ៌លឿង បញ្ជាក់ថាបំពង់ពន្លត់អគ្គិភ័យនោះជិតខូចគុណភាព តែបើទ្រនិចនាឡិកាចង្អុលពណ៌ក្រហមវិញ បញ្ជាក់ថាបំពង់ពន្លត់អគ្គិភ័យនោះខូចគុណភាពហើយ។

**វិធីប្រើប្រាស់ទុយោបាញ់ទឹកពន្លត់អគ្គិភ័យ**

ការប្រើប្រាស់ទុយោបាញ់ទឹកក៏មានប្រសិទ្ធភាពចំពោះការពន្លត់អគ្គិភ័យដែរ ហើយវិធីប្រើប្រាស់វាមានដូចជា៖

- វាយបំបែកកញ្ចក់ដែលនៅជាប់ជញ្ជាំងប្រអប់ឧបករណ៍ពន្លត់អគ្គិភ័យ។
- យកកូនសោដែលដាក់ជាប់ជញ្ជាំងប្រអប់ឧបករណ៍ពន្លត់អគ្គិភ័យមកចាក់បើកប្រអប់នោះ។
- ទាញទុយោទឹកដែលដាក់ខាងក្នុងប្រអប់។
- តម្រង់ឲ្យចំកន្លែងដែលឆាបឆេះ ហើយត្រូវឈរចម្ងាយប្រហែល ២ម៉ែត្រពីចំណុចដែលបានឆាបឆេះ។
- បើកវ៉ានទឹកដែលនៅខាងក្រោមទុយោបាញ់ទឹកដើម្បីបញ្ចេញទឹកទៅពន្លត់ភ្លើងដែលឆេះ។
- មួលក្បាលទុយោទឹកដើម្បីឲ្យទឹកចេញបានតិច ឬច្រើនតាមតម្រូវការ។
- ត្រូវឈរបាញ់ពីលើខ្យល់ បាញ់ដេញពីជិតទីឆ្ងាយ។
- ពេលអគ្គិភ័យឆេះខ្លាំង ត្រូវប្រើកម្លាំងរួមគ្នាដើម្បីជួយពន្លត់។



រូបភាព៨៧ របៀបបាញ់ពន្លត់អគ្គិភ័យ

# ការពន្លត់ហ្គាសដោយសន្ទប់ខ្យល់







រូបភាព៨៨ របៀបពន្លត់អគ្គិភ័យដោយសន្ទប់ខ្យល់

## សំណួរពិភាក្សា

1. តើបំពង់ពន្លត់អគ្គិភ័យមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. ចូរនិយាយអំពីវិធីប្រើប្រាស់បំពង់ពន្លត់អគ្គិភ័យ ?
3. តើបំពង់ពន្លត់អគ្គិភ័យប្រភេទ A ប្រើពន្លត់អ្វី ?
4. តើបំពង់ពន្លត់អគ្គិភ័យប្រភេទ B ប្រើពន្លត់អ្វី ?
5. តើបំពង់ពន្លត់អគ្គិភ័យប្រភេទ C ប្រើពន្លត់អ្វី ?
6. តើបំពង់ពន្លត់អគ្គិភ័យប្រភេទ E ប្រើពន្លត់អ្វី ?
7. ចូរនិយាយអំពីវិធីសាស្រ្តក្នុងការថែទាំបំពង់ពន្លត់អគ្គិភ័យ ?
8. ចូរនិយាយអំពីវិធីសាស្រ្តក្នុងការប្រើប្រាស់ទុយោបាញ់ទឹកពន្លត់អគ្គិភ័យ ?

- សៈ៥ ឬ5s

**តើអ្វីទៅជាគោលការណ៍ សៈ៥?**

គោលការណ៍ សៈ៥ បានមកពីពាក្យ 5S គឺជាគោលការណ៍ ឬវិធីដែលមានសិល្បៈដែលផ្ដើមដំបូងដោយអក្សរ ស ចំនួនប្រាំ សម្រាប់អនុវត្តទៅលើការរៀបចំកន្លែងការងារឲ្យមានប្រសិទ្ធភាព និងមានគុណភាពលើគ្រប់វិស័យ មិនថាវិស័យសុខាភិបាល វិស័យឧស្សាហកម្ម សិប្បកម្ម ....។

សៈ៥ ជួយអភិវឌ្ឍបរិយាកាសកន្លែងធ្វើការដោយធ្វើឲ្យឧបករណ៍ បរិក្ខារ ម៉ាស៊ីនមានភាពប្រសើរ ឡើងដើម្បីឲ្យកន្លែងធ្វើការមានសុវត្ថិភាព មានប្រសិទ្ធភាព ភាពរីករាយ និងមានផលិតភាពខ្ពស់ឡើង ដោយការប្រើប្រាស់វិធីត្រឹមត្រូវ។ សៈ៥ ក៏បានចូលរួមចំណែកដល់ការរីកចម្រើន ផ្នែកធនធានមនុស្ស តាមរយៈការបណ្ដុះគំនិតធ្វើការរួមគ្នា និងចូលរួមថែរក្សាសម្ភារៈនៅកន្លែងធ្វើការ។ ការអនុវត្ត សៈ៥ មួយជំហានម្ដងៗ សន្សឹមៗ និងបន្តជាប់គ្នាហេតុជាចំណុចមួយសំខាន់ បំផុតដើម្បីបង្កើតវប្បធម៌រៀបចំដ៏រឹងមាំមួយនៅកន្លែងធ្វើការ។




រូបភាព៨៩ គោលការណ៍ សៈ៥

សៈ៥ ជាវិធីសាស្ត្រសម្រាប់រៀបចំកន្លែងធ្វើការដែលក្លាយមកពីភាសាជប៉ុនប្រាំពាក្យគឺៈ

**Seiri សម្រិតសម្រាំង**

សម្រាំងយកវត្ថុចាំបាច់ ដោយញែករវាងវត្ថុចាំបាច់ និងមិនចាំបាច់ ហើយធ្វើការដកវត្ថុទាំងឡាយណាដែលមិនចាំបាច់ចេញ។

**Seiton សណ្ដាប់ធ្នាប់**

រៀបចំវត្ថុចាំបាច់ទាំងឡាយទៅតាមលំដាប់លំដោយឲ្យបានល្អ ធ្វើដូចនេះ វានឹងងាយស្រួលរើសយកវត្ថុទាំងនោះមកប្រើនៅពេលណាដែលត្រូវការ។

Seiso ស្អាត ឬសម្អាត

សម្អាត និងពិនិត្យឲ្យបានម៉ត់ចត់គ្រប់កន្លែងការងារ ហេតុនេះនឹងមិនមានធូលីនៅលើឥដ្ឋ ម៉ាស៊ីន និងបរិក្ខារប្រើប្រាស់នោះទេ។

Seiketsu ស្តង់ដា

ត្រូវរក្សាស្តង់ដាឲ្យបានខ្ពស់នៅគ្រប់ទីកន្លែងការងារ តាមរយៈការរក្សាអ្វីៗឲ្យបានស្អាត និងមានសណ្តាប់ធ្នាប់គ្រប់ពេលវេលាទាំងអស់។

Shitsuke ស្ថិតស្ថេរ

ត្រូវបណ្តុះបណ្តាលមនុស្សឲ្យអនុវត្តប្រព័ន្ធ ស៥ ជាបន្តបន្ទាប់ជានិច្ច ដូចនេះវានឹងក្លាយជាទម្លាប់និងត្រូវបានរក្សាទុកនៅក្នុងវប្បធម៌ការងារនៅក្នុងក្រុមហ៊ុន។

ដើម្បីឲ្យការអនុវត្ត ស៥ ទទួលជោគជ័យ ចាំបាច់ ត្រូវមានការវាស់វែងមួយដ៏ត្រឹមត្រូវ។ សវនកម្ម ស៥ ត្រូវបានគេចាត់ទុកជាផ្នែកមួយ ខណៈដែលវាជាឧបករណ៍យ៉ាងសំខាន់ដើម្បីឲ្យប្រាកដពីភាពត្រឹមត្រូវនៃការអនុវត្ត ស៥ ក្នុងកន្លែងធ្វើការ។ តាមរយៈសវនកម្ម ស៥ អាចឲ្យក្រុមហ៊ុនកំណត់ពីកម្រិតសក្តានុពលនៃគុណភាព កែលម្អ និងអាចវាយតម្លៃពីភាពខ្លាំង និងខ្សោយនៃការអនុវត្ត ស៥ ទៅតាមផ្នែកនីមួយៗក្នុងក្រុមហ៊ុន។

- សម្រិតសម្រាំង ( Sort )
  - កំណត់ និងរៀបចំឧបករណ៍ សម្ភារៈចាំបាច់ និងមិនចាំបាច់ដាក់ដោយឡែកពីគ្នា។
  - កាត់បន្ថយ ឬជំរុះចោលនូវឧបករណ៍ សម្ភារៈដែលមិនប្រើប្រាស់។
  - ធ្វើបញ្ជី និងកត់ត្រាសម្ភារៈចាំបាច់ទាំងអស់។



រូបភាព៩០ សម្រិតសម្រាំង

- សណ្តាប់ធ្នាប់ ( Set in order )
  - រៀបចំឧបករណ៍ សម្ភារៈឲ្យមានសណ្តាប់ធ្នាប់។
  - រៀបចំឧបករណ៍ សម្ភារៈចាំបាច់ និងប្រើប្រាស់ជាញឹកញាប់ឲ្យនៅក្បែរខ្លួន។

- រៀបចំឲ្យមានលំហូរការងារដោយរលូន និងងាយស្រួល



រូបភាព៩១ សណ្ដាប់ធ្នាប់

- សម្អាត ( Shine / Sweep )
  - សម្អាតកន្លែងធ្វើការឲ្យបានស្អាត និងជាប្រចាំ។
  - កំណាត់រកប្រភពធូលី និងឬសគល់ដែលធ្វើឲ្យមានធូលី។
  - កន្លែងការងារ ត្រូវមានសុវត្ថិភាពខ្ពស់ និងងាយស្រួលប្រតិបត្តិ។



រូបភាព៩២ សម្អាត

- ស្តង់ដា ( Standard )
  - រៀបចំឲ្យមានស្តង់ដាការងារ តាមកន្លែងធ្វើការ។
  - រក្សាឧបករណ៍ សម្ភារៈទាំងអស់ឲ្យត្រូវមានស្តង់ដា ដែលបានកំណត់ទុក។
  - ប្រើប្រាស់ដ្យាក្រាមបង្ហាញពីបែបបទការងារ។



រូបភាព៩៣ ស្តង់ដា

- ស្ថិតស្ថេរ ( Sustain )
    - យល់ដឹង គោរព និងអនុវត្ត នូវបទបញ្ជាតាមការណែនាំដែលបានបង្កើតឡើង។
    - ខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការរក្សាបាននូវលក្ខខណ្ឌស្ថិតស្ថេរដែលចង់បាន។




រូបភាព៩៤ ស្ថិតស្ថេរ

## សំណួរពិភាក្សា

1. តើការអនុវត្តការងារដោយមានសុវត្ថិភាពមានអ្វីខ្លះ?
2. ចូរពន្យល់នូវចំណុច " កុំធ្វើការងារម្នាក់ឯង "?
3. ចូរពន្យល់នូវចំណុច " ចាក់សោ និងដាក់ផ្លាកសញ្ញា "?
4. ចូរពន្យល់នូវចំណុច " គ្រឿងអលង្ការ និងវត្ថុលោហៈ "?
5. ចូរពន្យល់នូវចំណុច " គម្រោងការងារដើម្បីជៀសវាងនៃការធ្លាក់ពីទីខ្ពស់ "?
6. ចូរពន្យល់នូវចំណុច " ការដាក់ជណ្តើរឲ្យមានសុវត្ថិភាព "?
7. ចូរពន្យល់នូវចំណុច " ជៀសវាងធ្វើការងារក្នុងស្ថានភាពសើម និងគ្រោះថ្នាក់ផ្សេងៗ "?
8. ចូរពន្យល់នូវចំណុច " ជៀសវាងពីខ្សែដែលមានអានុភាពធំតាមបណ្តាញអាកាស "?
9. ចូរពន្យល់នូវចំណុច " ការប្រើប្រាស់ខ្សែ និងការធ្វើតំណខ្សែឲ្យបានត្រឹមត្រូវ "?
10. ចូរពន្យល់នូវចំណុច " ការត្រួតពិនិត្យឧបករណ៍សម្ភារៈ មុនប្រើប្រាស់វា "?
11. ចូរពន្យល់នូវចំណុច " ការប្រើប្រាស់ឧបករណ៍បានត្រឹមត្រូវ "?
12. ចូរពន្យល់នូវចំណុច " ការពារឧបករណ៍របស់អ្នក "?
13. តើ ស៥ ( 5s ) ជាអ្វី? ចូរពន្យល់អត្ថន័យនីមួយៗ?

## •វិធីសាស្ត្រសង្គ្រោះបឋម

នៅពេលទទួលរងការធេក់ដោយអគ្គិសនីនោះ យើងត្រូវរកវិធីសាស្ត្រផ្សេងៗដែលអាចជួយឲ្យជនរងគ្រោះរួចផុតពីគ្រោះថ្នាក់។ ប៉ុន្តែប្រសិនបើមនុស្សស្ថិតនៅទីកន្លែងដែលកំពុងគ្រោះថ្នាក់នៃអគ្គិសនីក្នុងរយៈពេលយូរ មនុស្សនោះនឹងឈានទៅរកសេចក្តីស្លាប់ ដូច្នេះពួកយើងមិនអាចជួយសង្គ្រោះបានឡើយ។ យ៉ាងណាមិញបើយើងជួបនូវករណីមានមនុស្សធេក់ហេតដល់បាត់ស្មារតី ឬសន្លប់យើងអាចជួយជនរងគ្រោះតាមរយៈដំណោះស្រាយដូចខាងក្រោម៖

- **ការជួយសង្គ្រោះបឋម " ការជួយសង្គ្រោះបន្ទាន់ "**
  - បន្ធូរសម្លៀកបំពាក់ ជួយសម្រួលផ្លូវដង្ហើម និងបេះដូង។
  - បន្តការជួយសង្គ្រោះរហូតដល់ក្រុមជួយសង្គ្រោះមកដល់។
- **វិធីសម្រួលដង្ហើម**
  - ដាក់ឱ្យជនរងគ្រោះដេកត្រង់ខ្លួនផ្ងារ។
  - ផ្តល់ដង្ហើមតាមមាត់ដោយការផ្លុំខ្យល់ចូលតាមមាត់ ជាចង្វាក់ៗប្រមាណ ១៥ ទៅ ២០ដង ក្នុង១នាទី។
  - ប្រើដៃសង្កត់ដើមទ្រូងបរិវេណបេះដូងរបស់ជនរងគ្រោះ ដោយប្រើចង្វាក់បេះដូងប្រមាណ ៦០ ដងក្នុង ១នាទី។



រូបភាព៩៥ ដកដង្ហើមឱ្យបានជ្រៅ (១)



រូបភាព៩៦ ការផ្លុំខ្យល់ចូលតាមមាត់ (២)



រូបភាព៩៧ ដាក់ឲ្យជងរងគ្រោះដេកត្រង់ខ្លួនផ្ងារ និងភ្ងើយក្បាលដូចទិសដៅព្រួញ (៣)



រូបភាព៩៨ ទាញចង្កាជនរងគ្រោះទៅមុខ និង សង្កត់ក្បាលតាមទិសដៅព្រួញ (៤)

**•វិធីសង្រ្គោះមនុស្សឱ្យផុតពីគ្រោះថ្នាក់ដោយការឆក់ចរន្តអគ្គិសនី**

ដើម្បីជួយសង្រ្គោះមនុស្សឱ្យផុត ពីគ្រោះថ្នាក់នៅពេលដែលមនុស្សម្នាក់ ត្រូវឆក់ដោយចរន្តអគ្គិសនីដែលកើតឡើងនៅលើខ្សែចម្លង ឬនៅលើគ្រឿងបរិក្ខារអគ្គិសនីផ្សេងៗ យើងត្រូវអនុវត្តដូចខាងក្រោម៖

- ត្រូវប្រញាប់ជួយជនរងគ្រោះដោយ៖

-ត្រូវផ្តាច់ប្រភពចរន្តអគ្គិសនីពីឌីសង់ទ័រ ប៉ារ៉ែត ឬកុងតាក់ ដែលនៅក្បែរកន្លែងកើតហេតុមុនគេបង្អស់ មុននឹងយើងចូលទៅជួយសង្រ្គោះជនរងគ្រោះ។

-ប្រសិនបើយើងមិនអាចរកប្រភព ដើម្បីបិទចរន្តអគ្គិសនីបានទេ (ក្នុងករណីដែលប្រភពភ្លើង នៅឆ្ងាយពេកពីកន្លែងកើតហេតុ) យើងត្រូវតែរកមធ្យោបាយផ្សេងទៀតដើម្បីជួយជនរងគ្រោះដោយយើងរកវត្ថុ ដូចជាកំណាត់ឈើស្ងួត ឫស្សីស្ងួត ទៅឆ្កឹះទាញយកខ្សែភ្លើងនោះចេញពីជនរងគ្រោះ។

-ឬក៏យើងយករបស់អ្វីមួយដែលមុត ហើយមានដងស្ងួត ឬមានអ៊ីសូឡង់ការពារចរន្តអគ្គិសនី ទៅកាប់ផ្តាច់ខ្សែភ្លើងនោះក៏បាន។

-ឬយើងយកក្រមាស្ងួត ទៅទាក់ខ្លួនជនរងគ្រោះទាញចេញពីប្រភពចរន្តអគ្គិសនីក៏បានដែរ។

-ឬយើងអាចលូកចាប់ខោ ឬក៏ចាប់អាវជនរងគ្រោះទាញចេញពីកន្លែងប្រភពអគ្គិសនីក៏បាន ដោយរក្សារាងកាយរបស់យើងមិនឲ្យប៉ះទៅនឹងរាងកាយរបស់ជនរងគ្រោះ ដែលកំពុងគ្រោះថ្នាក់ដោយចរន្ត អគ្គិសនីឡើយ ហើយស្ថិតនៅស្ថានភាពសម្លៀកបំពាក់របស់ជនរងគ្រោះ ស្ងួតជាដាច់ខាត បើសម្លៀកបំពាក់ជនរងគ្រោះសើម ឬក៏មានសំណើមសូម្បីមានបន្តិចបន្តួចក៏ដោយ ក៏វាធ្វើឲ្យយើងដែលជាអ្នកជួយសង្រ្គោះគេបណ្តាលឲ្យមានគ្រោះថ្នាក់ដូចគេផងដែរ។

-ដាក់ជនរងគ្រោះនៅឱ្យស្ងៀមមួយកន្លែងដើម្បីកាត់បន្ថយការឆក់ និងមានខ្យល់ចេញចូលគ្រប់គ្រាន់ តែបើទុកយូរមិនបានគ្រាន់បើជាងមុន ត្រូវបញ្ជូនជនរងគ្រោះ ទៅមន្ទីរពេទ្យជាបន្ទាន់ ក្នុងករណីឡានពេទ្យមកដល់។

-តែបើក្នុងករណីឡានពេទ្យមិនទាន់មកដល់ យើងត្រូវធ្វើការសង្រ្គោះបឋម ។

- វិធីសាស្ត្រសង្រ្គោះបឋម CPR ( cardiopulmonary resuscitation )

-ជំហាន១ ត្រួតពិនិត្យការឆ្លើយតប

តើលោកអាចឮខ្ញុំនិយាយបានទេ? សូមបើកភ្នែក តើលោកឈ្មោះអ្វី? ចាប់ដៃខ្ញុំ



រូបភាព៩៩ ជំហាន១

-ជំហាន២ រៀបចំសម្រួលដង្ហើម

ចាប់ផ្តើម និងងើយក្បាល ប្រសិនបើអ្នកឃើញស្លេះ ឬវត្ថុចំឡែក ត្រូវផ្អៀងក្បាលជនរងគ្រោះ ហើយសម្អាតរបស់ទាំងនោះចេញ



រូបភាព១០០ ជំហាន២

-ជំហាន៣ ត្រូវពិនិត្យការដកដង្ហើម

មើលទៅដើមទ្រូង ស្តាប់សំឡេងខ្យល់ចេញចូល ទទួលអារម្មណ៍ថា មានខ្យល់ចេញចូល សម្រួលឱ្យទ្រូងពើងឡើង



រូបភាព១០១ ជំហាន៣

-ជំហាន៤ បើគ្មានសញ្ញាថាមានជីវិត

ផ្តល់ការសង្កត់ ៣០ដង ចំកណ្តាលទ្រូង និងផ្តល់ដង្ហើមសង្គ្រោះ ២ដង ហើយធ្វើដូចនេះយ៉ាងតិច ៥ដង ក្នុងរយៈពេល ២នាទី។



រូបភាព១០២ ជំហាន៤ ពេលឃើញមនុស្សសន្លប់



រូបភាព១០៣ សញ្ញាប្រុងយ័ត្ន



រូបភាព១០៤ ត្រូវត្រួតពិនិត្យពីភាពគ្រោះថ្នាក់បើគ្មានសញ្ញាថាមានជីវិតត្រូវ ផ្តល់ការសង្គ្រោះCPR

-ជំហាន៥ បើសិនគ្មានដង្ហើម

ត្រូវផ្តល់ដង្ហើមសង្គ្រោះ ២ដង



រូបភាព១០៥ ជំហាន៥

-ជំហាន៦ បើសិនបើជនរងគ្រោះនៅមានជីវិត ត្រូវប្រែជនរងគ្រោះឲ្យដេកផ្អៀង



រូបភាពទី១០៦ ជំហាន៦

-ជំហាន៧ បន្តការសង្គ្រោះរហូតដល់ជំនួយ(រថយន្តសង្គ្រោះ) មកដល់

ប្រសិនបើអាចប្រើឧបករណ៍ឆក់ជំនួយបេះដូង ( defibrillator ) ឱ្យបានឆាប់តាមដែលអាចធ្វើបាន



រូបភាព១០៧ ជំហាន៧

+ព័ត៌មានអ្វីដែលអ្នកនឹងត្រូវផ្តល់នៅពេលដែលអ្នកទូរស័ព្ទរកជំនួយ (រថយន្តសង្គ្រោះ)?

-ស្នើសុំរថយន្តសង្គ្រោះ។

-ប្រាប់ទីតាំងភូមិសាស្ត្រដែលអ្នកកំពុងនៅ។

-ពេលនោះបុគ្គលិកទំនាក់ទំនងរថយន្តសង្គ្រោះ នឹងបញ្ជូនភ្នាក់ងារសង្គ្រោះទៅជួយសង្គ្រោះ ហើយបុគ្គលិកទំនាក់ទំនង នឹងសួរសំណួរមួយចំនួនដូចខាងក្រោម៖

-ទីតាំងដែលកើតហេតុ។

-លេខទូរស័ព្ទដែលគេអាចទំនាក់ទំនងមកវិញបាន។

-ព្រឹត្តិការណ៍លម្អិតនៃការកើតហេតុ។

-តើជនរងគ្រោះនៅដឹងខ្លួន?

-តើជនរងគ្រោះនៅមានដង្ហើម?

-ស្ថានភាពពិតប្រាកដនៃរបួស ឬជំងឺរបស់ជនរងគ្រោះ។

បុគ្គលិកទំនាក់ទំនងរថយន្តសង្គ្រោះ នឹងផ្តល់ដំបូន្មានពីសកម្មភាពចាំបាច់ដែលអ្នកគួរតែធ្វើ រហូតដល់ភ្នាក់ងារសង្គ្រោះមកដល់។

- ការធ្វើ CPR សង្គ្រោះសម្រាប់មនុស្សពេញវ័យ និងសង្គ្រោះសម្រាប់កុមារ (១ ដល់ ៨ឆ្នាំ )៖

១. ងើយក្បាល។។

២. ផ្តល់ដង្ហើមសង្គ្រោះ ២ដង

៣. ចាប់ផ្តើមធ្វើចលនាបេះដូងដោយសង្កត់ប្រើដៃទាំងពីរទៅលើទ្រូងឱ្យបាន ៣០ដង។

៤. ធ្វើសារឡើងវិញជំហានទី២ និងទី៣។

៥. បន្តរហូតដល់រថយន្តសង្គ្រោះមកដល់ ឬរហូតដល់ជនរងគ្រោះដឹងខ្លួន ឬធ្វើរហូតទាល់តែមិនអាចធ្វើបាន។



រូបភាព១០៨ សង្គ្រោះសម្រាប់មនុស្សពេញវ័យ និងសង្គ្រោះសម្រាប់កុមារ

❖ ការធ្វើ CPR សង្គ្រោះសម្រាប់ទារក ( ០ ដល់ ១ ឆ្នាំ )

ហាមងើយក

១. ងើយក្បាល។

២. ផ្តល់ដង្ហើមសង្គ្រោះ ២ដង។

៣. ចាប់ផ្តើមធ្វើចលនាបេះដូងដោយសង្កត់ប្រើដៃទាំងពីរទៅលើទ្រូងឱ្យបាន ៣០ដង។

៤. ធ្វើសារឡើងវិញជំហានទី២ និងទី៣។

៥. បន្តរហូតដល់រថយន្តសង្គ្រោះមកដល់ ឬរហូតដល់ជនរងគ្រោះដឹងខ្លួន ឬធ្វើរហូតទាល់តែ មិនអាចធ្វើបាន។




រូបភាព១០៩ សង្គ្រោះសម្រាប់ទារក ( ០ ដល់ ១ ឆ្នាំ )

## សំណួរពិភាក្សា

1. ការឆក់ចរន្តអគ្គិសនីគឺជាអ្វី?
2. ហេតុអ្វីបានជាចរន្តអគ្គិសនីមានគ្រោះថ្នាក់?
3. ការឆក់ដោយចរន្តអគ្គិសនីមានប៉ុន្មានប្រភេទ ?អ្វីខ្លះ ?
4. ដូចម្ដេចដែលហៅថា ការឆក់ដោយផ្ទាល់?
5. ដូចម្ដេចដែលហៅថា ការឆក់ដោយប្រយោល?
6. ចូរពន្យល់នៃការឆក់ចរន្តអគ្គិសនីដូចជា៖ 0.001A , 0.015A , 0.05A , 0.1A ?
7. តើចរន្តលេចធ្លាយចេញមកក្រៅប៉ុន្មាន អំពែ (A) ដែលបង្កហានិភ័យបាន?
8. តើការឆេះ ឬដុតបណ្ដាលមកពីអគ្គិសនីគឺជាអ្វី?
9. តើការបែកផ្កាភ្លើងនៃអគ្គិសនីកើតឡើងដោយសារអ្វី?
10. តើលទ្ធផលនៃការបែកផ្កាភ្លើងអគ្គិសនីមានគ្រោះថ្នាក់អ្វីខ្លះ?
11. តើឯកសណ្ឋានសុវត្ថិភាពមានអ្វីខ្លះ ?ចូរពន្យល់រូបនីមួយៗ។
12. ចូរពន្យល់ពី វិធីសាស្ត្រសង្គ្រោះមនុស្សឲ្យផុតពីគ្រោះថ្នាក់ដោយការឆក់ចរន្តអគ្គិសនី?

## មេរៀនទី៣

# ការចាត់ជាអាទិភាពនិងរៀបចំការងារ និងការគ្រប់គ្រងពេលវេលា

### ១.សេចក្តីណែនាំ

### សន្លឹកព័ត៌មាន ១.១៖ ការស្វែងយល់អំពីរបៀបក្នុងការគិត និងរៀបចំផែនការសម្រាប់អនាគត

### តើមនុស្សម្នាក់ៗរៀបចំផែនការសម្រាប់អនាគតយ៉ាងដូចម្តេច?

តើអ្នកយល់យ៉ាងណាចំពោះអនាគតកាល? តើអ្នកមានទស្សនវិស័យពិតប្រាកដនឹងក្លាយជាអ្វី? តើអ្នកនឹងនៅជាមួយអ្នកណា ធ្វើអ្វីក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយៗទៀត? តើអ្នកគិតថា អ្នកនឹងប្រើប្រាស់នូវគុណតម្លៃរបស់អ្នកដូចម្តេច ដើម្បីឲ្យអ្នកចាប់យកជម្រើសទាំងឡាយដែលអ្នកត្រូវយកមកប្រើប្រាស់ ជឿជាក់ថាអ្នកនឹងជួបប្រទះឱកាសល្អៗក្នុងឆាកជីវិត និងទទួលបាននូវការងារដែលអ្នកពេញចិត្ត ទំនាក់ទំនងយ៉ាងប្រសើរ និងជីវិតមួយដ៏ប្រពៃ? ឬមួយក៏អ្នកគិតតែអំពីអ្វីដែលត្រូវធ្វើក្នុងថ្ងៃនេះ ច្រើនជាងគិតលើអ្វីដែលត្រូវបំពេញសម្រាប់ថ្ងៃស្អែក ដោយផ្តោតការយកចិត្តទុកដាក់លើសកម្មភាពជាក់ស្តែងភ្លាមៗនាពេលបច្ចុប្បន្ន ជាជាងការគិតទុកអំពីអនាគត?

ចូរស្វែងយល់អំពីរបៀបក្នុងការគិត និងរៀបចំផែនការសម្រាប់អនាគត។ ជាការពិតណាស់ មានមនុស្សមួយចំនួន ផ្តោតសំខាន់ទៅលើលទ្ធផលចុងក្រោយ ដោយគេបានកំណត់គោលដៅសម្រាប់ខ្លួនគេរួចហើយ រួចចាប់ផ្តើមអនុវត្តសកម្មភាពដោយព្យាយាម និងគំនិតតែមួយ ដើម្បីសម្រេចគោលដៅរបស់គេ។ ចំណែកមនុស្សមួយចំនួនទៀត គឺតម្រង់យកសកម្មភាពជាគោល។ មនុស្សទាំងនេះរីករាយ នឹងបំពេញការងារយ៉ាងសកម្មក្នុងពេលបច្ចុប្បន្ន ហើយគេចំណាយពេលតិចតួចបំផុតគិតទៅលើបញ្ហាផ្សេងៗ ក្រៅពីការងារ ឬគម្រោងបន្ទាន់។ ខណៈដែលនៅមានមនុស្សមួយចំនួនផ្សេងទៀត ផ្តោតទៅលើទិសដៅ និងទស្សន វិស័យពេញលេញមួយ។ គេគិតអំពីអនាគត ដែលជាផ្នែកមួយនៃទស្សនវិស័យសំខាន់ផ្ទាល់ខ្លួន ហើយគេធ្វើការសម្របសម្រួលសកម្មភាពបច្ចុប្បន្ន ជាមួយការស្រមើលស្រមៃ ដែលលេចចេញមកដោយពុំទាន់មានភាពជាក់លាក់។ ដោយសារតែមនុស្សម្នាក់មានរបៀបគិតខុសៗគ្នាអំពីអនាគត និងការធ្វើផែនការ គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើន ដែលកើតឡើងក្នុងពេលដែលគេពិចារណាលើការរៀបចំផែនការ និងយុទ្ធសាស្ត្ររបស់អង្គភាព។

ផែនការនិងយុទ្ធសាស្ត្ររបស់អង្គភាពភាគច្រើនផ្តោតស្ទើរតែទាំងស្រុងទៅលើគោលដៅនិងវត្ថុបំ ណងជាក់លាក់ ដោយមិនគិតគូរ ឬផ្តោតតិចតួចថា តើទស្សនវិស័យមានភាពសំខាន់ដែលអាចផ្តល់នូវអត្ថន័យយ៉ាងជ្រាលជ្រៅ ចំពោះយើង និងធនធានដែលយើងមានបំណងធ្វើការចំណាយយ៉ាងដូចម្តេច?។ អត្ថន័យនៃជីវិត និងការងារមានសារៈសំខាន់ ពីព្រោះមនុស្សជាភាវៈដែលពោរពេញទៅដោយគោលបំណង។ តាមពាក្យរបស់ភាសាក្រិច «teleos» មានន័យថាទប់ជំហររបស់យើង។ មនុស្សយើងតែងតែឈានជើងឆ្ពោះទៅមុខជានិច្ចទៅរកអនាគត ដែលប្រសើរជាងថ្ងៃនេះ។ ដោយការឆ្ពោះទៅមុខ យើងនឹងស្វែងរកអនាគតដ៏មានន័យល្អឥតខ្ចោះ និងពេញលេញ។ យើងស្វែងរកគោលបំណង បេសកកម្ម និងទស្សនវិស័យដ៏ល្អ ព្រមទាំងមធ្យោបាយដើម្បីទៅដល់ទិសដៅ តាមរយៈយុទ្ធសាស្ត្រ ផែនការ គោលដៅ និងសកម្មភាព។ បើសិនជាអ្នកមានភាពម្ចាស់ការ ដើម្បីឈានទៅដល់គោលដៅ នោះអ្នកនឹងរកឃើញមធ្យោបាយ ដើម្បីជំរុញឱ្យអ្នកដទៃ រក

ឃើញអត្ថន័យនៅក្នុងទស្សនវិស័យនិងមានទឹកចិត្តបំពេញការងារ  ហេតុនេះអ្នកកាន់តែទទួលបានជោគជ័យក្នុងការបង្កើត អនុវត្តផែនការ និងយុទ្ធសាស្ត្រ។

**ស្វ័យវាយតម្លៃ ១.១**
**ចូរឆ្លើយនឹងសំណួរខាងក្រោម៖**

១. តើមានវិធីសាស្ត្រអ្វីខ្លះដែលប្រើប្រាស់ក្នុងការរៀបចំផែនការ ?
២. ហេតុអ្វីបានជាអត្ថន័យនៃជីវិត និងការងារ មានសារៈសំខាន់សម្រាប់មនុស្ស ?
៣. ផែនការ និងយុទ្ធសាស្ត្ររបស់អង្គភាពភាគច្រើនផ្តោតលើអ្វី ?

**ចម្លើយគំរូ ១.១**

១. វិធីសាស្ត្រដែលប្រើប្រាស់ក្នុង ការរៀបចំផែនការ ជាទូទៅមានបី (១)ផ្តោតលើគោលដៅ/លទ្ធផល (២)សកម្មភាពបច្ចុប្បន្ន និង(៣)ទស្សនវិស័យ។

២. បានជាអត្ថន័យនៃជីវិតនិងការងារ មានសារៈសំខាន់សម្រាប់មនុស្ស ព្រោះមនុស្សជាភាវៈ ដែលពោរពេញទៅដោយគោលបំណង។

៣. ផែនការ និងយុទ្ធសាស្ត្ររបស់អង្គភាពភាគច្រើនផ្តោតលើគោលដៅ និងវត្ថុបំណងជាក់លាក់។

## សន្លឹកព័ត៌មាន ១.២៖ ពិពណ៌នាអំពីដំណើរការធ្វើផែនការក្នុងអង្គភាព

**ផែនការកម្ម** ជាដំណើរការអភិវឌ្ឍលំដាប់សកម្មភាពប្រកបដោយបញ្ញា គំនិតច្នៃប្រឌិត និងឥរិយាបថ ដើម្បីសម្រេចគោលដៅ ឬធ្វើដំណើរឆ្ពោះទៅមុខតាមការស្រមៃទៅអនាគត។ អ្នកប្រាជ្ញបានឱ្យគំនិតផ្សេងៗគ្នាក្នុងការធ្វើផែនការក្នុងអង្គភាពមួយ។ ភាគច្រើនបានឯកភាពជាមួយលោក ហ៊ែនរីមិនស៍ប៊ែគ (Henry Minzberg) ដែលបានចាត់ទុកថា ការធ្វើផែនការ គឺជាដំណើរការផ្លូវការមួយ ដែលរួមបញ្ចូលការវិភាគ ការច្នៃប្រឌិតនិងការសំយោគនៃគំនិត។ ដំណើរការនេះអាចជួយឱ្យគេសម្រេចចិត្តបានទៅលើជំហាន និងសកម្មភាពដែលអាចរួមបញ្ចូលគ្នា ដើម្បីនាំមនុស្ស និងអង្គភាពឆ្ពោះទៅរកគោលដៅនាពេលអនាគត ដែលគេប្រាថ្នាចង់បាន។

របៀបដែលមនុស្សបង្កើតទស្សនទានសម្រាប់អនាគតមានលក្ខណៈស្មុគស្មាញ។ របៀបដែលយើងរៀបចំផែនការផ្អែកលើផ្នែកមួយមានលក្ខណៈផ្ទាល់ខ្លួនដែលរួមមានអារម្មណ៍ផ្លាស់ប្តូទៅរកសុទិដ្ឋិនិយម ឬទុទិដ្ឋិនិយម។ សំខាន់ជាងនេះទៅទៀត របៀបដែលយើងគិតគូរពីអនាគត និងផែនការ គឺអាស្រ័យលើអ្វីដែលយើងបានរៀនសូត្រពីក្រុមគ្រួសារ សាលារៀន វប្បធម៌ ព្រមទាំងអាស្រ័យលើបទដ្ឋាន និងការអនុវត្តក្នុងអង្គភាពដែលយើងធ្វើការ។ យើងរៀនពីជំនាញទាក់ទងនឹងការធ្វើផែនការពីអ្នកដទៃ និងពីបរិយាកាសសង្គមដែលនៅជុំវិញយើង រួមបញ្ចូលទាំងអង្គភាពផ្សេងៗជាដើម។

ជាញឹកញាប់ ដំណើរការកំណត់គោលដៅ តែងតែមានភាពយល់ច្រឡំជាមួយនឹងការរៀបចំផែនការ។ ជាក់ស្តែងការកំណត់គោលដៅគ្រាន់តែជាទិដ្ឋភាពមួយនៃការធ្វើផែនការប៉ុណ្ណោះ វាជាទិដ្ឋភាពមួយដែលផ្តោតលើគំនូសព្រាង សកម្មភាពជាក់លាក់ និងលទ្ធផលដែលនឹងនាំមនុស្សឆ្ពោះទៅរកទីដៅ ដែលបានកំណត់យ៉ាងច្បាស់លាស់មួយ។ ការធ្វើផែនការតម្រង់ទៅរកគោលដៅពាក់ព័ន្ធជាមួយការកំណត់សកម្មភាព និងជំហាន ដែលនឹងនាំយើងចេញពីចំណុចបច្ចុប្បន្នទៅកាន់ទីដៅដែលបានកំណត់យ៉ាងច្បាស់លាស់។

### ផែនការកម្មតាមទិសដៅ

រាល់ការរៀបចំផែនការទាំងអស់ មិនមែនសុទ្ធតែមានលក្ខណៈតម្រង់ទៅរកគោលដៅទាំងអស់នោះទេ។ ជាញឹកញាប់ យើងជ្រើសរើសជំហានដោយផ្អែកលើទិសដៅជាទូទៅដែលយើងមានបំណងឆ្ពោះទៅ។ ផែនការកម្មតាមទិសដៅ កំណត់នូវដែនមួយ (សកម្មភាពទូទៅ) និងទិសដៅ(គុណតម្លៃ និងសកម្មភាពដែលចង់បាន) ជាងគោលដៅជាក់លាក់។ នេះមានន័យថា ដោយផ្អែកលើគុណតម្លៃផ្ទាល់ខ្លួន និងអង្គភាព មនុស្សមួយចំនួនធ្វើការសម្រេចចិត្ត សូម្បីតែការសម្រេចចិត្តប្រចាំថ្ងៃក៏ដោយ។ ការរៀបចំផែនការរបៀបនេះពាក់ព័ន្ធជាមួយប្រភេទផ្សេងៗគ្នានៃការផ្តោតលើគោលដៅនោះ គឺផ្តោតលើផ្លូវគោលដៅ ដែលត្រូវដើរជាជាងទិសដៅនៃគោលដៅដែលត្រូវធ្វើឱ្យបានសម្រេច។ ការផ្តោតលើគុណតម្លៃជាជាងផ្តោតលើគោលដៅជាក់លាក់ចុងក្រោយ វាជួយដល់យើងក្នុងការកំណត់បាននូវសកម្មភាពដែលត្រូវអនុវត្ត។

### ការរៀបចំផែនការតម្រង់ទៅរកសកម្មភាព

មនុស្សមួយចំនួនជៀសវាងពីការកំណត់គោលដៅ និងជៀសវាងផងដែរលើការកំណត់ផ្លូវដើរទូទៅមួយសម្រាប់អនាគត។ ផ្ទុយទៅវិញ ធនធានរបស់ពួកគេតម្រង់ទៅរកសកម្មភាពបន្ទាន់ៗ និងរយៈពេលខ្លី។

ជាការជាក់ស្តែង ការផ្តោតខ្លាំងពេកលើកិច្ចការបន្ទាន់ អាចធ្វើឱ្យមានការបង្អាក់ការធ្វើផែនការសម្រាប់ពេលអនាគត។ ម្យ៉ាងវិញទៀត ការតម្រង់ទៅរកសកម្មភាព ឬសមត្ថភាពក្នុងការធ្វើឱ្យនរណា ម្នាក់ផ្តោតការយកចិត្តទុកដាក់ពេញលេញលើកិច្ចការចំពោះមុខវឹតតែមានភាពសំខាន់ និងត្រូវតែបំពេញឱ្យបានផងដែរ។

**ស្វ័យវាយតម្លៃ ១.២**

១. ផែនការកម្ម គឺជាអ្វី?

២. តើការរៀបចំផែនការតម្រង់ទៅរកសកម្មភាពមានន័យដូចម្តេច?

៣. ហាងលក់សំលៀកបំពាក់មួយមានផែនការកត់ត្រារាល់ការផ្តល់វគ្គបំប៉នសមត្ថភាពសម្រាប់អ្នកគ្រប់គ្រ និងបុគ្គលិកផ្នែកលក់ វគ្គបំប៉នលើសេវាកម្មអតិថិជន និងការដាក់ចេញគោលដៅផ្នែកលក់។ តើការរៀបចំផែនការប្រភេទណាដែលត្រូវបានប្រើប្រាស់នៅក្នុងឧទាហរណ៍នេះ?

ក. ផែនការហិរញ្ញវត្ថុ

ខ. ផែនការប្រតិបត្តិការ

គ. ផែនការយុទ្ធសាស្ត្រ

**ចម្លើយគំរូ ១.២**

១. ផែនការកម្ម ជាដំណើរការអភិវឌ្ឍលំដាប់សកម្មភាពប្រកបដោយបញ្ញា គំនិតច្នៃប្រឌិត និងឥរិយាបថ ដើម្បីសម្រេចគោលដៅ ឬធ្វើដំណើរឆ្ពោះទៅមុខតាមការស្រមៃទៅអនាគត។

២. ការរៀបចំផែនការតម្រង់ទៅរកសកម្មភាព គឺដើម្បីធ្វើឱ្យយើងផ្តោតការយកចិត្តទុកដាក់ពេញលេញ លើកិច្ចការចំពោះមុខរឹតតែមានភាពសំខាន់ និងត្រូវតែបំពេញឱ្យបានផងដែរ។

ក. ផែនការហិរញ្ញវត្ថុ

ខ. ផែនការប្រតិបត្តិការ

គ. ផែនការយុទ្ធសាស្ត្រ

**សន្លឹកព័ត៌មាន ១.៣៖ ពន្យល់អំពីបញ្ហាជាទូទៅដែលកើតមានឡើងក្នុងការធ្វើផែនការ**
**តើមានបញ្ហាអ្វីខ្លះកើតឡើងនៅក្នុង ការរៀបចំផែនការដែលធ្វើឱ្យមានរនាំងឧបសគ្គ?**

| **បញ្ហាទូទៅក្នុងការរៀបចំធ្វើផែនការ** | |
|---|---|
| មនុស្សមួយចំនួននៅមិនទាន់យល់ | នេះ គឺជាការពិត ហើយគោលដៅមួយនៃគោលដៅទាំងអស់របស់យើង ដែលត្រូវធ្វើការកែតម្រូវលើបញ្ហានេះ។ |
| តម្រូវការផ្នែកសតិបញ្ញា | នេះ គឺជារឿងត្រឹមត្រូវ ហើយមិនមានការលើកលែងដែរ។ អ្នកទាំងអស់គ្នា គឺជាមនុស្សឆ្លាត បើមិនដូច្នោះទេ អ្នកនឹងមិនអាចទទួលបាននូវអ្វីដែលអ្នកមានដូចថ្ងៃនេះទេ។ វានឹងជួយឱ្យការងាររបស់អ្នកកាន់ តែគួរឱ្យចាប់អារម្មណ៍។ |
| ត្រូវការប្ដេជ្ញាចិត្ត | ពិតជាត្រឹមត្រូវខ្លាំងណាស់ ហើយយើងនឹងធ្វើការពិភាក្សាអំពីមូលហេតុរបស់វា។ |
| មានប្រវត្តិមិនសូវល្អ | នេះមិនមែនជារឿងសមហេតុសមផលឡើយ ប៉ុន្តែវាបានកើតឡើងរួចហើយ។ គម្រោងជាច្រើនមានបញ្ហា ឬបញ្ចប់ដោយកប់បញ្ហាជាច្រើនទៅជាមួយផង។ ការពិតអ្នកគ្រប់គ្រងថ្នាក់កណ្ដាល ឬបុគ្គលិកមានទំនុកចិត្ត តិចតួចលើអ្នកធ្វើផែនការ។ ជាទូទៅបញ្ហាកើតឡើងពីអ្នកធ្វើផែនការមិនមែនខ្លឹមសារផែនការទេ។តាមពិតមានឧទាហរណ៍រាប់លានអំពីការរៀបចំផែនការដែលទទួលបានជោគជ័យ។ **ឧ.** កម្មវិធីរបស់អង្គការ ណាសា... ។ល។ |
| ពាក់ព័ន្ធតែជាមួយថ្នាក់គ្រប់គ្រងខ្លាំងពេក | មនុស្សមួយចំនួនយល់ថា មានតែអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ប៉ុណ្ណោះ ដែលចូលរួមក្នុងការរៀបចំផែនការ។ នេះជារឿងមិនពិតនោះទេ! |
| **ចំណុចគន្លឹះ** | |
| កុំភ្លេចថាការធ្វើផែនការ គឺនិយាយពី**សកម្មភាព** មិនមែនជាព័ត៌មាននោះទេ។<br>ការគ្រប់គ្រងដឹកនាំ ក៏ជាសកម្មភាពដែរ។ ដូច្នេះ ការរៀបចំផែនការ គឺជាមិត្តដ៏ល្អរបស់អ្នក | |

ការរៀបចំផែនការ គឺជារឿងធម្មតាហើយសាមញ្ញ។ ទស្សនៈនេះអាចផ្ទុយនឹងអ្វីដែលអ្នកបានឮ ឬបានឃើញ។ ប្រការសំខាន់ដែលត្រូវចងចាំ គឺថានៅលើពិភពលោកយើងនេះពោរពេញទៅដោយមនុស្សដែលចូលចិត្តធ្វើឱ្យជីវិតស្មុគស្មាញ បង្កើតនូវពាក្យពិបាកយល់ និងក្រុមឯកទេសផ្សេងៗ។

ចំណុចគន្លឹះ៖

វិធីសាស្ត្រក្នុងការរៀបចំផែនការទាំង៣ មានគុណតម្លៃ ហើយអ្នកគួរតែយល់ដឹងអំពីវិធីសាស្ត្រទាំងនោះ ដើម្បីអាចបង្កើតផែនការដែលនឹងទាញចំណាប់អារម្មណ៍ និងការប្ដេជ្ញាចិត្តរបស់អ្នកដទៃ និងខ្លួនអ្នកផ្ទាល់។ ជាញឹកញាប់ ក្នុងនាមជាអ្នកគ្រប់គ្រង ឬអ្នកដឹកនាំក្រុម អ្នកនឹងត្រូវជួយដល់អ្នកនៅក្រោមបង្គាប់ក្នុងការរៀបចំផែនការ ព្រោះថាការរៀបចំផែនការមិនមែនត្រូវធ្វើឡើងម្ដងម្កាល ឬសម្រាប់តែថ្នាក់គ្រប់គ្រង ឬអ្នកដឹកនាំតែឯកឯងនោះទេ។

ផែនការត្រូវបានបង្កើតឡើង និងអនុវត្តជារៀងរាល់ថ្ងៃក្នុងអង្គភាពដោយស្ទើរតែគ្រប់និយោជិកទាំងអស់។ តាមពិតអ្នកគ្រប់គ្រងធ្វើផែនការជាបន្តបន្ទាប់។ អ្នកគ្រប់គ្រងរៀបចំផែនការមួយចំនួនដែលនឹងចាប់ផ្ដើម និង

បញ្ចប់ក្នុងថ្ងៃដដែល ហើយផែនការផ្សេងទៀតនឹងត្រូវបញ្ចប់រាប់ឆ្នាំ។ ការរៀបចំផែនការ គឺជាផ្នែកយ៉ាងសំខាន់មួយនៃការងាររបស់អ្នកគ្រប់គ្រង។ ហេតុនេះហើយ វាមានសារៈសំខាន់សម្រាប់បុគ្គលគ្រប់រូប ក្នុងការរៀនសូត្រជំនាញផ្សេងៗ ដែលពាក់ព័ន្ធនឹងការរៀបចំផែនការមានដូចជា ការដាក់ចេញនូវទស្សនវិស័យ ការកំណត់គោលដៅ និងការផ្សារភ្ជាប់សកម្មភាពជាក់ស្ដែងទៅនឹងគោលដៅ និងទស្សនវិស័យទាំងនោះ។

**ស្វ័យវាយតម្លៃ ១.៣**

**សំណួរទី១៖**

ចូររៀបរាប់បញ្ហាទូទៅ ៥យ៉ាង ដែលតែងតែជួបប្រទះនៅក្នុងការរៀបចំផែនការ។

ក. ..............................................................

ខ. ..............................................................

គ. ..............................................................

ឃ. ..............................................................

ង. ..............................................................

**សំណួរទី២៖**

ចូរបំពេញចន្លោះខាងក្រោមដោយប្រើពាក្យ *ព័ត៌មាន* និង *សកម្មភាព*

សូមចងចាំថាការរៀបចំផែនការ គឺ................. មិនមែនគ្រាន់តែជា..................នោះទេ។

**ចម្លើយគំរូ ១.៣**

**ចម្លើយរបស់អ្នកគួរតែដកស្រង់គំនិតដូចខាងក្រោម៖**

១- ចូររៀបរាប់បញ្ហាទូទៅ ៥ យ៉ាងដែលតែងតែជួបប្រទះនៅក្នុងការរៀបចំផែនការ

**ក. មនុស្សយើងមិនទាន់យល់ច្បាស់អំពីការរៀបចំផែនការ។**

**ខ. វាជាតម្រូវការផ្នែកខាងផ្លូវចិត្ត។**

**គ. វាត្រូវកាសរការតាំងចិត្តខ្ពស់។**

**ឃ. វាមានប្រវត្តិមិនសូវល្អ។**

**ង. វាពាក់ព័ន្ធច្រើនតែនឹងថ្នាក់គ្រប់គ្រង។**

២- ចូរបំពេញចន្លោះខាងក្រោមដោយប្រើពាក្យ *ព័ត៌មាន* និង *សកម្មភាព*

សូមចងចាំថាការរៀបចំផែនការ គឺ***<u>សកម្មភាព</u>*** មិនមែនគ្រាន់តែជា***<u>ព័ត៌មាន</u>*** នោះទេ

**សន្លឹកព័ត៌មាន ២.១៖ ផែនការ គោលដៅ គោលដៅរង ចំណុចគោលដៅ និង ជំហានសកម្មភាព**

**ដំណើរការក្នុងការរៀបចំផែនការឱ្យប្រកបដោយថាមវន្ត (Dynamic) និងអាចទទួលយកបានរួមមាន៖**

១- ភ្ជាប់ផែនការទៅនឹងបេសកកម្ម និងទស្សនវិស័យ។

២- រួមបញ្ចូលគោលដៅរងផ្សេងៗទៀតដែលមានលក្ខណៈដាច់ៗពីគ្នា និងរៀបចំដោយឡែក។

**តើអ្នកកំណត់ផែនការមិនជាក់លាក់មួយដោយរបៀបណា?**

ចូរធ្វើការប្រៀបធៀបដំណើរការនៃការរៀបចំផែនការជាក់លាក់ ជាមួយនឹងដំណើរការនៃការរៀបចំផែនការមួយដែលកើតឡើងក្នុងកំឡុងពេលមិនប្រាកដណាមួយ។

ពាក្យថា «ផែនការ(Plan)» ត្រូវបានប្រើប្រាស់តាំងពីសតវត្សទី១៥។ ពាក្យ «ផ្ទៃរាប(Plane)» មានន័យថា កម្រិត ឬផ្ទៃរាបស្មើ។ ក្រោយមកពាក្យនេះបានប្រែមកជា «គ្រោងសកម្មភាព» ឬ«ការរៀបរៀង»។ តាមកំណត់ត្រាដំបូងនៅឆ្នាំ១៧០៦ និងដើមកំណើតរបស់វាបានស្ថិតក្នុងគំនិតថា ជាដំណើរការតាមខ្សែត្រង់ច្បាស់លាស់អ្វីមួយដែលមានចំណុច បញ្ចប់ពីរ ឬការប្រែប្រួលពីសភាពមួយទៅសភាពមួយទៀត។ ប៉ុន្តែជីវិតមិនដូច្នេះទេ ហើយផែនការកម្មក៏មិនដូច្នេះដែរ។ ផែនការជាច្រើន នៅក្នុងអង្គភាពមានលក្ខណៈ ស្មុគស្មាញ និងសមស្របជាមួយផែនការផ្សេងទៀត ហើយមិនដំណើរការតាមខ្សែត្រង់។ រាល់ផែនការតែងប្រែប្រួល ពេលណាដែលផែនការមួយមិនមានភាពប្រែប្រួល នោះផែនការនោះមិនឆ្លើយតបទៅនឹងគោលដៅទេ។ នេះដោយសារតែអ្វីៗទាំងអស់មានការប្រែប្រួល ហើយបើសិនជាផែនការមិនអាចផ្លាស់ប្តូរបាន ផែនការនឹងបរាជ័យ។ ប្រការសំខាន់ត្រូវរក្សាគោលដៅ គោលបំណង និងទស្សនវិស័យ។ ទោះជាយ៉ាងណាក៏ដោយបុគ្គលម្នាក់ក្រុមមនុស្ស និងអង្គភាពដែលតម្រង់ឆ្ពោះទៅកាន់ទស្សនវិស័យ ផែនការ និងគោលដៅណាមួយក៏ដោយ ក៏ត្រូវធ្វើការកែតម្រូវដែរ។

**គោលដៅ គោលដៅរង ចំណុចគោលដៅ និងជំហានសកម្មភាព ៖ ការបង្កើតផែនទីធ្វើដំណើរទៅកាន់ទិសដៅរបស់អ្នក**

**គោលដៅ (Goal) ៖** យោងតាមវចនានុក្រម American Heritage បានឱ្យនិយមន័យពាក្យគោលដៅថា «គោលបំណងមួយឆ្ពោះទៅរកការខិតខំប្រឹងប្រែងមួយដែលមានការតម្រង់ទិស ដែលហៅថា **វត្ថុបំណង**»។ ពាក្យ ***គោលដៅ*** មានអត្ថន័យដើមថា «**ចំណុចបញ្ចប់**» ហើយវាប្រហែលជាក្លាយមកពីពាក្យភាសាអង់គ្លេសសម័យមុនគឺ Gal ដែលមានន័យថា «**ឧបសគ្គ**»។ គោលដៅ និង គោលដៅរង ដែលមានលក្ខណៈ **SMART** គឺជាក់លាក់ (specific) អាចវាស់វែងបាន (measurable) អាចសម្រេចជោគជ័យបាន (achievable) ដែលមានភាពពាក់ព័ន្ធ (relevant) និង មានពេលវាលាច្បាស់លាស់ (time specific) ។

**គោលដៅរង (Sub goal) ៖** គោលដៅរង គឺជាគោលដៅមួយដែលបានបង្កើតឡើង ដើម្បីជួយឱ្យសម្រេចគោលដៅធំនិងមានលក្ខណៈស្មុគស្មាញ។ គោលដៅធំតែងមានគោលដៅរងជាច្រើន ដែលគោលដៅរងនីមួយៗងាយស្រួលសម្រេចបាន និងច្បាស់លាស់ជាងគោលដៅធំ។

**ចំណុចគោលដៅ(Milestone) ៖** ពាក្យ Milestone មានដើមកំណើតមកពីការកំណត់ចម្ងាយផ្លូវដោយការដាក់ថ្មជាសញ្ញាសម្គាល់ពីចំណុចមួយទៅចំណុចមួយ។ សព្វថ្ងៃនេះ បង្គោលចម្ងាយសំដៅទៅលើ

ឧបករណ៍សម្គាល់ទាំងឡាយណាដែលប្រាប់ថាយើងបានធ្វើដំណើរបានឆ្ងាយប៉ុណ្ណាហើយ។ សញ្ញានេះជួយយើងឱ្យកំណត់បានថាតើយើងបានឈានដល់កម្រិតណា ហើយក្នុងការសម្រេចនូវគោលដៅរបស់យើង។

**ជំហានសកម្មភាព (Action steps)** ៖ ជំហានសកម្មភាពជាសកម្មភាពនីមួយៗ ដែលទ្រទ្រង់ទៅដល់ការសម្រេចគោលដៅធំ និងគោលដៅរង។ ពាក្យថាជំហាន ជាទូទៅសំដៅទៅលើដំណើរការខ្សែបណ្តោយតាមពេលវេលា។ ទោះជាយ៉ាងណា ជំហានសកម្មភាពមិនមែនសុទ្ធតែត្រូវបានរៀបចំតាមលំដាប់ពេលវេលា ឬជាខ្សែបណ្តោយជានិច្ចនោះទេ។

*ការរៀបចំផែនការម៉ូឌុល*

យើងអាចដឹងបន្តិចបន្តួចអំពីការរៀបចំផែនការបែបម៉ូឌុលពីអ្នកគណិតវិទូ អែនគ្រេម៉ាកខូវ (Andrey Markov) ដែលបានបង្ហាញយើងថា ការវិភាគនូវអ្វីដែលអាចកើតមានឡើង ពេលខាងមុខអាចជួយឱ្យយើងសម្រួលផែនការរបស់យើងបាន។

អ្នកគ្រប់គ្រងនាសតវត្សទី២១ នេះតែងតែប្រឈមមុខទៅនឹងការផ្លាស់ប្តូរជាបន្តបន្ទាប់ និងឆាប់រហ័ស។ សមត្ថភាពក្នុងការសម្របតាមការផ្លាស់ប្តូរទាន់ពេលវេលា ជាមធ្យោបាយដែលអាចចែកដាច់ពីគ្នារវាងបុគ្គលិក អ្នកគ្រប់គ្រង និងអ្នកដឹកនាំដែលជោគជ័យ។ ដូច្នេះទោះបីជាផែនការ គោលដៅ និងគោលដៅរង គឺជាមគ្គុទេសក៏សំខាន់ក៏ដោយ ក៏ការផ្លាស់ប្តូរក្នុងការរៀបចំផែនការតែងតែកើតមានឡើងមិនអាចចៀសផុតបាន។

*ការរៀបចំផែនការបែបសេណារីយ៉ូ*

ផែនការបែបសេណារីយ៉ូ ជាដំណើរការប្រកបដោយថាមពល និងមានលក្ខណៈជាប្រព័ន្ធមួយ ដែលមនុស្សទូទៅអាចមើលឃើញសេណារីយ៉ូ «តើមានអ្វីកើតឡើងប្រសិនបើ....» សម្រាប់ស្ថានភាពណាមួយ និងផែនការចំពោះអ្វីដែលអាចកើតឡើង។

អ្នកគ្រប់គ្រង អ្នកដឹកនាំ និងបុគ្គលិកដែលទន់ភ្លន់ សកម្មជាមុនចំពោះផែនការ អាចនឹងសម្រេចបានភាពជោគជ័យផ្ទាល់ខ្លួន និងភាពជោគជ័យរបស់អង្គភាព ជាជាងអ្នកដែលចង់បានស្ថេរភាព និងរក្សាស្ថានភាពបច្ចុប្បន្នឱ្យនៅដដែល។

## ស្វ័យវាយតម្លៃ ២.១

| ការត្រួតពិនិត្យចំណេះដឹង |
| --- |

**១. ចូរផ្គូរផ្គងពាក្យ និងអត្ថន័យដូចខាងក្រោម៖**

| | |
| --- | --- |
| គោលដៅ | ក. គោលដៅដែលត្រូវបានបង្កើតឡើង ដើម្បីជួយសម្រេចបានគោលដៅធំ និងស្មុគស្មាញ។ |
| គោលដៅរង | ខ. ជាបំណងមួយដែលការខិតខំប្រឹងប្រែងធ្វើឡើងតាមការតម្រង់ទិស។ |
| ចំណុចគោលដៅ | គ. ជួយយើងកំណត់បាននូវការរីកចម្រើនឆ្ពោះទៅការសម្រេចគោលដៅ ឬគោលដៅរង។ |
| ជំហានសកម្មភាព | ឃ. ជាសកម្មភាពនីមួយៗ ដែលជួយទ្រទ្រង់ដល់ការសម្រេចគោលដៅ និងគោលដៅរង។ |

**២. ការរៀបចំផែនការសេណារីយ៉ូគឺជា៖**

- ☐ ដំណើរការប្រកបដោយថាមពល។
- ☐ ដំណើរការដែលមានលក្ខណៈជាប្រព័ន្ធ។
- ☐ ដំណើរការដែលមានលក្ខណៈដដែលៗ។
- ☐ ដំណើរការដែលមិនបានគ្រោងទុកមុន។

ចម្លើយគំរូ ២.១

១. ចូរផ្គូរផ្គងពាក្យ និងអត្ថន័យដូចខាងក្រោម៖

1. **គោលដៅ** ⇨ ខ.
2. **គោលដៅរង** ⇨ ក.
3. **ចំណុចគោលដៅ** ⇨ គ.
4. **ជំហានសកម្មភាព** ⇨ ឃ.

២. ការរៀបចំផែនការសេណារីយោគឺជា ៖

☑ **ដំណើរការប្រកបដោយថាមពល**
☑ **ដំណើរការដែលមានលក្ខណៈជាប្រព័ន្ធ**
☐ ដំណើរការដែលមានលក្ខណៈដដែលៗ
☐ ដំណើរការដែលមិនបានគ្រោងទុកមុន

## សន្លឹកព័ត៌មាន ២.២៖ បេសកកម្ម និងសារៈសំខាន់នៃទស្សនវិស័យ
## តើអ្វីទៅជា បេសកកម្ម? តើហេតុអ្វីបានជាទស្សនវិស័យមានសារៈសំខាន់?

កំណត់និយមន័យ និងស្វែងយល់អំពីសារៈសំខាន់របស់ "បេសកកម្ម និងទស្សនវិស័យ" ដែលជាមូលហេតុនាំឱ្យអង្គភាពមួយទទួលបានជោគជ័យ។

បេសកកម្មរបស់អង្គភាពមួយបញ្ជាក់យ៉ាងច្បាស់ អំពីគោលបំណងជាមូលដ្ឋានរបស់អង្គភាពនោះ។ ខ្លឹមសាររបស់បេសកកម្ម ពិពណ៌នាអំពីអង្គភាពជាអង្គភាពអ្វីធ្វើអ្វីខ្លះ និងតំណាងឱ្យអ្វីខ្លះ?។ អ្នកប្រាជ្ញម្នាក់ដែលគាត់បានសិក្សាអំពីខ្លឹមសារបេសកកម្មជាច្រើនបាននិយាយថា «ខ្លឹមសារបេសកកម្មមួយ គឺការបង្ហាញគោលបំណងយូរអង្វែងរបស់អង្គភាព ដែលបញ្ជាក់អំពីវិសាលភាពក្នុងប្រតិបត្តិការផ្អែកតាមន័យទីផ្សារ និងផលិតផល ព្រមទាំងឆ្លុះបញ្ចាំងពីគុណតម្លៃ និងអាទិភាព»។ ខ្លឹមសារច្បាស់លាស់របស់បេសកកម្មមួយ មិនមែនបង្កើតឡើងដើម្បីគ្រាន់តែឱ្យបុគ្គលមានមោទនភាពចំពោះអង្គភាពប៉ុណ្ណោះទេ (ទោះបីជាយ៉ាងនេះ ក៏ដោយបុគ្គលទាំងនោះនៅតែមោទនភាពដដែល)។ ខ្លឹមសារបេសកកម្មមានលក្ខណៈច្បាស់លាស់ ហើយជួយចង្អុលបង្ហាញមនុស្សត្រូវធ្វើអ្វីខ្លះនៅកន្លែងធ្វើការ។

ក្នុងអត្ថន័យយុទ្ធសាស្ត្រ បេសកកម្មរបស់អង្គភាពមួយ គឺជាអ្វីដែលកំណត់ដាច់ពីគ្នា ដោយបញ្ជាក់យ៉ាងច្បាស់ពីលក្ខខណ្ឌវិជ្ជមាន និងផ្តល់ប្រយោជន៍ប្រកួតប្រជែងផ្សេងៗ ដែលញែកអង្គភាពនោះឱ្យខុសប្លែកពីអង្គភាពដទៃៗទៀត។

បេសកកម្មបង្កើតមូលដ្ឋានមួយសម្រាប់បុគ្គលិកបំពេញការងារដែលឯកភាពគ្នា។ បេសកកម្មដែលមានសក្តានុពលនឹងធ្វើឱ្យអ្នកគ្រប់គ្រង និងអ្នកដឹកនាំសម្រេចចិត្តបានត្រឹមត្រូវ លើកទឹកចិត្តដល់នយោជិក បង្កើតឱ្យមានសាមគ្គីភាព និងរួមបញ្ចូលគ្នារវាងគោលដៅរយៈពេលខ្លី និងគោលដៅរយៈពេលវែង។ នៅក្នុងន័យដូចគ្នានេះដែរ **ទស្សនវិស័យ** របស់អង្គភាពជាចលករមួយជំរុញដល់បុគ្គលិក និងក៏ដូចជាអតិថិជន។ ទស្សនវិស័យ មួយបង្ហាញអំពីអ្វីដែលអង្គភាពចង់បាន និងអត្តសញ្ញាណអង្គភាពនាពេលអនាគត ដែលសម្រេចបានតាមរយៈជោគជ័យនៃបេសកកម្មរបស់អង្គភាព។ ទស្សនវិស័យរបស់អង្គភាពមួយត្រូវបានបង្ហាញនៅក្នុងសារប្រយោគទស្សនវិស័យ។

## បេសកកម្មដែលប្រកបដោយគុណភាពនឹងនាំមកនូវជម្រើសដ៏ប្រសើរ

ប្រសិនបើគ្មានបេសកកម្មដែលបានកំណត់ត្រឹមត្រូវ អង្គភាពមួយមិនដឹងថាត្រូវធ្វើអ្វីខ្លះនោះទេ។ អ្នកដឹកនាំមានជម្រើសជាច្រើន។ គុណភាពបេសកកម្ម និងទស្សនវិស័យ គឺសម្រាប់ដឹកនាំអង្គភាពនោះហាក់ដូចជាចង្កូតនាវារបស់អង្គភាពនោះដែរ។ ភាពច្បាស់លាស់នៃបេសកកម្មរបស់អង្គភាពជាគ្រឹះ និងរបៀបដែលអង្គភាពមួយមានលក្ខណៈខុសពីគូប្រជែង ដែលអាចជួយឱ្យគេងាយស្រួលចាប់យកជ្រើសរើសទាំងឡាយ និងឈានទៅរកភាពជោគជ័យ។

## បេសកកម្ម៖ ជាសេចក្តីប្រាថ្នាដ៏ខ្ពង់ខ្ពស់របស់អង្គភាព

ខណៈដែលអ្នកដឹកនាំមានការយល់ច្បាស់ពីបេសកកម្ម គេត្រូវធ្វើការផ្សារភ្ជាប់បេសកកម្មទៅនឹងទស្សនវិស័យដែលមានលក្ខណៈច្បាស់លាស់ និងអាចសម្រេចបាន។ ទស្សនវិស័យពន្យល់អំពីស្ថានភាពអនាគតដែលអង្គភាពមិនទាន់សម្រេចបាន ប៉ុន្តែវាអាចសម្រេចទៅបានដោយមានផែនការ និងយុទ្ធសាស្រ្តត្រឹមត្រូវ។ បុគ្គលិកក៏ដូចជាអតិថិជនអាចត្រូវបានលើកទឹកចិត្តតាមរយៈទស្សនវិស័យរបស់អង្គភាពដែលផ្តល់នូវការងាររបស់បុគ្គលិកប្រកបដោយការប្តេជ្ញាចិត្ត និងអតិថិជនប្រចាំរបស់អង្គភាព។

បេសកកម្ម និងទស្សនវិស័យ គឺជាក្បាលម៉ាស៊ីនសម្រាប់រាល់សកម្មភាពដែលកើតឡើងនៅក្នុងអង្គភាព។ គ្រប់យុទ្ធសាស្រ្ត ផែនការ គម្រោង គំនិតផ្តួចផ្តើម និងការងារទាំងអស់ត្រូវទាក់ទងទៅនឹងគោលបំណងរបស់អង្គភាព។ ជាក់ស្តែងក្នុងការអនុវត្តការងារ អ្នកគ្រប់គ្រង និងអ្នកដឹកនាំទាំងអស់ត្រូវជួយឱ្យអ្នករាល់គ្នាយល់ថាតើពួកគេគួរធ្វើការអ្វីខ្លះ និងដោយរបៀបណា ដើម្បីបញ្ជាក់ថាការងារផ្សារភ្ជាប់ទៅនឹងបេសកកម្ម និងទស្សនវិស័យ។ អ្នកគ្រប់គ្រង និងអ្នកដឹកនាំទាំងនោះក៏ត្រូវបង្កើតទស្សនវិស័យផ្ទាល់ខ្លួន ដោយបញ្ជាក់ឱ្យច្បាស់លាស់អំពីអ្វីដែលគេ និងក្រុមការងារត្រូវតែសម្រេចឱ្យបាន។

**ស្វ័យវាយតម្លៃ ២.២**

១- ខ្លឹមសារបេសកកម្មត្រូវបានបង្កើតឡើងដើម្បីគ្រាន់តែឱ្យបុគ្គលិកមានមោទនភាពចំពោះអង្គភាពតែប៉ុណ្ណោះ

☐ ពិត

☐ មិនពិត

២- ទស្សនវិស័យបង្ហាញអំពីអ្វីដែលអង្គភាពចង់ក្លាយទៅជាអ្វីមួយនៅពេលអនាគត

☐ ពិត

☐ មិនពិត

៣- ដើម្បីផ្លាស់ប្តូរអង្គភាពមួយ ផែនការត្រូវផ្សារភ្ជាប់រវាងបេសកកម្ម និងគោលបំណង ទៅនឹងគោលដៅ និងសកម្មភាព

☐ ពិត

☐ មិនពិត

**ចម្លើយគំរូ ២.២**

១- ខ្លឹមសារបេសកកម្មត្រូវបានបង្កើតឡើងដើម្បីគ្រាន់តែឱ្យបុគ្គលិកមានមោទនភាពចំពោះអង្គភាពតែប៉ុណ្ណោះ។

☐ ពិត

☑ **មិនពិត**

២- ទស្សនវិស័យបង្ហាញអំពីអ្វីដែលអង្គភាពចង់ក្លាយទៅជាអ្វីមួយនៅពេលអនាគត។

☑ **ពិត**

☐ មិនពិត

៣- ដើម្បីផ្លាស់ប្តូរអង្គភាពមួយ ផែនការត្រូវផ្សារភ្ជាប់រវាងបេសកកម្ម និងគោលបំណង ទៅនឹងគោលដៅ និងសកម្មភាព។

☑ **ពិត**

☐ មិនពិត

**សន្លឹកព័ត៌មាន ២.៣៖ តើអ្វីទៅជាយុទ្ធសាស្ត្រ ?**

**យុទ្ធសាស្ត្រ** គឺជាផែនការដែលរួមបញ្ចូលគ្រប់ផ្នែកទាំងអស់ ហើយបញ្ជាក់អំពីទិសដៅ វិធីសាស្ត្រ ផ្នែកដែលត្រូវផ្តោតការយកចិត្តទុកដាក់ខ្លាំង និងគោលដៅចម្បងៗ។

ការបង្កើតយុទ្ធសាស្ត្រមានន័យថា ការវាយតម្លៃលើភាពជាក់ស្តែង ការធ្វើការសន្មត ការមើលឃើញ ដែលចេញពីទស្សនទានជាច្រើន និងការបង្កើតជម្រើសផ្សេងៗ។ មានន័យថាគេត្រូវប្រថុយនឹងហានិភ័យ ព្រោះការសន្មតមានន័យស្មើនឹងការឃ្លាតចាកពីដែនកំណត់សុវត្ថិភាព។

**យុទ្ធសាស្ត្រភ្ជាប់ទំនាក់ទំនងរវាងបេសកកម្ម ទស្សនវិស័យ គោលដៅ និងសកម្មភាព**

យុទ្ធសាស្ត្រជួយឱ្យអង្គភាពមួយយល់ច្បាស់អំពីបេសកកម្មរបស់ខ្លួន និងធ្វើឱ្យទស្សនវិស័យក្លាយជាការពិត។ គ្រប់អង្គភាពទាំងអស់ មិនថាជាក្រុមបាល់ទាត់ប្រចាំសាលា សាជីវកម្មខ្នាតតូចដែលទើបនឹងបើកថ្មី ឬក្រុមហ៊ុនសាជីវកម្មធំៗនោះទេ សុទ្ធតែត្រូវការយុទ្ធសាស្ត្រ ដើម្បីជាមគ្គុទ្ទេសក៏ក្នុងការសម្រេចចិត្ត តម្រង់ឥរិយាបថ និងសកម្មភាពរបស់អង្គភាព។ នៅក្នុងផ្នែកនេះ យើងនឹងធ្វើការសិក្សាអំពីទស្សនទានសំខាន់ៗទាក់ទងទៅនឹងយុទ្ធសាស្ត្រ។

យុទ្ធសាស្ត្រភាគច្រើន មិនថាអាជីវកម្មតូចៗនោះទេ សុទ្ធសឹងមានលក្ខណៈស្មុគស្មាញ ហើយវាមានកម្រិតស្មុគស្មាញទ្វេដងសម្រាប់ក្រុមហ៊ុនធំៗ។

| សមាសភាគនៃយុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| ឧទាហរណ៍ | បេសកកម្ម | ទស្សនវិស័យ | គោលដៅយុទ្ធសាស្ត្ររយៈពេលវែង | គោលដៅ និងគោលដៅរងរយៈពេលខ្លី | តាកទិច និងសកម្មភាព |
| ការបើកហាងកាហ្វេ | ផ្តល់កាហ្វេដែលមានគុណភាពខ្ពស់បំផុតនៅក្នុងក្រុង និងទីកន្លែងប្រកបដោយបរិយាកាសរីករាយសម្រាប់អតិថិជនព្រមទាំងបុគ្គលិក | ក្លាយជាហាងកាហ្វេដែលពេញនិយមក្នុងក្រុងសម្រាប់ការនិយមញ៉ាំកាហ្វេ និងជួបជុំមិត្តភ័ក្តិ | ១- បើកសាខាពីរបន្ថែមទៀតក្នុងរយៈពេល ៣ ឆ្នាំ<br>២-ទិញយកអាគារ/ហាងដែលកំពុងជួលសព្វថ្ងៃ | ១- កំណត់ និងជ្រើសរើសអ្នកផ្គត់ផ្គង់ដែលល្អ<br>២- ផ្តល់វគ្គបំប៉នដល់បុគ្គលិកផ្នែកកាហ្វេ<br>៣- ផ្តល់វគ្គបំប៉នលើសេវាបម្រើអតិថិជនដល់បុគ្គលិក | ១- ផ្តល់ការភ្លក់រសជាតិនៅតាមពិធីពិពណ៌តាមដងផ្លូវផ្សេងៗ<br>២- សាកល្បង និងទិញគ្រឿងសង្ហារឹមដែលប្រកបដោយផាសុកភាព |

**ស្វ័យវាយតម្លៃ ២.៣**

១- ការបង្កើតយុទ្ធសាស្ត្រជាការបង្កើតផែនការទោលសម្រាប់អនាគត និងការធ្វើការតាមដានលើផែនការនោះ។

☐ ពិត

☐ មិនពិត

២- ចូរជ្រើសរើសចម្លើយខាងក្រោម៖ តើចំណុចណាខ្លះជាប្រភេទនៃយុទ្ធសាស្ត្រ?

☐ សហប្រតិបត្តិការ

☐ មុខងារ

☐ កំណើន

☐ គ្រឹះស្ថាន

៣- ផែនការយុទ្ធសាស្ត្រគឺជាដំណើរការត្រួតពិនិត្យតែទៅលើបរិយាកាសខាងក្រៅអង្គភាពប៉ុណ្ណោះ។

☐ ពិត

☐ មិនពិត

**ចម្លើយគំរូ ២.៣**

ចម្លើយគន្លឹះ

១- ការបង្កើតយុទ្ធសាស្ត្រគាំជាការបង្កើតផែនការទោលសម្រាប់អនាគត និងការធ្វើការតាមដានលើផែនការនោះ។

☑ **ពិត**

☐ មិនពិត

២. ចូរជ្រើសរើសចម្លើយខាងក្រោម៖ តើចំណុចណាខ្លះជាប្រភេទនៃយុទ្ធសាស្ត្រ? (**ចម្លើយទាំងអស់**)

☑ **សហប្រតិបត្តិការ**

☑ **មុខងារ**

☑ **កំណើន**

☑ **គ្រឹះស្ថាន**

៣- ផែនការយុទ្ធសាស្ត្រគឺជាដំណើរការត្រួតពិនិត្យតែទៅលើបរិយាកាសខាងក្រៅអង្គភាពប៉ុណ្ណោះ។

☐ ពិត

☑ **មិនពិត**

### សន្លឹកព័ត៌មាន ២.៤៖ ប្រភេទយុទ្ធសាស្ត្រ

មធ្យោបាយមួយដែលអ្នកគ្រប់គ្រង និងអ្នកដឹកនាំអនុវត្តផែនការយុទ្ធសាស្ត្រដែលមានលក្ខណៈស្មុគស្មាញនៅក្នុងអង្គភាពធំៗ គឺ**ការធ្វើចំណាត់ថ្នាក់ប្រភេទយុទ្ធសាស្ត្រ**។ ហើយមធ្យោបាយមួយសម្រាប់ចាត់ថ្នាក់យុទ្ធសាស្ត្រទាំងនោះគឺ បកស្រាយយុទ្ធសាស្ត្រទាំងនោះទៅតាមផ្នែករបស់អង្គភាព ដែលគេគាំទ្រ។ យុទ្ធសាស្ត្រសាជីវកម្មត្រូវបង្កើតឡើងដើម្បីអនុវត្តនៅក្នុងអង្គភាពទាំងមូល។ យុទ្ធសាស្ត្រពាណិជ្ជកម្មត្រូវបង្កើតឡើងសម្រាប់អនុវត្តផ្នែក ឬតាមសង្វាក់ផលិតកម្មណាមួយ។ យុទ្ធសាស្ត្រមុខងារប្រើប្រាស់នៅក្នុងផ្នែកសំខាន់ៗនៃអង្គភាពដូចជា ផ្នែកធនធានមនុស្ស ហិរញ្ញវត្ថុ និងទីផ្សារជាដើម។ នៅក្នុងប្រភេទនៃយុទ្ធសាស្ត្រធំៗ ក៏មានយុទ្ធសាស្ត្រតូចៗជាច្រើនប្រភេទទៀត ដែលជួយឱ្យគេសម្រេចគោលដៅរបស់អង្គភាព។

### យុទ្ធសាស្ត្រសាជីវកម្ម

ក្រុមហ៊ុនមួយអាចមានជម្រើសយុទ្ធសាស្ត្រជាច្រើនក្នុងកម្រិតសាជីវកម្ម។ **ឧទាហរណ៍៖** ក្រុមហ៊ុនអាចសម្រេចចិត្តអនុវត្តតាម«**យុទ្ធសាស្ត្រកំណើន**» ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការ និងបន្ថែមភាគហ៊ុនក្នុងទីផ្សារ។ យុទ្ធសាស្ត្រកំណើនអាចរួមបញ្ចូលនូវផែនការសម្រាប់គម្រោងមួយចំនួនដូចជា ទីផ្សារកែលម្អ និងបង្កើតថ្មី ការប្រមូលដើមទុនដើម្បីពង្រីកខ្លួនលើដែនថ្មី ឬផែនការកែលម្អផលិតភាព។

លើសពីនេះ មានមធ្យោបាយជាច្រើនដែលក្រុមហ៊ុនអាចអនុវត្តយុទ្ធសាស្ត្រកំណើន។ មធ្យោបាយមួយទៀតគឺ ប្រើប្រាស់វិធីសាស្ត្រទិញ ដែលសំដៅលើការទិញផ្នែកខ្លះ ការរួមបញ្ចូលគ្នា ឬការទិញយកទាំងស្រុងនូវក្រុមហ៊ុនមួយផ្សេងទៀត។ យុទ្ធសាស្ត្រនេះអាចអនុវត្តសម្រាប់ការទិញក្រុមហ៊ុនដែលមានមុខជំនួញដូចគ្នា ឬក្រុមហ៊ុនផ្សេងទៀត។ យុទ្ធសាស្ត្រនេះក៏អាចតម្រូវឱ្យទិញក្រុមហ៊ុនផ្សេងៗ ទាំងមូលផងដែរ។

យុទ្ធសាស្ត្រសហព័ន្ធ ឬយើងអាចហៅម៉្យាងទៀតថា **កិច្ចសន្យាប្រតិបត្តិការ** (ការចូលហ៊ុន) ជាវិធីសាស្ត្រមួយផ្សេងទៀតសម្រាប់ក្រុមហ៊ុនអនុវត្តយុទ្ធសាស្ត្រកំណើន។ កិច្ចសន្យាប្រតិបត្តិការ គឺជាកិច្ចព្រមព្រៀងផ្លូវការរវាងភាគីពីរ ឬច្រើន ដើម្បីអនុវត្តសកម្មភាពពាណិជ្ជកម្មជាមួយគ្នា និងការបែងចែកហានិភ័យជាមួយគ្នា។

ជម្រើសមួយដើម្បីរក្សាលំនឹង អាចហៅថា «**យុទ្ធសាស្ត្ររក្សាស្ថេរភាព**»។ យុទ្ធសាស្ត្រនេះមានបំណងរក្សាទីតាំងបច្ចុប្បន្នរបស់ក្រុមហ៊ុន។ អាស្រ័យដោយវិបត្តិសេដ្ឋកិច្ច ចលាចលក្នុងសង្គម ឬការវិវត្តនៃបច្ចេកវិទ្យា អ្នកគ្រប់គ្រងអាចជ្រើសយកយុទ្ធសាស្ត្រនេះ ដែលជាវិធីសាស្ត្រដ៏ល្អសម្រាប់រក្សាស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុន។ នេះមិនមែនជាយុទ្ធសាស្ត្រដែលក្រុមហ៊ុនមិនមានសកម្មភាពអ្វីនោះទេ។ តាមពិតក្នុងពេលមានវិបត្តិ ឬពេលលំបាក ក្រុមហ៊ុនអាចរកវិធានការណ៍មួយ ដើម្បីធានាស្ថេរភាព ដូចជា ការធ្វើកំណែទម្រង់ បញ្ចប់ផែនការ ឬបញ្ឈប់សកម្មភាពជាបណ្ដោះអាសន្ន ដើម្បីរក្សាស្ថានភាពបច្ចុប្បន្នក្នុងទីផ្សារ។

យុទ្ធសាស្ត្រទី៣ នៅក្នុងយុទ្ធសាស្ត្រសាជីវកម្មគឺ យុទ្ធសាស្ត្រ «**កាត់បន្ថយចំណាយ**»។ យុទ្ធសាស្ត្រប្រភេទនេះ ត្រូវបានយកមកអនុវត្ត នៅពេលដែលក្រុមហ៊ុនត្រូវការរៀបចំឡើងវិញ និងការពារខ្លួនឯង ខណៈដែលក្រុមហ៊ុនពង្រឹងខ្លួនឡើងវិញ។

វិធីសាស្ត្រចុងក្រោយគឺ «**យុទ្ធសាស្ត្រដកទុន**»។ យុទ្ធសាស្ត្រនេះទាក់ទងទៅនឹងការលក់ចោល ឬបោះបង់ចោលនូវពាណិជ្ជកម្មមួយផ្នែក ឬខ្សែសង្វាក់សេវាកម្មណាមួយរបស់ក្រុមហ៊ុន ដើម្បីឱ្យក្រុមហ៊ុនអាចផ្តោតពេញលេញទៅលើពាណិជ្ជកម្មស្នូលរបស់ខ្លួន។

| យុទ្ធសាស្ត្រសាជីវកម្ម | |
|---|---|
| **យុទ្ធសាស្ត្រសាជីវកម្ម** | **ផ្ដោតទៅលើ** |
| **កំណើន** | ការពង្រីកខ្លួនទៅក្នុងទីផ្សារថ្មី ឬការបង្កើនតម្លៃហ៊ុនក្នុងទីផ្សារ ។ អាចសម្រេចទៅបាន តាមរយៈការពង្រីកជំនួញ ការទិញ ឬរួមបញ្ចូលជាមួយក្រុមហ៊ុនដទៃ និងចូលហ៊ុនគ្នា។ |
| **ស្ថេរភាព** | ការរក្សាទីតាំងរបស់ក្រុមហ៊ុនឱ្យនៅដដែលនៅក្នុងទីផ្សារ។ |
| **កាត់បន្ថយចំណាយ** | ឥរិយាបថការពារសម្រាប់ទប់ទល់នឹងការគំរាមកំហែងផ្សេងៗខណៈពេលដែលក្រុមហ៊ុនកំពុងពង្រឹងខ្លួន។ |
| **ដកទុន** | លក់ចោល ឬលុបចោលនូវផ្នែកនៃជំនួញណាមួយ។ |

**យុទ្ធសាស្ត្រពាណិជ្ជកម្ម**

នៅក្នុងកម្រិតពាណិជ្ជកម្ម ក្រុមហ៊ុនផ្សេងៗបានសម្រេចចិត្តយ៉ាងឆ្លាតវៃជ្រើសរើសយកនូវយុទ្ធសាស្ត្រណាដែលអាចជួយទប់លំនឹងពាណិជ្ជកម្ម និងជោគជ័យក្នុងការចាប់យកទីផ្សារ។

យុទ្ធសាស្ត្រទីមួយគឺ «**យុទ្ធសាស្ត្របង្កើតភាពខុសប្លែកគេ**» ដែលយុទ្ធសាស្ត្រនេះសំដៅលើការផ្ដល់នូវផលិតផល ឬសេវាកម្ម ដែលអតិថិជនយល់ឃើញថាជាផលិតផល ឬសេវាកម្មដែលមានលក្ខណៈខុសប្លែកពីគេ។ **សមត្ថភាពស្នូល** គឺជាសកម្មភាពមួយដែលអង្គភាពអនុវត្តបានយ៉ាងប្រសើរ។ ជំនាញ និងចំណេះដឹងជាអ្វីដែលអតិថិជនបានកំណត់សម្គាល់ក្រុមហ៊ុនរួចមកហើយ និងក៏ជាចំណុចដែលធ្វើឱ្យក្រុមហ៊ុនមានប្រៀបលើគូប្រកួតប្រជែង។

យុទ្ធសាស្ត្របន្ទាប់គឺ «**យុទ្ធសាស្ត្រនាំមុខតម្លៃ**»។ យុទ្ធសាស្ត្រនេះពាក់ព័ន្ធនឹងការដាក់តម្លៃទាបបំផុតលើផលិតផល ចង្វាក់ផលិតកម្ម ឬសេវាកម្ម។ **យុទ្ធសាស្ត្រនិច** សំដៅដល់ការចែកចំណែកតូចៗនៃទីផ្សារ។

ចុងក្រោយគឺ «**យុទ្ធសាស្ត្រសមាហរណកម្មតាមខ្សែបញ្ឈរ**» ដែលអភិវឌ្ឍន៍ជំនួញតាមខ្សែចង្វាក់ផ្គត់ផ្គង់។ ខ្សែចង្វាក់ផ្គត់ផ្គង់រួមមាន ប្រភពធនធាន ផលិតផល សេវាកម្ម និងប្រតិបត្តិការទាំងឡាយដែលចូលរួមក្នុងការផលិត និងលក់នូវផលិតផល ឬសេវាកម្ម។

| យុទ្ធសាស្ត្រពាណិជ្ជកម្មតាមកម្រិត | |
|---|---|
| **យុទ្ធសាស្ត្រពាណិជ្ជកម្ម** | **ផ្ដោតទៅលើ** |
| **បង្កើតភាពខុសប្លែកគេ** | ការផ្ដល់នូវផលិតផល ឬសេវាកម្មដែលមានលក្ខណៈខុសប្លែកពីផលិតផលដទៃ។ |
| **នាំមុខតម្លៃ** | ការដាក់កម្រិតថ្លៃប្រកួតប្រជែង (ថ្លៃទាបបំផុត)។ |
| **តិចនិច** | ការសំដៅទៅលើចំណែកទីផ្សាមួយពិសេស ឬតម្រូវការពិសេសណាមួយ។ |
| **ការរួមបញ្ចូលតាមខ្សែបញ្ឈរ** | ការស្វែងរកប្រសិទ្ធភាព និងការសន្សំសំចៃថ្លៃដើមតាមរយៈប្រតិបត្តិការជំនួញ ដោយការជ្រើសរើសបណ្ដាញផ្គត់ផ្គង់ល្អ(ផ្ដល់តម្លៃទាប)។ |

**យុទ្ធសាស្ត្រមុខងារ**

**ឧទាហរណ៍៖ មុខងារ** រួមមាន ផ្នែកធនធានមនុស្ស ផ្នែកហិរញ្ញវត្ថុ ផ្នែកទីផ្សារ ផ្នែកផលិតកម្ម ផ្នែកសុខភាព និងសុវត្ថិភាពការងារជាដើម។ ក្រុមហ៊ុនធំៗជាច្រើនមានផ្នែកនានាសម្រាប់មុខងារទាំងនេះ។ នៅក្នុងក្រុមហ៊ុនតូច សេវាកម្មភាគច្រើនធ្វើឡើងតាមការចាត់តាំងបុគ្គល ឬផ្តល់តាមរយៈការប្រឹក្សា ឬក្រុមហ៊ុនឯកទេស។

**យុទ្ធសាស្ត្រមុខងារ ៖** ជាយុទ្ធសាស្ត្រតាមផ្នែក ដែលអភិវឌ្ឍន៍សម្រាប់ជួយឱ្យអង្គភាពសម្រេចបាននូវគោលដៅដែលបានកំណត់ទុក។

ចំណុចគន្លឹះ៖

- ផែនការភាគច្រើននៅក្នុងអង្គភាពមានលក្ខណៈស្មុគស្មាញ ដោយសម្របតាមផែនការផ្សេងៗ ដែលមិនបាច់អនុវត្តតាមខ្សែបណ្តោយ។ ផែនការមិនមានភាពនឹងនរទេ អាចប្រែប្រួលបាន។
- សមត្ថភាពសម្របតាមការផ្លាស់ប្តូរទាន់ពេលវេលាបានកំណត់ដាច់ពីគ្នា សម្រប់បុគ្គលិក អ្នកគ្រប់គ្រង និងអ្នកដឹកនាំ។ ដូច្នេះ ទោះបីជាផែនការ គោលដៅ និងគោលដៅរងជាមគ្គុទ្ទេសក៏សំខាន់ក៏ដោយ ក៏យើងត្រូវចងចាំជានិច្ចថា ផែនការអាចប្រែប្រួលបានគ្រប់ពេលវេលា។
- បេសកកម្មរបស់អង្គភាពមួយបង្ហាញយ៉ាងច្បាស់នូវគោលបំណងជាមូលដ្ឋាន
- ខណៈដែលអ្នកដឹកនាំទាំងអស់យល់ច្បាស់អំពីបេសកកម្មរបស់អង្គភាព គេត្រូវផ្សារភ្ជាប់បេសកកម្មទៅនឹង ទស្សនវិស័យដែលច្បាស់លាស់ និងអាចសម្រេចបាន។
- យុទ្ធសាស្ត្រជាជំនួយដល់អង្គភាពឱ្យកំណត់បាននូវបេសកកម្មរបស់ខ្លួន ព្រមទាំងធ្វើឱ្យទស្សនវិស័យមានសភាពរស់រវើក មិនថាអង្គភាពនោះជាអង្គភាពតូច ឬធំលំដាប់ណាក៏ដោយ។ គ្រប់អង្គភាពទាំងអស់សុទ្ធតែត្រូវការយុទ្ធសាស្ត្រដើម្បីដឹកនាំគេទៅដល់ការសម្រេចចិត្ត ឥរិយាបថដឹកនាំ និងការរៀបចំសកម្មភាពផ្សេងៗ។

## ស្វ័យវាយតម្លៃ ២.៤

១- យុទ្ធសាស្ត្រសហប្រតិបត្តិការត្រូវបានបង្កើតឡើងដើម្បី៖

- ☐ អង្គភាពទាំងមូល
- ☐ គ្រប់ក្រុមហ៊ុននៅក្នុងទីក្រុងភ្នំពេញ
- ☐ អ្នកគ្រប់គ្រងទាំងអស់
- ☐ អ្នកដឹកនាំ

២- វិធីសាស្ត្រម៉្យាងក្នុងការអនុវត្តយុទ្ធសាស្ត្រកំណើនគឺតាមរយៈ៖

- ☐ យុទ្ធសាស្ត្រទិញ
- ☐ កិច្ចសន្យាប្រតិបត្តិការ
- ☐ យុទ្ធសាស្ត្រស្ថេរភាព
- ☐ អ្នកគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន

៣- យុទ្ធសាស្ត្រដកទុន គឺជាយុទ្ធសាស្ត្រម៉្យាងដែលអ្នក៖

- ☐ លក់អង្គភាពសាជីវកម្ម
- ☐ លក់នូវផ្នែកណាមួយ ឬខ្សែសេវាណាមួយ
- ☐ បណ្តេញបុគ្គលិកចេញ
- ☐ ពង្រឹងពាណិជ្ជកម្មរបស់អ្នក

៤- អ្វីដែលអង្គភាពមួយធ្វើបានប្រសើរគឺ៖

- ☐ សមត្ថភាពស្នូល
- ☐ ភាពខុសដាច់ពីគេ
- ☐ កម្រិតពាណិជ្ជកម្មរបស់វា
- ☐ វិធីសាស្ត្រនិច

**ចម្លើយគំរូ ២.៤**

ចម្លើយគន្លឹះ

១- យុទ្ធសាស្ត្រសហប្រតិបត្តិការត្រូវបានបង្កើតឡើងដើម្បី

☑ **អង្គភាពទាំងមូល**

☐ គ្រប់ក្រុមហ៊ុននៅក្នុងទីក្រុងភ្នំពេញ

☐ អ្នកគ្រប់គ្រងទាំងអស់

☐ អ្នកដឹកនាំ

២- វិធីសាស្ត្រម៉្យាងក្នុងការអនុវត្តយុទ្ធសាស្ត្រកំណើនគឺតាមរយៈ

☑ **យុទ្ធសាស្ត្រទិញ**

☐ កិច្ចសន្យាប្រតិបត្តិការ

☐ យុទ្ធសាស្ត្រស្ថេរភាព

☐ អ្នកគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន

៣- យុទ្ធសាស្ត្រដកទុន គឺជាយុទ្ធសាស្ត្រម៉្យាងដែលអ្នក

☐ លក់អង្គភាពសាជីវកម្ម

☑ **លក់នូវផ្នែកណាមួយ ឬខ្សែសេវាណាមួយ**

☐ បណ្តេញបុគ្គលិកចេញ

☐ ពង្រឹងពាណិជ្ជកម្មរបស់អ្នក

៤- អ្វីដែលអង្គភាពមួយធ្វើបានប្រសើរគឺ

☑ **សមត្ថភាពស្នូល**

☐ ភាពខុសដាច់ពីគេ

☐ កម្រិតពាណិជ្ជកម្មរបស់វា

☐ វិធីសាស្ត្រនិច

## សន្លឹកព័ត៌មាន ២.៥៖ គំនិតផ្តួចផ្តើម និង ការកំណត់ទិសដៅខ្លួនឯង

### ទិដ្ឋភាពទូទៅ

នៅក្នុងជីវិតផ្ទាល់ខ្លួន និងជីវិតការងាររបស់អ្នក អ្នកប្រហែលជាធ្លាប់ឮគេនិយាយពីបុគ្គលខ្លះ ដែលជាមនុស្ស **"ស្វាហាប់"** ឬក៏ **"នាំមុខ"**។ ពាក្យនេះត្រូវបានប្រើប្រាស់ទៅលើមនុស្ស ដែលមានឆន្ទៈក្នុងការបញ្ចេញសកម្មភាពមុនពេលគេបង្គាប់គាត់ឱ្យធ្វើការ។ មនុស្សដែលនាំមុខអាចជំរុញឱ្យអ្នកដទៃចង់ធ្វើតាមរយៈចំណង់ និងគំនិតច្នៃប្រឌិតរបស់គេ។ នៅកន្លែងធ្វើការ មនុស្សប្រភេទនេះត្រូវបានគេចាត់ទុកថា ជាមនុស្សដែលមានគំនិតផ្តួចផ្តើម។ ផ្នែកមួយនៃការបង្ហាញពីគំនិតផ្តួចផ្តើម គឺថាមនុស្សនោះចេះកំណត់ទិសដៅខ្លួនឯង ដែលមានន័យថាជាមនុស្សត្រូវការបំពេញការងារបានដោយត្រូវការជំនួយតិចតួច ឬមិនចាំបាច់មានជំនួយ។




មនុស្សម្នាក់អាចបង្ហាញពីគំនិតផ្តួចផ្តើម និងមានទិសដៅខ្លួនឯងនៅនឹងកន្លែងការងារ ដោយកំណត់គោលដៅអាជីព ការគ្រប់គ្រងពេលវេលាបានល្អតាមជំនាញ និងចេះរៀបចំការងារឱ្យមានប្រសិទ្ធភាព។ វាមានលក្ខណៈសំខាន់ខ្លាំងណាស់ក្នុងការក្រេបជញ្ជក់យកជំនាញទាំងនេះ ដោយការស្វែងយល់ពីបច្ចេកទេស និងលក្ខណៈនៃការច្នៃប្រឌិត និងការដឹកនាំខ្លួនឯង។

មនុស្សមួយចំនួនមានទំនោរពីធម្មជាតិក្នុងការព្រមទទួលយកការងារយ៉ាងឆាប់ ដោយពុំចាំបាច់គេប្រាប់ច្រើនដង ខណៈពេលដែលមនុស្សមួយចំនួនផ្សេងទៀតត្រូវការគេប្រាប់ពីរដង ឬច្រើនដង។ ទោះបីជាអ្នកមានការពិបាកស្ទើរគ្រប់ពេលវេលាដើម្បីបង្ហាញពីគំនិតផ្តួចផ្តើម វានូវតែអាចធ្វើបានដោយអ្នកអាចរៀនពីរបៀបសម្តែងចេញនូវគំនិតផ្តួចផ្តើមឱ្យបានកាន់តែច្រើននៅក្នុងការបំពេញការងាររបស់អ្នក។

***ការមានទិសដៅខ្លួនឯង*** គឺមានលក្ខណៈដូចគ្នានឹងការមានឯករាជ្យភាពផ្ទាល់ខ្លួន។ មនុស្សដែលមានទិសដៅខ្លួនឯង មានការនាំមុខលើគ្រប់ស្ថានភាព និងបំពេញការងារបានសម្រេចជានិច្ច។ ក្នុងកន្លែងធ្វើការ បុគ្គលិកមានទិសដៅខ្លួនឯងត្រូវបានសមាជិកក្នុងក្រុមផ្សេងទៀតឱ្យតម្លៃខ្ពស់ ពីព្រោះគេបានបង្ហាញនូវគំនិតផ្តួចផ្តើមនិងបំពេញការងារបានជោគជ័យ។ ការរៀនអំពីអ្វីដែលជាចលករធ្វើឱ្យមនុស្សម្នាក់មានទិសដៅខ្លួនឯង អាចជួយឱ្យមនុស្សម្នាក់កសាងភាពខ្លាំងរបស់ខ្លួន ដើម្បីបង្កើនឥរិយាបថដែលកំណត់ទិសដៅខ្លួនឯង។

## *តើគំនិតផ្តួចផ្តើមគឺជាអ្វី?*

**ឧទាហរណ៍ទី១**



លោក Joe បានដើរកាត់បន្ទប់សម្រាក ហើយបានឃើញទឹកដែលមាននូវលើម៉ាស៊ីនទឹកត្រជាក់អស់។ គាត់បានយកដបទឹកថ្មីមកប្តូរជំនួសដបទឹកដែលអស់វិញ។

**ឧទាហរណ៍ទី២**



Sharon បានដើរកាត់បន្ទប់រង់ចាំខាងមុខ ហើយឃើញថាអ្នកទទួលភ្ញៀវដែលមានការណាត់ញ៉ាំអាហារថ្ងៃត្រង់ជាមួយវេជ្ជបណ្ឌិត មិនទាន់ត្រឡប់មកដល់កន្លែងធ្វើការវិញ។ នាងបានរៀនពីការទទួលទូរស័ព្ទ ដូច្នេះហើយនាងក៏អង្គុយនៅការិយាល័យខាងមុខនោះ និងឆ្លើយទូរស័ព្ទជំនួសរហូតដល់អ្នកទទួលភ្ញៀវនោះត្រឡប់មកវិញ។

**ឧទាហរណ៍ទី៣**




នៅពេលជិតចប់វេន Mike បានពិនិត្យឃើញថា កុងទ័រប្រេងរបស់ ម៉ាស៊ីនលើកវ៉ាន់ ដែលគាត់ប្រើបានបង្ហាញថាជិតអស់ប្រេង គាត់ក៏ យកម៉ាស៊ីននោះទៅចាក់ប្រេងបំពេញមុនពេលគាត់ចាកចេញ។

## *របៀបអភិវឌ្ឍន៍គំនិតផ្តួចផ្តើម*

តារាងខាងក្រោមបង្ហាញពីបុគ្គលិកលក្ខណៈរបស់បុគ្គលិកមួយចំនួន ដែលមានគំនិតផ្តួចផ្តើមនៅកន្លែងធ្វើការ។ ការអភិវឌ្ឍគំនិតផ្តួចផ្តើមមិនពិបាកទេ ឱ្យតែមនុស្សម្នាក់មានឆន្ទៈឈប់បណ្តែតបណ្តោយ ហើយតាំងចិត្តស្វែងយល់ និងចង់ដឹងបន្ថែម ថាតើក្រុមហ៊ុន ឬអង្គភាពកំពុងធ្វើអ្វី ហើយមានអ្វីដែលយើងអាចជួយបាន។

| មានគំនិតផ្តួចផ្តើម | កង្វះគំនិតផ្តួចផ្តើម | អភិវឌ្ឍន៍គំនិតផ្តួចផ្តើមបន្ថែម |
|---|---|---|
| **សួរសំណួរ** | មិនសួរសំណួរ | បើសិនជាអ្នកមិនយល់ពីដំណើរការ ឬនិតិវិធីណាមួយ ចូរសួរសំណួរ។ ត្រូវស្វែងយល់ថា តើហេតុអ្វីក៏មានរបៀបធ្វើការ តាមរបៀបកំណត់ណាមួយ។ ត្រូវប្រុងប្រយ័ត្នកុំសួរសំណួរណាដែលអាចធ្វើឱ្យអ្នកដទៃខឹង និងប៉ះពាល់ដល់អារម្មណ៍របស់គេ។ **ឧទាហរណ៍៖** «រឿងនេះគួរ |

| | | |
|---|---|---|
| | | ឱ្យចាប់អារម្មណ៍ ។ ប្រសិនបើខ្ញុំចង់ធ្វើដែរ តើមានផលប៉ះពាល់អ្វីដល់ផ្នែកដទៃដែរ ឬទេ ?» |
| **តាមដានរាល់ការអភិវឌ្ឍន៍នានា ដែលជះឥទ្ធិពលដល់អង្គភាព** | មានចំណាប់អារម្មណ៍តិចតួច អំពីការអភិវឌ្ឍនានាដែលជះឥទ្ធិពលដល់អង្គភាព | ចូរអានព័ត៌មានទាំងអស់ដែលពាក់ព័ន្ធនឹងក្រុមហ៊ុន ឬអង្គភាព។ ព័ត៌មានទាំងអស់នោះមាន ខិតប័ណ្ណសម្រាប់អតិថិជន របាយការណ៍ផ្ទៃក្នុង និងសេចក្តីជូនដំណឹងផ្សេងៗ ព្រមទាំងឯកសារដទៃទៀតដែលពាក់ព័ន្ធទាំងអស់។ ពេលនោះអ្នកនឹងដឹងថាតើក្រុមហ៊ុន ឬអង្គភាពត្រូវការអ្វី និងមិនទាន់ធ្វើអ្វីបានសម្រេច។ |
| **បង្ហាញចំណាប់អារម្មណ៍ ដល់អ្នកដទៃ និងអ្នកដែល មានតួនាទីផ្សេងៗក្នុងកន្លែងធ្វើការ** | មានទំនាក់ទំនងតែជាមួយបុគ្គលិកក្នុងផ្នែករបស់ខ្លួន | សន្ទនាជាមួយអ្នកគ្រប់គ្រងអាចឱ្យអ្នកដឹងអំពីទិដ្ឋភាព ពីបញ្ហាដែលអ្នកគ្រប់គ្រងកំពុងដោះស្រាយជាប្រចាំ។ ដូចគ្នានេះដែរ រឿងនេះអាចកើតមានឡើងចំពោះបុគ្គលិកគ្រប់លំដាប់ថ្នាក់ |
| **ទទួលយកការងារថ្មីដោយពុំចាំបាច់បង្គាប់** | ផ្តោតការយកចិត្តទុកដាក់តែលើការងារដែលគេបង្គាប់ | ជួនកាលកិច្ចការថ្មីមិនត្រូវបានគេដាក់ឱ្យដល់ស្ថាប័នអ្នកទេ អាស្រ័យ លើគោលនយោបាយរបស់ស្ថាប័ននីមួយៗ។ ចូរអង្កេតស្ថានភាពផ្សេងៗ ដោយប្រុងប្រយ័ត្ន ហើយពិគ្រោះជាមួយប្រធានរបស់អ្នក មុនពេលយកបញ្ហាណាមួយមកដាក់ក្នុងស្ថាប័នអ្នក។ |

## *ការបង្កើនភាពដឹកនាំខ្លួនឯង*

នៅពេលដែលអ្នកដឹងពីគុណភាពការងាររបស់មនុស្សម្នាក់ដែលបង្ហាញនៅកន្លែងការងារ ហើយគេជាមនុស្សដែលដឹកនាំខ្លួនឯងនោះ គឺងាយស្រួលកំណត់គុណភាពជាងមនុស្សទាំងឡាយដែលមិនមានទិសដៅខ្លួនឯង។ មានជំនាញមូលដ្ឋានសំខាន់ៗមួយចំនួនដែលអ្នកអាចអភិវឌ្ឍន៍ ដើម្បីក្លាយខ្លួនឱ្យទៅជាមនុស្សដែលមានទិសដៅខ្លួនឯង។

## *គុណភាពរបស់បុគ្គលដែលមានទិសដៅខ្លួនឯង*

| **មនុស្សមានទិសដៅខ្លួនឯង** | **មនុស្សគ្មានទិសដៅខ្លួនឯង** |
|---|---|
| ប្រាកដប្រជា សកម្ម | អសកម្ម |
| យកចិត្តទុកដាក់ មេត្តាករុណា | ខ្ជិលច្រអូស ស្ពឹក |
| ងាយណែនាំ និងឆាប់យល់ | សួរដដែលៗពីការណែនាំ និងរបៀបធ្វើការងារ |
| ត្រូវការការណែនាំតិចតួច ឬក៏មិនត្រូវការការណែនាំក្នុងការបំពេញការងារ | ត្រូវការជំនួយយ៉ាងច្រើនក្នុងការបំពេញការងារ |
| គ្រប់គ្រងពេលវេលាបានល្អ | គ្រប់ពេលវេលាមិនបានល្អ |
| មានរបៀបរៀបរយរក្សាកន្លែងធ្វើការឱ្យមានសណ្តាប់ធ្នាប់ និងស្អាត | គ្មានរបៀបរៀបរយកន្លែងការងារ មានភាពរប៉ាត់រប៉ាយ |

## *ការបង្កើនភាពមានទិសដៅខ្លួនឯង*

| | |
|---|---|
| ស្តាប់ | ស្តាប់ដោយយកចិត្តទុកដាក់ពេលនរណាម្នាក់និយាយ និងមិននិយាយកាត់ ទាំងនេះបង្ហាញថាអ្នកមានចំណាប់អារម្មណ៍ចំពោះអ្នកនិយាយនោះ។ |
| យល់ | អាចរៀបរាប់ឡើងវិញនូវអ្វីដែលគេបាននិយាយ បង្ហាញថាអ្នកយល់ពីអ្វីដែលគេបានប្រាប់។ |
| ការរៀបចំ | ការរៀបចំពេលវេលា និងកន្លែងការងារបង្ហាញថា អ្នកជាមនុស្សមានសណ្តាប់ធ្នាប់ និងមានប្រសិទ្ធភាពក្នុងការងារ។ |

**ស្វ័យវាយតម្លៃ ២.៥**

**ចូរផ្តល់ចម្លើយនូវសំណួរខាងក្រោមៈ**

១- តើគំនិតផ្តួចផ្តើម គឺជាអ្វី?

ក- គោលដៅដែលអ្នកប្រាថ្នាថាសម្រេចឱ្យបាន។

ខ- ឱកាសទទួលយកការងារមុនអ្នកដទៃ។

គ- ការកំណត់បានពីរបៀបធ្វើការឱ្យបានល្អប្រសើរជាងមុន។

ឃ- បង្ហាញថាអ្នកយកចិត្តទុកដាក់ពីក្រុមហ៊ុនដែលកំពុងតែដំណើរការល្អ។

២- តើផលចំណេញបានពីការមានគំនិតផ្តួចផ្តើមនៅកន្លែងធ្វើការមានអ្វីខ្លះ?

ក- ធ្វើឱ្យអ្នកក្លាយជាបេក្ខភាពដែលមានគុណសម្បត្តិប្រសើរក្នុងការដំឡើងតំណែង និងប្រាក់កម្រៃ។

ខ- មិនត្រូវការជំនួយច្រើនក្នុងការបំពេញការងារ។

គ- កំណត់ថាតើរង្វាន់ជំរុញទឹកចិត្តពីខាងក្នុង និងពីខាងក្រៅជាអ្វី។

៣- ការសម្រេចបាននូវគោលដៅអាជីពទាមទារនូវគំនិតផ្តួចផ្តើមជាច្រើន។ តើលក្ខណៈដូចខាងក្រោមមួយណាដែលមនុស្សមានគំនិតផ្តួចផ្តើមគួរមាន? ចូរគូសគ្រប់ចំណុចដែលមាន។

ក- គ្រប់គ្រងពេលវេលាបានល្អ។

ខ- សួរសំណួរឱ្យបានច្រើន។

គ- ជាធម្មតាចង់ធ្វើការម្នាក់ឯង។

ឃ- យកចិត្តទុកដាក់ និងមានក្តីអាណិតអាសូរ។

៤- មនុស្សដែលមានទិសដៅខ្លួនឯង ធ្វើការដោយខ្លួនឯង ដើម្បីដឹកនាំស្ថានភាពរបស់ខ្លួន និងធ្វើកិច្ចការឱ្យបានសម្រេច។

ក- ពិត

ខ- មិនពិត

៥- តើជំនាញអ្វីដែលអ្នកអាចសិក្សាដើម្បីប្រែក្លាយខ្លួនឱ្យទៅជាមនុស្សកាន់តែមានទិសដៅខ្លួនឯង?

ក- ការយល់ការណ៍ ការរៀបចំ ការច្នៃប្រឌិត។

ខ- ការស្តាប់សកម្ម ការយល់ការណ៍ និងការរៀបចំ។។

គ- គំនិតត្រិះរិះ ការច្នៃប្រឌិត ភាពច្បាស់លាស់។

ឃ- ភាពច្បាស់លាស់ និងមានពេលវេលាល្អ។

៦ .មនុស្សមានទិសដៅខ្លួនឯង គឺដឹងពីរបៀបគ្រប់គ្រងពេលវេលា។

ក- ពិត

ខ- មិនពិត

**ពិនិត្យចំណេះដឹងរបស់អ្នក**

**ចូររៀបប្រយោគនីមួយៗខាងក្រោមឱ្យត្រឹមត្រូវតាមប្រភេទ។**

| មានគំនិតផ្តួចផ្តើម | ខ្វះគំនិតផ្តួចផ្តើម |
|---|---|
| | |

**ប្រយោគ៖**

- *Tina រៀបចំគ្រប់យ៉ាងសម្រាប់ថ្ងៃផ្ទាល់ខ្លួន ទោះបីថ្ងៃនេះជាថ្ងៃទីមួយនៃសារពើភ័ណ្ឌប្រចាំឆ្នាំ។*
- *ពេលដល់វេនយាមSam ផឹកបង្ហើយកាហ្វេដែលបានឆុងរួច ហើយមិនឆុងដាក់ប៉ាន់បន្ថែមទុកទៀតទេ។*
- *Alfred បែងចែកការបញ្ជារទិញតាមលំដាប់អក្ខរក្រមមុនពេលប្រគល់ជូនទៅផ្នែកសេវាកម្មអតិថិជន។*
- *George សម្អាតកៅអីសាធារណៈក្នុងពេលសម្រាក។*
- *Jane ប្រាប់អ្នកជិតខាងរបស់នាងដែលធ្វើការឱ្យសាខាក្រុមហ៊ុនមួយរបស់នាង អំពីផលិតផលថ្មីដែលកំពុងចេញលក់។*
- *Mary បានដើរឆ្លងកាត់គំនរសំបុត្រដែលបោះត្រារួចនៅតុទទួលភ្ញៀវ ហើយមិនបានប្រាប់ថានាងកំពុងតែទៅបន្ទប់សំបុត្រនោះឡើយ។*

**ចម្លើយគំរូ ២.៥**

**ចូរផ្តល់ចម្លើយនូវសំណួរខាងក្រោមៈ**

១- តើគំនិតផ្តួចផ្តើម គឺជាអ្វី?

ក- គោលដៅដែលអ្នកប្រាថ្នាថាសម្រេចឱ្យបាន។

**ខ- ឱកាសទទួលយកការងារមុនអ្នកដទៃ។**

គ- ការកំណត់បានពីរបៀបធ្វើការឱ្យបានល្អប្រសើរជាងមុន។

ឃ- បង្ហាញថាអ្នកយកចិត្តទុកដាក់ពីក្រុមហ៊ុនដែលកំពង់តែដំណើរការល្អ។

២- តើផលចំណេញបានពីការមានគំនិតផ្តួចផ្តើមនៅកន្លែងការមានអ្វីខ្លះ?

**ក- ធ្វើឱ្យអ្នកក្លាយជាបេក្ខភាពដែលមានគុណសម្បត្តិប្រសើរក្នុងការដំឡើងតំណែង និងប្រាក់កម្រៃ។**

ខ- មិនត្រូវការជំនួយច្រើនក្នុងការបំពេញការងារ។

គ- កំណត់ថាតើរង្វាន់ជំរុញទឹកចិត្តពីខាងក្នុង និងពីខាងក្រៅជាអ្វី។

៣- ការសម្រេចបាននូវគោលដៅអាជីពទាមទារនូវគំនិតផ្តួចផ្តើមជាច្រើន។ តើលក្ខណៈដូចខាងក្រោមមួយណាដែលមនុស្សមានគំនិតផ្តួចផ្តើមគួរមាន? ចូរគូសគ្រប់ចំណុចដែលមាន។

**ក- គ្រប់គ្រងពេលវេលាបានល្អ។**

ខ- សួរសំណួរឱ្យបានច្រើន។

គ- ជាធម្មតាចង់ធ្វើការម្នាក់ឯង។

**ឃ- យកចិត្តទុកដាក់ និងមានក្តីអាណិតអាសូរ។**

៤- មនុស្សដែលមានទិសដៅខ្លួនឯង ធ្វើការដោយខ្លួនឯង ដើម្បីដឹកនាំស្ថានភាពរបស់ខ្លួន និងធ្វើកិច្ចការឱ្យបានសម្រេច។

**កពិត.**

ខមិនពិត.

៥. តើជំនាញអ្វីដែលអ្នកអាចសិក្សាដើម្បីប្រែក្លាយខ្លួនឱ្យទៅជាមនុស្សកាន់តែមានទិសដៅខ្លួនឯង?

ក- ការយល់ការណ៍ ការរៀបចំ ការច្នៃប្រឌិត។

**ខ- ការស្តាប់សកម្ម ការយល់ការណ៍ និងការរៀបចំ។**

គ- គំនិតត្រិះរិះ ការច្នៃប្រឌិត ភាពច្បាស់លាស់។

ឃ- ភាពច្បាស់លាស់ និងមានពេលវេលាល្អ។

៦- មនុស្សមានទិសដៅខ្លួនឯង គឺដឹងពីរបៀបគ្រប់គ្រងពេលវេលា។

**ក- ពិត**

ខ- មិនពិត

**ត្រួតពិនិត្យចំណេះដឹងរបស់អ្នក**

**ចូររៀបប្រយោគនីមួយៗខាងក្រោមឱ្យត្រឹមត្រូវតាមប្រភេទ។**

| **មានគំនិតផ្តួចផ្តើម** | **ខ្វះគំនិតផ្តួចផ្តើម** |
|---|---|
| • Alfred បែងចែកការបញ្ជាទិញតាមលំដាប់អក្ខរក្រមមុនពេលប្រគល់ជូនទៅផ្នែកសេវាកម្មអតិថិជន។<br><br>• George សម្អាតកៅអីសាធារណៈក្នុងពេលសម្រាក។<br><br>• Jane ប្រាប់អ្នកជិតខាងរបស់នាងដែលធ្វើការឱ្យសាខាក្រុមហ៊ុនមួយរបស់នាងអំពីផលិតផលថ្មីដែលកំពុងចេញលក់។ | • Tina រៀបចំគ្រប់យ៉ាងសម្រាប់ថ្ងៃផ្ទាល់ខ្លួន ទោះបីថ្ងៃនេះជាថ្ងៃទីមួយនៃសារពើភ័ណ្ឌប្រចាំឆ្នាំ។<br><br>• ពេលដល់វេនយាម Sam  ផឹកបង្ហើយកាហ្វេដែលបានឆុងរួច ហើយមិនឆុងដាក់ប៉ាន់បន្ថែមទុកទៀតទេ។<br><br>• Mary បានដើរឆ្លងកាត់គំនរសំបុត្រដែលបោះត្រារួចនៅតុទទួលភ្ញៀវ ហើយមិនបានប្រាប់ថានាងកំពុងតែទៅបន្ទប់សំបុត្រនោះឡើយ។ |

**សន្លឹកព័ត៌មាន ២.៦៖ ការគ្រប់គ្រងពេលវេលា**

ផ្នែកមួយនៃការកំណត់ទិសដៅខ្លួនឯង គឺការដឹងពីរបៀបរៀបចំ និងគ្រប់គ្រងពេលវេលា។ ការពង្រឹងជំនាញ គ្រប់គ្រងពេលវេលា មានតួនាទីយ៉ាងសំខាន់ក្នុងការកសាងទំនុកចិត្តរវាងសហការី និងអ្នកគ្រប់គ្រង។

**ចំណុចនីមួយៗនៃបញ្ជីត្រួតពិនិត្យខាងក្រោមនេះ គឺជាការអនុវត្តការគ្រប់គ្រងពេលវេលាបានល្អបំផុត**

- ☑ នៅចុងបញ្ចប់នៃការងារប្រចាំថ្ងៃរបស់អ្នក ចូរសរសេរអំពីអ្វីដែលអ្នកចង់ធ្វើឱ្យបានសម្រេចនៅថ្ងៃស្អែក។
- ☑ ប្រើប្រាស់ប្រតិទិនក្នុងការកត់ចំណាំការណាត់ជួប កិច្ចប្រជុំ វិសម្មកាល ថ្ងៃឈឺ ថ្ងៃសម្រាក និង បញ្ហាផ្សេងៗទៀតមាននៅក្នុងកាលវិភាគ។
- ☑ ផ្តោតការយកចិត្តទុកដាក់លើកិច្ចការដែលគេប្រគល់។ កុំព្យាយាមធ្វើការងារពីរផ្សេងគ្នាក្នុងពេលតែមួយ។
- ☑ ធ្វើកិច្ចការណាដែលសំខាន់បំផុតមុនគេ ក្នុងបញ្ជីតាមដានការងាររបស់អ្នក។

**ការរៀបចំ**



ក្នុងការកំណត់ទិសដៅខ្លួនឯង បុគ្គលិកដែលមានប្រសិទ្ធភាពខិតខំប្រឹងប្រែងដើម្បីឱ្យមានរបៀបរៀបរយ មិនត្រឹមតែសម្រាប់ភារកិច្ចនោះទេ ប៉ុន្តែរួមទាំងកន្លែងការងារទាំងមូលផងដែរ។

**សំណួរដែលត្រូវសួរនៅពេលរៀបចំកន្លែងការងាររបស់អ្នក**

- សម្រាប់សម្ភារដែលខ្ញុំប្រើប្រាស់រាល់ថ្ងៃ តើមានភាពងាយស្រួលក្នុងការយកវាមកប្រើប្រាស់ឬទេ?
- តើខ្ញុំអាចរកអ្វីដែលខ្ញុំត្រូវការនៅតុការងារ ឬក៏កន្លែងអនុវត្តការងារបានងាយស្រួលឬទេ?
- តើអ្នករួមការងារអាចស្វែងរកអ្វីដែលគេត្រូវការនៅនិងតុការងារខ្ញុំ ឬក៏កន្លែងអនុវត្តការងារ ដោយពុំចាំបាច់សួរខ្ញុំជាមុនដែរ ឬទេ?
- តើមានទុកផ្លូវចេញចូលពីកន្លែងការងារខ្ញុំទៅច្រកចេញបានសមរម្យដែរ ឬទេ?

**ចំណុចគន្លឹះ៖**

- មនុស្សដែលចេះកំណត់ទិសដៅខ្លួនឯងតែងតែនាំមុខក្នុងការបំពេញកិច្ចការ និងសម្រេចកិច្ចការគ្រប់ស្ថានភាព។ នៅកន្លែងធ្វើការ បុគ្គលិកដែលកំណត់ទិសដៅខ្លួនឯង ត្រូវបានគេផ្តល់តម្លៃខ្ពស់ពីព្រោះពួកគេបានបញ្ចេញនូវគំនិតផ្តួចផ្តើម។
- ការដឹងពីអ្វីដែលធ្វើឱ្យមនុស្សម្នាក់កំណត់ទិសដៅខ្លួនឯងបាន អាចជួយឱ្យអ្នកកសាងបាននូវភាពខ្លាំងរបស់ខ្លួនដែលមានស្រាប់ និងលើកកម្ពស់ឥរិយាបថក្នុងការកំណត់ទិសដៅខ្លួនឯង។
- ចូរបង្កើតលំនឹកពីរបៀបដែលអ្នកបំពេញការងារ។ ចូរគិតពីវេលាដែលអ្នកបានប្រព្រឹត្តគំនិតផ្តួចផ្តើម និងវេលា ដែលអ្នកមិនបានប្រើប្រាស់គំនិតផ្តួចផ្តើម។
- ការប្រើប្រាស់បច្ចេកទេសកំណត់ទិសដៅខ្លួនឯងនឹងជួយអ្នកឱ្យកាន់តែស្ទាត់ជំនាញ ក្នុងការធ្វើការកំណត់ទិសដៅខ្លួនឯង បង្កើនជំនាញអាជីពរបស់អ្នក និងអាចមានឱកាសច្រើនក្នុងការឡើងតំណែង ឬក៏បានទទួលខុសត្រូវលើការងារផ្សេងៗបន្ថែមទៀត។

**ស្វ័យវាយតម្លៃ ២.៦**

សំណួរត្រួតពិនិត្យ

១- តើចំណុចខាងក្រោមណាដែលអ្នកគួរធ្វើមុនគេ បើសិនជាអ្នកកំពុងខិតខំធ្វើការដើម្បីឆ្ពោះទៅកាន់ការដំឡើងតំណែង ឬឋានៈ?

ក- សួរថៅហ្វាយអ្នកថាតើកម្រិតប្រាក់កាសប៉ុន្មានដែលគេនឹងផ្តល់នៅពេលឡើងតំណែង។

ខ- កំណត់អ្វីដែលអ្នកចាំបាច់ត្រូវធ្វើដើម្បីធ្វើឱ្យការងារអ្នកមានភាពប្រសើរឡើង។

គ- ពិនិត្យឡើងវិញនូវតួនាទីការងារបច្ចុប្បន្នរបស់អ្នក។

២- ពង្រឹងពង្រីកជំនាញគ្រប់គ្រងពេលវេលារបស់អ្នកមានតួនាទីយ៉ាងសំខាន់ក្នុង....

ក- ការទទួលយកកិច្ចការថ្មី។

ខ- ការកសាងទំនុកចិត្តរវាងអ្នករួមការងារ។

គ- ការដើរលេងកំសាន្តនៅចុងសប្តាហ៍។

ឃ- ការធ្វើឱ្យមិត្តស្រីរបស់អ្នកមានចំណាប់អារម្មណ៍។

៣- ចំណុចខាងក្រោមនេះ គឺមិនមែនជាបច្ចេកទេស "អនុវត្តល្អបំផុត" សម្រាប់ការគ្រប់គ្រងពេលវេលា

ក- សរសេរគ្រប់ចំណុចនូវអ្វីដែលអ្នកចង់ធ្វើឱ្យសម្រេចបានសម្រាប់ថ្ងៃបន្ទាប់។

ខ- ប្រើប្រាស់ប្រតិទិនក្នុងការកត់ចំណាំថ្ងៃដែលមានការណាត់ជួប។

គ- ទាក់ទងទៅថៅហ្វាយអ្នកដែលមានជំនាញឯកទេសខាងគ្រប់គ្រងពេលវេលា។

ឃ- ធ្វើកិច្ចការណាដែលសំខាន់ជាងគេ មុនគេ ក្នុងបញ្ជីកិច្ចការរបស់អ្នក។

៤- ចូរសរសេរសំណួរបួន ដែលអ្នកត្រូវសួរនៅពេលរៀបចំការងាររបស់អ្នក?

**ចម្លើយគំរូ ២.៦**

១- តើចំណុចខាងក្រោមណាដែលអ្នកគួរធ្វើមុនគេ បើសិនជាអ្នកកំពុងខិតខំធ្វើការដើម្បីឆ្ពោះទៅកាន់ការដំឡើងតំណែង ឬឋានៈ?

ក- សួរចៅហ្វាយអ្នកថាតើកម្រិតប្រាក់កាសប៉ុន្មានដែលគេនឹងផ្ដល់នៅពេលឡើងតំណែង។

ខ- កំណត់អ្វីដែលអ្នកចាំបាច់ត្រូវធ្វើ ដើម្បីធ្វើឱ្យការងារអ្នកមានភាពប្រសើរឡើង។

**គ- ពិនិត្យឡើងវិញនូវតួនាទីការងារបច្ចុប្បន្នរបស់អ្នក។**

២- ពង្រឹងពង្រីកជំនាញគ្រប់គ្រងពេលវេលារបស់អ្នក មានតួនាទីយ៉ាងសំខាន់ក្នុង....

ក- ការទទួលយកកិច្ចការថ្មី។

**ខ- ការកសាងទំនុកចិត្តរវាងអ្នករួមការងារ។**

គ- ការដើរលេងកំសាន្តនៅចុងសប្តាហ៍។

ឃ- ការធ្វើឱ្យមិត្តស្រីរបស់អ្នកមានចំណាប់អារម្មណ៍។

៣- ចំណុចខាងក្រោមនេះ គឺមិនមែនជាបច្ចេកទេស "អនុវត្តល្អបំផុត" សម្រាប់ការគ្រប់គ្រងពេលវេលា

ក- សរសេរគ្រប់ចំណុចនូវអ្វីដែលអ្នកចង់ធ្វើឱ្យសម្រេចបានសម្រាប់ថ្ងៃបន្ទាប់។

ខ- ប្រើប្រាស់ប្រតិទិនក្នុងការកត់ចំណាំថ្ងៃដែលមានការណាត់ជួប។

**គ- ទាក់ទងទៅចៅហ្វាយអ្នកដែលមានជំនាញឯកទេសខាងគ្រប់គ្រងពេលវេលា។**

ឃ- ធ្វើកិច្ចការណាដែលសំខាន់ជាងគេ មុនគេ ក្នុងបញ្ជីកិច្ចការរបស់អ្នក។

៤- ចូរសរសេរសំណួរបួន ដែលអ្នកត្រូវសួរ នៅពេលរៀបចំការងាររបស់អ្នក?

- **សម្រាប់សម្ភារដែលខ្ញុំប្រើប្រាស់រាល់ថ្ងៃ តើមានភាពងាយស្រួលក្នុងការយកវាមកប្រើប្រាស់ឬទេ?**
- **តើខ្ញុំអាចរកអ្វីដែលខ្ញុំត្រូវការនៅតុការងារ ឬក៏កន្លែងអនុវត្តបានងាយស្រួលឬទេ?**
- **តើអ្នករួមការងារអាចស្វែងរកអ្វីដែលគេត្រូវការនៅនិងតុការងារខ្ញុំ ឬក៏កន្លែងអនុវត្តការងារ ដោយពុំចាំបាច់សួរខ្ញុំជាមុនដែរឬទេ?**
- **តើមានទុកផ្លូវចេញចូលពីកន្លែងការងារខ្ញុំទៅច្រកចេញបានសមរម្យដែរឬទេ?**

## មេរៀនទី៤

# ការប្រាស្រ័យទាក់ទងនៅកន្លែងការងារ

### ១. សេចក្តីណែនាំ

ការយល់ដឹងពីបរិយាកាសខាងក្នុង និងក្រៅអង្គភាពមានសារៈសំខាន់សម្រាប់ធ្វើការប្រាស្រ័យទាក់ទង។ បច្ចុប្បន្ននេះ របៀបគ្រប់គ្រងអាជីវកម្មចាស់ត្រូវបានសម្រេបយ៉ាងឆាប់ ទៅនឹងរបៀបគ្រប់គ្រងបែបថ្មី។ លក្ខណៈបីយ៉ាងនៅកន្លែងធ្វើការងារថ្មី ក្រុមហ៊ុនជាច្រើនចាប់យកវិធីសាស្ត្រគិតឆ្ពោះទៅមុខ សម្រាប់ការធ្វើអាជីវកម្មដែលពាក់ព័ន្ធនឹងការបោះបង់ ចោលនូវរបៀបបង្គាប់បញ្ជាការត្រួតត្រា និងប្រកាន់ខ្ជាប់នូវលក្ខខណ្ឌដូចខាងក្រោម៖

| | |
|---|---|
| **ការផ្តល់សិទ្ធិអំណាច ដល់បុគ្គលិក** | ការផ្តល់សិទ្ធិអំណាចដល់បុគ្គលិក សំដៅទៅលើការផ្តល់ដល់អ្នកក្រោមបង្គាប់ធ្វើការសម្រេចចិត្តដ៏សំខាន់ នៅក្នុងរបៀបដែលពួកគេធ្វើការតាមគោលបំណងរបស់ខ្លួន។ អ្នកចាត់ការទូទៅត្រូវប្រាប់បុគ្គលិកពីអ្វី ដែលត្រូវបំពេញដោយផ្តល់ឱកាសឱ្យគេរកវិធីល្អបំពេញការងារ។ បុគ្គលិកត្រូវបានប្រគល់សិទ្ធិអំណាចធនធានពីក្រុមហ៊ុនកាន់តែច្រើន។<br>**ឧទាហរណ៍៖** និយោជិតអាចដោះស្រាយ ការងារដោយផ្ទាល់ជាមួយអតិថិជន ត្រូវបានផ្តល់សិទ្ធិអំណាចឱ្យដូចជា៖ ការបង្វិលប្រាក់សង ការលក់បញ្ចុះតម្លៃ ការផ្តល់សំណង ឬសេវាកម្មផ្សេងទៀត ក្នុងគោលបំណងដោះស្រាយបញ្ហានៅនឹងកន្លែង ដោយមិនចាំបាច់ ផ្ទៀងផ្ទាត់ជាមួយនឹងថៅកែរបស់ពួកគេជាមុន ឡើយ។ការស្រាវជ្រាវបានបង្ហាញថា ការផ្តល់សិទ្ធិអំណាច រួមចំណែកដល់ការលើកទឹកចិត្តកាន់តែច្រើនជាងមុន និងឱ្យមានការពេញចិត្តនៅកន្លែងធ្វើការក្នុងចំណោមបុគ្គលិកទាំងឡាយ។ |
| **ការងារខាងក្រៅ** | ការធ្វើការក្រៅអង្គភាព ការសម្រេចចិត្តត្រូវធ្វើដោយបុគ្គល ឬក្រុមការងារ។ សព្វថ្ងៃនេះជាង២០% នៃអ្នកធ្វើការនៅសហរដ្ឋអាមេរិក ធ្វើការងារនៅផ្ទះ។ ចំណែកការងារផ្សេងទៀត ពេលខ្លះទៅជួបអតិថិជននៅនឹងកន្លែង ដូចជាក្នុង ព្រលានយន្តហោះ ឬនៅទីកន្លែងណាមួយ ដែលពួកគេ អាចបង្កើតការតភ្ជាប់អ៊ីនធឺណេតបាន។ |
| **ការងារជាក្រុម** | ការងារជាក្រុមត្រូវបានអនុវត្ត ក្នុងបែបបទសម្របសម្រួលមួយ ដោយក្រុមនិយោជិត ដែលតែងតែបង្ហាញនូវជំនាញគ្រប់ប្រភេទ។ ឧទាហរណ៍៖ គណនេយ្យ អតិថិជន ដ៏សំខាន់ៗ ជាច្រើនត្រូវបានដោះស្រាយដោយក្រុមផ្សេងៗ រួមមាន បុគ្គលិក ផ្នែកលក់ អ្នកបច្ចេកទេសជំនាញ និងអ្នក |

តំណាងផ្នែកសេវាអតិថិជន។ ពួកគេ ធ្វើការរួមគ្នា ដើម្បីទទួលបានគណនេយ្យ និងរក្សាវាទុក។ ក្រុមផ្សេងៗ អាចមានជាអចិន្ត្រៃយ៍ ឬពួកគេអាចត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយបញ្ហា ឬឱកាសខណៈដែលវាកើតមានឡើង។

## ២. ការប្រឈមចំពោះការប្រាស្រ័យទាក់ទងថ្មី

ការទទួលយកដែលចេះតែកើនឡើង នូវការផ្តល់អំណាចដល់បុគ្គលិកការងារក្រៅអង្គភាព និងការងារជាក្រុមបានបង្ហាញពីបញ្ហាប្រឈមជាច្រើនក្នុងការគ្រប់គ្រង។ ឧទាហរណ៍៖ អ្នកត្រួតពិនិត្យការងារជាច្រើនព្រួយបារម្ភថា ពួកគេមិនអាចត្រួតពិនិត្យការងាររបស់បុគ្គលិកក្រោមបង្គាប់ដែលធ្វើការនៅផ្ទះ ឬនៅតាមផ្លូវឱ្យមានប្រសិទ្ធភាពខ្ពស់បានទេ។ ការប្រាស្រ័យទាក់ទងអាចមានការលំបាកសម្រាប់ក្រុមដែល មានសមាជិកនិយាយ ភាសា និងមានវប្បធម៌ផ្សេងៗគ្នា។ មនុស្សដែលមានសាវតារខុសគ្នា តែងតែមិននិយាយភាសាអាជីពដូចគ្នាទេ នៅពេលដែលពួកគេធ្វើការជាមួយគ្នា។

### ២.២. ដំណោះស្រាយចំពោះបញ្ហាប្រឈមនៃការប្រាស្រ័យទាក់ទង

ក្រុមហ៊ុនបានឆ្លើយតបទៅនឹងបញ្ហាប្រឈមជាច្រើន ក្នុងការប្រាស្រ័យទាក់ទងគ្នាតាមមធ្យោបាយផ្សេងៗគ្នា។ ក្រុមហ៊ុនជាច្រើនបានរៀបចំរចនាសម្ព័ន្ធ និងបរិយាកាសការងារនៅការិយាល័យបានល្អ។ ចូរគិតពិចារណានូវ ដំណោះស្រាយដូចខាងក្រោម៖

- រៀបចំកន្លែងការងារ ឱ្យមានលក្ខណៈសាមញ្ញដែលមនុស្សអាចជួបគ្នា និងចែករំលែកគំនិតយោបល់។
- រៀបចំបន្ទប់ដោយឡែកសម្រាប់សមាជិកក្រុមការងារអាចបង្ហាញទិន្នន័យ ពិនិត្យមើលផលិតផលគូប្រកួតប្រជែង និងពិសារកាហ្វេរួមគ្នា ខណៈពេលចែករំលែក ។
- រៀបចំបុគ្គលិកដែលត្រូវការធ្វើការប្រាស្រ័យទាក់ទងជាញឹកញាប់នៅកន្លែងតែមួយរួមគ្នា។ ឧទាហរណ៍៖ ក្រុមហ៊ុនមួយដែលបានទទួលស្គាល់ថាបុគ្គលិកលក់របស់គាត់ និងបុគ្គលិកបម្រើសេវាអតិថិជន ត្រូវការចែក រំលែកព័ត៌មានច្រើនច្របាច់បញ្ចូលគ្នាតែមួយក្រុម។
- បើការិយាល័យរបស់អ្នកគ្រប់គ្រង និងអ្នកត្រួតពិនិត្យការងារឱ្យជិតគ្នា ជាមួយបុគ្គលិកក្រោមបង្គាប់។
- ផ្សព្វផ្សាយព័ត៌មានសំខាន់ៗដល់គ្រប់ភាគីពាក់ព័ន្ធ។ ជារឿយៗ វិធានការនៃការប្រតិបត្តិការងារ ត្រូវបានចែករំលែកនៅកន្លែងការងារថ្មី តាមរយៈប្រកាសព័ត៌មាន។

## ២.៣. ការសរសេរអ៊ីម៉ែលប្រកបដោយប្រសិទ្ធភាព

អ៊ីម៉ែលមានផលប្រយោជន៍ចំពោះការប្រាស្រ័យទាក់ទង ប៉ុន្តែក៏មានគុណវិបត្តិដែរ។ ជារឿយៗ អ៊ីម៉ែលត្រូវបានបញ្ជូនទៅកាន់មនុស្សដែលមិនត្រូវការព័ត៌មាន ឬអ្នកដែលមិនពាក់ព័ន្ធក្នុងការពិភាក្សា។ បញ្ហាទាំងនេះអាច ត្រូវបានដោះស្រាយ តាមរយៈការអនុវត្តគោលការណ៍ប្រាស្រ័យទាក់ទងល្អ។

<table>
<tr><td>ដាក់ប្រធានបទអ៊ីម៉ែល</td><td>ក្នុងការបង្កើតសារថ្មីមួយ អ្នកនឹងឃើញមានបន្ទាត់បីដែលត្រូវបំពេញគឺ ផ្ញើជូន (To) ចម្លងជូន (cc) និងឈ្មោះប្រធានបទ ឬកម្មវត្ថុ (Subject)។<br><br>១. ចាប់ផ្តើមសរសេរប្រធានបទ<br>២. សរសេរអាសយដ្ឋានអ្នកដែលត្រូវផ្ញើជូន<br>៣. សរសេរអាសយដ្ឋានអ្នកដែលត្រូវចម្លងជូន<br>៤. ភ្ជាប់ឯកសារ (ប្រសិនបើមាន) ។<br>បន្ទាត់ប្រធានបទគួរតែធ្វើរឿងពីរៈ<br><br>• ចង្អុលបង្ហាញសារសំខាន់របស់អ្នក។ ឧទាហរណ៍ៈ "របាយការណ៍លក់ ប្រចាំខែ" កុំធ្វើឱ្យអ្នកទទួលស្មានបានអំពីខ្លឹមសារ ឬគោលបំណងអ៊ីម៉ែល របស់អ្នក។ ពេលខ្លះ អ្នកអាចផ្ញើសារទាំងមូលនៅក្នុងបន្ទាត់ប្រធានបទដែលធ្វើ ឱ្យអ្នកទទួលមិនចាំបាច់ ត្រូវការបើកមើលអ៊ីម៉ែលទាំងមូល។<br><br>• ទាញចំណាប់អារម្មណ៍របស់អ្នកទទួល។ មនុស្សមួយចំនួនទទួលបានអ៊ីម៉ែលច្រើនពេក រហូតដល់សារខ្លះគេបានអាន ហើយសារខ្លះទៀតមិនបានអាន។ ប្រើបន្ទាត់ ប្រធានបទមួយដែលលើកទឹកចិត្តឱ្យអ្នកទទួល បើក និងអាន អ៊ីម៉ែលរបស់អ្នក។</td></tr>
<tr><td>ប្រើសារមួយសម្រាប់អ៊ីម៉ែលមួយ</td><td>សូមពិចារណាពីសារសំខាន់នៃអ៊ីម៉ែលរបស់អ្នក។ អ្វីៗដែលអ្នកត្រូវនិយាយ ត្រូវធ្វើឱ្យមាន លក្ខណៈសាមញ្ញផ្តោតតែលើបញ្ហាមួយ។ សួរសំណួរមួយ បង្ហាញជម្រើសមួយ ផ្តល់ទិន្នន័យ ឬអ្វីផ្សេងទៀត ប៉ុន្តែកុំបង្ហាញអ្វីគ្រប់យ៉ាងក្នុងពេលតែមួយ។ ផ្ញើសារមួយសម្រាប់ អ៊ីម៉ែលមួយធ្វើឱ្យមានលក្ខណៈ ងាយស្រួលសម្រាប់ភាគីម្ខាងទៀតឆ្លើយតប។ ប្រសិនបើអ្នកមាន បញ្ហាអ្វីផ្សេងសូមសរសេរអ៊ីម៉ែល មួយទៀត។</td></tr>
<tr><td>ពិនិត្យអ៊ីម៉ែលឡើងវិញមុនពេលផ្ញើចេញ</td><td>ដោយសារតែអ៊ីម៉ែលមានភាពងាយស្រួលពេកក្នុងការសរសេរ និងផ្ញើចេញខ្លឹមសារដែលមិនត្រឹមត្រូវ តែងតែកើតមានឡើងជាញឹកញាប់ អ៊ីម៉ែលទាំងនេះធ្វើឱ្យអារម្មណ៍អ្នកផ្ញើមិនល្អ។</td></tr>
</table>

ឧទាហរណ៍ពាក្យមានកំហុស៖
"សូមអរគុណសាររបស់អក ខ្ញុំនៅក្រៅការិយាល័យ នឹងឆ្លើយតបអ្នកវិញក្នុងពេលឆប់ៗ"។

**ស្វ័យវាយតម្លៃ ២.១**

ចូរអានសំណួរខាងក្រោមហើយយកឱកាសនេះ ដើម្បីពិចារណាពីរបៀបដែលអ្នកអាចឆ្លើយបាន។ បន្ទាប់មក ពិនិត្យមើលការឆ្លើយតបរបស់អ្នក ប្រើប្រាស់បណ្តាញការប្រាស្រ័យទាក់ទង តាមអ៊ីនធឺណិត។

**សំណួរ៖** តើគោលការណ៍ណែនាំអ្វីខ្លះ ដើម្បីសរសេរអ៊ីម៉ែលប្រកបដោយប្រសិទ្ធភាព?

**សូមពិនិត្យមើលការយល់ដឹងរបស់អ្នក**

**សំណួរទី១៖** នៅក្នុងពិភពជំនួញបច្ចុប្បន្ន បុគ្គលិកធ្វើការនៅក្នុងទីតាំងកណ្តាលមួយ ហើយនៅពេលដូចគ្នា។

ជ្រើសរើសចម្លើយ៖

ក. ពិត

ខ. មិនពិត

**សំណួរទី២៖** ធ្វើការពីផ្ទះបង្កើតបញ្ហាប្រឈមសម្រាប់និយោជិក ដែលថាគេមិនអាចសម្រេចកិច្ចការបាន។

ជ្រើសរើសចម្លើយ៖

ក. ពិត

ខ. មិនពិត

**សំណួរទី៣៖** ការផ្តល់អំណាចដល់និយោជិក សំដៅទៅលើរបៀបគ្រប់គ្រងមួយដែលផ្តល់ឱ្យអ្នកក្រោមបង្គាប់មានការសម្រេចចិត្តដ៏សំខាន់ តាមរបៀបដែលគេសម្រេចនូវគោលដៅរបស់ខ្លួន។

ជ្រើសរើសចម្លើយ៖

ក. ពិត

ខ. មិនពិត

**សំណួរទី៤៖** កន្លែងធ្វើការខុសគ្នាៗតាមភូមិសាស្ត្រ ឬការធ្វើការក្រៅតំបន់ គឺជាការងារដែលសម្រេចដោយបុគ្គល ឬដោយក្រុមការងារដែលមានទីតាំងផ្សេងគ្នា។

ជ្រើសរើសចម្លើយ៖

ក. ពិត

ខ. មិនពិត

**ចម្លើយគំរូ ២.២**

**ចម្លើយរបស់អ្នកគួរតែដកស្រង់គំនិតដូចខាងក្រោម៖**

សំណួរ៖ តើគោលការណ៍ណែនាំអ្វីខ្លះ ដើម្បីសរសេរអ៊ីម៉ែលប្រកបដោយប្រសិទ្ធភាព?

- ប្រើបន្ទាត់ប្រធានបទមួយ បន្ទាត់ប្រធានបទរបស់អ្នកគួរតែផ្តល់ឱ្យអ្នកអាននូវព័ត៌មាន គ្រប់គ្រាន់អំពីអ៊ីម៉ែលដែលគាត់ ឬនាងមានការយល់ដឹងទូទៅអំពីខ្លឹមសារអ្វីមួយ ដែលអ៊ីម៉ែល នោះមាន។ មិនគួរទុកឱ្យអ្នកអានសង្ស័យឡើយ។
- ប្រើសារតែមួយគត់ក្នុងមួយសារអ៊ីម៉ែល៖ ជ្រើសយកគំនិតមួយ ឬសារសម្រាប់អ៊ីម៉ែលនីមួយៗ ផ្តោតការយកចិត្តទុកដាក់លើអ៊ីម៉ែល។ សារជាច្រើននៅក្នុងអ៊ីម៉ែលមួយអាចធ្វើឱ្យអ្នកអានយល់ច្រឡំ និងគិតខុស។
- អ្នកត្រួតពិនិត្យមើលជានិច្ច មុនពេលផ្ញើចេញ វាគឺជាការងាយស្រួលក្នុងការធ្វើឱ្យមានកំហុស មួយនៅពេលដែលសរសេរអ៊ីម៉ែលមួយ។ មើលអ៊ីម៉ែលរបស់អ្នកជានិច្ចមុនពេលផ្ញើវាចេញ។ សម្រាប់អ៊ីម៉ែល ដែលសំខាន់ខ្លាំង គួរឱ្យមាននរណាម្នាក់ផ្សេងទៀត អានអ៊ីម៉ែលនេះផងដែរ ជាការល្អ។

សំណួរទី១៖ នៅក្នុងពិភពជំនួញសព្វថ្ងៃនេះ បុគ្គលិកធ្វើការនៅក្នុងទីតាំងកណ្តាលមួយ ហើយនៅពេល ដូចគ្នា?

ចម្លើយដែលត្រឹមត្រូវគឺ៖ **មិនពិត។**

សំណួរទី២៖ ធ្វើការពីផ្ទះបង្កើតបញ្ហាប្រឈមសម្រាប់និយោជិក ដែលថាគេមិនអាចសម្រេចកិច្ចការបាន។

ចម្លើយដែលត្រឹមត្រូវគឺ៖ **មិនពិត។**

សំណួរទី៣៖ ការផ្តល់អំណាចដល់និយោជិក សំដៅទៅលើរបៀបគ្រប់គ្រងមួយដែលផ្តល់ឱ្យអ្នកក្រោម បង្គាប់មានការសម្រេចចិត្តដ៏សំខាន់ តាមរបៀបដែលគេសម្រេចនូវគោលដៅរបស់ខ្លួន។

ចម្លើយដែលត្រឹមត្រូវគឺ៖ **ពិត។**

សំណួរទី៤៖ កន្លែងធ្វើការខុសគ្នាៗតាមភូមិសាស្ត្រ ឬការធ្វើការក្រៅតំបន់ គឺជាការងារដែលសម្រេចដោយបុគ្គល ឬដោយក្រុមការងារដែលមានទីតាំងផ្សេងគ្នា។

ចម្លើយដែលត្រឹមត្រូវគឺ៖ **ពិត។**

**មេរៀនទី៥**

# សហគ្រិនភាព

## សកម្មភាព ១ក ៖ ការស្គាល់គ្នា

ក្នុងសកម្មភាព ១ក នេះ យើងនឹងបានស្គាល់សមាជិកក្នុងក្រុម និងបានដឹងពីគំនិតអាជីវកម្ម ឬ ចំណាប់អារម្មណ៍ក្នុងការធ្វើអាជីវកម្មផ្ទាល់ខ្លួនរបស់គ្នាទៅវិញទៅមក។



**ការណែនាំសម្រាប់ការធ្វើសកម្មភាព**

ដំបូងយើងនឹងអានការណែនាំទាំងអស់មុនពេលចាប់ផ្តើមជំហានទី១ ដើម្បីឱ្យយើង ទាំងអស់គ្នាយល់ពីលំដាប់លំដោយនៃសកម្មភាពដែលត្រូវធ្វើ។ បន្ទាប់មកក្រុមធ្វើសកម្មភាពម្តងមួយៗ ទៅតាមពេលវេលាដែលមានកំណត់សម្រាប់សកម្មភាពនោះ។ នៅពេលអស់ពេលវេលាសម្រាប់ជំហាននីមួយៗ អ្នកអានក្នុងក្រុមនឹងបញ្ជាក់ដល់ក្រុម ដើម្បីឱ្យក្រុមអាចបន្តទៅជំហានបន្ទាប់រហូតដល់បញ្ចប់សកម្មភាព ១ក នេះទាំងមូល។

១) គូររូបភាពបង្ហាញពីអាជីវកម្មបច្ចុប្បន្ន ឬគំនិតអាជីវកម្មថ្មី របស់យើងម្នាក់ៗនៅលើក្រដាសតូច ដោយធ្វើការរៀងៗខ្លួន។ ប្រសិនបើយើងចេះសរសេរអក្សរ យើងក៏អាចសរសេរជំនួសឱ្យការ គូរបាន

២) សិក្ខាកាមម្នាក់ៗនឹងណែនាំខ្លួនក្នុងក្រុម ដោយបង្ហាញពីឈ្មោះ កន្លែងកំណើត រួចបង្ហាញរូបភាពអាជីវកម្មរបស់ខ្លួន និងពន្យល់ពីចំណុចសំខាន់ៗនៃអាជីវកម្មនោះ



ក្នុងសកម្មភាពទី ១ក មុននេះ យើងបានស្គាល់សមាជិកក្នុងក្រុម និងចែករំលែកគំនូរ និងនិយាយអំពីគំនិតអាជីវកម្មដែលយើងម្នាក់ៗមាន។ ឥឡូវនេះយើងអាចបន្តទៅសកម្មភាពបន្ទាប់បាន។

## សកម្មភាព ១ខ ៖ ការវាយតម្លៃកត្តាជះឥទ្ធិពល

ក្នុងសកម្មភាព ១ខ យើងនឹងគិតអំពីអ្វីដែលជំរុញទឹកចិត្តរបស់យើងក្នុងការធ្វើអាជីវកម្ម។ ការជំរុញទឹកចិត្តអាចកើតឡើងដោយសារឥទ្ធិពលរបស់កត្តាមួយចំនួន ឧទាហរណ៍ដូចជាអ្វីដែល យើងចង់ដឹងចង់ឃើញខ្លាំង បទពិសោធន៍ពីមុនរបស់យើង ឬបុគ្គលសំខាន់ៗក្នុងជីវិតរបស់យើង ។ ការដឹងពីឥទ្ធិពលទាំងនេះអាចជួយយើងឱ្យមានការយល់ដឹងច្រើនពីជម្រើសអាជីវកម្មដែលជាអាទិភាពរបស់យើង ហើយដឹងថាតើវាមានការជះឥទ្ធិពលមកលើជម្រើសអាជីវកម្មរបស់យើងយ៉ាងណាខ្លះ។



**ការណែនាំសម្រាប់ការធ្វើសកម្មភាព**

១) សមាជិកម្នាក់ៗត្រូវបំពេញ **តារាង ១.១ --តារាងវាយតម្លៃអំពីខ្លួនឯង**។ សមាជិកក្រុមត្រូវជួយដល់សមាជិកក្រុមណាម្នាក់ផ្សេងទៀត ដែលមិនចេះអក្សរ ដើម្បីបំពេញតារាងនេះ

**តារាង ១.១ -- តារាងវាយតម្លៃអំពីខ្លួនឯង**

សម្រាប់សកម្មភាព ១ខ – ការវាយតម្លៃកត្តាជះឥទ្ធិពលរបស់ខ្ញុំ

| | |
|---|---|
| **ចំណាប់អារម្មណ៍របស់ខ្ញុំ** – ការងារដែលខ្ញុំចង់ដឹង និងចូលចិត្តធ្វើ | |
| | |
| | |
| **បទពិសោធន៍របស់ខ្ញុំ** – ខ្ញុំមានបទពិសោធន៍ការងារដូចតទៅនេះ (រួមបញ្ចូល ការបណ្ដុះបណ្ដាល និងការអប់រំ) | |
| | |
| | |
| **បុគ្គលគំរូរបស់ខ្ញុំ** – ខ្ញុំកោតសរសើរមនុស្ស មួយចំនួនដែលខ្ញុំស្គាល់ ដូចតទៅនេះ (អាចជាសមាជិកគ្រួសារ មិត្តភក្តិ គ្រូបង្រៀន អ្នកជំនួញ អ្នកដឹកនាំសហគមន៍ជាដើម។ល។) | |
| | |
| | |

២)	សមាជិកក្រុមម្នាក់ៗប្រើប្រាស់ តារាងវាយតម្លៃអំពីខ្លួនឯង ដើម្បីបង្ហាញដល់ក្រុម ពីចំណុចដែល មានឥទ្ធិពលរបស់ពួកគេម្នាក់ៗ។

៣)	ពិភាក្សាក្នុងក្រុម ថាតើឥទ្ធិពលផ្សេងៗទាំងនេះមានភាពពាក់ព័ន្ធនឹងគំនិតអាជីវកម្ម និងការជំរុញទឹកចិត្តរបស់ខ្លួនក្នុងការធ្វើអាជីវកម្មយ៉ាងដូចម្តេចខ្លះ?



ក្នុងមេរៀនទី១នេះ យើងបានស្វែងយល់ពីឥទ្ធិពលផ្សេងៗដែលជំរុញទឹកចិត្តរបស់យើងក្នុងការធ្វើអាជីវកម្ម។ យើងមានការយល់ដឹងកាន់តែច្បាស់អំពីចំណាប់អារម្មណ៍របស់យើង និងរបៀបដែលចំណាប់អារម្មណ៍ទាំងនោះពាក់ព័ន្ធនឹងគំនិតអាជីវកម្មរបស់យើង។

## ១.៥. សំណួរ និងកិច្ចការ

## ការជ្រើសរើសគំនិតអាជីវកម្ម




ក្នុងមេរៀននេះ យើងនឹងបង្កើតគំនិតអាជីវកម្មផ្សេងៗ និងវាយតម្លៃគំនិតអាជីវកម្មទាំងនោះ និងកំណត់ជ្រើសរើសគំនិតអាជីវកម្មដែលមានសក្តានុពលបំផុត។ នៅចុងបញ្ចប់មេរៀននេះសមាជិក ក្រុមនឹងជ្រើសរើសការបន្តធ្វើការរួមគ្នាលើគំនិតអាជីវកម្មដែលមានសក្តានុពលជាងគេមួយ ឬក៏ជួយគ្នាបង្កើតផែនការសម្រាប់ចំណាប់អារម្មណ៍អាជីវកម្មផ្ទាល់ខ្លួន។

*ចូរជ្រើសរើសសមាជិកក្រុមម្នាក់ឱ្យធ្វើជា "អ្នកអានក្នុងក្រុម" ដើម្បីអានខ្លឹមសារ ក្នុងសៀវភៅមេរៀន ឱ្យលឺៗដល់សមាជិកក្រុម*

### សកម្មភាព ២ក ៖ ការបំផុសគំនិតអាជីវកម្ម

ក្នុងសកម្មភាព ២ក នេះ យើងនឹងធ្វើការជាក្រុមដើម្បីបំផុសគំនិតអាជីវកម្មថ្មី និងមានភាពច្នៃប្រឌិតជាច្រើន។ យើងគួរផ្តោតលើការបង្កើតគំនិតប្លែកៗ ដែលមិនធ្លាប់មាននៅក្នុងសហគមន៍ ព្រោះយើងអាចមានការលំបាកក្នុងការទទួលបានជោគជ័យ ប្រសិនបើមានមនុស្សច្រើនពេកធ្វើអាជីវកម្មដូចគ្នាក្នុងកន្លែងតែមួយ។

នៅពេលបំផុសគំនិត សូមគិតពិចារណាពីប្រភេទ និងសកម្មភាពអាជីវកម្មផ្សេងៗ ដែលអាចមានដូចខាងក្រោម៖

**អ្នកលក់រាយ** ៖ អាជីវកម្មដែលលក់ផលិតផលឱ្យអ្នកប្រើប្រាស់ដោយផ្ទាល់ ដូចជា តូបលក់ផ្លែឈើ ឬភោជនីយដ្ឋានតូចៗ។

**អ្នកលក់ដុំ** ៖ អាជីវកម្មដែលទិញ - លក់ផលិតផល ក្នុងបរិមាណច្រើនឱ្យអាជីវកម្មផ្សេង ដើម្បីលក់បន្ត ដូចជា អ្នកជួញដូរអង្ករ-ស្រូវ។

**អ្នកផលិត** ៖ អាជីវកម្មដែលប្រើប្រាស់វត្ថុធាតុដើម និងគ្រឿងបរិក្ខារដើម្បីផលិតរបស់របរផ្សេងៗ ដោយដៃ ឬម៉ាស៊ីន ដូចជាសិប្បកម្មប្រពៃណី ឬកាត់ដេរសម្លៀកបំពាក់។

**សេវាកម្ម** ៖ អាជីវកម្មដែលពាក់ព័ន្ធនឹងការបំពេញកិច្ចការ ប៉ុន្តែមិនផលិតទំនិញ ដូចជា ការម៉ាស្សា ការកាត់សក់ ឬសេវាមគ្គុទេសក៍ទេសចរណ៍។

**កសិកម្ម** ៖ អាជីវកម្មដែលពាក់ព័ន្ធនឹងការដាំដុះ និងលក់ផលដំណាំ ឬកែច្នៃវត្ថុធាតុដើមជាអាហារ និងភេសជ្ជៈ ដូចជា អ្នកចិញ្ចឹមជ្រូក ឬអ្នកធ្វើប្រហុក។

## ការណែនាំសម្រាប់ការធ្វើសកម្មភាព

១). ធ្វើការជាក្រុមដើម្បីបង្កើតបញ្ជីគំនិតអាជីវកម្ម និងកត់ត្រាលើក្រដាស។ សមាជិកក្រុមម្នាក់ គួរផ្តល់គំនិតអាជីវកម្មយ៉ាងហោចណាស់ចំនួន៣ និងផ្តល់ការពន្យល់ខ្លីៗពីគំនិតនីមួយៗ របស់ខ្លួនមុនពេលក្រុមកត់ត្រា។ ត្រូវព្យាយាមរកគំនិតអាជីវកម្មថ្មីៗ និងមានភាពច្នៃប្រឌិត។

២). ជំហានបន្ទាប់គឺក្រុមត្រូវធ្វើការវាយតម្លៃពីសក្តានុពលជោគជ័យនៃគំនិតនីមួយៗ។ ដាក់សញ្ញាសម្រាប់ ⊕ គំនិតអាជីវកម្មណាដែលក្រុមយល់ថាមានសក្តានុពលខ្ពស់ជាងគេ ឬដាក់សញ្ញា សម្រាប់គំនិតអាជីវកម្មណាដែល ⊖ ក្រុមគិតថាមិនអាចជោគជ័យ។ ប្រការសំខាន់ក្រុមត្រូវពិភាក្សា ពីគំនិតអាជីវកម្មដែលបានលើកឡើងទាំងអស់ និងប្រាប់ពីមូលហេតុដែលគិតថាគំនិតមួយណាមាន សក្តានុពលទាប ឬខ្ពស់មុនពេលក្រុមធ្វើការសម្រេចចិត្ត។

### សកម្មភាព ២ខ៖ លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសគំនិតអាជីវកម្ម

អាជីវកម្មដែលជោគជ័យគឺជាអាជីវកម្មមួយដែលលក់អ្វីដែលអតិថិជនត្រូវការ ឬចង់បាន ក្នុងតម្លៃដែលសមស្របសម្រាប់អតិថិជន ហើយក៏គួរជាអាជីវកម្មដែលធ្វើឱ្យសហគ្រិនខ្លួនឯងពេញចិត្តផងដែរ។ សម្រាប់មូលហេតុទាំងនេះ ប្រការសំខាន់អ្នកត្រូវវាយតម្លៃឱ្យបានល្អិតល្អន់លើគំនិតអាជីវកម្មមុននឹងអ្នកសម្រេចជ្រើសរើស។

ក្នុងសកម្មភាពនេះ យើងនឹងសិក្សាពីកត្តាសំខាន់ៗបីសម្រាប់ការជ្រើសរើសគំនិតអាជីវកម្មដែលល្អប្រសើរ៖

**<u>ជំនាញ</u>**

ដើម្បីឱ្យអាជីវកម្មមួយដំណើរការដោយជោគជ័យ យើងត្រូវការចាំបាច់នូវជំនាញផ្សេងៗក្នុងផ្នែកជាច្រើន។ ជំនាញទាំងនេះអាចរួមមាន **ជំនាញបច្ចេកទេសវិជ្ជាជីវៈ** (ឧទាហរណ៍ដូចជា ធ្វើម្ហូប កាត់សក់ ឬជួសជុលម៉ាស៊ីន) **ជំនាញទន់** (ឧទាហរណ៍ដូចជា ជំនាញទំនាក់ទំនង ការគ្រប់គ្រង ពេលវេលា ការធ្វើការងារជាក្រុម ការដោះស្រាយបញ្ហា ការគិតដោយច្នៃប្រឌិត) និង**បទពិសោធន៍** និង **ចំណេះដឹងជាក់ស្តែង** មួយចំនួនទៀត ឧទាហរណ៍ដូចជា រៀបចំគម្រោងសកម្មភាព ការស្វែងរកថវិកា ការចេះនិយាយភាសាផ្សេងៗលើសពីភាសាកំណើត ។ល។ យើងម្នាក់ៗប្រហែលជាបាន និងកំពុងប្រើប្រាស់ ជំនាញទាំងនេះនៅផ្ទះ សាលារៀន កន្លែងធ្វើការ ឬក្នុងសហគមន៍។

នៅពេលធ្វើការសម្រេចចិត្តជ្រើសរើសគំនិតអាជីវកម្មណាមួយ ជាការសំខាន់យើងត្រូវគិតអំពីជំនាញដែលយើងម្នាក់ៗមាន និងថាតើយើងអាចប្រើប្រាស់ជំនាញទាំងនោះដោយរបៀបណា។

<u>**ធនធាន**</u>

ដើម្បីចាប់ផ្តើមអាជីវកម្មមួយ យើងត្រូវការធនធាន។ ឧទាហរណ៍ យើងអាចត្រូវការ សម្ភារ បរិក្ខារ ដី ឧបករណ៍ ថវិកា ឬបុគ្គលិក។ នៅពេលរៀបចំផែនការសម្រាប់អាជីវកម្មថ្មីមួយ យើងគួរតែគិត អំពីធនធានដែលយើងមាន ឬដែលយើងអាចរកបាន នៅក្នុងនិងជុំវិញសហគមន៍ របស់យើង។

<u>**តម្រូវការ**</u>

អាជីវកម្មទាំងអស់ត្រូវការតម្រូវការទំនិញ ឬសេវាកម្ម ដែលយើងផលិត។ មុននឹងចាប់ផ្តើមអាជីវកម្មណាមួយ យើងត្រូវមានភាពប្រាកដប្រជាថា នឹងមានគេចាប់អារម្មណ៍លើទំនិញ ឬសេវាកម្ម ដែលយើងនឹងផលិត ដូច្នេះយើងនឹងអាចដឹងថាយើងនឹងមានអតិថិជន នៅពេលដែលអាជីវកម្មរបស់យើងចាប់ផ្តើមដំណើរការ។

## ការណែនាំសម្រាប់ការធ្វើសកម្មភាព

១). អ្នកអានក្នុងក្រុម អាន**តារាងគំរូ**/ឧទាហរណ៍ ដែលរៀបរាប់ពីជំនាញ ធនធាន និងតម្រូវការ ដែលបានកំណត់ដោយក្រុមមួយដែលបានចូលរួមក្នុងវគ្គ ស៊ីបិឌ/**CBED** ពីមុន ។

**តារាងគំរូ៖ ជំនាញ ធនធាន តម្រូវការ**

| ជំនាញ | ធនធាន | តម្រូវការ |
|---|---|---|
| • កាត់ដេរ<br>• ចម្អិនត្រី<br>• ធ្វើផ្កាបង្ការ<br>• ដាំបន្លែ<br>• និយាយពីរភាសា<br>• ជួសជុលម៉ូតូ<br>• ជំនាញគណនេយ្យ | • ផ្លែឈើ និងបន្លែ<br>• ផលិតផលព្រៃឈើ<br>• សញ្ញាបត្រពីសាលាបច្ចេកទេស<br>• ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុពីធនាគារ<br>• ដីសម្រាប់ជួលនៅជិតផ្សារក្នុងមូលដ្ឋាន<br>• បំពង់ពន្លត់អគ្គីភ័យ | • ឱសថបុរាណ<br>• សាច់ស្រស់<br>• បន្លែសរីរាង្គ<br>• អ្នករចនាគេហទំព័រ<br>• មគ្គុទេសន៍ ទេសចរណ៍<br>• ជាងជួសជុលកង់ |

២). ពិភាក្សាក្នុងក្រុមអំពីចំណុចស្រដៀងគ្នា និងចំណុចខុសគ្នាអំពីអ្វីដែលមានក្នុងសហគមន៍របស់អ្នក។

៣). ធ្វើការជាក្រុមតូចដែលមានសមាជិក ២ ឬ ៣នាក់ ដើម្បីបំពេញតារាង ២.១ ខាងក្រោម។ រៀបរាប់ពីជំនាញដែលអ្នកមាន និងធនធានដែលអ្នកមាន ឬដែលអ្នកមានលទ្ធភាពអាច ទទួលបាន និងតម្រូវការដែលសហគមន៍ត្រូវការ ។

**តារាង ២.១ ជំនាញ ធនធាន និងតម្រូវការ ដែលយើងមាន ឬមានលទ្ធភាពទទួលបាន**

| ជំនាញ | ធនធាន | តម្រូវការ |
|---|---|---|
| | | |

**សកម្មភាព ២គ ៖ ការជ្រើសរើសគំនិតអាជីវកម្ម**

ក្នុងសកម្មភាពនេះ អ្នកនឹងវាយតម្លៃគំនិតអាជីវកម្មទាំងឡាយដែលអ្នកមាន ដោយពិចារណាពីកត្តាសំខាន់បីសម្រាប់អាជីវកម្មដែលជោគជ័យគឺ ជំនាញ ធនធាន និងតម្រូវការ។ ការវាយតម្លៃរបៀបនេះ មានសារៈសំខាន់ដើម្បីស្វែងយល់កាន់តែច្បាស់អំពីគំនិតណាដែលមានសក្តានុពលខ្ពស់ជាងគេ។

**ការណែនាំសម្រាប់ការធ្វើសកម្មភាព**

១). ធ្វើការជាក្រុម កត់ត្រាគំនិតអាជីវកម្មដែលមានសក្តានុពលខ្ពស់ដែលបានពិភាក្សានៅក្នុងសកម្មភាព ២ក ទៅក្នុង **តារាងទី ២.២ -- ការធ្វើចំណាត់ថ្នាក់អាជីវកម្ម**

២). បន្ទាប់មក ប្រៀបធៀបជំនាញដែលសមាជិកក្រុមម្នាក់ៗបានរៀបរាប់ក្នុងសកម្មភាព ២ខ ខាងលើ និងកំណត់ថាតើជំនាញណាខ្លះដែលចាំបាច់សម្រាប់គំនិតអាជីវកម្មដែលបានលើកឡើង។ ដើម្បីធ្វើការងារនេះបាន សមាជិកក្រុមម្នាក់ៗគួរចូលរួមពិភាក្សាដូចខាងក្រោម ៖

- ប្រសិនបើមានជំនាញជាច្រើនក្នុងក្រុមរបស់អ្នកត្រូវគ្នានឹង គំនិតអាជីវកម្មណាមួយ សូមគូសនៅក្បែរ ✓✓✓ អាជីវកម្មនោះ ក្នុងកូឡោនគំនិតអាជីកម្ម ។
- ប្រសិនបើមានជំនាញតែមួយត្រូវគ្នានឹងគំនិតអាជីវកម្មណាមួយ សូមគូសនៅក្បែរ ✓ គំនិតអាជីវកម្មនោះ ក្នុងកូឡោនគំនិតអាជីវកម្ម។
- ប្រសិនបើមិនមានជំនាញណាត្រូវគ្នានឹងគំនិតអាជីវកម្មណាមួយ សូមគូសនៅក្បែរ ✗ គំនិតអាជីវកម្មនោះ ក្នុងកូឡោនគំនិតអាជីវកម្ម

៣). បន្តធ្វើការជាក្រុម និងធ្វើតាមដំណើរការនេះឡើងវិញសម្រាប់ធនធាន និងតម្រូវការដែលបានកំណត់ដោយក្រុមៈ



**តារាងទី ២.២ -- ការធ្វើចំណាត់ថ្នាក់អាជីវកម្ម**

| គំនិតអាជីវកម្ម | ជំនាញ | ធនធាន | តម្រូវការ |
|---|---|---|---|
| | | | |

៤). ធ្វើការជាក្រុមដើម្បីពិភាក្សានូវសំណួរដូចតទៅៈ តើគំនិតអាជីវកម្មណាដែលមានសក្តានុពលបំផុតដោយផ្អែកលើការវាយតម្លៃជំនាញ ធនធាន និងតម្រូវការ? តើវាដូចគ្នានឹងអាជីវកម្មដែលបានកំណត់ថាមានសក្តានុពលខ្ពស់ ក្នុងសកម្មភាព ២ក ដែរឬទេ?

### សកម្មភាព ២ឃ ៖ ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង (ស្វត/SWOT)

នៅក្នុងសកម្មភាពនេះ អ្នកនឹងបានស្វែងយល់ពី ឧបករណ៍សម្រាប់វិភាគអាជីវកម្ម ហៅថា ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងកត្តាគំរាមកំហែង (ស្វត/SWOT) ដែលជាវិធីសាមញ្ញ និងមានប្រសិទ្ធភាពសម្រាប់ការវាយតម្លៃចំណុចខ្លាំង និងចំណុចខ្សោយនៃអាជីវកម្មដែលមាន សក្តានុពលរបស់អ្នក ក៏ដូចជាឱកាស និងការគំរាមកំហែងដែលអ្នកអាចនឹងប្រឈមនៅពេលអ្នកចាប់ផ្តើមអាជីវកម្មថ្មីរបស់អ្នក។



### ការណែនាំសម្រាប់ការធ្វើសកម្មភាព

១). អ្នកអានក្នុងក្រុម អានខ្លឹមសារពន្យល់អំពី ស្វត/SWOT នៅខាងក្រោម និងត្រូវប្រាកដថា សមាជិកទាំងអស់នៅក្នុងក្រុមយល់ពីនិយមន័យ ស្វត/SWOT នេះ



អ្នកតាមដានពេលវេលាក្នុងក្រុម សូមកុំភ្លេចរំលឹកដល់ក្រុមពីពេលវេលាដែលនៅសល់សម្រាប់សកម្មភាពនីមួយៗ។

## តារាងទី ២.៣ -- ការវិភាគ ស្វត/SWOT



ចំនុចខ្លាំង (S)

ជាលក្ខណៈសម្បត្តិ ឬរបស់ខាងក្នុងដែលនឹង

ផ្តល់ អត្ថប្រយោជន៍ដល់អាជីវកម្មរបស់អ្នក

- តើអ្នកអាចធ្វើអ្វីខ្លះដែលប្រសើរជាងអ្នកដទៃ?
- តើកត្តាអ្វីដែលធ្វើឱ្យអ្នកពិសេសខុសប្លែកពីគេ?



ចំណុចខ្សោយ (W)

ជាលក្ខណៈសម្បត្តិ ឬរបស់ខាងក្នុង ដែលអ្នកត្រូវកែលម្អ

- តើអ្វីដែលអ្នកត្រូវពង្រឹងបន្ថែម?
- តើអ្វីដែលអ្នកត្រូវជៀសវាង?
- តើអ្វីដែលអ្នកដទៃអាចមើលឃើញថាជា

  ចំនុចខ្សោយរបស់អ្នក?



ឱកាស (O)

ជាអ្វីដែលកើតមានក្រៅអាជីវកម្មរបស់អ្នក ដែលអ្នកអាចទាញយកប្រយោជន៍ដើម្បី ទទួលបានជោគជ័យ

- តើមានតម្រូវការពីអ្នកដទៃទេ?
- តើមនុស្សចូលចិត្តអ្វីថ្មីប្លែកដែរឬទេ?
- តើមានការផ្លាស់ប្តូរកើតឡើងដែលអាចជាឱកាស សម្រាប់អាជីវកម្មរបស់អ្នកដែរ



ការគំរាមកំហែង (T) ជាអ្វីដែលកើតមានក្រៅអាជីវកម្មរបស់អ្នក ដែលអាចបង្កឧបសគ្គដល់ភាពជោគជ័យអាជីវកម្ម

- តើកត្តាខាងក្រៅអ្វីខ្លះដែលអាចរារាំងភាពជោគជ័យ

ជ័យរបស់អ្នកឬធ្វើឱ្យមានបញ្ហាសម្រាប់អ្នក?

- តើអ្នកជួបប្រទះឧបសគ្គ ឬបញ្ហាប្រឈមអ្វីខ្លះ?
- តើដៃគូរប្រកួតប្រជែងរបស់អ្នកកំពុងធ្វើអ្វី

២). សូមពិនិត្យមើលឧទាហរណ៍ក្នុងតារាងខាងក្រោមនៃការវិភាគស្វត/SWOT សម្រាប់អាជីវកម្ម លក់ផ្លែឈើ និងពិភាក្សា តើថាមាន <u>ចំណុចខ្លាំង</u> **ច្រើនជាង** <u>ចំណុចខ្សោយ</u>ឬទេ? តើមាន<u>ឱកាស</u>**ច្រើនជាង** <u>កត្តាគំរាមកំហែង</u> ឬទេ? តើយើងអាចដោះស្រាយ <u>ចំណុចខ្សោយ</u> និង<u>កត្តាគំរាមកំហែង</u> បានដោយរបៀបណា? និងពិភាក្សាក្នុងក្រុមថាតើអាជីវម្មលក់ផ្លែឈើនេះជាគំនិតអាជីវកម្មល្អឬទេ ដោយផ្អែកលើលទ្ធផលនៃការវិភាគ ស្វត/SWOT ។

**តារាងទី ២.៤ SWOT**




**ឧទាហរហ៍នៃការវិភាគ ស្វត**/SWOT

៣). ធ្វើការជាក្រុមដើម្បីវិភាគ ស្វត/SWOT សម្រាប់គំនិតអាជីវកម្មដែលមានសក្តានុពលខ្ពស់ជាងគេ ដែលបានកំណត់ជ្រើសរើសក្នុងសកម្មភាព ២គ ។

## តារាងទី ២.៥ -- ការវិភាគ ស្វត/SWOT សម្រាប់អាជីវកម្មរបស់អ្នក

| | |
|---|---|
|  ចំនុចខ្លាំង (S) |  ចំណុចខ្សោយ (W) |
|  ឱកាស (O) |  ការគំរាមកំហែង (T) |



ជាចុងបញ្ចប់ សូមកុំភ្លេចពិភាក្សាក្នុងក្រុមអំពីលទ្ធផលនៃសកម្មភាពដែលបាន អនុវត្ត នីមួយៗ នៅពេលមានការណែនាំឱ្យធ្វើ។ ចូរលើកទឹកចិត្តដល់សមាជិក ក្រុមទាំងអស់ ចូលរួមឱ្យបានសកម្ម។ ត្រូវប្រាកដថា គ្មានសមាជិកណាម្នាក់ ត្រួតត្រាការពិភាក្សា ឬក៏ មិនចូលរួមពិភាក្សាទាល់តែនោះសោះ។



ក្នុងមេរៀននេះ អ្នកបានរៀនពីការបង្កើតគំនិតអាជីវកម្មថ្មីៗ និងពីរបៀបនៃការ វាយតម្លៃគំនិតទាំងនោះ។ អ្នកក៏បានសិក្សា ថាតើអាជីវកម្មនោះមានចំណុចខ្លាំង និងឱកាស **ច្រើនជាង** ចំណុចខ្សោយ និងកត្តាគំរាមកំហែង ឬយ៉ាងណា ហើយតើវាអាចជាគំនិតអាជីវកម្មមួយដែលមានសក្តានុពលខ្ពស់ក្នុងការជោគជ័យដែរ ឬទេ ?

៤). អធិប្បាយគំនិតអាជីវកម្ម និងអតិថិជនសក្តានុពល

ក្រោយពីបញ្ចប់មេរៀននេះសិស្សមានសមត្ថភាពអធិប្បាយពីលក្ខណៈចម្បងៗរបស់គំនិតអាជីវកម្ម និងជួយរៀបចំជ្រើសរើសបង្កើតគំនិតពីអតិថិជនគោលដៅ ។

៥). សំណួរ និងកិច្ចការ



កាលពីមេរៀនមុន អ្នកបានជ្រើសរើសគំនិតអាជីវកម្មរួចរាល់ហើយ។ ជំហានបន្ទាប់គឺការចាប់ផ្តើមធ្វើផែនការអាជីវកម្ម។ មេរៀននេះនឹងជួយអ្នកក្នុងការរៀបចំគំនិត និងយល់ដឹងកាន់តែច្បាស់ពីរបៀបបង្កើតអាជីវកម្មរបស់អ្នក

*ចូរជ្រើសរើសសមាជិកក្រុមម្នាក់ឱ្យធ្វើជា **អ្នកអានក្នុងក្រុម**" ដើម្បីអានខ្លឹមសារក្នុង សៀវភៅមេរៀន ឱ្យលឺៗដល់សមាជិកក្រុម*

## សកម្មភាព ៣ក ៖ ការរៀបរាប់ពីគំនិតអាជីវកម្មរបស់អ្នក

ក្នុងសកម្មភាព ៣ក នេះ អ្នកនឹងបង្កើតគម្រោងសាមញ្ញនៃផែនការអាជីវកម្មរបស់អ្នក។ គម្រោង នេះនឹងរៀបរាប់លម្អិតពីអាជីវកម្ម ដែលអាចឱ្យអ្នកដទៃយល់បានច្បាស់អំពីអ្វីដែលអាជីវកម្មរបស់អ្នក នឹងធ្វើនិងអំពីអ្នកណាដែលជាអតិថិជនសក្តានុពលរបស់អ្នក។

### ការណែនាំសម្រាប់ការធ្វើសកម្មភាព

១). អ្នកអានក្នុងក្រុមនឹងអាន រឿងរ៉ាវរបស់កញ្ញា សុភាព ឱ្យក្រុមស្តាប់៖

កញ្ញា សុភាព រស់នៅក្នុងភូមិមួយមិនឆ្ងាយពីទីក្រុង។ ក្រោយពេលរៀនចប់ គាត់បានចាប់ផ្តើមអាជីវកម្មលក់នំប៉័ងនៅតូបក្នុងផ្សារ។ មិនមានហាងនំនៅក្នុងភូមិឡើយដូច្នេះ កញ្ញា សុភាព យល់ថានំប៉័ងរបស់គាត់នឹងមានតម្រូវការខ្ពស់។ ក្រៅពីនេះគាត់ចង់លក់នំប៉័ងទៅឱ្យអាជីវករផ្សេងៗទៀត ដែលអាចប្រើប្រាស់នំប៉័ងរបស់គាត់ជាគ្រឿងផ្សំជាមួយមុខម្ហូបរបស់ពួកគេ។

ម្តាយរបស់ កញ្ញា សុភាព មានភាពល្បីល្បាញក្នុងការដុតនំ ហើយគាត់នឹងជួយបង្រៀនកញ្ញាសុភាព ពីរូបមន្តសម្ងាត់មួយចំនួន និងអនុញ្ញាតឱ្យកញ្ញាប្រើប្រាស់ចង្ក្រាន និងគ្រឿងបរិក្ខាររបស់គាត់សម្រាប់ដុតនំ។ កញ្ញា សុភាព មានសំណាង ព្រោះមីងរបស់គាត់មានតូបលក់ផ្លែឈើដ៏ជោគជ័យមួយក្នុងផ្សារ។ ម្តាយមីងបានអនុញ្ញាតឱ្យកញ្ញាជួលតូបរបស់គាត់មួយចំហៀងដើម្បីលក់នំប៉័ង។ កញ្ញាសុភាព នឹងដាក់ឈ្មោះអាជីវកម្មថា "សុភាពលក់នំប៉័ងឆ្ងាញ់"។ ទោះបីជាកញ្ញាមិនមានបទពិសោធន៍អាជីវកម្ម ប៉ុន្តែគាត់ជឿជាក់ថាគាត់អាចរៀនសូត្រយ៉ាងលឿនពីម្តាយ និងមីងរបស់គាត់។

២). ធ្វើការជាក្រុមដើម្បីពិនិត្យមើលគ្រោងផែនការអាជីវកម្មសម្រាប់ហាងនំប៉័ង **សុភាពលក់នំប៉័ងឆ្ងាញ់** និង ពិនិត្យភាពត្រឹមត្រូវនៃព័ត៌មានទាំងនោះ៖

| តារាងគំរូ -- គ្រោងផែនការអាជីវកម្មសម្រាប់ហាងនំប៉័ង "សុភាពលក់នំប៉័ងឆ្ងាញ់" | |
|---|---|
| ឈ្មោះអាជីវកម្ម | សុភាពលក់នំប៉័ងឆ្ងាញ់ |
| **ប្រភេទអាជីវកម្ម** | អ្នកលក់រាយ ✓ |
| | អ្នកលក់ដុំ ✓ |
| | អ្នកផលិត |
| | អ្នកផ្តល់សេវា |
| | កសិកម្ម |
| **តើទំនិញ/ផលិតផលអ្វីដែលអាជីវកម្មនេះនឹងផលិត?** | នំប៉័ង |
| **តើសេវាកម្មអ្វីដែលអាជីវកម្មនេះនឹងផលិត?** | - |
| **តើអ្នកណាជាអតិថិជនគោលដៅ?** | អ្នកភូមិ និង អាជីវករក្នុងផ្សារ |
| **តើអាជីវកម្មនេះនឹងមានទីតាំងនៅទីកន្លែងណា?** | ការលក់ឱ្យអតិថិជននឹងធ្វើឡើងពីក្នុងតូបអាហារតូចមួយក្នុងផ្សារមូលដ្ឋាន។ ការដុតនំនឹងធ្វើឡើងក្នុងផ្ទះបាយរបស់កញ្ញាសុភាព។ |

៣) ធ្វើការរួមគ្នាក្នុងក្រុម ដើម្បីបំពេញគ្រោងផែនការអាជីវកម្មរបស់អ្នក ដោយប្រើប្រាស់តារាង ៣.១ ខាងក្រោម សម្រាប់គំនិតអាជីវកម្មដែលមានសក្ដានុពលខ្ពស់ជាងគេដែលអ្នកបានជ្រើសរើស នៅក្នុងមេរៀនទី ២ *(តារាង២.២)*

តារាង ៣.១ -- គ្រោងផែនការអាជីវកម្មរបស់អ្នក

| | |
|---|---|
| ឈ្មោះអាជីវកម្ម | |
| ប្រភេទអាជីវកម្ម | អ្នកលក់រាយ<br>អ្នកលក់ដុំ<br>អ្នកផលិត<br>អ្នកផ្ដល់សេវា<br>កសិកម្ម |
| តើទំនិញ/ផលិតផលអ្វី ដែល អាជីវកម្មនេះនឹងផលិត? | |
| សេវាកម្មអ្វីដែលអាជីវកម្មនេះនឹងផលិត? | |
| តើអ្នកណាជាអតិថិជន គោលដៅ? | |
| តើអាជីវកម្មនេះនឹងមាន ទីតាំងនៅទីកន្លែងណា? | |

ក្នុងសកម្មភាពមុននេះ អ្នកបានបង្កើតគ្រោងជាមូលដ្ឋានមួយនៃគំនិតអាជីវកម្ម ដែលមានសក្ដានុពលខ្ពស់ដែលអ្នកបានជ្រើសរើស។ វាមានប្រយោជន៍ក្នុងការ ចែករំលែកគំនិតជាមូលដ្ឋាននៃអាជីវកម្មរបស់អ្នកជាមួយនឹងអ្នកដទៃ និងជាវិធីមួយដើម្បីគិតពីផ្នែកផ្សេងៗនៃអាជីវកម្មរបស់អ្នក ដែលអ្នកនឹងត្រូវការនៅពេលក្រោយដើម្បីរៀបចំផែនការអាជីវកម្ម។

## សកម្មភាព ៣៦ ៖ ការស្រាវជ្រាវទីផ្សារ

បន្ទាប់ពីបានគ្រោងគំនិតអាជីវកម្មរបស់អ្នក ជំហានបន្ទាប់គឺបង្កើតផែនការពីរបៀបលក់ផលិតផល ឬសេវាកម្មរបស់អ្នក។ ផែនការដែលល្អគួរតែរួមបញ្ចូលនូវ៖ តើអ្នកណាជាអតិថិជនសក្តានុពលរបស់អ្នក? តើពួកគេត្រូវការ និងចង់បានអ្វី? តម្លៃណាដែលសមស្របសម្រាប់ពួកគេ ដែលពួកគេចង់ចំណាយ។ សកម្មភាពដែលអ្នកធ្វើដើម្បីស្វែងរកព័ត៌មានទាំងអស់នេះហៅថា **ការស្រាវជ្រាវទីផ្សារ**។

### ការស្រាវជ្រាវទីផ្សារអាចមានលក្ខណៈសាមញ្ញ

១. ពិភាក្សាជាមួយអតិថិជនដែលមានសក្តានុពល
- តើពួកគេចង់ទិញផលិតផល/សេវាកម្មអ្វី?

២. សង្កេតមើលអាជីវកម្មរបស់គូប្រកួតប្រជែង
- តើអាជីវកម្មរបស់ពួកគេមានចំណុចល្អ និងមិនល្អអ្វីខ្លះ? តើអ្នកអាចរៀនសូត្រអ្វីខ្លះពីអាជីវកម្មរបស់ពួកគេ?

៣. សាកសួរមិត្តភក្តិ គ្រួសារ និងអ្នកជំនួញផ្សេងទៀត
- តើពួកគេយល់យ៉ាងណាពីគំនិតអាជីវកម្មរបស់អ្នក? តើពួកគេមានដំបូន្មាន ឬមតិយោបល់ផ្សេងៗចង់ណែនាំដល់អ្នកដែរឬទេ? តើពួកគេយល់យ៉ាងណាចំពោះផលិតផលរបស់គូប្រកួតប្រជែងរបស់អ្នក?

*ព័ត៌មានដែលប្រមូលបានក្នុងការស្រាវជ្រាវទីផ្សារ គួរត្រូវបានកត់ត្រាក្នុងតារាងវិភាគទីផ្សារ។*

### ការណែនាំសម្រាប់ការធ្វើសកម្មភាព

១. មុនពេលចាប់ផ្តើមសកម្មភាពនេះ អ្នកអានក្នុងក្រុមនឹងអានការស្រាវជ្រាវទីផ្សាររបស់កញ្ញា សុភាពឱ្យ ក្រុមស្តាប់។ ធ្វើការជាក្រុមដើម្បីពិភាក្សាពីរបៀបដែលសុភាពអាចប្រើប្រាស់ព័ត៌មានក្នុងការរៀបផែនការអាជីវកម្មរបស់គាត់។ ព័ត៌មានដែលគាត់ប្រមូលបានស្តីពីតម្លៃសមស្របសម្រាប់អតិថិជន និងតម្លៃរបស់គូប្រកួតប្រជែង ត្រូវបានកត់ត្រាក្នុងតារាងមួយទៀតដែលអ្នកនឹងពិនិត្យមើល នៅពេលក្រោយ។

តារាងគំរូ -- ការស្រាវជ្រាវទីផ្សាររបស់ កញ្ញា សុភាព

| អតិថិជនសក្តានុពល | **ប្រភពព័ត៌មានទីផ្សារ** | **ទំនិញ និងសេវា កម្មដែលមានតម្រូវការ** | **តម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន** | **ការវិភាគគូប្រកួតប្រជែង** |
|---|---|---|---|---|
| **សមាជិកសហគមន៍មូលដ្ឋាន ជាពិសេស អ្នកដែលមានមាជិកគ្រួសារវ័យក្មេង** | ការអង្កេតគូរប្រកួតប្រជែង និងការពិភាក្សាជាមួយអតិថិជនសក្តានុពល | នំប៉័ងសម្រាប់ធ្វើសាំងវិច | ចង់ទិញនំប៉័ងដុតថ្មីរៀងរាល់ថ្ងៃ | ហាងនំជិតបំផុតគឺស្ថិតនៅចម្ងាយ ៣០ គីឡូម៉ែត្រពីទីក្រុងនៅក្នុងភូមិ គេអាចទិញនំប៉័ងនៅហាង ៧១១ ប៉ុន្តែវាមិនមែនជានំប៉័ងដុតថ្មីទេ។ ហាង៧១១ ក៏លក់នំដុតជាច្រើន ដូចជានំខេក និងប៊ីស្គីតផងដែរ |
| អាជីវករក្នុងភូមិ និងមីងរបស់ខ្ញុំ | ការសង្កេតគូរប្រកួតប្រជែង និងការពិភាក្សាជាមួយអ្នកជំនួញក្នុងមូលដ្ឋាន | នំប៉័ងសម្រាប់ ធ្វើបង្អែមក្នុងមូលដ្ឋាន។ នំប៉័ងក្រៀមលក់តាមប្រាសាទ សម្រាប់ធ្វើចំណីត្រី | ចង់បានការផ្គង់ផ្គង់ដែលមានតម្លៃធូរថ្លៃបំផុត | អាជីវករក្នុងមូលដ្ឋានសហការគ្នាដើម្បីទិញនំប៉័ងច្រើនពីហាងនំពីទីក្រុង។ អ្នកលក់ក្នុងមូលដ្ឋានបញ្ជូននំដោយគិតថ្លៃទាបម្តងក្នុងមួយសប្តាហ៍។ |

២. ធ្វើការជាក្រុម ដើម្បីបំពេញព័ត៌មានការស្រាវជ្រាវទីផ្សារ សម្រាប់គំនិតអាជីវកម្មរបស់ក្រុមអ្នកនៅក្នុងតារាងទី ៣.២ ហើយសមាជិកម្នាក់ៗ គួរចូលរួមក្នុងកិច្ចពិភាក្សាលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ក្នុងកូឡោនទី ១ រៀបរាប់ពីអតិថិជនគោលដៅ។
- ក្នុងកូឡោនទី ២ កំណត់ប្រភពផ្តល់ព័ត៌មានស្តីពីទីផ្សាររបស់អ្នក។
- ក្នុងកូឡោនទី ៣ រៀបរាប់ប្រភេទទំនិញ និងសេវាកម្មជាតម្រូវការរបស់អតិថិជន។
- ក្នុងកូឡោនទី ៤ រៀបរាប់ពីតម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន។ ពិចារណាពីការជំរុញទឹកចិត្ត និងទីកន្លែង របៀប និងភាពញឹកញាប់នៃការទិញរបស់ពួកគេ។
- ក្នុងកូឡោនទី ៥ រៀបរាប់ព័ត៌មានពាក់ព័ន្ធនឹងគូប្រកួតប្រជែង (១៥ នាទី)។

តារាង ៣.២ -- ព័ត៌មាននៃការស្រាវជ្រាវទីផ្សាររបស់អ្នក

| អតិថិជនសក្តានុពល | **ប្រភពព័ត៌មានទីផ្សារ** | **ទំនិញ និងសេវា កម្មដែលមានតម្រូវការ** | **តម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន** | **ការវិភាគគូប្រកួតប្រជែង** |
|---|---|---|---|---|
| | | | | |

៣. ធ្វើការជាក្រុម ផ្លាស់ប្តូរលទ្ធផលតារាង "**ព័ត៌មាននៃការស្រាវជ្រាវទីផ្សាររបស់អ្នក**" ដើម្បីពិនិត្យមើលថាមានចំណុចខុសគ្នាដែរឬទេ? ត្រូវប្រាកដថាអ្នកកែលម្អ ឬ បំពេញតារាងបន្ថែម បើមានការណែនាំពីមិត្តភក្តិក្នុងក្រុម។



មេរៀនទី៣នេះ បានជួយអភិវឌ្ឍជំនាញរបស់អ្នក ក្នុងការបង្កើតគ្រោងផែនការ អាជីវកម្ម និងការស្រាវជ្រាវទីផ្សារ ដែលជាកត្តាសំខាន់ដែលអាជីវកម្មជោគជ័យត្រូវអនុវត្តជាប្រចាំ។ តម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជនតែងតែផ្លាស់ប្តូរ ហើយគូប្រកួតប្រជែងតែងតែព្យាយាមបំពេញតម្រូវការនោះ។

៤.២.៣ ផែនការទីផ្សារ និងការកំណត់ថ្លៃ

ក្រោយពីបញ្ចប់មេរៀននេះ សិស្សមានសមត្ថភាពអនុវត្តការងាររៀបចំផែនការទីផ្សារនិងកំណត់ថ្លៃរបស់អាជីវកម្មធុនតូច ។

## ៣.៥. សំណួរ និងកិច្ចការ

## ការបង្កើតផែនការទីផ្សាររបស់អ្នក



ផែនការទីផ្សារកំណត់ពីយុទ្ធសាស្ត្រអាជីវកម្មដើម្បីធ្វើឱ្យទំនិញ និងសេវាទាក់ទាញអតិថិជនសក្តានុពល។ អ្នកនឹងបង្កើតផែនការទីផ្សារជាជំហានម្តងមួយៗ ដោយសម្រេចចិត្តពីយុទ្ធសាស្ត្រដែលអ្នកនឹងប្រើប្រាស់ក្នុងផ្នែកផ្សេងៗនៃអាជីវកម្មរបស់អ្នក។ ផ្នែកទាំងនេះហៅថាគោលការណ៍ទីផ្សារ 4P’s (ហ្វ ភី)។

*ចូរជ្រើសរើសសមាជិកក្រុមម្នាក់ឱ្យធ្វើជា "អ្នកអានក្នុងក្រុម" ដើម្បីអានខ្លឹមសារក្នុង សៀវភៅមេរៀ ឱ្យលឺៗដល់សមាជិកក្រុម*

## គោលការណ៍ 4P's (ហ្វ ភី) នៃយុត្តិសាស្ត្រទីផ្សារ



**ផលិតផល៖** តើទំនិញ ឬ សេវាអ្វីដែលអ្នកនឹងលក់ឱ្យអតិថិជន?



**ទីកន្លែង៖** តើទីកន្លែងណាដែលអ្នកនឹងលក់ ទំនិញ ឬ សេវាកម្មឱ្យអតិថិជន?



**ថ្លៃ៖** តើអ្នកនឹងកំណត់តម្លៃ ទំនិញ ឬ សេវាកម្មប៉ុន្មាន?



**ការផ្សព្វផ្សាយ៖** តើអ្នកនឹងប្រើប្រាស់វិធីសាស្ត្រអ្វី ដើម្បីបង្ហាញ និងទាក់ទាញអតិថិជនឱ្យមកប្រើប្រាស់ផលិតផល ឬសេវារបស់អ្នក?



អ្នកតាមដានពេលវេលាក្នុងក្រុម សូមកុំភ្លេចរំលឹកដល់ក្រុមពីពេលវេលាដែលនៅសល់សម្រាប់សកម្មភាពនីមួយៗ។

**សកម្មភាព ៤ក ៖ កំណត់លក្ខណៈផលិតផលរបស់អ្នក**

អ្នកនឹងចាប់ផ្តើមធ្វើផែនការទីផ្សារដោយកំណត់លក្ខណៈមួយចំនួននៃផលិតផលសេវារបស់អ្នក និងការរៀបរាប់ពីចំណុចដែលធ្វើឱ្យផលិតផល និងសេវាទាំងនោះមានលក្ខណៈពិសេស ឬខុសប្លែកពីគូប្រកួតប្រជែង។



**ការណែនាំសម្រាប់ការធ្វើសកម្មភាព**

១. សូមស្តាប់អ្នកអានក្នុងក្រុម អានពីផែនការផលិតផលរបស់កញ្ញាសុភាព និងពិភាក្សាថាតើ ផែនការនឹងមានលក្ខណៈខុសប្លែកពីផែនការនេះយ៉ាងដូចម្តេចខ្លះ ប្រសិនបើអាជីវកម្មរបស់កញ្ញា សុភាព ផ្តល់សេវាជំនួសឱ្យការលក់ផលិតផលវិញ ។

តារាងគំរូ -- ផែនការទីផ្សារ ផលិតផលរបស់ កញ្ញា សុភាព

| | |
|---|---|
| ផលិតផល (ទំនិញ ឬសេវា) | នំប៉ុង |
| គុណភាព | នំប៉ុងដុតភ្លាមៗ ធ្វើដោយដៃ និងមានសំបកស្រួយ |
| ពណ៌ | សាច់នំប៉ុងស សំបកក្រម៉ៅ |
| ទំហំ | ទំហំមធ្យម (១២ ចំណិត) |
| ការវេចខ្ចប់ | ថង់ផ្លាស្ទិកថ្លា |
| លក្ខណៈប្លែករបស់ផលិតផលធៀបនឹងគូប្រកួតប្រជែង | ធ្វើដោយដៃ និងដុតភ្លាមៗរៀងរាល់ថ្ងៃ។ |

២. ធ្វើការជាក្រុមដើម្បីបំពេញតារាង ៤.១ ដោយមើលទៅលើ ឧទាហរណ៍ផែនការទីផ្សារផលិតផលរបស់កញ្ញាសុភាពខាងលើ។

តារាង ៤.១ -- ទម្រង់ផែនការទីផ្សារផលិតផលរបស់អ្នក

| | |
|---|---|
| ផលិតផល (ទំនិញ ឬសេវា) | |
| គុណភាព | |
| ពណ៌ | |

| | |
|---|---|
| ទំហំ | |
| ការវេចខ្ចប់ | |
| លក្ខណៈប្លែករបស់ផលិតផល ធៀបនឹងគូប្រកួតប្រជែង | |

## សកម្មភាព ៤៩ ៖ ការជ្រើសរើសទីតាំង

ជំហានបន្ទាប់នៃផែនការទីផ្សាររបស់អ្នក គឺការសម្រេចជ្រើសរើស "**ទីតាំង**" សម្រាប់អាជីវកម្ម។ ការជ្រើសរើសទីតាំង ឬទីកន្លែងត្រឹមត្រូវ ចាំបាច់ត្រូវផ្តោតសំខាន់ទៅលើ ប្រភេទអាជីវកម្មរបស់អ្នក គ្រឿងបរិក្ខារ ការផ្គត់ផ្គង់ធនធានដែលអ្នកត្រូវការ និងទីតាំងរបស់អតិថិជន។

## ប្រភេទទីតាំងដែលសហគ្រិនអាចសម្រេចជ្រើសរើសរួមមាន៖

**នៅក្នុងផ្ទះ** ៖ ការធ្វើអាជីវកម្មនៅក្នុងផ្ទះរបស់អ្នក ឬផ្ទះរបស់សមាជិកក្នុងក្រុមណាម្នាក់ ។

**លក់រាយ ឬលក់ដុំ** ៖ ទីតាំងអចល័តដែលរៀបចំឡើងសម្រាប់ដំណើរការអាជីវកម្ម ដូចជាអគារការិយាល័យ ផ្សារទំនើប តូប ឬឃ្លាំង។

**ចល័ត** ៖ ប្រសិនបើអ្នកមានផលិតផល ឬសេវាដែលអ្នកត្រូវបញ្ជូនឱ្យអតិថិជន ទីតាំងល្អបំផុតអាចជារទេះ ម៉ូតូកង់បី ឬរថយន្តដឹក។

**ឧស្សាហកម្ម** ៖ ប្រសិនបើអាជីវកម្មរបស់អ្នកពាក់ព័ន្ធនឹងការផលិត ឬផលិតកម្មធំៗ អាចត្រូវមានកន្លែងបែងចែកត្រឹមត្រូវសម្រាប់ការរក្សាទុកផលិតផល តាមតម្រូវការជាក់លាក់ នៃអាជីវកម្មប្រភេទនេះ។ ការជ្រើសរើសទីតាំងគឺជាការសម្រេចចិត្តរយៈពេលវែង និងអាចត្រូវចំណាយច្រើនក្នុងការផ្លាស់ប្តូរ នៅពេលអាជីវកម្មកំពុង

ដំណើរការ។ សុវត្ថិភាពទីកន្លែង ក៏ជាកត្តាដ៏សំខាន់ដែលគួរគិតគូនៅពេលធ្វើការសម្រេចចិត្តជ្រើសរើសទីតាំង ត្រូវកំណត់មុខសញ្ញាគ្រោះថ្នាក់ និងចាត់វិធានការកាត់បន្ថយហានិភ័យនៃមុខសញ្ញាគ្រោះថ្នាក់ទាំងនោះ។

## ការណែនាំសម្រាប់ការធ្វើសកម្មភាព

១. ធ្វើការជាក្រុម អាននូវផែនការទីតាំងអាជីវកម្មរបស់កញ្ញាសុភាព។ នៅពេលអ្នកពិនិត្យមើលផែនការនោះ សូមពិភាក្សាថា តើសមាជិកក្នុងក្រុមយល់ស្របនឹងជម្រើសរបស់គាត់ដែរឬអត់។ ប្រសិនបើអ្នកជារូបគាត់ (សុភាព) តើមានចំណុចណាដែលអ្នកនឹងធ្វើខុសពីនេះដែរ ឬទេ?

តារាងគំរូ -- ផែនការទីតាំងសម្រាប់អាជីវកម្មរបស់កញ្ញា សុភាព

| | |
|---|---|
| ទីតាំងអាជីវកម្ម | ខ្ញុំនឹងជួលផ្នែកខ្លះនៃតូបរបស់មីងខ្ញុំក្នុងផ្សារ។ |
| ប្រភេទទីតាំង | កន្លែងលក់រាយ/លក់ដុំ (តូបក្នុងផ្សារ) |
| ស្ថានភាព | ជួល ✓<br>ជាម្ចាស់<br>ត្រូវសាងសង់<br>ផ្សេងទៀត (សូមបញ្ជាក់) |
| មូលហេតុនៃការជ្រើសរើស | មានទីតាំងល្អ ចំកន្លែងដែលអតិថិជនរបស់ខ្ញុំទិញម្ហូប។ |
| គុណសម្បត្តិរបស់ទីតាំង | ទីតាំងនេះមានតម្លៃថោក ព្រោះខ្ញុំជួលបន្តពីមីង។ |
| គុណវិបត្តិរបស់ទីតាំង | តូបអាហារស្ថិតនៅក្រោយផ្សារ មិនមានអតិថិជនច្រើនដើរកាត់។ |
| សុវត្ថិភាពកន្លែងធ្វើការ-ការគំរាមកំហែង/មុខសញ្ញាគ្រោះថ្នាក់ | គ្មានបំពង់ពន្លត់អគ្គីភ័យ ឬគ្រឿងបរិក្ខារ។<br>កន្លែងអ៊ូអរ និងមិនសូវមានខ្យល់អាកាសល្អ ។<br>បរិយាកាសក្តៅខ្លាំង។ |
| តម្លៃជួល/ខែ | ១២០,០០០រៀល។ |
| ចំណាយរាប់បញ្ចូល | ចំណាយនេះសម្រាប់តែលើការជួលទីតាំងប៉ុណ្ណោះ*(មិនគិតថ្លៃទឹក&ភ្លើង)។* |

២. ធ្វើការជាគូរ ដើម្បីបំពេញផែនការទីតាំងសម្រាប់អាជីវកម្មរបស់អ្នក ក្នុងតារាង៤.២។

តារាង ៤.២ -- ផែនការទីតាំងរបស់អ្នក

| | |
|---|---|
| ទីតាំងអាជីវកម្ម | |
| ប្រភេទទីតាំង<br>ស្ថានភាព | ជួល<br>ជាម្ចាស់<br>ត្រូវសាងសង់<br>ផ្សេងទៀត (សូមបញ្ជាក់) |
| មូលហេតុនៃការជ្រើសរើស | |
| គុណសម្បត្តិរបស់ទីតាំង | |
| គុណវិបត្តិរបស់ទីតាំង | |
| សុវត្ថិភាពកន្លែងធ្វើការ-ការគំរាមកំហែង/មុខសញ្ញាគ្រោះថ្នាក់ | |
| តម្លៃជួល/ខែ | |
| ចំណាយរាប់បញ្ចូល | |

## សកម្មភាព ៤គ ៖ ការផ្សព្វផ្សាយពីអាជីវកម្មរបស់អ្នក

ក្នុងសកម្មភាពនេះ យើងនឹងសិក្សាពីរបៀបបង្កើតផែនការដើម្បីទាក់ទាញអតិថិជន ដោយផ្សព្វផ្សាយពីអាជីវកម្ម និងផលិតផលរបស់យើង។ យើងប្រហែលជាមានគំនិតមួយចំនួនពីការផ្សាយពាណិជ្ជកម្ម ប៉ុន្តែប្រការសំខាន់ត្រូវចាំថា ការផ្សាយពាណិជ្ជកម្មគ្រាន់តែជាវិធីមួយនៃការផ្សព្វផ្សាយពីអាជីវកម្មប៉ុណ្ណោះ។

- **ការផ្សាយពាណិជ្ជកម្ម** ៖ ជាការផ្តល់ព័ត៌មានដល់អតិថិជនដើម្បីឱ្យពួកគេចាប់អារម្មណ៍ទិញផលិតផល ឬសេវាកម្មរបស់អ្នក។ វាតែងតែផ្តោតលើលក្ខណៈរបស់ផលិតផលដែលខុសប្លែក ឬល្អជាងគូរប្រកួតប្រជែង។

- **យុទ្ធសាស្ត្រលក់** ៖ ផ្តោតសំខាន់លើអ្វីដែលអ្នកអាចធ្វើបានដើម្បីជំរុញអតិថិជនឱ្យទិញផលិតផល ឬសេវា របស់អ្នកកាន់តែច្រើន នៅពេលពួកគេមកកន្លែងអាជីវកម្មរបស់អ្នក។

នៅពេលបំផុសគំនិតសម្រាប់ផែនការផ្សព្វផ្សាយរបស់អ្នក ប្រការសំខាន់ត្រូវពិចារណាពីការចំណាយ និងចាំថាអ្នកមិនចាំបាច់ធ្វើទាំងពីរ ឬតែមួយណានោះទេ។ ចំណុចសំខាន់បំផុតគឺ ត្រូវសម្រេចចិត្តពីផែនការ ដែលនឹងធ្វើឱ្យមានកំណើនប្រាក់ចំណេញ ឬការលក់។ ផែនការទាំងនេះអាចមានរយៈពេលខ្លី ដូចជាសម្រាប់ តែពីរទៅបីម៉ោង ឬពីរទៅបីថ្ងៃ ឬរយៈពេលវែងជាច្រើនសប្តាហ៍ ខែ ឬឆ្នាំ។

## ការណែនាំសម្រាប់ការធ្វើសកម្មភាព

១. ក្នុងក្រុមអាននូវផែនការផ្សព្វផ្សាយសម្រាប់អាជីវកម្មរបស់កញ្ញា សុភាព។ នៅពេលអ្នកពិនិត្យ ឡើងវិញលើ ផែនការនេះ សូមពិភាក្សាថាតើអ្នកយល់ស្របលើជម្រើសរបស់សុភាពដែរ ឬទេ ?
ប្រសិនបើអ្នកជារូបគាត់( សុភាព ) តើអ្នកនឹងធ្វើខុសប្លែកពីនេះដែរឬទេ ?

តារាងគំរូ -- ផែនការផ្សព្វផ្សាយសម្រាប់ កញ្ញា សុភាព

*តារាងគំរូ -- ផែនការផ្សាយពាណិជ្ជកម្ម*

| វិធីសាស្ត្រ | **ព័ត៌មានលម្អិត** | **រយៈពេលកំណត់** |
|---|---|---|
| **សញ្ញាខាងមុខតូប** | ដាក់សញ្ញានៅខាងមុខតូបដោយផ្សព្វផ្សាយពីឈ្មោះអាជីវកម្ម និងប្រភេទនំប៉័ងផ្សេងៗ | អចិន្ត្រៃយ៍ |
| **នាមប័ណ្ណ** | បង្កើតនាមប័ណ្ណដែលមានឈ្មោះរបស់ខ្ញុំអាសយដ្ឋានទំនាក់ទំនងសម្រាប់ចែកជូនអតិថិជននៅពេលពួកគេចាប់អារម្មណ៍លើហាងនំនេះ ឬនៅពេលពួកគេទិញនំ | ត្រូវមាននាមប័ណ្ណជានិច្ច |
| **ព័ត៌មានទំនាក់ទំនងនៅលើស្លាកផលិតផល** | បោះពុម្ពលេខទូរស័ព្ទលើស្លាកផលិតផល | ត្រូវមានស្លាកលើផលិតផលជានិច្ច |

*តារាងគំរូ -- ផែនការលក់*

| Ste យុទ្ធសាស្ត្រ | **ព័ត៌មានលម្អិត** | **រយៈពេលកំណត់** |
|---|---|---|
| **ទិញ៣ដុំ និងទទួលបានដុំទី៤ ក្នុងតម្លៃ ៥០%** | ប្រសិនបើអតិថិជនទិញ៣ដុំពួកគេនឹងទទួលបានដុំទី៤ក្នុងតម្លៃ ៥០% | ១ សប្តាហ៍ |

*តារាងគំរូ -- ផែនការជំរុញការលក់*

| វិធីសាស្ត្រផ្សាយពាណិជ្ជកម្ម | **ការជំរុញការលក់** |
|---|---|
| **ផ្លាកផ្សព្វផ្សាយពីកម្មវិធីពិសេសដាក់នៅមុខតូប**<br>**ខិត្តប័ណ្ណផ្សព្វផ្សាយពីកម្មវិធីពិសេស** | ទិញ ១ ថែម ១ |

២. ធ្វើការរួមគ្នាដើម្បីបំពេញតារាងទី ៤.៣ និង ៤.៤ សម្រាប់អាជីវកម្មរបស់ក្រុមដោយប្រើប្រាស់វិធីសាស្រ្តផ្សេងៗ សម្រាប់ការផ្សាយពាណិជ្ជកម្ម និងការជំរុញការលក់ ដែលសមាជិកក្រុមបានដឹង និងមានបទពិសោធន៍។ សូមស្វែងយល់ឧទាហរណ៍ពីអាជីវកម្មរបស់កញ្ញាសុភាពដែលមានស្រាប់។ នៅពេលអ្នកទទួលបានគំនិតទាំងនេះសូមព្យាយាមបញ្ចូលទាំងវិធីសាស្រ្ត ដែលមានលក្ខណៈពេញនិយមក្នុងសហគមន៍ ក៏ដូចជាគំនិតថ្មីៗ និងច្នៃប្រឌិត។

*តារាង ៤.៣ -- ផែនការជំរុញការលក់របស់អ្នក*

| វិធីសាស្រ្តផ្សព្វផ្សាយ | ផែនការជំរុញការលក់ |
|---|---|
| | |

តារាង ៤.៤ -- ផែនការផ្សព្វផ្សាយសម្រាប់អាជីវកម្មរបស់អ្នក

*ផែនការផ្សាយពាណិជ្ជកម្មរបស់អ្នក*

| វិធីសាស្រ្ត | **ព័ត៌មានលម្អិត** | **រយៈពេលកំណត់** |
|---|---|---|
| | | |

| *ផែនការលក់របស់អ្នក* | | |
|---|---|---|
| យុទ្ធសាស្ត្រ | ព័ត៌មានលម្អិត | រយៈពេលកំណត់ |
| | | |



ក្នុងមេរៀននេះ យើងបានសិក្សាពីរបៀបបង្កើតផែនការផលិតផល ទីតាំង និងការផ្សព្វផ្សាយក្នុងអាជីវកម្ម។ ផ្នែកចុងក្រោយនៃផែនការទីផ្សារគឺការបង្កើត**ផែនការកំណត់តម្លៃ**។ នេះជាផ្នែកដ៏សំខាន់បំផុតមួយនៃផែនការអាជីវកម្ម និងពាក់ព័ន្ធនឹងការគណនាចំណាយក្នុងអាជីវកម្ម។

## ៤.៥. សំណួរ និងកិច្ចការ

## ការកំណត់តម្លៃរបស់អ្នក




*ចូរជ្រើសរើសសមាជិកក្រុមម្នាក់ឱ្យធ្វើជា "អ្នកអានក្នុងក្រុម" ដើម្បីអានខ្លឹមសារក្នុង សៀវភៅមេរៀន ឱ្យលឺៗដល់សមាជិកក្រុម?*

### សកម្មភាព ៥ក ៖ អតិថិជន និងការប្រកួតប្រជែង

ក្នុងសកម្មភាពនេះ អ្នកនឹងបានរៀនពីការស្រាវជ្រាវ និងការកំណត់តម្លៃផលិតផល ដែលសមស្រប សម្រាប់អតិថិជន និងតម្លៃរបស់គូប្រកួតប្រជែង។



### ការណែនាំសម្រាប់ការធ្វើសកម្មភាព

១. ធ្វើការជាក្រុម ដើម្បីពិនិត្យឡើងវិញ លើការស្រាវជ្រាវ និងការកំណត់តម្លៃផលិតផលរបស់ កញ្ញាសុភាព អំពីតម្លៃសមស្របសម្រាប់អតិថិជន និងតម្លៃរបស់គូប្រកួតប្រជែង។ ពិភាក្សាពីរបៀបដែលគាត់ប្រមូលព័ត៌មានទាំងនេះ និងអ្វីដែលអ្នកអាចធ្វើបានដើម្បីប្រមូលព័ត៌មានទាំងនេះ នៅពេលរៀបចំផែនការអាជីវកម្មផ្ទាល់ខ្លួន (៥ នាទី)។

**តារាងគំរូ -- ការស្រាវជ្រាវការកំណត់ថ្លៃផលិតផលរបស់កញ្ញា សុភាព (នំប៉័ង)**

| ប្រភេទផលិត | តម្លៃមធ្យមក្នុងទីផ្សារ | តម្លៃខ្ពស់បំផុតរបស់គូប្រកួត | តម្លៃទាបបំផុត | តម្លៃរបស់ខ្ញុំ |
|---|---|---|---|---|

| ផល (ទំនិញ ឬសេវា) | | ប្រដែង | របស់គូប្រកួតប្រដែង | |
|---|---|---|---|---|
| **នំប៉័ង** | ៦,៥០០រៀល/ដុំ | ៨,០០០រៀល/ដុំ → ពីហាងនំក្នុងភូមិជិតខាង | ៥,០០០រៀល/ ដុំ → ពីហាង 711 | ៦,០០០រៀល/ដុំ |

២. ធ្វើការជាក្រុម ជួយគ្នាបំពេញតារាងការស្រាវជ្រាវការកំណត់តម្លៃផលិតផល សម្រាប់គំនិតអាជីវកម្មដែលក្រុមអ្នកបានជ្រើសរើសក្នុង (តារាងទី ៥.១) ។ ប្រការសំខាន់ត្រូវមានភាពប្រាកដប្រជាពីតម្លៃទាំងនេះ។ ប្រសិនបើអ្នកមិនដឹងពីតម្លៃសមស្របសម្រាប់អតិថិជនទេ ត្រូវសួរសមាជិកក្នុងក្រុមពីថ្លៃសមស្របដែលពួកគេគិតថាគេអាចទិញបាន។

**តារាង ៥.១ -- ការស្រាវជ្រាវការកំណត់តម្លៃផលិតផលអាជីវកម្មរបស់ខ្ញុំ**

| ប្រភេទផលិតផល (ទំនិញ ឬ សេវា) | តម្លៃមធ្យមក្នុងទីផ្សារ | តម្លៃខ្ពស់បំផុតរបស់គូប្រកួតប្រដែង | តម្លៃទាបបំផុតរបស់គូប្រកួតប្រដែង | តម្លៃរបស់ខ្ញុំ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |



នៅពេលដែលតម្លៃគូប្រកួតប្រជែងត្រូវបានកំណត់រួចរាល់ ជំហានបន្ទាប់នៃការកំណត់តម្លៃគឺ ការប៉ាន់ស្មានបរិមាណដែលអ្នកអាចលក់បានក្នុងមួយខែ និងបរិមាណដែលអ្នកគួរផលិតដើម្បីបំពេញតម្រូវការនេះ។ ព័ត៌មានទាំងនេះនឹងអាចឱ្យអ្នកកំណត់ប្រាក់ចំណូលរំពឹងទុកដោយ ផ្អែកលើតម្លៃដែលអ្នកស្នើឡើង។

**សកម្មភាព ៥ខ ៖ ការប៉ាន់ស្មានការផលិត និងការលក់ប្រចាំខែ**

ក្នុងសកម្មភាពនេះ យើងនឹងសិក្សាពីវិធីគណនាការផលិត និងការលក់ប្រចាំខែ។ ដើម្បីសម្រេចគោលដៅនេះ យើងត្រូវមានគំនិតប្រាកដប្រជាពីបរិមាណដែលយើងអាចលក់បាននៅពេលចាប់ផ្តើមអាជីវកម្ម។ ក្នុងវគ្គបណ្តុះបណ្តាលនេះ សមាជិកក្នុងក្រុមនឹងជួយគ្នាព្យាករតួលេខលក់ជាក់ស្តែង ប៉ុន្តែសហគ្រិនដែលផ្តោតសំខាន់លើការចាប់ផ្តើមអាជីវកម្មថ្មី គួរធ្វើសកម្មភាពនេះឡើងវិញ បន្ទាប់ពីការបញ្ចប់វគ្គបណ្តុះបណ្តាលនេះ ដោយប្រើប្រាស់ព័ត៌មានដែលប្រមូលបានតាមវិធីមួយ ឬច្រើនដូចខាងក្រោម៖

១. ប្រៀបធៀបជាមួយអាជីវកម្មស្រដៀងគ្នា តាមរយៈការសង្កេត ឬសាកសួរម្ចាស់អាជីវកម្ម។

២. ស្រាវជ្រាវទីផ្សារ ដោយអង្កេតអតិថិជនសក្តានុពលអំពីផលិតផល តម្លៃដែលគេហ៊ានទិញ ហើយនិងបរិមាណនិងភាពញឹកញាប់ដែលពួកគេទិញផលិតផលរបស់អ្នក។

៣. សាកល្បងលើការលក់របស់អ្នកដោយចាប់ផ្តើមអាជីវកម្មក្នុងទ្រង់ទ្រាយតូច ដើម្បីប៉ាន់ស្មានតម្លៃដែលអតិថិជនហ៊ានទិញ និងចំនួនដែលអ្នកអាចលក់បាន។

៤. ការកម្មង់ទុកជាមុន ជាវិធីសាស្ត្រដែលជួយឱ្យអ្នកអាចទទួលបានការធានាពីអតិថិជននាថ្ងៃអនាគតក្នុងការទិញផលិតផលរបស់អ្នក មុនពេលធ្វើការផលិត។ ត្រូវចាំថាកិច្ចសន្យាទិញជាលាយលក្ខណ៍អក្សរគឺល្អជាងការសន្យាជាពាក្យសំដី។



**ការណែនាំសម្រាប់ការធ្វើសកម្មភាព**

១. ក្នុងក្រុមអាននូវតារាងប៉ាន់ស្មានការផលិត និងការលក់សម្រាប់អាជីវកម្មរបស់កញ្ញាសុភាព។ ដោយសារតែអាជីវកម្មរបស់គាត់ទើបតែចាប់ផ្តើម គាត់បានប៉ាន់ស្មានសម្រាប់តែរយៈពេល ៦ ខែប៉ុណ្ណោះ។ ពិភាក្សាពីរបៀបដែលគាត់គណនាមធ្យមភាគប្រចាំខែ និងអ្វីដែលគាត់អាចធ្វើបានចំពោះការផលិតលើស ប្រសិនបើមិនមានការខូចខាតផលិតផល ឬតម្រូវការខ្ពស់។

### តារាងគំរូ -- ផែនការប៉ាន់ស្មានការលក់ និងការផលិតប្រចាំខែរបស់ កញ្ញា សុភាព

| ផលិតផល (ទំនិញ ឬសេវា) | | ការលក់ប្រចាំខែ/ការផលិត | | | | | | ផលិតសរុប | មធ្យមភាគ/ខែ |
|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | | |
| **ព្យាករណ៍ចំនួនដុំនៃនំប៉ុងដែលអាចលក់ឱ្យអតិថិជនបាន** | ប៉ាន់ស្មានការលក់ | 100 | 150 | 150 | 200 | 200 | 250 | 1050 | 175 ដុំ/ខែ |
| **ដើម្បីគណនាផលិតផលដែលត្រូវខូច ឬតម្រូវការខ្ពស់ ត្រូវផលិត ២០% បន្ថែម លើសពីចំនួននៃការប៉ាន់ស្មានការលក់ (ភាគរយនេះត្រូវបានគណនាសម្រាប់ផលិតផលដែលខូច ឬតម្រូវការខ្ពស់ និងអាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្ដែង)។** | | | | | | | | | |
| **ចំនួននំប៉ុងក្នុងតួបដែលត្រូវផលិតដើម្បីលក់ឱ្យអតិថិជន** | បរិមាណដែលត្រូវផលិត | 120 | 180 | 180 | 240 | 240 | 300 | 1260 | 210 ដុំ/ខែ |

២. ធ្វើការជាគូរ ដើម្បីបំពេញផែនការប៉ាន់ស្មានការលក់ និងការផលិតប្រចាំខែសម្រាប់អាជីវកម្មរបស់ក្រុមអ្នកក្នុងតារាងទី ៥.២។

### តារាង ៥.២ -- ផែនការប៉ាន់ស្មានការលក់ និងការផលិតប្រចាំខែរបស់អ្នក

| ផលិតផល (ទំនិញ ឬសេវា) | ការលក់ប្រចាំខែ/ការផលិត | | | | | | ផលិតសរុប | មធ្យមភាគ/ខែ |
|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | ៦ | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ប៉ាន់ស្មានការលក់ | | | | | | | | |
| | ប៉ាន់ស្មានការលក់ | | | | | | | | |
| | ប៉ាន់ស្មានការលក់ | | | | | | | | |
| | បរិមាណត្រូវផលិត | | | | | | | | |
| | បរិមាណត្រូវផលិត | | | | | | | | |
| | បរិមាណត្រូវផលិត | | | | | | | | |

៣. ផ្លាស់វេនគ្នា ចែករំលែកចម្លើយពីការព្យាករណ៍ការផលិត និងការលក់ប្រចាំខែរបស់អាជីវកម្មក្រុមអ្នក។ ត្រូវប្រាកដថាអ្នកបានប៉ាន់ស្មានពីចំនួនផលិតផលខូច ឬតម្រូវការខ្ពស់ - តើសមាជិកម្នាក់ៗបានប្រើប្រាស់តួលេខ ២០% ដូចឧទាហរណ៍ដែរឬទេ?

**សកម្មភាព ៥គ ៖ ដឹងពីការចំណាយរបស់អ្នក**

អាជីវកម្មមួយ អាចមានចំណាយខុសៗគ្នាជាច្រើនផ្នែក។ នៅក្នុងសកម្មភាពនេះ អ្នកនឹងសិក្សាពីប្រភេទចំណាយខុសៗគ្នា (ចំណាយអថេរ *(ចំណាយដែលប្រែប្រួល)* និង ចំណាយថេរ) និងសិក្សាពីវិធីគណនាចំណាយទាំងនេះ។

## ប្រភេទនៃការចំណាយ

### ១. ចំណាយអថេរ (ចំណាយដែលប្រែប្រួល)

ចំណាយនេះផ្លាស់ប្តូរទៅតាមបរិមាណទំនិញនិងសេវាដែលបានផលិត ជាធម្មតាត្រូវបានផ្តោតទៅលើវត្ថុធាតុដើម ឬកម្លាំងពលកម្ម។

- **វត្ថុធាតុដើម៖** វត្ថុធាតុសំខាន់ៗសម្រាប់ធ្វើជាផលិតផល ឬសេវាសម្រេចចុងក្រោយ ។ **ឧទាហរណ៍៖** ការចំណាយផ្សេងៗក្នុងដំណើរការហាងកាត់សក់រួមមាន សាប៊ូ និងដែលលាបសក់ ឬទឹក និងភ្លើង។ ទាំងនេះជាចំណាយអថេរ ព្រោះវានឹងផ្លាស់ប្តូរទៅតាមបរិមាណទំនិញ និងសេវាកម្មដែលត្រូវផលិត។

- **ចំណាយលើកម្លាំងពលកម្ម៖** ចំណាយទាំងនេះជាចំនួនប្រាក់ឈ្នួលដែលអ្នកបង់ឱ្យនិយោជិត (បុគ្គលិក) និងប្រាក់ខែរបស់អ្នកក្នុងនាមជាម្ចាស់។ ទាំងនេះជាចំណាយដែលប្រែប្រួល ប្រសិនបើអ្នកបើកប្រាក់ឈ្នួលឱ្យបុគ្គលិកនិងខ្លួនឯងផ្លាស់ប្តូរទៅតាមបរិមាណទំនិញ ឬសេវាកម្មដែលបានផលិត។

### ២. ចំណាយថេរ

ចំណាយថេរគឺជាការចំណាយដែលនៅហ្នឹង ដោយមិនអាស្រ័យលើបរិមាណទំនិញ និងសេវាកម្មដែលបានផលិត ហើយជាធម្មតាផ្តោតលើទីតាំង និងគ្រឿងបរិក្ខារ។ ចំណាយលើកម្លាំងពលកម្មក៏អាចជាចំណាយថេរ ប្រសិនបើអ្នកបើកប្រាក់ឈ្នួលឱ្យបុគ្គលិកនិងខ្លួនឯងថេរដោយមិនផ្លាស់ប្តូរទៅតាមបរិមាណទំនិញ ឬសេវាកម្មដែលបានផលិត។

១. អានតារាងគំរូខាងក្រោមស្តីពីវត្ថុធាតុដើមសម្រាប់អាជីវកម្មរបស់កញ្ញាសុភាព និង ពិភាក្សា ពីរបៀបនៃការគណនានីមួយៗ ។

**តារាងគំរូ -- ចំណាយអថេររបស់កញ្ញា សុភាព - វត្ថុធាតុដើម**

| វត្ថុធាតុដើម | ចំនួនត្រូវការ/ផលិតផល | តម្លៃឯកតា | ចំណាយ/ផលិតផល |
|---|---|---|---|
| **មេដំបែ** | ០.០៥ គ.ក្រ | ២,០០០ រៀល/គ.ក្រ | ១០០ រៀល |
| **អំបិល** | ០.១០ គ.ក្រ | ១,០០០ រៀល/គ.ក្រ | ១០០ រៀល |
| **ប្រេង** | ០.១០ លីត្រ | ២,០០០ រៀល/លីត្រ | ២០០ រៀល |
| **ស៊ុត** | ១ គ្រាប់ | ៥០០ រៀល/គ្រាប់ | ៥០០ រៀល |
| **ម្សៅ** | ០.២ គ.ក្រ | ៤,០០០ រៀល/គ.ក្រ | ៨០០ រៀល |
| **ចំណាយសរុបសម្រាប់ផលិត** | ១,៧០០ រៀល/ដុំ | | |
| **ការផលិតក្នុងមួយខែ*** | ២១០ ដុំ/ខែ | | |
| **ចំណាយសរុប/ខែ**** | ៣៥៧,០០០ រៀល/ខែ | | |

*** ចំនួននេះយកចេញពីតារាងគំរូក្នុងសកម្មភាព ៥ខ។**

****ដើម្បីគណនាចំណាយសរុប/ខែ = ការចំណាយសរុបសម្រាប់នំប៉័ង ១ដុំ x ការផលិត/ខែ។**

២. ជួយគ្នាបំពេញការបែងចែកចំណាយលើវត្ថុធាតុដើមសម្រាប់ទំនិញ ឬ សេវាមួយដែលត្រូវផលិតក្នុងគំនិតអាជីវកម្មរបស់ក្រុម ក្នុងតារាង៥.៣។

## តារាង ៥.៣ -- គណនាចំណាយអថេរប្រចាំខែរបស់អ្នក – វត្ថុធាតុដើម

| វត្ថុធាតុដើម | ចំនួនត្រូវការ/ផលិតផល | តម្លៃឯកតា | ចំណាយ/ផលិតផល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| **ចំណាយសរុបសម្រាប់ផលិត** | | | |
| **ការផលិតក្នុងមួយខែ *** | | | |
| **ចំណាយសរុប/ខែ * *** | | | |

****ដើម្បីគណនាចំណាយសរុបប្រចាំខែ = ចំណាយសរុបក្នុងផលិតផលមួយ x ចំនួនផលិតសរុបក្នុងមួយខែ**

៣. ក្នុងក្រុម អានតារាងគំរូស្តីពីកម្លាំងពលកម្មសម្រាប់អាជីវកម្មរបស់កញ្ញាសុភាព និងពិភាក្សា ពីប្រាក់បៀវត្ស ឬប្រាក់ចំណូលសមស្របសម្រាប់ម្ចាស់អាជីវកម្ម។

**តារាងគំរូ -- ចំណាយអថេររបស់កញ្ញា សុភាព – កម្លាំងពលកម្ម**

| មនុស្ស | ចំនួនម៉ោង/ខែ | តម្លៃក្នុងមួយម៉ោង | តម្លៃក្នុងមួយខែ |
|---|---|---|---|
| **សុភាព** | ១២០ | ៣,០០០ រៀល | ៣៦០,០០០ រៀល |
| ចំណាយសរុប/ខែ | ៣៦០,០០០ រៀល/ខែ | | |

៤. ធ្វើការជាក្រុមជួយគ្នាបំពេញការគណនាចំណាយលើកម្លាំងពលកម្មសម្រាប់ទំនិញ ឬសេវាកម្មមួយដែលបានផលិតក្នុងគំនិតអាជីវកម្មរបស់ក្រុម ។

**តារាង ៥.៤ -- គណនាចំណាយអថេរប្រចាំខែរបស់អ្នក – កម្លាំងពលកម្ម**

| មនុស្ស | ចំនួនម៉ោង/ខែ | តម្លៃក្នុងមួយម៉ោង | តម្លៃក្នុងមួយខែ |
|---|---|---|---|
| | | | |
| | | | |

| | | | |
|---|---|---|---|
| | | | |
| **ចំណាយសរុប/ខែ** | | | |

**សកម្មភាព ៥ឃ ៖ ការគណនាចំណាយថេរ**

ចូរចងចាំថា ក្នុងអាជីវកម្មមួយ ត្រូវមានប្រភេទចំណាយពីរ គឺចំណាយថេរ និងចំណាយអថេរ។ ក្នុងសកម្មភាពនេះ យើងនឹងសិក្សាអំពីការគណនាចំណាយថេរ។



**ការណែនាំសម្រាប់ការធ្វើសកម្មភាព**

១. ក្នុងក្រុមអាននូវតារាងគំរូស្តីពីចំណាយថេរសម្រាប់អាជីវកម្មរបស់កញ្ញា សុភាព និងពិភាក្សាពីរបៀបនៃការគណនានីមួយៗ។

**តារាងគំរូ -- ចំណាយថេររបស់កញ្ញា សុភាព (ធ្វើនំប៉ុង)**

| មុខទំនិញ | តម្លៃទិញ | អាយុកាលប្រើប្រាស់ (ខែ) | ចំណាយ/ខែ |
|---|---|---|---|
| **កាំបិត** | ១០,០០០ រៀល | ១២ ខែ | ៨៣៣.៣០ រៀល |
| **ចានដែក** | ២០,០០០ រៀល | ២៤ ខែ | ៨៣៣.៣០ រៀល |
| **ម៉ាស៊ីនលាយម្សៅ** | ១២០,០០០ រៀល | ២៤ ខែ | ៥,០០០ រៀល |
| **វែកឈើ** | ៤,០០០ រៀល | ១២ ខែ | ៣៣៣.៣០ រៀល |
| **បំពង់ពន្លត់អគ្គីភ័យ** | ១០០,០០០ រៀល | ២៤ ខែ | ៤,១៦៦.៦៧ រៀល |
| **ជួល/ខែ** | - | - | ១០០,០០០ រៀល |
| **ការដឹកជញ្ជូន/ខែ** | - | - | ៤០,០០០ រៀល |
| **ចំណាយសរុប/ខែ** | | | **១៥១,១៦៧ រៀល** |

២. ធ្វើការជាក្រុម ជួយគ្នាបំពេញការគណនាចំណាយថេរសម្រាប់ទំនិញ ឬសេវាកម្មមួយដែលបាន ផលិត ចំពោះគំនិតអាជីវកម្មរបស់ក្រុម ក្នុងតារាង៥.៥។

**តារាង ៥.៥ -- ចំណាយថេរប្រចាំខែរបស់អ្នក**

| មុខទំនិញ | តម្លៃទិញ | អាយុកាលប្រើប្រាស់ (ខែ) | ចំណាយ/ខែ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

| | | | |
|---|---|---|---|
| | | | |
| | | | |
| **ចំណាយសរុប/ខែ** | | | |

**សកម្មភាព ៥ង ៖ ការគណនាចំណាយសរុប**

អ្នកបានសិក្សារួចមកហើយពីវិធីសាស្ត្រក្នុងការគណនាទាំងចំណាយអថេរ និងចំណាយថេរ សម្រាប់គំនិតអាជីវកម្មរបស់អ្នក។ នៅក្នុងជំហានចុងក្រោយនេះ  អ្នកនឹងសិក្សាអំពីការគណនាចំណាយសរុប។



**ការណែនាំសម្រាប់ការធ្វើសកម្មភាព**

១. ក្នុងក្រុម អាននូវគំរូការគណនាចំណាយសរុបសម្រាប់អាជីវកម្មរបស់កញ្ញា សុភាព និងពិភាក្សាពីរបៀបនៃការគណនានីមួយៗ។

**តារាងគំរូ -- ការគណនាចំណាយសរុបរបស់កញ្ញា សុភាព (ធ្វើនំប៉ុង)**

| ប្រភេទចំណាយ | ចំណាយក្នុងមួយខែ |
|---|---|
| **ចំណាយអថេរលើវត្ថុធាតុដើម** | ៣៥៧,០០០ រៀល |
| **ចំណាយអថេរលើកម្លាំងពលកម្ម** | ៣៦០,០០០ រៀល |
| **ចំណាយថេរ** | ១៥១,១៦៧ រៀល |
| **ចំណាយសរុប/ខែ** | ៨៦៨,១៦៧ រៀល |

២. ធ្វើការជាក្រុមជួយគ្នាបំពេញតារាង ការគណនាចំណាយសរុបសម្រាប់ទំនិញ ឬសេវាកម្មមួយដែលផលិត ក្នុងគំនិតអាជីវកម្មដែលក្រុមរបស់អ្នកបានជ្រើសរើស ក្នុងតារាង៥.៦។

**តារាង ៥.៦ -- ចំណាយសរុបរបស់អ្នកសម្រាប់ផលិតផល ទំនិញ ឬសេវាកម្មរបស់អ្នក**

| | |
|---|---|
| ឈ្មោះផលិតផល ទំនិញ ឬសេវាកម្ម | |
| ប្រភេទចំណាយ | **ចំណាយ/ខែ** |
| ចំណាយអថេរលើវត្ថុធាតុដើម | |
| ចំណាយអថេរលើកម្លាំងពលកម្ម | |
| ចំណាយថេរ | |
| ចំណាយសរុប/ខែ | |



ក្នុងសកម្មភាពមុននេះ យើងបានសិក្សាពីរបៀបប៉ាន់ស្មានចំណាយប្រចាំខែសម្រាប់អាជីវកម្មដែលផលិតទំនិញ ឬសេវាមួយ ដោយគណនាចំណាយសម្រាប់វត្ថុធាតុដើម កម្លាំងពលកម្ម គ្រឿងបរិក្ខារ និងទីតាំង។ មុនពេលអ្នកអនុវត្តតាមផែនការអាជីវកម្មរបស់ខ្លួន ប្រការសំខាន់ត្រូវមានការគណនាទាំងនេះសម្រាប់ទំនិញ ឬសេវាកម្មនីមួយៗ និងបូកសរុបឱ្យបានច្បាស់លាស់ ។

## សកម្មភាព ៥ច ៖ ការគណនាប្រាក់ចំណេញ

ជំហានចុងក្រោយក្នុងការកំណត់តម្លៃផលិតផលគឺត្រូវកំណត់ថាតើអ្នកចំណេញ ឬខាត ដោយផ្អែកលើការប៉ាន់ស្មានតម្លៃ ការលក់ ការផលិត និងចំណាយរបស់អ្នក។

- អ្នកទទួលបានប្រាក់ចំណេញនៅពេលប្រាក់**ចំណូលពីការលក់របស់អ្នកច្រើនជាងចំណាយ។**
- អ្នកខាតបង់នៅពេល**ចំណាយច្រើនជាងប្រាក់ចំណូលពីការលក់។**



ប្រសិនបើអ្នកដឹងថា អ្នកកំពុងខាតបង់ អ្នកត្រូវផ្តោតលើចំណុចខាងក្រោមដើម្បីធ្វើការកែលម្អ ៖

- តម្លៃ-- តើអ្នកអាចកំណត់ថ្លៃខ្ពស់ជាងនេះបានដែរឬទេ?
- ការលក់--តើអ្នកអាចលក់បានច្រើនជាងនេះបានដែរឬទេ? តើមានការផ្សព្វផ្សាយណាដែលនឹងជួយឱ្យអ្នកលក់បានច្រើនឬទេ?
- ការចំណាយ-- តើមានវិធីអាចកាត់បន្ថយការចំណាយដែរឬទេ?

ប្រសិនបើអ្នកមិនអាចកែលម្អបាន ឬក៏អ្នកបានកែលម្អហើយ ប៉ុន្តែនៅតែខាតបង់ ប្រការសំខាន់ត្រូវពិចារណាពីគំនិតអាជីវកម្មថ្មីផ្សេងទៀត។ ដើម្បីគណនាប្រាក់ចំណេញ អ្នកត្រូវប្រៀបធៀបតម្លៃលក់របស់ផលិតផល ការលក់ និងការចំណាយសម្រាប់អាជីវកម្មរបស់អ្នក។



### ការណែនាំសម្រាប់ការធ្វើសកម្មភាព

១. ក្នុងក្រុមអាននូវតារាងគំរូប្រាក់ចំណេញសម្រាប់អាជីវកម្មរបស់កញ្ញា សុភាព និងពិភាក្សាពីរបៀបគណនា។

**តារាងគំរូ -- គណនាប្រាក់ចំណេញសម្រាប់អាជីវកម្មរបស់កញ្ញា សុភាព**

| ជំហានទី ១ |
| --- |

| តម្លៃ (**តម្លៃរបស់សុភាព ក្នុងសកម្មភាព ៥ក**) | X | **មធ្យមភាគប្រចាំខែ** (ការលក់របស់សុភាព ក្នុងសកម្មភាព ៥ខ) | = | **ការលក់ប្រចាំខែ** |
|---|---|---|---|---|
| **៦,០០០ រៀល/ ដុំ** | | ១៧៥ ដុំ | | ១,០៥០,០០០ រៀល |
| ជំហានទី ២ | | | | |
| ការលក់ប្រចាំខែ | - | **ចំណាយ** (ចំណាយរបស់សុភាព ក្នុងសកម្មភាព ៥គ) | = | **ប្រាក់ចំណេញ** |
| **១,០៥០,០០០ រៀល** | | ៨៦៨,១៦៧ រៀល | | ៣៦៣,៨៣៣ រៀល |

២. ធ្វើការជាគូ ដើម្បីបំពេញតារាងប្រាក់ចំណេញ ៥.៧ សម្រាប់គំនិតអាជីវកម្មរបស់ក្រុម ដោយប្រើប្រាស់ការគណនាក្នុងសកម្មភាពមុនៗ។

៣.បន្ទាប់ពីបំពេញតារាង៥.៧ រួចហើយពិភាក្សាក្នុងក្រុមពីអ្វីដែលសមាជិកក្រុមបានសិក្សាពីវគ្គបណ្តុះបណ្តាលនេះ និងផែនការក្នុងការកែលម្អនានាក្នុងផែនការអាជីវកម្មដោយប្រើប្រាស់ចំណេះដឹងថ្មីនេះ ។

## តារាង ៥.៧ -- ប្រាក់ចំណេញរបស់អ្នក

| ជំហានទី ១ | | | | |
|---|---|---|---|---|
| តម្លៃ | X | មធ្យមភាគប្រចាំខែ | = | ការលក់ប្រចាំខែ |
| | | | | |
| ជំហានទី ២ | | | | |
| ការលក់ប្រចាំខែ | - | **ចំណាយ** | = | **ប្រាក់ចំណេញ** |
| | | | | |

មេរៀនស្តីពីការកំណត់តម្លៃបានបង្ហាញពីឧបករណ៍ យុទ្ធសាស្ត្រផ្សេងៗ ដែលសហគ្រិនអាចប្រើប្រាស់ដើម្បីកំណត់តម្លៃសមរម្យសម្រាប់ផលិតផល។ ប្រការសំខាន់ត្រូវចាំថា ការចំណាយក្នុងអាជីវកម្មរបស់អ្នក និងតម្លៃរបស់គូប្រកួតប្រជែង នឹងមានឥទ្ធិពលលើការកំណត់តម្លៃសម្រាប់ការលក់ផលិតផលរបស់អ្នកទៅឱ្យអតិថិជន។

៤. កត្តាកំណត់ពីភាពជោគជ័យក្នុងអាជីវកម្ម ៖

ក្នុងមេរៀននេះ សិស្សមានសមត្ថភាពកំណត់ពីនិយមន័យរបស់អាជីវកម្មជោគជ័យ ។

## កត្តាកំណត់ពីភាពជោគជ័យក្នុងអាជីវកម្ម



នៅក្នុងសកម្មភាព ៦ក នេះ អ្នកនឹងអាចពិចារណាពីអាជីវកម្មជោគជ័យដែលអ្នកបានដឹង និងកំណត់និយមន័យនៃអាជីវកម្មដែលជោគជ័យ និងកត្តាសំខាន់ៗដែលធ្វើឱ្យ អាជីវកម្មទាំងនោះទទួលបានជោគជ័យ។

## សកម្មភាព ៦ក ៖ ការកំណត់ភាពជោគជ័យក្នុងអាជីវកម្ម

ទាំងនេះជាកត្តាសំខាន់ៗធ្វើឱ្យអាជីវកម្មទទួលបានជោគជ័យ ដែលអ្នកត្រូវពិចារណាសម្រាប់អាជីវកម្មផ្ទាល់ខ្លួន។ សកម្មភាពបន្ទាប់នឹងជួយអ្នកកំណត់លក្ខណៈវិនិច្ឆ័យរបស់អ្នក ដើម្បីជានាភាពជោគជ័យក្នុងអាជីវកម្មរបស់អ្នក។

- ផែនការអាជីវកម្ម ច្បាស់លាស់
- ថ្នាក់គ្រប់គ្រងមានឥរិយាបថល្អ
ចំពោះបុគ្គលិក និងអតិថិជន
- ថ្នាក់គ្រប់គ្រងមានសមត្ថភាព ប្រឈមនឹងហានិភ័យ

- ផលិតផលមានតម្រូវការខ្ពស់
- យុទ្ធសាស្ត្រទីផ្សារ ប្រកបដោយ
ភាពច្នៃប្រឌិត
- ការរចនាផលិតផលបានល្អ

- ទីតាំងប្រកបអាជីវកម្មមានអំ-ណោយផលល្អ និងមានលក្ខណៈជាយុទ្ធសាស្ត្រ
- កន្លែងធ្វើការមានសុវត្ថិភាពល្អ
- ម្ចាស់អាជីវកម្មពេញចិត្តនឹងអាជីវកម្មរបស់ខ្លួន

*ចូរជ្រើសរើសសមាជិកក្រុមម្នាក់ឱ្យធ្វើជា "អ្នកអានក្នុងក្រុម" ដើម្បីអានខ្លឹមសារក្នុង សៀវភៅមេរៀន ឱ្យលឺៗដល់សមាជិកក្រុម*

## ការណែនាំសម្រាប់ការធ្វើសកម្មភាព

១. ធ្វើការជាក្រុមដើម្បីពិភាក្សាពីឧទាហរណ៍នៃអាជីវកម្មជោគជ័យដោយតម្រូវឱ្យសមាជិកម្នាក់ៗ ផ្តល់ឧទាហរណ៍មួយ។ ដំបូងគូសតារាងទី ៦.១ នៅលើក្រដាស ស ផ្ទាំងធំ ហើយពិភាក្សាពីមូលហេតុដែលកំណត់ថាអាជីវកម្មទទួលបានជោគជ័យ ។

២. ធ្វើការជាដៃគូ ដើម្បីជួយគ្នាកំណត់ចំណុចសំខាន់ៗ ដែលសំគាល់ថាអាជីវកម្មរបស់ក្រុមអ្នកជោគជ័យកត់ត្រាចំណុចទាំងនេះនៅក្នុងតារាងទី ៦.១។

៣.ធ្វើការជាក្រុម ចែករំលែកតារាងបង្ហាញពីកត្តាជោគជ័យក្នុងអាជីវកម្មរបស់ក្រុមអ្នក។ ពិភាក្សាពីចំណុចខុសគ្នាដែលសមាជិកក្រុមបានលើកឡើង និងផ្តល់មតិយោបល់ល្អៗ ស្តីពីសកម្មភាពដែលអាចធ្វើឡើងដើម្បីសម្រេចចំណុចសំខាន់ៗទាំងនេះ។ ធ្វើការកែសម្រួលតារាងរបស់អ្នកដោយបញ្ចូលគំនិតទាំងនេះ ។

| តារាងគំរូ -- អាជីវកម្មជោគជ័យ និងកត្តាកំណត់ភាពជោគជ័យ | |
|---|---|
| កត្តាកំណត់ជោគជ័យរបស់អ្នក | **សកម្មភាពដែលអ្នកអាចធ្វើដើម្បី សម្រេចបានចំណុចនេះ** |
| **ទទួលបានប្រាក់ចំណេញ មិនមានគូប្រកួតប្រជែង** | ទទួលបានប្រាក់ចំណេញប្រចាំខែចំនួន ៣៦៣,៨៣៣ រៀល និងមិនមានគូប្រកួតប្រជែង ក្នុងមូលដ្ឋាន |
| | |

| តារាង ៦.១ -- កត្តាសំគាល់ពីភាពជោគជ័យក្នុងអាជីវកម្មរបស់អ្នក | |
|---|---|
| កត្តាកំណត់ជោគជ័យរបស់អ្នក | **សកម្មភាពដែលអ្នកអាចធ្វើដើម្បី សម្រេចបានចំណុចនេះ** |
| | |
| | |

ក្នុងមេរៀននេះ អ្នកបានកំណត់ចំណុចសម្រាប់វិនិច្ឆ័យភាពជោគជ័យក្នុងអាជីវកម្មរបស់អ្នក និងសកម្មភាពដែលអ្នកអាចធ្វើ ដើម្បីសម្រេចចំណុចទាំងនោះ។ ប្រការសំខាន់ត្រូវចាំថា អាជីវកម្មត្រូវបង្កើតប្រាក់ចំណូលគ្រប់គ្រាន់ និងផ្តល់ភាពពេញចិត្តដល់ម្ចាស់អាជីវកម្ម។ មុនពេលចាប់ផ្តើមអាជីវកម្មថ្មី អ្នកគួរធ្វើឡើងវិញនូវ ផែនការអាជីវកម្មដែលអ្នកបានរៀនបង្កើតឡើងនៅក្នុងវគ្គបណ្តុះបណ្តាលនេះ និងត្រូវជឿជាក់ថាវានឹងជួយឱ្យអ្នកសម្រេចបានកត្តាកំណត់ជោគជ័យក្នុងអាជីវកម្ម។

៤. ផែនការសកម្មភាអាជីវកម្មគ្រួសារ

ក្នុងមេរៀននេះសិស្សមានសមត្ថភាពអធិប្បាយ និងរៀបចំផែនការសកកម្មភាពគ្រប់គ្រងអាជីវកម្មគ្រួសារបែបងាយៗ។

**៥. សំណួរ និងកិច្ចការ**

**ផែនការសកម្មភាព**



នៅក្នុងមេរៀនចុងក្រោយនេះ អ្នកនឹងពិនិត្យឡើងវិញលើជំនាញទាំងអស់ ដែលត្រូវបានបង្កើតឡើងក្នុងវគ្គបណ្តុះបណ្តាលនេះ ដើម្បីកំណត់ជំហានបន្ទាប់របស់អ្នក។ មេរៀននីមួយៗតាមដំណាក់កាលក្នុងវគ្គបណ្តុះបណ្តាលនេះមានភាពត្រូវគ្នានឹងជំហាននីមួយៗ ដែលអ្នកអាចធ្វើបាន ប្រសិនបើអ្នកសម្រេចចិត្តចាប់ផ្តើមអាជីវកម្ម។

## សកម្មភាព៧ក ៖ ការអនុវត្តសកម្មភាព

ការរៀបចំផែនការសកម្មភាពចុងក្រោយ ជាជំហានដ៏សំខាន់សម្រាប់ជួយអ្នកឱ្យសម្រេចចិត្តពីរបៀបអនុវត្តចំណុចទាំងឡាយដែលអ្នកបានរៀនសូត្រពីវគ្គបណ្តុះបណ្តាលនេះក្នុងកិច្ចការ និងក្នុងជីវិតរស់នៅរបស់អ្នក។ អ្នកអាចប្រើប្រាស់ផែនការនោះ រួមជាមួយនឹងកិច្ចការរបស់អ្នកដែលបានបំពេញក្នុងសៀវភៅមេរៀនរបស់អ្នក ដើម្បីកែសម្រួល និងចែករំលែកជាមួយអ្នកដទៃពីគំនិត និងពីផែនការអាជីវកម្មរបស់អ្នក។

### ការណែនាំសម្រាប់ការធ្វើសកម្មភាព

១. ស្តាប់អ្នកអានក្នុងក្រុមអានពីជំហាននីមួយៗ ក្នុងតារាងកិច្ចការរៀបចំផែនការសកម្មភាព។ ក្នុងពេលស្តាប់ ត្រូវសរសេរ បាទ/ចាស ឬទេ ក្នុងកូឡោនទី១ ដើម្បីបង្ហាញថាតើអ្នកបានរៀនធ្វើសកម្មភាពនោះ ឬយ៉ាងណា។

**តារាង ៧.១ -- ការរៀបចំផែនការសកម្មភាព**

| ជំហាននានាក្នុងការចាប់ផ្តើមអាជីវកម្ម | បានរៀន ?<br>បាទ/ចាស/ទេ | ជំហានបន្ទាប់នឹងធ្វើនៅពេលណា<br>សម្រាប់អាជីវកម្មផ្ទាល់ខ្លួន |
|---|---|---|
| ១. ជ្រើសរើសគំនិតអាជីវកម្មរបស់អ្នក | | |
| ២. កំណត់គំនិតអាជីវកម្មរបស់អ្នក | | |
| ៣. កំណត់អតិថិជនគោលដៅរបស់អ្នក | | |
| ៤. សម្រេចចិត្តពីលក្ខណៈផលិតផលរបស់អ្នក (ពណ៌ ទំហំ គុណភាព) | | |
| ៥. ជ្រើសរើសទីតាំង | | |
| ៦.ជ្រើសរើសយុទ្ធសាស្ត្រផ្សាយពាណិជ្ជកម្ម និងផែនការជំរុញការលក់របស់អ្នក | | |

| | | |
|---|---|---|
| ៧. ដឹងពីតម្លៃរបស់គូប្រកួតប្រជែង | | |
| ៨. ដឹងពីតម្លៃដែលអតិថិជនហ៊ានទិញ | | |
| ៩.ប៉ាន់ស្មានចំណាយលើវត្ថុធាតុដើម គ្រឿងបរិក្ខារ កម្លាំងពលកម្ម និងចំណាយទូទៅ | | |
| ១០. សម្រេចយកកត្តាកំណត់ជោគជ័យក្នុងអាជីវកម្មរបស់អ្នក | | |

ចូរជ្រើសរើសសមាជិកក្រុមម្នាក់ឱ្យធ្វើជា "អ្នកអានក្នុងក្រុម" ដើម្បីអានខ្លឹមសារក្នុង សៀវភៅមេរៀន ឱ្យលឺៗដល់សមាជិកក្រុម។

## សកម្មភាព៧ខ ៖ ផែនការអាជីវកម្មសង្ខេបរបស់ខ្ញុំ

មេរៀននេះ បានជួយអ្នកក្នុងការសម្រេចថាតើអាជីវកម្មប្រភេទណាដែលអ្នកចង់ចាប់ផ្តើម។ នៅក្នុងសកម្មភាពនេះ យើងនឹងសង្ខេបឡើងវិញនូវអ្វីដែលយើងបានរៀន និងបានសម្រេចចិត្តទៅលើអាជីវកម្មរបស់យើង តាមសកម្មភាពគ្រប់ជំហានទាំងអស់នៃមេរៀននេះ។

### ការណែនាំសម្រាប់ការធ្វើសកម្មភាព

១. ស្តាប់អ្នកអានក្នុងក្រុម អានពីជំហាននីមួយៗក្នុងតារាង រៀបចំផែនការអាជីវកម្ម ខាងក្រោមតារាង ៧.២។

២. ធ្វើការរៀងខ្លួន សរសេរនូវផែនការដែលអ្នកមានសម្រាប់អាជីវកម្មរបស់អ្នកគ្រប់ផ្នែកទាំងអស់ដែលបានរៀបរាប់ក្នុងតារាងខាងក្រោម។ បន្ទាប់មកឆ្លាស់វេនគ្នាម្នាក់ម្តងៗ ចែករំលែកផែនការអាជីវកម្មជាមួយសមាជិកក្នុងក្រុម ។

តារាង៧.២ផែនការអាជីវកម្ម

| |
|---|
| គំនិតអាជីវកម្មរបស់ខ្ញុំ<br>**សរសេរការពិពណ៌នាខ្លីមួយ ដែលរៀបរាប់អំពីអ្វីដែលអាជីវកម្មរបស់អ្នកនឹងធ្វើ និងផលិតផលឬសេវាកម្មដែលអ្នកនឹងលក់។** |
| |
| ធនធានដែលខ្ញុំមាន |

| |
|---|
| **តើជំនាញនិងធនធានអ្វីខ្លះដែលអ្នកមានដើម្បីដំណើរការអាជីវកម្មរបស់អ្នក?** |
| |
| អតិថិជនរបស់ខ្ញុំ<br>**តើអ្នកបានកំណត់ហើយ ឬនៅថានរណានឹងក្លាយជាអតិជនគោលដៅរបស់អ្នក?** |
| |
| ផែនការទីផ្សាររបស់ខ្ញុំ<br>**តើយុទ្ធសាស្ត្រទីផ្សារអ្វីខ្លះ ដែលអ្នកនឹងប្រើប្រាស់សម្រាប់រកទីផ្សារឱ្យផលិតផល ឬសេវាកម្មរបស់អ្នក?** |
| |
| ការកំណត់តម្លៃរបស់ខ្ញុំ<br>**តើផលិតផល ឬសេវាកម្មរបស់អ្នកនឹងត្រូវចំណាយថ្លៃដើមអស់ប៉ុន្មាន? តើគូប្រជែងរបស់អ្នកលក់ផលិតផលស្រដៀងគ្នានឹងរបស់អ្នកក្នុងតម្លៃប៉ុន្មាន? តើតម្លៃប៉ុន្មាន ដែលអតិថិជនរបស់អ្នកហ៊ានចំណាយ?** |
| |
| ការចំណាយរបស់ខ្ញុំ<br>**តើអាជីវកម្មរបស់អ្នកត្រូវចំណាយប៉ុន្មាន? គិតអំពីការចំណាយថេរ និងចំណាយអថេរសម្រាប់អាជីវកម្មរបស់អ្នក។** |
| |

| |
|---|
| កត្តាកំណត់ជោគជ័យក្នុងអាជីវកម្មរបស់អ្នក<br>**តើអ្វីជាកត្តាកំណត់ជោគជ័យក្នុងអាជីវកម្មរបស់អ្នក? តើអ្នកនឹងចាត់វិធានការអ្វីខ្លះដើម្បីធានាថាអាជីវកម្មរបស់អ្នកនឹងទទួលជោគជ័យ?** |
| |

៤.៥. ការវាយតម្លៃសមត្ថភាព

សំនួរពិភាក្សា

- ចូរកំណត់ជ្រើសរើសអាជីវកម្ម។
- ក្រុមពិភាក្សាកំណត់គំណិតអាជីវកម្ម និងអតិថិជនគោលដៅ។
- ចូរកំណត់បង្កើតផែនការទីផ្សាររបស់អាជីវកម្ម និងកំណត់ថ្លៃ។
- ចូរបង្ហាញពីការពិភាក្សាកំណត់ពីភាពជោគជ័យក្នុងអាជីវកម្មបែបគ្រួសារ។
- បទបង្ហាញជាក្រុមពីផែនការសកម្មភាពរបស់អាជីវកម្មងាយៗ។

**មេរៀនទី៦**

# មូលដ្ឋានគ្រឹះនៃច្បាប់ស្តីពីការងារ

## ១. លក្ខខណ្ឌទូទៅនៃការងារ

### ១.១. បែបបទសហគ្រាស

#### ១.១.១. សហគ្រាស គ្រឹះស្ថាន

នៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ យើងឃើញមានរំលេចនូវអត្តសញ្ញាណនៃតួអង្គផ្សេងៗគ្នា ដូចជានិយោជក សហគ្រាស/គ្រឹះស្ថាន កម្មករនិយោជិត និងតួអង្គដទៃផ្សេងទៀត។ តួអង្គទាំងនេះដើរតួនាទីខុសៗគ្នា និងមានសារៈសំខាន់ក្នុងការចូលរួមកំណត់នូវអត្តសញ្ញាណនៃទំនាក់ទំនងការងារបម្រើឱ្យមុខសញ្ញានៃការអនុវត្តច្បាប់។ ដោយឡែកសហគ្រាស គ្រឹះស្ថាន ដែលសំដៅដល់តួអង្គនិយោជក គឺជាសញ្ញាណមួយដែលគេឃើញមានកំណត់នៅក្នុងច្បាប់ស្តីពីការងារផង និងច្បាប់ពាក់ព័ន្ធក្នុងវិស័យធុរកិច្ចផងដែលអធិការការងារត្រូវស្វែងយល់ឱ្យបានច្បាស់អំពីទំនាក់ទំនងនៃសញ្ញាណនេះ នៅក្នុងច្បាប់ពាក់ព័ន្ធទាំងអស់ ដើម្បីជាចំណេះដឹងចាំបាច់មួយបម្រើឱ្យការត្រួតពិនិត្យអនុលោមភាពរបស់ភាគីពាក់ព័ន្ធ នៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ ជាពិសេសតួអង្គនិយោជក ដែលអធិការត្រូវដឹង និងស្គាល់ឱ្យបានច្បាស់អំពីសមាសភាព និងចរិតលក្ខណៈនៃតួអង្គនេះ។

ក្នុងក្របខណ្ឌច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រុមហ៊ុននៅក្នុងន័យនៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ជាទូទៅគឺជាប្រភេទមួយនៃតួអង្គនិយោជកក្នុងន័យនៃច្បាប់ស្តីពីការងារ។ ដោយឈរលើមូលដ្ឋាននៃការទទួលខុសត្រូវ ក្រុមហ៊ុនត្រូវបានបែងចែកជា២ប្រភេទ គឺក្រុមហ៊ុនទទួលខុសត្រូវគ្មានកម្រិតដែលហៅថាក្រុមហ៊ុនសហកម្មសិទ្ធ និងក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតដែលហៅថាក្រុមហ៊ុនមូលធន។ ក្រុមហ៊ុនសហកម្មសិទ្ធិមាន ២ប្រភេទ គឺក្រុមហ៊ុនសហកម្មសិទ្ធទូទៅ និងសហកម្មសិទ្ធទទួលខុសត្រូវមានកម្រិត។ ក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត មានពីរប្រភេទគឺ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

ក្នុងក្របខណ្ឌច្បាប់ស្តីពីការងារ មាត្រា១ នៃច្បាប់ស្តីពីការងារចែងថា “*ច្បាប់នេះគ្រប់គ្រងរាល់ទំនាក់ទំនង ដែលកើតចេញពីកិច្ចសន្យាការងារ រវាងនិយោជក និងកម្មករនិយោជិត ដើម្បីយកមកអនុវត្តលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ទោះបីកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយ ទោះបីភាគីទាំងនោះមានសញ្ជាតិជាអ្វីហើយស្នាក់នៅទីណាក៏ដោយ*”។

មាត្រា២ នៃច្បាប់ស្តីពីការងារក៏បានចែងផងដែរថា រូបវន្តបុគ្គល ឬនីតិបុគ្គលជាសាធារណៈ ឬឯកជនទាំងអស់នឹងត្រូវចាត់ទុកជានិយោជកដែលបង្កើតសហគ្រាសតាមន័យនៃច្បាប់នេះ លុះត្រាតែបុគ្គលទាំងនោះមានប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះមិនបានជាប់លាប់ក៏ដោយ។ ក្នុងន័យនេះ យើងអាចនិយាយបានថា និយោជក គឺសំដៅលើបុគ្គលដែលមានប្រើប្រាស់កម្មករនិយោជិតចាប់ពីមួយនាក់ឡើងទៅ (មានទំនាក់ទំនងការងារ) ទោះបុគ្គលនោះមិនបានចុះបញ្ជី ឬធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសក៏ដោយ។

ដោយឡែកមាត្រា៣ នៃច្បាប់ស្តីពីការងារបានកំណត់និយមន័យរបស់កម្មករនិយោជិតយ៉ាងច្បាស់លាស់ ដោយបានចែងអំពីលក្ខណៈវិនិច្ឆ័យថា កម្មករនិយោជិត តាមន័យនៃច្បាប់នេះ គឺជនគ្រប់ប្រភេទ និងគ្រប់សញ្ជាតិដែលបានចុះកិច្ចសន្យាធ្វើការយកកម្រៃក្រោមការដឹកនាំ បង្គាប់បញ្ជារបស់បុគ្គលម្នាក់ទៀត ដែលហៅថានិយោជក។

សូមបញ្ជាក់ផងដែរថា តាមន័យនៃច្បាប់ស្តីពីការងារ យើងឃើញថាសញ្ញាណនៃសហគ្រាស គ្រឹះស្ថានមានលក្ខណៈទូលាយ មានន័យថាក្រៅពីសហគ្រាសពាណិជ្ជកម្ម និយោជកក្នុងន័យនៃច្បាប់ស្តីពីការងារអាចជារូបវន្តបុគ្គល និងនីតិបុគ្គលដទៃទៀតដែលមិនមែនជាពាណិជ្ជករ ដូចជា សមាគម អង្គការ ស្ថាប័នឯកជន និងសាធារណៈ ដទៃទៀត។

### ១.១.២. សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស

មាត្រា១៧ នៃច្បាប់ស្តីពីការងារបានចែងថា និយោជកទាំងអស់ដែលត្រូវអនុវត្តច្បាប់ស្តីពីការងារ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងទៅ ក្រសួងទទួលបន្ទុកវិស័យការងារ នៅពេលបើកសហគ្រាសគ្រឹះស្ថាន។ សេចក្តីប្រកាសជូនដំណឹងនេះហៅថាសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងដាក់ជូនទៅ ក្រសួងទទួលបន្ទុកវិស័យការងារ នៅមុនពេលបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ។ ប្រកាសលេខ២៨៨ សកបយ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីសេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន បានកំណត់អំពីបែបបទ និងនីតិវិធីនៃការធ្វើសេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាសនេះ។

យោងតាមច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គឺជាការបញ្ជាក់ព័ត៌មានរបស់សហគ្រាស គ្រឹះស្ថាន ដូចជា កាលបរិច្ឆេទបង្កើតការប្រើប្រាស់កម្លាំងពលកម្ម ចំនួនម៉ោងការងារ ដែលកម្មករនិយោជិតត្រូវបំពេញក្នុងមួយថ្ងៃ ឬមួយសប្តាហ៍ ប្រាក់ឈ្នួល រូបវន្តបុគ្គល ឬនីតិបុគ្គលនៃសហគ្រាស គ្រឹះស្ថាន។

សេចក្តីប្រកាសជូនដំណឹងនេះមានសារៈសំខាន់ណាស់សម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើការត្រួតពិនិត្យពីអនុលោមភាពរបស់សហគ្រាស គ្រឹះស្ថានទៅនឹងច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីរបបសន្តិសុខសង្គម និងបទបញ្ញត្តិដទៃទៀតនៃវិស័យការងារ។ ការក្តាប់បាននូវសណ្ឋាន ទ្រង់ទ្រាយ និងប្រភេទសហគ្រាស គ្រឹះស្ថាន គឺជាមូលដ្ឋានដែលឈានទៅការរក្សាបាននូវការគោរពនិងអនុវត្តច្បាប់ពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ការគ្រប់គ្រងបាននូវកម្លាំងពលកម្ម ចរន្តនៃទីផ្សារការងារ តម្រូវការនៃការអនុវត្ត ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ របបសន្តិសុខសង្គមរបស់កម្មករនិយោជិត និងការអនុវត្តនូវសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ។ ក្នុងករណីសហគ្រាស គ្រឹះស្ថានគ្មានសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស នឹងត្រូវទទួលការដាក់កំហិត និងរងការពិន័យ ដោយល្មើសនឹងមាត្រា១៧ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ ២៨៨ សកបយ ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០០១។

### ១.១.៣. សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

មាត្រា២០ នៃច្បាប់ស្តីពីការងារ បានចែងថា និយោជកត្រូវបើកប្រើ និងរក្សាទុកឱ្យបានត្រឹមត្រូវនូវសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានមួយ ដែលអធិការការងារបានចុះលេខរៀង និងចុះហត្ថលេខាសង្ខេប។ សៀវភៅនេះត្រូវចេញដោយអធិការការងារសម្រាប់កត់ត្រានូវកំណត់សម្គាល់ របស់អធិការការងារនៅពេលចុះធ្វើអធិការកិច្ចការងារ។ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថានមានមុខងារសំខាន់ សម្រាប់មន្ត្រីអធិការការងារធ្វើការ

តាមដានស្ថានភាពក៏ដូចជាវឌ្ឍនភាពនៃការអនុវត្តច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនិងវិស័យការងាររបស់សហគ្រាសគ្រឹះស្ថាន ដើម្បីធានាថានិយោជក មិនមានការរំលោភបំពានលក្ខខណ្ឌការងារ និងសិទ្ធិសេរីភាពក៏ដូចជាផលប្រយោជន៍ស្របច្បាប់របស់កម្មករ និយោជិត។

សៀវភៅនេះមានសុពលភាពជាអចិន្ត្រៃយ៍ ហើយក្នុងករណីប្រើប្រាស់គ្រប់ទំព័រ ឬបាត់មិនអាចប្រើប្រាស់បានត្រូវរៀបចំឡើងវិញ។ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន ដែលបានប្រើប្រាស់គ្រប់ទំព័រទាំងអស់ហើយ និយោជកត្រូវថែរក្សាទុកឱ្យគង់វង្សក្នុងរយៈពេល ៣ឆ្នាំ។ អធិការការងារ ឬអភិបាលការងារអាចទាររកសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានបានគ្រប់ពេលវេលា។ ក្នុងករណី គ្មានសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន ដែលបានចុះបញ្ជិកា សហគ្រាស គ្រឹះស្ថាន ត្រូវទទួល ការដាក់កំហិត និងរងការពិន័យ ដោយល្មើសនឹងមាត្រា២០ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ ២៦៨ សកបយ ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០០១។

### ១.១.៤. សៀវភៅបើកប្រាក់ ឬបញ្ជីបើកប្រាក់ឈ្នួល

មាត្រា៣៩ នៃច្បាប់ស្តីពីការងារបានចែងថា និយោជកត្រូវកាន់ដោយទៀងទាត់ជាដរាបនូវសៀវភៅបើកប្រាក់មួយដែលមានគំរូ និងកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។ មុននឹងយកទៅប្រើ សៀវភៅបើកប្រាក់ត្រូវមានចុះលេខគ្រប់ទំព័រ និងចុះហត្ថលេខា សង្ខេបដោយអធិការការងារ។ សៀវភៅបើកប្រាក់ គឺជាបញ្ជីកត់ត្រាព័ត៌មាន កម្មករនិយោជិតនៅក្នុងសហគ្រាស លក្ខណៈសម្គាល់អំពីការងារដែលបានធ្វើ អំពីប្រាក់ឈ្នួល ការឈប់សម្រាក និងអត្ថប្រយោជន៍ផ្សេងៗដែលកម្មករនិយោជិតម្នាក់ៗត្រូវទទួលបាន និងត្រូវបើកពីនិយោជក។ សៀវភៅបើកប្រាក់នេះ នឹងទុកជាត្រឹមត្រូវបាន លុះត្រាមានចុះលេខទំព័រ និងចុះហត្ថលេខា សង្ខេបគ្រប់ទំព័រដោយអធិការការងារ។ សៀវភៅបើកប្រាក់ និយោជក ត្រូវមាន កាតព្វកិច្ចរក្សាឱ្យគង់វង្សក្នុង រយៈពេល៣ឆ្នាំ។

មាត្រា៤១ នៃច្បាប់ស្តីពីការងារក៏បានចែងផងដែរថា និយោជកសហគ្រាស គ្រឹះស្ថានណាដែលចង់ធ្វើសៀវភៅបើកប្រាក់តាមរបៀបផ្សេងពីនេះត្រូវមានចុះព័ត៌មាន និងបែបបទដូចមានចែងក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសលេខ២៦៩ សកបយ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ស្តីពីការបង្កើតសៀវភៅបើកប្រាក់។

សៀវភៅបើកប្រាក់មានសារៈសំខាន់ដែលត្រូវត្រួតពិនិត្យ និងចេញដោយអធិការការងារដើម្បីត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តរបស់សហគ្រាសគ្រឹះស្ថានទៅនឹង៖

- ច្បាប់ស្តីពីការងារ (ភាពត្រឹមត្រូវនៃអត្តសញ្ញាណប្រាក់ឈ្នួល ចំនួនថ្ងៃធ្វើការសម្រាប់ការទទួលបានប្រាក់ឈ្នួល ការគណនាប្រាក់ឈ្នួលពេលធ្វើការបន្ថែមម៉ោងនៅពេលថ្ងៃនិងពេលយប់ ឬនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ប្រាក់ឈ្នួលសម្រាប់ការងារ ដែលបានបំពេញក្នុងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ប្រាក់លំហែរមាតុភាព។ល។)
- ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា (ការធានានូវការអនុវត្តប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងទៀតដែលត្រូវបានកំណត់ក្នុងក្របខណ្ឌជាមួយគ្នា)។
- ច្បាប់ស្តីពីរបបសន្តិសុខសង្គម (ការកំណត់អត្រាភាគទានដែលត្រូវកាត់ពីនិយោជក ឬកម្មករនិយោជិតទៅក្នុងរបបសន្តិសុខសង្គម)។

ក្នុងករណី គ្មានសៀវភៅបញ្ជីបើកប្រាក់ ឬមានសៀវភៅបើកប្រាក់តែគ្មានបញ្ជិកា សហគ្រាស គ្រឹះស្ថាន ត្រូវទទួលការដាក់កំហិត និងវងការពិន័យ ដោយល្មើសនឹងមាត្រា៣៩នៃច្បាប់ស្តីពីការងារ និង ប្រកាសលេខ ២៦៩ សកបយ ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០០១។

**១.៥. បទបញ្ជាផ្ទៃក្នុង**

មាត្រា២២ នៃច្បាប់ស្តីពីការងារបានចែងថា និយោជកនៃសហគ្រាស ឬគ្រឹះស្ថានដែលមានកម្មករនិយោជិតយ៉ាងតិចប្រាំបីនាក់ ត្រូវតែរៀបចំឱ្យមានបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសមួយជាដរាប។ មាត្រា២៤ នៃច្បាប់ស្តីពីការងារ បានកំណត់ផងដែរថា បទបញ្ជាផ្ទៃក្នុង មុននឹងដាក់ឱ្យប្រើត្រូវតែទទួលទិដ្ឋាការអំពីអធិការការងារជាមុន។

បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន គឺជាបទប្បញ្ញត្តិទាក់ទងនឹងលក្ខខណ្ឌទទួលធ្វើការ ការគិត និងការបើកប្រាក់ឈ្នួល ពេលម៉ោងធ្វើការ ការឈប់សម្រាក ការជូនដំណឹងមុន វិធានការអនាម័យ និងសន្តិសុខ កាតព្វកិច្ច និងទណ្ឌកម្មដែលនឹងអាចតម្រូវលើកម្មករនិយោជិត។ បទបញ្ជាផ្ទៃក្នុង ត្រូវតែរៀបចំដោយនាយកសហគ្រាស គ្រឹះស្ថាន ក្រោយពីបានពិគ្រោះយោបល់នឹងតំណាងកម្មករនិយោជិតក្នុងរយៈពេល ៣ខែ បន្ទាប់ពីថ្ងៃបើកសហគ្រាស។ ត្រូវអនុវត្តបទបញ្ជាផ្ទៃក្នុងឱ្យស្របទៅតាមបទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីពីការងារដែលមានលក្ខខណ្ឌដូចខាងក្រោម ៖

- លក្ខខណ្ឌនៃការជ្រើសឱ្យចូលបម្រើការងារ
- ម៉ោងពេលការងារ
- ការអនុវត្តវិធានការវិន័យ
- ប្រភេទនៃទណ្ឌកម្មវិន័យដែលត្រូវអនុវត្ត
- លក្ខខណ្ឌនៃការឈប់សម្រាកប្រចាំសប្តាហ៍
- ការឈប់សម្រាកប្រចាំឆ្នាំ
- ការបើក និងការកាត់ប្រាក់ឈ្នួល
- លក្ខខណ្ឌនៃការបញ្ឈប់កម្មករនិយោជិតពីការងារ
- លក្ខខណ្ឌស្តីពីសុខសុវត្ថិភាពនៅកន្លែងការងារ។ល។

បទបញ្ជាផ្ទៃក្នុង មានតម្លៃដូចគ្នានឹងច្បាប់ដែលត្រូវអនុវត្តនៅក្នុងសហគ្រាស គ្រឹះស្ថាន។ បទបញ្ជាផ្ទៃក្នុងត្រូវមានការត្រួតពិនិត្យយ៉ាងល្អិតល្អន់ និងយកចិត្តទុកដាក់អំពីអនុលោមភាពនៃបទបញ្ជានេះ ទៅនឹងច្បាប់ស្តីពីការងារ ក៏ដូចជាបទដ្ឋានពាក់ព័ន្ធដទៃផ្សេងទៀត ដែលកិច្ចការនេះត្រូវតែអនុវត្ត និងផ្តល់ទិដ្ឋាការដោយមន្ត្រីអធិការការងារ។ ការធេកល្វែងក្នុងការត្រួតពិនិត្យប្រការណាមួយនៃបទបញ្ជាផ្ទៃក្នុងនឹងអនុញ្ញាតឱ្យនិយោជក ដែលមានចេតនាទុច្ចរិតឆ្លៀតឱកាសរំលោភបំពានមកលើសិទ្ធិ និងសេរីភាពរបស់កម្មករនិយោជិត។

ក្នុងករណី គ្មានបទបញ្ជាផ្ទៃក្នុងដែលបានចុះទិដ្ឋាការ សហគ្រាស គ្រឹះស្ថាន ត្រូវទទួលការដាក់កំហិត និងវងការពិន័យ ដោយល្មើសនឹងមាត្រា២២ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ ២៦៩ សកបយ ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០០១។

## ១.៦. សៀវភៅការងារ

### ១.៦.១. និយមន័យ

សៀវភៅការងារជនកម្ពុជា ឬសៀវភៅការងារកម្មករនិយោជិតខ្មែរ គឺជាសៀវភៅដែលកត់ត្រាពីអត្តសញ្ញាណរបស់កម្មករនិយោជិត និងព័ត៌មានសង្ខេបអំពីប្រវត្តិការងាររបស់កម្មករនិយោជិតដូចជា សហគ្រាស គ្រឹះស្ថានដែលកម្មករនិយោជិតធ្លាប់ធ្វើការ តួនាទី ថ្ងៃខែចូលបម្រើការងារ និងលាឈប់ពីការងារ ប្រាក់ឈ្នួលជាដើម។

### ១.៦.២. វិធាន

- ជនដែលមានសញ្ជាតិខ្មែរធ្វើការយកឈ្នួលពីនិយោជកណាមួយ ត្រូវតែមានសៀវភៅការងារ។ ជនណាក៏ដោយ មិនអាចប្រើកម្មករនិយោជិត ដែលមិនប្រតិបត្តិតាមបទប្បញ្ញត្តិ នៃកថាខណ្ឌខាងលើនេះបានទេ។ ចំពោះកម្មករដែលធ្វើការយកឈ្នួលតាមរដូវក្នុងចម្ការអាចមានសៀវភៅការងារ ឬគ្មានក៏បាន។
- សៀវភៅការងារ សម្រាប់សំគាល់អត្តសញ្ញណសាមីខ្លួន។ ប្រភេទការងារដែលជននេះបានចុះកិច្ចសន្យាធ្វើ ចិរវេលានៃកិច្ចសន្យា ប្រាក់ឈ្នួលដែលបានព្រមព្រៀងគ្នា និងរបៀបបើកប្រាក់ឈ្នួលនេះ ព្រមទាំងការចុះកិច្ចសន្យាបន្តៗមកទៀត។
- សៀវភៅការងារនេះ ធ្វើដោយអធិការការងារ និងចេញឱ្យតាមសេចក្តីស្នើសុំរបស់កម្មករនិយោជិតដោយបង្ហាញលិខិតអត្តសញ្ញាណប័ណ្ណ ដែលអាជ្ញាធរមានសមត្ថកិច្ចចេញឱ្យ និងវិញ្ញាបនបត្រមុខរបរ ដែលនិយោជកខ្លួនចេញឱ្យ។
- នៅពេលជាមួយគ្នានឹងការចេញសៀវភៅការងារ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីខេត្តនីមួយៗក៏មានចេញជូនសាមីជនកម្មករនិយោជិតផងដែរនូវ«ប័ណ្ណសម្គាល់កម្មករនិយោជិតខ្មែរ»។
- នៅពេលដែលមានការផ្លាស់ប្តូរមុខងារ និងប្រាក់ឈ្នួលរបស់កម្មករនិយោជិតម្តងៗ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវកត់ត្រាក្នុងសៀវភៅការងាររបស់សាមីខ្លួន និងយកសៀវភៅការងារទៅចុះទិដ្ឋាការឱ្យបានត្រឹមត្រូវ ដូចពេលចូលធ្វើការងារ ឬឈប់ពីការងារផងដែរ។
- នៅពេលដែលកម្មករនិយោជិតឈប់ពីការងារ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវប្រគល់សៀវភៅការងារជូនសាមីជនកម្មករនិយោជិតវិញ។
- មិនត្រូវយកសៀវភៅការងាររបស់កម្មករនិយោជិត ទៅប្រើប្រាស់ខុសពីគោលដៅ នៃការបង្កើតសៀវភៅនេះទេ។
- កាលណាកម្មករនិយោជិតឈប់ធ្វើការឱ្យនិយោជក និយោជកនោះមិនត្រូវចារមូលវិចារអ្វីលើសៀវភៅការងារនេះទេ។
- ការបាត់សៀវភៅការងារត្រូវតែប្តឹងទៅអធិការដ្ឋានការងារ។ ទុតិយតា អាចនឹងចេញឱ្យបានក្នុងលក្ខខណ្ឌដូចគ្នានឹងការចេញសៀវភៅការងារដែរ។

## ២. ១. ប្រាក់ឈ្នួល

### ២.១.១. សញ្ញាណទូទៅនៃប្រាក់ឈ្នួល

យោងតាមមាត្រា៣នៃច្បាប់ស្តីពីការងារ បានបញ្ញត្តថា "កម្មករនិយោជិត តាមន័យនៃច្បាប់នេះ គឺជនគ្រប់ប្រភេទ និងគ្រប់សញ្ជាតិដែលបានចុះកិច្ចសន្យាធ្វើការយកកម្រៃក្រោមការដឹកនាំ និងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀតជារូបវន្តបុគ្គលឬនីតិបុគ្គលជាសាធារណៈឬឯកជន។ [...]"។ តាមន័យនេះ ប្រាក់ឈ្នួល (កម្រៃ) គឺជាធាតុផ្សំមួយយ៉ាងសំខាន់ក្នុងការកំណត់ទំនាក់ទំនងវិជ្ជាជីវៈរបស់កម្មករនិយោជិត និងនិយោជក។ យោងលើខ្លឹមសារនៃមាត្រាដដែលនេះ បានកំណត់ផងដែរថា ចំនួនប្រាក់ឈ្នួលតិចឬច្រើន គឺមិនមែនជាលក្ខខណ្ឌក្នុងការបញ្ជាក់លក្ខណៈសម្បត្តិនៃកម្មករនិយោជិតឡើយ។ ដូចនេះយើងអាចនិយាបានថាការកំណត់សញ្ញាណនៃប្រាក់ឈ្នួលគឺយើងមិនគិតទៅលើចំនួនរបស់វានោះទេ ពោលគឺចំនួន១០០រៀល ក៏អាចត្រូវចាត់ទុកថាជាប្រាក់ឈ្នួលបានដែរ។

ច្បាប់ស្តីពីការងារ ត្រង់មាត្រា១០២ បានកំណត់និយមន័យប្រាក់ឈ្នួលថា គឺជាឈ្នួលការងារ ឬឈ្នួលសេវាដែលអាចគិតជាប្រាក់បាន ឬកម្រិតបានដោយការព្រមព្រៀងគ្នាឬដោយច្បាប់ជាតិ ហើយដែលនិយោជកត្រូវបើកឱ្យកម្មករនិយោជិតតាមកិច្ចសន្យាជួលការងារ ឬសេវាដោយលាយលក្ខណ៍អក្សរ ឬដោយមាត់ទទេ ទោះចំពោះការងារដែលបានធ្វើក្តីឬដែលត្រូវធ្វើក្តី ចំពោះសេវាដែលបានបំពេញ ឬត្រូវបំពេញក្តី។

យោងតាមមាត្រា១០៣ នៃច្បាប់ស្តីពីការងារ

▪ ប្រាក់ឈ្នួលមានជាអាទិ៍ ដូចតទៅ៖

- ប្រាក់ឈ្នួលសុទ្ធសាធ
- ប្រាក់ម៉ោងបន្ថែម
- កម្រៃជើងសា
- បុព្វលាភនិងប្រាក់បំណាច់
- ភាគកម្មក្នុងប្រាក់ចំណេញ
- ប្រាក់ដែលបើកជារង្វាន់
- តម្លៃអត្ថប្រយោជន៍ជាវត្ថុ
- វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់
- វិភាជន៍សម្រាប់ការឈប់សម្រាក ឬបំណាច់សម្រាប់ទូទាត់ការឈប់សម្រាក
- ចំនួនប្រាក់ដែលនិយោជកត្រូវផ្តល់ឱ្យក្នុងពេលបាត់បង់សមត្ថភាពពលកម្មនិងក្នុងពេលលំហែមាតុភាព។

▪ មិនត្រូវរាប់បញ្ចូលជាមួយប្រាក់ឈ្នួល៖

- ការព្យាបាលសុខភាព
- វិភាជន៍គ្រួសារតាមច្បាប់
- សោហ៊ុយធ្វើដំណើរ
- អត្ថប្រយោជន៍ដែលផ្តល់ឱ្យជាពិសេសចំពោះកម្មករនិយោជិតដើម្បីសម្រួលការបំពេញមុខងារ។

តាមបញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រង់មាត្រា១០៣ យើងអាចសម្គាល់បានថា ប្រាក់ឈ្នួល គឺត្រូវរាប់បញ្ចូលទាំងប្រាក់ឈ្នួលសុទ្ធសាធ និងធាតុផ្សំបន្ទាប់បន្សំរបស់ប្រាក់ឈ្នួល ដែលយើងអាចកំណត់និយមន័យបានដូចខាងក្រោម៖

❖ **ប្រាក់ឈ្នួលសុទ្ធសាធ (ប្រាក់ឈ្នួលមូលដ្ឋាន ឬប្រាក់ឈ្នួលគោល)** ត្រូវបានផ្តល់និយមន័យថា ជាកម្រៃដែលកម្មករនិយោជិតបានទទួលតាមរយៈការព្រមព្រៀងជាមួយនិយោជករបស់ខ្លួន ជាថ្នូរនឹងការបំពេញការងារ ឬសេវារបស់ខ្លួន។ ប្រាក់ឈ្នួលសុទ្ធសាធនេះ គឺជាកម្រៃដែលមានកំណត់ក្នុងកិច្ចសន្យាការងារ ទោះដោយលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក្តី ហើយដែលគេនិយមហៅថាប្រាក់ឈ្នួលគោល ឬប្រាក់ឈ្នួលមូលដ្ឋាន។ ប្រាក់ឈ្នួលសុទ្ធសាធនេះ គឺជាប្រាក់ឈ្នួលដែលមិនទាន់ត្រូវបានកាត់ពន្ធ។ ចំពោះសហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ប្រាក់ឈ្នួលសុទ្ធសាធនេះ មិនអាចមានចំនួនតិចជាងប្រាក់ឈ្នួលអប្បបរមា ដែលត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្រ្តីក្រសួងទទួលបន្ទុកវិស័យការងារនោះទេ។

❖ **ធាតុផ្សំនៃប្រាក់ឈ្នួល** គឺជាប្រាក់ឈ្នួលដែលនិយោជកអាចផ្តល់ឱ្យកម្មករនិយោជិតរបស់ខ្លួន បន្ថែមលើប្រាក់ឈ្នួលសុទ្ធសាធ។ យោងមាត្រា១០៣ នៃច្បាប់ស្តីពីការងារ ធាតុផ្សំនៃប្រាក់ឈ្នួលទាំងនោះមានក្នុងតារាងដូចខាងក្រោម ៖

| ល.រ | ធាតុផ្សំនៃប្រាក់ឈ្នួល | និយមន័យ |
|---|---|---|
| ១ | ប្រាក់ម៉ោងបន្ថែម | ប្រាក់ដែលទទួលបានលើសពីប្រាក់ឈ្នួលដែលបានធ្វើការរយៈពេល៨ម៉ោង/ថ្ងៃ។ |
| ២ | កម្រៃជើងសា | កម្រៃដែលបានដោយសារការនាំពាក្យត្រឡប់សាចុះសាឡើងពីខាងនេះទៅខាងនោះ។ |
| ៣ | បុព្វលាភនិងប្រាក់បំណាច់ | រង្វាន់។ |
| ៤ | ភាគកម្មក្នុងប្រាក់ចំណេញ | ចំណែកនៃប្រាក់ចំណេញដែលត្រូវបែងចែកឱ្យកម្មករនិយោជិត។ |
| ៥ | ប្រាក់ដែលបើកជារង្វាន់ | ប្រាក់ដែលនិយោជកផ្តល់ជូនកម្មករនិយោជិតជារង្វាន់ដូចជា៖ ប្រាក់រង្វាន់ធ្វើការទៀងទាត់ ប្រាក់រង្វាន់អតីតភាពការងារ..។ល។ |
| ៦ | តម្លៃអត្ថប្រយោជន៍ជាវត្ថុ | មានដូចជាផ្តល់ម៉ាស់ ស្រោមដៃ សម្លៀកបំពាក់ កន្សែងជូតក្បាល អង្ករ គ្រឿងឧបភោគបរិភោគ។ |
| ៧ | វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់ | ក្រសួងមិនទាន់បានកំណត់។ |
| ៨ | វិភាជន៍សម្រាប់ការឈប់សម្រាក ឬបំណាច់សម្រាប់ទូទាត់ការឈប់សម្រាក | ប្រាក់រង្វាន់ឬកម្រៃដែលផ្តល់ជូនកម្មករនិយោជិតសម្រាប់ការទូទាត់ជួសឱ្យការឈប់សម្រាក។ឧទាហរណ៍៖ ប្រាក់បំណាច់ |

| | | |
|---|---|---|
| | | ជួសឱ្យការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ ដែលផ្តល់ជូននៅពេលបញ្ចប់កិច្ចសន្យាការងារ។ |
| ៩ | ចំនួនប្រាក់ដែលនិយោជកត្រូវផ្តល់ឱ្យក្នុងពេលបាត់បង់សមត្ថភាពពលកម្ម និងក្នុងពេលលំហែមាតុភាព | អនុវត្តតាមប្រកាសរបស់ក្រសួង(បសស)។ |

មាត្រា១០៣ នៃច្បាប់ស្តីពីការងារក៏បានបញ្ជាក់ផងដែរអំពីប្រភេទអត្ថប្រយោជន៍ ឬប្រាក់មួយចំនួនដែលមិនត្រូវរាប់បញ្ចូលជាមួយប្រាក់ឈ្នួល ដែលមានក្នុងតារាងខាងក្រោម៖

| **ល.រ** | **មិនរាប់បញ្ចូលជាមួយប្រាក់ឈ្នួល** | **និយមន័យ** |
|---|---|---|
| ១ | ប្រាក់ព្យាបាលសុខភាព | មានកំណត់ក្នុងប្រកាសរបស់ក្រសួង(បសស)។ |
| ២ | វិភាជន៍គ្រួសារតាមច្បាប់ | ក្រសួងមិនទាន់បានកំណត់។ |
| ៣ | សោហ៊ុយធ្វើដំណើរ | គឺកម្រៃដែលនិយោជកផ្តល់ជូនកម្មករនិយោជិតសម្រួលក្នុងការធ្វើដំណើរដើម្បីបំពេញការងារជូននិយោជក។ |
| ៤ | អត្ថប្រយោជន៍ដែលផ្តល់ឱ្យជាពិសេសចំពោះកម្មករនិយោជិត ដើម្បីសម្រួលការបំពេញមុខងារ | អត្ថប្រយោជន៍ជាវត្ថុឬជាសាច់ប្រាក់ដែលផ្តល់ជូនកម្មករនិយោជិតសម្រាប់សម្រួលការបំពេញការងារណាមួយជាកំណត់។ ឧទាហរណ៍៖ កាតទូរស័ព្ទ, កាតសាំង ឬប្រាក់ថ្លៃសាំង...។ |

### ២.១.២. ប្រាក់ឈ្នួលអប្បបរមា

មាត្រា៤ នៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា បានបញ្ញត្តថា " *ប្រាក់ឈ្នួលយ៉ាងតិចណាស់ក៏ត្រូវឱ្យស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលជាប្រាក់ឈ្នួលកម្រិតទាបបំផុត និងត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ* "។ តាមន័យនេះ យើងអាចកំណត់និយមន័យប្រាក់ឈ្នួលអប្បបរមា គឺជាប្រាក់ឈ្នួលកម្រិតទាបបំផុត និងត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។ បន្ថែមលើនេះ យោងតាមច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមានេះ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវបានបង្កើតឡើងដើម្បីទទួលបេសកកម្មសិក្សាស្រាវជ្រាវអំពីប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិត ដែលតាមវិធានចាស់ បេសកកម្មនេះត្រូវបានផ្តល់ឱ្យគណៈកម្មការប្រឹក្សាការងារ។

### ២.១.៣. ប្រាក់ធនានុគ្រោះ

ប្រាក់ធនានុគ្រោះនេះ ត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា១៣៤ នៃច្បាប់ស្តីពីការងារ ។ ប្រាក់ធនានុគ្រោះនេះ គឺជាកម្រៃដែលអតិថិជនឱ្យទៅបុគ្គលិកនៃសហគ្រាសខ្លះ ភោជនាគារ ផ្ទះកាហ្វេ ផ្ទះលក់ភេសជ្ជៈ ផ្ទះកាត់សក់ជាដើម ហើយដែលនិយោជកបានទទួលជាភាគរយដែលត្រូវតែបន្ថែមលើកំណត់ទារប្រាក់ពីអតិថិជនក្រោមចំណារសម្គាល់ថា "សម្រាប់សេវា"។ ចំពោះប្រាក់ដែលមិនត្រូវបានបញ្ជាក់ក្នុងវិក័យបត្រ ហើយត្រូវបានអតិថិជនផ្តល់ឱ្យកម្មករនិយោជិតជារង្វាន់ នោះគឺមិនចាត់ទុកថាជាប្រាក់ធនានុគ្រោះទេ។

ប្រាក់ធនានុគ្រោះនេះ គឺជាធាតុផ្សំមួយនៃប្រាក់ឈ្នួលរបស់កម្មករនិយោជិត។ យោងលើខ្លឹមសារនៃមាត្រា១៣៤ ខាងលើនេះ និយោជកត្រូវប្រមូលប្រាក់ធនានុគ្រោះនេះ រួចហើយត្រូវបើកឱ្យបុគ្គលិកដែលទាក់ទងនឹងអតិថិជនវិញទាំងអស់។ យោងលើពាក្យ "បុគ្គលិកដែលទាក់ទងនឹងអតិថិជន" ដែលមានចែងក្នុងមាត្រាខាងលើនេះ គឺមានតែកម្មករនិយោជិតដែលបានបំពេញការងារដោយមានទំនាក់ទំនង ដោយផ្ទាល់ជាមួយនឹងអតិថិជនតែប៉ុណ្ណោះ ទើបមានសិទ្ធិទទួលបានប្រាក់ធនានុគ្រោះនេះ។ ការកំណត់បែបនេះ គឺអាចជាដើមហេតុមួយបង្កឱ្យមានការមិនស្មើភាពគ្នារវាងកម្មករនិយោជិត ដែលមានសិទ្ធិទទួលបានប្រាក់ធនានុគ្រោះនឹងកម្មករនិយោជិតដែលពុំមានសិទ្ធិទទួលបានប្រាក់ធនានុគ្រោះ។ ដំណោះស្រាយរបស់និយោជកមួយចំនួន គឺបានដំឡើងប្រាក់ឈ្នួល ឬផ្តល់ប្រាក់រង្វាន់ជូនកម្មករនិយោជិតដែលមិនមានសិទ្ធិទទួលបានប្រាក់ធនានុគ្រោះ ដើម្បីបង្ការករណីមានវិវាទជាយថាហេតុ។

យោងមាត្រា១៣៥ នៃច្បាប់ស្តីពីការងារបានកំណត់ថា និយោជកត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីការទទួល និងការប្រគល់ឱ្យបុគ្គលិកនូវប្រាក់ធនានុគ្រោះនេះ។ របៀបបែងចែកប្រាក់ធនានុគ្រោះ ប្រភេទបុគ្គលិកដែលត្រូវចូលរួមក្នុងការបែងចែកប្រាក់ធនានុគ្រោះនេះ ត្រូវកម្រិតតាមទំលាប់នៃវិជ្ជាជីវៈ ឬបើគ្មានទេត្រូវកម្រិតតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

### ២.១.៤. ប្រាក់បំណាច់អតីតភាពការងារ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច "គ" ផ្នែកទី៣ នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨។ ច្បាប់នេះ ត្រូវបានរៀបចំឡើងដើម្បីកែសម្រួលបញ្ញត្តមាត្រា៨៩ ស្តីពីការទូទាត់ប្រាក់បំណាច់បណ្តេញចេញ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីការងារ ដែលយោងតាមវិធានចាស់ទាំងនេះ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានមានកាតព្វកិច្ចទូទាត់ប្រាក់បំណាច់បណ្តេញចេញ ដោយផ្អែកលើអតីតភាពការងារ គឺនៅពេលបញ្ឈប់កម្មករនិយោជិត ឬនៅពេលរោងចក្រ សហគ្រាសក្ស័យធន តែប៉ុណ្ណោះ។

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការងារក្នុងឆ្នាំ២០១៨ និងប្រកាសលេខ៤៤៣ ក.ប/ប្រ.ក.ខ.ល ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ បានកំណត់អំពីប្រាក់បំណាច់អតីតភាពការងារ ដែលបានតម្រូវឱ្យនិយោជកធ្វើការទូទាត់ប្រាក់បំណាច់អតីតភាពការងារនេះជូនកម្មករនិយោជិតជារៀងរាល់ ៦ខែម្តង។ សូមបញ្ជាក់ផងដែរថា ប្រាក់បំណាច់អតីតភាពការងារនេះ គឺត្រូវអនុវត្តទៅលើតែកម្មករនិយោជិតដែលកំពុងបម្រើការងារ ហើយកំពុងប្រើប្រាស់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់តែប៉ុណ្ណោះ។ ជាការពិតណាស់ប្រាក់បំណាច់អតីតភាពការងារនេះ គឺមាន២ប្រភេទ ដែលយើងត្រូវបែងចែកឱ្យបានច្បាស់លាស់ ពោលគឺ ១)ប្រាក់បំណាច់អតីតភាពការងារ ដែលមានមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំ ដែលមានចាប់ពីឆ្នាំ២០១៩។ ប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ គឺជាប្រាក់បំណាច់ដែលនិយោជកត្រូវបើករំលឹកស្របទៅតាមអតីតភាពការងារជាក់ស្តែងរបស់កម្មករនិយោជិត ពោលគឺនិយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតនូវប្រាក់បំណាច់អតីតភាពការងារ ដែលស្មើនឹងប្រាក់ឈ្នួលសុទ្ធសាធចំនួន១៥ថ្ងៃក្នុងមួយឆ្នាំ។ ការបើករំលឹកនេះ ត្រូវបានកំណត់យកត្រឹម ១៥៦ថ្ងៃ

ជាចំនួនអតិបរមា ពោលគឺត្រូវរាប់ចាប់ពីឆ្នាំ២០០៨ មកដល់បំណាច់ឆ្នាំ២០១៨តែប៉ុណ្ណោះ។ ចំណែកឯប្រាក់បំណាច់អតីតភាពការងារដែលមានចាប់ពីឆ្នាំ២០១៩ គឺជាការទូទាត់អតីតភាពការងារថ្មីក្នុងឆ្នាំ ដែលនិយោជកត្រូវផ្ដល់ឱ្យកម្មករនិយោជិត១៥ថ្ងៃក្នុង១ឆ្នាំ ដោយត្រូវគិតជាឆមាស ឬ៦ខែម្ដង។ ប្រាក់បំណាច់នេះ មិនមានការកំណត់ចំនួនអតិបរមានោះទេ ពោលគឺកម្មករនិយោជិតដែលកំពុងបម្រើការងារមានសិទ្ធិទទួលបានប្រាក់បំណាច់នេះមួយជីវិតការងារតែម្ដង។

## ២.១.៤.១. ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩

❖ **ការគិតអតីតភាពការងារ៖** ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារនេះ គឺត្រូវអនុវត្ត ចំពោះកម្មករនិយោជិតដែលបានបំពេញលក្ខខណ្ឌដូចជា៖ ជាកម្មករនិយោជិតស្ថិតក្រោមកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) បានបម្រើការងារក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួនមុនឆ្នាំ២០១៩ និងកំពុងបម្រើការងារ។ ប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩នេះ មានចំនួនជាអតិបរមាដែលត្រូវបើករំលឹក គឺមិនអាចលើសពី៦ខែនៃប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមតាមឆ្នាំនីមួយៗ ដែលស្មើនឹងចំនួន១៥៦ថ្ងៃ។ មានន័យថាកម្មករនិយោជិតត្រូវទទួលបានប្រាក់រំលឹកអតីតភាពការងារចាប់ពីឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១៨ គឺស្មើនឹងចំនួន ១៥៦ថ្ងៃ។

| អតីតភាពការងារ | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | ចំនួនថ្ងៃសរុបសម្រាប់គិតរំលឹកប្រាក់បំណាច់អតីតភាពការងារ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 11ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 6 | 156 |
| 10 ឆ្នាំ | | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 150 |
| 9 ឆ្នាំ | | | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 135 |
| 8 ឆ្នាំ | | | | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 120 |
| 7 ឆ្នាំ | | | | | 15 | 15 | 15 | 15 | 15 | 15 | 15 | 105 |
| 6 ឆ្នាំ | | | | | | 15 | 15 | 15 | 15 | 15 | 15 | 90 |
| 5 ឆ្នាំ | | | | | | | 15 | 15 | 15 | 15 | 15 | 75 |
| 4 ឆ្នាំ | | | | | | | | 15 | 15 | 15 | 15 | 60 |
| 3 ឆ្នាំ | | | | | | | | | 15 | 15 | 15 | 45 |
| 2 ឆ្នាំ | | | | | | | | | | 15 | 15 | 30 |
| 1 ឆ្នាំ | | | | | | | | | | | 15 | 15 |

❖ **ការគិតអតីតភាពការងារសម្រាប់ឆ្នាំការងារដំបូង៖** ចាប់ពីឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១៨ ចំពោះឆ្នាំការងារដំបូងដែលជាមូលដ្ឋាន ត្រូវរំលឹកអតីតភាពការងារកម្មករនិយោជិតដែលបានបំពេញការងារជាប់ជានិច្ចចាប់ពី១ខែ ទៅដល់ ៦ខែ ត្រូវទទួលបានប្រាក់បំណាច់អតីតភាពការងារស្មើនឹងចំនួន៧,៥ថ្ងៃ និងបើបំពេញការងារបានលើសពី៦ខែ ត្រូវគិតស្មើនឹង១ឆ្នាំពេញ ដោយត្រូវទទួលបានប្រាក់បំណាច់អតីតភាពការងារស្មើនឹងចំនួន១៥ថ្ងៃ (១៥ថ្ងៃក្នុង១ឆ្នាំ) ដូចតារាងខាងក្រោម៖

| អតីតភាពការងារ | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|---|---|---|---|---|---|
| 11ឆ្នាំ | 15 ឬ 7.5 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 6ឬ 13.5 |
| 10 ឆ្នាំ | | 15 ឬ 7.5 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 |
| 9 ឆ្នាំ | | | 15ឬ 7.5 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 |
| 8 ឆ្នាំ | | | | 15ឬ 7.5 | 15 | 15 | 15 | 15 | 15 | 15 | 15 |
| 7 ឆ្នាំ | | | | | 15ឬ 7.5 | 15 | 15 | 15 | 15 | 15 | 15 |
| 6 ឆ្នាំ | | | | | | 15ឬ 7.5 | 15 | 15 | 15 | 15 | 15 |
| 5 ឆ្នាំ | | | | | | | 15ឬ 7.5 | 15 | 15 | 15 | 15 |
| 4 ឆ្នាំ | | | | | | | | 15ឬ 7.5 | 15 | 15 | 15 |
| 3 ឆ្នាំ | | | | | | | | | 15ឬ 7.5 | 15 | 15 |
| 2 ឆ្នាំ | | | | | | | | | | 15ឬ 7.5 | 15 |
| 1 ឆ្នាំ | | | | | | | | | | | 15ឬ 7.5 |

❖ របៀបគណនាការរំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩

ការគណនាការរំលឹកប្រាក់បំណាច់អតីតភាពការងារត្រូវអនុវត្តដូចខាងក្រោម៖

- ទី១ ត្រូវគណនាប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង ១ខែ៖

$$\text{ប្រាក់ឈ្នួលសុទ្ធសាធជាមធ្យមក្នុង ១ខែ} = \frac{\text{ផលបូកប្រាក់ឈ្នួលសុទ្ធសាធប្រចាំខែ នៅក្នុងរយៈពេល ដែលត្រូវទទួលបានការរំលឹកប្រាក់បំណាច់អតីតភាពការងារ}}{\text{ចំនួនខែសរុប ក្នុងរយៈពេលដែលត្រូវទទួលបាន ការរំលឹកប្រាក់បំណាច់អតីតភាពការងារ}}$$

- ទី២ ត្រូវគណនាប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមក្នុង ១ថ្ងៃ៖

$$\text{ប្រាក់ឈ្នួលសុទ្ធសាធជាមធ្យមក្នុង ១ថ្ងៃ} = \frac{\text{ប្រាក់ឈ្នួលសុទ្ធសាធជាមធ្យមក្នុង ១ខែ}}{\text{២៦ថ្ងៃ}}$$

ដូច្នេះ ប្រាក់រំលឹកអតីតភាពការងារដែលត្រូវទទួលបានតាមឆ្នាំនីមួយៗ គឺ៖

$$\text{ប្រាក់រំលឹកអតីតភាពការងារក្នុង១ឆ្នាំ} = \text{ប្រាក់ឈ្នួលសុទ្ធសាធជាមធ្យមក្នុង ១ថ្ងៃ} \times \text{១៥}$$

❖ របៀបបើករំលឹកប្រាក់បំណាច់អតីតភាពការងារ ដែលមានមុនឆ្នាំ២០១៩

- **សហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង៖** និយោជកត្រូវបើករំលឹកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិត២ ដងក្នុង១ឆ្នាំ ដែលក្នុងម្តងៗស្មើនឹងប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមចំនួន១៥ថ្ងៃ គឺចំនួន១៥ថ្ងៃ នៅពេលបើកប្រាក់ឈ្នួលលើកទី២ សម្រាប់ខែមិថុនា និងចំនួន១៥ថ្ងៃទៀត នៅពេលបើកប្រាក់ឈ្នួលលើកទី២ សម្រាប់ខែធ្នូ នៃឆ្នាំនីមួយៗ។ ការបើករំលឹកនេះនិយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតទៅតាមអតីតភាពការងារជាក់ស្តែង របស់កម្មករនិយោជិតម្នាក់ៗពោលគឺចាប់ពីឆ្នាំ២០០៨ រៀងមក។ ការបើករំលឹកនេះ ត្រូវអនុវត្តដូចតារាងខាងក្រោម៖

| ប្រសិនមានអតីតភាពការងារ | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | | ២០២៣ | | ២០២៤ | ចំនួនថ្ងៃសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិថុនា | ធ្នូ | មិថុនា | ធ្នូ | មិថុនា | ធ្នូ | មិថុនា | ធ្នូ | មិថុនា | ធ្នូ | មិថុនា | |
| 11ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 6 | 156 |
| 10 ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | | 150 |
| 9 ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | | | 135 |
| 8 ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | 15 | | | | 120 |
| 7 ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | 15 | | | | | 105 |
| 6 ឆ្នាំ | 15 | 15 | 15 | 15 | 15 | 15 | | | | | | 90 |
| 5 ឆ្នាំ | 15 | 15 | 15 | 15 | 15 | | | | | | | 75 |
| 4 ឆ្នាំ | 15 | 15 | 15 | 15 | | | | | | | | 60 |
| 3 ឆ្នាំ | 15 | 15 | 15 | | | | | | | | | 45 |
| 2 ឆ្នាំ | 15 | 15 | | | | | | | | | | 30 |
| 1 ឆ្នាំ | 15 | | | | | | | | | | | 15 |

- **សហគ្រាស គ្រឹះស្ថានក្រៅពីផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូបៈ** យោងសេចក្តីណែនាំលេខ០៤២/១៩ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ ត្រូវបានពន្យារពេលក្នុងការអនុវត្តទៅខែធ្នូ ឆ្នាំ២០២១ ដោយត្រូវទូទាត់រំលឹកចំនួន ៦ថ្ងៃក្នុង១ឆ្នាំ ក្នុងនោះចំនួន៣ថ្ងៃ នៅក្នុងខែមិថុនា និងចំនួន៣ថ្ងៃទៀត នៅក្នុងខែធ្នូ។ និយោជកត្រូវបើកផ្តាច់ជូនកម្មករនិយោជិតនូវប្រាក់រំលឹកនេះ ក្នុងករណីកម្មករនិយោជិតណាដែលត្រូវបានបញ្ឈប់ពីការងារដោយមូលហេតុក្រៅពីកំហុសធ្ងន់ ឬចូលនិវត្តន៍ ឬទទួលមរណៈភាពក្នុងអំឡុងពេលនៃការពន្យារនេះ។

### *២.១.៤.២. ការបើកប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំ ដែលមានចាប់ពីឆ្នាំ២០១៩*

❖ **របៀបគិតអតីតភាពការងារ**

ចាប់ពីឆ្នាំ២០១៩ តទៅ អតីតភាពការងាររបស់កម្មករនិយោជិតសម្រាប់ទូទាត់ប្រាក់បំណាច់អតីតភាពការងារត្រូវគិតក្នុងរយៈពេល១ឆមាស (៦ខែ) ម្តង គឺឆមាសទី១ ពីខែមករា ដល់ខែមិថុនា និងឆមាសទី២ ពីខែកក្កដា ដល់ខែធ្នូ។ កម្មករនិយោជិតដែលបានបំពេញការងារនៅក្នុងឆមាសនីមួយៗ ជាប់ជានិច្ចចាប់ពី១ខែ ទៅ៦ខែ ហើយបានបម្រើការងាររហូតដល់ដំណាច់ខែចុងក្រោយនៃឆមាសនីមួយៗ (ខែមិថុនា ឬខែធ្នូ) នោះទើបកម្មករនិយោជិតអាចទទួលបាននូវប្រាក់បំណាច់អតីតភាពការងារចំនួន៧,៥ថ្ងៃ នៅក្នុងឆមាសនីមួយៗ។

អតីតភាពការងារកម្មករនិយោជិតសម្រាប់ទូទាត់ប្រាក់បំណាច់អតីតភាពការងារ ត្រូវគិតចាប់ពីពេលបានចុះកិច្ចសន្យាការងារជាកម្មករនិយោជិតពេញសិទ្ធិ ដោយមិនរាប់បញ្ចូលចិរវេលាសាកល្បង។ កម្មករនិយោជិតដែលបានបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថាន យ៉ាងតិចចំនួន២១ថ្ងៃ ត្រូវចាត់ទុកថាបំពេញការងារបាន១ខែពេញ ដែលអាចទទួលបានប្រាក់បំណាច់អតីតភាពការងារ។

❖ **របៀបគណនាប្រាក់បំណាច់អតីតភាពការងារក្នុងឆ្នាំដែលមានចាប់ពីឆ្នាំ២០១៩**

ការគណនាប្រាក់បំណាច់អតីតភាពការងារត្រូវអនុវត្តដូចខាងក្រោមៈ

- ទី១ ត្រូវគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំក្នុង ១ខែ

$$\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ} = \frac{\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំសរុបក្នុងឆមាស}}{\text{៦ខែ ឬតាមចំនួនខែបានធ្វើការងារជាក់ស្តែង}}$$

- ទី២ ត្រូវគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ

$$\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ} = \frac{\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង១ខែ}}{\text{២២ថ្ងៃ ឬ២៤ថ្ងៃ ឬ២៦ថ្ងៃ (អាស្រ័យលើចំនួនថ្ងៃធ្វើការនៃសហគ្រាស គ្រឹះស្ថាននីមួយៗ)}}$$

$$\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ} = \frac{\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង១ខែ}}{\text{២២ថ្ងៃឬ២៤ថ្ងៃ ឬ២៦ថ្ងៃ (អាស្រ័យលើចំនួនថ្ងៃធ្វើការនៃសហគ្រាស គ្រឹះស្ថាននីមួយៗ)}}$$

ដូច្នេះ ប្រាក់បំណាច់អតីតភាពការងារដែលទទួលបាននៅក្នុងឆមាសនីមួយៗ គឺៈ

$$\text{ប្រាក់បំណាច់អតីតភាពការងារក្នុង១ឆមាសនីមួយៗ} = \text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង១ថ្ងៃ} \times \text{៧,៥}$$

❖ **របៀបបើកប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំ ដែលមានចាប់ពីឆ្នាំ២០១៩**

ប្រាក់បំណាច់អតីតភាពការងារនេះ ត្រូវបើកជាមួយនឹងប្រាក់ឈ្នួល ដែលកម្មករនិយោជិតត្រូវទទួលបានលើកទី២ (១ខែ បើក ២ដង) សម្រាប់ខែមិថុនា និងខែធ្នូ។

និយោជកត្រូវញែកឱ្យដាច់ពីគ្នារវាងចំនួនប្រាក់ឈ្នួលប្រចាំខែ និងប្រាក់បំណាច់អតីតភាពការងារ ដើម្បីងាយស្រួលក្នុងការអនុវត្តកាតព្វកិច្ចពន្ធដារ។

### *២.១.៥. ការកំណត់ប្រាក់ឈ្នួល*

ការកំណត់ប្រាក់ឈ្នួល គឺត្រូវធ្វើឡើងស្របតាមការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យាការងារ ពោលគឺរវាងកម្មករនិយោជិត និងនិយោជក។ យើងអាចនិយាយបានថា ការកំណត់ប្រាក់ឈ្នួល គឺអាចធ្វើឡើងតាមគោលការណ៍សេរីភាពនៃកិច្ចសន្យាការងារ។ ទោះបីជាការកំណត់ប្រាក់ឈ្នួលអាចត្រូវបានធ្វើឡើងដោយឈរលើគោលការណ៍នេះក៏ដោយ និយោជកត្រូវគោរពផងដែរនូវបញ្ញត្តច្បាប់ពាក់ព័ន្ធជាធរមាន។

អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៣៦ វាក្យខណ្ឌទី២ បញ្ញត្តថា *"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា"* ។ យោងលើបញ្ញត្តនៃមាត្រានេះគោលការណ៍នៃភាពមិនរើសអើងចំពោះប្រាក់ឈ្នួលនេះ គឺត្រូវបានធានាដោយច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា។ មានន័យថា សេរីភាពនៃការកំណត់ប្រាក់ឈ្នួលត្រូវតែអនុវត្ត ដោយគោរពលើគោលការណ៍ជាធម្មនុញ្ញភាពនេះ។ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ក៏បានកំណត់ផងដែរអំពីគោលការណ៍មិនរើសអើងចំពោះប្រាក់ឈ្នួលនេះ។ មាត្រា៨ នៃច្បាប់នេះបានបញ្ញត្តថា *"ចំពោះការងារដែលមានលក្ខខណ្ឌស្មើគ្នា ភាពប៉ិនប្រសព្វខាងវិជ្ជាជីវៈ និងផលដែលធ្វើបានស្មើគ្នា ប្រាក់ឈ្នួលត្រូវឱ្យស្មើគ្នាដល់កម្មករនិយោជិតទាំងអស់ដែលស្ថិតក្រោមវិសាលភាពនៃច្បាប់នេះ ដោយមិនគិតពីដើមកំណើត ភេទ ឬអាយុ"* ។ យោងតាមខ្លឹមសារនៃបញ្ញត្តច្បាប់ទាំងនេះ ការផ្តល់ ឬកំណត់ប្រាក់ឈ្នួលជូនកម្មករនិយោជិត និយោជកត្រូវធានាថាមិនមានការរើសអើងរវាងកម្មករនិយោជិតដែលបានបំពេញការងារដូចគ្នា ឬចំពោះកម្មករនិយោជិតដែលបានបំពេញការងារដែលមានលក្ខខណ្ឌស្មើគ្នា ភាពប៉ិនប្រសប់ ខាងវិជ្ជាជីវៈ និងផលដែលធ្វើបានស្មើគ្នា ពោលគឺមានសមត្ថភាពការងារ បទពិសោធន៍ការងារ គោរពវិន័យការងារ និងផលិតភាពការងារស្មើគ្នា។ល។ បន្ថែមលើនេះ ការកំណត់ប្រាក់ឈ្នួលមិនអាចធ្វើឡើងដោយយោងលើដើមកំណើត ភេទ ឬអាយុនោះទេ។ មានន័យថា កម្មករនិយោជិតជាខ្មែរ ឬបរទេស ជាបុរសឬស្ត្រី ជាចាស់ឬក្មេង គឺមានសិទ្ធិទទួលបានប្រាក់ឈ្នួលស្មើគ្នា ប្រសិនបើការបំពេញការងារត្រូវបានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់ក្នុងមាត្រាខាងលើ។ យោងលើមាត្រា២៤ នៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា និយោជកដែលបំពានគោលការណ៍នេះ នឹងត្រូវពិន័យអន្តការណ៍ជាប្រាក់មិនលើសពីសែសិបលានរៀល។

សូមបញ្ជាក់ផងដែរថា ដើម្បីធានាការអនុវត្តន៍គោលការណ៍មិនរើសអើងចំពោះប្រាក់ឈ្នួលនេះ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ក៏បានកំណត់ផងដែរអំពីប្រាក់ឈ្នួលអប្បបរមាដែលចាំបាច់ក្នុងការធានានូវជីវភាពរស់នៅសមរម្យរបស់កម្មករនិយោជិតគ្រប់រូប។ ការកំណត់ប្រាក់ឈ្នួលអប្បបរមា ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ គឺជាការកម្រិតប្រាក់ឈ្នួលមួយដែលមានលក្ខណៈចាប់បង្ខំឱ្យនិយោជកត្រូវគោរពតាមពោលគឺនិយោជកមិនអាចកំណត់ប្រាក់ឈ្នួលមួយ ដែលទាបជាងប្រាក់ឈ្នួលអប្បបរមានេះបានឡើយ (មាត្រា៤នៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា)។ ការកំណត់ប្រាក់ឈ្នួលអប្បបរមានេះ ត្រូវធ្វើឡើងស្របទៅនឹងបញ្ញត្តនៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា។ យោងលើមាត្រា២៤ នៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា និយោជកដែលបំពានដោយផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតរបស់ខ្លួន ក្រោមកម្រិតប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា នឹងត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពីសែសិបលានរៀល។ បន្ថែមលើទណ្ឌកម្មនេះ

និយោជក នឹងត្រូវសងត្រឡប់ទៅកម្មករនិយោជិតវិញនូវចំនួនទឹកប្រាក់ដែលបានបំពាន ដោយគិតបញ្ចូលទាំងការប្រាក់ដែលត្រូវទទួលបាន ក្នុងអត្រាដែលកំណត់ដោយច្បាប់ផងដែរ។

មាត្រា៧ នៃច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា ក៏បានបញ្ញត្តផងដែរអំពីការកំណត់ប្រាក់ឈ្នួលចំពោះការងារម៉ៅការនិងការងារតាមបរិមាណផលិតផល។ មាត្រានេះ បានចែងថា " *ចំពោះការងារម៉ៅការឬតាមបរិមាណផលិតផល ប្រាក់ឈ្នួលត្រូវគិតយ៉ាងណាឱ្យកម្មករនិយោជិតដែលមានការប៉ិនប្រសព្វមធ្យមធ្វើការជាធម្មតា បានទទួលក្នុងចិរវេលាធ្វើការដដែលនូវប្រាក់ឈ្នួលយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ហើយដែលកំណត់សម្រាប់កម្មករនិយោជិតនោះ* "។ កថាខណ្ឌទី២នៃមាត្រាដដែលក៏បានបញ្ញត្តផងដែរថា " *កម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួលគិតតាមបរិមាណផលិតផល ត្រូវទទួលបានប្រាក់ឈ្នួលតាមទិន្នផលជាក់ស្ដែងដែលធ្វើបាន។ បើទិន្នផលការងារទទួលបាននោះលើសពីចំនួនប្រាក់ឈ្នួលអប្បបរមា កម្មករនិយោជិតនោះត្រូវទទួលបានតាមចំនួនលើសនោះ។ ប្រសិនបើទាបជាងប្រាក់ឈ្នួលអប្បបរមា និយោជកត្រូវបន្ថែមឱ្យគ្រប់ចំនួនស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា* "។ យោងលើខ្លឹមសារនៃមាត្រានេះ កម្មករនិយោជិតនៃការងារម៉ៅការឬតាមបរិមាណផលិតផល ត្រូវបានការពារយ៉ាងពិសេសក្នុងការទទួលបាននូវប្រាក់ឈ្នួលមួយដែលសមរម្យ ពោលគឺយ៉ាងហោចណាស់ស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា។ តាមន័យនេះ និយោជកត្រូវមានកាតព្វកិច្ចបត់បែន ក្នុងការកំណត់ប្រាក់ឈ្នួលជូនកម្មករនិយោជិតនៃប្រភេទការងារទាំងនេះ។ យោងលើមាត្រា២៤ នៃច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា និយោជកដែលបំពានគោលការណ៍នៃប្រាក់ឈ្នួលអប្បបរមាសម្រាប់ការងារម៉ៅការនិងតាមបរិមាណផលិតផលនេះ នឹងត្រូវពិន័យអន្តការណ៍ជាប្រាក់មិនលើសពីសែសិបលានរៀល។ បន្ថែមលើទណ្ឌកម្មនេះ និយោជកដែលបានបើកប្រាក់ឈ្នួលដល់កម្មករនិយោជិតតិចជាងប្រាក់ឈ្នួលអប្បបរមា នឹងត្រូវសង ត្រឡប់ទៅកម្មករនិយោជិតវិញនូវចំនួនទឹកប្រាក់ដែលបានបំពាន ដោយគិតបញ្ចូលទាំងការប្រាក់ដែលត្រូវទទួលបានក្នុងអត្រាដែលកំណត់ដោយច្បាប់ផងដែរ។

ការកំណត់ប្រាក់ឈ្នួលអាចធ្វើឡើង ស្របតាមពេលវេលាកំណត់ (ប្រចាំម៉ោង ប្រចាំថ្ងៃ ឬប្រចាំខែ) ឬតាមបរិមាណផលិតផល (ដេរស៊ីប៉ុង)។ ការគិតប្រាក់ឈ្នួលតាមបរិមាណផលិតផល (ដេរស៊ីប៉ុង) គឺអាស្រ័យទៅលើតម្លៃប៉ុងក្នុង១ម៉ោង។ ករណីប្រាក់ឈ្នួលធម្មតាក្នុង១ម៉ោងច្រើនជាងតម្លៃប៉ុងក្នុង១ម៉ោង គឺយកប្រាក់ឈ្នួលធម្មតាក្នុង១ម៉ោងមកគណនា។ ផ្ទុយទៅវិញករណីប្រាក់ឈ្នួលធម្មតាក្នុង១ម៉ោងតិចជាងតម្លៃប៉ុងក្នុង១ម៉ោង គឺយកតម្លៃប៉ុងក្នុង១ម៉ោងមកគណនា។

- **ការគណនាប្រាក់ឈ្នួលតាមបរិមាណផលិតផល (ដេរស៊ីប៉ុង) មានដូចខាងក្រោម៖**

  ១- រកចំនួនម៉ោងធ្វើការសរុបនៅក្នុងខែ (ទាំងម៉ោងធ្វើការធម្មតា ទាំងម៉ោងធ្វើការបន្ថែមម៉ោង)

  ២- រកប្រាក់ថ្លៃប៉ុងសរុប = ថ្លៃប៉ុង ១ឯកតា X ចំនួនប៉ុងសរុប

  ៣- រកប្រាក់ឈ្នួលធម្មតាក្នុង១ម៉ោង = ប្រាក់ថ្លៃប៉ុងសរុប ÷ ចំនួនម៉ោងធ្វើការសរុប

  = (២) ÷ (១)

**<u>កំណត់ចំណាំ</u>៖** បើប្រាក់ឈ្នួលធម្មតាក្នុងមួយម៉ោងទាបជាងប្រាក់ឈ្នួលគោលក្នុងមួយម៉ោងនោះត្រូវយកប្រាក់ឈ្នួលជាមធ្យមក្នុង១ម៉ោងមកគណនាវិញ។ ឧទាហរណ៍ថាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២៣ ស្មើនឹង ២០០ដុល្លារ ៖

$$\text{ប្រាក់ឈ្នួលជាមធ្យមក្នុង១ម៉ោង} = \frac{\text{២០០ \$}}{\text{២៦ x ៨}} = \text{០.៩៦ \$}$$

៤- រកប្រាក់ឈ្នួលម៉ោងធម្មតាសរុប (មិនគិតថ្ងៃបុណ្យ និងថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍)

= ប្រាក់ឈ្នួលជាមធ្យមក្នុង១ម៉ោង x ចំនួនម៉ោងធ្វើការធម្មតា

៥- រកប្រាក់ឈ្នួលធ្វើការថែមម៉ោងពេលថ្ងៃនៃថ្ងៃធ្វើការធម្មតា

= ប្រាក់ឈ្នួលជាមធ្យមក្នុង១ម៉ោង x ចំនួនម៉ោងធ្វើការបន្ថែមពេលថ្ងៃ នៃថ្ងៃធ្វើការធម្មតា x ១.៥

៦- រកប្រាក់ឈ្នួលម៉ោងធ្វើការថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍ និងឈប់សម្រាកថ្ងៃបុណ្យ

= ប្រាក់ឈ្នួលជាមធ្យមក្នុង១ម៉ោង x ចំនួនម៉ោងធ្វើការថ្ងៃឈប់សម្រាកបុណ្យ និងថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍ x ២

៧- រកប្រាក់ឈ្នួលសរុបត្រូវទទួលបានក្នុងខែ = (៤) + (៥) + (៦) + ប្រាក់បន្ទាប់បន្សំផ្សេងៗទៀត

(ដូចជារង្វាន់ទៀងទាត់ រង្វាន់អតីតភាពប្រាក់សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថមថ្លៃបាយពេលធ្វើការបន្ថែមម៉ោង...។ល។)

**ឧទាហរណ៍៖** កម្មករនិយោជិតម្នាក់ធ្វើការបានចំនួន ២៦០ម៉ោងនៅក្នុងខែ (គាត់បានធ្វើការម៉ោងធម្មតា ២០៨ម៉ោង ម៉ោងថ្ងៃបុណ្យ៨ម៉ោង ថ្ងៃអាទិត្យ៤ម៉ោង និងធ្វើការបន្ថែមម៉ោងពេលថ្ងៃ នៃថ្ងៃធ្វើការធម្មតា៤០ម៉ោង) ប្រាក់ខែគោលសុទ្ធសាធក្នុងមួយខែ គឺ ២០០ $ និងប្រាក់បុងសរុបក្នុងខែចំនួន ២៥៥ $។

ប្រាក់ឈ្នួលរបស់គាត់ត្រូវបានគណនាដូចតទៅ៖

១- ម៉ោងធ្វើការសរុប ២៦០ម៉ោង

២- ចំនួនថ្លៃបុងសរុប ២៥៥ $

៣- $$\text{ប្រាក់ឈ្នួលជាមធ្យមក្នុង១ម៉ោង} = \frac{\text{២៥៥\$ (តំលៃបុងសរុប)}}{\text{២៦០ (ម៉ោងសរុបក្នុង១ខែ)}} = \text{០.៩៨ \$}$$

<u>កំណត់ចំណាំ</u>៖ ដោយប្រាក់ឈ្នួលធម្មតាក្នុង១ម៉ោងនៃការដេរស៊ីងបុងនេះច្រើនជាងប្រាក់ឈ្នួលគោលក្នុង១ម៉ោង (០.៩៨ ធំជាង ០.៩៦) ត្រូវយកប្រាក់ឈ្នួលធម្មតានៃការដេរស៊ីបុងនោះមកគិត។

៤- ប្រាក់ឈ្នួលម៉ោងធម្មតាសរុប = ០.៩៨ x ២០០ = ១៩៦ $

៥- ប្រាក់ឈ្នួលធ្វើការលើសម៉ោងពេលថ្ងៃ នៃថ្ងៃធម្មតា

= ០.៩៨$ x ៤០ x ១.៥ = ៥៩ $

៦- ប្រាក់ឈ្នួលម៉ោងធ្វើការថ្ងៃឈប់សម្រាកបុណ្យ និងថ្ងៃឈប់សម្រាកប្រចាំសប្ដាហ៍

= ០.៩៨$ x ( ៨ + ៤ ) x ២ = ២៣.៥២ $

៧- ប្រាក់ឈ្នួលសរុបត្រូវទទួលបានក្នុងខែ = ១៩៦ $ + ៥៨ $ +២៣.៥២ $ =**២៧៧.៥២ $**

**បញ្ជាក់៖** ប្រាក់ឈ្នួលនេះមិនទាន់ត្រូវបានបូកបញ្ចូលជាមួយនឹងអត្ថប្រយោជន៍ដែលកម្មករនិយោជិតត្រូវបាននៅក្នុងខែនេះទេ។

### ២.១.៦. ការបើកប្រាក់ឈ្នួល

យោងលើមាត្រា១១៣ នៃច្បាប់ស្ដីពីការងារ និយោជកត្រូវបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតរបស់ខ្លួន ដោយផ្ទាល់ដៃ លើកលែងតែកម្មករនិយោជិតព្រមបើកតាមវិធីផ្សេងៗទៀត។ តាមន័យនេះ យើងអាចនិយាយបានថា ការបើកប្រាក់ឈ្នួលដោយផ្ទាល់ដៃមិនមែនជាវិធានដែលតម្រូវឱ្យនិយោជកត្រូវអនុវត្តដោយដាច់ខាតនោះទេ ពោលគឺនិយោជកអាចស្នើសុំការព្រមព្រៀងពីកម្មករនិយោជិតសាមី ក្នុងករណីដែលខ្លួនមានបំណងបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតដោយរបៀបផ្សេងដូចជាការបើកតាមប្រព័ន្ធធនាគារជាដើម។ មាត្រា១១៣នៃច្បាប់ស្ដីពីការងារ ក៏បានចែងផងដែរថា ប្រាក់ឈ្នួលរបស់កម្មករនិយោជិតត្រូវបើកជាប្រាក់ លោហធាតុ ឬជាក្រដាសប្រាក់ដែលចាយជាផ្លូវច្បាប់ ទោះបីមានបទប្បញ្ញត្តិចែងផ្ទុយពីនេះក៏ដោយ។ ច្បាប់ស្ដីពីការងារត្រង់មាត្រា១១៥ក៏បានកំណត់ផងដែរថា ការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតជាគ្រឿងស្រវឹង ឬថ្នាំសង្កូវដែលឱ្យទោស គឺមិនត្រូវឱ្យមានជាដាច់ខាត ទោះក្នុងករណីណាក៏ដោយ។

កថាខណ្ឌទី៣នៃមាត្រា១១៥នៃច្បាប់ស្ដីពីការងារ បានកំណត់ថា និយោជកមិនត្រូវបើកប្រាក់ឈ្នួលនៅថ្ងៃដែលកម្មករនិយោជិតមានសិទ្ធិឈប់សម្រាកឡើយ ហើយប្រសិនបើការបើកប្រាក់ឈ្នួលត្រូវធ្វើឡើងចំលើថ្ងៃឈប់សម្រាកនោះ និយោជកត្រូវធ្វើការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតរបស់ខ្លួន ១ថ្ងៃមុនការឈប់សម្រាកនោះ។ ពាក់ព័ន្ធនឹងពេលវេលានៃការបើកប្រាក់ឈ្នួលនេះ ច្បាប់ស្ដីពីការងារត្រង់មាត្រា១០៦បញ្ញត្តផងដែរថា ប្រាក់ឈ្នួលនៃកម្មករត្រូវបើកយ៉ាងហោចណាស់ពីរដងក្នុង១ខែ ដោយមានចន្លោះពេលយ៉ាងច្រើន១៦ថ្ងៃ។ ចំណែកប្រាក់ឈ្នួលនៃនិយោជិតត្រូវបើកយ៉ាងហោចណាស់១ដងក្នុង១ខែ។ បន្ថែមលើនេះ ប្រកាសលេខ ៤៤២ ក.ប/ប្រ.ក.ខ.ល ស្ដីពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ បានតម្រូវឱ្យនិយោជកត្រូវបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតរបស់ខ្លួនចំនួន២ដងក្នុងខែ ដោយត្រូវចាប់ផ្ដើមអនុវត្តចាប់ពីខែមករា នៃឆ្នាំ២០១៩តទៅ។ យោងលើប្រកាសនេះ ការបើកប្រាក់ឈ្នួលប្រចាំខែលើកទី១ គឺនិយោជកត្រូវបើកប្រាក់ចំនួន៥០%នៃប្រាក់ឈ្នួលសុទ្ធសាធក្នុងមួយខែ និងលើកទី២ គឺនិយោជកត្រូវបើកប្រាក់ឈ្នួលសុទ្ធសាធដែលនៅសល់ ប្រាក់ឈ្នួលបន្ទាប់បន្សំ និងអត្ថប្រយោជន៍ផ្សេងៗទៀត ដែលកម្មករនិយោជិតត្រូវទទួលបាននៅក្នុងខែនីមួយៗ។

យោងមាត្រា១១៦ នៃច្បាប់ស្ដីពីការងារ ក្នុងករណីរំលាយកិច្ចសន្យាការងារ និយោជកត្រូវបើកជូនកម្មករនិយោជិតរបស់ខ្លួននូវប្រាក់ឈ្នួល និងប្រាក់បំណាច់គ្រប់ប្រភេទក្នុងរយៈពេល ៤៨ម៉ោង បន្ទាប់ពីថ្ងៃឈប់ធ្វើការ។

### ២.១.៧. ការកាត់ប្រាក់ឈ្នួល

កម្មករនិយោជិតមានសិទ្ធិសេរីភាពក្នុងការប្រើប្រាស់ប្រាក់ឈ្នួលរបស់ខ្លួនតាមចិត្ត ដែលនិយោជកមិនអាចបន្ថយសេរីភាពនេះបានឡើយ ទោះដោយមូលហេតុយ៉ាងណាក៏ដោយ (មាត្រា១១៤ នៃច្បាប់ស្តីពីការងារ)។ ដូចនេះ សិទ្ធិរបស់កម្មករនិយោជិតទៅលើប្រាក់ឈ្នួលគឺជាសិទ្ធិដែលត្រូវបានការពារយ៉ាងរឹងមាំដោយច្បាប់ស្តីពីការងារ ដែលនិយោជកមិនអាចបំពានបានឡើយ។ ជាក់ស្តែង ច្បាប់ស្តីពីការងារ ត្រង់មាត្រា១២៦ បានហាមឃាត់មិនឱ្យមានការកាត់ប្រាក់ឈ្នួលក្នុងគោលបំណងឱ្យអ្នកទទួលរកការឱ្យធ្វើ ទោះបីដោយចំពោះក្តី ឬមិនចំពោះក្តី ឱ្យទៅនិយោជក អ្នកតំណាងនិយោជក ឬអន្តរការីណាម្នាក់ដូចជាភ្នាក់ងារទទួលជ្រើសរើសហត្ថពលករជាដើម។

យោងមាត្រា១២៧ នៃច្បាប់ស្តីពីការងារ បានហាមឃាត់មិនឱ្យមានការទូទាត់ណាមួយ ដើម្បីជាផលប្រយោជន៍និយោជក រវាងប្រាក់ឈ្នួលដែលត្រូវបើកឱ្យកម្មករនិយោជិត និងប្រាក់ដែលកម្មករ និយោជិត ត្រូវសងទៅនិយោជក ចំពោះការផ្តល់សម្ភារផ្សេងៗ ទោះប្រភេទណាក៏ដោយ។ ប៉ុន្តែគោលការណ៍នេះ ត្រូវបានលើកលែង ដោយមិនអនុវត្តទៅលើការផ្តល់ដោយនិយោជកនូវសម្ភារមួយចំនួនដូចជា៖

- គ្រឿងប្រដាប់ប្រដានិងឧបករណ៍ចាំបាច់សម្រាប់ការងារដែលកម្មករនិយោជិតមិនបានយកមកប្រគល់ឱ្យវិញនៅពេលឈប់ធ្វើការ។
- វត្ថុធាតុនិងសម្ភារដែលកម្មករនិយោជិតទទួលបន្ទុកនិងប្រើប្រាស់។
- ចំនួនប្រាក់ដែលបានបើកមុនដើម្បីទិញវត្ថុទាំងនោះ។
- ចំនួនប្រាក់ដែលនៅជំពាក់អាគារូបដ្ឋាន។

ទោះបីជាមានករណីដូចបានរៀបរាប់ខាងលើនេះ ដែលបានអនុញ្ញាតឱ្យនិយោជកធ្វើការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត មាត្រាដដែលខាងលើក៏បានបញ្ជាក់បន្ថែមផងដែរថា ការកាត់ប្រាក់ឈ្នួលមិនត្រូវឱ្យហួសដល់ទៅបរិមាណភាគជាចាំបាច់ សម្រាប់ការចិញ្ចឹមជីវិតនៃកម្មករនិយោជិត និងគ្រួសារបានឡើយ។ ម្យ៉ាងវិញទៀត ចំពោះករណីដែលនិយោជកបានឱ្យកម្មករនិយោជិតខ្ចីប្រាក់មុន ក្រៅអំពីប្រាក់បើកសម្រាប់ទិញប្រដាប់ប្រដា ឧបករណ៍ វត្ថុធាតុ និងសម្ភារសម្រាប់ឱ្យកម្មករនិយោជិតទទួលបន្ទុកនិងប្រើប្រាស់នោះ ច្បាប់ស្តីពីការងារ ត្រង់មាត្រា១២៨ បានកំណត់ឱ្យមានការសងវិញបានតែតាមវិធីកាត់ប្រាក់ឈ្នួលបន្តិចម្តងៗ ហើយក្នុងភាគប្រាក់ឈ្នួលដែលអាចផ្ទេរឬរឹបអូសបានតែប៉ុណ្ណោះ។ កថាខណ្ឌទី៣នៃមាត្រា១២៨ ក៏បានកំណត់ផងដែរថា និយោជកអាចកាត់ទុកនៅពេលបើកប្រាក់ជាបន្ទាប់បាន ចំពោះប្រាក់រំលស់ដូចមានចែងក្នុងមាត្រា១១៦ និងប្រាក់ឈ្នួលដែលបើកបន្តិចម្តងៗមុនកាលកំណត់ធម្មតា ប៉ុន្តែជាឈ្នួលការងារដែលបានធ្វើរួចហើយ។

មាត្រា១២៩ នៃច្បាប់ស្តីពីការងារ និងមាត្រា២៦ នៃច្បាប់ស្តីពីសហជីព បានតម្រូវឱ្យនិយោជកកាត់ប្រាក់ឈ្នួលកម្មករនិយោជិតដែលជាសមាជិកសហជីព ដើម្បីផ្ទេរទៅឱ្យសហជីពនោះជាស្វ័យប្រវត្តិក្រោយពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិតដែលជាសមាជិករបស់ខ្លួន។ បែបបទនៃការអនុវត្តកាត់ប្រាក់ភាគទាននេះ ត្រូវបានកំណត់ដោយប្រកាសលេខ៣០០ ក.ប/ប្រ.ក.ក.ប.ក ស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨។

### ២.២. ថិរវេលាធ្វើការ

#### ២.២.១. ថិរវេលាធ្វើការធម្មតា

យោងមាត្រា១៣៧ នៃច្បាប់ស្តីពីការងារ ថិរវេលាធ្វើការរបស់កម្មករនិយោជិតមិនអាចមានចំនួនលើសពី៨ម៉ោងក្នុងមួយថ្ងៃ ឬ៤៨ម៉ោងក្នុងមួយសប្តាហ៍ទេ។ ច្បាប់ស្តីពីការងារក៏បានកំណត់ផងដែរថា ដោយមិនត្រូវបំពានចំនួនម៉ោងការងារ ដែលត្រូវបានកំណត់នេះ និយោជកមានសិទ្ធិក្នុងការកំណត់របៀបចែកពេលធ្វើការរបស់ខ្លួនសម្រាប់កន្លែងធ្វើការផ្សេងៗតាមប្រភេទនៃសកម្មភាព និងរបៀបរៀបចំនៅក្នុងសហគ្រាសនីមួយៗ ដោយអាចដំណើរការលើសពី១វេន ក្នុង ១ថ្ងៃ។ ក្នុងករណីសហគ្រាសដំណើរការ ៣វេន អាចចែកជា វេនព្រឹក វេនរសៀល និងវេនយប់ ដោយម៉ោងធ្វើការនៃវេននីមួយៗ មិនត្រូវឱ្យលើសថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតក្នុង ១ថ្ងៃ។ សហគ្រាសអាចចែកពេលធ្វើការនៃវេននីមួយៗជា ២វគ្គ ដាច់ៗពីគ្នា (មាត្រា១៣៨ ថ្មី នៃច្បាប់ស្តីពីការងារ)។

ដោយគោរពថិរវេលាធ្វើការមិនឱ្យលើស៤៨ម៉ោងក្នុងមួយសប្តាហ៍ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបែងចែកម៉ោងធ្វើការក្នុងសប្តាហ៍ស្របតាមសកម្មភាពជាក់ស្តែងរបស់សហគ្រាស គ្រឹះស្ថានខ្លួន។ ច្បាប់ស្តីពីការងារត្រង់មាត្រា១៤១ បានកំណត់ថា ក្រសួងទទួលបន្ទុកវិស័យការងារអាចចេញប្រកាសកំណត់ការចែកម៉ោងធ្វើការក្នុងសប្តាហ៍ដែលត្រូវធ្វើការតែ៤៨ម៉ោង ដើម្បីឱ្យបានសម្រាកនៅពេលរសៀលថ្ងៃសៅរ៍ ឬបែបបទឯទៀតដូចគ្នា ប៉ុន្តែការបន្ថែមលើពេលម៉ោងធម្មតាមិនត្រូវឱ្យលើសពីមួយម៉ោងទេក្នុងមួយថ្ងៃ។ ពាក់ព័ន្ធនឹងករណីនេះ ក្រសួងបានចេញប្រកាសលេខ១៤២ សកបយ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបែងចែកម៉ោងធ្វើការក្នុងសប្តាហ៍ ដើម្បីឱ្យបានឈប់សម្រាកបន្ថែមនារសៀលថ្ងៃសៅរ៍។ ក្រសួងក៏បានចេញប្រកាសលេខ១៤៣ សកបយ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ ស្តីពី ការបែងចែកម៉ោងធ្វើការក្នុងរយៈពេលក្រៅពីសប្តាហ៍ធម្មតាដោយគិតជាមធ្យមចំនួន១២សប្តាហ៍បន្តបន្ទាប់។ ប្រកាសនេះបានកំណត់អំពីលក្ខខណ្ឌនៃការបែកចែកម៉ោងធ្វើការក្នុងរយៈពេលក្រៅពីសប្តាហ៍នេះ។ ក្រៅពីករណីទាំងពីរនេះ ក្រសួងពុំទាន់បានចេញប្រកាសកំណត់អំពីករណីផ្សេងទៀតដែលមានកំណត់ក្នុងមាត្រា១៤១ នៃច្បាប់ស្តីពីការងារនោះទេ។

#### ២.២.២.ការងារពេលយប់

ព្រះរាជក្រមលេខ នស/រកម/០៧០៧/០២០ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ បានប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា១៤៤នៃច្បាប់ស្តីពីការងារ ដែលបានកែសម្រួលការកំណត់និយមន័យពាក់ព័ន្ធនឹងការងារពេលយប់។ ជាក់ស្តែងមាត្រា១៤៤ថ្មី នៃច្បាប់ស្តីពីការងារបានកំណត់ពាក្យ "យប់" មានន័យថារយៈពេល១១ ម៉ោងបន្តបន្ទាប់គ្នាយ៉ាងតិច ដោយក្នុងនោះត្រូវមានពេលពីម៉ោង២២ ទៅម៉ោង៥ភ្លឺផង។ មាត្រាដដែលបានបញ្ជាក់បន្ថែមថា ក្រៅពីបន្តបន្ទាប់ដែលក្រុមកម្មករផ្លាស់វេនគ្នាធ្វើការជួនថ្ងៃ ជួនយប់ ការងារនៃសហគ្រាសអាចមានធ្វើមួយផ្នែកនៃពេលយប់ជានិច្ច។ ការងារពេលយប់ត្រូវឱ្យប្រាក់ឈ្នួល តាមមាត្រា ១៣០% (មួយរយសាមសិបភាគរយ) នៃប្រាក់ឈ្នួល ការងារពេលថ្ងៃ។

ការកំណត់អត្តសញ្ញាណនៃការងារពេលយប់នេះមានសារៈសំខាន់ណាស់ ព្រោះទាំងប្រាក់ឈ្នួល និងប្រាក់ឈ្នួលពេលថែមម៉ោងសម្រាប់ការងារពេលយប់ ត្រូវបានច្បាប់កំណត់ដោយឡែកខុសពីអត្រាប្រាក់ឈ្នួលការងារពេលថ្ងៃ ចំណែកនិយោជកក៏ត្រូវមានកាតព្វកិច្ចដោយឡែកបន្ថែមសម្រាប់កម្មករនិយោជិតដែលធ្វើការពេលយប់ផងដែរ។ ការងារពេលយប់ក៏ជាកត្តាសម្រាប់ត្រួតពិនិត្យលក្ខខណ្ឌការងារកុមារផងដែរ មាន

ន័យថាក្នុងករណីណាក៏ដោយ បើទោះបីការងារនោះជាការងារស្រាលក្តី ឬមិនប៉ះពាល់ពេលវេលាសិក្សាក្តី ការប្រើប្រាស់កម្លាំងពលកម្មកុមារក្នុងពេលយប់ត្រូវហាមឃាត់ជាដាច់ខាត។

យោងលើប្រការ៦នៃប្រកាសលេខ៨០ សកបយ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា សហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតធ្វើការពេលយប់ និយោជកត្រូវផ្តល់ទីកន្លែងសម្រាកទទួលទានដំណេកឱ្យបានសមរម្យដល់កម្មករនិយោជិត ដែលចេញពីធ្វើការនៅពេលយប់ពុំនោះសោតទេ ត្រូវផ្តល់មធ្យោបាយសម្រាប់ដឹកជញ្ជូនកម្មករនិយោជិតទៅដល់លំនៅឋានរៀងៗខ្លួនវិញប្រកបដោយសុវត្ថិភាពនៅពេលចប់ម៉ោងធ្វើការពេលយប់។

### ២.២.៣.ការងារបន្ថែមម៉ោង

យោងមាត្រា១៣៩ ថ្មី និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន អាចតម្រូវឱ្យកម្មករនិយោជិតធ្វើការបន្ថែមក្រៅម៉ោងពេលធម្មតា ក្នុងករណីមានកិច្ចការប្រញាប់ខុសធម្មតា។ មាត្រាដដែលបានបញ្ជាក់បន្ថែមថា ម៉ោងពេលបន្ថែមទាំងនេះ ត្រូវឱ្យឈ្នួលតាមអត្រាដំឡើង ៥០% ហើយប្រសិនបើធ្វើការបន្ថែមនៅពេលយប់ ចន្លោះពីម៉ោង២២ ទៅម៉ោង៥ភ្លឺ ឬនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវផ្តល់ប្រាក់បន្ថែមតាមអត្រាដំឡើង ១០០%។

| **បរិយាយ** | **អត្រាប្រាក់ឈ្នួល** |
|---|---|
| **កម្មករនិយោជិតធ្វើការបន្ថែមម៉ោងពេលថ្ងៃនៃថ្ងៃធ្វើការធម្មតា** | **អត្រាដំឡើង ៥០% ឬគុណនឹង១,៥ ដង** |
| **កម្មករនិយោជិតធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍** | **អត្រាដំឡើង ១០០% ឬគុណនឹង ២ ដង** |
| **កម្មករនិយោជិតធ្វើការនៅថ្ងៃឈប់សម្រាកថ្ងៃបុណ្យដែលត្រូវមានប្រាក់ឈ្នួល** | **អត្រាបន្ថែម ១០០% ឬគុណនឹង ២ ដង** |
| **កម្មករនិយោជិតធ្វើការបន្ថែមម៉ោងនៅពេលយប់ពីម៉ោង ២២ដល់ម៉ោង ៥ ភ្លឺ** | **អត្រាដំឡើង ១០០% ឬគុណនឹង ២ ដង** |

ដើម្បីគណនារកអត្រាប្រាក់ឈ្នួលបន្ថែមម៉ោង យើងត្រូវកំណត់អត្រាប្រាក់ឈ្នួលក្នុងមួយម៉ោងជាមុនសិន។ ការគណនាត្រូវធ្វើតាមរូបមន្តស្របតាមករណីនៃការងារបន្ថែមម៉ោង ដូចខាងក្រោម៖

❖ **អត្រាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងពីថ្ងៃចន្ទ ដល់ថ្ងៃសៅរ៍ ក្រៅពីម៉ោងការងារយប់**

- សម្រាប់កម្មករនិយោជិតទទួលប្រាក់ឈ្នួលតាមពេលវេលា
  - ប្រាក់ឈ្នួលក្នុង១ម៉ោង $= \frac{\text{ប្រាក់ឈ្នួលមូលដ្ឋានប្រចាំខែ} \times ១២\ (\text{ខែ})}{៤៨(\text{ម៉ោង}) \times ៥២(\text{សប្តាហ៍})} \times ១.៥$
  - ប្រាក់ឈ្នួលសរុប = ប្រាក់ឈ្នួលក្នុង១ម៉ោង × ចំនួនម៉ោងធ្វើការបន្ថែមម៉ោងសរុប
- សម្រាប់កម្មករនិយោជិតទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល (អ្នកស៊ីបុង)
  - ប្រាក់ឈ្នួលសរុប = ចំនួនបុងសរុប × ១.៥ × តម្លៃបុង

*(ប្រសិនបើទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផលមិនបានគ្រប់ "ប្រាក់ឈ្នួលមូលដ្ឋាន" កំណត់ ត្រូវគិតដូចអ្នកទទួលប្រាក់ឈ្នួលតាមពេលវេលាដែរ ដោយយក "ប្រាក់ឈ្នួលគោល" ធ្វើជាមូលដ្ឋាន)*

បន្ទាប់ពីរកឃើញអត្រាប្រាក់ឈ្នួលក្នុង១ម៉ោង យើងត្រូវយកអត្រានៃប្រាក់ឈ្នួលនេះគុណនឹង ចំនួនម៉ោងនៃការងារបន្ថែមម៉ោង និងអត្រាប្រាក់ឈ្នួលបន្ថែមម៉ោង ដោយត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

អត្រាប្រាក់ឈ្នួលក្នុង១ម៉ោង × ចំនួនម៉ោងធ្វើការបន្ថែមម៉ោង × អត្រាប្រាក់ឈ្នួលបន្ថែមម៉ោង = ប្រាក់ឈ្នួលបន្ថែមម៉ោង ។

❖ **អត្រាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងនៅពេលយប់ (ម៉ោង ២២ ដល់ម៉ោង៥)**

- សម្រាប់កម្មករនិយោជិតទទួលប្រាក់ឈ្នួលតាមពេលវេលា
  - ប្រាក់ឈ្នួលក្នុង១ម៉ោង$=\frac{\text{ប្រាក់ឈ្នួលមូលដ្ឋានប្រចាំខែ}\times\text{១២ (ខែ)}}{\text{៤៨}\left(\text{ម៉ោង}\right)\times\text{៥២ (សប្តាហ៍)}}\times\text{២}$
  - ប្រាក់ឈ្នួលសរុប = ប្រាក់ឈ្នួលក្នុង១ម៉ោង × ចំនួនម៉ោងធ្វើការបន្ថែមម៉ោងសរុប
- សម្រាប់កម្មករនិយោជិតទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល (អ្នកស៊ីបុង)
  - ប្រាក់ឈ្នួលសរុប = ចំនួនបុងសរុប × ២ × តម្លៃបុង

*(ប្រសិនបើទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផលមិនបានគ្រប់ "ប្រាក់ឈ្នួលមូលដ្ឋាន" កំណត់ ត្រូវគិតដូចអ្នកទទួលប្រាក់ឈ្នួលតាមពេលវេលាដែរ ដោយយក "ប្រាក់ឈ្នួលគោល" ធ្វើជាមូលដ្ឋាន)*

❖ **អត្រាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ឬថ្ងៃឈប់បុណ្យ**

- សម្រាប់កម្មករនិយោជិតទទួលប្រាក់ឈ្នួលតាមពេលវេលា
  - ប្រាក់ឈ្នួលក្នុង១ម៉ោង $=\frac{\text{ប្រាក់ឈ្នួលមូលដ្ឋានប្រចាំខែ }\times\text{១២ (ខែ)}}{\text{ចំនួនម៉ោងធ្វើការក្នុង១សប្តាហ៍ }\times\text{៥២ (សប្តាហ៍)}}\times\text{២}$
  - ប្រាក់ឈ្នួលសរុប = ប្រាក់ឈ្នួលក្នុង១ម៉ោង × ចំនួនម៉ោងធ្វើការសរុប
- សម្រាប់កម្មករនិយោជិតទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល (អ្នកស៊ីបុង)
  - ប្រាក់ឈ្នួលសរុប = ចំនួនបុងសរុប × ២ × តម្លៃបុង

*(ប្រសិនបើទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផលមិនបានគ្រប់ "ប្រាក់ឈ្នួលមូលដ្ឋាន" កំណត់ ត្រូវគិតដូចអ្នកទទួលប្រាក់ឈ្នួលតាមពេលវេលាដែរ ដោយយក "ប្រាក់ឈ្នួលគោល" ធ្វើជាមូលដ្ឋាន)*

### ២.៣. ការឈប់សម្រាកផ្សេងៗ

#### ២.៣.១. ការឈប់សម្រាកប្រចាំសប្តាហ៍

មាត្រា១៤៦ នៃច្បាប់ស្តីពីការងារបានបញ្ញត្តថា " *ត្រូវហាមឃាត់មិនឱ្យប្រើនិយោជិតកម្មករតែម្នាក់ដដែលៗលើសពីប្រាំមួយថ្ងៃក្នុងមួយសប្តាហ៍ទេ* "។ បន្ថែមលើនេះ មាត្រា១៤៧ នៃច្បាប់ស្តីពីការងារក៏បញ្ញត្តផងដែរថា "*ការឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវមានថិរវេលាអប្បបរមាម្ភៃបួនម៉ោងបន្តបន្ទាប់គ្នា។ តាមគោលការណ៍ ត្រូវឱ្យឈប់នៅថ្ងៃអាទិត្យសម្រាប់កម្មករនិយោជិតទាំងអស់* "។ ជាធម្មតា ម្ចាស់សហគ្រាស នាយកសហគ្រាស ឬអ្នកចាត់ការ ដែលចង់ព្យួរការឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវសុំសេចក្តីអនុញ្ញាតពីអធិការការងារនៅមុនចាប់ផ្តើមធ្វើការព្យួរ វៀរលែងតែក្នុងករណីប្រធានសក្តិ (មាត្រា១៦០ នៃច្បាប់ស្តីពីការងារ)។

ចំពោះការលើកពេលឈប់សម្រាកនៅថ្ងៃអាទិត្យ ច្បាប់ស្តីពីការងារ ត្រង់មាត្រា១៤៨ ចែងថា ប្រសិនបើការឈប់សម្រាករបស់កម្មករនិយោជិតទាំងអស់នៅថ្ងៃអាទិត្យតែម្តងនាំឱ្យខូចប្រយោជន៍ ដល់សាធារណជន ឬក៏ធ្វើឱ្យខូចដំណើរការធម្មតានៃសហគ្រាស គ្រឹះស្ថាន នោះនិយោជកអាចស្នើសុំមកក្រសួងទទួលបន្ទុកវិស័យការងារ ដើម្បីរៀបចំការឈប់សម្រាកនេះដូចខាងក្រោម៖

- ឱ្យបុគ្គលិកគ្រឹះស្ថានទាំងអស់សម្រាកនៅថ្ងៃមួយទៀតក្រៅពីថ្ងៃអាទិត្យ។
- សម្រាកពីថ្ងៃត្រង់នៃថ្ងៃអាទិត្យទៅថ្ងៃត្រង់នៃថ្ងៃចន្ទ។
- សម្រាកផ្លាស់វេនគ្នាគ្រប់កម្មករនិយោជិតទាំងអស់។

#### ២.៣.២. ការឈប់សម្រាកដោយមានប្រាក់ឈ្នួល

❖ **ថ្ងៃឈប់បុណ្យដែលត្រូវបានប្រាក់ឈ្នួល៖** យោងតាមច្បាប់ស្តីពីការងារ ត្រង់មាត្រា១៦១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចេញប្រកាសមួយជារៀងរាល់ឆ្នាំ ដើម្បីកំណត់ថ្ងៃបុណ្យដែលត្រូវឈប់មានប្រាក់ឈ្នួល សម្រាប់កម្មករនិយោជិតនៃសហគ្រាសទាំងអស់។ មាត្រា១៦២ នៃច្បាប់ស្តីពីការងារ ក៏ចែងផងដែរថា ក្នុងករណីថ្ងៃបុណ្យដែលត្រូវបានឈប់សម្រាកត្រូវចំលើថ្ងៃអាទិត្យនោះ កម្មករនិយោជិតនឹងត្រូវបានឈប់សម្រាកមួយថ្ងៃបន្តទៀត។ មាត្រា១៦៣ នៃច្បាប់ស្តីពីការងារ តម្រូវឱ្យនិយោជកផ្តល់ប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួលដែលបង់ខាតមកពីមានការឈប់បុណ្យ ចំពោះកម្មករនិយោជិតធ្វើការតាមម៉ោង ប្រចាំថ្ងៃ ឬតាមបរិមាណផលិតផល។

ច្បាប់ស្តីពីការងារ ត្រង់មាត្រា ១៦៤ ក៏បញ្ញត្តផងដែរថា កម្មករនិយោជិតទាំងឡាយដែលជាប់ធ្វើការក្នុងថ្ងៃឈប់បុណ្យ ត្រូវមានសិទ្ធិទទួលក្រៅអំពីប្រាក់ឈ្នួលនៃការងារដែលខ្លួនបានធ្វើ នូវប្រាក់បំណាច់មួយដែលនៅលើបន្ទុកនិយោជកដែរ ហើយដែលកម្រិតក្នុងប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។

❖ **ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ៖** ច្បាប់ស្តីពីការងារ ត្រង់មាត្រា១៦៦ បញ្ញត្តថាកម្មករនិយោជិតទាំងអស់ត្រូវមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំ មានប្រាក់ឈ្នួល ដែលនិយោជកត្រូវចេញឱ្យ។ ឈប់សម្រាកនេះត្រូវគិតជាថ្ងៃធ្វើការធម្មតាមួយថ្ងៃកន្លះ ក្នុងរយៈពេលធ្វើការ១ខែជាប់។ ថិរវេលានៃថ្ងៃឈប់សម្រាកនេះ ត្រូវបន្ថែមឱ្យកម្មករនិយោជិតតាមអតីតភាពរបស់ខ្លួនក្នុងសហគ្រាស ដោយត្រូវបន្ថែមមួយថ្ងៃ "ថ្ងៃធ្វើការ" ក្នុងរយៈពេលធ្វើការបាន៣ឆ្នាំ។ ដូច្នេះមានន័យថាសម្រាប់កម្មករនិយជិតធ្វើការជាប់លាប់ នោះគាត់នឹងទទួលបានថ្ងៃឈប់សម្រាកចំនួន១,៥ក្នុងមួយខែ ត្រូវជា១៨ថ្ងៃក្នុង១ឆ្នាំ។ ចំនួនថ្ងៃនេះនឹងត្រូវបាន

បន្ថែមចំនួន១ថ្ងៃរៀងរាល់ពេលកម្មករនិយោជិតធ្វើការបានចំនួនបីឆ្នាំ មានន័យថា ពីឆ្នាំទី១ដល់ឆ្នាំទី៣ កម្មករនិយោជិតមានថ្ងៃឈប់សម្រាកប្រចាំឆ្នាំ១៨ថ្ងៃ/១ឆ្នាំ; ឆ្នាំទី៤ដល់ឆ្នាំទី៦ កម្មករនិយោជិតមានថ្ងៃឈប់សម្រាកប្រចាំឆ្នាំ១៩ថ្ងៃ/១ឆ្នាំ; ឆ្នាំទី៧ដល់ឆ្នាំទី៩ កម្មករនិយោជិតមានថ្ងៃឈប់សម្រាកប្រចាំឆ្នាំ ២០ថ្ងៃ ក្នុង១ឆ្នាំ និងបន្ថែមមួយថ្ងៃយ៉ាងដូច្នេះរហូតរៀងរាល់បីឆ្នាំការងាររបស់កម្មករនិយោជិត ដោយមិនមានកំណត់ចំនួនអតិបរមានៃការបន្ថែមនេះនោះទេ។

មាត្រា១៦៦ កថាខណ្ឌ៣ ក៏បានបញ្ញត្តផងដែរថា "នៅក្នុងមុខរបរដែលការងារប្រព្រឹត្តទៅមិនទៀងទាត់ក្នុងមួយឆ្នាំ កាលបើកម្មករនិយោជិតបានធ្វើការក្នុងមួយខែបានម្ភៃមួយថ្ងៃជាមធ្យមនោះ គេត្រូវចាត់ទុកថាបានធ្វើការជាប់ហើយ។ ដោយឡែកចំពោះករណីកម្មករនិយោជិតមិនជាប់លាប់ មាត្រា១០នៃច្បាប់ស្តីពីការងារបានចែងថា "កម្មករនិយោជិតម្តងម្កាលត្រូវប្រតិបត្តិនូវវិជាន និងកាតព្វកិច្ចដូចគ្នានឹងកម្មករនិយោជិតជាប់លាប់ ហើយក៏មានសិទ្ធិដូចគ្នាដែរ។ ជាមួយគ្នានេះ មាត្រា១៦៦ កថាខណ្ឌ២បានចែងថា "កម្មករនិយោជិតណាដែល មិនបានធ្វើការចំនួនពីរខែបន្តបន្ទាប់ទេ មានសិទ្ធិនៅពេលផ្តាច់កិច្ចសន្យាការងារ ទទួលនូវប្រាក់បំណាច់ឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល ដោយគិតជាសមាមាត្រនឹងពេលវេលាដែលបានធ្វើការក្នុងសហគ្រាស" ។

ដូច្នេះយោងតាមមាត្រាខាងលើនេះ មានន័យថាកម្មករនិយោជិតមិនជាប់លាប់ក៏ទទួលបាននូវការឈប់សម្រាកប្រចាំឆ្នាំសមមាត្រទៅនឹងពេលវេលាធ្វើការរបស់ពួកគេនៅក្នុងសហគ្រាសគ្រឹះស្ថាន។

ច្បាប់ស្តីពីការងារ ត្រង់មាត្រា១៦៧ ក៏បានកំណត់ផងដែរថា ទាល់តែកម្មករនិយោជិតធ្វើការមកបានគ្រប់មួយឆ្នាំ ទើបអាចមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំនេះ។ យោងមាត្រា១៧០នៃច្បាប់ស្តីពីការងារការឈប់សម្រាកប្រចាំឆ្នាំ ត្រូវអនុញ្ញាតក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ លើកលែងតែមានកិច្ចព្រមព្រៀងលើពេលណាមួយទៀតរវាងនិយោជក និងកម្មករនិយោជិត។ ក្នុងករណីនេះនិយោជកត្រូវជូនដំណឹងជាមុនមកអធិការការងារអំពីការដែលបានស្រុះស្រួលគ្នា។ ដូច្នេះយោងតាមស្មារតីនៃច្បាប់ស្តីពីការងារ បើទោះបីជាការឈប់សម្រាកប្រចាំឆ្នាំជាផលប្រយោជន៍របស់ កម្មករនិយោជិតក៏ពិតមែន ប៉ុន្តែមិនមានន័យថាកម្មករនិយោជិតអាចប្រើប្រាស់ការឈប់សម្រាកនេះដោយអត្តនោម័តនោះទេ ដោយច្បាប់បានតម្រូវឱ្យភាគីទាំងពីរមានការឯកភាពគ្នាក្នុងការប្រើប្រាស់សិទ្ធិនេះជៀសវាង ការដែលប្រើប្រាស់សិទ្ធិឈប់សម្រាកប្រចាំឆ្នាំ របស់កម្មករនិយោជិតនាំឱ្យប៉ះពាល់ដល់ សង្វាក់ផលិតកម្មរបស់សហគ្រាស។

ប៉ុន្តែទោះបីជាច្បាប់កំណត់អំពីអតីតភាពរបស់កម្មករនិយោជិត១ឆ្នាំទើបមានសិទ្ធិប្រើប្រាស់ការឈប់សម្រាកនេះក៏ដោយ ប៉ុន្តែក្នុងករណីដែលគោលនយោបាយសហគ្រាសគ្រឹះស្ថានអនុញ្ញាតឱ្យកម្មករនិយោជិតអាចប្រើប្រាស់ការឈប់សម្រាកនេះក្នុងឆ្នាំដំបូង នោះច្បាប់ក៏មិនមានការហាមឃាត់នោះទេ។

ច្បាប់ស្តីពីការងារ បានហាមឃាត់មិនឱ្យមានអនុសញ្ញារួមណាដែលមានគ្រោងឱ្យប្រាក់បំណាច់ដោយទូទាត់សម្រាប់ជួសការឈប់សម្រាកប្រចាំឆ្នាំ ព្រមទាំងការព្រមព្រៀងស្តីពីការបោះបង់ឬមិនព្រមប្រើសិទ្ធិឈប់សម្រាកប្រចាំឆ្នាំ មានន័យថានិយោជកមិនអាចដោះដូរការឈប់សម្រាករបស់កម្មករនិយោជិតជាមួយនឹងការបង់ប្រាក់ជំនួសនោះបានឡើយ បើទោះបីជាមានការយល់ព្រមពីកម្មករនិយោជិតក៏ដោយ។ ក្នុងន័យ

ជាមួយគ្នានេះដែរ ក៏ត្រូវហាមឃាត់និយោជកមិនត្រូវបង្ខំឱ្យកម្មករនិយោជិត ប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំក្នុងកំឡុងពេលដែលសហគ្រាសគ្រឹះស្ថានពុំមានការងារធ្វើនោះដែរ។

ច្បាប់ស្តីពីការងារក៏បានកំណត់បន្ថែមទៀតថា ក្នុងករណីដែលមានផ្តាច់ ឬចប់កិច្ចសន្យាមុនដែលកម្មករនិយោជិតបានទទួល សិទ្ធិឈប់សម្រាកនោះត្រូវសងប្រាក់បំណាច់ទៅកម្មករនិយោជិតនោះតាមកម្រិតកំណត់ក្នុងមាត្រា១៦៦នៃច្បាប់ស្តីពីការងារ។ ដូច្នេះការទូទាត់ជាលុយអាចធ្វើទៅបានតែក្នុងករណីនៅពេលបញ្ចប់កិច្ចសន្យាការងារ ហើយកម្មករនិយោជិតនៅសល់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំតែប៉ុណ្ណោះ។ ច្បាប់ស្តីពីការងារ បានហាមឃាត់មិនឱ្យមានអនុសញ្ញារួមណា ដែលមានគ្រោងឱ្យប្រាក់បំណាច់ដោយទូទាត់សម្រាប់ជួសការឈប់សម្រាក ប្រចាំឆ្នាំ ព្រមទាំងការព្រមព្រៀងស្តីពីការបោះបង់ឬមិនព្រមប្រើសិទ្ធិឈប់សម្រាកប្រចាំឆ្នាំ។

ចំពោះការលើកសិទ្ធិឈប់សម្រាកប្រចាំឆ្នាំ ច្បាប់ស្តីពីការងារបានកំណត់ថា មិនត្រូវចាត់ទុកថាកម្មករនិយោជិតបានលះបង់សិទ្ធិឈប់សម្រាកប្រចាំឆ្នាំនោះទេ ប្រសិនបើសាមីកម្មករនិយោជិតសុខចិត្តលើកសិទ្ធិឈប់សម្រាកខ្លះ ឬទាំងមូលទៅប្រើនៅពេលចប់កិច្ចសន្យា។ ប៉ុន្តែកម្មករនិយោជិតមានសិទ្ធិពន្យារការឈប់សម្រាកនេះយ៉ាងច្រើនបំផុតត្រឹមបីឆ្នាំបន្តបន្ទាប់គ្នា ហើយអាចអនុវត្តបានតែចំពោះភាគ នៃការឈប់សម្រាកណាដែលហួសពី១២ថ្ងៃ ដែលជាថ្ងៃធ្វើការក្នុងមួយឆ្នាំ (មាត្រា១៦៧ នៃច្បាប់ស្តីពីការងារ)។

### ២.៣.៣. ការឈប់សម្រាកពិសេស និងការឈប់សម្រាកដទៃផ្សេងទៀត

❖ **ការឈប់សម្រាកពិសេស៖** កម្មករនិយោជិតអាចឈប់សម្រាករហូតដល់ ៧ថ្ងៃ ដោយមូលហេតុផ្ទាល់ខ្លួនដែលប៉ះពាល់ដល់គ្រួសារ។ ហើយនិយោជកមិនត្រូវបដិសេធដោយមិនសមហេតុផលលើការឈប់សម្រាកនេះទេ។ ក្នុងឱកាសដែលកម្មករនិយោជិតមានធុរៈផ្ទាល់ខ្លួន ឬក្នុងឱកាសមានព្រឹត្តិការណ៍ប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃកម្មករនិយោជិតនោះ ដូចជា៖ ការរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន ប្រពន្ធសម្រាលកូន រៀបអាពាហ៍ពិពាហ៍កូន ប្តី ប្រពន្ធ កូន ឪពុក ម្តាយ មានជំងឺ ឬទទួលមរណភាព។ (យោងមាត្រា១៧១ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ២៦៧ សកបយ. ស្តីពីការឈប់សម្រាកពិសេស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ )។

❖ **ការឈប់សម្រាកដោយជំងឺ៖** កម្មករនិយោជិតដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យ នោះនិយោជកត្រូវតែផ្តល់ការឈប់ សម្រាកឈឺទៅកម្មករនិយោជិតតហូតដល់ ៦ខែ ប្រសិនបើកម្មករនិយោជិត អវត្តមានពីការងារដោយសារជំងឺ និងមានលិខិតបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ។ និយោជកអាចបញ្ចប់ការងារកម្មករនិយោជិតបាន ប្រសិនបើកម្មករ និយោជិតនោះ ឈប់សម្រាកឈឺលើសពី ៦ខែ។ (យោងមាត្រា៧១ នៃច្បាប់ស្តីពីការងារ)។

❖ **ការឈប់សម្រាកលំហែមាតុភាព៖** និយោជកត្រូវតែផ្តល់ឱ្យកម្មករនិយោជិតដែលសម្រាលកូននូវការឈប់សម្រាកលំហែមាតុភាពចំនួន៩០ថ្ងៃ។ ហើយនិយោជកមិនត្រូវបញ្ឈប់កម្មករនិយោជិតដោយមូលហេតុមានផ្ទៃពោះ នៅពេលកំពុងឈប់លំហែមាតុភាព ឬមុនពេលឈប់លំហែមាតុភាពបានទេ។ និយោជកត្រូវឱ្យនូវប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំពាក់កណ្តាលទៅកម្មករនិយោជិតដែលមានអតីតភាពការងារយ៉ាងតិច១ឆ្នាំក្នុងអំឡុងពេលឈប់លំហែមាតុភាព។ និយោជក ត្រូវគិតប្រាក់ឈ្នួលដោយផ្អែកតាមមូលដ្ឋានប្រាក់ឈ្នួលជាមធ្យមភាគរបស់កម្មករនិយោជិតក្នុងអំឡុងពេល១២ខែ។ ក្រោយពីឈប់សម្រាលកូនមក ក្នុងរយៈ

ពេល២ខែដែលបានចូលធ្វើការ ត្រូវឱ្យស្ត្រីធ្វើតែការងារណាស្រាលៗ។ ដូចគ្នានេះដែរ កម្មករនិយោជិតនឹងទទួលបាននូវរយៈពេល១ម៉ោងក្នុងថ្ងៃធ្វើការដើម្បីបំបៅដោះកូនក្នុង រយៈពេល១ឆ្នាំចាប់ពីថ្ងៃដែលសម្រាលកូនរួច។ (យោងមាត្រា ៤៦ នៃរដ្ឋធម្មនុញ្ញ, មាត្រា១៨២,១៨៣,១៨៤ និង១៨៥ នៃច្បាប់ស្តីពីការងារ)។

❖ **ការឈប់សម្រាកដោយគ្រោះថ្នាក់ការងារ(ឬជំងឺវិជ្ជាជីវៈ)៖** គឺគ្រោះថ្នាក់ ឬដែលកើតឡើងទាក់ទងនឹងការងារចំពោះកម្មករ និយោជិត ដោយសារធ្វើការ ក្នុងម៉ោងធ្វើការ ឬពេលពួកគេកំពុងធ្វើដំណើរដោយត្រង់ពីផ្ទះទៅកន្លែងធ្វើការ ឬពី កន្លែងធ្វើការទៅផ្ទះ។ (យោងមាត្រា២៤៨ និង២៥៧ នៃច្បាប់ស្តីពីការងារ និងត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលទាក់ទងនឹងបេឡាជាតិរបបសន្តិសុខសង្គម)។

## ២. កិច្ចសន្យាការងារ

### សញ្ញាណទូទៅនៃកិច្ចសន្យាការងារ

### ២.១. និយមន័យ

យោងមាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី "កិច្ចសន្យា គឺជាកិរិយាដែលបុគ្គល២នាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច"។ មានន័យថាទំនាក់ទំនង នៃកិច្ចសន្យាចងភ្ជាប់ដោយកាតព្វកិច្ច។ កិច្ចសន្យា គឺជាច្បាប់របស់គូភាគី។ យោងតាមមាត្រា១ នៃក្រឹត្យច្បាប់លេខ៣៨ ដែលត្រូវបាននិរាករណ៍ដោយក្រមរដ្ឋប្បវេណី ចែងថា៖ "កិច្ចសន្យា គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គល២នាក់ ឬច្រើននាក់ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬច្រើនដែលទាក់ទិននឹងខ្លួន។

ក្នុងអត្ថន័យខាងលើ បុគ្គលអាចជារូបវន្តបុគ្គល ជានីតិបុគ្គល។ នីតិបុគ្គល អាចធ្វើកិច្ចសន្យាតាមរយៈបុគ្គលដែលជាតំណាងរបស់ខ្លួន។"

**អ្វីទៅជាកិច្ចសន្យាការងារ? គេថាកិច្ចសន្យាការងារ ជាកិច្ចសន្យាពិសេស ជាងកិច្ចសន្យាទូទៅ ហេតុអ្វី?**

យោងមាត្រា៦៦៤ នៃក្រមរដ្ឋប្បវេណី "១.កិច្ចសន្យាការងារ ត្រូវបានបង្កើតឡើងដោយការសន្យារបស់ភាគីម្ខាងថា ធ្វើពលកម្មឱ្យភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតសន្យាថា ផ្តល់ប្រាក់ឈ្នួល ទៅលើកិច្ចការពលកម្មនោះ។..." យោងតាមមាត្រា៦៥ នៃច្បាប់ស្តីពីការងារ៖ "កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងារ រវាងកម្មករនិយោជិត និងនិយោជក។ កិច្ចសន្យានេះត្រូវនៅក្រោមវិជានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទំរង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា។

កិច្ចសន្យានេះអាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយមាត់ទទេ។ កិច្ចសន្យានេះអាចសរសេរ និងចុះហត្ថលេខាទៅតាមទំលាប់ស្រុក ហើយប្រសិនជាត្រូវចុះបញ្ជិកា ក៏ត្រូវធ្វើដោយឥតបង់ពន្ធអ្វីឡើយ។

កិច្ចសន្យាធ្វើដោយមាត់ទទេ ត្រូវទុកដូចជាមានការព្រមព្រៀងរវាងនិយោជក និងកម្មករនិយោជិតតាមលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ជាការងារ ទោះបីមិនមានបញ្ជាក់ច្បាស់លាស់ក៏ដោយ"។

ជាគោលការណ៍ទូទៅ ថ្វីត្បិតតែច្បាប់ស្តីពីការងារពុំបានកំណត់ច្បាស់លាស់ក្តី គេអាចនិយាយបានថានៅក្នុងកិច្ចសន្យាការងារមានលក្ខណៈវិនិច្ឆ័យ ៣យ៉ាង៖

- ការងារ៖ កម្មករនិយោជិតបំពេញការងារ ជូននិយោជក
- ប្រាក់ឈ្នួល៖ ជាផលតបស្នង និយោជកនឹងផ្តល់ប្រាក់ឈ្នួលតាមការព្រមព្រៀងគ្នាដល់កម្មករនិយោជិត (យ៉ាងហោចណាស់ស្មើនឹងប្រាក់ឈ្នួលអប្បបរមា បើមាន)
- ចំណងអធិនភាព៖ កម្មករនិយោជិត ត្រូវបំពេញការងារក្រោមការដឹកនាំ និងគ្រប់គ្រងរបស់និយោជក (មាត្រា៣)។

ក្នុងន័យនេះ និយោជកផ្តល់នូវការងារដល់កម្មករនិយោជិតដើម្បីបំពេញជាថ្នូរ និងប្រាក់ឈ្នួលដែលនិយោជកផ្តល់ឱ្យ ហើយកម្មករនិយោជិតត្រូវស្ថិតនៅជាចំណុះនិយោជក។ លក្ខណៈទាំងនេះហើយដែលនាំឱ្យកិច្ចសន្យាការងារមានលក្ខណៈខុសគ្នាពីកិច្ចសន្យាដទៃ។

### ២.២. ប្រភេទនៃកិច្ចសន្យាការងារ

មុននឹងឈានទៅដល់ការបង្កើតទំនាក់ទំនងការងាររវាងកម្មករនិយោជិត និងនិយោជកតាមរយៈកិច្ចសន្យាការងារមានថិរវេលាកំណត់ ឬកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ភាគីទាំងពីរអាចព្រមព្រៀងគ្នាឱ្យមានការចុះកិច្ចសន្យាសាកល្បងការងារ មុននឹងចាប់ផ្តើមការងារពេញលេញក្នុងនាមជាកម្មករនិយោជិតពេញសិទ្ធិ។

#### ២.២.១.កិច្ចសន្យាសាកល្បង

មាត្រា៦៨ នៃច្បាប់ស្តីពីការងារចែងថា "ការចុះកិច្ចសន្យាសាកល្បងការងារមិនអាចមានថិរវេលាលើសកាលបរិច្ឆេទជាចាំបាច់សំរាប់ឱ្យនិយោជកវិនិច្ឆ័យវិជ្ជាជីវៈនៃកម្មករនិយោជិត ហើយនិងសម្រាប់កម្មករនិយោជិតស្គាល់យ៉ាងជាក់ច្បាស់នូវលក្ខខណ្ឌនៃការងារដែលគេផ្តល់ឱ្យនោះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការចុះកិច្ចសន្យាសាកល្បងការងារមិនអាចមានថិរវេលាលើសពី ៣ខែទេ ចំពោះនិយោជិត ២ខែចំពោះកម្មករឯកទេស និង១ខែចំពោះកម្មករធម្មតា។"

កិច្ចសន្យាសាកល្បងនេះ ពុំមែនជាកិច្ចសន្យាការងារទេ ប៉ុន្តែជារយៈពេលសាកល្បង ឬអន្តរកាលមុននឹងឈានទៅបង្កើតចំណងគតិយុត្តរវាងកម្មករនិយោជិត និងនិយោជក ក្រោមចំណងជាកិច្ចសន្យាការងារប្រភេទណាមួយ។ ផ្អែកតាមរយៈពេលនេះ និយោជកអាចវិនិច្ឆ័យបានថាតើកម្មករនិយោជិតនោះ ស័ក្តិសមសម្រាប់ការងារ ឬទេ? រីឯកម្មករនិយោជិតវិញ ក៏អាចដឹងបានថាតើលក្ខខណ្ឌ ឬបរិយាកាសការងារពេញចិត្តសម្រាប់ខ្លួនដែរ ឬទេ។

កិច្ចសន្យាសាកល្បងនេះ ពុំមែនជាកាតព្វកិច្ចដែលតម្រូវឱ្យមាននៅមុនពេលចុះកិច្ចសន្យាការងារទេ។

ក្នុងកំឡុងពេលសាកល្បងនេះ កម្មករនិយោជិតមិនទទួលបានអត្ថប្រយោជន៍ ឬការការពារ ដូចកម្មករនិយោជិតពេញសិទ្ធិនោះទេ ជាពិសេសនីតិវិធីនៃការបញ្ឈប់កម្មករនិយោជិតក្នុងកំឡុងពេលសាកល្បងការងារ។ យោងតាមមាត្រា៨២ នៃច្បាប់ស្តីពីការងារ ភាគីទាំងពីរពុំមានកាតព្វកិច្ចជូនដំណឹងមុនអំពីការផ្តាច់កិច្ចសន្យាសាកល្បងការងារទេ។ មួយវិញទៀត ផ្អែកតាមប្រកាស ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ក្រុមការងារត្រីភាគីតែងតែឯកភាពគ្នាក្នុងការផ្តល់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសាកល្បងការងារ តិចជាងកម្មករនិយោជិតពេញសិទ្ធិ។ ប៉ុន្តែទោះបីជាមានការកំណត់បែបនេះក៏ដោយ ក៏មិនមែនមានន័យថានិយោជកមិនអាចផ្តល់ប្រាក់ឈ្នួល ឬអត្ថប្រយោជន៍ផ្សេងទៀតដូចគ្នានឹងកម្មករនិយោជិតពេញសិទ្ធិនោះទេ ទោះស្ថិតក្នុងវិស័យណាក៏ដោយ។

ច្បាប់ស្តីពីការងារ មិនបានកំណត់លក្ខខណ្ឌអ្វីច្រើនក្រៅតែពីថិរវេលាអតិបរមា នៃការសាកល្បងការងារតែប៉ុណ្ណោះ។ ការកំណត់រយៈពេលបែបនេះ គឺជាផ្នែកមួយដ៏សំខាន់បំផុតក្នុងការការពារពី ការរំលោភបំពានដោយចេតនាក្តីអចេតនាក្តីទៅលើកំលាំងពលកម្មរបស់កម្មករនិយោជិត។ ក្នុងករណីដែលច្បាប់ពុំបានកំណត់រយៈពេលអតិបរមាសម្រាប់ការវាស់ស្ទង់សមត្ថភាពវិជ្ជាជីវៈ របស់កម្មករនិយោជិតទេ ហើយក្នុងរយៈពេលសាកល្បងនេះ ច្បាប់ក៏ពុំបានផ្តល់ការការពារពេញលេញដូចជាកម្មករនិយោជិតពេញសិទ្ធិទៀត និយោជកអាចនឹងប្រើប្រាស់ចន្លោះប្រហោងនៃច្បាប់នេះ ដើម្បីប្រើកម្មករនិយោជិតក្នុងនាមជាអ្នកសាកល្បងការងារយូរជាងនេះដើម្បីកេងចំណេញ។

ច្បាប់ស្តីពីការងារក៏មិនបានកំណត់ដែរអំពីលក្ខខណ្ឌទម្រង់នៃកិច្ចសន្យានេះដែរ។ មិនមានការកំណត់ថាកិច្ចសន្យាសាកល្បងការងារ ត្រូវរៀបចំយ៉ាងដូចម្តេច ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង យើងសង្កេតឃើញថាភាគីអាចចុះកិច្ចសន្យាដោយឡែកមួយ ដែលកំណត់អំពីលក្ខខណ្ឌនៃការសាកល្បងការងារ ឬកំណត់យករយៈពេលសម្រាប់សាកល្បងការងារជា "ខ" នៃកិច្ចសន្យាការងារវិញ។ ទម្រង់ទាំង២នេះ សុទ្ធតែមិនផ្ទុយនឹងច្បាប់ ឱ្យតែគោរពរយៈពេលអតិបរមាដែលច្បាប់អនុញ្ញាត។

### ២.២.២. កិច្ចសន្យាការងារមានកំណត់ថិរវេលា

កិច្ចសន្យាការងារមានកំណត់ថិរវេលា គឺជាកិច្ចសន្យាការងារដែលធ្វើឡើងសម្រាប់ថិរវេលាមួយជាកំណត់។ មាត្រា៦៧ នៃច្បាប់ស្តីពីការងារចែងថា៖

- នៅពេលចុះហត្ថលេខាលើកិច្ចសន្យាការងារ ដែលធ្វើឡើងដោយការព្រមព្រៀងគ្នាដោយកំណត់ថិរវេលាពិតប្រាកដ ត្រូវតែមានចែងកាលបរិច្ឆេទច្បាស់លាស់នៃការបញ្ចប់កិច្ចសន្យានោះ។

- កិច្ចសន្យាការងារដែលធ្វើឡើងដោយការព្រមព្រៀងគ្នា ដោយមានកំណត់ថិរវេលាពិតប្រាកដមិនអាចមានរយៈពេលលើសពី ពីរឆ្នាំបានឡើយ។ កិច្ចសន្យានេះ អាចបន្តសារជាថ្មីម្តង ឬច្រើនដង ដរាបណាការបន្តសារជាថ្មីនោះមានថិរវេលាអតិបរមាមិនលើសពី ពីរឆ្នាំ។"

ការអនុវត្តផ្ទុយពីវិធានខាងលើ នាំឱ្យកិច្ចសន្យានោះក្លាយជាគ្មានកំណត់ថិរវេលាពិតប្រាកដ។

- កិច្ចសន្យាការងារមានកំណត់ថិរវេលាពិតប្រាកដ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ បើមិនធ្វើជាលាយលក្ខណ៍អក្សរទេ កិច្ចសន្យាការងារនេះក្លាយជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។

- នៅពេលណាកិច្ចសន្យា ដែលធ្វើឡើងដោយមានកំណត់ថិរវេលាពិតប្រាកដតិចជាង ឬស្មើនឹងពីរឆ្នាំត្រូវបន្តដោយស្ងៀមស្ងាត់នៅពេលផុតកំណត់នោះ កិច្ចសន្យាត្រូវចាត់ទុកជាកិច្ចសន្យាការងារ មានថិរវេលាមិនកំណត់។

មាត្រា៧៣ កថាខណ្ឌទី៥នៃច្បាប់ស្តីពីការងារចែងថា "ប្រសិនបើកិច្ចសន្យាមានកំណត់ថិរវេលាលើសពីប្រាំមួយខែ កម្មករនិយោជិតត្រូវបានគេជូនដំណឹងជាមុន ចំនួនដប់ថ្ងៃ អំពីការផុតរលត់នៃកិច្ចសន្យា ឬការមិនបន្តឡើងវិញនៃកិច្ចសន្យា។ រយៈពេលជូនដំណឹងមុននេះ ត្រូវកំណត់ឱ្យដល់ដប់ប្រាំថ្ងៃ ចំពោះកិច្ចសន្យាដែលមានថិរវេលាលើសពីមួយឆ្នាំ។ បើគ្មានការជូនដំណឹងមុនទេ កិច្ចសន្យាត្រូវបន្តក្នុងថិរវេលាស្មើគ្នានឹងថិរវេលាដែលបានចុះកិច្ចសន្យាគ្រាដំបូង ឬត្រូវចាត់ទុកថាជាកិច្ចសន្យាការងារ មានថិរវេលាមិនកំណត់បើថិរវេលាសរុបនៃការបន្តកិច្ចសន្យានោះលើសពីថិរវេលាដែលមានកំណត់ក្នុង មាត្រា៦៧។"

តាមរយៈមាត្រាខាងលើនេះ ដើម្បីឱ្យកិច្ចសន្យាការងារមានកំណត់ថិរវេលាមានសុពលភាព នោះត្រូវគោរពលក្ខខណ្ឌ ៣ ជាចាំបាច់៖

- កិច្ចសន្យាត្រូវធ្វើជាលាយលក្ខណ៍អក្សរ។
- ត្រូវមានបញ្ជាក់កាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យា។
- មិនត្រូវមានរយៈពេលលើសពី ២ឆ្នាំទេ និងអាចបន្តសារជាថ្មីម្តង ឬច្រើនដងបាន ដរាបណាការបន្តសារជាថ្មីនោះមានចិរវេលាអតិបរមាមិនលើសពី២ឆ្នាំ។

ការបកស្រាយនេះ ក៏ត្រូវបានបញ្ជាក់បន្ថែម តាមរយៈសេចក្តីណែនាំលេខ០៥០/១៩ ក.ប/ស.ណ.ន.គ.ប.ក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការកំណត់ប្រភេទកិច្ចសន្យាការងារផងដែរ។

**ឧទាហរណ៍៖**

- ទី១.បើកិច្ចសន្យាការងារលើកទី១មានចិរវេលាកំណត់៦ខែ ដូច្នេះចិរវេលាសរុបនៃកិច្ចសន្យាមានចិរវេលាកំណត់ជាអតិបរមា ២ឆ្នាំ៦ខែ។
- ទី២.បើកិច្ចសន្យាការងារលើកទី១មានចិរវេលាកំណត់១ឆ្នាំ ដូច្នេះចិរវេលាសរុបនៃកិច្ចសន្យាមានចិរវេលាកំណត់ជាអតិបរមា ៣ឆ្នាំ។
- ទី៣.បើកិច្ចសន្យាការងារលើកទី១មានចិរវេលាកំណត់២ឆ្នាំ ដូច្នេះចិរវេលាសរុបនៃកិច្ចសន្យាមានចិរវេលាកំណត់ជាអតិបរមា ៤ឆ្នាំ។

❖ អញ្ញាត្រកម្មចំពោះរយៈពេលនៃកិច្ចសន្យាការងារមានចិរវេលាកំណត់៖

យោងតាមមាត្រា៦៧ កិច្ចសន្យាការងារមានកំណត់ចិរវេលា អាចមានកាលបរិច្ឆេទកំណត់មិនពិតប្រាកដ ប្រសិនបើកិច្ចសន្យានោះត្រូវបានធ្វើឡើងដើម្បី៖

- រ៉ាប់រងជំនួសកម្មករនិយោជិតណាម្នាក់ ដែលអវត្តមានជាបណ្តោះអាសន្ន។
- ការងាររយៈពេលមួយរដូវ។
- កំណើនម្តងម្កាលនៃការងារ ឬសកម្មភាពខុសធម្មតារបស់សហគ្រាស ។

ដូច្នេះ ចិរវេលានៃកិច្ចសន្យានេះត្រូវបានបញ្ចប់៖

- នៅពេលដែលកម្មករនិយោជិតណាម្នាក់ ដែលអវត្តមានជាបណ្តោះអាសន្ននោះត្រឡប់មកធ្វើការវិញ ឬការផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងនោះ។
- នៅពេលចប់រដូវ។
- នៅពេលកំណើនម្តងម្កាលនៃការងារ ឬសកម្មភាពខុសធម្មតារបស់សហគ្រាសត្រូវបញ្ចប់ ។

**ខ.៣ កិច្ចសន្យាការងារមានចិរវេលាមិនកំណត់**

កិច្ចសន្យាការងារមានចិរវេលាមិនកំណត់សំដៅដល់កិច្ចសន្យាការងារ ដែលភាគីទាំងពីរមិនបានកំណត់កាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យាការងារច្បាស់លាស់ កិច្ចសន្យានេះអាចធ្វើឡើងដោយលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ មានន័យថា ៖

- កិច្ចសន្យាការងារទាំងឡាយណាដែលធ្វើជាលាយលក្ខណ៍អក្សរ ប៉ុន្តែមិនមានកំណត់កាលបរិច្ឆេទច្បាស់លាស់ នៅតែជាកិច្ចសន្យាការងារដែលមានចិរវេលាមិនកំណត់។
- កិច្ចសន្យាការងារទាំងឡាយណាដែលធ្វើជាលាយលក្ខណ៍អក្សរ ទោះបីមានកំណត់កាលបរិច្ឆេទច្បាស់លាស់ក៏ដោយ ប៉ុន្តែកាលបរិច្ឆេទនោះលើសពី ២ ឆ្នាំ នៅតែជាកិច្ចសន្យាការងារដែលមានចិរវេលាមិនកំណត់។

- ក្នុងការអនុវត្តជាក់ស្តែង ជួនកាលនិយោជក និងកម្មករនិយោជិតបានព្រមព្រៀងដោយផ្ទាល់មាត់ រួចហើយអនុញ្ញាតឱ្យកម្មករនិយោជិតចូលធ្វើការតាមលក្ខខណ្ឌនៃបទបញ្ជាការងារ ឬបទបញ្ជាផ្ទៃក្នុង ដោយគ្រាន់តែតម្រូវឱ្យកម្មករនិយោជិតបំពេញតែប្រវត្តិរូប ក៏ចាត់ទុកថាជាកិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ផងដែរ (ជាកិច្ចសន្យាការងារដោយផ្ទាល់មាត់)។

### ២.២.៤ កិច្ចសន្យាការិយភារី

#### ២.២.៤.១. និយមន័យនៃកិច្ចសន្យាការិយភារី

យោងមាត្រា៤៥ នៃច្បាប់ស្តីពីការងារ " *ការិយភារី គឺជាអ្នកទទួលការពីសហគ្រិន ជ្រើសរើសកម្មករហត្ថពលិកដោយខ្លួនឯងតាមត្រូវការ ដើម្បីប្រតិបត្តិការងារ ឬផ្តល់សេវាណាមួយដោយគិតថ្លៃសរុប។*" ស្របតាមស្មារតីនៃមាត្រានេះ កិច្ចសន្យាការិយភារី គឺមានទំនាក់ទំនងគតិយុត្តរវាងបីភាគី គឺ ១)សហគ្រិន ២)ការិយភារីខ្លួនឯង និង ៣) កម្មករនិយោជិតរបស់ការិយភារី។ តាមន័យនេះ គឺមានកិច្ចសន្យាចំនួន២ ដែលត្រូវបានធ្វើឡើងដើម្បីប្រតិបត្តិការងារ ឬផ្តល់សេវាណាមួយជាកំណត់ ពោលគឺ ១)កិច្ចសន្យាការិយភារី ដែលធ្វើឡើងរវាងការិយភារី និងសហគ្រិន និង២) កិច្ចសន្យាការងារ ដែលធ្វើឡើងរវាងការិយភារី និង កម្មករនិយោជិតរបស់ការិយភារី។ ប៉ុន្តែយើងត្រូវកត់សម្គាល់ផងដែរថា សញ្ញាណការិយភារីនេះ គឺមានលក្ខណៈប្រហែលនឹងសញ្ញាណនៃអ្នកម៉ៅការ។

យោងតាមមាត្រា៦៥២ នៃក្រមរដ្ឋប្បវេណី " *កិច្ចសន្យាម៉ៅការ សំដៅទៅលើកិច្ចសន្យា មួយ ដែលភាគីម្ខាង មានករណីយកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាងទៀតមានករណីកិច្ចផ្តល់កម្រៃចំពោះលទ្ធផលនៃការងារដែលបានធ្វើនោះ។*" យោងលើខ្លឹមសារនៃមាត្រានេះ យើងអាចកំណត់សម្គាល់បានថា កិច្ចសន្យាម៉ៅការ គឺមានលក្ខណៈប្រហាក់ប្រហែលនឹងកិច្ចសន្យាការិយភារី ប្រសិនបើយើងវិភាគទៅលើខ្លឹមសារនៃមាត្រា៤៥ នៃច្បាប់ស្តីពីការងារ ដែលបានឱ្យនិយមន័យការិយភារី។ ជាក់ស្តែង អ្នកម៉ៅការ ដែលមានករណីកិច្ចសម្រេចការងារដែលបានព្រមព្រៀង ជាមួយម្ចាស់ការជាថ្នូរនឹងប្រាក់កម្រៃចំពោះលទ្ធផល ការងារ គឺមានលក្ខណៈប្រហាក់ប្រហែលទៅនឹងសញ្ញាណនៃការិយភារីដែលជាអ្នកទទួលការពីសហគ្រិន ដើម្បីប្រតិបត្តិការងារ ឬផ្តល់សេវាណាមួយដោយគិតថ្លៃសរុប។

សំនួរដែលត្រូវចោទសួរ គឺថាតើអ្នកម៉ៅការអាចជ្រើសរើសកម្មករនិយោជិតដោយខ្លួនឯងបានដែរ ឬទេ? ហើយថាតើកម្មករនិយោជិតនោះ មានបុព្វសិទ្ធិដូចគ្នានឹងកម្មករនិយោជិតរបស់ការិយភារីដែរឬទេ? ជាការពិតណាស់ អ្នកម៉ៅការគឺអាចជ្រើសរើសកម្មករនិយោជិតដោយខ្លួនឯងបាន ដោយមិនចាំបាច់សុំការអនុញ្ញាតពីម្ចាស់ការឡើយ ដូចគ្នាទៅនឹងលក្ខណៈរបស់ការិយភារីដែលអាចជ្រើសរើសកម្មករនិយោជិតដោយខ្លួនឯង ដោយមិនចាំបាច់សុំការអនុញ្ញាតពីសហគ្រិនឡើយ។ ជាការសន្និដ្ឋាន យើងអាចនិយាយបានថា អ្នកម៉ៅការនឹងត្រូវចាត់ទុកថាជាការិយភារី នៅពេលដែលអ្នកម៉ៅការនោះបានជ្រើសរើសកម្មករនិយោជិតដើម្បីជួយបំពេញការងាររបស់ខ្លួន ដែលទទួលបានពីម្ចាស់ការ។ ប៉ុន្តែ ត្រូវចាត់ទុកថាជាអ្នកម៉ៅការដដែល នៅពេលដែលអ្នកម៉ៅការនោះមិនមានប្រើប្រាស់កម្មករនិយោជិត ហើយបានបំពេញការងារដែលទទួលបានពីម្ចាស់ការដោយខ្លួនឯង។

**ដើម្បីស្វែងយល់ឱ្យបានច្បាស់រវាងសញ្ញាណនៃកិច្ចសន្យាទាំងពីរ យើងអាចពិនិត្យមើលគំនូសព្រួញដូចខាងក្រោម៖**

❖ កិច្ចសន្យាម៉ៅការ (ករណីអ្នកម៉ៅការមានប្រើប្រាស់កម្មករនិយោជិត)




❖ លក្ខណៈការិយការី (មាត្រា៤៥ នៃច្បាប់ស្តីពីការងារ)



## ២. កាតព្វកិច្ចរបស់ការិយការី

ការិយការីត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារដូចគ្នានឹងនិយោជក ដូចនេះមានន័យថា ការិយការីត្រូវទទួលខុសត្រូវដូចគ្នានឹងការទទួលខុសត្រូវរបស់និយោជកដែរ (មាត្រា៤៧ នៃច្បាប់ស្ដីពីការងារ)។ ក្នុងន័យនេះ ការិយការីត្រូវអនុវត្តកាតព្វកិច្ចមួយចំនួនដែលមានបញ្ញត្តក្នុងច្បាប់ស្ដីពីការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលមានជាអាទិ៍ដូចជាការចុះបញ្ជិកា និងទិដ្ឋាការសៀវភៅបើកប្រាក់ បទ ស្ដីពីសហគ្រាស គ្រឹះស្ថាន លក្ខខណ្ឌការងារ សុខភាព និងសុវត្ថិភាពការងារ សេរីភាពអង្គការវិជ្ជាជីវៈរបបសន្តិសុខសង្គម។ល។ ការិយការីក៏ត្រូវបានហាមឃាត់មិនឱ្យធ្វើការកេងប្រយោជន៍ ឬធ្វើការវាយបន្លោកថ្លៃកម្មករនិយោជិតបាននោះទេ(មាត្រា៤៦ នៃច្បាប់ស្ដីពីការងារ) ។

ការិយការីមានកាតព្វកិច្ចត្រូវបិទប្រកាសបញ្ជាក់នៅទីណាដែលគេងាយអាចអានបាន ក្នុងរោងជាង កណ្ដាគារ ឬការដ្ឋានធ្វើការនីមួយៗ នូវឋានៈរបស់ខ្លួន និងនាមអាស័យដ្ឋាន នៃសហគ្រិន ឬម្ចាស់នាយកសហគ្រាស គ្រឹះស្ថាន (មាត្រា៤៩ នៃច្បាប់ស្ដីពីការងារ)។ កាតព្វកិច្ចនេះ គឺមានសារសំខាន់ក្នុងការអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចការងារ កម្មករនិយោជិត ក៏ដូចជាសាធារណៈជនអាចដឹងនូវព័ត៌មានចាំបាច់មួយចំនួន ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិតប្រកបដោយប្រសិទ្ធិភាព ស្របតាមបញ្ញត្តិដែលអនុវត្តលើលក្ខណៈការងារ នៃការិយការី។

## ៣. កាតព្វកិច្ចរបស់និយោជកពាក់ព័ន្ធនឹងការិយការី

យោងមាត្រា៥០ នៃច្បាប់ស្ដីពីការងារ សហគ្រិន ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវកាន់ជាទៀងទាត់នូវបញ្ជីរាយនាមការិយការីដែលខ្លួនបានចុះកិច្ចសន្យាជាមួយ។ បញ្ជីរាយនាមនោះ ត្រូវបញ្ជាក់អំពីនាម អាស័យដ្ឋាន និងឋានៈនៃការិយការី ព្រមទាំងស្ថានភាពនៃទីកន្លែងធ្វើការនីមួយៗ និងត្រូវតែផ្ដល់ជូនទៅអធិការដ្ឋានការងារក្នុងរយៈពេល៧ថ្ងៃពេញ ក្រោយពីថ្ងៃធ្វើកិច្ចសន្យាជួលការិយការីនេះ។ ចំពោះសហគ្រាស គ្រឹះស្ថានផ្នែកកសិកម្ម រយៈពេលនៃការផ្ដល់បញ្ជីនេះ ត្រូវកំណត់ឱ្យដល់១៥ថ្ងៃ។

### ការប្រតិបត្តិកិច្ចសន្យាការងារ

### ៣.១. សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី

ជាគោលការណ៍ ភាគីនៃកិច្ចសន្យាការងារត្រូវកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនឱ្យបានច្បាស់លាស់នៅក្នុងកិច្ចសន្យា ដើម្បីបង្ការវិវាទដែលអាចកើតឡើងជាយថាហេតុ។ ដូចនេះកិច្ចសន្យាការងារគួរកំណត់ឱ្យបានច្បាស់លាស់អំពី៖

- សមាសភាពគូភាគី។
- ប្រភេទកិច្ចសន្យា និងកាលបរិច្ឆេទចាប់ផ្ដើមនៃការអនុវត្ត។
- ទីកន្លែងធ្វើការ។
- មុខងារ និងភារកិច្ចសំខាន់ៗ។
- រយៈពេលសាកល្បង។
- ម៉ោងធ្វើការ និងការឈប់សម្រាក។

- ប្រាក់ឈ្នួល និង អត្ថប្រយោជន៍ផ្សេងៗ។
- លក្ខខណ្ឌក្នុងការកែប្រែ ការបញ្ចប់ និងកាតព្វកិច្ចជូនដំណឹងមុន។
- ព័ត៌មានសម្ងាត់ ។
- ការដោះស្រាយវិវាទ។

ជាក់ស្តែង ទោះបីជាមានការលើកទឹកចិត្តឱ្យមានការកំណត់ដូចខាងលើក៏ដោយ គូភាគីនៃកិច្ចសន្យាការងារមានសិទ្ធិសេរីភាពក្នុងការចុះកិច្ចសន្យាតាមទម្រង់ និងទម្លាប់ស្រុករបស់ខ្លួន។ មាត្រា៦៥ នៃច្បាប់ស្តីពីការងារ បានកំណត់ថាកិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងាររវាងកម្មករនិយោជិត និងនិយោជក។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទម្រង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា។ កិច្ចសន្យានេះអាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយមាត់ទទេ។ "កិច្ចសន្យានេះអាចសរសេរ និងចុះហត្ថលេខាទៅតាមទំលាប់ស្រុក"។

### ៣.១.១. សិទ្ធិ និងកាតព្វកិច្ចរបស់និយោជក

**សិទ្ធិរបស់និយោជកៈ** យោងតាមស្មារតីនៃច្បាប់ស្តីពីការងារ និយោជកមានសិទ្ធិចាត់ចែង គ្រប់គ្រង និងបង្គាប់បញ្ជាកម្មករនិយោជិតរបស់ខ្លួន។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសិទ្ធិក្នុងការរៀបចំម៉ោង វេន ទីកន្លែងបំពេញការងារ ចិរវេលាសម្រាករបស់កម្មករនិយោជិត និងវិធានការវិន័យស្របតាមស្ថានភាពអាជីវកម្មរបស់ខ្លួនផងដែរ។ ជាគោលការណ៍សិទ្ធិចាត់ចែងទាំងនេះ ត្រូវកំណត់ឱ្យបានជាក់លាក់ជាមុននៅក្នុងកិច្ចសន្យាការងារ ឬបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន។ មាត្រា២២ នៃច្បាប់ស្តីពីការងារបានកំណត់ថា និយោជកនៃសហគ្រាស ឬគ្រឹះស្ថានដែលមានកម្មករនិយោជិតយ៉ាងតិចប្រាំបីនាក់ ត្រូវតែរៀបចំឱ្យមានបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថានមួយជាដរាប។ បទបញ្ជាផ្ទៃក្នុងនេះ គឺជាឯកសារសំខាន់សម្រាប់គាំទ្រសិទ្ធិចាត់ចែង គ្រប់គ្រង និងការវិធានការពិន័យរបស់និយោជក។

**កាតព្វកិច្ចរបស់និយោជកៈ** យោងតាមស្មារតីនៃច្បាប់ស្តីពីការងារ និយោជកមានកាតព្វកិច្ចក្នុងការផ្តល់ការងារ ឬសេវាឱ្យកម្មករនិយោជិតរបស់ខ្លួន ដោយត្រូវផ្តល់ប្រាក់ឈ្នួល រៀបចំបែងចែកចិរវេលាបំពេញការងារ និងចិរវេលាសម្រាក ស្របតាមការព្រមព្រៀង និងតាមច្បាប់កំណត់ជាធរមាន។ ទន្ទឹមនឹងនេះ និយោជកត្រូវធានាឱ្យបាននូវសុវត្ថិភាព និងសុខភាពការងារ និងសេចក្តីថ្លៃថ្នូររបស់កម្មករនិយោជិតរបស់ខ្លួន។ មាត្រា១៧២ នៃច្បាប់ស្តីពីការងារ បានកំណត់ថា និយោជកដែលមានប្រើកម្មករជាក្មេង ឬកូនជាងអាយុតិចជាង១៨ឆ្នាំ ឬស្ត្រីឱ្យធ្វើការក្នុងនោះត្រូវមើលឱ្យមានកិរិយាមារយាទល្អ ហើយនឹងរក្សាការសមរម្យចំពោះសាធារណៈជនផង។ ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹងចំពោះការរំលោភខាងផ្លូវភេទគ្រប់ទ្រង់ទ្រាយទាំងអស់។

មាត្រា១២ នៃច្បាប់ស្តីពីការងារក៏បានតម្រូវឱ្យនិយោជកគោរពនូវកាតព្វកិច្ចមិនលម្អៀង ដោយបានចែងថា គ្មាននិយោជកណាម្នាក់អាចយកបញ្ហាៈ

- ពូជសាសន៍
- ពណ៌សម្បុរ
- ភេទ

- ជំនឿ
- សាសនា
- គំនិតនយោបាយ
- ជាតិកំណើត
- ដើមកំណើតសង្គម
- ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព។

ដើម្បីជាលេសធ្វើសេចក្ដីសម្រេចអំពី :

- ការជួល
- ការកំណត់និងការបែងចែកការងារ
- ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ការដំឡើងថ្នាក់
- ការដំឡើងឋានន្តរសក្តិ
- ការផ្ដល់កម្រៃ
- ការផ្ដល់អត្ថប្រយោជន៍សង្គម
- វិន័យ ឬការផ្ដាច់កិច្ចសន្យាការងារ។

### ៣.១.២. សិទ្ធិ និងកាតព្វកិច្ចរបស់កម្មករនិយោជិត

យោងតាមមាត្រា៣ នៃច្បាប់ស្ដីពីការងារ កម្មករនិយោជិត គឺជនគ្រប់ភេទ និងគ្រប់សញ្ជាតិដែលបាន " ចុះកិច្ចសន្យាធ្វើការយកកម្រៃ ក្រោមការដឹកនាំ និងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀតជារូបវន្តបុគ្គល ឬនីតិបុគ្គលជាសាធារណៈ ឬឯកជន។" អនុលោមតាមខ្លឹមសារនៃបញ្ញត្តនេះ យើងអាចនិយាយបានថា កម្មករនិយោជិតមានកាតព្វកិច្ចក្នុងការបំពេញការងារ ឬសេវា ដោយត្រូវគោរពតាមការចាត់តាំង ដឹកនាំ និងគ្រប់គ្រងរបស់និយោជក ហើយកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួល ជាថ្នូរនឹងការធ្វើការរបស់ខ្លួន។ ទោះបីជាយ៉ាងនេះក៏ដោយ យើងសង្កេតឃើញថា ច្បាប់ស្ដីពីការងារបានចែងបន្ថែមអំពីសិទ្ធិ និងកាតព្វកិច្ចរបស់កម្មករនិយោជិត ដែលមានជាអាទិ៍ដូចខាងក្រោម៖

**សិទ្ធរបស់កម្មករនិយោជិត៖** នៅពេលនិយាយអំពីសិទ្ធិរបស់កម្មករនិយោជិត យើងនឹងនឹកឃើញដល់លក្ខខណ្ឌការងារ ដែលមានរាប់បញ្ចូលអំពីប្រាក់ឈ្នួល, ថិរវេលាធ្វើការ និងការឈប់សម្រាក។ យោងតាមច្បាប់ស្ដីពីការងារ កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួល ជាថ្នូរនឹងការបំពេញការងារ ឬសេវា។ ពួកគាត់មានសិទ្ធិទទួលបានការបំពេញការងារ ឬសេវា ដោយមានកំណត់ជាមុននូវថិរវេលាធ្វើការជាក់លាក់ និងមានថិរវេលាសម្រាកផងដែរ។ ម៉ោងធ្វើការធម្មតារបស់កម្មករនិយោជិត ត្រូវកំណត់ចំនួន ៨ម៉ោងក្នុងមួយថ្ងៃ និងត្រូវមានម៉ោងសម្រាកប្រចាំសប្ដាហ៍យ៉ាងហោចណាស់ ២៤ ម៉ោងបន្តបន្ទាប់គ្នា។ ការស្វែងយល់លំអិតអំពីលក្ខខណ្ឌការងារ នឹងត្រូវធ្វើឡើងក្នុងក្របខណ្ឌមេរៀនលក្ខខណ្ឌទូទៅនៃការងារ។

ក្រៅពីសិទ្ធិទទួលបានលក្ខខណ្ឌការងារល្អស្របតាមច្បាប់កំណត់ កម្មករនិយោជិតក៏មានសិទ្ធិទទួលបានលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារល្អនៅកន្លែងធ្វើការផងដែរ។ យោងមាត្រា២២៩ នៃច្បាប់ស្ដីពីការងារ គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការ ត្រូវរក្សាឱ្យបានស្អាត ហើយបង្ហាញថាមានលក្ខខណ្ឌអនាម័យ និងសុខភាពសុខសប្បាយជានិច្ច ឬជាទូទៅត្រូវឱ្យមានលក្ខខណ្ឌការងារជាចាំបាច់សម្រាប់សុខភាពរបស់កម្មករនិយោជិត។ ការតាមដានត្រួតពិនិត្យលក្ខខណ្ឌនេះ យើងអាចកំណត់លើចំណុចជាអាទិ៍ ដូចខាងក្រោម៖

- គុណភាពនៃទីកន្លែងធ្វើការ
- ការបោសសម្អាត
- ឋបនភ័ណ្ឌសុខាភិបាលដែលត្រូវមានសម្រាប់សេចក្តីត្រូវការរបស់បុគ្គលិក
- ភេសជ្ជៈនិងអាហារ
- ការស្នាក់នៅជាយថាហេតុរបស់បុគ្គលិក
- ប៉ុស្តិ៍ការងារ និងការរៀបចំអាសនៈធ្វើការ
- វិធានការសម្រាប់ធ្វើឱ្យខ្យល់ចេញចូលបានស្រួល និងការសម្អាតបរិយាកាសកន្លែងធ្វើការ
- ឧបករណ៍ការពារផ្ទាល់ខ្លួន និងសំលៀកបំពាក់ការងារ
- ពន្លឺ និងសម្លេងក្នុងកន្លែងធ្វើការ។

ការស្វែងយល់លម្អិតនៃលក្ខខណ្ឌស្តីពីសុវត្ថិភាព និងសុខភាពការងារ នឹងត្រូវធ្វើឡើងក្នុងក្របខណ្ឌមេរៀន ស្តីពីសុវត្ថិភាព និងសុខភាពការងារ។

សិទ្ធសេរីភាពអង្គការវិជ្ជាជីវៈ ក៏ត្រូវតែធានាសម្រាប់កម្មករនិយោជិតផងដែរ។ កម្មករនិយោជិតមានសិទ្ធិក្នុងការចូលរួម ឬមិនចូលរួមបង្កើតអង្គការវិជ្ជាជីវៈ និងការចូលរួមចរចាអនុសញ្ញារួម ព្រមទាំងការធ្វើកូដកម្មស្របច្បាប់។ មាត្រា៥ នៃច្បាប់ស្តីពីសហជីព បានកំណត់ថា កម្មករនិយោជិតមានសិទ្ធិបង្កើតសហជីពតាមការជ្រើសរើសរបស់ខ្លួន ក្នុងគោលបំណងសម្រាប់តែការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ការលើកតម្កើងផលប្រយោជន៍ និងការការពារសិទ្ធិ ក៏ដូចជាផលប្រយោជន៍ផ្នែកស្មារតី និងសម្ភារជាសមូហភាព និងជាឯកកត្តជនចំពោះបុគ្គលដែលលក្ខន្តិកៈរបស់សហជីពបានកំណត់។ មាត្រាដដែលបានកំណត់ផងដែរថា កម្មករនិយោជិតមានសិទ្ធិ៖

- ចូលរួមបង្កើតសហជីព
- អាចជាសមាជិករបស់សហជីពហើយស្ថិតនៅក្រោមវិធានរបស់សហជីពនោះ
- អាចចូលរួមនៅក្នុងសកម្មភាពស្របច្បាប់របស់សហជីពដែលគាត់ជាសមាជិក
- អាចស្វះស្វែង និងទទួលបានមុខងារនៅក្នុងសហជីពណាមួយដែលខ្លួនជាសមាជិក ហើយស្ថិតនៅក្រោមវិធានរបស់សហជីពនោះ
- អាចចូលរួមនៅក្នុងការបោះឆ្នោតជ្រើសរើសអ្នកតំណាងនៅកន្លែងការងារនៅពេលដែលមានបទបញ្ញត្តចែងអំពីការជ្រើសរើស ឬតែងតាំងនេះ

ការស្វែងយល់លម្អិតអំពីសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈនេះ នឹងត្រូវធ្វើឡើងក្នុងក្របខណ្ឌមេរៀនស្តីពីសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ។

**កាតព្វកិច្ចរបស់កម្មករនិយោជិត៖** បន្ទាប់ពីព្រមព្រៀងចុះកិច្ចសន្យាការងារជាមួយនិយោជក ទោះជាប្រភេទកិច្ចសន្យាការងារអ្វីក៏ដោយ ទោះជាត្រូវធ្វើឡើងដោយផ្ទាល់មាត់ ឬមិនផ្ទាល់មាត់ក៏ដោយ កម្មករនិយោជិតត្រូវតែគោរពកាតព្វកិច្ចរបស់ខ្លួន ដូចមានកំណត់ជាអាទិ៍ក្នុងកិច្ចសន្យាការងារ បទបញ្ជាផ្ទៃក្នុង និងច្បាប់ជាធរមាន។ កម្មករនិយោជិតត្រូវគោរពម៉ោងពេលបំពេញការងារ ភារកិច្ចដែលនិយោជកដាក់ឱ្យ និងស្ថិតនូវក្រោមការគ្រប់គ្រង និងការបង្គាប់បញ្ជារបស់និយោជក ដោយមិនត្រូវយកម៉ោងការងារទៅបំពេញកិច្ចការផ្ទាល់ខ្លួន ឬ/និងធ្វើសកម្មភាពមិនសមស្របណាមួយនោះឡើយ។ មាត្រា៦៩ នៃច្បាប់ស្តីពីការងារបានកំណត់ថា នៅក្នុងក្របខ័ណ្ឌ នៃកិច្ចសន្យា កម្មករនិយោជិតត្រូវបញ្ចេញគ្រប់សកម្មភាពវិជ្ជាជីវៈរបស់ខ្លួនដល់ សហគ្រាសជាអាទិ៍ កម្មករនិយោជិតត្រូវធ្វើការដែលគេជួលឱ្យធ្វើ ហើយអនុវត្តការងារនោះដោយខ្លួនឯង និងដោយយកចិត្តទុកដាក់។

កម្មករនិយោជិតត្រូវបំពេញការងារ ឬសេវាជូនដល់និយោជក ដោយត្រូវគោរពកាតព្វកិច្ចមិនប្រកួតប្រជែង ពោលគឺកម្មករនិយោជិតមិនត្រូវធ្វើសកម្មភាពណាមួយបម្រើដល់សហគ្រាស គ្រឹះស្ថានដែលមានសកម្មភាពអាជីវកម្មប្រកួតប្រជែងជាមួយនឹងសហគ្រាស គ្រឹះស្ថានដែលខ្លួនកំពុងបំពេញការងារ ឬសេវាជូនឡើយ។ ពាក់ព័ន្ធនឹងការមិនប្រកួតប្រជែងនេះ មាត្រា៧០ នៃច្បាប់ស្តីពីការងារ បានកំណត់ថា ត្រូវចាត់ទុកជាមោឃៈដោយពេញច្បាប់ នូវខណាមួយនៃកិច្ចសន្យាដែលហាមឃាត់កម្មករនិយោជិតមិនឱ្យធ្វើសកម្មភាពអ្វីមួយ បន្ទាប់ពីកិច្ចសន្យាបានផុតរលត់។ អនុលោមតាមបទប្បញ្ញត្តនេះ កម្មករនិយោជិតមានកាតព្វកិច្ចគោរពនូវកាតព្វកិច្ចមិនប្រកួតប្រជែងនេះ ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យាការងាររវាងកម្មករនិយោជិតសាមី និងនិយោជកតែប៉ុណ្ណោះ។ មានន័យថា ក្នុងករណីកិច្ចសន្យាការងារត្រូវបានផុតរលុត នោះនិយោជកមិនអាចហាមឃាត់កម្មករនិយោជិតមិនឱ្យបំពេញសកម្មភាពប្រកួតប្រជែងណាមួយបានទៀតឡើយ។

## ៤. ការព្យួរកិច្ចសន្យាការងារ

ការព្យួរកិច្ចសន្យាការងារ មានន័យថាកិច្ចសន្យាការងារនៅតែមានសុពលភាពដដែល ប៉ុន្តែភារកិច្ចនិងកាតព្វកិច្ចមួយចំនួនរបស់កម្មករនិយោជិត និងនិយោជកត្រូវបានព្យួរទុកជាបណ្តោះអាសន្ន (ព្យួរកាតព្វកិច្ច)។

### ៤.១. មូលហេតុនៃការព្យួរ

មាត្រា៧១ នៃច្បាប់ស្តីពីការងារបានកំណត់អំពីមូលហេតុ ១១ចំណុច ក្នុងការព្យួរការអនុវត្តកិច្ចសន្យាការងារ រួមមាន៖

១.ការបិទគ្រឹះស្ថាន ដោយហេតុនិយោជកត្រូវបំពេញកាតព្វកិច្ចការពារមាតុភូមិ ឬក្នុងរយៈពេលជាកាតព្វកិច្ចត្រូវរៀនវិជ្ជាយោធា។

២.អវត្តមាននៃកម្មករនិយោជិត ក្នុងពេលត្រូវបំពេញកាតព្វកិច្ចការពារមាតុភូមិ និងក្នុងរយៈពេលជាកាតព្វកិច្ចត្រូវរៀនវិជ្ជាយោធា។

៣.អវត្តមាននៃកម្មករនិយោជិត ក្នុងករណីមានជំងឺដែលមានគ្រូពេទ្យផ្លូវការបានបញ្ជាក់ត្រឹមត្រូវ។ ថិរវេលាអវត្តមាននោះត្រូវមានកំណត់ត្រឹម៦ខែ ប៉ុន្តែអាចពន្យាររហូតដល់មានអ្នកជំនួស។

៤.ពេលអាក់ខានធ្វើការដោយហេតុមានគ្រោះថ្នាក់ការងារ ឬមានជំងឺក្នុងវិជ្ជាជីវៈ។

៥.ការឈប់សម្រាកដែលបានអនុញ្ញាតឱ្យស្ត្រីជាកម្មករនិយោជិត ក្នុងឱកាសមានគភ៌ និងសម្រាលកូន ព្រមទាំងមានជំងឺបណ្តាលមកពីសម្រាលកូន។

៦.អវត្តមាននៃកម្មករនិយោជិត ដែលនិយោជកបានអនុញ្ញាតតាមច្បាប់ តាមការព្រមព្រៀងរួម ឬការយល់ព្រមរៀងខ្លួន។

៧.ការបញ្ឈប់កម្មករនិយោជិតក្នុងមួយរយៈដោយមានមូលហេតុសមស្របតាមបទបញ្ជាផ្ទៃក្នុង។

៨.អវត្តមាននៃកម្មករនិយោជិត ក្នុងឱកាសឈប់សម្រាកដោយមានប្រាក់ឈ្នួល ដោយគិតបន្ថែមទាំងថិរវេលាធ្វើដំណើរជាយថាហេតុផង។

៩.ការឃាត់ខ្លួននៃកម្មករនិយោជិតដែលមិនបណ្តាលឱ្យជាប់ពិរុទ្ធ។

១០.ប្រធានសក្តិដែលបណ្តាលឱ្យភាគីណាមួយ បំពេញកាតព្វកិច្ចមិនបានក្នុងរយៈពេលមិនលើសពី៣ខែ។

១១.ពេលណាដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសម្ភារធ្ងន់ធ្ងរ ឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពសហគ្រាសមិនលើសពី២ខែ។ ការព្យួរសកម្មភាពនេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ។

មួយវិញទៀត កូដកម្មក៏នាំឱ្យព្យួរកិច្ចសន្យាការងារដែរ។ យោងតាមមាត្រា៣៣២ នៃច្បាប់ស្តីពីការងារចែងថា៖

"កិច្ចសន្យាការងារត្រូវព្យួរនៅពេលធ្វើកូដកម្ម។ ក្នុងអំឡុងពេលនៃកូដកម្ម តាវកាលិកការងារ មិនត្រូវបានផ្តល់ឱ្យទេ ហើយប្រាក់បៀវត្សក៏មិនត្រូវបានបើកឱ្យដែរ។

កម្មករនិយោជិតត្រូវបានទទួលការងាររបស់ខ្លួនវិញ នៅពេលចប់កូដកម្ម។

អាណត្តិរបស់តំណាងកម្មករនិយោជិតមិនត្រូវបានព្យួរទេក្នុងពេលធ្វើកូដកម្ម ដើម្បីអ្នកតំណាងទាំងនោះ អាចរក្សាទំនាក់ទំនងជាមួយតំណាងនិយោជក។"

**៤.២. អានុភាពនៃការព្យួរ**

យោងតាមមាត្រា៧២ នៃច្បាប់ស្តីពីការងារ ក្នុងកំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ៖

- កម្មករនិយោជិតមិនមានកាតព្វកិច្ចធ្វើការជូននិយោជកនោះទេ
- និយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតទេ លើកលែងតែមានបទប្បញ្ញត្តផ្ទុយពីនេះ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល។
- មិនប៉ះពាល់ដល់អាណត្តិនៃសហជីព ឬអាណត្តិនៃតំណាងកម្មករនិយោជិត
- ចិរវេលានៃការព្យួរនេះ ត្រូវយកមកសម្រាប់គណនាអតីតភាពការងារ លើកលែងតែមានបទប្បញ្ញត្តផ្ទុយ។

និយោជកអាចបញ្ចប់ការព្យួរកិច្ចសន្យាការងារបាន លុះត្រាណាតែបុព្វហេតុទាំងឡាយនៃការព្យួរកិច្ចសន្យានេះបានផុតរលត់ហើយ និងត្រូវជូនដំណឹងដល់កម្មករនិយោជិតអំពីកាលបរិច្ឆេទនៃថ្ងៃចូលធ្វើការវិញ។

❖ *ក្នុងអំឡុងនៃការព្យួរកិច្ចសន្យាការងារនោះ ការផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេង អាចអនុវត្តបាន ប្រសិនបើមានកំណត់ក្នុងអនុញ្ញារួម បទបញ្ជាផ្ទៃក្នុង ឬបានព្រមព្រៀងគ្នារវាងកម្មករនិយោជិត និងនិយោជកក្នុងអំឡុងពេលព្យួរនោះ។*

## ៥. ការកែប្រែលក្ខខណ្ឌគតិយុត្តរបស់និយោជក

មាត្រា៨៧ ថ្មី នៃច្បាប់ស្តីពីការងារ បានកំណត់ថា ការកែប្រែលក្ខខណ្ឌគតិយុត្តរបស់និយោជកមានជាអាទិ៍ដូចជា ដោយឧត្តរាធិការ "ការបន្តមរតក" ការលក់ ការបញ្ចូលមូលនិធិ ឬការផ្លាស់ប្តូរមូលនិធិ ការដាក់ជាក្រុមហ៊ុន។ សំនួរអាចនឹងត្រូវចោទសួរឡើងថា ករណីមានការកែប្រែនេះ តើនឹងមានផលវិបាកគតិយុត្តអ្វីខ្លះ ដែលប៉ះពាល់ដល់ទំនាក់ទំនងការងាររវាងកម្មករនិយោជិត និងនិយោជក។ ដើម្បីឆ្លើយតបនឹងសំនួរនេះ មាត្រា៨៧ថ្មី ក៏បានបញ្ជាក់ផងដែរថា ក្នុងករណីមានការកែប្រែលក្ខខណ្ឌគតិយុត្តរបស់និយោជក កិច្ចសន្យាការងារទាំងឡាយដែលកំពុងប្រតិបត្តិមកដល់ថ្ងៃមានការកែប្រែនោះ ត្រូវស្ថិតនៅដដែលរវាងនិយោជកថ្មី និងកម្មករនិយោជិតក្នុងសហគ្រាសចាស់។ ករណីកែប្រែនេះ ច្បាប់ស្តីពីការងារពុំបានចែងលំអិតនោះទេ ដោយគ្រាន់តែមានកំណត់តែក្នុងមាត្រា ៨៧ថ្មីនេះ ប៉ុណ្ណោះ។

## ការរំលាយកិច្ចសន្យាការងារ

យោងតាមច្បាប់ស្តីពីការងារ កិច្ចសន្យាការងារមាន២ប្រភេទគឺ កិច្ចសន្យាការងារមានកំណត់ចិរវេលា និងកិច្ចសន្យាការងារមានចិរវេលាមិនកំណត់។ ជាគោលការណ៍ ដើម្បីទូទាត់ប្រាក់បំណាច់រំលាយកិច្ចសន្យាការងារឱ្យបានត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ យើងត្រូវពិនិត្យលើប្រភេទកិច្ចសន្យាការងារជាមុនសិន ថាតើជាប្រភេទកិច្ចសន្យាការងារមានកំណត់ចិរវេលា ឬកិច្ចសន្យាការងារមានចិរវេលាមិនកំណត់ និងប្រភេទករណីនៃការរំលាយកិច្ចសន្យាការងារ ព្រមទាំងត្រូវស្វែងរកហេតុផលនៃការរំលាយកិច្ចសន្យាការងារផងដែរ។

**៥.១. កិច្ចសន្យាមានថិរវេលាកំណត់**

កិច្ចសន្យាការងារប្រភេទនេះអាចត្រូវបានរំលាយដោយកិច្ចសន្យាការងារដល់កាលកំណត់ ឬដោយមុនកាលកំណត់ ហើយប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារដែលកម្មករនិយោជិតត្រូវទទួលបានអាស្រ័យតាមករណីដូចខាងក្រោម៖

**៥.១.១. កិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) ដល់កាលកំណត់**

**៥.១.១.១. ការមិនបន្តកិច្ចសន្យាការងារ ដោយនិយោជកក្នុងករណីបានជូនដំណឹងត្រឹមត្រូវតាមច្បាប់ កម្មករនិយោជិតទទួលបាន៖**

១). ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២). ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦ និងម.១៦៧)។

៣). ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥%នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា (ម.៧៣)។

**៥.១.១.២. ការមិនបន្តកិច្ចសន្យាការងារដោយនិយោជក ក្នុងករណីមិនបានជូនដំណឹងមុនត្រឹមត្រូវតាមច្បាប់ ឬមិនបានជូនដំណឹង**

១). ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦) ។

២). ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦និងម.១៦៧) ។

៣). ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥%នៃប្រាក់ឈ្នួល ដែលកម្មករនិយោជិត បានបើកក្នុងរយៈពេលនៃកិច្ចសន្យា (ម.៧៣)។

*4). បើគ្មានការជូនដំណឹងមុន ឬ**ជូនដំណឹងមិនត្រឹមត្រូវតាមច្បាប់**ទេ កិច្ចសន្យាត្រូវបន្តក្នុងថិរវេលាដែលបានចុះកិច្ចសន្យាគ្រាដំបូង ដូច្នេះបើកសិទ្ធិឱ្យទាមទារជំងឺចិត្តដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលក្នុងរយៈពេលនៃការបន្តកិច្ចសន្យាចុងក្រោយ (ម. ៧៣)*

**៥.១.១.៣.ការមិនបន្តកិច្ចសន្យាការងារដោយកម្មករនិយោជិត ក្នុងករណីនិយោជកបានជូនដំណឹងបន្តត្រឹមត្រូវតាមច្បាប់ កម្មករនិយោជិតទទួលបាន៖**

១) ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦ និងម.១៦៧) ។

៣) ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥%នៃប្រាក់ឈ្នួល ដែលកម្មករនយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា (ម.៧៣)។

**៥.១.២. ការរំលាយកិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) មុនកាលកំណត់**

**៥.១.២.១. ការរំលាយកិច្ចសន្យាការងារដោយឆន្ទៈកម្មករនិយោជិត កម្មករនិយោជិតទទួលបាន៖**

១)ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦) ។

២)ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់(ម.១៦៦ និងម.១៦៧)។

** ក្នុងករណីដែលនិយោជកមិនយល់ព្រមឱ្យឈប់ធ្វើការ និយោជកអាចទាមទារជំងឺចិត្តស្មើនឹងការ ខូចខាតរបស់ខ្លួនដែលបានផ្តល់ឱ្យកម្មករនិយោជិត (ម.៧៣)* ។

**៥.១.២.២. ការរំលាយកិច្ចសន្យាការងារដោយឆន្ទៈនិយោជក កម្មករនិយោជិតទទួលបាន៖**

១)ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២)ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦និងម.១៦៧)។

៣)ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥%នៃប្រាក់ឈ្នួល ដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា (ម.៧៣)។

៤)ជំងឺចិត្តដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួល ដែលកម្មករនិយោជិតត្រូវទទួលរហូតដល់ ពេលចប់កិច្ចសន្យាការងារ (ម.៧៣)។

**៥.១.២.៣. ការរំលាយកិច្ចសន្យាការងារដោយកំហុសធ្ងន់របស់កម្មករនិយោជិត (ម.៨៣) កម្មករនិយោជិតទទួលបាន៖**

១) ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦) ។

២) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦ និងម.១៦៧)។

**៥.១.២.៤. ការរំលាយកិច្ចសន្យាការងារក្នុងករណីប្រធានសក្តិ ដោយនិយោជកគ្មានលទ្ធភាពបំពេញ ខសន្យា (ម.៨៥) កម្មករនិយោជិតទទួលបាន៖**

១)ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦) ។

២)ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់(ម.១៦៦ និងម.១៦៧)។

**៥.១.២.៥. ការរំលាយកិច្ចសន្យាការងារក្នុងករណីប្រធានសក្តិ ដោយកម្មករនិយោជិតគ្មានលទ្ធភាពបំពេញខសន្យា (ម.៨៦) កម្មករនិយោជិតទទួលបាន៖**

១) ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦ និងម.១៦៧)។

**៥.១.២.៦. ករណីរោងចក្រ សហគ្រាស ដួលរលំ ឬថៅកែរត់ចោល ហើយត្រូវដោះស្រាយតាមប្រាក់បុរេប្រទានរបស់រាជរដ្ឋាភិបាល កម្មករនិយោជិតទទួលបាន៖**

១) ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ (ម.១៦៦ និងម.១៦៧)។

៣) ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥% នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា (ម.៧៣)។

**៥.១.២.៧. ការរំលាយកិច្ចសន្យាការងារក្នុងករណីអាជ្ញាធរសាធារណៈតម្រូវឱ្យបិទទ្វារ ឬដកអាជ្ញាបណ្ណ កម្មករនិយោជិតទទួលបាន៖**

១) ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦) ។

២) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ (ម.១៦៦ និងម.១៦៧)។

៣) ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥% នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា (ម.៧៣)។

**ប្រសិនបើការបិទ ឬដកអាជ្ញាបណ្ណនេះ កើតចេញពីកំហុសរបស់និយោជក កម្មករនិយោជិតអាចទាមទារសោហ៊ុយជំងឺចិត្ត ដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវទទួលរហូតដល់ពេលចប់កិច្ចសន្យាការងារ (ម.៧៣)។*

**៥.២. កិច្ចសន្យាមានថិរវេលាមិនកំណត់**

កិច្ចសន្យាការងារប្រភេទនេះ អាចត្រូវបានរំលាយដោយភាគីណាមួយបានគ្រប់ពេលវេលាដោយត្រូវគោរពតាមនីតិវិធីច្បាប់ និងមានហេតុផលសមរម្យ។ ក្នុងករណីភាគីណាមួយរំលាយកិច្ចសន្យាការងារដោយមិន

ស្របតាមច្បាប់ ភាគីនោះត្រូវទទួលខុសត្រូវក្នុងការផ្តល់ប្រាក់បំណាច់ ឬសំណងបញ្ចប់កិច្ចសន្យាការងារ ដូចមានកំណត់តាមករណីដូចខាងក្រោម៖

**៥.២.១. កម្មករនិយោជិតលាលែងពីការងារដោយខ្លួនឯង កម្មករនិយោជិតទទួលបាន៖**

១) ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦ និងម.១៦៧)។

**៥.២.២. ការរំលាយកិច្ចសន្យាការងារដោយនិយោជកគ្មានមូលហេតុសមស្រប កម្មករនិយោជិតទទួលបាន៖**

១)ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦) ។

២)ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់(ម.១៦៦និងម.១៦៧)។

៣)ប្រាក់បំណាច់ជួសការឱ្យដំណឹងមុនក្នុងករណីដែលនិយោជកមិនបានជូនដំណឹងមុនត្រឹមត្រូវតាមច្បាប់ស្តីពីការងារ (ម.៧៥និងម.៧៧)។

៤)ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសណាមួយ ដែលកម្មករនិយោជិតត្រូវបានបញ្ឈប់ និងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារសរុបដែលនិយោជកមិនទាន់បានបើក(ម.៨៩ថ្មី)។

៥)សោហ៊ុយជំងឺចិត្ត៖ កម្មករនិយោជិតអាចទាមទារប្រាក់បំណាច់ផ្តាច់មួយដែលមានចំនួនស្មើនឹងប្រាក់បំណាច់អតីតភាពការងារដែលបាន និងត្រូវទទួលក្នុងអំឡុងពេលនៃកិច្ចសន្យាការងារ (ម.៩១ថ្មី និងសេចក្តីណែនាំលេខ០៥៧ និងលេខ០៥៨)។

**៥.២.៣.ការរំលាយកិច្ចសន្យាការងារដោយនិយោជកមានមូលហេតុសមស្រប កម្មករនិយោជិតទទួលបាន៖**

១)ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២)ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់(ម.១៦៦និងម.១៦៧)។

៣)ប្រាក់បំណាច់ជួសការឱ្យដំណឹងមុនក្នុងករណីដែលនិយោជកមិនបានជូនដំណឹងមុនត្រឹមត្រូវតាមច្បាប់ស្តីពីការងារ (ម.៧៥និងម.៧៧)។

៤)ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសណាមួយ ដែលកម្មករនិយោជិតត្រូវបានបញ្ឈប់ និងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារសរុបដែលនិយោជកមិនទាន់បានបើក(ម.៨៩ថ្មី)។

**៥. ២.៤. ការរំលាយកិច្ចសន្យាការងារដោយកំហុសធ្ងន់របស់កម្មករនិយោជិត កម្មករនិយោជិតទទួលបាន៖**

១) ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦និងម.១៦៧)។

**៥.២.៥. ការរំលាយកិច្ចសន្យាការងារក្នុងករណីប្រធានសក្តិ និងដោយនិយោជកគ្មានលទ្ធភាពបំពេញខសន្យា កម្មករនិយោជិតទទួលបាន៖**

១)ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦) ។

២)ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦ និងម.១៦៧)។

**៥.២.៦. ការរំលាយកិច្ចសន្យាការងារក្នុងករណីប្រធានសក្តិ និងដោយកម្មករនិយោជិតគ្មានលទ្ធភាពបំពេញខសន្យា៖**

១)ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦ និងម.១៦៧)។

**៥.២.៧. ករណីរោងចក្រ សហគ្រាស ដួលរលំ ឬថៅកែរត់ចោល ហើយត្រូវដោះស្រាយតាមប្រាក់បុរេប្រទានរបស់រាជរដ្ឋាភិបាល កម្មករនិយោជិតទទួលបាន៖**

១) ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (ម.១៦៦ និងម.១៦៧)។

៣) ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសណាមួយ ដែលកម្មករនិយោជិតត្រូវបានបញ្ឈប់ និងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារសរុបដែលនិយោជកមិនទាន់បានបើក(ម.៨៩ថ្មី)។

**៥.២.៨. ការរំលាយកិច្ចសន្យាការងារក្នុងករណីអាជ្ញាធរសាធារណៈតម្រូវឱ្យបិទទ្វារ ឬដកអាជ្ញាបណ្ណ កម្មករ និយោជិតទទួលបាន៖**

១) ប្រាក់ឈ្នួលដែលមិនទាន់បានបើក (ម.១១៦)។

២) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់(ម.១៦៦ និងម.១៦៧)។

៣) ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសណាមួយដែលកម្មករនិយោជិតត្រូវបានបញ្ឈប់ និងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារ មុនឆ្នាំ២០១៩សរុប ដែលនិយោជកមិនទាន់បានបើក (ម.៨៩ថ្មី)។

**ប្រសិនបើការបិទ ឬដកអាជ្ញាបណ្ណនេះ កើតចេញពីកំហុសរបស់និយោជក កម្មករនិយោជិតអាចទាមទារប្រាក់បំណាច់ផ្តាច់មួយដែលមានចំនួនស្មើនឹងប្រាក់បំណាច់អតីតភាពការងារដែលបាន និងត្រូវទទួលក្នុងកំឡុងពេលនៃកិច្ចសន្យាការងារ(ម.៩១ថ្មី និងសេចក្តីណែនាំលេខ០៥៧ និងលេខ០៥៨)។*

## ៥.៣. ការគណនាប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ

### ៥.៣.១. កិច្ចសន្យាការងារមានកំណត់ថិរវេលា

#### ៥.៣.១.១. ប្រាក់ឈ្នួលខែចុងក្រោយ ដែលមិនទាន់បានបើក (មាត្រា ១១៦)

ប្រាក់ឈ្នួលខែចុងក្រោយ សំដៅលើប្រាក់ឈ្នួលសុទ្ធសាធ ដែលមានកំណត់ក្នុងកិច្ចសន្យាការងារ និងប្រាក់បន្ទាប់បន្សំដែលកម្មករ និយោជិតបានធ្វើការនៅក្នុងខែដែលបញ្ចប់កិច្ចសន្យាការងារ។ចំនួនប្រាក់ឈ្នួលនេះ អាចមានការប្រែប្រួល ក្នុងករណីមានការឈប់សម្រាកដោយគ្មានប្រាក់ឈ្នួល ឬការព្យួរកិច្ចសន្យាការងារ...។

ប្រាក់ឈ្នួលនេះទទួលបានតាមពេលវេលាកំណត់ (ប្រចាំម៉ោង ប្រចាំថ្ងៃ ឬប្រចាំខែ) ឬតាមបរិមាណផលិតផល (ដេរស៊ីបុង)។

- **ការគិតប្រាក់ឈ្នួលតាមពេលវេលា**

$$\text{ប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ} = \frac{\text{ប្រាក់ឈ្នួលសុទ្ធសាធ និងប្រាក់បន្ទាប់បន្សំ ក្នុង១ខែ}}{\text{២២ថ្ងៃ ឬ២៤ថ្ងៃ ឬ២៦ថ្ងៃ}}$$

*(អាស្រ័យលើចំនួនថ្ងៃធ្វើការនៃរោងចក្រសហ*

$$\text{ប្រាក់ឈ្នួលជាមធ្យមក្នុង ១ម៉ោង} = \frac{\text{ប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង១ថ្ងៃ}}{\text{៨ម៉ោង}}$$

*(អាស្រ័យលើចំនួនម៉ោងធ្វើការនៃរោងចក្រសហគ្រាសនីមួយៗ)*

- **ការគិតប្រាក់ឈ្នួលតាមបរិមាណផលិតផល (ដេរស៊ីប៉ុង)**

ការគិតប្រាក់ឈ្នួលតាមបរិមាណផលិតផល (ដេរស៊ីប៉ុង) គឺអាស្រ័យទៅលើតម្លៃប៉ុងក្នុង១ម៉ោង។ ករណីប្រាក់ឈ្នួលធម្មតាក្នុង១ម៉ោងច្រើនជាងតម្លៃប៉ុងក្នុង១ម៉ោង គឺយកប្រាក់ឈ្នួលធម្មតាក្នុង១ម៉ោងមកគណនា។ ផ្ទុយទៅវិញករណីប្រាក់ឈ្នួលធម្មតាក្នុង១ម៉ោងតិចជាងតម្លៃប៉ុងក្នុង១ម៉ោង គឺយកតម្លៃប៉ុងក្នុង១ម៉ោងមកគណនា។

- **ការគណនាប្រាក់ឈ្នួលតាមបរិមាណផលិតផល (ដេរស៊ីប៉ុង) មានដូចខាងក្រោម៖**

១- រកចំនួនម៉ោងធ្វើការសរុបនៅក្នុងខែ (ទាំងម៉ោងធ្វើការធម្មតា ទាំងម៉ោងធ្វើការបន្ថែមម៉ោង)

២- រកប្រាក់ថ្លៃប៉ុងសរុប = ថ្លៃប៉ុង ១ឯកតា x ចំនួនប៉ុងសរុប

៣- រកប្រាក់ឈ្នួលធម្មតាក្នុង១ម៉ោង = ប្រាក់ថ្លៃប៉ុងសរុប ÷ ចំនួនម៉ោងធ្វើការសរុប = (២) ÷ (១)

កំណត់ចំណាំ៖ បើប្រាក់ឈ្នួលធម្មតាក្នុងមួយម៉ោងទាបជាងប្រាក់ឈ្នួលគោលក្នុងមួយម៉ោងនោះត្រូវយកប្រាក់ឈ្នួលគោលជាមធ្យមក្នុង១ម៉ោងមកគណនាវិញ។ ឧទាហរណ៍ថាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២៣ ស្មើនឹង២០០ ដុល្លារ ៖

$$\text{ប្រាក់ឈ្នួលគោលជាមធ្យមក្នុង១ម៉ោង} = \frac{\text{២០០ \$}}{\text{២៦ថ x ៨ម}} = \text{០.៩៦ \$}$$

៤- រកប្រាក់ឈ្នួលម៉ោងធម្មតាសរុប (មិនគិតថ្ងៃបុណ្យ និងថ្ងៃសម្រាកប្រចាំសប្តាហ៍)
= ប្រាក់ឈ្នួលជាមធ្យមក្នុង១ម៉ោង x ចំនួនម៉ោងធ្វើការធម្មតា

៥- រកប្រាក់ឈ្នួលធ្វើការថែមម៉ោងពេលថ្ងៃនៃថ្ងៃធ្វើការធម្មតា
= ប្រាក់ឈ្នួលជាមធ្យមក្នុង១ម៉ោង X ចំនួនម៉ោងធ្វើការបន្ថែមពេលថ្ងៃ នៃថ្ងៃធ្វើការធម្មតា X ១.៥

៦- រកប្រាក់ឈ្នួលម៉ោងធ្វើការថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ និងឈប់សម្រាកថ្ងៃបុណ្យ
= ប្រាក់ឈ្នួលជាមធ្យមក្នុង១ម៉ោង x ចំនួនម៉ោងធ្វើការថ្ងៃឈប់សម្រាកបុណ្យ និងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ x ២

៧- រកប្រាក់ឈ្នួលសរុបត្រូវទទួលបានក្នុងខែ = (៤) + (៥) + (៦) + ប្រាក់បន្ទាប់បន្សំផ្សេងៗទៀត (ដូចជារង្វាន់ទៀងទាត់ រង្វាន់អតីតភាពប្រាក់សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភថ្លៃបាយពេលធ្វើការបន្ថែមម៉ោង...។ល។)

**ឧទាហរណ៍៖** កម្មករនិយោជិតម្នាក់ធ្វើការបានចំនួន ២៦០ម៉ោងនៅក្នុងខែ (គាត់បានធ្វើការម៉ោងធម្មតា ២០៨ម៉ោង ម៉ោងថ្ងៃបុណ្យ៨ម៉ោង ថ្ងៃអាទិត្យ៤ម៉ោង និងធ្វើការបន្ថែមម៉ោងពេលថ្ងៃ នៃថ្ងៃធ្វើការធម្មតា ៤០ម៉ោង) ប្រាក់ខែគោលសុទ្ធសាធក្នុងមួយខែ គឺ ២០០ $ និងប្រាក់ប៉ុងសរុបក្នុងខែចំនួន ២៥៥ $។

ប្រាក់ឈ្នួលរបស់គាត់ត្រូវបានគណនាដូចតទៅ៖

១- ម៉ោងធ្វើការសរុប ២៦០ម៉ោង

២- ចំនួនថ្លៃប៉ុងសរុប ២៥៥ $

$$\text{៣- ប្រាក់ឈ្នួលជាមធ្យមក្នុង១ម៉ោង} = \frac{\text{២៥៥\$ (តំលៃប៉ុងសរុប)}}{\text{២៦០ (ម៉ោងសរុបក្នុង១ខែ)}} = \text{០.៩៨ \$}$$

កំណត់ចំណាំ៖ដោយប្រាក់ឈ្នួលធម្មតាក្នុង១ម៉ោងនៃការដេរស៊ីបុងនេះច្រើនជាងប្រាក់ឈ្នួលគោលក្នុង១ម៉ោង (០.៩៨ ធំជាង ០.៩៦) ត្រូវយកប្រាក់ឈ្នួលធម្មតានៃការដេរស៊ីបុងនោះមកគិត។

៤- ប្រាក់ឈ្នួលម៉ោងធម្មតាសរុប = ០.៩៨ x ២០០ = ១៩៦ $

៥- ប្រាក់ឈ្នួលធ្វើការលើសម៉ោងពេលថ្ងៃ នៃថ្ងៃធម្មតា

= ០.៩៨$ x ៤០ x ១.៥ = ៥៩ $

៦- ប្រាក់ឈ្នួលម៉ោងធ្វើការថ្ងៃឈប់សម្រាកបុណ្យ និងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍

= ០.៩៨$ x ( ៨ + ៤ ) x ២ = ២៣.៥២ $

៧- ប្រាក់ឈ្នួលសរុបត្រូវទទួលបានក្នុងខែ = ១៩៦ $ + ៥៨ $ +២៣.៥២ $ =**២៧៧.៥២ $**

បញ្ជាក់៖ ប្រាក់ឈ្នួលនេះមិនទាន់ត្រូវបានបូកបញ្ចូលជាមួយនឹងអត្ថប្រយោជន៍ដែលកម្មករនិយោជិតត្រូវបាននៅក្នុងខែនេះទេ។

**៣.១.២.ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និងមាត្រា១៦៧)**

$$\text{ប្រាក់ឈ្នួលជួសការឈប់សម្រាកប្រចាំឆ្នាំក្នុង ១ថ្ងៃ} = \frac{\text{ប្រាក់ឈ្នួលសុទ្ធសាធ ក្នុង១ខែ}}{\text{២២ថ្ងៃ ឬ២៤ថ្ងៃ ឬ២៦ថ្ងៃ}}$$

*(អាស្រ័យលើចំនួនថ្ងៃធ្វើការនៃរោងចក្រសហគ្រាសនីមួយៗ)*

**៣.១.៣. ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥% នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា (មាត្រា ៧៣)**

$$\text{ប្រាក់បំណាច់ ៥\%} = \frac{\text{ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ ដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា x ៥}}{\text{១០០}}$$

**៣.១.៤. ជំងឺចិត្តដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវទទួលរហូតដល់ពេល ចប់កិច្ចសន្យាការងារ (មាត្រា ៧៣)**

ជំងឺចិត្ត = ប្រាក់ឈ្នួលសុទ្ធសាធដែលកំណត់ក្នុងកិច្ចសន្យា x រយៈពេលដែលនៅសល់រហូតដល់ពេលចប់កិច្ចសន្យា

**ឧទាហរណ៍៖** កម្មករនិយោជិតម្នាក់បានធ្វើការនៅក្នុងរោងចក្រមួយនៅរាជធានីភ្នំពេញដោយប្រើប្រាស់កិច្ចសន្យាមានកំណត់ថិរវេលារយៈពេល១ឆ្នាំ (ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣)

ហើយគាត់ទទួលបានប្រាក់ឈ្នួលចំនួន ២០០ដុល្លារ ក្នុងមួយខែ។ គាត់ត្រូវបានបញ្ចប់កិច្ចសន្យាការងារមុនកាលកំណត់ដោយនិយោជកនៅខែកញ្ញា ឆ្នាំ២០២៣។

ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាដែលកម្មករនិយោជិតទទួលបាន មានដូចខាងក្រោម៖

១. ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំខែចុងក្រោយ = ២៧០ $

២. ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ = ២០០ $ / ២៦ ថ្ងៃ = ៧.៦៩ $ x ១២ ថ្ងៃ = ៩២.៣ $

៣.ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ៥%

= ( ២៥០+២៦០+២៧០+២៦៥+២៥០+២៧០+២៧០+២៧០ ) x ៥ / ១០០ = ១០៥.២៥ $

៤. ជំងឺចិត្ត = ២០០ $ x ៤ ខែ = ៨០០ $

ដូច្នេះប្រាក់បំណាច់បញ្ចប់កិច្ចសន្យាដែលកម្មករនិយោជិតទទួលបាន៖

= ២៧០ $ + ៩២.៣ $ + ១០៥.២៥ $ + ៨០០ $ = **១២៦៧.៥៥ $**

**៣.២.កិច្ចសន្យាការងារមានថិរវេលាមិនកំណត់**

**៣.២.១. ប្រាក់ឈ្នួលខែចុងក្រោយ ដែលមិនទាន់បានបើក (មាត្រា ១១៦)**

អនុវត្តដូចចំណុច ៣.១.១ ប្រាក់ឈ្នួលខែចុងក្រោយដែលមិនទាន់បានបើក។

**៣.២.២.ប្រាក់បំណាច់ជួសការឱ្យដំណឹងមុន ក្នុងករណីដែលនិយោជកមិនបានជូនដំណឹងមុនតាមច្បាប់កំណត់ (មាត្រា៧៥ និងមាត្រា៧៧)**

| |
|---|
| ប្រាក់បំណាច់ជួសការឱ្យដំណឹងមុន<br>= ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំគិតជាមធ្យមក្នុង១ថ្ងៃ ឬ១ខែ X រយៈពេលនៃការជូនដំណឹងមុន |

- **ទី១ ការគណនាប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ**

| |
|---|
| ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ<br>$= \frac{\text{ប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំប្រចាំខែនៅក្នុងរយៈពេល១២ខែចុងក្រោយ}}{\text{១២ខែ}}$ |

**បញ្ជាក់៖ ករណីផ្អាកអាជីវកម្ម, ធ្វើការឆ្លាស់វេនគ្នា ឬព្យួរកិច្ចសន្យាការងារ... ត្រូវដកចេញខែណាដែលកម្មករនិយោជិតមិនបានបំពេញការងារពេញលេញ (តិចជាង២១ថ្ងៃ) រួចរាប់បញ្ចូលថយក្រោយយកខែណាដែលកម្មករនិយោជិតបានបំពេញការងារពេញលេញ។*

- **ទី២ ការគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ**

| |
|---|
| ប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ $= \frac{\text{ប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំគិតជាមធ្យមក្នុង ១ខែ}}{\text{២២ថ្ងៃ ឬ២៤ថ្ងៃ ឬ២៦ថ្ងៃ}}$<br>*(អាស្រ័យលើចំនួនថ្ងៃធ្វើការនៃរោងចក្រ សហគ្រាសនីមួយៗ)* |

៣.២.៣. ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា ១៦៦ និងមាត្រា១៦៧)

$$\text{ប្រាក់ឈ្នួលជួសការឈប់សម្រាកប្រចាំឆ្នាំក្នុង ១ថ្ងៃ} = \frac{\text{ប្រាក់ឈ្នួលសុទ្ធសាធ ក្នុង១ខែ}}{\text{២២ថ្ងៃ ឬ២៤ថ្ងៃ ឬ២៦ថ្ងៃ}}$$

*(អាស្រ័យលើចំនួនថ្ងៃធ្វើការនៃរោងចក្រសហគ្រាសនីមួយៗ)*

៣.២.៤.ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារ និងប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំ ដែលមិនទាន់បានទូទាត់ (មាត្រា៨៩ថ្មី)

❖ ទី១ ការគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ

ប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ

$$= \frac{\text{ប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំប្រចាំខែនៅក្នុងរយៈពេល១២ខែចុងក្រោយ}}{\text{១២ខែ}}$$

** បញ្ជាក់៖ ករណីផ្អាកអាជីវកម្ម ធ្វើការឆ្លាស់វេនគ្នា ឬព្យួរកិច្ចសន្យាការងារ... ត្រូវដកចេញខែណាដែលកម្មករនិយោជិតមិនបានបំពេញការងារពេញលេញ (តិចជាង២១ថ្ងៃ) រួចរាប់បញ្ចូលថយក្រោយយកខែណាដែលកម្មករនិយោជិតបានបំពេញការងារពេញលេញ។*

❖ ទី២ ការគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ

$$\text{ប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ} = \frac{\text{ប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំគិតជាមធ្យមក្នុង ១ខែ}}{\text{២២ថ្ងៃ ឬ២៤ថ្ងៃ ឬ២៦ថ្ងៃ}}$$

*(អាស្រ័យលើចំនួនថ្ងៃធ្វើការនៃរោងចក្រ សហគ្រាសនីមួយៗ)*

៣.២.៥. សោហ៊ុយជម្ងឺចិត្ត

ការគណនាសោហ៊ុយជំងឺចិត្ត គឺទទួលបានស្មើនឹងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ ២០១៩ និងប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំ ដែលបាននិងត្រូវទទួលបាន ប៉ុន្តែអតិបរមាមិនលើសពី ៦ខែ។ *(ករណីគ្មានភស្តុតាងបង្ហាញពីការខូចខាត)*

ប្រាក់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់បានរយៈពេល ១ឆ្នាំ ហើយគាត់ទទួលបានប្រាក់ឈ្នួលចំនួន ២០០ដុល្លារ ក្នុងមួយខែ។ គាត់ត្រូវបានបញ្ចប់កិច្ចសន្យាការងារដោយនិយោជកដោយមិនបានជូនដំណឹងមុនតាមច្បាប់នៅខែកញ្ញា ឆ្នាំ២០២៣។

ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាដែលកម្មករនិយោជិតទទួលបាន មានដូចខាងក្រោម៖

១. ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំខែចុងក្រោយ = **២៧០ $**

២. ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់

- ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំក្នុង ១ថ្ងៃ = ២០០ $ / ២៦ ថ្ងៃ = ៧.៦៩ $
- ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ = ៧.៩៦ $ x ១៨ ថ្ងៃ =**១៣៨ $**

៣. ប្រាក់បំណាច់ជួសឱ្យការជូនដំណឹងមុន

- ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ = (២៥០ + ២៥៥ + ២៦០ +២៧០ + ២៧៥ +២៧០ +២៥៥ +២៦៥ +២៥៥ +២៦០ +២៧០ +២៧៥) / ១២ ខែ = ២៦៣ $
- ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ = ២៦៣ $ / ២៦ ថ្ងៃ = ១០.១១ $
- ប្រាក់បំណាច់ជួសឱ្យការជូនដំណឹងមុន = ១០.១១ $ x ១៥ ថ្ងៃ = **១៥១.៦៥ $**

៤. ប្រាក់បំណាច់អតីតភាពការងារដែលមិនទាន់ទូទាត់

- ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ = (២៥០ + ២៥៥ + ២៦០ +២៧០ + ២៧៥ +២៧០ +២៥៥ +២៦៥ +២៥៥ +២៦០ +២៧០ +២៧៥) / ១២ ខែ = ២៦៣ $
- ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ = ២៦៣ $ / ២៦ ថ្ងៃ = ១០.១១ $
- ប្រាក់បំណាច់អតីតភាពការងារក្នុងឆ្នាំដែលមិនទាន់បានទូទាត់៖
  = ១០.១១ $ x ៧ ថ្ងៃ = **៧០.៧៧ $**

៥. ប្រាក់សោហ៊ុយជំងឺចិត្តដែលកម្មករនិយោជិតទទួលបាន

- ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ខែ = (២៥០ + ២៥៥ + ២៦០ +២៧០ + ២៧៥ +២៧០ +២៥៥ +២៦៥ +២៥៥ +២៦០ +២៧០ +២៧៥) / ១២ ខែ = ២៦៣ $
- ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជាមធ្យមក្នុង ១ថ្ងៃ = ២៦៣ $ / ២៦ ថ្ងៃ = ១០.១១ $
- ប្រាក់សោហ៊ុយជំងឺចិត្តដែលកម្មករនិយោជិតទទួលបាន = ១០.១១ $ x ៧ ថ្ងៃ = **៧០.៧៧ $**

ដូច្នេះប្រាក់បំណាច់បញ្ចប់កិច្ចសន្យាដែលកម្មករនិយោជិតទទួលបាន = ២៧០ $ + ១៣៨ $ + ១៥១.៦៥ $ + ៧០.៧៧ $ + ៧០.៧៧ $ = **៧០១.១៩ $**

## ៥.៤. ការបញ្ឈប់ពីការងាររួម

យោងតាមមាត្រា៩៥ នៃច្បាប់ស្តីពីការងារ និយោជកអាចអនុវត្តការបញ្ឈប់ពីការងាររួម ចំពោះកម្មករនិយោជិតនៅផ្នែកណាមួយនៃចង្វាក់ផលិតកម្ម ខណៈពេលដែលមានការសើរើរៀបចំផ្ទៃក្នុងរោងចក្រ សហគ្រាស ដើម្បីឆ្លើយតបនឹងវិបត្តិសេដ្ឋកិច្ច ពោលគឺកម្មករនិយោជិតក្នុងថ្នាក់គ្រប់គ្រងទាំងជនជាតិខ្មែរ និងបរទេស ថ្នាក់ដឹកនាំ និងសមាជិកសហជីព ឬកម្មករនិយោជិតទូទៅសុទ្ធតែអាចត្រូវបានបញ្ឈប់ពីការងាររួមគ្នា ដោយត្រូវទទួលបានការទូទាត់សំណងត្រឹមត្រូវតាមច្បាប់ស្តីពីការងារ និងគ្រាន់តែជូនដំណឹងមកអធិការការងារ។ ប៉ុន្តែនិយោជកត្រូវពិនិត្យមើលសម្បទាខាងវិជ្ជាជីវៈ ឬសមត្ថភាពបំពេញការងាររបស់កម្មករនិយោជិតក្នុងបណ្តាឆ្នាំកន្លងមក ដើម្បីធ្វើការចាត់ថ្នាក់កម្មករនិយោជិតដែលមានសម្បទាខាងវិជ្ជាជីវៈអន់ជាងគេ ដើម្បីធ្វើការបញ្ឈប់ពីការងាររួមគ្នាមុនគេ។ បន្ទាប់មកនិយោជក អាចបញ្ឈប់ក្រុមកម្មករនិយោជិតណាដែលមានអតីតភាពការងារតិចជាងគេ។ អតីតភាពការងាររបស់កម្មករនិយោជិតមិនមែនជាលក្ខខណ្ឌអាទិភាពដែលនិយោជកត្រូវពិនិត្យក្នុងការបញ្ឈប់ពីការងាររួមគ្នានោះទេ។ ដូចនេះ ក្រុមកម្មករនិយោជិតដែលមានអតីតភាពការងារតិចជាងគេអាចនឹងត្រូវបញ្ឈប់ពីការងារ បន្ទាប់ពីការបញ្ឈប់ក្រុមកម្មករនិយោជិតដែលមានសម្បទាខាងវិជ្ជាជីវៈអន់ជាងគេ។

ការបញ្ឈប់ពីការងាររួមគ្នានេះ តាមគោលការណ៍ច្បាប់ គឺនិយោជកមានសិទ្ធិក្នុងការជ្រើសរើសចាត់ថ្នាក់កម្មករនិយោជិតរូបណាដែលគួរត្រូវបញ្ឈប់មុនគេ និងត្រូវបញ្ឈប់ជាបន្តបន្ទាប់។ ការផ្តល់សិទ្ធិដល់និយោជក គឺដើម្បីធានាអំពីនិរន្តភាពនៃដំណើរការអាជីវកម្ម ដែលមានតែនិយោជកទេដែលអាចកំណត់សមត្ថភាពរបស់កម្មករនិយោជិតរបស់ខ្លួនបានថា តើគួរបញ្ឈប់កម្មករនិយោជិតរូបណា និងគួរទុកកម្មករនិយោជិតរូបណាស្របទៅនឹងសម្បទាវិជ្ជាជីវៈនិងតម្រូវការចាំបាច់ក្នុងដំណើរការអាជីវកម្មប្រចាំថ្ងៃ ដូចមានកំណត់ក្នុងមាត្រា៩៥ នៃច្បាប់ស្តីពីការងារ។ កម្មករនិយោជិតដែលមិនសុខចិត្តក្នុងការកាត់បន្ថយ ឬបញ្ឈប់ពីការងារ ពួកគាត់អាចប្តឹងជាលក្ខណៈបុគ្គល ឬរួមគ្នាមកអធិការការងារ ឬប្តឹងទៅតុលាការមានសមត្ថកិច្ចដោះស្រាយបន្ត។

យោងមាត្រា៩៥ និងមាត្រា១១០ថ្មី នៃច្បាប់ស្តីពីការងារ និងសេចក្តីបំភ្លឺស្តីពីការទូទាត់ប្រាក់បំណាច់ទូទាត់ជួសការឱ្យដំណឹងមុន និងសោហ៊ុយជំងឺចិត្តនៅពេលបញ្ចប់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅពេលបញ្ចប់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) ដោយមានហេតុផលសមរម្យ (ការបញ្ឈប់ពីការងាររួម) និយោជកត្រូវទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារចំនួន ៤ចំណុចៈ

១. ប្រាក់ឈ្នួលខែចុងក្រោយដែលមិនបានបើក (មាត្រា១១៦)។
២. ប្រាក់បំណាច់ជួសការឱ្យដំណឹងមុន ក្នុងករណីដែលនិយោជកមិនបានជូនដំណឹងមុនតាមច្បាប់កំណត់ (មាត្រា៧៥ និងមាត្រា៧៧)។
៣. ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និងមាត្រា១៦៧)។
៤. ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារ និងប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំដែលមិនទាន់បានទូទាត់ (មាត្រា៨៩ថ្មី)។

## មេរៀនទី៧

# ចរណវិជ្ជា

### ១. សេចក្តីផ្តើម

មនុស្សយើងរស់បានមកដល់សព្វថ្ងៃនេះគឺអាស្រ័យដោយមានសីលធម៌ ភាពសណ្តាសប្រណី ភាពជឿទុកចិត្ត និងទំនួលខុសត្រូវប្រកបដោយមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះយើងសង្កេតឃើញថា សីលធម៌នៃការរស់នៅរបស់មនុស្សកាន់តែធ្លាក់ចុះបន្តិចម្តងៗជារៀងរាល់ថ្ងៃ។ ការធ្លាក់ចុះនេះ គឺបណ្តាលមកពីការមិនយកចិត្តទុកដាក់អប់រំកូនចៅនូវក្រមសីលធម៌។ លទ្ធផលនៃការធ្លាក់ចុះនូវក្រមសីលធម៌ គឺបណ្តាលឱ្យកើតមាននូវជម្លោះទាស់ទែងគ្នា បង្ករជាហិង្សា សង្គ្រាមកាប់សម្លាប់គ្នា បង្ករភាពអសន្តិសុខក្នុងសង្គមជាដើម។

បច្ចុប្បន្នកម្ពុជាកំពុងតែជួបប្រទះនូវបញ្ហាអសីលធម៌ អមនុស្សធម៌ កូនមិនស្តាប់បង្គាប់ឪពុកម្តាយ សិស្សមិនស្តាប់គ្រូ មនុស្សមានចរិតដូចសត្វ មនុស្សមានចិត្តទមិឡឥតសាសនា និងគ្មានមនោសញ្ចេតនាជាដើម។ ទាំងនេះ គឺមិនមែនកើតឡើងតែនៅក្នុងខ្លួនមនុស្សល្ងិតល្ងង់ អវិជ្ជាប៉ុណ្ណោះទេ សូម្បីតែអ្នកប្រាជ្ញ បណ្ឌិត បញ្ញវន្ត មន្ត្រីធំតូច ក៏កំពុងតែពន្លេចនូវទង្វើអសីលធម៌ អមនុស្សធម៌ ដោយអំណាចនៃតណ្ហា មហិច្ឆតារបស់ខ្លួន ដែលកេងប្រវ័ញ្ចទ្រព្យសម្បត្តិកម្លាំងពលកម្ម ជួញដូរមនុស្សដូចវត្ថុឬសត្វជាតុផ្សេងៗ ការរំលោភសិទ្ធិរស់នៅ ការរំលោភសិទ្ធិប្រពៃណី ទំនៀមទម្លាប់ និងឈានដល់ការកាប់សម្លាប់មនុស្សជាតិ ក៏កំពុងតែកើតមានក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន ក៏ដូចជាបណ្តាប្រទេសមួយចំនួនក្នុងពិភពលោក។

ការអប់រំផ្នែកសីលធម៌ គឺជាការអភិវឌ្ឍមនុស្សឱ្យក្លាយទៅជាមនុស្សល្អនៅក្នុងសង្គម។ ដូចនេះគេពុំគួរមើលរំលងនូវក្រមសីលធម៌នោះទេ បានសេចក្តីថាបើមនុស្សម្នាក់ៗពុំបានអប់រំសីលធម៌ទេ មនុស្សនោះនឹងយកចំណេះដឹងរបស់គេទៅប្រើប្រាស់ក្នុងគោលបំណងអាក្រក់ ប្រាសចាកនូវសីលកុសល ក៏ដូចជាការប្រកាន់យកឥរិយាបថអត្តទត្តភាពជាដើម។ ដូចនេះយើងទាំងអស់គ្នាត្រូវតែចូលរួមឱ្យតម្លៃក្នុងការរស់នៅរបស់មនុស្សដែលប្រកបដោយក្រមសីលធម៌ខ្ពស់។

### ២. និយមន័យ

#### ២.១.និយមន័យពាក្យចរណវិជ្ជា

*ចរណវិជ្ជា* ពាក្យនេះផ្សំឡើងដោយពាក្យពីរគឺ *ចរណៈ* និង *វិជ្ជា*។ បើយោងតាមសន្ធានុក្រមពុទ្ធសាសនា មានន័យថា ការប្រព្រឹត្ត សេចក្តីប្រព្រឹត្តល្អ ក្រឹត្យដែលអ្នកប្រាជ្ញគួរប្រព្រឹត្ត គួរកាន់យក បែបបទសណ្តាប់ធ្នាប់។ ចំណែកឯវិជ្ជា មានន័យថា សេចក្តីដឹងច្បាស់ ការចេះដឹង ចំណេះ វេទមន្ត មន្តអាគម។ រួមសេចក្តីមកចរណវិជ្ជា គឺជាវិជ្ជាដែលមនុស្សគ្រប់គ្នាគួរប្រព្រឹត្តនូវសេចក្តីល្អ ប្រកបដោយសីលធម៌ គុណធម៌ សុជីវធម៌ ចរិយាធម៌ វៀរចាកនូវអំពើអាក្រក់ទាំងឡាយ។

## ២.២ និយមន័យនៃពាក្យសីលធម៌

***សីលធម៌*** ពាក្យនេះកាត់ជា២បទ គឺ ***សីល១*** និង ***ធម៌១។*** ***សីល*** គឺជាការក្សា កាយ វាចា ឱ្យរៀបរយល្អ និងឱ្យប្រាសចាកទោស។ ដែលហៅថា សីល បានដល់សីល៥, សីល៨, សីល១០ជាដើម។ សភាវទ្រទ្រង់ហៅថា ***ធម៌។*** ពាក្យថា***ធម៌*** ជារបស់ផ្លូវកណ្ដាល គឺទ្រទង់ទាំងខាងល្អ និងទ្រទង់ទាំងខាង អាក្រក់។ បើខាងល្អគឺទ្រទ្រង់អ្នកប្រព្រឹត្តល្អមិនឱ្យធ្លាក់ទៅក្នុងទីអាក្រក់ ហៅថាធម៌ល្អ(កុសលធម៌)។ បើខាងអាក្រក់ គឺទ្រទ្រង់អ្នកប្រព្រឹត្តអំពើអាក្រក់ឱ្យធ្លាក់ទៅក្នុងទីអាក្រក់ ហៅថាធម៌អាក្រក់(អកុសលធម៌)។ ***ធម៌*** ក្នុងពាក្យថាសីលនេះសំដៅយកធម៌ខាងល្អ។ ធម៌មានលក្ខណៈទាក់ទងនឹងកិច្ចផ្សេងៗអំពីសីល។ ***សីល*** មានការរៀបរយ កាយ វាចាជាលក្ខណៈដែលមានការកម្ចាត់បង់នូវសេចក្ដីអាក្រក់ដែលនឹងគប្បីប្រព្រឹត្តកន្លងដោយកាយ វាចាជានិច្ច រមែងសម្រេចជាសីលបានដោយការលះវៀរ គឺលះវៀរតាមសិក្ខាបទនៃអំពើនោះ។

ចំណែកឯ ***ធម៌*** មានសភាពទ្រទ្រង់អ្នកប្រព្រឹត្តខុសមិនឱ្យធ្លាក់ទៅក្នុងទីអាក្រក់ មានកិរិយាធ្វើអធ្យាស្រ័យដល់មនុស្សអ្នកប្រព្រឹត្ត ឱ្យរឹតតែល្អិតល្អន់សុខុមក្រៃលែង ជាងភាពដើម ជាលក្ខណៈដែលមានការកម្ចាត់បង់នូវសេចក្ដីអាក្រក់ ដែលនឹងគប្បីកើតឡើងក្នុងចិត្តជាកិច្ចរមែងសម្រេចប្រយោជន៍ដល់អ្នកប្រតិបត្តិបានដោយការធ្វើតាម*សីល* និង*ធម៌*។

វចនានុក្រមខ្មែរ រៀបរៀងដោយសម្ដេចព្រះសង្ឃរាជ***ជួន ណាត*** ពន្យល់ថា ***សីលធម៌*** គឺជាកិរិយាមារយាទ សណ្ដាប់ធ្នាប់ ដំបូន្មាន ឬទម្លាប់នៃការប្រព្រឹត្តដែលប្រាសចាកអំពើអាក្រក់ ដោយប្រព្រឹត្តតែអំពើល្អ។ តាមន័យទូទៅ សីលធម៌ ដឹកនាំមនុស្សទៅរកផ្លូវល្អ ចៀសវាងផ្លូវអាក្រក់នៅក្នុងជីវិតរស់នៅ។

រីឯមនុស្សដែលមានសីលធម៌ គឺជាមនុស្សដែលប្រព្រឹត្តតែអំពើល្អនៅក្នុងការងារ និងជីវិតរស់នៅ ទាំងសម្រាប់ខ្លួនឯង សម្រាប់ក្រុមគ្រួសារ និងសម្រាប់សង្គម។

រួមសេចក្ដីមក ពាក្យថា***សីលធម៌*** សម្រាប់ប្រជាជនខ្មែរយើង គឺមានអត្ថន័យទូលំទូលាយណាស់។ ពាក្យនេះ គឺសំដៅដល់រាល់ទង្វើនៃឥរិយាបថ ឬអាកប្បកិរិយារបស់មនុស្សដែលប្រព្រឹត្តជាប្រចាំថ្ងៃដោយបែងចែកជាអំពើល្អ និងអំពើអាក្រក់។

## ២.៣ ក្រមសីលធម៌វិជ្ជាជីវៈ

តើអ្វីទៅជាក្រមសីលធម៌វិជ្ជាជីវៈ?

ក្រមសីលធម៌វិជ្ជាជីវៈ បានផ្ដល់នូវការណែនាំសំខាន់ៗដែលអ្នកត្រូវការដើម្បីយល់ដឹងអំពីការទទួលខុសត្រូវរបស់អ្នក រួមទាំងកាតព្វកិច្ចក្នុងការអនុលោមទៅតាមច្បាប់។ ក្រមសីលធម៌វិជ្ជាជីវៈ គឺជាក្រមសីលធម៌នៃការប្រព្រឹត្តរបស់មនុស្សគ្រប់រូបដែលគ្មាននរណាខ្វះបានឡើយ។ សីលធម៌វិជ្ជាជីវៈ បានជួយតម្រង់ផ្លូវដល់អ្នកប្រកបមុខរបរទាំងអស់ឱ្យអនុវត្តទៅតាមក្រមសីលធម៌វិជ្ជាជីវៈរៀងៗខ្លួន។

ការមិនគោរពក្រមសីលធម៌វិជ្ជាជីវៈ នោះនឹងបណ្តាលឱ្យកិច្ចការរបស់ខ្លួនមិនទទួលបានជោគជ័យឡើយ (ភាពគ្មានសេចក្តីថ្លៃថ្នូរ ការរំលោភបំពាន ការច្រណែនឈ្នានីស ភាពមិនស្មោះត្រង់ ការកេងប្រវ័ញ្ច និងពុករលួយ) ការនិយាយពីវិជ្ជាជីវៈ គឺមានវិសាលភាពធំធេងណាស់ ទាំងនៅក្នុងក្របខណ្ឌរដ្ឋ និងឯកជន ហេតុនេះយើងក៏មិនអាចរៀបរាប់ឱ្យមានពិស្តារបានគ្រប់ជ្រុងជ្រោយនោះទេ។ ការលើកឡើងនេះវាស្តួចស្តើងណាស់ ប៉ុន្តែទោះជាយ៉ាងណាក៏ជាការក្រើនរំលឹកដល់អ្នកប្រកបមុខរបរវិជ្ជាជីវៈ ទាំងអស់យកទៅធ្វើការគិតពិចារណាថ្លឹងថ្លែង ដើម្បីប្រព្រឹត្តទៅតាមអ្វីដែលគួរ និងអ្វីដែលមិនគួរប្រកបដោយសីលធម៌ ជៀសវាងនូវការដាក់ទោសទណ្ឌពីសំណាក់មហាជន ពីធម្មជាតិ ពីទំនៀមទម្លាប់ប្រពៃណី សាសនា ជាពិសេសច្បាប់របស់រដ្ឋ។

### ៣. អត្ថប្រយោជន៍នៃសីលធម៌

សីលធម៌ បាននាំឱ្យមនុស្សទៅរកនូវផ្លូវល្អដែលប្រកបដោយគុណធម៌ មានតម្លៃស្តែងចេញពី កាយ វាចា និងចិត្តរបស់បុគ្គលម្នាក់ៗ ទៅតាមឥរិយាបថសីលធម៌របស់មនុស្ស។ តាមទស្សនៈវិទូបារាំងលោក អេមីល ដាកឃីន (Emile Durkheim) បាននិយាយថា សង្គមនីមួយៗសុទ្ធតែមានសីលធម៌។ ប្រសិនបើគ្មានសីលធម៌ ពិតជាការរស់នៅរបស់សមាជិកសង្គមនោះរស់បែបអាណាធិបតេយ្យ។ លើសពីនេះទៀត សង្គមនឹងគ្មានសណ្តាប់ធ្នាប់ គ្មានវប្បធម៌ច្បាស់លាស់។ ដូចនេះ ការអប់រំសីលធម៌ជាគ្រឹះនៃការបង្កើតសង្គម ការអប់រំសីលធម៌ជាអាទិភាពក្នុងចំណោមនៃការអប់រំទាំងឡាយ។ នៅក្នុងគ្រួសារមួយ ជំហានដំបូងគឺឱ្យមនុស្សចេះគោរពស្រឡាញ់សមាជិកក្នុងគ្រួសារជាបុព្វហេតុនៃសីលធម៌។ ក្នុងកំឡុងស.វទី១៩,២០ និងទី២១ការអប់រំសីលធម៌បានទទួលលទ្ធផលអវិជ្ជមានច្រើន ដែលស្របនឹងការរីកចម្រើននៃវិទ្យាសាស្ត្របច្ចេកទេស និងការប្រកួតប្រជែងទីផ្សារសម្ភារ។ ក្នុងនោះសីលធម៌បានផ្តល់ផលប្រយោជន៍ដល់ការអប់រំមនុស្សដូចជា៖

- ការទទួលខុសត្រូវ ស្គាល់ល្អ ស្គាល់អាក្រក់។
- គោរពពេលវេលា។
- មានភាពស្មោះត្រង់ចំពោះគ្នា។
- ការដឹងច្បាស់នូវកតព្វកិច្ចរបស់ខ្លួន។
- មានសាមគ្គីភាពស្រឡាញ់សន្តិភាព។
- ការទទួលខុសត្រូវចំពោះខ្លួនឯង អ្នកដទៃ សង្គមជាតិ។
- មានទំនាក់ទំនងល្អដោយមិនរើសអើងអ្វីទាំងអស់។

### ៤. មូលហេតុមួយចំនួនដែលនាំឱ្យសីលធម៌ធ្លាក់ចុះ

ក្នុងសង្គមនាពេលបច្ចុប្បន្ន សីលធម៌របស់មនុស្សមានការធ្លាក់ចុះគួរឱ្យបារម្ភ។ បារម្ភព្រោះថាវាបានបង្កការលំបាក និងភាពច្របូកច្របល់នៅក្នុងសង្គម។ យ៉ាងណាមិញ សីលធម៌នៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន ត្រូវបានមតិមួយចំនួនលើកឡើងថា ក៏មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ផងដែរ។ ថ្វីត្បិតតែពុំមានការ

សិក្សាណាមួយបង្ហាញឱ្យបានច្បាស់លាស់ អំពីការលើកឡើងនេះក៏ដោយ ក៏គេនៅតែអាចមើលឃើញពីការធ្លាក់ចុះនៃសីលធម៌ក្នុងសង្គមខ្មែរ តាមរយៈទំព័រសារព័ត៌មានជារៀងរាល់ថ្ងៃ។

តាមរយៈទំព័រសារព័ត៌មាន មានការផ្សព្វផ្សាយអំពើកាប់ចាក់ កូនចាក់ឪពុក ឪពុករំលោភកូន កូនរំលោភម្តាយ ព្រះសង្ឃឆាន់ស្រាពិសារបាយល្ងាច អំពើហិង្សាប្តីវាយសម្លាប់ប្រពន្ធ ស្នេហាត្រីកោណ ក៏ដូចជាការវាយប្រហារគ្នានៅក្នុងវង់រាំកម្សាន្តជាដើម ហើយបានលេចឡើងលើទំព័រកាសែតជារឿយៗ និងកាន់តែច្រើនឡើងៗ។ ក្រៅពីនេះ ក៏មានអំពើលួចឆក់ប្លន់ កេងបន្លំ រាប់តាំងពីលួចមាន់ លួចទា រហូតដល់លួចកិបកេងទ្រព្យសម្បត្តិរដ្ឋថែមទៀត។ ចំណែកការអួតអាង និងប្រើប្រាស់អំណាចពីសំណាក់មន្ត្រីមានមុខមាត់ទៅលើអ្នកក្រីក្រទន់ខ្សោយ ក៏កើតឡើងជាញឹកញាប់ផងដែរ។ រឿងរ៉ាវទាំងអស់នេះ បង្ហាញឱ្យឃើញយ៉ាងច្បាស់ពីការស្រុតចុះនៃសីលធម៌សង្គមយ៉ាងធ្ងន់ធ្ងរ ដែលទាមទារការយកចិត្តទុកដាក់ជាបន្ទាន់។ ខាងក្រោមនេះជាមូលហេតុមួយចំនួនដែលធ្វើឱ្យសីលធម៌ធ្លាក់ចុះ៖

*មូលហេតុទី១*៖ គឺដោយសារតែពលរដ្ឋខ្មែរលែងយល់ពីតម្លៃរបស់សីលធម៌។ សីលធម៌ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ ដើម្បីកសាងសង្គមមួយប្រកបដោយសុខមាលភាព និងសន្តិភាព។ ជាការពិត ដើម្បីរស់នៅក្នុងសង្គមប្រកបដោយភាពសុខដុមរមនា មនុស្សត្រូវតែមានសីលធម៌ ត្រូវចេះគោរពស្រឡាញ់រាប់អានគ្នាទៅវិញទៅមក និងចាំបាច់ណាស់ គឺត្រូវតែពិភាក្សាដោះស្រាយបញ្ហាជាមួយគ្នាដោយសន្តិវិធី។ ប៉ុន្តែ នៅក្នុងសង្គមដែលមានការប្រកួតប្រជែងកាន់តែខ្លាំងដូចសព្វថ្ងៃ ពលរដ្ឋខ្មែរលែងចេះស្តាប់គ្នា លែងទុកចិត្តគ្នា លែងចេះជួយយកអាសារគ្នាទៀតហើយ។ ពលរដ្ឋខ្មែរ ហាក់ដូចជាមើលរំលង ឬលែងយល់ពីតម្លៃរបស់ក្រមសីលធម៌ដែលជាហេតុធ្វើឱ្យមនុស្សនៅក្នុងសង្គមជួបភាពវឹកវរ។

*មូលហេតុទី២*៖ គឺការហូរចូលយ៉ាងគំហុកនៃវប្បធម៌បរទេស។ យុវជនខ្មែរ ជាពិសេសសិល្បៈករនិយមចូលចិត្តចម្លងវប្បធម៌បរទេសមកអនុវត្ត ទាំងការនិយាយស្តី ការស្លៀកពាក់តុបតែងខ្លួន និងកាយវិការព្រមទាំងការប្រព្រឹត្តអបាយមុខផ្សេងៗ។ ការទទួលយកឥទ្ធិពលពីវប្បធម៌បរទេសជ្រុលហួសហេតុយកមកអនុវត្តដូច្នេះ គឺពិបាកនឹងទទួលយកខ្លាំងណាស់ នៅក្នុងសង្គមកម្ពុជា។ ពិបាកទទួលយកព្រោះវាបានធ្វើឱ្យសីលធម៌ដ៏ល្អផូរផង់របស់ខ្មែរធ្លាក់ចុះដាលំដាប់គួរឱ្យព្រួយបារម្ភ។

*មូលហេតុទី៣*៖ គឺការយកចិត្តទុកដាក់របស់អ្នកដឹកនាំនៅមានកម្រិត។ អ្នកវិភាគសង្គមមួយចំនួនបន្ទោសថា ដោយសារតែការយកចិត្តទុកដាក់របស់អ្នកដឹកនាំនៅមានចំណុចខ្វះខាត ទើបបណ្តាលឱ្យក្រមសីលធម៌ខ្មែរមានការធ្លាក់ចុះយ៉ាងដូច្នេះ។ នៅក្នុងសង្គមខ្មែរ ដែលអ្នកដឹកនាំមានឥទ្ធិពលយ៉ាងច្រើនទៅលើប្រជាពលរដ្ឋរបស់ខ្លួន គេអាចលើកកម្ពស់ក្រមសីលធម៌ តាមរយៈឆន្ទៈរបស់អ្នកដឹកនាំ។ បើអ្នកដឹកនាំនៅកម្ពុជាបង្ហាញឆន្ទៈច្រើនជាងនេះទៅទៀត គេប្រាកដជាអាចធ្វើឱ្យសីលធម៌នៅក្នុងសង្គមកម្ពុជាប្រសើរឡើងជាក់ជាពុំខាន។

## ៥. ឧស្សនអប់រំសីលធម៌តាមលទ្ធិសាសនាផ្សេងៗ

សីលធម៌មានប្រភពពិតប្រាកដមកពីជំនឿ និងសាសនា។ មនុស្សគ្រប់រូបត្រូវស្វែងយល់ពីក្រមសីលធម៌ ព្រោះក្រមសីលធម៌បានចាប់កំណើតជាមួយជំនឿ សាសនា និងលទ្ធិផ្សេងៗទៀតនៅលើពិភពលោកយើងនេះ។

### ៥.១. អប់រំសីលធម៌តាមសាសនាឥស្លាម



ឥស្លាមសាសនាមានដើមកំណើតនៅប្រទេសអារ៉ាប់។ ពួកឥស្លាមសាសនាមានជំនឿលើព្រះអាឡ្លា (ALLAH) តែមួយគត់ ដោយមានបន្ទូលឱ្យមហាម៉័តកត់ត្រាពាក្យពេចន៍របស់ព្រះអង្គ ទុកក្នុងគម្ពីរមួយឈ្មោះថា គម្ពីរកូអាន(Quran)។ បញ្ញត្តិដែលមិនត្រូវប្រព្រឹត្តមានដូចជា៖

- កុំលួចទ្រព្យសម្បត្តិ ឬកេងប្រវ័ញ្ចបោកបញ្ឆោតគេ។
- កុំលួចប្រពន្ធគេ។
- កុំមុសា មួលបង្កាច់ តិះដៀល ពោលពាក្យកុហក ។
- កុំសម្លាប់មនុស្សស្លូតត្រង់។

+សីលធម៌ដែលគួរប្រព្រឹត្តមានដូចជា៖




- ប្រព្រឹត្តិអំពើល្អ ចំពោះគ្នាទៅវិញទៅមកក្នុងសង្គម។
- អនុវត្តច្បាប់មនុស្សធម៌ចំពោះគ្នាទៅវិញទៅមក។
- មានចិត្តសណ្តោសប្រណីចំពោះមនុស្សដូចគ្នា។
- ត្រូវមានសមភាពរវាងជនជាតិអារ៉ាប់ទាំងអស់។
- មានអធ្យាស្រ័យទៅលើស្ត្រីភេទ។

### ៥.២. ការអប់រំសីលធម៌តាមគ្រឹស្តសាសនា



សាសនាគ្រឹស្ត គឺជាសាសនាមួយក្នុងចំណោមសាសនាក្នុងពិភពលោកមានដើមកំណើតនៅប្រទេសអ៊ីស្រាអែល។ ព្រះគម្ពីរប៊ីប (Bible) គឺជាដំណើរកត់ត្រាប្រតិបត្តិនៃការជួយសង្គ្រោះមនុស្សលោករបស់ព្រះដោយតស៊ូបំពេញដោយយេស៊ូគ្រឹស្ត។ បញ្ញត្តិផ្សេងៗ មានដូចជា៖

- ត្រូវគោរពព្រះសួគ៌។
- មិនត្រូវប្រមាថព្រះនាមរបស់ព្រះអង្គ ឬយកនាមព្រះអង្គមកស្បថស្បែរ។
- ថ្ងៃអាទិត្យត្រូវញុំាងខ្លួនឱ្យបរិសុទ្ធ(បញ្ឈប់កិច្ចការដទៃក្រៅពីសាសនា)។

– ត្រូវគោរពមាតាបិតា និងអ្នកដទៃ ព្រមទាំងជួយបំពេញកិច្ចការសម្រាប់ជាតិ។
– មិនត្រូវធ្វើមនុស្សឃាត រួមទាំងខ្លួនឯង។
– កុំប្រព្រឹត្តអំពើទុច្ចរិត។
– កុំយកទ្រព្យអ្នកដទៃ ឬរំពៃទ្រព្យអ្នកដទៃ។
– កុំពោលពាក្យកុហក។
– ត្រូវកំចាត់សេចក្តីប្រាថ្នាលាមក។



### ៥.៣ ការអប់រំសីលធម៌តាមព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា ជាបរមគ្រូនៃយើងមុនពេលនៃព្រះអង្គយាងចូលបរិនិព្វាន ព្រះអង្គបានបន្សល់ទុកនូវឱវាទដ៏ល្អប្រពៃជាទស្សនៈ និងជាទ្រឹស្តីក្នុងការអប់រំសីលធម៌ល្អដល់មនុស្សលោកឱ្យប្រតិបត្តិតាម។ រហូតមកដល់ពេលនេះ អស់រយៈពេលជាង២០០០ឆ្នាំមកហើយ។ សីលធម៌ដែលមនុស្សត្រូវប្រតិបត្តិរួមមាន៖



– វៀរចាកការសម្លាប់ជីវិតសត្វដទៃ។
– វៀរចាកការប្រកាន់យកទ្រព្យសម្បត្តិរបស់អ្នកដទៃ។
– វៀរចាកការរួមប្រវេណី គឺប្រព្រឹត្តផ្លូវភេទ ជាមួយប្រពន្ធកូនរបស់ជនដទៃ។
– វៀរចាកការនិយាយពាក្យមិនពិត។
– វៀរចាកការផឹកទឹកស្រវឹង ដែលជាហេតុឱ្យកើតសេចក្តីប្រមាទផ្សេងៗ។

### ៥.៤. ការអប់រំសីលធម៌តាមព្រហ្មញ្ញសាសនា

ព្រាហ្មណ៍សាសនាជាសាសនាមួយធំជាងគេនិងមានវ័យចំណាស់ជាងគេផងដែរ នៅប្រទេសឥណ្ឌាដែលមាន កំណើតប្រមាណជាង១៥០០ ឆ្នាំមុន គ.ស.។ គោលការណ៍អប់រំសីលធម៌របស់សាសនាព្រាហ្មណ៍ ផ្អែកលើអាទិទេពជាធំ ហើយខ្លឹមសារក្នុងគម្ពីរវេទ គឺ ចងក្រងឡើងដើម្បីអានុភាពនៃអាទិទេព។ ពិធីផ្សេងៗដើម្បីថ្វាយពរជ័យដល់អាទិទេព និងទេវៈផ្សេងៗ។ ការបង្ហាញអំពីសីលធម៌របស់សាសនាព្រាហ្មណ៍ គឺ មានជំនឿថាការគោរពព្រះព្រហ្មជាអាទិទេពបង្កើតលោក និងជាអ្នកផ្ដល់ជីវិតឱ្យ មនុស្ស សត្វ និងអ្វីៗទាំងអស់នៅលើផែនដី។ *ព្រហ្ម័ន* គឺស្ថិតនៅក្នុងព្រលឹងនៃព្រហ្ម ហើយនៅក្នុងព្រលឹងតូចៗជាច្រើនហៅថាអាត្ម័ន។ អាត្ម័ននេះហើយជាអ្នកបង្កើតជីវិត។ *កម្ម* សម្គាល់ទៅលើអំពើដែលជាកុសល និងអកុសលដែលបុគ្គលម្នាក់ៗបានប្រព្រឹត្តក្នុងដំណើរជីវិតបច្ចុប្បន្ន និងអតីតជាតិរបស់គេ។




## ៦. ក្រមសីលធម៌ដើម្បីឱ្យជីវិតជោគជ័យ

មនុស្សខ្លះគិតថា ជីវិតជោគជ័យគឺជាជីវិតដែលមានអំណាចយសស័ក្តិ និងមានទ្រព្យសម្បត្តិដ៏ច្រើនមហាសាល។ បើទោះបីជាយើងមានរបស់ទាំងអស់នោះហើយក៏ដោយ ក៏យើងនៅតែមិនពេញចិត្ត(មិនស្ងប់ចិត្ត) ហើយយើងមានកង្វល់ថានឹងបាត់បង់របស់នោះទៅវិញនៅថ្ងៃណាមួយជាក់ជាមិនខាន។ ជាពិសេសនោះ គឺនៅពេលដែលយើងយករបស់ទាំងអស់នោះមកដោយកម្លាំងញើសឈាមរបស់អ្នកដទៃ នោះមានន័យថាយើងកំពុងតែបង្កនូវបញ្ហាបណ្ដុះនូវគំនិតអសីលធម៌ អគុណធម៌ដល់ក្មេងជំនាន់ក្រោយ។

ជីវិតជោគជ័យគឺជាជីវិតដែលបានបង្កើតមិត្តជាច្រើន ហើយមានមនុស្សជាច្រើនដែលមានការសប្បាយរីករាយដោយមានយើងជាមិត្តរបស់គេ។ ដូច្នេះវាមិននាំឱ្យមានបញ្ហាទេថា តើយើងមានលុយកាក់ និងអំណាចច្រើនប៉ុណ្ណាក៏ដោយ ក៏យើងនឹងមានការគាំទ្រផ្នែកចិត្តនិងអារម្មណ៍ពីបណ្ដាមិត្តយ៉ាងពេញទំហឹងដែលរងចាំផ្ដល់ឱ្យយើងនូវថាមពលក្នុងការដោះស្រាយរឿងរ៉ាវនានាដែលអាចកើតឡើងនៅក្នុងឆាកជីវិតរបស់យើង។

គោលការណ៍ណែនាំនៃក្រមសីលធម៌ គឺបង្ហាញនូវប្រភេទនៃអាកប្បកិរិយាដែលនាំយើងទៅរកសុខសុភមង្គល និងបង្ហាញយើងនូវប្រភេទនៃអាកប្បកិរិយាដែលបង្កនូវវិបត្តិនិងបញ្ហានានា។ នៅពេលដែលយើងមានសភាពចិត្តស្មោះត្រង់ និងមានបំណងប្រាថ្នាចង់ផ្ដល់នូវសុភមង្គលដល់អ្នកដទៃ នោះពួកគេជឿទុកចិត្ត

លើយើងថាមិនបោកប្រាស់ មិនកោងកាចនិងមិនកេងប្រវ័ញ្ចពួកគេទេ។ ទំនុកចិត្តនេះគឺជាមូលដ្ឋានគ្រឹះនៃមិត្តភាពរបស់យើងជាមួយមនុស្សរាល់គ្នាដែលយើងជួបប្រសព្វនៅក្នុងឆាកជីវិត។ ពួកគេនឹងមានអារម្មណ៍ធូរស្បើយ និងសប្បាយរីករាយដែលបានស្ថិតនៅជាមួយយើង ហើយគេគិតថាគ្មានអ្វីត្រូវខ្លាចនោះទេ។

ដូចគ្នានេះដែរ ទង្វើបែបនេះធ្វើឱ្យយើងមានអារម្មណ៍កាន់តែសប្បាយរីករាយ។ តើនរណាចង់ឱ្យមនុស្សមានអារម្មណ៍អសុវត្ថិភាព និងមានការភ័យខ្លាចនៅពេលណាដែលយើងចូលទៅជិតគេនោះ? មនុស្សរាល់គ្នាគេស្វាគមន៍អ្នកដែលមានមុខមាត់ញញឹម។

យើងត្រូវការការគាំទ្រ និងជំនួយពីមនុស្សដទៃទៀតដើម្បីរស់រានមានជីវិត។ មិនថាពេលដែលយើងទើបនឹងកើតមកជាកូនង៉ាប៉ុណ្ណោះទេ សូម្បីតែពេលដែលយើងជាមនុស្សចាស់ជរាកោងខ្នងស្ថិតនៅក្នុងផ្ទះសម្រាប់ថែទាំមនុស្សចាស់ហើយក៏ដោយ ក៏យើងត្រូវការជំនួយពីអ្នកដទៃផងដែរ។ យើងត្រូវការជំនួយនិងការយកចិត្តទុកដាក់ខ្វល់ខ្វាយពីអ្នកដទៃពេញមួយជីវិតរបស់យើង។ ការគាំទ្រផ្នែកអារម្មណ៍ដែលយើងទទួលបានពីមិត្តជាទីស្រលាញ់នានាបង្កើតនូវជីវិតដ៏ពេញបរិបូរណ៍។ ការមានស្មារតីនៃក្រមសីលធម៌ជ្រាលជ្រៅអាចបង្កលក្ខណៈឱ្យយើងបង្កើតនូវទំនាក់ទំនងជាមិត្តភាពល្អជាមួយបុគ្គលណាដែលយើងជួបប្រសព្វនៅក្នុងឆាកជីវិតរបស់យើង។

### ៧. អាកប្បកិរិយា ឬឥរិយាបថដែលយើងគួរប្រតិបត្តិ

នៅពេលដែលយើងចាប់ផ្តើមគិតថា តើយើងត្រូវរៀបចំអាកប្បកិរិយាយ៉ាងដូចម្តេចដើម្បីឱ្យសមស្របទៅនឹងស្ថានភាព? ពេលនោះ ទើបយើងដឹងថា ការរៀបចំអាកប្បកិរិយា ឬឥរិយាបទពិតជាមានសារសំខាន់ខ្លាំងណាស់។ ខាងក្រោមនេះគឺអ្វីដែលយើងគួរស្វែងយល់ពីអាកប្បកិរិយារបស់មនុស្សនៅក្នុងសង្គម៖

• [illegible] ( ការស្វាគមន៍ ឬការគោរព គឺជាទង្វើមួយ នៃការទំនាក់ទំនង ដែលមនុស្សតែងតែអនុវត្ត នៅរៀងរាល់ពេលដែលពួកគេជួបគ្នា។ អ្វីដែលសំខាន់នោះ របៀបនៃការគោរព មានភាពខុសប្លែកពីគ្នា អាស្រ័យទៅតាមទីកន្លែង ដែលមនុស្សម្នាក់ៗរស់នៅផងដែរ។ ខាងក្រោមនេះ ជារៀបនៃការស្វាគមន៍ និងគោរពគ្នា៖






## ៧.២ សីលធម៌ក្នុងការប្រើប្រាស់កាយវិការ

មនុស្សមួយចំនួនពុំបានខ្វាយខ្វល់ជាមួយនឹងកាយវិការរបស់ខ្លួននោះទេ។ នៅក្នុងការរស់នៅ យើងចាំបាច់ត្រូវតែគិតពីកាយវិការរបស់យើងគ្រប់ពេលវេលា។ កាយវិការខ្លះនឹងធ្វើឱ្យខ្លួនយើងមើលទៅឆ្គាំឆ្គង រហូតមនុស្សមួយចំនួនគិតវាជារឿងអសីលធម៌។ ដូចនេះ យើងគួរតែប្រុងប្រយ័ត្នរាល់ការប្រើប្រាស់កាយវិការសម្រាប់ទំនាក់ទំនងគ្នា។ យ៉ាងណាមិញ ខ្លឹមសាររួមនៃសីលធម៌អប់រំរបស់ព្រះពុទ្ធសាសនា ក៏បានក្រើនរំលឹកដល់មនុស្សទូទៅឱ្យប្រុងប្រយ័ត្ននូវកាយទុច្ចរិត៣គឺ វៀរចាកនូវអំពើបៀតបៀនដល់ជីវិត(មនុស្ស និងសត្វ) អំពើកែងប្រវ័ញ្ច ឬលួចប្លន់ និងអំពើខុសឆ្គងក្នុងកាមគុណខុសគន្លងប្រពៃណី។

ខាងក្រោមនេះ ជាឥរិយាបថទាំងបួន( ដេក ដើរ ឈរ អង្គុយ )របស់មនុស្ស៖













ទន្ទឹមនឹងនេះ យើងគប្បីដឹងខ្លះៗ នៃកាយវិការមួយចំនួនដែលអ្នកគួរស្វែងយល់៖

❖ *ការប្រើទឹកមុខ*

នៅពេលធ្វើទំនាក់ទំនង ឬសន្ទនាគ្នាគួចេះប្រើទឹកមុខឱ្យបានល្អទៅតាមពេលវេលា និង កាលៈទេសៈ។ ត្រូវចេះប្រើទឹកមុខស្រស់ស្រាយ រក្សានូវស្នាមញញឹមជានិច្ចនៅពេលជជែកគ្នាលេង និងប្រើទឹកមុខក្រៀមក្រំនៅពេលសម្តែងមរណៈទុក្ខ ប្រើទឹកមុខយកចិត្តទុកដាក់នៅពេលពិភាក្សាការងារ ឬត្រូវប្រើទឹកមុខម៉ឺងម៉ាត់នៅពេល ដាក់បទបញ្ជារណាមួយ។ ការប្រើប្រាស់ទឹកមុខគឺជារឿងសំខាន់នៅក្នុងការទំនាក់ទំនងរបស់មនុស្ស។ ការប្រើប្រាស់ទឹកមុខមិនត្រឹមត្រូវ និងខុសពេលវេលា ធ្វើឱ្យការទំនាក់ទំនងរបស់យើងត្រូវទទួលបរាជ័យ។ ពេលខ្លះយើងជាមនុស្សល្អមានមុខល្អ តែ



បើយើងមានទឹកមុខក្រម៉ូវ នាំឱ្យគេយល់មកយើងថាជាមនុស្សអាក្រក់ មនុស្សមិនរាប់ញាតិ មនុស្សអត់រស់ជាតិ។ អ្នកខ្លះចិត្តមិនល្អទេ តែមានទឹកមុខល្អ ធ្វើឱ្យគេស្រលាញ់ ចូលចិត្ត និងមានជំនឿទុកចិត្ត។ ទាំងនេះ បញ្ជាក់ឱ្យឃើញថាការប្រើប្រាស់ ទឹកមុខជារឿងសំខាន់ណាស់ដែលអាចធ្វើឱ្យជីវិតយើងជោគជ័យ ឬបរាជ័យក៏ដោយសារទឹកមុខនេះដែរ។

❖ *សីលធម៌ក្នុងការប្រើក្រសែភ្នែក*



អ្នកខ្លះមិនចូលចិត្តមើលមុខគ្នា ឬប្រើក្រសែភ្នែកជាមួយដៃគូសន្ទនានៅពេលប្រាស្រ័យទាក់ទងគ្នា។ កាយវិការបែបនេះគឺបង្ហាញឱ្យឃើញពីភាពខ្វះទំនុកចិត្តរបស់យើង ហើយជាពិសេសនោះ ធ្វើឱ្យដៃគូសន្ទនាយល់ថា យើងមិនយកចិត្តទុកដាក់ មិនឱ្យតម្លៃទៅអ្នកដែលយើងកំពុងប្រាស្រ័យទាក់ទងជាមួយ។ គេនិយាយបានមួយបែបទៀតថា នៅពេលដែលយើងនិយាយមិនមើលមុខគ្នាអាចធ្វើឱ្យគេយល់ថា យើងជាមនុស្សវាយឫក ឬក្រអឺតក្រទម។

### ❖ *ប្រើកាយវិការឱបដៃ*




នេះអាចជាកាយវិការសាកលមួយបង្ហាញឱ្យឃើញថា អង្គុយ ឬឈរឱបដៃនិយាយជាមួយគេ គឺជាកាយវិការមិនសមរម្យមួយ។ ជាទូទៅគេច្រើនគិតថា កាយវិការបែបនេះ គឺជាការផ្ញើសារប្រាប់ថា គេមិនចាប់អារម្មណ៍ ចំពោះយើង។ កាយវិការបែបនេះ នាំឱ្យគេគិតថា យើងមិនឱ្យតម្លៃដល់គេ។

### ❖ *យកដៃទ្រចង្កាខ្ពស់ពេក*



អ្នកខ្លះច្រើនយកដៃទ្រចង្ការបស់ខ្លួន នៅពេលនិយាយដើម្បីបង្ហាញនិងឱ្យមានទំនុកចិត្តក្នុងការសន្ទនា។ ប៉ុន្តែប្រសិនបើលើកចង្កាខ្ពស់ពេក វានឹងធ្វើឱ្យគេមើលមកយើងថា បែបវាយឫក ក្រអឺតក្រទម និងមិនចាប់អារម្មណ៍នឹងការសន្ទនាទៅវិញទេ។ ស្រដៀងនឹងកាយវិការឱបដៃដែរ យកដៃទ្រចង្កាហួត និងខ្ពស់ពេក វានឹងធ្វើឱ្យដៃគូសន្ទនារបស់យើងយល់ថាស យើងមើលងាយ និងមានអំនួតដោយប្រយោជន៍។




❖ ***កាយវិការចង្អុល*** នេះជាកាយវិការដែលគេចាត់ទុកថា ឈ្លើយ ព្រហើនច្រឡងខាម។ នៅក្នុងការសន្ទនា គេមិនប្រើការចង្អុលនោះទេ បើសិនជាត្រូវការប្រើដៃទៅរកដៃគូសន្ទនា យើងគួរតែប្រើដៃលាទាំងអស់។

### ❖ *ឧស្សាហ៍មើលម៉ោង*




នេះជាកាយវិការមួយបង្ហាញថា យើងកំពុងតែធុញដល់កំពូល។ នៅក្នុងពេលនិយាយជាមួយនរណាម្នាក់ ហើយយើងតែងតែលួចមើលនាឡិកាដៃ ឬទូរស័ព្ទដៃដើម្បីមើលម៉ោងនោះ គេនឹងគិតថា យើងកំពុងទន្ទឹងរង់ចាំពេលវេលានឹងចាកចេញកាន់តែឆាប់កាន់តែល្អ។

### ៧.៣ សីលធម៌ក្នុងការប្រើពាក្យសំដី

ការប្រើពាក្យសំដី អ្នកគួរតែចងប្រយ័ត្ន ព្រោះក្នុងសុភាសិតខ្មែរតែងពោលថា អណ្តាតជាអាតកន្លង បានសុខទុក្ខក៏ព្រោះតែអណ្តាត។ អណ្តាតនៅក្នុងន័យនេះ គឺសំដៅដល់ការប្រើពាក្យសំដី និយាយទៅកាន់នរណាម្នាក់ គួរត្រូវបានពិចារណាជាមុន។ ប្រសិនបើពាក្យសំដីដែលយើងប្រើទៅហើយមានសីលធម៌ល្អគឺយើងនឹងបានសុខ តែផ្ទុយទៅវិញបើពាក្យសំដីណាដែលយើងនិយាយហើយត្រូវបានគេចាត់ទុក្ខថាជា អសីលធម៌នោះយើងនឹងមានទុក្ខទោសនៅថ្ងៃណាមួយជាក់ជាមិនខាន។ ក្នុងធម៌អប់រំរបស់ព្រះពុទ្ធសាសនាក៏បានទូន្មានយើង ទ្រង់បញ្ញត្តអំពីវិធីទុច្ចរិតមាន៤យ៉ាងគឺ៖

- វៀរចាកពាក្យសំដីកុហកបោកបញ្ឆោត។
- វៀរចាកពាក្យសំដីញុះញង់ អុជអាលអ្នកដទៃ។
- វៀរចាកពាក្យសំដីទ្រគោះបោះបោក ។
- និងវៀរចាកពាក្យសំដីឥតប្រយោជន៍(ឡេះឡោះគ្មានន័យ) ។

## ៨. ការរៀបចំខ្លួននៅក្នុងកន្លែងការងារ

ការរៀបចំខ្លួន ត្រូវអនុលោមទៅតាមកាលៈទេសៈ និងស្ថានភាពដែលយើងត្រូវចូលរួម ឬទៅតាមការកំណត់របស់អង្គភាព ឬស្ថាប័នដែលយើងត្រូវធ្វើការ។ ការរៀបចំខ្លួនត្រូវបានបែងចែកជា២គឺ ការរៀបចំខាងក្រៅខ្លួន និងការរៀបចំខាងក្នុងខ្លួន។

### ៨.១ ការរៀបចំខាងក្រៅខ្លួន

ការរៀបចំខាងក្រៅខ្លួនគឺសំដៅដល់សម្ភារប្រើប្រាស់សម្រាប់បិទបាំងកាយ និងតុបតែងលម្អរូបរាងកាយរបស់យើង។ សម្ភារទាំងអស់នោះរួមមាន៖

- *ការស្លៀកសម្លៀកបំពាក់៖*



ការជ្រើសរើសសម្លៀកបំពាក់ និងពណ៌របស់សម្លៀកបំពាក់ ត្រូវជ្រើសរើសទៅតាមកាលៈទេសៈនៃការងារ(កម្មករ វិស្វករ ពេទ្យ គ្រូបង្រៀន សន្តិសុខ) កម្មវិធីផ្សេងៗ(មង្គលការ បុណ្យសព ប្រជុំ) ឬដំណើរកំសាន្ត។

❖ *ការជ្រើសរើសស្បែកជើង៖*

ស្បែកជើងក៏ស្ថិតនៅក្នុងប្រភេទនៃសម្លៀកបំពាក់ដែរ។ យ៉ាងណាមិញ មនុស្សជាច្រើនបានកំពុងប្រើប្រាស់ស្បែកជើងខុសទម្រង់ក្នុងការប្រកបការងារ។ ការប្រើប្រាស់ខុសស្ថានភាពនេះហើយ អាចបណ្តាលឱ្យតម្លៃខ្លួនយើងធ្លាក់ចុះឬបង្កជាបញ្ហាគ្រោះថ្នាក់(ជាក់ស្តែងដូចជាការប្រើប្រាស់ស្បែកជើងក្នុងវិស័យសំណង់)។

ប្រសិនបើយើងសម្លឹង ទៅរកមើលស្បែកជើង នោះយើងនឹងឃើញស្បែកជើងមានច្រើនប្រភេទនិងខុសៗគ្នា។ យ៉ាងណាមិញតើយើងគួរជ្រើសរើសស្បែកជើងប្រភេទណា ឱ្យសក្តិសមទៅនឹងប្រភេទការងាររបស់យើង?



❖ *ការតុបតែងខ្លួន៖*

ការតុបតែងខ្លួន គឺជារឿងសំខាន់ណាស់សម្រាប់មនុស្សគ្រប់គ្នាៗ។ សម្ភារតុបតែងខ្លួនមានដូចជាគ្រឿងសម្អាងផ្សេងៗ គ្រឿងអលង្ការ ក្រចក សក់ជាដើម។តើយើង គួរតុបតែងខ្លួនយ៉ាងដូចម្តេចដើម្បីឱ្យត្រូវទៅតាមកម្មវិធីដែលអ្នកចូលរួម?



## ៨.២ ការរៀបចំខាងក្នុងខ្លួន

❖ *ភាពស្មោះត្រង់៖*

ភាពស្មោះត្រង់ គឺជាគុណតម្លៃនៃជីវិតរបស់មនុស្ស ហើយធ្វើឱ្យអ្នកដទៃគោរព និងផ្តល់តម្លៃឱ្យ។ មនុស្សយើងឱ្យតែមានភាពស្មោះត្រង់នៅក្នុងខ្លួនជានិច្ច អ្នកដទៃនឹងគោរព ឱ្យតម្លៃ និងស្មោះត្រង់ចំពោះយើងវិញជាក់ជាមិនខាន។ មិនថានៅកាលៈទេសៈ ឬពេលណាៗក៏ដោយ ភាពស្មោះត្រង់នៅតែមានតម្លៃសម្រាប់ជីវិតយើងគ្រប់គ្នា។ មនុស្សមានលុយ អំណាចយសស័ក្តិ គឺអាចធ្វើឱ្យអ្នកដទៃគេគោរពកោតខ្លាចតែនៅនឹងមុខតែប៉ុណ្ណោះ ប៉ុន្តែបើមានភាពស្មោះត្រង់ចំពោះចំពោះអ្នកដទៃវិញ គឺធ្វើឱ្យគេចងចាំជារៀងរហូត។ ហេតុនេះ មនុស្សត្រូវប្រកាន់ភ្ជាប់នូវភាពស្មោះត្រង់ដើម្បីសេចក្តីថ្លៃថ្នូរ គុណធម៌ និងដើម្បីកិត្តិយសខ្លួនយើង។

❖ ***ការតាំងចិត្ត និងទំនួលខុសត្រូវ*** ៖មនុស្សម្នាក់ៗត្រូវតែតាំងចិត្តឱ្យមុះមុតនិងតាំងចិត្តធ្វើកិច្ច






ការឱ្យបានសម្រេច មិនត្រូវរារែកនឹងការលំបាក ឬឧបសគ្គ ធ្វើការដោយយកចិត្តទុកដាក់ ហើយមានសេចក្តីព្យាយាមផងដែរ។ **ទំនួលខុសត្រូវ** គឺជាកាតព្វកិច្ចដែលត្រូវជានារ៉ាប់រងរាល់អំពើទាំងឡាយដែលខ្លួនបានធ្វើ ដោយហ៊ានទទួលសារភាព និងទទួលនូវផលវិបាកនៅចំពោះមុខខ្លួនឯង និងចំពោះមុខច្បាប់សង្គមផង។ ទំនួលខុសត្រូវចែកចេញជាពីរប្រភេទ គឺទំនួលខុសត្រូវផ្នែកសីលធម៌ និងទំនួលខុសត្រូវផ្នែកសង្គម។ ទំនួលខុសត្រូវផ្នែកសីលធម៌ គឺជាទំនួលខុសត្រូវដែលអ្នកប្រព្រឹត្តហ៊ានទទួលសារភាព ដោយស្មោះត្រង់ដោយពុំមានការបង្ខិតបង្ខំ ហើយក៏ជាការទទួលខុសត្រូវផ្ទាល់នៅចំពោះមុខខ្លួនឯង នូវរាល់ទង្វើដែលខ្លួនបានធ្វើដោយគ្មានវិប្បដិសារី។ ទំនួលខុសត្រូវសង្គម គឺជាទំនួលខុសត្រូវ ដែលអ្នកប្រព្រឹត្តហ៊ានសារភាពទោសកំហុសរបស់ខ្លួននៅចំពោះមុខច្បាប់សង្គម ។

## ៩.សេចក្តីសន្និដ្ឋាន

ចរណៈវិជ្ជា ឬក្រមសីលធម៌វិជ្ជាជីវៈពិតជាមានតម្លៃខ្លាំងណាស់សម្រាប់មនុស្សគ្រប់គ្នានៅក្នុងសង្គមបច្ចុប្បន្ន។ ជាការពិតការលើកកម្ពស់តម្លៃសីលធម៌សង្គម គឺជាការងារដ៏ចាំបាច់មួយ ដែលគេមិនអាចមើលរំលងបានទេ នៅក្នុងស្ថានភាពសង្គមកម្ពុជាសព្វថ្ងៃនេះ។ យ៉ាងណាក៏ដោយ ការស្រោចស្រង់សីលធម៌សង្គមដែលកំពុងធ្លាក់ចុះ មិនមែនជារឿងងាយស្រួលនោះឡើយ ព្រោះថា សង្គមដែលមានក្រមសីលធម៌ គឺត្រូវការពលរដ្ឋដែលមានសីលធម៌។ ដូច្នេះ តម្លៃរបស់មនុស្សគឺអាស្រ័យទៅលើការរស់នៅប្រកបដោយក្រមសីលធម៌ មានវិន័យសណ្តាប់ធ្នាប់ និងនាំគ្នាគោរពច្បាប់ នោះសង្គមកម្ពុជាយើងនឹងបានល្អប្រសើរឡើង។ យើងត្រូវចងចាំថា ដើម្បីបានសង្គមមួយដ៏ល្អគេចាំបាច់ត្រូវការពេលវេលា និងការចូលរួមពីគ្រប់បុគ្គលទាំងអស់ ហើយនាំគ្នាបណ្តុះការយល់ដឹងផ្នែកសីលធម៌សង្គមឡើងវិញ។

## លំហាត់អនុវត្ត និងពិភាក្សា

១. តើទង្វើឬសកម្មភាពបែបណាដែលអ្នកគិតថាត្រូវ ឬខុសនៃក្រមសីលធម៌?

២.ហេតុអ្វីត្រូវខ្វល់ខ្វាយជាមួយនឹងក្រមសីលធម៌?

៣. តើអ្នកធ្លាប់ជួបប្រទះនឹងជម្លោះដែលបណ្តាលមកពីខ្វះក្រមសីលធម៌ដែរឬទេ? ចូររៀបរាប់ពីស្ថានភាពនៃជម្លោះនោះ? ហើយគេដោះស្រាយយ៉ាងដូចម្តេច?

៤. ចូរបង្កើតក្រុមពិភាក្សាមួយដោយស្វែងរកផលប៉ះពាល់ដែលបណ្តាលមកពីអំពើអសីលធម៌ក្នុងសង្គម?

៥. តើយើងគួររៀបចំឥរិយាបថ ឬអាកប្បកិរិយាបែបណាដើម្បីចាត់ទុកថាមានសីលធម៌ល្អ?

៦. តើអ្នកត្រូវរៀបចំខ្លួនបែបណាខ្លះ ដែលចាត់ទុកថាជាមនុស្សតម្លៃនៃគ្មានសីលធម៌?

៧.តើក្រមសីលធម៌អាចឱ្យយើងរកប្រាក់បានដោយរបៀបណា?



### មេរៀនទី ៨

# ការប្រតិបត្តិការបណ្តុះបណ្តាលបៃតងក្នុងគ្រឹះស្ថាន អ.ប.វ.

## ១.លក្ខណៈទូទៅនៃបរិស្ថាន

### ១.១ សេចក្តីផ្តើម

តើបរិស្ថានមានន័យថាយ៉ាងដូចម្តេច?

បរិស្ថានមានន័យថាអ្វីៗ ដែលនៅជុំវិញខ្លួនយើង និងខ្លួនយើងផង ដែលរាប់ទាំងភាវៈមានជីវិត និងភាវៈគ្មានជីវិតទាំងអស់នៅលើផែនដី មានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក ហើយអាចជះ និងទទួលឥទ្ធិពលពីគ្នាទៅវិញទៅមកដោយផ្ទាល់ និងដោយប្រយោល។

ទោះបីយើងដឹងថាភាវៈមានជីវិតមានទំនាក់ទំនងទៅនឹងបរិស្ថានក៏ដោយ ក៏យើងមិនទាន់យល់អំពីទំនាក់ទំនងនេះច្បាស់លាស់នៅឡើយដែរ។ ដូចនេះប្រសិនបើមនុស្សផ្លាស់ប្តូរបរិស្ថានលឿនពេក ហើយប្រើប្រាស់ធនធានធម្មជាតិច្រើនពេកនោះ យើងអាចសន្និដ្ឋានបានថា ផលប៉ះពាល់នឹងកើតមានឡើងចំពោះភាវៈមានជីវិត និងភាវៈគ្មានជីវិត ។

ឧទាហរណ៍៖ ផលិតផលត្រីនៅបឹងទន្លេសាបមានទំនាក់ទំនងទៅនឹងព្រៃលិចទឹក ប្រសិនបើព្រៃលិចទឹកត្រូវបានបំផ្លាញ យើងមិនអាចដឹងបានទេថាភាវៈមានជីវិត និងភាវៈគ្មានជីវិតត្រូវរងនូវផលប៉ះពាល់ដូចម្តេចខ្លះ? ដើម្បីយល់ដឹងអំពីបរិស្ថានឱ្យបានកាន់តែច្បាស់ថែមទៀត យើងអាចសិក្សាអំពីបរិស្ថានធម្មជាតិ និងបរិស្ថានសង្គម។



រូបភាព

## ១.២. និយមន័យ

គេធ្វើការបែងចែកបរិស្ថានជាពីរគឺៈ បរិស្ថានធម្មជាតិ និងបរិស្ថានសង្គម។

**បរិស្ថានធម្មជាតិ** សំដៅដល់អ្វីៗដែលមាននៅលើភពផែនដីដែលមិនបង្កើតឡើងដោយមនុស្ស។ ក្នុងនោះរួមមានភាវៈមានជីវិតទាំងអស់ដូចជារុក្ខជាតិ សត្វ និងភាវៈឥតជីវិត ដែលភាវៈមានជីវិតពឹងផ្អែកទៅលើទឹក ដី ភ្លើង និងខ្យល់។ ឧទាហរណ៍ៈ រុក្ខជាតិពឹងផ្អែកទៅលើទឹក និងដី ។

**បរិស្ថានសង្គម** សំដៅដល់បរិស្ថានដែលបង្កើតឡើងដោយមនុស្ស រួមមានអ្វីៗទាំងអស់ដែលមនុស្សកែច្នៃ ឬផលិតឡើងដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួនដូចជា ចំណីអាហារ ជម្រក និងសម្លៀកបំពាក់។ លើសពីនេះ នៅមានភាវៈដទៃទៀតដែលមនុស្សបង្កើតឡើងដូចជា សាលារៀន មន្ទីរពេទ្យ វត្តអារាម ស្ពាន ថ្នល់ និងវត្ថុផ្សេងៗទៀតជាច្រើន ។




រូបភាពៈ ជ្រុងមួយនៃបរិស្ថានធម្មជាតិ



រូបភាពៈ ជ្រុងមួយនៃបរិស្ថានសង្គម

- **លក្ខណៈ និងប្រភេទនៃប្រព័ន្ធអេកូឡូស៊ី**

**ប្រព័ន្ធអេកូឡូស៊ី** ជាប្រព័ន្ធជីវសាស្រ្តដែលបង្កើតឡើងដោយអន្តរអំពើរវាងភាវៈមានជីវិត (រុក្ខជាតិ សត្វ មនុស្ស) និងភាវៈគ្មានជីវិត (ទឹក ដី ខ្យល់ និងពន្លឺព្រះអាទិត្យ)។ អេកូឡូស៊ីប្រភេទនីមួយៗមានលក្ខណៈពិសេស និងខុសៗគ្នា។ ប្រព័ន្ធអេកូឡូស៊ីទាំងអស់នៅតែសកម្ម និង "មានសុខភាពល្អ" ដរាបណាតុល្យភាពអេកូឡូស៊ីត្រូវបានរក្សា។



រូបភាពៈ ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ



រូបភាពៈប្រព័ន្ធអេកូឡូស៊ីសិប្បនិម្មិត

ប្រព័ន្ធអេកូឡូស៊ីសិប្បនិម្មិត គឺជាអ្វីដែលត្រូវបានបង្កើតឡើងពីសកម្មភាពរបស់មនុស្ស។

## ២. បរិស្ថាន និងការរស់នៅ

### ២.១. សេចក្តីផ្តើម

បរិស្ថានគឺជាអ្វីៗទាំងឡាយដែលនៅជុំវិញយើង ហើយវាមានឥទ្ធិពលដល់យើងវិញដោយរួមមានទាំងអ្វីដែលបានមកពីធម្មជាតិ និងមិនធម្មជាតិ។ បើយើងនិយាយពីការរស់នៅ សំដៅដល់សកម្មភាពមនុស្ស សត្វ និងរុក្ខជាតិ ដែលមានវត្តមាន មានជីវិតនៅលើភពផែនដីរបស់យើង។



រូបភាព៖ ទិដ្ឋភាពនៃការរស់នៅ(ក្នុងស្ថានភាពពីរផ្សេងគ្នាក្នុងរូបភាព)

### ២.២. បរិស្ថាន

(បរិស្ថានវិទ្យា) environment មជ្ឈដ្ឋានជុំវិញទាំងអស់ (សំណុំរូបសាស្ត្រ សំណុំគីមី សំណុំជីវសាស្ត្រ) ដែលមានឥទ្ធិពលទៅលើជីវិត និងការលូតលាស់របស់មនុស្ស សត្វ និងរុក្ខជាតិ។
ឧទាហរណ៍៖ ការការពារបរិស្ថានជាភារកិច្ចរបស់មនុស្សយើងទាំងអស់គ្នានៅលើផែនដី។

បរិស្ថានស្អាតដោយសារមនុស្ស រីឯបរិស្ថានមិនស្អាត(អាក្រក់) ក៏ដោយសារមនុស្ស។ ដូច្នេះមនុស្សចាំបាច់ត្រូវតែដើរតួជាអ្នកអភិវឌ្ឍផង និងជាអ្នកអភិរក្សផង មិនអាចជ្រើសរើសយកតែមួយបានទេ។ ពីព្រោះផែនដី ឬហៅថាសង្គមមនុស្ស មានតម្រូវការជារៀងរាល់ពេល និងនៅគ្រប់ទីកន្លែងទាំងអស់ មិនថានៅលើដី ក្នុងទឹក និងលើអាកាសឡើយ។ បរិស្ថានសង្គម មានឥទ្ធិពលខ្លាំងណាស់សម្រាប់ភពផែនដីរបស់យើង។ មនុស្សបានបង្កើតវត្ថុធាតុជាច្រើនសម្រាប់ផែនដី ប៉ុន្តែក្នុងដំណើរការអនុវត្តធ្វើឱ្យកកើតជាផលអវិជ្ជមានជាច្រើនឥតគណនាតែមនុស្សជាភាវៈមួយឆ្លាតបំផុតចេះកែច្នៃ និងទប់ទល់នូវអ្វីដែលជាផលមិនល្អឱ្យប្រែក្លាយជាប្រយោជន៍បម្រើដល់មនុស្សវិញ ទោះបីមិនបាន១០០ភាគរយក៏ដោយ។

## ២.៣. ការរស់នៅក្នុងបរិស្ថាន

មនុស្ស សត្វ និងរុក្ខជាតិ ជាភាវៈមានជីវិតពឹងអាស្រ័យទាំងស្រុងទៅនឹងភាវៈឥតជីវិត( ទឹក ដី ភ្លើង និង ខ្យល់) ក្នុងការទ្រទ្រង់ជីវិតរស់នៅឱ្យប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ ទៅតាមវដ្តជីវិត និងការងារ។




រូបភាព

មនុស្សរស់នៅក្នុងបរិបទមួយ ប្រកបដោយភាពសម្បូរបែបណាស់ ធ្វើអ្វីៗតែងតែមានការគិតពិចារណា ស្វែងរកហេតុ និងផលមុននឹងសម្រេច។ មនុស្សមានសភាពដូចសត្វ ប៉ុន្តែសត្វមិនមានសភាពដូចមនុស្សនោះឡើយ។ មនុស្សចេះរៀបចំទីកន្លែងរស់នៅប្រកបដោយបរិយាកាសស្អាត ស្រស់ថ្លា ជាពិសេសប្រើប្រាស់សម្ភារ ឧបករណ៍ និងបរិក្ខារដែលបានមកពីបរិស្ថានសង្គមជាច្រើនរបស់ខ្លួន។

ការរស់នៅរបស់មនុស្ស យើងសង្កេតឃើញថា មនុស្សចេះសម្រិតសម្រាំង សណ្ដាប់ធ្នាប់ និងស្អាតបាត ស្ដង់ដា និងស្ថិតស្ថេរ។ ពិសេសគឺយកចិត្តទុកដាក់បំផុតលើបញ្ហាសុខភាព និងថែទាំសុខភាពរបស់ខ្លួន។



រូបភាព



រូបភាព

### ៣. ការអភិវឌ្ឍបៃតង

#### ៣.១. សេចក្តីផ្តើម

តើពាក្យ Green Growth នេះមានអត្ថន័យយ៉ាងណា?

Green Growth នៅក្នុងន័យកម្ពុជារបស់យើងដែលបកប្រែគឺមានន័យថា ការអភិវឌ្ឍបៃតង។

ហេតុអ្វីបានជាគេត្រូវចាំបាច់ត្រូវការការអភិវឌ្ឍបៃតង?

ន័យសំខាន់បំផុតគឺយើងចង់ជំរុញការអភិវឌ្ឍមួយដែលមាននិរន្តរភាព ហើយឱ្យវាមានសមភាពទៅតាមរយៈការប្រើប្រាស់ធនធានធម្មជាតិ ឬក៏សកម្មភាពអភិវឌ្ឍទាំងឡាយណាដែលយើងបានគិតគូរទៅដល់បរិស្ថានដូចជា ទាក់ទងជាមួយនឹងខ្យល់ នៅពេលដែលយើងអភិវឌ្ឍទៅធ្វើឱ្យមាននិរន្តរភាព កុំឱ្យមានការបំពុលខ្យល់។

ឧទាហរណ៍៖ នៅពេលដែលយើងអភិវឌ្ឍខ្លាំងបែរជាមានការបំពុលខ្លាំងធ្វើឱ្យយើងរស់នៅមិនកើត ឬក៏ប្រភពទឹកមានការបំពុលនៅតាមដងទន្លេ នៅពេលដែលយើងបានអភិវឌ្ឍមិនបានគិតនឹងមានការបំពុលទឹកខ្លាំង ទឹកទន្លេខូចអស់ ត្រីក៏ងាប់អស់ ឬក៏មានសំរាមពាសពេញ វានឹងធ្វើឱ្យទីក្រុងមួយ ឬក៏តំបន់មួយមិនអាចរស់នៅបាន ដូច្នេះនៅពេលដែលមានការអភិវឌ្ឍបែបនេះ បើយើងមិនបានគិតគូរវែងឆ្ងាយនោះទេ គឺវាមានផលប៉ះពាល់ដល់បរិស្ថាន។

Green Growth គឺជាការអភិវឌ្ឍមួយដែលគិតគូរដល់បរិស្ថាន និរន្តរភាព សមភាពសេដ្ឋកិច្ច មានន័យថា ប្រជាជនទាំងអស់ដែលរស់នៅក្នុងទីក្រុង ឬនៅក្នុងប្រទេសទាំងមូលនឹងទទួលបាននូវផលប្រយោជន៍ចេញពីការអភិវឌ្ឍមួយ។



រូបភាព៖

**៣.២. ការអភិវឌ្ឍបៃតង**

ទាក់ទងនឹងគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលរបស់យើងតែម្តង យើងគិតមើលទៅការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលបានបន្តរយៈពេលជាងមួយទសវត្សរ៍មកហើយ គិតចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ២០០០។ កាលនោះយើងចាប់ផ្តើមពិភាក្សាគ្នាទាក់ទងនឹងការអភិវឌ្ឍបៃតង ហើយយើងមានការចូលរួមយ៉ាងសកម្មពីវិទ្យាស្ថានអភិវឌ្ឍបៃតងសកល(Global Green Growth Institute) ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាដៃគូអភិវឌ្ឍផ្សេងៗបានជួយដល់ក្រសួងបរិស្ថាន ដែលបច្ចុប្បន្នមានក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព គឺបានធ្វើការងារដើម្បីជំរុញការអភិវឌ្ឍបៃតង។ នៅក្រោមអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍដោយចីរភាព មាននាយកដ្ឋានមួយហៅថា នាយកដ្ឋានសេដ្ឋកិច្ចបៃតង ដែលបានធ្វើការច្រើននៅពេលកន្លងមករួមមានផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍបៃតងពីឆ្នាំ ២០១៣ ដល់ឆ្នាំ២០៣០ និងមានផែនទីបង្ហាញផ្លូវផងដែរ។ ផែនការទាំងអស់មានភាពបន្សីុគ្នាជាមួយនឹងផែនការយុទ្ធសាស្ត្ររយៈពេលវែងទៅលើការបញ្ចេញ**ឧស្ម័នផ្ទះកញ្ចក់** ដោយកំណត់ឱ្យវាមានកម្រិតសូន្យមានន័យថានៅឆ្នាំ២០៥០ គឺប្រទេសកម្ពុជាយើងមានការបំភាយឧស្ម័នផ្ទះកញ្ចក់ឱ្យបានតិចបំផុត។ ការចូលរួមគិតគូរអំពីគុណភាពខ្យល់ដូចជាការកាត់បន្ថយការបំភាយ**ឧស្ម័នផ្ទះកញ្ចក់** គឺជាការចូលរួមចំណែកមួយក្នុងការកាត់បន្ថយការកើនឡើងនៃកម្តៅផែនដី។






រូបភាព

គោលនយោបាយនៃការអភិវឌ្ឍបៃតងគឺជាគោលនយោបាយធំមានលក្ខណៈជាអន្តរវិស័យ។ វាមានទំនាក់ទំនងទៅនឹងវិស័យផ្សេងៗដូចជា វិស័យព្រៃឈើ វិស័យថាមពល វិស័យដឹកជញ្ជូន និងវិស័យសំណង់ជាដើម។

ទំនាក់ទំនងអន្តរវិស័យ៖ យើងអាចនិយាយបានថា វិស័យថាមពល វិស័យដឹកជញ្ជូន ឬការគ្រប់គ្រងកាកសំណល់ ទាំងកាកសំណល់រឹង និងកាកសំណល់រាវ ឬក៏ការបង្កើននូវផលិតកម្មនៅក្នុងវិស័យឧស្សាហកម្មជាដើម នេះសុទ្ធតែជាវិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍ។ ឧទាហរណ៍៖ ឧស្សាហកម្មកាត់ដេរត្រូវការប្រើប្រាស់ថាមពល។ តាមការស្រាវជ្រាវ ការប្រើប្រាស់ថាមពលបច្ចុប្បន្នគឺមានលទ្ធភាពសន្សំសំចៃរហូតដល់ទៅ ៣០% ដោយគ្រាន់តែយើងក៏ត្រូវមានការវិនិយោគទៅលើការប្រើប្រាស់បច្ចេកវិទ្យាសន្សំសំចៃថាមពល ឬការប្រើប្រាស់ថាមពលស្អាតដូចជា ផ្ទាំងសូឡាដែលប្រើថាមពលពីពន្លឺព្រះអាទិត្យ។ល។



រូបភាព៖ ថាមពលពន្លឺព្រះអាទិត្យ

កាកសំណល់រឹង៖ នៅពេលដែលយើងមិនបានបែងចែកសំរាមឱ្យបានល្អ (សំរាមទាំងអស់ដាក់ក្នុងធុងតែមួយ) យើងឃើញថាមានសំរាមច្រើនណាស់។ ប្រសិនបើសំរាមត្រូវបានបែងចែកត្រឹមត្រូវ ទៅជាសំរាមដែលអាចប្រើប្រាស់ឡើងវិញបាន សំរាមដែលអាចធ្វើជាជីកំប៉ុស និងសំរាមដែលត្រូវចោលទាំងក្នុងរោងចក្រ និងនៅតាមផ្ទះនីមួយៗ នោះសំរាមនឹងមានបរិមាណតិច។ មួយទៀតគេអាចប្រើប្រាស់បច្ចេកវិទ្យានៅក្នុងការដុតសំរាម ហើយបម្លែងឱ្យទៅជាថាមពលសម្រាប់ការប្រើប្រាស់។ ធ្វើបែបនេះនឹងផ្តល់ផលចំណេញយ៉ាងច្រើនដូចជា ១). បរិមាណសំរាមមានកាន់តែតិច ២). កាត់បន្ថយបន្ទុកនៃទីធ្លាចាក់សំរាម ៣). កាត់បន្ថយសារធាតុពុល ឬកង្វក់ដែលកើតចេញពីសំរាម ដែលអាចផ្តល់ផលប៉ះពាល់ដល់ មនុស្ស សត្វ និងរុក្ខជាតិ និង ៣). ចំណេញថាមពលសម្រាប់ការប្រើប្រាស់។ល។

ការអភិរក្សព្រៃឈើ និងការដាំដុះដើមឈើឡើងវិញ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពផ្សេងទៀតដែលរួមចំណែកដល់ការអភិវឌ្ឍបៃតង។ តាមការស្រាវជ្រាវរបស់**វិទ្យាស្ថានអភិវឌ្ឍបៃតងសកល** បង្ហាញថា បើយើងអនុវត្តទៅតាមវិធីសាស្ត្រក្នុងការអភិវឌ្ឍបៃតងគិតទៅដល់ឆ្នាំ២០៣០ ប្រទេសកម្ពុជាអាចនឹងផ្តល់ការងារដល់ទៅ៥០ម៉ឺននាក់។ ដំណាក់កាលដំបូងការវិនិយោគត្រូវការចំណាយច្រើន ប៉ុន្តែនឹងផ្តល់ផលចំណេញច្រើនក្នុងរយៈពេលយូរក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។

ចំពោះការអភិវឌ្ឍបៃតងនៅក្នុងប្រទេសកម្ពុជា មានភាពល្អប្រសើរពីមួយដំណាក់កាលទៅមួយដំណាក់កាល បើធៀបទៅនឹងប្រទេសក្នុងតំបន់អាស៊ី ដោយគិតអំពីមូលដ្ឋានគោលនយោបាយទាក់ទងជាមួយនឹងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ គឺរាជរដ្ឋាភិបាលមានផែនការជាច្រើនមានការសិក្សាស្រាវជ្រាវ។ ជាងនេះទៅទៀតកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍអាចរៀនសូត្របានពីបទពិសោធន៍របស់ប្រទេសផ្សេងៗទាក់ទងនឹងការអភិវឌ្ឍបៃតងដើម្បីយកមកអនុវត្តនៅក្នុងប្រទេស។ ជាក់ស្តែងខេត្តក្រុងព្រះសីហនុទទួលបានពានអាស៊ានទាក់ទងនឹងការអភិវឌ្ឍដោយចីរភាព។ រាជរដ្ឋាភិបាលកម្ពុជាព្យាយាមតម្រង់ទិស គោលនយោបាយ ស្ថាប័ន និងអ្នកពាក់ព័ន្ធដើម្បីតម្រង់ឆ្ពោះទៅរកការអភិវឌ្ឍបៃតង ទោះបីជាការអភិវឌ្ឍនេះជួបប្រទះនឹងបញ្ហាប្រឈមផ្នែកធនធានហិរញ្ញវត្ថុ បច្ចេកវិទ្យា ទស្សនៈ និងឥរិយាបថរបស់សាធារណជនក៏ដោយ។

ទោះបីជាការគ្រប់គ្រងសំរាម ការប្រើប្រាស់ធនធាន ការប្រើប្រាស់ថាមពលអគ្គិសនី ការអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះនៅមានកម្រិតក៏ដោយ ប៉ុន្តែយើងសង្កេតឃើញថា ពីមួយថ្ងៃទៅមួយថ្ងៃ មនុស្សមានការ

ប្រែប្រួលឥរិយាបថឆ្ពោះទៅរកការអភិវឌ្ឍបៃតង ដែលគិតគូរអំពីបរិស្ថាន អំពីនិរន្តរភាព វិសមភាពនៅក្នុងសង្គមផងដែរ។

ប្រទេសជាច្រើននៅទ្វីបអឺរ៉ុប និងអាស៊ី ដូចជា ជប៉ុន កូរ៉េ ជាប្រទេសដែលមានការគ្រប់គ្រងសំរាមបានល្អ។ ពេលខ្លះគេសឹងតែរកសំរាមយកទៅដុតក្នុងឡឧស្ម័នមិនបានផង ដោយសារតែការគ្រប់គ្រង និងការបែងចែកសំរាមក្នុងប្រទេសទាំងនេះបានល្អ។ ការគ្រប់គ្រងសំរាមបានល្អដោយសារមានការចូលរួមយ៉ាងសកម្មពី




ប្រជាពលរដ្ឋ ពីសាធារណជន កម្រិតចំណេះដឹងរបស់ប្រជាពលរដ្ឋ និងការអនុវត្តច្បាប់ទាក់ទងជាមួយនឹងការគ្រប់គ្រងសំរាម។ ថាមពលបានមកពីប្រភពថាមពលស្អាតផ្សេងៗដូចជា ថាមពលបង្កើតដោយខ្យល់ ថាមពលដែលបង្កើតពន្លឺព្រះអាទិត្យ (សូឡា) ត្រូវបានប្រើប្រាស់ក្នុងអគារ។ ដូច្នេះការប្រើប្រាស់ថាមពលពីហ្វូស៊ីលមានតិចតួចបំផុត។ នេះជាបទពិសោធន៍ល្អមួយសម្រាប់ប្រទេសកម្ពុជាអាចរៀនបាន។ ដៃគូអភិវឌ្ឍជាច្រើនបានចូលរួមចំណែកជួយដូចជា កម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ (UNDP) គម្រោងវិទ្យាស្ថានអភិវឌ្ឍបៃតងសាកល និងដៃគូអភិវឌ្ឍផ្សេងៗទៀត។ វិស័យឯកជនក៏បានចូលរួមយ៉ាងសកម្មផងដែរ ក្នុងការផ្តល់នូវបច្ចេកវិទ្យាថ្មីៗសម្រាប់ការអភិវឌ្ឍ។

គម្រោងទីក្រុងស្អាតត្រូវបានអនុវត្តសាកល្បងនៅក្នុងខេត្តបាត់ដំបង សៀមរាប ទីក្រុងភ្នំពេញ ហើយថ្មីៗនេះក្រសួងបរិស្ថានបានសហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថាប័នពាក់ព័ន្ធជំរុញការប្រើប្រាស់យានយន្តអគ្គិសនី ដើម្បីចូលរួមកាត់បន្ថយការបំភាយឧស្ម័នដែលប៉ះពាល់ដល់បរិស្ថាន។ រាជរដ្ឋាភិបាលបានជំរុញសកម្មភាពជាច្រើនទាក់ទងជាមួយនឹងការគ្រប់គ្រងព្រៃឈើ។ នៅក្នុងឯកសារយុទ្ធសាស្ត្រថ្មីនេះៗ ដើម្បីសម្រេចបាននូវកម្រិតអព្យាក្រឹតកាបូន រាជរដ្ឋាភិបាលកំណត់យកវិស័យព្រៃឈើជាវិស័យអាទិភាពសម្រាប់ផែនការរយៈពេលវែង។ រាជរដ្ឋាភិបាលបានបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ ដៃគូអភិវឌ្ឍ និងសាធារណជនបានចូលរួមចំណែកសកម្មភាពក្នុងការអភិវឌ្ឍបៃតង។ ការលក់កាបូនរបស់ប្រទេសកម្ពុជាកាន់ទៅទីផ្សារអន្តរជាតិ

គឺជា សញ្ញាបង្ហាញពីភាពវិជ្ជមានមួយតបស្នងទៅនឹងការខិតខំប្រឹងប្រែងអភិរក្សធនធានព្រៃឈើរបស់ប្រទេសកម្ពុជាពីសំណាក់ប្រទេសអភិវឌ្ឍដែលជាអ្នកបំភាយឧស្ម័នផ្ទះកញ្ចក់ច្រើនទៅក្នុងបរិយាកាស។

### ៣.៣. គន្លងដែលទទួលខុសត្រូវចំពោះការបំពុលបរិស្ថាន

#### ៣.៣.១. សេចក្ដីផ្ដើម

សកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច បានបង្កើតជាផលវិបាកផ្នែកបរិស្ថានសំខាន់ៗ រួមទាំងការបំពុលខ្យល់ ការបំពុលទឹក ការបំពុលសំឡេង និងបញ្ហាសំណល់រឹង។ឧស្សាហកម្ម គឺជាវិស័យមួយដ៏សំខាន់ក្នុងចំណោមវិស័យផ្សេងៗទៀតចំពោះសេដ្ឋកិច្ចកម្ពុជា។



ការបំពុលខ្យ ... តុពុល គំរាមកំហែងដល់ជីវិតមនុស្ស។ ... ាត់ថ្នាក់ទី១៦២ លើ ១៧៨ ប្រទេស ផ្អែកលើគុណភាពខ្យល់នៅក្នុងឆ្នាំ២០១៤។

ការបំពុលទឹក ធ្វើឱ្យមានការប៉ះពាល់ដោយផ្ទាល់ដល់បរិស្ថាន ហើយវាក៏ប៉ះពាល់ទាំងដោយផ្ទាល់ និងដោយប្រយោលដល់មនុស្ស និងសត្វផងដែរ។ ការប្រើប្រាស់ទឹកស្អាត និងប្រកបដោយនិរន្តរភាពនៅតែជាបញ្ហាប្រឈមមួយ ជាពិសេសគ្រួសារនៅតាមជនបទ។ កត់សម្គាល់ផងដែរថា ទឹកទន្លេដែលរងការបំពុលនៅតែជាប្រភពទឹកសំខាន់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជនដោយហេតុថា ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារទឹកនៅមានកម្រិតនៅឡើយ។ ទឹកកខ្វក់ ឬរងការបំពុលជាលទ្ធផលបណ្ដាលមកពី ឧស្សាហកម្មរ៉ែ និងសកម្មភាពឧស្សាហកម្មផ្សេងៗទៀត ដែលនាំឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស។

នៅក្នុងប្រទេសកម្ពុជាក៏ដូចជាប្រទេសកំពុងអភិវឌ្ឍដទៃទៀត បញ្ហាបរិស្ថានចម្បងមួយទៀតនោះគឺការចោល និងការគ្រប់គ្រងសំណល់រឹង។ ការបញ្ចេញសំណល់មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងកំណើនប្រជាជនដែលនាំឱ្យមានការព្រួយបារម្ភពីបញ្ហាបរិស្ថាន និងសុខភាពមនុស្ស។ ដោយសារកង្វះខាតនៃការ អនុវត្តការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវ និងការយល់ដឹងរបស់សាធារណជននៅមានកម្រិត បញ្ហាសំណល់រឹងនៅតែជាសម្ពាធបរិស្ថានមួយដ៏ធំ។

ក្រសួងបរិស្ថានត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣ ទទួលបន្ទុកលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការធ្វើផែនការបរិស្ថាន ការគ្រប់គ្រង និងការអភិរក្សធនធានធម្មជាតិ ច្បាប់បរិស្ថាន និងការអប់រំបរិស្ថានជាដើម។

ការបង្កើតក្រសួងបរិស្ថានឡើងនេះ គឺជាជំហានដំបូងយ៉ាងសំខាន់ឆ្ពោះទៅរកការគ្រប់គ្រងបរិស្ថាននៅកម្ពុជា។ ទន្ទឹមនឹងនេះ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ ក៏បានបង្កើតនិងកំណត់ស្តង់ដាមូលដ្ឋានសម្រាប់ការបំពុលខ្យល់។ ការគ្រប់គ្រងបញ្ហាការបំពុល និងសំណល់រឹង គឺស្ថិតក្រោមអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្នាំ១៩៩៩ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹងឆ្នាំ១៩៩៩ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសំឡេងនៅឆ្នាំ២០០០ និងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹកឆ្នាំ១៩៩៩។

មកដល់ពេលនេះ ក្រសួងបរិស្ថានបានបង្កើតផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍបៃតងថ្នាក់ជាតិ ក្នុងគោលបំណងរាប់បញ្ចូលការអភិវឌ្ឍបៃតងចូលទៅក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ។ នៅក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍបៃតង សម្រាប់ឆ្នាំ ២០១៣-២០៣០ ក្នុងគោលបំណងលើកកម្ពស់ និងអភិវឌ្ឍសេដ្ឋកិច្ចបៃតង តាមរយៈការធ្វើចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង ហិរញ្ញវត្ថុបៃតង ឥណទានបៃតង និងវិនិយោគទុនបៃតង។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ អនុក្រឹត្យថ្មីស្តីពីការគ្រប់គ្រងកាកសំណល់ត្រូវបានបង្កើត និងដាក់ឱ្យអនុវត្ត។ អាជីវកម្ម សហគ្រាស និងប្រជាពលរដ្ឋនឹងត្រូវពិន័យជាប្រាក់ពី ១០,០០០ ទៅ ២០០,០០០ រៀល (ប្រហែល ២,៥០ ទៅ ៥០ ដុល្លារអាមេរិក) ប្រសិនបើមានការបោះចោល ឬដុតសំរាម នៅតាមទីសាធារណៈ និងមិនអនុវត្តតាមគោលការណ៍ណែនាំអំពីការបែងចែក និងទុកដាក់សំណល់ឱ្យបានត្រឹមត្រូវ។

**៣.៣.២. ការបំពុលបរិស្ថាន**

ការបំពុលបរិស្ថាន ជាបញ្ហាដ៏ធំមួយដែលពិភពលោកកំពុងព្រួយបារម្ភយ៉ាងខ្លាំង។ របាយការណ៍មួយបានបង្ហាញថា ការបំពុលបរិស្ថាន បានធ្វើឱ្យមានអ្នកស្លាប់ប្រមាណ ៩លាននាក់ជារៀងរាល់ឆ្នាំ ដោយភាគច្រើនបណ្តាលមកពីបញ្ហាបំពុលខ្យល់។ អត្រាអ្នកស្លាប់ដោយសារការបំពុលបរិស្ថានភាគច្រើនកើតមាននៅក្នុងបណ្តាប្រទេសក្រីក្រ និងប្រទេសមានចំណូលមធ្យម។

ការបំពុលបរិស្ថាន ត្រូវបានរាប់បញ្ចូលទាំងការបំពុលដី បំពុលទឹក និងបំពុលខ្យល់។ វាជាបញ្ហាគំរាមកំហែងជីវិតមនុស្សដ៏ធំមួយនាពេលបច្ចុប្បន្ន ដោយបានសម្លាប់មនុស្សប្រមាណ ៩លាននាក់ជារៀងរាល់ឆ្នាំក្នុងពិភពលោក។ ក្នុងនោះ ការបំពុលខ្យល់ ជាបញ្ហាប្រឈមខ្លាំងជាងគេដែលបង្កឱ្យមានការស្លាប់ ៦,៥លាននាក់ក្នុងមួយឆ្នាំៗ។

បញ្ហាកខ្វក់ខ្យល់ បានបង្កផលប៉ះពាល់ដល់សុខភាពមនុស្សទាំងអស់ក្នុងពិភពលោក តែក្នុងកម្រិតខុសៗគ្នា។ អត្រាអ្នកស្លាប់ដោយការបំពុលបរិស្ថានប្រមាណ ៩២ភាគរយឯណោះកើតឡើងចំពោះប្រទេសក្រីក្រ និងប្រទេសមានចំណូលមធ្យម។ ជាការពិតប្រទេសចំណូលខ្ពស់ក៏រងការប៉ះពាល់ដោយសារការបំពុលបរិស្ថានដែរ ពិសេសការបំពុលខ្យល់។ តាមការប៉ាន់ស្មានរបស់អង្គការសុខភាពពិភពលោក ប្រជាជនពិភពលោក ៩៩ភាគរយទៅហើយដែលស្រូបយកខ្យល់មិនបរិសុទ្ធតាមដំណកដង្ហើម។

កត្តាបង្កការបំពុលបរិស្ថានធំជាងគេ គឺការបំពុលដោយសារជាតុគីមីដែលបានសម្លាប់មនុស្សជិត ២លាននាក់ជារៀងរាល់ឆ្នាំ។ សារជាតុគីមី ត្រូវបានរកឃើញទាំងនៅក្នុងដី ក្នុងទឹក និងក្នុងខ្យល់។ សារជាតុគីមីក្នុងដី និងទឹកភាគច្រើនបង្កពីការប្រើជីគីមីក្នុងវិស័យកសិកម្ម និងសំណល់ប្លាស្ទិកជាដើម។ ចំណែកការបំពុល

ខ្យល់បណ្ដាលមកពីការបំភាយចេញពីយានយន្ត រោងចក្រ និងចេញពីធម្មជាតិដោយភ្លើងឆេះព្រៃ ឬបន្ទុះភ្នំភ្លើងជាដើម។

ការបំពុលបរិស្ថានមួយផ្នែកធំ ត្រូវបានបង្កឡើងដោយសកម្មភាពមនុស្ស ហើយការបំពុលទាំងអស់នេះមានទំនាក់ទំនងបន្តជាមួយការប្រែប្រួលអាកាសធាតុ ដែលបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពមនុស្ស។ ហេតុនេះមនុស្សចាំបាច់បញ្ឈប់ ឬកាត់បន្ថយសកម្មភាពបង្កឱ្យមានការបំពុលផ្សេងៗ ដើម្បីជាប្រយោជន៍សម្រាប់សុខភាពមនុស្ស។ មនុស្សគួរតែយកចិត្តទុកដាក់ខ្លាំងទៅលើការការពារបរិស្ថាន ខណៈវាកំពុងបង្កផលប៉ះពាល់មកលើមនុស្សវិញម្ដងបន្តិចៗហើយ។

បច្ចុប្បន្ននេះ បញ្ហាធ្ងន់ធ្ងរបំផុតទាក់ទងនឹងការការពារបរិស្ថាន និងតម្រូវឱ្យមានដំណោះស្រាយជាអាទិភាពត្រូវបានកំណត់ដូចជា៖

- ការបំផ្លាញជម្រកធម្មជាតិ
- ការបំផ្លាញស្រទាប់អូហ្សូន
- ផលប៉ះពាល់ដោយឧស្ម័នផ្ទះកញ្ចក់
- សំណឹកដី
- ការចាប់ផ្ដើមនៃវាលខ្សាច់
- ភ្លៀងអាស៊ីត
- ការបំផ្លាញព្រៃឈើត្រូពិច
- ការប្រើប្រាស់ធនធានធម្មជាតិគ្មានប្រសិទ្ធភាព។

## ៤.ផលប៉ះពាល់នៃភាពមិនបៃតង

### ៤.១. សេចក្ដីផ្ដើម

*ភាពមិនបៃតង សំដៅដល់សកម្មភាពទាំងឡាយណាដែលមនុស្ស ឬធម្មជាតិបានធ្វើឱ្យខូចដល់ភាពបៃតងរបស់បរិស្ថានធម្មជាតិ។*



*រូបភាព*

### ១. ហេតុអ្វីបានជាខ្យល់នៅជុំវិញខ្លួនយើងមានសារៈសំខាន់?

*ខ្យល់គឺយើងមើលមិនឃើញទេ ប៉ុន្តែវានៅជុំវិញខ្លួនយើង! ខ្យល់ គឺជាឧស្ម័នចម្រុះគ្នា ភាគច្រើនគឺជាអុកស៊ីសែន និងនីត្រូហ្សែន ដែលរុក្ខជាតិ សត្វ និងមនុស្សត្រូវការដើម្បីរស់រានមានជីវិត។*

**២. តើការបំពុលខ្យល់កើតមកពីណា?**

ការបំពុលខ្យល់កើតឡើងនៅពេលសារធាតុប្រកបដោយគ្រោះថ្នាក់ (សារធាតុពុល) ត្រូវបានបញ្ចេញទៅក្នុងខ្យល់នៅក្នុង ឬក្រៅផ្ទះរបស់យើង។ ការបំពុលខ្យល់អាចបំផ្លាញរាងកាយរបស់យើង និងថែមទាំងបង្កើនឱកាសកាន់តែច្រើនឱ្យយើងមានជំងឺមួយចំនួនផងដែរ។

ការបំពុលខ្យល់អាចកើតឡើងពីប្រភពធម្មជាតិ ដូចជាភ្លើងឆេះព្រៃ ធូលី និងបន្ទុះភ្នំភ្លើង។ ប៉ុន្តែភាគច្រើនសកម្មភាពរបស់មនុស្សបង្កការបំពុលខ្យល់ពីសកម្មភាពនានាដូចជា រោងចក្រថាមពលដែលដុតឥន្ធនៈហ្វូស៊ីល (ធ្យូងថ្ម ប្រេង ឧស្ម័នធម្មជាតិ) ជី និងសំណល់សត្វពីកសិដ្ឋាន ចង្ក្រានដុតអុស ការបើកបររថយន្ត ការហោះហើរយន្តហោះ និងសកម្មភាពជាច្រើនផ្សេងទៀត...។

**៣. មនុស្សចំនួន ១,៨៣ន់លាននាក់អាយុក្រោម ១៥ឆ្នាំ** ដកដង្ហើមយកខ្យល់ពុលខ្លាំង ដែលបង្កហានិភ័យចំពោះសុខភាព និងការអភិវឌ្ឍរបស់ពួកគេ។

សកម្មភាពរបស់យើងជាមនុស្ស មិនត្រឹមតែរួមចំណែកធ្វើឱ្យមានបម្រែបម្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដោយផ្ទាល់ទៅលើសុខភាពរបស់យើងផងដែរ។

- សារធាតុពុលនៅក្នុងខ្យល់អាចចូលទៅក្នុងសួត និងប្រព័ន្ធឈាមរបស់យើង ដែលបង្កើនហានិភ័យចំពោះជំងឺបេះដូង ជំងឺផ្លូវដង្ហើម និងជំងឺមហារីកសួត។
- ការស្រូបយកខ្យល់ពុលក្នុងរយៈពេលវែងអាចផ្លាស់ប្តូររចនាសម្ព័ន្ធខួរក្បាលរបស់យើង និងកាត់បន្ថយសមត្ថភាពរបស់យើងក្នុងការរៀនពូកែនៅសាលារៀន និងការផ្តោតអារម្មណ៍នៅពេលប្រឡង។

**៤.២. ភាពមិនប្រែគម/លទ្ធផលអវិជ្ជមាន**

១. លក្ខខណ្ឌទូទៅ

**តើអ្នកដឹងទេថាការស្រូបយកខ្យល់ពុលក្នុងរយៈពេលវែងអាចផ្លាស់ប្តូររចនាសម្ព័ន្ធខួរក្បាលរបស់យើង និងកាត់បន្ថយសមត្ថភាពរបស់យើងក្នុងការរៀនឱ្យពូកែនៅសាលារៀន និងការផ្តោតអារម្មណ៍នៅពេលប្រឡង។ ដោយសារយើងមើលមិនឃើញខ្យល់ វាពិតជាពិបាកមើលឃើញខ្យល់ពុលណាស់ ។**

សញ្ញាបង្កហេតុ ៣ចំណុចដែលយើងអាចកំណត់សម្គាល់៖

- ភាពស្ទួត/ក្រហាយភ្នែក ឈឺក្បាល អស់កម្លាំង អាលាក់ហ្ស៊ី ឬដង្ហើមខ្លី។
- តើនៅតំបន់អ្នករស់នៅមានរោងចក្រ រថយន្ត រថយន្តដឹកទំនិញ រោងចក្រអគ្គិសនីដែរឬទេ? ប្រសិនបើមាន នោះអ្នកប្រហែលប្រឈមនឹងការបំពុលខ្យល់កម្រិតខ្ពស់។
- ប្រសិនបើ អ្នករស់នៅជាមួយអ្នកមានជំងឺហឺត អ្នកអាចឃើញពួកគេមានជំងឺហឺតកាន់តែធ្ងន់ធ្ងរ ដង្ហើមខ្លី ឈឺទ្រូង ក្អក ឬដកដង្ហើមតឹង។

តើអ្នកដឹងថា កុមារ និងយុវជនរងផលប៉ះពាល់ពីការបំពុលខ្យល់ខ្លាំងជាងមនុស្សពេញវ័យដែរឬទេ?

មូលហេតុ គឺដោយសារអ្នកដកដង្ហើមលឿនជាងមនុស្សពេញវ័យ និងស្រូបយកសារធាតុពុលច្រើនជាង។ បន្ថែមលើនេះ ដោយសារខួរក្បាល និងរាងកាយរបស់អ្នកកំពុងអភិវឌ្ឍនៅឡើយ ហើយសារធាតុពុលទាំងនេះ អាចបង្កគ្រោះថ្នាក់ចំពោះអ្នកបានស្របពេលអ្នកនៅតែកំពុងលូតលាស់។

ការសម្រេចបាននូវគោលដៅនានានៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសអាចសង្គ្រោះជីវិតមនុស្សប្រហែល១ លាន នាក់នៅទូទាំងពិភពលោកក្នុងមួយឆ្នាំ នៅត្រឹមឆ្នាំ២០៥០ ដោយគ្រាន់តែកាត់បន្ថយការបំពុលខ្យល់ប៉ុណ្ណោះ។ នេះមានន័យថា យើងមានការងារជាច្រើនត្រូវធ្វើ ប៉ុន្តែយើងអាចធ្វើឱ្យបរិស្ថាន និងសុខភាពរបស់យើងកាន់តែល្អប្រសើរ។

ហេតុដូចនេះ តើគុណភាពខ្យល់នៅជុំវិញយើងមានស្ថានភាពយ៉ាងដូចម្ដេច?

សន្ទស្សន៍គុណភាពខ្យល់ (AQI) គឺជាឧបករណ៍មួយ ដែលអាចប្រាប់អំពី គុណភាពនៃខ្យល់នៅជុំវិញយើងបាន។ AQI កាន់តែខ្ពស់មានន័យថា ការបំពុលខ្យល់កាន់តែខ្លាំង។

វឌ្ឍនភាពវិជ្ជមានកំពុងកើតឡើង

ក្នុងឆ្នាំ២០២០ វេទិកាដ៏ធំបំផុតរបស់ពិភពលោកសម្រាប់ទិន្នន័យអំពី គុណភាពខ្យល់ត្រូវបានដាក់ឱ្យអនុវត្ត។ វេទិកានេះធ្វើឱ្យអ្នកដឹកនាំរបស់យើងមានគណនេយ្យភាព និងលើកទឹកចិត្តយើងទាំងអស់ឱ្យស្វែងរកការគាំទ្រមតិ ដើម្បីឱ្យមានការតាមដានត្រួតពិនិត្យគុណភាពខ្យល់កាន់តែល្អ។

ប្រទេសកាន់តែច្រើនកំពុងតាមដានត្រួតពិនិត្យការបំពុលខ្យល់ និងចាត់វិធានការដើម្បីកាត់បន្ថយការបំពុលខ្យល់ច្រើនជាងពេលណាៗទាំងអស់ពីមុនមក។ ហេតុនេះ សូមធ្វើកិច្ចការរបស់អ្នក និងដឹងអំពីគុណភាពខ្យល់នៅជុំវិញខ្លួនយើង។




រូបភាព

## ៤.៣. លក្ខខណ្ឌនៅក្នុងគ្រឹះស្ថាន

### ៤.៣.១. គ្រឹះស្ថានអ.ប.វ.

គ្រឹះស្ថានអ.ប.វ. ជាទីកន្លែងផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជាកន្លែងមួយដែលសិស្ស និស្សិត គ្រូ សាស្ត្រាចារ្យ មន្ត្រី និងថ្នាក់ដឹកនាំ រៀន បង្រៀន និងធ្វើការ។ ជាកន្លែងចាប់ផ្តើមបង្កើតឱ្យមានភាពបៃតង ឬភាពមិនបៃតងក៏អាចកើតមាននៅទីនេះមុនគេដែរ។ ដូច្នេះគ្រឹះស្ថានអ.ប.វ. មានតួនាទីបណ្តុះបណ្តាលមនុស្សឱ្យមានចំណេះដឹង និងឥរិយាបថប្រកាន់ខ្ជាប់នូវការអនុវត្តបៃតងជាគំរូ ទាំងផ្នែកខាងក្នុង និងផ្នែកខាងក្រៅបរិវេណគ្រឹះស្ថាន។

### ៤.៣.២ កន្លែងធ្វើការ

កន្លែងធ្វើការសំដៅដល់ទីតាំងរបស់មនុស្សប្រុស ស្រី ដែលបាននឹងកំពុងប្រតិបត្តិកិច្ចការងាររបស់ខ្លួនទៅតាមមុខជំនាញរៀងៗខ្លួន។

ភាពបៃតងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការធ្វើឱ្យការអនុវត្តការងាររបស់មនុស្សមានប្រសិទ្ធភាព។ បើនៅកន្លែងធ្វើការមិនមានភាពបៃតងនោះទេ វានឹងធ្វើឱ្យអារម្មណ៍ធ្វើការងារ និងគុណភាពនៃការងារមានការថយចុះ ខាតពេលវេលា ចំណាយច្រើន ។ល។

### ៤.៣.៣. សហគមន៍

សហគមន៍ គឺសំដៅទៅលើមនុស្សផ្សេងៗគ្នា ដែលមានលំនៅឋានស្ថិតក្នុងតំបន់ភូមិសាស្ត្រដូចគ្នា និងអាស្រ័យផលធនធានធម្មជាតិក្នុងមូលដ្ឋានតែមួយ។

ចំពោះភាពបៃតង ចាំបាច់ត្រូវតែរួមគ្នាប្រតិបត្តិ ប្រសិនបើមាននរណាម្នាក់ ឬក្រុមណាមួយចាំតែបំផ្លាញនោះ ពិតជាទទួលនូវផលប៉ះពាល់ច្រើនដល់មនុស្ស។ ដូច្នេះ ដើម្បីឈានទៅរកភាពបៃតងបាន គឺត្រូវតែចាប់ផ្តើមពីបុគ្គលម្នាក់ ពីក្រុមតូច ក្រុមធំ សហការចូលរួមទាំងអស់គ្នាបង្កើតឡើង ។



រូបភាពៈ**គ្រឹះស្ថានអ.ប.វ**



រូបភាពៈ**កន្លែងធ្វើការ**



រូបភាពៈសហគមន៍

## ៥.អត្ថប្រយោជន៍នៃភាពបៃតង និងកិច្ចការពារបរិស្ថាន

### ៥.១. សេចក្តីផ្តើម

ការចាប់ផ្តើមអនុវត្តគំនិតផ្តួចផ្តើមសកម្មភាពបៃតងរបស់យើងទាំងអស់គ្នា ពិតជាបានធ្វើឱ្យប្រទេសកម្ពុជាមានភាពស្រស់ស្អាត និងអស្ចារ្យ។ គ្រឹះស្ថានអ.ប.វ. អ្នកសិក្សា អ្នកធ្វើការ ឧស្សាហកម្ម និងសាធារណជន មានតួនាទីចូលរួមទាំងអស់គ្នា ទើបទិដ្ឋភាពបៃតងអាចនឹងផុសចេញជារូបរាងសុះសាយគ្រប់ទីកន្លែងបាន។

### ៥.២. អត្ថប្រយោជន៍នៃភាពបៃតង

សកម្មភាពអនុវត្តទៅរកភាពបៃតងគឺជាការអនុវត្តដែលទទួលបាននូវផលចំណេញនិងជាការវិនិយោគមួយដែលផ្តល់ប្រយោជន៍ដល់សង្គម និងបរិស្ថានដែលទាមទារឱ្យមានការយល់ដឹងយ៉ាងស៊ីជម្រៅពីផលប៉ះពាល់។ គ្រឹះស្ថានអ.ប.វ. ត្រូវតែចូលរួមពិនិត្យ និងយកចិត្តទុកដាក់លើសកម្មភាពជាក់ស្តែងរបស់ខ្លួន ដើម្បីយកមកប្រើប្រាស់ពីរបៀបថាតើការប្រព្រឹត្ត និងគោលនយោបាយរបស់ខ្លួនមានសក្តានុពលអាចផ្លាស់ប្តូរសង្គម និងបរិស្ថានរបស់យើងបានល្អប្រសើរជាងមុន ឬអាក្រក់យ៉ាងដូចម្តេច? តទៅនេះយើងនឹងលើកយកថាតើគ្រឹះស្ថានអ.ប.វ.ត្រូវរៀបចំខ្លួនយ៉ាងណាខ្លះដើម្បីផ្សព្វផ្សាយ និងបណ្តុះចំណេះដឹងដល់អ្នកសិក្សា ឬអ្នកធ្វើការឧស្សាហកម្ម និងសាធារណជន? គ្រឹះស្ថានអ.ប.វ. ត្រូវតែប្រមូលព័ត៌មាន និងភស្តុតាងឱ្យបានពេញលេញ និងគ្រប់គ្រាន់ ដើម្បីបង្កើតជាមុខវិជ្ជា ម៉ូឌុលសិក្សា ឬមុខជំនាញដែលពាក់ព័ន្ធជាមួយនឹងផលប្រយោជន៍នៃការរក្សាឱ្យបាននូវភាពបៃតងសម្រាប់បរិស្ថានសង្គមរស់នៅរបស់ប្រជាជន។

អត្ថប្រយោជន៍នៃភាពបៃតងរួមមានៈ

- ធ្វើឱ្យអ្នកសិក្សា ឬសិស្ស ស្រឡាញ់ និងចូលចិត្តបរិស្ថានស្អាត និងចូលរួមកាត់បន្ថយភាពមិនស្អាត
- ធ្វើឱ្យគ្រូបង្រៀន ឬអ្នកបណ្តុះបណ្តាល កាន់តែមានគំនិតរិះរកអ្វីដែលជួយកាត់បន្ថយពីផលប៉ះពាល់ដែលកើតចេញពីបរិស្ថានសង្គមឱ្យមានភាពល្អឡើងៗ
- ធ្វើឱ្យអ្នកគ្រប់គ្រងទទួលបាននូវគំនិតច្នៃប្រឌិតច្រើននៅក្នុងគ្រឹះស្ថាន ដែលនាំទៅរកភាពបៃតង
- ធ្វើឱ្យសហគមន៍ ទទួលបានឥទ្ធិពល និងមានការចូលកាន់តែច្រើនលើការងារបរិស្ថាន
- ធ្វើឱ្យសង្គមមនុស្ស ទទួលបាននូវការរក្សាបរិស្ថានធម្មជាតិគង់វង្ស និងមនុស្សមានសុខភាពរឹងមាំ

### ៥.៣. កិច្ចការពារបរិស្ថាន

កិច្ចការពារបរិស្ថាន គឺជាយុទ្ធសាស្ត្រសម្រាប់និរន្តរភាពនៃការរីកចម្រើនឧស្សាហកម្ម។ ការការពារ និងកែលម្អប្រព័ន្ធអេកូឡូស៊ីបរិស្ថាន ជំរុញដល់ការអភិវឌ្ឍបៃតង ផ្តល់ការគាំទ្រដ៏សំខាន់ និងពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងសុខុមាលភាពសាធារណៈ។



រាជរដ្ឋាភិបាលបានបោះជំហានឆ្ពោះទៅមុខ ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់ដើម្បីធ្វើឱ្យមាននិរន្តរភាពនៃការប្រើប្រាស់បរិស្ថាន និងជីវៈចម្រុះ តាមរយៈការចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិជាច្រើនរួមមាន៖

- អនុសញ្ញាស្តីពីជីវៈចម្រុះ
- អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ
- អនុសញ្ញាស្តីពីតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ (អនុសញ្ញារ៉ាមសារ)
- អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិទៅលើសត្វព្រៃជិតផុតពូជ (ហៅកាត់ថា CITES)
- អនុសញ្ញាបេតិកភណ្ឌពិភពលោក
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ
- អនុសញ្ញាអន្តរជាតិសម្រាប់ការទប់ស្កាត់ការបំពុលពីនាវា
- កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ

មួយវិញទៀតចំពោះគ្រឹះស្ថានអ.ប.វ. កិច្ចការការពារបរិស្ថាន បាននឹងកំពុងគិតគូរនឹងយកចិត្តទុកដាក់យ៉ាងខ្លាំងតាមរយៈដៃគូគម្រោងនានាដែលបានផ្តល់ និងធ្វើកិច្ចសហប្រតិបត្តិការ។

### ៥.៤.ឥរិយាបថក្នុងសកម្មភាព អ.ប.វ. បៃតង

#### ៥.៤.១. សេចក្តីផ្តើម

ពិភពលោកបច្ចុប្បន្នកំពុងប្រឈមមុខនឹងបញ្ហាបរិស្ថានដោយសារអំពើរបស់មនុស្ស។ អំពើរបស់មនុស្សរួមមាន៖

- ❑ ការទាញផលពីធម្មជាតិ
- ❑ ការបោះចោលកាកសំណល់ទៅក្នុងបរិស្ថាន

❑ ការបំផ្លាញជម្រកធម្មជាតិ

ដើម្បីឱ្យបរិស្ថាននៅតែរក្សាបានភាពបៃតង មានតែមនុស្សជាអ្នកបង្ការ និងការពារពីអំពើរបស់ខ្លួនដែលបានបង្កើតឡើង។



គ្រឹះស្ថាន អ.ប.វ. គឺជាមណ្ឌលសម្រាប់រៀបចំ និងតម្រង់ទិសមនុស្សឱ្យមានសកម្មភាពចូលរួម សហការ ទាំងក្នុង និងក្រៅអង្គភាព។ គ្រឹះស្ថាន អ.ប.វ. ត្រូវធ្វើដូចម្ដេច ដើម្បីឱ្យការអនុវត្តសកម្មភាពបៃតង ក្នុងនិងក្រៅអង្គភាពមានស្ដង់ដា និងស្ថេរភាពបេបរិដ្ឋមាន?

## ៥.៤.២ ឥរិយាបថ និងទិដ្ឋភាពទូទៅសម្រាប់ អ.ប.វ. បៃតង

### ៥.៤.២.១ ការបោះចោលកាកសំណល់

សិស្សក្នុងគ្រឹះស្ថាន អ.ប.វ. មានចំនួនច្រើន ដូច្នេះបញ្ហាកំណើនកាកសំណល់ក៏កើតមានច្រើនដែរ។ ការចោលកាកសំណល់មិនបានត្រឹមត្រូវ ធ្វើឱ្យកង្វក់ដល់បរិស្ថានគ្រឹះស្ថាន អ.ប.វ. ក៏ដូចជាកង្វក់ដី និងកង្វក់ខ្យល់ ហើយបានបង្កជាហេតុរំខានក្នុងការសិក្សា អាចនឹងឈានដល់គ្រោះថ្នាក់ដល់សុខភាពរបស់អ្នកជុំវិញបានក្នុងកម្រិតធ្ងន់ផងដែរ។







### ៥.៤.២.២. ការមិនយកចិត្តដាក់ក្នុងការដាំ និងថែទាំដើមឈើ

ការបង្កើតឱ្យមានសួនបៃតងសម្រាប់ជាទីកន្លែងមនោរម្យដល់អារម្មណ៍រៀនសូត្រ និងស្វ័យសិក្សានៅក្រៅម៉ោងរៀនរបស់សិស្ស និងគ្រូបង្រៀន។ ការដាំដើមឈើ ដើម្បីបង្កើតជាម្លប់ ទាក់ទាញខ្យល់អាកាសល្អក្នុងបរិវេណគ្រឹះស្ថាន ជាទិដ្ឋភាពមួយនាំឱ្យសិស្សមានទឹកចិត្ត ចូលចិត្ត និងស្រឡាញ់ការសិក្សាកាន់តែខ្លាំងឡើង។ ជាពិសេសបណ្តុះ និងបង្កើនអារម្មណ៍ស្និទ្ធស្នាល និងទំនាក់ទំនងគ្នាទៅវិញទៅមក កាន់តែស្អិតរមួតពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតជារៀងរាល់ថ្ងៃ (អារម្មណ៍ផ្លូវចិត្ត មានមនោសញ្ចេតនាក្នុងការសិក្សា ការបង្រៀន និងអនុវត្តការងាររបស់មន្ត្រីទាំងអស់គ្នានៅក្នុងអង្គភាពពិតប្រាកដ)។

ផ្ទុយមកវិញ ក្នុងលក្ខខណ្ឌដែលគ្រឹះស្ថាន អ.ប.វ. មិនបានយកចិត្តដាក់លើបញ្ហាខាងលើនេះទេ វាក៏នាំមកនូវភាពអវិជ្ជមានផ្លូវចិត្ត ទាំងសិស្ស គ្រូ មន្ត្រី និងបុគ្គលិករួមទាំងអ្នកនៅក្នុងសហគមន៍ផងដែរ។



រូបភាព៖ទិដ្ឋភាពខាងក្រៅរបស់អគារ អ.ប.វ. (គំរូ)




រូបភាព៖ ទិដ្ឋភាពទីកន្លែងសម្រាប់ស្វ័យសិក្សារបស់សិស្ស អ.ប.វ. ក្រៅម៉ោងរៀន(គំរូ)

 

រូបភាព៖ ទិដ្ឋភាពទីកន្លែងបន្ទប់រៀន/ថ្នាក់ អ.ប.វ. (គំរូ)



រូបភាព៖ ទិដ្ឋភាពរោងជាងអនុវត្ត អ.ប.វ.(គំរូ)

### ៥.៥. ការកំណត់ចំណុចគោលសំខាន់ៗក្នុងការបង្កើតទិដ្ឋភាពបៃតងសម្រាប់គ្រឹះស្ថាន អ.ប.វ.

ជាកិច្ចការមួយសំខាន់ និងមានប្រយោជន៍សម្រាប់ការរៀបចំបង្កើតទិដ្ឋភាពបៃតង គឺការអនុវត្តឱ្យមានជាសកម្មភាពបៃតងដើម្បីរក្សាបានទាំងក្នុង និងក្រៅអង្គភាព។ វាមានចំណុចចម្បងៗជាច្រើនដែលត្រូវគិត និងយកមកពិចារណា ហើយស្វែងយល់ថាត្រូវធ្វើដូចម្តេចដើម្បីឱ្យទទួលបានទិដ្ឋភាព ឬបរិស្ថានបៃតងនោះ។

ខាងក្រោមនេះជាចំណុចគោលដែលយើងបានរកឃើញ និងបានអនុវត្តនៅក្នុងគ្រឹះស្ថានមួយចំនួនដែលទទួលបានផលជាច្រើន៖

- ❑ រៀបចំផែនការសកម្មភាពអនុវត្តបរិស្ថានបៃតងទាំងក្នុង និងក្រៅអង្គភាព
- ❑ រៀបចំរចនាសម្ព័ន្ធចាត់តាំងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់
- ❑ បណ្តុះបណ្តាលមន្ត្រី គ្រូ/សាស្ត្រាចារ្យ និងបុគ្គលិកឱ្យយល់ច្បាស់ពីបរិស្ថានបៃតង
- ❑ បង្កើនស្មារតីទទួលខុសត្រូវដល់គ្រូ/សាស្ត្រាចារ្យ និងបុគ្គលិក

- ❑ រួមគ្នាអនុវត្តតាមបទបញ្ជាផ្ទៃក្នុងគ្រឹះស្ថាន អ.ប.វ. បៃតង
- ❑ របាយការណ៍លទ្ធផលនៃសកម្មភាពអនុវត្តតាមផ្នែកនីមួយៗ
- ❑ ស្វ័យវាយតម្លៃលទ្ធផលនៃការអនុវត្តសកម្មភាព
- ❑ កែតម្រូវ និងសម្រួលចំណុចអវិជ្ជមានឱ្យក្លាយជាចំណុចវិជ្ជមាន




PDCA គឺជាវិធីសាស្ត្រ ៤ជំហានដដែលៗវិលជុំ សម្រាប់ធ្វើការកែលម្អ និងផ្លាស់ប្តូរនៅក្នុងកិច្ចការណាមួយដើម្បីឈានទៅរកភាពល្អប្រសើរ។ ពាក្យ PDCA តំណាងឱ្យពាក្យភាសាអង់គ្លេសចំនួន ៤គឺ Plan (គ្រោង) Do (អនុវត្ត) Check (ពិនិត្យ) និង Act (ចាត់វិធានការ)។ អ្នកអាចប្រើវិធីសាស្ត្រ PDCA នេះជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែក៏បាន។

### ៥.៦. កត្តាជំរុញឱ្យមានផ្នត់គំនិត និងទម្លាប់ អ.ប.វ. បៃតង

#### ៥.៦.១. សេចក្តីផ្តើម

ផ្នត់គំនិត និងសកម្មភាពវិជ្ជមានក្នុងការកសាងភាពបៃតងពិតជាធ្វើឱ្យសង្គមមនុស្សរបស់យើងមានឆន្ទៈដើរទៅមុខពោរពេញដោយកម្លាំង និងថាមពលឥតគណនា ក្នុងការសិក្សាស្រាវជ្រាវលើអ្វីដែលជាលទ្ធផលកើតចេញដែលជាផលប៉ះពាល់លើភាពមិនបៃតងរបស់បរិស្ថានសង្គម។



**រូបភាព៖ សកម្មភាពវិជ្ជមានក្នុងការកសាងភាពបៃតង**

### ៥.៦.២. ផ្នត់គំនិត និងវប្បធម៌ អ.ប.វ. បៃតង

តើ "ផ្នត់គំនិត" គឺជាអ្វី?

ពាក្យមួយអាចយកមកជំនួសពាក្យ "ផ្នត់គំនិត" នេះបានគឺ "ការយល់ឃើញ"។ **ផ្នត់គំនិត** ជាគំនិតនៃការយល់ឃើញដែលជិតជាមនៅក្នុងអារម្មណ៍ និងគំនិតរបស់មនុស្សម្នាក់ៗទៅតាមការកំណត់របស់សង្គម និងវប្បធម៌ ។ វាជាបុរេនិច្ឆ័យជំនឿតៗគ្នា ឬការយល់ឃើញដែលត្រូវបានអនុវត្តនៅក្នុងសង្គម។ ការបណ្ដុះចំណេះវិជ្ជា ប្រាជ្ញាស្មារតី និងរបៀបរស់នៅរបស់មនុស្សឱ្យបានលូតលាស់ចម្រើនដើម្បីសម្របសម្រួលទៅនឹងបរិស្ថាន និងការអភិវឌ្ឍសង្គមដោយវិទ្យាសាស្ត្រ ឬដោយសិល្បៈផ្សេងៗជាដើម ហៅថា**វប្បធម៌។**

**តើ "ផ្នត់គំនិត និងវប្បធម៌ អ.ប.វ. បៃតង" គឺជាអ្វី?**

**ផ្នត់គំនិត និងវប្បធម៌** អ.ប.វ. បៃតងគឺជាការយល់ឃើញ និងរបៀបរស់នៅបែបវិជ្ជមានរបស់មនុស្សក្នុងបរិស្ថានធម្មជាតិ និងបរិស្ថានសង្គម។ មនុស្សបានដឹង និងរៀបចំខ្លួនជាស្រេចហើយព្យាយាមខិតខំសិក្សាស្រាវជ្រាវរកអ្វីដែលជាមធ្យោបាយការពារភាពបៃតងឱ្យពិភពលោក។ មនុស្សបានដឹងថាពិភពលោកនឹងបាត់បង់ភាពបៃតងម្តងបន្តិចៗដោយសារតែការអភិវឌ្ឍរបស់មនុស្សក្នុងបរិស្ថានសង្គម។

មានកត្តាជាច្រើនបានជួយជំរុញឱ្យមានផ្នត់គំនិត និងវប្បធម៌ អ.ប.វ.បៃតងនេះឡើង។ បរិស្ថានជាបញ្ហារួមរបស់យើងទាំងអស់គ្នា ហើយទាមទារចាំបាច់នូវការចូលរួមរបស់យើងទាំងអស់គ្នាក្នុងការថែរក្សាអនាម័យបរិស្ថានជុំវិញខ្លួនយើងឱ្យបានល្អ ដើម្បីបង្កើតបរិយាកាសល្អ និងមានផាសុកភាពសម្រាប់ការរស់នៅរបស់យើង។ សង្គមកម្ពុជាមានបរិស្ថានស្អាត និងមានភាពបៃតង គឺកើតចេញពីពលរដ្ឋកម្ពុជាម្នាក់ៗចូលរួមក្នុងសកម្មភាពបរិស្ថាន មានមេត្រីភាពបរិស្ថានប្រកបដោយការទទួលខុសត្រូវ និងដោយស្មារតីស្រឡាញ់ បរិស្ថានខ្ពស់។




**រូបភាព៖ ក្រុមមួយនៃការចូលរួមរបស់យុវជនសម្រាប់បរិស្ថានស្អាត/បរិស្ថានបៃតង**

ចំណេះដឹង សមត្ថភាព និងស្មារតីទទួលខុសត្រូវគ្រប់កិច្ចការជាផ្នែកសំខាន់ រុញច្រានឱ្យយុវជនក្លាយជាមនុស្សមានផ្នត់គំនិតវិជ្ជមាន និងហ៊ានសម្រេចចិត្តដោយឯករាជ្យនៅក្នុងដំណើរជីវិតសិក្សា ការងារ ព្រមទាំងចូលរួមសកម្មភាពនានានៅក្នុងសង្គម។

យុវជនដែលជាកម្លាំងស្នូលរបស់ប្រទេសជាតិមិនត្រឹមតែពោរពេញដោយចំណេះដឹងមានវិជ្ជាជីវៈ សីល-ធម៌ និងការទទួលខុសត្រូវនោះទេ គឺត្រូវមានប្រតិបត្តិមេត្រីភាពបរិស្ថានដោយចូលរួមក្នុងការសម្អាតអនាម័យបរិស្ថាន ការវេចខ្ចប់សំណល់សំរាមឱ្យបានត្រឹមត្រូវ ចូលរួមបង្កើនភាពបៃតងដោយដាំដើមឈើ និងរុក្ខជាតិផ្សេងៗ ចូលរួមអភិរក្សជីវៈចម្រុះ សន្សំសំចៃការប្រើប្រាស់ទឹក និងចរន្តអគ្គិសនី ព្រមទាំងរស់នៅប្រកបដោយមេត្រីភាពបរិស្ថាន។ ការចូលរួមក្នុងកិច្ចការសង្គមនានាដូចជាការចូលរួមសម្អាតអនាម័យបរិស្ថានក៏ជាផ្នែកមួយសំខាន់ដើម្បីពង្រឹងតួនាទីជាពលរដ្ឋល្អ។



**រូបភាព**

ការកែទម្រង់ស៊ីជម្រៅ ក្នុងការកសាងសមត្ថភាពស្ថាប័ន ធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាអាទិភាពខ្ពស់ស្របទៅតាមទស្សនាទាននៃ «រដ្ឋបាលទំនើប» សំដៅលើប្រព័ន្ធការងារមួយដែលដំណើរការងារដោយបែបបទនីតិវិធីប្រកបដោយប្រសិទ្ធភាព និងធនធានមនុស្សប្រកបដោយគុណភាពដែលក្នុងនោះទាំងថ្នាក់ដឹកនាំ ទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់យល់ច្បាស់អំពីបេសកកម្មចក្ខុវិស័យ គោលបំណងរបស់ស្ថាប័ន អង្គភាពគ្រប់ជាន់ថ្នាក់ ហើយ***បំពេញតួនាទី ភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនម្នាក់ៗ ប្រកបដោយការភ្ញាក់រលឹក***មនសិការវិជ្ជាជីវៈ ការច្នៃប្រឌិត ដោយតម្កល់ខ្ពស់នូវបំណងប្រាថ្នាដ៏ពិសិដ្ឋ និងឧត្តមប្រយោជន៍នៃប្រជាជន និងជាតិមាតុភូមិ ពោលគឺជានាបាននូវកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព។

គោលបំណងដ៏សំខាន់របស់យើងគឺការក្ដាប់មកវិញនូវមោទនភាពជាតិ និងការកសាងជាតិទំនើបមួយដ៏រស់រវើក ក្នុងសេចក្តីប៉ងប្រាថ្នាប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលខ្ពស់ រឹងមាំ ពលរដ្ឋមានសមត្ថភាព និងបរិស្ថានរស់នៅល្អប្រសើរ កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិ ឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាពសម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំរុញឱ្យយុវជនទាំងនោះខិតខំបំពេញការងារ និងសូមកុំធ្វើសកម្មភាពសម្អាតអនាម័យបរិស្ថាន ឬប្រតិបត្តិមេត្រីភាពបរិស្ថានតែមួយរយៈពេលខ្លី ប៉ុន្តែត្រូវប្រតិបត្តិមេត្រីភាពបរិស្ថានជារៀងរាល់ថ្ងៃ គ្រប់ពេលវេលា គ្រប់ទីកន្លែង ដើម្បីបរិស្ថានស្អាត និងការពារភពផែនដីរបស់យើង។ យុវជន ទាំងអស់ត្រូវមានមោទន-ភាពចំពោះសកម្មភាពស្រឡាញ់បរិស្ថាន និងខ្វល់ខ្វាយពីបរិស្ថានរបស់ខ្លួន និងសូមកុំរួញរា ឬបាក់ទឹកចិត្តនៅ

ពេលបំណងប្រាថ្នារបស់ខ្លួនមិនទាន់បានសម្រេចព្រោះការអប់រំ និងកែប្រែឥរិយាបថ និងបណ្តុះស្មារតីមនុស្ស ឱ្យស្រឡាញ់បរិស្ថានគឺត្រូវការពេលវេលា និងទាមទារនូវភាពអំណត់ តស៊ូ ព្យាយាម និងអត់ធ្មត់ខ្ពស់បំផុត។

## ៥.៧.ការរស់នៅក្នុងសហគមន៍បៃតង

### ៥.៧.១. សេចក្តីផ្តើម

***តើសហគមន៍ជាអ្វី?*** ពាក្យ សហគមន៍ មានដើមកំណើតពីពាក្យឡាតាំង communitas។ សហគមន៍គឺជាដំណើរការនៃការរស់នៅរួមគ្នារបស់ពលរដ្ឋ/ប្រជាជន ដែលមានលំនៅឋានស្ថិតក្នុងតំបន់ភូមិសាស្ត្រដូចគ្នា និងអាស្រ័យផលធនធានធម្មជាតិក្នុងមូលដ្ឋានតែមួយ។

តើសហគមន៍បៃតងជាអ្វី? **សហគមន៍បៃតង** Green Community គឺសំដៅដល់សកម្មភាពដែលជាលទ្ធផលកកើតចេញពីការរស់នៅរបស់ប្រជាជនដែលបានរួមគ្នា សហការគ្នា ចងក្រងជាក្រុម រក្សា ឬរៀបចំកន្លែងរស់នៅរបស់ខ្លួនឱ្យទទួលបានបរិស្ថានធម្មជាតិរស់នៅប្រកបដោយសុខភាព និងសុវត្ថិភាព។

នៅពេលសហគមន៍មួយមានការយល់ដឹងដូចគ្នាអំពីបញ្ហាដែលបង្កឡើងដោយកាកសំណល់ នោះពួកគេអាចចាត់វិធានការដោះស្រាយបញ្ហាទាំងនោះ ដោយចាប់ផ្តើមជាមួយនឹងគម្រោងផ្សេងៗដែលបំពេញតម្រូវការ និងលទ្ធភាពរបស់សហគមន៍បានល្អបំផុត។

ការការពារសហគមន៍របស់យើងពីកាកសំណល់បង្កគ្រោះថ្នាក់ និងការប្រែក្លាយកាកសំណល់ឱ្យទៅជាធនធាន កែលម្អសុខភាពសហគមន៍ បរិស្ថាន និងសន្សំសំចៃប្រាក់ទៀតផង។



រូបភាព

មនុស្សគ្រប់គ្នា និងសហគមន៍ទាំងអស់ អាចទទួលខុសត្រូវលើការកាត់បន្ថយកាកសំណល់ និងការបោលកាកសំណល់យ៉ាងមានសុវត្ថិភាព។ ប៉ុន្តែ ខណៈដែលសហគមន៍នានាអាចធ្វើការងារនេះដោយខ្លួនឯង កាកសំណល់គឺជាបញ្ហានយោបាយមួយដែលអាចដោះស្រាយបាន លុះត្រាតែរដ្ឋាភិបាល ឧស្សាហកម្ម និងសហគមន៍ទាំងឡាយ សហការគ្នាដោយមានគោលដៅមួយ គឺការកែលម្អសុខភាពរបស់ប្រជាជន។

រដ្ឋាភិបាលត្រូវចាត់វិធានការកាត់បន្ថយបន្ទុកនៃកាកសំណល់មកលើប្រជាជននិងបរិស្ថាន តាមរយៈការទាមទារឱ្យឧស្សាហកម្មបង្កើតកាកសំណល់ឱ្យតិចបំផុតតាមដែលអាចធ្វើបាន។ ការគាំទ្ររបស់រដ្ឋាភិបាល

លើកម្មវិធីផ្សេងៗដែលលើកទឹកចិត្តប្រជាជនឱ្យប្រើប្រាស់ឡើងវិញ កែច្នៃឡើងវិញ និងចោលកាកសំណល់ប្រកបដោយសុវត្ថិភាព សន្សំសំចៃប្រាក់ បង្កើតការងារ និងជួយដោះស្រាយបញ្ហាក្នុងសហគមន៍។

**ការដើរមើលសំរាមនៅក្នុងសហគមន៍៖**

ផ្តល់ឱកាសមួយសម្រាប់ឱ្យប្រជាជនក្រឡេកមើល និងពិភាក្សាអំពីបញ្ហាសំរាម។ប្រជាជនអាចនិយាយពីការព្រួយបារម្ភរបស់ខ្លួនអំពីសំរាម និងពីក្តីសង្ឃឹមថានឹងមានសហគមន៍មួយដែលស្អាតជាងមុន និងមានសុខភាពល្អប្រសើរ។ ក្នុងពេល និងក្រោយពេលដើរសង្កេតមើលសំរាម ក្រុមប្រជាជនអាចពិភាក្សាអំពីជំហានចាំបាច់ផ្សេងៗក្នុងការសម្អាតសហគមន៍ និងក្នុងការរៀបចំផែនការកែច្នៃធនធាន។

**រៀបចំផែនការនៃការដើររបស់អ្នក៖**

សម្រេចចិត្តថាត្រូវដើរទៅកន្លែងណាខ្លះ រួចរួមគ្នាធ្វើជាបញ្ជីមួយរៀបរាប់ពីរបស់ដែលត្រូវសង្កេតមើលដូចជា ៖

- សំរាមដែលធ្វើឱ្យស្ទះលូបង្ហូរផ្លូវទឹកដទៃទៀត និងផ្លូវថ្នល់
- លាមកមនុស្ស និងសត្វនៅតាមផ្លូវ និងផ្លូវទឹក
- កាកសំណល់ពុល
- សត្វដែលស៊ីនៅគំនរសំរាម។

សួរសមាជិកចាស់ៗក្នុងសហគមន៍ឱ្យពួកគាត់រៀបរាប់ពីស្ថានភាពកាលពី២០ ឬ៣០ឆ្នាំមុន។ តើមានសំរាមច្រើន ឬតិចជាងសព្វថ្ងៃ ឬមានសំរាមប្រភេទខុសៗគ្នា? តើពេលនោះប្រជាជនធ្វើដូចម្តេចខ្លះចំពោះសំរាមរបស់ខ្លួន? គិតពីចំណុចទាំងនេះក្នុងពេលកំពុងដើរ។

**ដើរសង្កេតមើល!**

បំបែកគ្នាជាក្រុមតូចៗ ដើរតាមទីតាំងខុសៗគ្នានៅក្នុងសហគមន៍។ ដោយសារក្រុមខុសៗគ្នានឹងសង្កេតឃើញបញ្ហាខុសៗគ្នានោះអ្នកអាចបង្កើតក្រុមដែលមានតែបុរសសុទ្ធ ឬមានតែស្ត្រី ឬបង្កើតក្រុមយុវវ័យឱ្យដើរបែកគ្នាពីក្រុមមនុស្សធំ ឬអ្នកអាចបង្កើតក្រុមចម្រុះតែម្តង។ ចូរសង្កេតមើលកន្លែងដាក់សំរាម និងរបៀបទូទៅនៃការបោះចោលសំរាម។ តើមានធុងសំរាមសាធារណៈឬទេ? តើប្រជាជនដុតសំរាម ឬចាក់ចោលនៅកណ្តាលវាលដែរឬទេ? យកវាទៅចាក់ក្នុងរណ្តៅសំរាមឬឡដុត? តើមានការប្រមូល និងប្រើប្រាស់ ឬកែច្នៃឡើងវិញឬទេ ដូចជាដបធ្វើពីកែវ ឬក្រដាសកាសែត? ចុះកាកសំណល់តាមក្រុមហ៊ុនមានការរៀបចំទុកដាក់ដូចម្តេចដែរ? ឱ្យមនុស្សម្នាក់នៅក្នុងក្រុមកត់ត្រាក្នុងបញ្ជីមួយ ឬគូររូបនូវបញ្ហាទាំងឡាយដែលបានមើលឃើញក្នុងពេលដើរ រួមទាំងប្រភេទនៃកាកសំណល់ដែលអ្នកបានឃើញផងដែរ។

**មើលកាកសំណល់នៅក្នុងផ្ទះ តើមានចំនួនប៉ុន្មាន និងមានប្រភេទអ្វីខ្លះ?** ផ្នែកមួយនៃការដើរ

**បែងចែកប្រភេទកាកសំណល់ជា៥គំនរ ៖**

- ➢ កាកសំណល់អាហារ និងកាកសំណល់សារធាតុសរីរាង្គដែលសើម
- ➢ ប្លាស្ទិក
- ➢ ក្រដាស
- ➢ លោហៈ
- ➢ កាកសំណល់ដទៃទៀត




រូបភាព៖ បង្កើតកម្មវិធីមួយហៅថា "កុំចោលសំរាមរបស់អ្នក យើងទិញវា"

**នៅពេលមិនបានបោះចោលត្រឹមត្រូវ កាកសំណល់បណ្តាលឲ្យមានបញ្ហាសុខភាពជាច្រើន៖**

**នៅពេលដែលអ្នកមិនបានបោះកាកសំណល់ចោលឱ្យបានត្រឹមត្រូវ នោះវានឹងបណ្តាលឱ្យមានបញ្ហាសុខភាពជាច្រើន៖**

- គំនរសំរាមនៅកណ្តាលវាល ផ្តល់កន្លែងបង្កកំណើតដល់សត្វកណ្តុរ រុយ មូស កន្លាត និងសត្វល្អិតដទៃទៀតដែលចម្លងជំងឺ ដូចជាជំងឺគ្រុនចាញ់ គ្រុនឈាម ជំងឺរលាកថ្លើម គ្រុនពោះវៀន និងជំងឺដទៃទៀត។
- រណ្តៅសំរាម និងគំនរសំរាម ចិញ្ចឹមមេរោគ។ មេរោគទាំងនេះអាចចម្លងទៅកុមារដែលលេងនៅទីនោះ និងអ្នករើសអេតចាយលើគំនរកាកសំណល់។ មេរោគនៅក្នុងសំរាមអាចបណ្តាលឱ្យមានបញ្ហាសុខភាពផ្សេងៗ ដូចជាជំងឺរាក និងអាសន្នរោគ កមរមាស់ តេតាណូស មេរោគផ្សិត និងការបង្ករោគផ្សេងៗទៀតនៅលើស្បែក និងភ្នែក។
- សំរាមធ្វើឱ្យស្ទះផ្លូវទឹក និងលូបង្ហូរ។ បែបនេះអាចបណ្តាលឱ្យមានទឹកនឹងដែលសត្វល្អិតអាចបង្កកំណើត និងធ្វើឱ្យជន់នៅពេលភ្លៀងធ្លាក់។ នៅពេលលូបង្ហូរក្លាយជាជន់ ហើយក្នុងនោះមានលាមកមនុស្ស ឬសត្វ វាបណ្តាលឱ្យឆ្លងរោគដល់ប្រភពទឹកផឹក និងដី។
- នៅពេលគំនរកាកសំណល់ធំៗដួលរលំ វានឹងបង្កគ្រោះថ្នាក់ដល់អ្នកដែលធ្វើការជាមួយកាកសំណល់ ឬអ្នករស់នៅក្បែរៗនោះ។
- សារជាតុគីមីពុលនៅក្នុងកាកសំណល់ ជ្រាបទៅក្នុងប្រភពទឹកនិងដី ធ្វើឱ្យពុលដល់មនុស្សជាច្រើនឆ្នាំ។ជួនកាលគំនរកាកសំណល់ដែលមានសារជាតុពុល អាចផ្ទុះ ឬឆេះផងក៏មាន។
- នៅពេលដុតប្លាស្ទិក និងកាកសំណល់ពុលដទៃទៀតនៅទីវាល ឬនៅក្នុងឡដុត សារជាតុគីមីត្រូវបានបញ្ចេញទៅក្នុងខ្យល់ ហើយផេះពុលធ្វើឱ្យកខ្វក់ដល់ដី និងទឹក។ ក្នុងពេលភ្លាមៗ សារជាតុគីមីពុលទាំង

នោះបណ្ដាលឱ្យមានជំងឺតឹងទ្រូង ក្អក ចង្អោរ ក្អួត និងការបង្ករោគនៅភ្នែក។ ក្នុងពេលយូរអង្វែងវាបណ្ដាលឱ្យមានជំងឺរុំារ៉ៃ ដូចជាមហារីក និងពិការភាពពីកំណើត។ល។

## ៥.៨.ការគ្រប់គ្រងកាកសំណល់/សំរាម

### ៥.៨.១. សេចក្តីផ្តើម

នៅពេលកាកសំណល់បានចាក់ជាគំនរ ឬរាយប៉ាយក្នុងសហគមន៍របស់យើង វាមានសភាពអាក្រក់មើល មានក្លិនមិនល្អ និងមិនល្អសម្រាប់សុខភាព។ នៅពេលមិនបែងចែកប្រភេទកាកសំណល់ បរិមាណកាកសំណល់ និងបញ្ហាដែលកើតឡើងដោយកាកសំណល់គឺមានទំហំធំធេងជាងការរៀបចំកាកសំណល់ទៅទៀត។



រូបភាព៖ កាកសំណល់បានចាក់ជាគំនរ ឬរាយប៉ាយក្នុងសហគមន៍

កម្មវិធីគ្រប់គ្រងកាកសំណល់រឹងក្នុងសហគមន៍ដែលមានលក្ខណៈពេញលេញ ត្រូវរួមបញ្ចូលនូវជំហានអស់ទាំងនេះ៖

- កាត់បន្ថយបរិមាណកាកសំណល់ដែលបង្កើតដោយមនុស្ស ជាពិសេសផលិតផលពុល និងផលិតផលដែលមិនអាចកែច្នៃឡើងវិញបាន។
- ដាក់កាកសំណល់ដាច់ដោយឡែកពីគ្នា ដើម្បីងាយរៀបចំ




រូបភាព

- ធ្វើជីកំប៉ុសពីកាកសំណល់អាហារ និងកាកសំណល់សារធាតុសរីរាង្គដទៃទៀត

- ប្រើប្រាស់សម្ភារឡើងវិញនៅពេលដែលអាច។
- កែច្នៃសម្ភារឡើងវិញទាមទារឱ្យរដ្ឋាភិបាល និងឧស្សាហកម្មបង្កើតកម្មវិធីកែច្នៃធនធាននៅក្នុងសហគមន៍។
- ប្រមូល ដឹកជញ្ជូន និងទុកដាក់កាកសំណល់ឱ្យមានសុវត្ថិភាព។ ផ្តល់ការគោរព និងផ្តល់ប្រាក់ពលកម្មសមរម្យសម្រាប់អ្នកដែលធ្វើការងារនេះ។



រូបភាព៖ ប្រមូល ដឹកជញ្ជូន និងទុកដាក់កាកសំណល់

- បោះចោលឱ្យមានសុវត្ថិភាពនូវកាកសំណល់ទាំងឡាយដែលមិនអាចប្រើប្រាស់ ឬកែច្នៃឡើងវិញបាន។

### ៥.៨.២. ការកាត់បន្ថយកាកសំណល់

កាកសំណល់ដែលស្ថិតនៅតាមផ្លូវថ្នល់ ផ្ទះសម្បែង និងស្រែចម្ការ ចាប់ផ្តើមមាននៅពេលឧស្សាហកម្មផលិតផលិតផលដែលមិនអាចប្រើប្រាស់ ឬកែច្នៃឡើងវិញបាន។

គោលដៅមួយរបស់កម្មវិធីកាកសំណល់ក្នុងសហគមន៍ គឺដើម្បីកាត់បន្ថយកាកសំណល់ក្នុងរយៈពេលយូរ ដោយការជួយប្រជាជនប្រើប្រាស់ឱ្យបានតិចបំផុតនូវសម្ភារដែលក្លាយជាកាកសំណល់៖

- កុំទិញផលិតផលដែលវេចខ្ចប់ច្រើនជាន់
- ជ្រើសរើសយកកញ្ចក់ ឬក្រដាសរឹងជំនួសប្លាស្ទិក និងលោហៈ
- ប្រើប្រាស់ថង់ ឬកន្ត្រកផ្ទាល់ខ្លួន និងកុំយកថង់ប្លាស្ទិកពីកន្លែងលក់
- ទិញអាហារឱ្យច្រើនដើម្បីកាត់បន្ថយបរិមាណថង់ដែលអ្នកយកទៅផ្ទះ។

ដើម្បីបង្ការសម្ភារដែលបង្កបញ្ហាសុខភាព និងបញ្ហានៃការបោះចោល មិនឱ្យចូលមកក្នុងសហគមន៍តាំងពីដើមដំបូង។ ការរៀបចំសកម្មភាពរបស់សហគមន៍ អាចដាក់សម្ពាធលើរដ្ឋាភិបាលឱ្យបង្កើតច្បាប់នានាដែលបង្ខំឱ្យក្រុមហ៊ុនពាណិជ្ជកម្មទទួលខុសត្រូវលើកាកសំណល់ដែលពួកគេបង្កើតឡើង។

### ៥.៨.២.១. ការបែងចែកប្រភេទកាកសំណល់នៅប្រភពរបស់វា

ការទុកដាក់កាកសំណល់អាហារមិនឱ្យឡូកឡំគ្នាជាមួយកាកសំណល់ក្រដាស ឬកញ្ចក់។ល។ ធ្វើឱ្យងាយស្រួលក្នុងការប្រើប្រាស់ឡើងវិញ កែច្នៃ ឬបោះចោលសម្ភារៈនោះ និងជួយបង្ការបញ្ហាសុខភាពដែលបណ្ដាលមកពីការដាក់កាកសំណល់រួមគ្នា។ ការដាក់កាកសំណល់ដាច់ដោយឡែកពីគ្នា គឺជាជំហានទី១ក្នុងការគ្រប់គ្រងកាកសំណល់យ៉ាងល្អប្រសើរ។ ទោះបីយ៉ាងណា វាអាចដោះស្រាយបញ្ហាបានល្អលុះត្រាតែមានវិធីសាស្ត្រល្អក្នុងការរៀបចំកាកសំណល់បន្ទាប់ពីដាក់ដោយឡែកហើយ។

ការបែងចែកប្រភេទកាកសំណល់ គឺជាផ្នែកមួយនៃប្រព័ន្ធ ដែលរួមមានការប្រើប្រាស់ឡើងវិញ ការធ្វើជីកំប៉ុស ការប្រមូលកាកសំណល់ជាប្រចាំ និងការចោលកាកសំណល់ប្រកបដោយសុវត្ថិភាព។

**វិធីបែងចែកប្រភេទកាកសំណល់ ៖**

ផ្នែកដ៏ធំបំផុតនៃកាកសំណល់ដែលបានបង្កើតនៅក្នុងទីក្រុង និងជនបទ គឺជាកាកសំណល់សារធាតុសរីរាង្គ ឬកាកសំណល់សើម (កាកសំណល់អាហារ និងកាកសំណល់នៅសួនដំណាំ ដូចជារុក្ខជាតិនិងស្លឹកងាប់)។ កាកសំណល់សារធាតុសរីរាង្គត្រូវបានបំបែកដោយពន្លឺថ្ងៃ និងទឹក ឬត្រូវបានស៊ីដោយវត្ថុមានជីវិត( ដង្កូវ សត្វល្អិត និងបាក់តេរី ) រួចក្លាយទៅជាជីកំប៉ុស។

ជាធម្មតាមានក្រដាស កញ្ចក់ លោហៈ និងប្លាស្ទិកជាច្រើននៅក្នុងកាកសំណល់។ ផ្នែកដ៏ធំនៃកាកសំណល់នេះត្រូវបានបោះចោលជាកញ្ចប់។ កាកសំណល់តាមផ្ទះ អាចមានរួមបញ្ចូលសារធាតុពុល ដូចជាថ្នាំលាបថ្នាំពិល ខោទឹកនោមកុមារធ្វើពីប្លាស្ទិក ប្រេងម៉ាស៊ីន ថ្នាំសម្លាប់សត្វល្អិតចាស់ៗ និងប្រដាប់ដាក់ផលិតផលសម្អាត។







...របែងចែ...

- ក... ស
- កាកសំណល់ស្ងួតត្រូវបានបែងចែក និងប្រើប្រាស់ឡើងវិញ កែច្នៃ ឬបញ្ជូនទៅរណ្ដៅចាក់សំរាម
- កាកសំណល់ពុលត្រូវការរៀបចំ និងបោះចោលយ៉ាងពិសេស។

**តើនរណាជាអ្នកទទួលខុសត្រូវលើការបែងចែកប្រភេទកាកសំណល់?**

ម្ចាស់ផ្ទះ និងក្រុមហ៊ុនដែលជាអ្នកបង្កើតកាកសំណល់ អាចបែងចែកកាកសំណល់បាន ឬបែងចែកដោយប្រជាជនដែលប្រមូលវា។ ទោះបីសហគមន៍របស់អ្នក ប្រើប្រាស់ប្រព័ន្ធអ្វីក៏ដោយក្នុងការបែងចែក និងប្រមូលកាកសំណល់សម្រាប់ប្រើប្រាស់ឡើងវិញ កែច្នៃ ឬបោះចោល ការសំខាន់គឺអ្នកដែលធ្វើការងារនេះទទួលបានការគោរព និងប្រាក់ឈ្នួលពលកម្មសមរម្យ។

អ្នកប្រមូលកាកសំណល់អាចរកប្រាក់តាមរយៈការបែងចែកប្រភេទវា ហើយលក់វត្ថុដែលមានតម្លៃ និងយកកាកសំណល់នៅសល់ទៅមណ្ឌលកែច្នៃធនធាន។ អ្នកប្រមូលកាកសំណល់ខ្លះ ជូនប្រាក់បន្តិចបន្តួចដល់ម្ចាស់ផ្ទះណាដែលបែងចែកប្រភេទកាកសំណល់រួចជាស្រេច ឬគិតប្រាក់បន្តិចបន្តួចពីម្ចាស់ផ្ទះចំពោះកាកសំណល់ដែលមិនបានបែងចែក។

ប្រសិនបើបែងចែកកាកសំណល់នៅផ្ទះ នោះកាកសំណល់ស្ងួត អាចទុកដាក់នៅក្នុងធុងមួយនៅក្នុងផ្ទះបានរហូតអ្នកប្រមូលមកដល់។ ធុងដាក់កាកសំណល់សើម អាចដាក់នៅក្រៅផ្ទះ ហើយកាកសំណល់សើមនេះអាចធ្វើជាជីកំប៉ុសសម្រាប់សួនដំណាំនៅផ្ទះ ឬប្រមូលទៅឱ្យគម្រោងជីកំប៉ុសរបស់អ្នកជិតខាង។



**រូបភាព៖ការបែងចែកប្រភេទកាកសំណល់បន្ទាប់ពីបានដាក់ដល់រណ្ដៅសំរាម**

- **ការធ្វើជីកំប៉ុស ៖**



**រូបភាព៖ជីកំប៉ុសដែលរួចរាល់ត្រឹមត្រូវ មានក្លិនល្អ និងមានសភាពទន់ដូចដីក្នុងព្រៃដែលមានពណ៌ខ្មៅនិងមានជីជាតិ**

➢ **ប្រែក្លាយកាកសំណល់សារធាតុសរីរាង្គឱ្យទៅជាជី៖**

ដោយសារសារធាតុសរីរាង្គជាទូទៅគឺជាផ្នែកដ៏ច្រើនបំផុតនៃកាកសំណល់ភាគច្រើន ដូច្នេះការបែងចែក និងធ្វើជីកំប៉ុសនូវកាកសំណល់អាហារ ជួយកាត់បន្ថយកាកសំណល់បានយ៉ាងច្រើន។ ការដាក់ជីកំប៉ុសទៅឱ្យដី គឺជាវិធីមួយក្នុងការផ្តល់សារធាតុចិញ្ចឹមរបស់ដំណាំឱ្យត្រឡប់ទៅផែនដីវិញ។

វិធីធ្វើជីកំប៉ុសដែលល្អបំផុត គឺអាស្រ័យលើទីធ្លាដែលមាន។ អាចធ្វើជីកំប៉ុសតិចតួចនៅក្នុងសម្ភារដាក់របស់របរនៅតាមផ្ទះ ឬក្រុមហ៊ុន។ កន្លែងធ្វើជីកំប៉ុសធំៗ អាចបង្កើតឡើងនៅក្នុងទីក្រុង និងនៅកសិដ្ឋានដែលមានទីធ្លាសម្រាប់ជីករណ្តៅកាកសំណល់ធំ។

➢ **ប្រើប្រាស់ឡើងវិញតាមដែលអាចធ្វើបាន៖**

សំរាមរបស់មនុស្សម្នាក់ ច្រើនតែមានប្រយោជន៍សម្រាប់មនុស្សម្នាក់ទៀត។ នៅទូទាំងពិភពលោក មនុស្ស សន្សំសំចៃប្រាក់ និងការពារបរិស្ថាន ដោយការច្នៃប្រឌិតមធ្យោបាយផ្សេងៗដើម្បីប្រើប្រាស់ឡើងវិញយ៉ាងមានសុវត្ថិភាពនូវសម្ភារដែលបានបោះចោល។

- កង់ឡាន អ្នកអាចច្នៃធ្វើជាស្បែកជើងសង្រែក ធុង និងផើងដាំរុក្ខជាតិ។
- សំបកកំប៉ុង អ្នកអាចច្នៃធ្វើជាអំពូល ផើងដាំរុក្ខជាតិ និងប្រដាប់ដាក់ទៀន។
- ប្រអប់អាហាររលោងៗ អ្នកអាចធ្វើជាថង់ដាក់ទំនិញពេលទៅផ្សារ។
- ត្រឡោកដូង អ្នកអាចធ្វើជាពែង សម និងស្លាបព្រា។
- ស្លឹកចេក អ្នកអាចធ្វើជាចានទាប និងចានក្រឡូម។
- លោហៈសំណល់ អ្នកអាចធ្វើជាចង្ក្រាន អំពូល និងវត្ថុសិល្បៈ។



**រូបភាព៖ផលិតផលថ្មីៗជាច្រើនអាចផលិតយ៉ាងងាយចេញពីកាកសំណល់ដែលបានបោះចោល**



រូបភាព៖**ផលិតផលថ្មីៗជាច្រើនអាចផលិតយ៉ាងងាយចេញពីកាកសំណល់ដែលបានបោះចោល**

**ការកែច្នៃកាកសំណល់ឱ្យទៅជាធនធាន៖**

គេយកផលិតផលដែលលែងមានប្រយោជន៍ រួចប្រែក្លាយវាទៅជាវត្ថុធាតុដើម ដើម្បីបង្កើតផលិតផលមានប្រយោជន៍ថ្មី។ ការកែច្នៃសម្ភារខ្លះ (ដូចជាលោហៈ និងកៅស៊ូ) ត្រូវតែធ្វើនៅក្នុងរោងចក្រ។ សម្ភារដទៃទៀតដូចជាក្រដាស និងកញ្ចក់ មិនសូវទាមទារឧបករណ៍ និងទីធ្លាទេ និងអាចត្រូវបានកែច្នៃនៅក្នុងរោងជាងតូចៗ ឬក្នុងផ្ទះប្រជាជនបាន។

ការកែច្នៃគឺជាវិធីដ៏សំខាន់មួយក្នុងការកាត់បន្ថយកាកសំណល់។ ប៉ុន្តែការកែច្នៃត្រូវការការគាំទ្រពីរដ្ឋាភិបាល និងឧស្សាហកម្ម ក៏ដូចជាការប្តេជ្ញាចិត្តពីសំណាក់សហគមន៍ និងប្រជាជន។ ប្រសិនបើគ្មានទីផ្សារសម្រាប់ផលិតផលកែច្នៃ ឬបើផលិតផលនោះត្រូវបានកែច្នៃដោយគ្មានសុវត្ថិភាព នោះការកែច្នៃគឺមិនមែនជាដំណោះស្រាយឡើយ។

ការកែច្នៃ កាត់បន្ថយកាកសំណល់ដោយការប្រែក្លាយវាឱ្យទៅជាផលិតផលថ្មីៗ និងក៏សន្សំសំចៃថាមពលសម្រាប់ប្រើប្រាស់នៅក្នុងរោងចក្រដែរ។ ឧទាហរណ៍ ការកែច្នៃក្រដាសត្រូវការថាមពលតែ២ភាគ៣នៃការផលិតក្រដាសថ្មី ឬការផលិតដែកពីលោហៈសំណល់ ត្រូវការថាមពល២ភាគ៣នៃការផលិតចេញពីរ៉ែដែកឆៅ។ ការផលិតអាលុយមីញ៉ូមចេញពីកាកសំណល់ ត្រូវការថាមពលតិចតួចបំផុត ខុសពីការផលិតចេញពីរ៉ែបុកស៊ីតឆៅ។

**ការកែច្នៃ ៖**

ការកែច្នៃគឺថែរក្សាធនធានដែលអ្នក និងខ្ញុំត្រូវការដើម្បីរស់នៅ

- កាត់បន្ថយបរិមាណនៃកាកសំណល់រឹងដែលបំពុលបរិស្ថានរបស់យើង។
- កាត់បន្ថយបរិមាណនៃកាកសំណល់រឹងដែលយើងត្រូវបោះចោល បន្ថយបន្ទុកទីធ្លាចោលសំរាម និងសន្សំសំចៃប្រាក់។
- កាត់បន្ថយការប្រើប្រាស់ធនធាន តាមរយៈការប្រើប្រាស់ធនធានលើសពីមួយដង។
- ជួយសេដ្ឋកិច្ចក្នុងតំបន់ ឬជាតិ ព្រោះយើងត្រូវការនាំចូលវត្ថុធាតុដើមតិចជាងមុន។
- ផ្តល់ការងារសម្រាប់ប្រជាជន។

## តើសម្ភារអ្វីខ្លះដែលអាចកែច្នៃបាន ?

សម្ភារដែលអាចកែច្នៃបាន គឺអាស្រ័យលើឧស្សាហកម្មកែច្នៃក្នុងសហគមន៍៖

កញ្ចក់ត្រូវបានផលិតចេញពីខ្សាច់ ម្សៅសូដា និងក្រួចថ្មារ។ នៅពេលបោះចោល វាអាចសឹកដាច់ ប៉ុន្តែមិនបំបែកទៅជាវត្ថុធាតុដើមវាវិញទេ។ ដើម្បីកែច្នៃកញ្ចក់ គេបែងចែកវាតាមពណ៌ រួចដុតរំលាយទៅជាទឹក ហើយចាក់ទៅជាក្នុងពុម្ពផ្សេង។ កញ្ចក់ខ្លះត្រូវបានកែច្នៃទៅជាសម្ភារដែលប្រើប្រាស់ក្នុងផ្លូវថ្នល់ឬសំណង់អាគារ។

អាលុយមីញ៉ូមត្រូវបានផលិតចេញពីរ៉ែបុកស៊ីតដែលខួងចេញពីដី។ វាមិនបំបែកទៅជាវត្ថុធាតុដើមវាវិញទេ ប៉ុន្តែសឹកដាច់ដូចកញ្ចក់ដែរ។ អាលុយមីញ៉ូមត្រូវបានកែច្នៃដោយការដុតរំលាយ រួចចាក់ក្នុងពុម្ពកំប៉ុង និងវត្ថុថ្មីៗផ្សេងទៀត។

សំណប៉ាហាំងដែលគេយកមកស្រោបកំប៉ុងដែក ដូចជាកំប៉ុងស៊ុប និងផ្លែឈើ ត្រូវបានកែច្នៃដោយការញែកវាចេញពីដែកវិញ។ បន្ទាប់មក ដែក និងសំណប៉ាហាំងត្រូវបានសម្អាត និងលក់ ដើម្បីផលិតកំប៉ុងថ្មីៗ ឬផលិតផលផ្សេងៗទៀត។

កៅស៊ូត្រូវបានផលិតចេញពីជ័រឈើ និងប្រេងកាត។ ជួនកាលកៅស៊ូត្រូវបានកែច្នៃដោយការដុតរំលាយ ឬចាំងវាជាកំទេច រួចចាក់ទៅក្នុងពុម្ពវត្ថុថ្មីៗទៀត។

ក្រដាសត្រូវបានផលិតចេញពីឈើ កប្បាស និងរុក្ខជាតិដទៃទៀតដែលមានសរសៃមាំ។ ក្រដាសគឺជាសម្ភារមួយក្នុងចំណោមសម្ភារភាគតិចដែលអាចកែច្នៃទៅជាសម្ភារដើមឡើងវិញ។ ក្រដាសផ្នែកជំនួញច្រើនតែបានកែច្នៃនៅក្នុងរោងចក្រឧស្សាហកម្ម។ ក្រដាសក៏អាចត្រូវបានកែច្នៃដោយដៃ ដើម្បីបង្កើតជាផលិតផលក្រដាសស្អាតៗសម្រាប់ប្រើក្នុងផ្ទះ ឬសម្រាប់លក់។

ផលិតផលដែលមានសារជាតុពុល ដូចជាកុំព្យូទ័រ ថ្មពិល/អាគុយ ផលិតផលអេឡិចត្រូនិក ថ្នាំលាប ទឹករំលាយ និងថ្នាំសម្លាប់សត្វល្អិត និងប្រដាប់ដាក់ផលិតផលទាំងនេះ ត្រូវការការរៀបចំដោយប្រុងប្រយ័ត្ន ដើម្បីកុំឱ្យកម្មកររោងចក្រកែច្នៃប្រឈមនឹងសារជាតុគីមីពុល។ ផលិតផលទាំងនេះមួយចំនួន មិនអាចកែច្នៃបានឡើយ ដូច្នេះហើយជាការប្រសើរគឺត្រូវផលិតវាតែបន្តិចបន្តួចតាំងពីដំបូង។

## បញ្ហានៃការកែច្នៃប្លាស្ទិក៖

នៅពេលប្លាស្ទិកត្រូវបានកែច្នៃ គុណភាពរបស់វាធ្លាក់ចុះ។ ដបប្លាស្ទិកមិនត្រូវបានកែច្នៃទៅជាដបប្លាស្ទិកថ្មីទេ ប៉ុន្តែត្រូវបានផលិតទៅជាវត្ថុផ្សេងដែលមានគុណភាពទាបជាង។ ដោយហេតុនេះហើយ ប្លាស្ទិកអាចត្រូវបានកែច្នៃតែពីរបីដងប៉ុណ្ណោះ មុននឹងបោះចោល។

ការកែច្នៃប្លាស្ទិកខ្លះធ្វើឱ្យបញ្ចេញឧស្ម័នពុលដែលបង្កគ្រោះថ្នាក់ដល់កម្មករនិងសហគមន៍ ។ ហើយប្លាស្ទិកជាច្រើនដែលអាចកែច្នៃបាន បែរជាត្រូវបោះចោលក្នុងរណ្តៅសំរាមទៅវិញ។ ដូច្នេះហើយ ល្អបំផុតគឺត្រូវប្រើប្រាស់ប្លាស្ទិកឱ្យបានតិចបំផុតតាមដែលអាចធ្វើបាន។

**ការប្រមូល ដឹកជញ្ជូន និងរក្សាទុកសំណល់៖**

ប្រសិនបើសហគមន៍របស់អ្នកមិនមានសេវាប្រមូលសំរាមដែលទុកចិត្តបានទេ អ្នកអាចរៀបចំសេវានេះដោយខ្លួនឯងដែលមានជំនួយពីអាជ្ញាធរ និងក្រុមហ៊ុន។ នៅពេលអ្នករៀបចំផែនការ ត្រូវគិតអំពីអ្វីដែលនឹងត្រូវប្រមូល និងថាតើវានឹងយកទៅលក់ឱ្យក្រុមហ៊ុនកែច្នៃធំៗ ឬកម្មវិធីកែច្នៃក្នុងសហគមន៍។

ចម្ងាយដែលកាកសំណល់ត្រូវបានដឹកជញ្ជូន បើកាន់តែជិត កាន់តែប្រសើរ។ ប៉ុន្តែសហគមន៍ជាច្រើនមិនអាចកែច្នៃដោយខ្លួនឯងទេ ដូច្នេះពួកគេត្រូវរកដំណោះស្រាយលើបញ្ហានេះ។






**របៀបរៀបចំកាកសំណល់៖**

របៀបរៀបចំកាកសំណល់សម្រាប់ការប្រមូល ដឹកជញ្ជូន និងរក្សាទុក គឺអាស្រ័យលើទំហំទីកន្លែងដែលអ្នកមាន អ្នកដែលនឹងធ្វើការងារនេះ អ្នកដែលនឹងទិញសំរាម និងថាតើវានឹងប្រើប្រាស់សម្រាប់អ្វី។

ដើម្បីបង្ការក្លិនអាក្រក់ និងការចម្លងមេរោគ គួររៀបចំសម្ភារឱ្យស្អាត ស្ងួត និងមានផ្ទៃរាប ឬតម្រៀបលើគ្នាដើម្បីចំណេញកន្លែង និងដើម្បីកាត់បន្ថយឱកាសនៃឧប្បត្តិហេតុផ្សេង។

កុំព្យូទ័រ វិទ្យុ និងទូរទស្សន៍ មានផ្នែកជាច្រើនដែលអាចលក់ និងកែច្នៃបាន ប៉ុន្តែភាគច្រើនវាមានសារធាតុពុល។ បន្ទាប់ពីទទួលការបណ្តុះបណ្តាលលើផលិតផលនីមួយៗ ល្អបំផុតគួរដោះវាចេញជាផ្នែកៗ និងប្រើប្រាស់ឧបករណ៍ការពារខ្លួន និងមានខ្យល់ចេញចូលល្អ។ រាល់ប្រដាប់ដាក់សម្ភារពុលទាំងអស់ ត្រូវការការរៀបចំពិសេស។

## ៦.កិច្ចការ/តួនាទីបុគ្គលក្នុងការចូលរួមសកម្មភាពអ.ប.វ. បៃតង

### ៦.១. សេចក្តីផ្តើម

ការបង្កើតឱ្យមានសកម្មភាពបៃតងក្នុងអ.ប.វ. ឱ្យកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ អាចធ្វើទៅបានលុះត្រាតែមានការចូលរួមទាំងអស់គ្នានៅក្នុងគ្រឹះស្ថានអ.ប.វ.។ ដូច្នេះគ្រឹះស្ថានអ.ប.វ. ត្រូវធ្វើការពង្រឹង និងកែលម្អ ផ្សព្វផ្សាយពីកិច្ចការដែលជាកាតព្វកិច្ចរបស់បុគ្គលិក អ្នកគ្រប់គ្រង គ្រូ មន្ត្រី និងសិស្សដែលកំពុងតែសិក្សាឱ្យចូលរួមយ៉ាងសកម្មក្នុងសកម្មភាពបៃតង។

*សំខាន់ថាតើយើងរួមគ្នា ឬមិនរួម ធ្វើ ឬមិនធ្វើតែប៉ុណ្ណោះ?*



រូបភាព៖ ទិដ្ឋភាពរបស់គ្រឹះស្ថានគំរូ ដែលបានប្រើសកម្មភាព អ.ប.វ.

**៦.២. ការអនុវត្តសកម្មភាព អ.ប.វ. បៃតង និងកិច្ចការពារបរិស្ថាន(គ្រឹះស្ថានអ.ប.វ.)**

បរិវេណគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់យើងទាំងផ្នែកខាងក្រៅនិងផ្នែកខាងក្នុង



រូបភាព៖ គ្រឹះស្ថានអ.ប.វ.

**អ្នកណាខ្លះដែលមានសិទ្ធិចូលរួម ថែរក្សាបរិស្ថានឱ្យរក្សាបាននូវបរិស្ថានបៃតងនោះ**

អ្នកដែលមានសិទ្ធិចូលរួមថែរក្សាបរិស្ថាន គឺមនុស្សគ្រប់រូប បុគ្គលម្នាក់ៗ ក្រុមគ្រួសារ សហគមន៍ និងបណ្តាប្រទេសទូទាំងពិភពលោក។



រូបភាព

ត្រូវរៀបចំ និងត្រួតពិនិត្យមើលនៅបរិវេណជុំវិញគ្រឹះស្ថានបណ្តុះបណ្តាលរបស់ខ្លួនលើទិដ្ឋភាពបរិស្ថានជុំវិញ ថាតើវាមានទិដ្ឋភាពដូចម្តេច? ក្នុងឋានៈជាអ្នកថ្នាក់ដឹកនាំ ចាំបាច់ត្រូវដឹកនាំមន្ត្រីក្រោមឱវាទពិនិត្យមើលនូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ✓ ការរក្សា និងទុកដាក់កាកសំណល់ នៅផ្នែកខាងក្នុង និងខាងក្រៅ( ស្ថានភាពធុងសំរាម )
- ✓ ស្ថានភាពទីធ្លាបរិវេណ ( សង្កេតលើការដក់ទឹក ឬលេចទឹក ឬមានភក់ជ្រាំ ឬក្លិន..... )
- ✓ ស្ថានភាពសួនច្បារ ( ពិនិត្យមើលស្ថានភាពការដាំដុះរុក្ខជាតិដែលមានក្នុងសួន )
- ✓ ទិដ្ឋភាពដើមឈើ ដែលមានវត្តមានក្នុងបរិវេណគ្រឹះស្ថាន( ក្នុង និងក្រៅ )
- ✓ ទិដ្ឋភាពអគារសិក្សា ( ការលាបថ្នាំអគារ ពណ៌ថ្នាំ ពន្លឺគ្រប់គ្រាន់ និងខ្យល់អាកាសចេញចូល )
- ✓ ទិដ្ឋភាពកន្លែងធ្វើការរបស់មន្ត្រី និងបុគ្គលិក ( បានអនុលោមតាមស៥ កម្រិតណា )
- ✓ ទិដ្ឋភាពថ្នាក់រៀន/បន្ទប់រៀន ( ពន្លឺ ខ្យល់អាកាសចាំងចូលគ្រប់គ្រាន់ )
- ✓ ទិដ្ឋភាពរោងជាង និងឃ្លាំងស្តុកសម្ភារ ( បានអនុលោមតាមតាមស៥ កម្រិតណា )

### ៦.៣. ការចាត់ចែងកាកសំណល់ក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ.

ដើម្បីឱ្យគ្រឹះស្ថាន អ.ប.វ. របស់យើងអាចគ្រប់គ្រងកាកសំណល់ឱ្យក្លាយជាគ្រឹះស្ថានអ.ប.វ.បៃតងបានលុះណាតែ៖

- ➢ ញែក និងកំណត់បានពីប្រភេទសំណល់ផ្សេងៗពិសេសប្រភេទសំណល់រលួយ និងមិនរលួយបានត្រឹមត្រូវ
- ➢ ពន្យល់ពីការគ្រប់គ្រងសំណល់តាមវិធីកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃបានត្រឹមត្រូវ
- ➢ ផ្សព្វផ្សាយដល់ក្រុមគ្រួសារ ឬសមាគមន៍សិស្សពីបញ្ហាទាក់ទងទៅនឹងសំណល់




រូបភាព៖ ប្រភេទធុងសំរាម ( ចំនួន៤ប្រភេទ )




រូបភាព៖ធុងសំរាមកំណត់ដោយពណ៌ (ចំនួន៤ប្រភេទ)

ហេតុអ្វីបានជាគេចាំបាច់ញែកសំរាមទៅតាមប្រភេទរបស់វា?..............................................

- ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងសំណល់
- ម៉្យាងទៀតយើងអាចក៏អាចរកប្រាក់ចំណូលបានពីសំណល់



តើសំណល់ណាខ្លះដែលបង្កគ្រោះថ្នាក់ដល់បរិស្ថាន?.................

ជាប្រភេទសំណល់មិនរលួយ។



ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដល់បរិស្ថាន ពីបញ្ហាកាកសំណល់គឺគេប្រើវិធីចំនួនបីអ(3R)៖

- ការកាត់បន្ថយ
- ការប្រើប្រាស់ឡើងវិញ
- និងការកែច្នៃ



### ៦.៤. ការិយាល័យបៃតង

ដើម្បីឱ្យការិយាល័យដែលជាកន្លែងធ្វើការងាររបស់គ្រូ មន្ត្រី និងបុគ្គលិករបស់យើង ប្រែក្លាយជាការិយាល័យបៃតងបានលុះណាតែ៖

បង្ហាញ និងពន្យល់ចំណុចខាងក្រោមពីសកម្មភាពជាក់លាក់ដល់ គ្រូ មន្ត្រី និងបុគ្គលិកនូវ៖

- ទង្វើនៃ «ការសម្រិតសម្រាំង»
- ទង្វើនៃ «ភាពមានសណ្តាប់ធ្នាប់»
- ទង្វើនៃ «ការសម្អាត»
- ទង្វើនៃ «រៀបចំពន្លឺ និងខ្យល់ចេញចូល»
- ទង្វើនៃ «ការច្នៃឱ្យមានរុក្ខជាតិបៃតង ចូលរួមក្នុងកន្លែងធ្វើការងារ»
- ទង្វើនៃ «ស្តង់ដា»
- ទង្វើនៃ «ស្ថិតស្ថេរ»



### ៦.៥. រោងជាងបៃតង

ដើម្បីឱ្យរោងជាងរបស់យើងប្រែក្លាយជារោងជាងបៃតងបានលុះណាតែ៖

បង្ហាញ និងពន្យល់ចំណុចខាងក្រោមពីសកម្មភាពជាក់លាក់ដល់នាយឃ្លាំងឬអ្នកគ្រប់គ្រងឃ្លាំងនូវ៖

- ទង្វើនៃ «ការសម្រិតសម្រាំង»
- ទង្វើនៃ «ភាពមានសណ្តាប់ធ្នាប់»
- ទង្វើនៃ «ការសម្អាត»
- ទង្វើនៃ «រៀបចំពន្លឺ និងខ្យល់ចេញចូល»
- ទង្វើនៃ «ស្តង់ដា»
- ទង្វើនៃ «ស្ថិតស្ថេរ»



### ៦.៦. បន្ទប់រៀនបៃតង

ដើម្បីឱ្យបន្ទប់រៀន/ថ្នាក់រៀនរបស់យើងប្រែក្លាយជាបន្ទប់រៀន/ថ្នាក់រៀនបៃតង បានលុះណាតែ៖

បង្ហាញ និងពន្យល់ចំណុចខាងក្រោមពីសកម្មភាពជាក់លាក់ដល់ គ្រូ មន្ត្រី និងបុគ្គលិកនូវ៖

➢ ទង្វើនៃ «ការសម្រិតសម្រាំង»
➢ ទង្វើនៃ «ភាពមានសណ្ដាប់ធ្នាប់»
➢ ទង្វើនៃ «ការសម្អាត»
➢ ទង្វើនៃ «រៀបចំពន្លឺនិងខ្យល់ចេញចូល»
➢ ទង្វើនៃ «ស្ដង់ដា»
➢ ទង្វើនៃ «ស្ថិតស្ថេរ»



## ៦.៧. ឃ្លាំងបៃតង

ដើម្បីឱ្យឃ្លាំងដែលជាកន្លែងសម្រាប់ស្តុកនូវសម្ភាររបស់យើងប្រែក្លាយជាឃ្លាំងបៃតង បានលុះណាតែះ បង្ហាញ និងពន្យល់ចំណុចខាងក្រោមពីសកម្មភាពជាក់លាក់ដល់នាយឃ្លាំង ឬអ្នកគ្រប់គ្រងឃ្លាំងនូវះ

➢ ទង្វើនៃ «ការសម្រិតសម្រាំង»
➢ ទង្វើនៃ «ភាពមានសណ្ដាប់ធ្នាប់»
➢ ទង្វើនៃ «ការសម្អាត»
➢ ទង្វើនៃ «រៀបចំពន្លឺ និងខ្យល់ចេញចូល»
➢ ទង្វើនៃ «រៀបចំផែនទី សម្ភារ ឧបករណ៍ បរិក្ខារ»
➢ ទង្វើនៃ «ស្ដង់ដា»
➢ ទង្វើនៃ «ស្ថិតស្ថេរ»

